ផ្ទះធម្មខ្មែរ

បរមត្ថធម៌សង្ខេប

ចិត្តសង្ខេប និងភាគបន្ថែម

ដោយ សុមិន្ត បរិហារវនខេត្ត

ប្រែសម្រួលដោយ សមាជិកផ្ទះធម្មខ្មែរ

Dhammadāna by Cambodia Dhamma Home

ព.ស. ២៥៦៩

បរមត្ថធម៌សង្ខេប
ចិត្តសង្ខេប
និងគាគបន្ថែម

ដោយ សុចិន្ត បរិហារវនខេត្ត

បកប្រែលើកទី ១ ដោយ លោកគ្រូ រស់ សុជាត ព.ស. ២៥៣៨
ប្រែសម្រួលន័យសេចក្តីលើកទី ២ ដោយ ខ្ពុំព្រះករុណា ខ្ពុំបាទ ចែម ជាន់ណារិទ្ធ
និងសមាជិកផ្ទះធម្មខ្មែរ ព.ស. ២៥៦៩

ធម្មទាន ដោយផ្ទះធម្មខ្មែរ

Dhammadāna by Cambodia Dhamma Home

ធម្មទានឈ្នះអស់ទានទាំងពួង

សម្រាប់ជាធម្មទាន

(ហាមទិញ-លក់)

បរមត្ថធម៌សង្ខេប ចិត្តសង្ខេប និងភាគបន្ថែម

ដោយ សុចិន្ត បរិហារវនខេត្ត

បោះពុម្ពលើកទី ១ ព.ស. ២៥៦៩ ចំនួន ១000 ក្បាល

បោះពុម្ពនៅ រោងពុម្ព អិមភី (ម៉ៅ ផុន) រាជធានីភ្នំពេញ

សម្រាប់ពុទ្ធបរិស័ទ ដែលមានបំណងនឹងបោះពុម្ពសៀវភៅរបស់ផ្ទះធម្មខ្មែរ

ដើម្បីជាធម្មទានសូមមេត្តាទាក់ទងមកផ្ទះធម្មខ្មែរ (ជំរំផ្ទះធម្ម)

ផ្ទះលេខ ២២ ផ្លូវ ៩ ជី ទីក្រុងរណបសិរីមង្គល ភូមិគោះគរ ឃុំរកាខ្ពស់ ក្រុង តាខ្មៅ ខេត្តកណ្តាល

លេខទូរស័ព្ទជំរំផ្ទះធម្មខ្មែរ ០៨៨ ៣៥៩៥២០៥

Facebook (ហ្វេសប៊ុក) ជំរំផ្ទះធម្ម

dhammahomekhmer@gmail.com

https://kh.dhammahome.com/

មាតិកា

ទំព័រ

ព្រះពុទ្ធសាសនាមានអង្គ ៩ .....៣

បរមត្ថធម៌សង្ខេប.....១១

ចិត្តសង្ខេប.....៦៥

មេរៀនទី ១ សេចក្តីសំខាន់របស់ចិត្ត.....៦៦

មេរៀនទី ២ ពាក្យអធិប្បាយ ៨៦

មេរៀនទី ៣ ពាក្យអធិប្បាយចិត្ត (បន្ត).....៩៥

មេរៀនទី ៤ វិថីចិត្ត ទ្វារ វត្ថុ.....១២៤

មេរៀនទី ៥ ជាតិរបស់ចិត្ត.....១៤០

មេរៀនទី ៦ ចិត្ត ៨៩ ចំណែកជា ៤ ជាតិ - កិច្ចរបស់ចិត្ត.....១៥២

មេរៀនទី ៧ អត្ថរបស់ចិត្ត ១៧៣

មេរៀនទី ៨ អត្ថរបស់ចិត្ត (បន្ត) ២០០

មេរៀនទី ៩ ភូមិរបស់ចិត្ត ២០៩

មេរៀនទី ១០ ចិត្តផ្សេងគ្នាដោយសម្បយុត្តធម៌.....២៣៦

មេរៀនទី ១១ សម្បយុត្តធម៌..... ២៥២

មេរៀនទី ១២ ពាក្យអធិប្បាយ អសង្ខារិក និងសសង្ខារិក.....២៥៨

មេរៀនទី ១៣ ចិត្តផ្សេងគ្នាដោយសម្បយុត្តធម៌ដែលជាហេតុ.....២៧០

មេរៀនទី១៤ ចិត្តផ្សេងគ្នាដោយន័យសោភណៈ និងអសោភណៈ...២៨៥

មេរៀនទី ១៥ ចិត្តផ្សេងគ្នាដោយន័យលោកិយ និងលោកុត្តរចិត្ត.....២៩៩
មេរៀនទី ១៦ អត្ថរបស់ចិត្តប្រការទី ៥ ឈ្មោះថាចិត្ត
ព្រោះធ្វើឱ្យវិចិត្រ ៣២១
បញ្ញត្តិ.....៣៣៧
ភាគមន្តែម.....៣៩៥
ចិត្ត ៨៩ ឬ ១២១ ប្រភេទ.....៣៩៧
ចេតសិក ៥២ ប្រភេទ.....៤៣១
រូប ២៨ ប្រភេទ.....៤៥៩
សមថភាវនា..... .....៤៧៥
វិបស្សនាភាវនា.....៥០៩
គន្លងផ្លូវចម្រើនវិបស្សនា..... .....៥៥៩

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

ព្រះពុទ្ធសាសនាមានអង្គ ៩

ព្រះពុទ្ធវចនៈ គឺព្រះធម៌វិន័យដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង ប្រកបដោយអង្គ ៩ គឺ

សុត្ត បានដល់ព្រះសូត្រទាំងឡាយ មានមង្គលសូត្រ ជាដើម រួមនឹងព្រះវិន័យបិដក និងនិទ្ទេស ។

គេយ្យ គឺព្រះសូត្រទាំងអស់ដែលមានគាថា មានសគាថវគ្គ ជាដើម ។

វេយ្យាករណ គឺព្រះអភិធម្មបិដក ព្រះសូត្រដែលមិនមានគាថាបញ្ចូលជាមួយ និងព្រះពុទ្ធវចនៈ ដែលមិនចាត់ចូលក្នុងអង្គ ៨ ។

គាថា គឺព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ។ ដែលមិនមានឈ្មោះថាសូត្រក្នុងសុត្តនិបាត ។

ឧទាន គឺព្រះសូត្រ ៨២ សូត្រដែលព្រះដ៏មានព្រះភាគទ្រង់ថ្លែងដោយសោមនស្សញ្ញាណ ។

ឥតិវុត្តក គឺព្រះសូត្រ ១១០ សូត្រដែលផ្តើមឡើងដោយពាក្យថា **វុត្តំ ហេតំ ភគវា** (ខ នេះសមពិតដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយ) ។

ជាតក គឺរឿងអតីតជាតិរបស់ព្រះដ៏មានព្រះភាគ និងព្រះសាវ័ក មានអបណ្ណកជាតក រួម ៥៥០ ជាតក ។

អព្ភូតធម៌ គឺព្រះសូត្រដែលប្រកបដោយអច្ឆរិយអព្ភូតធម៌ (ធម៌ដែលក្រៃលែង ដោយគុណវិសេស ដែលគួរអស្ចារ្យ) ។

វេទល្ល គឺព្រះសូត្រដែលកាលណាសួរហើយ ក៏បាននូវសេចក្តីដឹង និងសេចក្តីត្រេកអរក្រៃលែងឡើង ។ មានចូឡវេទល្ល សូត្រជាដើម ។

ព្រះពុទ្ធវចនៈមាន ៨៤០០០ ព្រះធម្មក្ខន្ធ ដែលព្រះអានន្ទរៀនអំពីព្រះដ៏មានព្រះភាគមក ៨២០០០ ព្រះធម្មក្ខន្ធ រៀនពីព្រះភិក្ខុមាន ព្រះសារីបុត្រ ជាដើម ២ ០០០ ព្រះធម្មក្ខន្ធ ។ ព្រះធម្មក្ខន្ធ គឺព្រះធម៌តែមួយ ខ ក៏សឹងអាចនឹងជាព្រះសូត្រ ១ សូត្រ នោះក៏បានជា ១ ព្រះធម្មក្ខន្ធ ឬក៏ជាបញ្ហា ១ ខ ក៏ជា ១ ព្រះធម្មក្ខន្ធ ។ ពាក្យវិសជ្ជនា ខ នីមួយ ៗ ក៏ជាព្រះធម្មក្ខន្ធ នីមួយ ៗ ដែរ ។

ព្រះវិន័យបិដក ចែកចេញជា ៥ គម្ពីរ គឺ

មហាវិភង្គ ១

ភិក្ខុនីវិភង្គ ១

មហាវគ្គ ១

ចុល្លវគ្គ ១

បរិវារ ១

គម្ពីរអដ្ឋកថា ដែលអធិប្បាយន័យសេចក្តីក្នុងព្រះវិន័យបិដក គឺ សមន្តបាសាទិកា

ព្រះសុត្តន្តបិដក មាន ៥ និកាយ គឺ

១ ទីឃនិកាយ រួមព្រះសូត្រខ្នាតវែងមានព្រះសូត្រ ៣៤ សូត្រ ចែកជា ៣ វគ្គ គឺ

សីលខន្ធវគ្គ

មហាវគ្គ

បដិកវគ្គ ។

គម្ពីរអដ្ឋកថា ទីឃនិកាយ គឺសុមង្គលវិលាសិនី

២ មជ្ឈិមនិកាយ រួមព្រះសូត្រខ្នាតកណ្តាល មានព្រះសូត្រ ១៥២ សូត្រ ចែកចេញជា ៣ បណ្ណាសកគឺ

- **មូលបណ្ណាសក** មាន ៥ វគ្គ ។ ១ វគ្គមាន ១0 សូត្រ រួម ៥0 សូត្រ ។
- **មជ្ឈិមបណ្ណាសក** មាន ៥ វគ្គ ។ ១ វគ្គមាន ១0 សូត្រ រួម ៥0 សូត្រ ។
- **ឧបរិបណ្ណាសក** មាន ៥ វគ្គ ។ ១ វគ្គមាន ១0 សូត្រ មាន ៤ វគ្គ វគ្គទី ៥ មាន ១២ សូត្រ រួមជា ៥២ សូត្រ ។

គម្ពីរអដ្ឋកថា មជ្ឈិមនិកាយ គឺបបញ្ចសូទនី

៣ សំយុត្តនិកាយ រួមព្រះសូត្រជាពួក ៗ ចែកជាវគ្គធំ ៗ ៥ វគ្គ គឺ

សគាថវគ្គ មាន ១១ សំយុត្ត

និទានវគ្គ មាន ៩ សំយុត្ត

ខន្ធវារវគ្គ មាន ១៣ សំយុត្ត

សឡាយតនវគ្គ មាន ១0 សំយុត្ត

មហាវារវគ្គ មាន ១២ សំយុត្ត
គម្ពីរអដ្ឋកថាសំយុត្តនិកាយ គឺសារត្ថបកាសិនី

៤ អង្គុត្តរនិកាយ រួមព្រះសូត្រតាមចំនួនប្រភេទនៃធម៌ ។ ចែកជា ១១ និបាត គឺ

ឯកនិបាត	រួមធម៌ប្រភេទពួក ១
ទុកនិបាត	រួមធម៌ប្រភេទពួក ២
តិកនិបាត	រួមធម៌ប្រភេទពួក ៣
ចតុកនិបាត	រួមធម៌ប្រភេទពួក ៤
បញ្ចកនិបាត	រួមធម៌ប្រភេទពួក ៥
ឆកនិបាត	រួមធម៌ប្រភេទពួក ៦
សត្តកនិបាត	រួមធម៌ប្រភេទពួក ៧
អដ្ឋកនិបាត	រួមធម៌ប្រភេទពួក ៨
នវកនិបាត	រួមធម៌ប្រភេទពួក ៩
ទសកនិបាត	រួមធម៌ប្រភេទពួក ១០
ឯកទសកនិបាត	រួមធម៌ប្រភេទពួក ១១

គម្ពីរអដ្ឋកថា អង្គុត្តរនិកាយ គឺ មនោរថបូរណី

៥- ខុទ្ទកនិកាយ ក្រៅពីនិកាយ ៤ មានទីឃនិកាយជាដើមនោះហើយ ព្រះពុទ្ធវចនៈដទៃពីនោះ រួមជាខុទ្ទកនិកាយ ទាំងអស់ដែលមាន **ខុទ្ទកបាដ្ឋ**

ធម្មបទ ឧទាន ឥតិវុត្តក សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក មហានិទ្ទេស ចូឡនិទ្ទេស បដិសម្ភិទាមគ្គ អបទាន ពុទ្ធវង្ស និង ចរិយាបិដក ។

គម្ពីរអដ្ឋកថា ខុទ្ទកនិកាយ គឺ

បរមត្ថជោតិកា	អដ្ឋកថាខុទ្ទកបាដ្ឋ និងសុត្តនិបាត
ធម្មបទដ្ឋកថា	អដ្ឋកថាគាថាធម្មបទ
បរមត្ថទីបនី	អដ្ឋកថាឧទាន និងឥតិវុត្តក បេតវត្ថុ ថេរគាថា ថេរីគាថា ចរិយាបិដក
ជាតកដ្ឋកថា	អដ្ឋកថាជាតក
សទ្ធម្មប្បជ្ជោតិកា	អដ្ឋកថាមហានិទ្ទេស និងចូឡទិទ្ទេស
សទ្ធម្មបកាសិនី	អដ្ឋកថាបដិសម្ភិទាមគ្គ
វិមលត្តវិលាសិនី	អដ្ឋកថាវិមានវត្ថុ
វិសុទ្ធជនវិលាសិនី	អដ្ឋកថាអបទាន
មធុរត្តវិលាសិនី	អដ្ឋកថាពុទ្ធវង្ស

ព្រះអភិធម្មបិដក ៧ គម្ពីរ គឺ

១- ធម្មសង្គណីបករណ អដ្ឋកថា គឺ អដ្ឋសាលិនី

២- វិភង្គបករណ អដ្ឋកថា គឺ សម្មោហវិនោទនី

៣- ធាតុកថាបករណ
៤- បុគ្គលប្បញ្ញត្តិបករណ
៥- កថាវត្ថុបករណ
៦- យមកបករណ
៧- បដ្ឋានបករណ
} អដ្ឋកថា គឺ បរមត្ថទីបនី បញ្ចបករណដ្ឋកថា

អដ្ឋកថាព្រះត្រៃបិដកនោះ ចំណែកធំ ព្រះពុទ្ធឃោសាចារ្យ លោកប្រែ និងរៀបរៀងពីអដ្ឋកថាដើមក្នុងភាសាសីហឡ គឺមហាអដ្ឋកថា មហាបច្ចរី និងកុរុន្ទីដែលបន្តគ្នាមកតាំងតែពីសម័យព្រះមហិន្ទត្ថេរ ព្រះឱរសព្រះចៅអសោកមហារាជ ទៅផ្សព្វផ្សាយព្រះពុទ្ធសាសនា នៅក្នុងប្រទេសស្រីលង្កា ។

ក្រៅពីគម្ពីរដីកា ដែលអធិប្បាយសេចក្តីក្នុងគម្ពីរអដ្ឋកថា និង អត្ថយោជនា គឺសារត្ថទីបនី (គម្ពីរដីកាព្រះ វិន័យបិដក) សារត្ថមញ្ជុសា (គម្ពីរដីកា ព្រះសុត្តន្តបិដក) បរមត្ថបកាសិនី (គម្ពីរដីកាព្រះអភិធម្មបិដក) និងអនុដីកាដែលអធិប្បាយពាក្យសព្ទក្នុងដីកាហើយស្រាប់ ។ គម្ពីរផ្លូវព្រះ

ពុទ្ធសាសនាដែលគួរដល់ការសិក្សា ដែលព្រះថេរដ៏មានគុណក្នុងអតីតសម័យត ៗ មក បានរចនាទុក គឺមានដូចនេះ

មិលិន្ទបញ្ហា រចនាដោយព្រះបិដកចុល្លភ័យ ប្រហែលក្នុង ព.ស. ៥00

វិសុទ្ធិមគ្គ រចនាដោយព្រះពុទ្ធឃោសាចារ្យ ប្រហែលក្នុង ព.ស. ជិត ១000

អភិធម្មត្ថសង្គហ រចនាដោយព្រះអនុរុទ្ធាចារ្យ ប្រហែលក្នុងព.ស. ជិត ១000

សារត្ថសង្គហ រចនាដោយព្រះនន្ទាចារ្យ ប្រហែលក្នុង ព.ស. ជិត ១000

បរមត្ថមញ្ជុសា (ដីកាអធិប្បាយវិសុទ្ធិមគ្គ) រចនាដោយព្រះធម្មបាលាចារ្យ

សច្ចសង្ខេប រចនាដោយព្រះធម្មបាលាចារ្យ

អភិធម្មត្ថវិភាវិនីដីកា (អធិប្បាយគម្ពីរអភិធម្មត្ថសង្គហ) រចនាដោយព្រះសុមង្គលាចារ្យ

មោហវិច្ឆេទនី (អធិប្បាយធម្មសង្គណីបករណ និងវិភង្គបករណ) រចនាដោយព្រះកស្សបប្រហែលក្នុង ព.ស. ១៧0៧ - ១៧៧៣

មង្គលត្ថទីបនី (អធិប្បាយមង្គលសូត្រ) រចនាដោយ

បរមត្ថធម៌សង្ខេប

បរមត្ថធម៌សង្ខេប

ក្នុងសម័យអតីតកាល នាសាលវ័នជាទីអាស្រ័យនៃពួកក្សត្រមល្ល ដែនកុសិនារា ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់បានរំលត់ខន្ធបរិនិព្វាន ចន្លោះនៃដើមសាលព្រឹក្សទាំងគូ ។ ជាពេលអស់ឱកាស ដែលសត្វលោក នឹងបានស្តាប់ព្រះធម៌ទេសនាចេញពីព្រះឱស្ឋ តទៅទៀតហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ប្រទានព្រះធម៌វិន័យ ដែលព្រះអង្គទ្រង់សម្តែង ហើយទ្រង់បញ្ញត្តិហើយទុកជាសាសនាជំនួសព្រះអង្គ កាលព្រះអង្គទ្រង់រំលត់ខន្ធបរិនិព្វានទៅហើយនោះ [1] ។

ពុទ្ធបរិស័ទតែងតែថ្វាយបង្គំសក្ការៈនូវព្រះធម៌ដ៏ប្រសើរ ជាទីបំផុតនៃព្រះដ៏មានព្រះភាគសព្វកាល ។ តាមការចេះដឹង ការយល់ក្នុងព្រះធម៌វិន័យ សូម្បីតែអ្នកណា បានឃើញព្រះវរៈកាយនៃព្រះអង្គ បានស្តាប់ព្រះធម៌ទេសនាចាកពីព្រះឱស្ឋ ឬសូម្បីតែចាប់ជាប់ នូវជាយសង្ឃាដីតាមព្រះអង្គទៅយ៉ាងណាក៏ដោយ តែបើមិនដឹងធម៌ទេ មិនឃើញធម៌ទេ អ្នកនោះក៏ឈ្មោះថា គោរពបូជាព្រះអង្គមិនបានឡើយ ។ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញ តថាគត[2]។

---

[1] ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ បទ ១៤១

[2] ខុទ្ទកនិកាយ ឥតិវុត្តក សង្ឃាដិសូត្រ បទ ២៧២

ព្រះពុទ្ធសាសនា គឺជាព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះអរហន្ត សម្មាសម្ពុទ្ធ ។ ព្រះពុទ្ធសាសនាមាន ៣ ថ្នាក់ គឺ

១- ថ្នាក់បរិយត្តិ គឺសិក្សាព្រះធម៌វិន័យ

២- ថ្នាក់បដិបត្តិ គឺចម្រើនធម៌ដើម្បីសម្រេចនូវធម៌ ដែលរំលត់កិលេស រំលត់ទុក្ខ

៣- ថ្នាក់បដិវេធ គឺដឹងច្បាស់នូវធម៌ដែលរំលត់កិលេស រំលត់ទុក្ខ ។

ព្រះពុទ្ធតម្រាស់ដែលថាអ្នកណាឃើញធម៌ អ្នកនោះឈ្មោះថារមែងឃើញតថាគត នេះគឺសំដៅដល់បុគ្គលដែលឃើញច្បាស់នូវធម៌ ដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង គឺលោកុត្តរធម៌ ៩ (មគ្គ ៤ ផល ៤ និព្វាន ១) ថ្នាក់បដិវេធ ។ ការឃើញព្រះធម៌ថ្នាក់បដិវេធ គឺជាផលនៃការចម្រើនធម៌ថ្នាក់បដិបត្តិ ។ ឯការចម្រើនធម៌ថ្នាក់បដិបត្តិ ក៏ត្រូវអាស្រ័យបរិយត្តិ ។ ដោយហេតុនេះហើយបរិយត្តិគឺការសិក្សាព្រះធម៌វិន័យ ទើបជាសរណៈ ទើបជាទីពឹង ជាផ្លូវនាំទៅដល់ព្រះពុទ្ធសាសនា គឺថ្នាក់បដិបត្តិ និងថ្នាក់បដិវេធ ទៅជាលំដាប់ ៗ តទៅ ។

ព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ តែងបានចងចាំ ត ៗ គ្នាមក ដោយមុខបាដ្ឋ គឺការទន្ទេញចាំអំពីព្រះអរហន្តសាវ័ក ដែលបានធ្វើសង្គាយនា ព្រះធម៌វិន័យ ជាបិដក ៣ ហៅថាព្រះត្រៃបិដក ។ ឯការទន្ទេញចាំនេះ ក៏បានធ្វើត ៗ គ្នាមក ដរាបរហូតដល់បានចារឹក ជាតួ

អក្សរ ។ ព្រះធម៌វិន័យដែលព្រះអរហន្តសាវ័កបានសង្គាយនា ជា ៣ បិដក នោះ គឺ

១ - ព្រះវិន័យបិដក

២ - ព្រះសុត្តន្តបិដក

៣ - ព្រះអភិធម្មបិដក

ព្រះវិន័យបិដកទាក់ទងនឹងរបៀប ខ ប្រព្រឹត្តប្រតិបត្តិដើម្បីព្រហ្ម-ចារ្យ ថ្នាក់ខ្ពស់ក្រៃលែងឡើងជាចំណែកធំ ១ ។ ព្រះសុត្តន្តបិដក ទាក់ទង នឹងគោលធម៌ដែលព្រះអង្គទ្រង់ទេសនាដល់បុគ្គលផ្សេង ៗ ក្នុងទីកន្លែង ផ្សេង ៗ ជាចំណែកធំ ១ ។ ព្រះអភិធម្មបិដក ទាក់ទងនឹងសភាវធម៌ព្រម ទាំងហេតុនិងផលនៃធម៌ទាំងពួង ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងនូវសភាវធម៌ ព្រមទាំងហេតុ និង ផលនៃធម៌ទាំងពួង ។ ព្រះអង្គទ្រង់សម្តែងធម៌ដែលព្រះអង្គទ្រង់ត្រាស់ ដឹងនោះ ដើម្បីអនុគ្រោះសត្វលោក ចាប់តាំងតែពីសម័យត្រាស់ដឹង ដរាប ដល់សម័យបរិនិព្វាន ដោយព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងព្រះមហា ករុណាទិគុណ ដែលមិនមានបុគ្គលណា ប្រៀបផ្ទឹមបានឡើយ។ ព្រះដ៏មាន ព្រះភាគទ្រង់បានបំពេញបារមីដើម្បីសម្រេចធម៌ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ជាម្ចាស់ ជាអ្នកទ្រទ្រង់ដល់ព្រមដោយសម្បទា[9] គឺហេតុសម្បទា ផលសម្បទា និងសត្ថុបការសម្បទា (ក្នុងអភិធម្មត្ថវិភាវិនីដីកា) ។

ហេតុសម្បទា ការដល់ព្រមដោយហេតុ គឺការដែលទ្រង់បំពេញព្រះបារមីដល់ព្រមដើម្បីត្រាស់ដឹងជាសម្មាសម្ពុទ្ធ ៤ អសង្ខ្យៃយ្យ ១ សែនកប្ប បន្ទាប់ពីទទួលការព្យាករណ៍ពីព្រះពុទ្ធទីបង្ករជាម្ចាស់ ។

ផលសម្បទា ការដល់ព្រមដោយផលមាន ៤ យ៉ាង គឺ

១-ញាណសម្បទា បានដល់មគ្គញ្ញាណ ដែលជាទីតាំងនៃព្រះសព្វញ្ញុតញ្ញាណ និងព្រះទសពលញ្ញាណជាដើមដែលមានមគ្គញ្ញាណ ជាមូល ។

២-បហានសម្បទា បានដល់ការដែលលះកិលេសទាំងអស់ ព្រមទាំងវាសនា ។ វាសនា គឺកិរិយាអាការតាមផ្លូវកាយ វាចាដែលមិនល្អ ដែលប្រព្រឹត្តជាទម្លាប់ ប្រសិនបើមិនមែនជាព្រះសម្មាសម្ពុទ្ធទេនោះ ក៏មិនអាចលះបានឡើយ ។

៣-អនុភាវសម្បទា បានដល់សេចក្តីជាធំក្នុងការធ្វើឱ្យសម្រេចបានតាម បំណងប៉ងប្រាថ្នា ។

៤- រូបកាយសម្បទា បានដល់ព្រះរូបសម្បត្តិដែលប្រកបដោយព្រះមហាបុរិសលក្ខណៈ និងអនុព្យញ្ជនៈដែលជាទីពេញភ្នែក ពេញចិត្តនៃសាធុជនទាំងអស់លើលោកទាំងមូល ។

កាលណាហេតុ គឺបារមីដល់ព្រមហើយ ក៏ធ្វើឱ្យដល់ព្រមដោយផលសម្បទា គឺការត្រាស់ដឹងជាសម្មាសម្ពុទ្ធ ។ កាលបើបានជាសម្មាសម្ពុទ្ធនោះ មិនមែនធ្វើឱ្យព្រះអង្គផុតទុក្ខ ត្រឹមតែមួយព្រះអង្គ

ឯងនោះទេ ។ ព្រះបារមីដែលទ្រង់បានបំពេញមកនោះ ក៏គឺដើម្បីការត្រាស់ដឹង និង ការសម្រេចជាសព្វញ្ញុពុទ្ធក្នុងធម៌ នោះ ។ ដើម្បី ទ្រង់សម្តែងធម៌ ប្រោសវេនេយ្យសត្វឱ្យផុតទុក្ខដូចជាព្រះអង្គដែរ ។ បើព្រះអង្គទ្រង់បានបំពេញបារមី ដើម្បីរំលត់កិលេសឱ្យផុតទុក្ខតែមួយអង្គឯងប៉ុណ្ណោះ នោះ ព្រះអង្គក៏នឹងមិនទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធជាម្ចាស់ដែរ ។ ព្រោះព្រះសម្មាសម្ពុទ្ធ នោះមាន ២ ប្រភេទ គឺ

១ - ព្រះសម្មាសម្ពុទ្ធ[៣] គឺជាអ្នកត្រាស់ដឹងដោយព្រះបញ្ញាដ៏ក្រៃលែងនូវសច្ចៈ ដោយព្រះអង្គឯងក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់មកពីមុនឡើយ ហើយក៏ទ្រង់បានសម្រេចជាព្រះសព្វញ្ញុពុទ្ធ ក្នុងធម៌នោះនិងទ្រង់សម្រេចជាអ្នកជំនាញក្នុងធម៌ដែលជាកម្លាំងទាំងឡាយ ។

២ - ព្រះបច្ចេកពុទ្ធ[៤] គឺជាអ្នកត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដោយព្រះអង្គឯងដែលមិនធ្លាប់បានស្តាប់មកពីមុន ។ ប៉ុន្តែមិនបានសម្រេចជាព្រះសព្វញ្ញុពុទ្ធ ក្នុងធម៌នោះទេ និងទាំងមិនបានដល់ជាអ្នកជំនាញ ក្នុងធម៌ដែលជាកម្លាំងទាំងឡាយនោះដែរ ។

ដូច្នោះការបំពេញហេតុ គឺបារមីដើម្បីសម្រេចធម៌ ជាព្រះពុទ្ធដែលជាផលនោះ ទើបមានតិច មានច្រើនផ្សេងគ្នា ។

---

[៣] ៣, ៤ បុគ្គលបញ្ញត្តិបករណ ឯកនិទ្ទេស

សត្តូបការសម្បទា គឺការដល់ព្រមដោយព្រះអធ្យាស្រ័យ និង ឧស្សាហៈ ឧបការៈ ដល់សត្វលោកជានិច្ច ។ សូម្បីតែក្នុងពួកសត្វ មាន កំហុស មានព្រះទេវទត្តជាដើមនោះ ក៏ព្រះអង្គនៅតែរង់ចាំវេលាចាស់ក្លា នៃឥន្ទ្រិយរបស់វេនេយ្យសត្វ ដែលមានបញ្ញិន្ទ្រិយនៅមិនទាន់ចាស់ក្លា និង ព្រះអង្គទ្រង់សម្តែងព្រះធម៌ដែលនឹងអាចនាំសត្វលោក ចេញចាកពីទុក្ខ ទាំងពួង ដោយទ្រង់មិនបានពិចារណា នូវលាភសក្ការៈ ជាដើមនោះឡើយ ។

កាលណាព្រះសម្មាសម្ពុទ្ធទ្រង់ដល់ព្រមដោយហេតុសម្បទា និង ផលសម្បទាហើយនោះ ព្រះអង្គក៏ទ្រង់ប្រោសវេនេយ្យសត្វឱ្យផុតទុក្ខ នេះ ជាការដល់ព្រមដោយសត្តូបការសម្បទា ។ ការដែលជាព្រះសម្មាសម្ពុទ្ធ នោះ ជាការដល់ព្រមដោយសម្បទាទាំង ៣ យ៉ាងនេះឯង ។

ដោយហេតុនេះ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនានោះ ទើបជាធម៌ ដែលព្រះអង្គទ្រង់ត្រាស់ដឹងពិត ។ ការត្រាស់ដឹងធម៌ទាំង ឡាយនោះ ធ្វើឱ្យព្រះអង្គទ្រង់អស់កិលេស ហើយព្រះអង្គទ្រង់សម្តែងធម៌ ដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះ ក៏ដើម្បីឱ្យអ្នកបដិបត្តិតាម អស់នូវ កិលេសផងដែរ ។

ដូច្នោះ ពុទ្ធសាសនិកជនទាំងឡាយ ទើបជាការគួរពិចារណា និង សិក្សាឱ្យបានដឹងថា ធម៌ និងសេចក្តីពិតដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះ

គឺអ្វី ? សេចក្តីពិតដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះជាសេចក្តីពិត ផ្សេងពីសេចក្តីពិតដែលយើងនឹកគិត ឬជាសេចក្តីពិតផ្សេងពីសេចក្តីពិត ដែលយើងយល់យ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ។

សេចក្តីពិត ដែលព្រះអង្គទ្រង់ត្រាស់ដឹង និងទ្រង់ទេសនាប្រៀនប្រដៅពុទ្ធបរិស័ទឱ្យយល់ និងបដិបត្តិតាមរហូតដល់ ឃើញសេចក្តីពិតនោះ ក៏គឺសភាវៈទាំងឡាយដែលប្រាកដនោះ ជាធម៌តែមួយបែប មួយប្រភេទ មិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ។ ធម៌ទាំងឡាយដែលកើតឡើងនោះ ព្រោះមានបច្ច័យតាក់តែង ទើបកើតឡើងបាន ដូចសេចក្តីលោភ សេចក្តីក្រោធ សេចក្តីអន់ចិត្ត សេចក្តីទុក្ខ សេចក្តីសុខ សេចក្តីឫស្សា សេចក្តីកំណាញ់ សេចក្តីមេត្តា សេចក្តីករុណា ការឃើញ ការឮ ការធុំក្លិន ... ជាដើម សុទ្ធតែជាសភាវធម៌មួយបែប មួយប្រភេទប៉ុណ្ណោះ ដែលសភាវធម៌ទាំងនោះផ្សេង ៗ គ្នា ព្រោះកើតអំពីបច្ច័យផ្សេង ៗ គ្នា ។

ការដែលវង្វេងប្រកាន់សេចក្តីលោភ សេចក្តីក្រោធ និងសភាវធម៌ដទៃ ៗ ដែលកើតឡើងនោះ ថាជាតួខ្លួន ជាសត្វ ជាបុគ្គលនោះ គឺជាការឃើញខុស ជាការយល់ខុស ធម៌ទាំងអស់មានការកើតឡើងហើយក៏រលត់ទៅ អស់ទៅ ផ្លាស់ប្តូររហូតទៅ គ្រប់ពេលវេលា តាំងពីកើតរហូតដល់ស្លាប់ ។

ការវង្វេងយល់ខុសថាជាតួខ្លួន ជាសត្វ ជាបុគ្គលនោះ ក៏ព្រោះតែមិនដឹងសេចក្តីពិតរបស់ធម៌ទាំងពួងនោះឯង ។ កាលឃើញខណៈណា ក៏ប្រកាន់ការឃើញដែលជាសភាវធម៌មួយបែបនោះ ថាជាតួខ្លួនយើងឃើញ កាលបានឮខណៈណា ក៏ប្រកាន់ការឮដែលជាសភាវធម៌មួយបែបនោះ ថាជាតួខ្លួនយើងឮ កាលបានដឹងក្លិនខណៈណា ក៏ប្រកាន់ការដឹងក្លិនដែលជាសភាវធម៌មួយបែបនោះ ថាជាតួខ្លួន យើងដឹងក្លិន កាលដឹងរសខណៈណា ក៏ប្រកាន់ថាការដឹងរសដែលជាសភាវធម៌មួយបែបនោះ ថាជាតួខ្លួនយើងដឹងរស កាលបានដឹងផោដ្ឋព្វៈខណៈណា ក៏ប្រកាន់ការដឹងផោដ្ឋព្វៈដែលជាសភាវធម៌មួយបែបនោះ ថាជាតួខ្លួនយើងដឹងផោដ្ឋព្វៈ កាលនឹកគិតរឿងណាខណៈណា ក៏ប្រកាន់សភាវធម៌ដែលនឹកគិតនោះ ថាជាតួខ្លួន យើងនឹកគិត ដូចយ៉ាងនេះជាដើម ។

កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹង នូវសេចក្តីពិតនៃធម៌ទាំងពួងហើយ ព្រះអង្គក៏ទ្រង់ទេសនាប្រៀនប្រដៅ ពុទ្ធបរិស័ទទាំងឡាយឱ្យដឹងថា ធម៌ទាំងពួងនោះ មិនមែនតួខ្លួនទេ មិនមែនសត្វទេ មិនមែនបុគ្គលទេ គឺជាបរមត្ថធម៌ ជាសភាវធម៌ដែលកើតឡើង ព្រោះហេតុបច្ច័យ ហើយក៏រលត់ទៅដូចដែលព្រះអង្គទ្រង់បានសម្តែងធម៌ដល់

ព្រះអានន្ទថា[៤] **សភាវៈណាកើតឡើងហើយ មានហើយ បច្ច័យតាក់តែងហើយមានការវិនាសជាធម្មតា ។**

កាលណាបើមិនដឹងក៏ធ្វើឱ្យកើតសេចក្តីយល់ខុសនឹងប្រកាន់ជាប់សភាវធម៌ដែលកើត រលត់ ថាជាតួខ្លួន ជាសត្វ ជាបុគ្គល ហើយក៏រមែងធ្វើឱ្យកើតសេចក្តីត្រេកអរ ពេញចិត្ត វង្វេងប្រកាន់ ជាប់ជំពាក់សន្សំកពូនក្រៃលែង ឡើងតែក្នុងយស បណ្តាសក្តិ ជាតិត្រកូល វណ្ណៈ ជាដើមតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែសេចក្តីពិតនោះ វត្ថុដែលមើលឃើញក៏ត្រឹមតែវណ្ណៈ ដែលប្រាកដតាមភ្នែកប៉ុណ្ណោះ ដែលមិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ។ សំឡេងដែលបានឮ ក៏ត្រឹមតែជាសំឡេងដែលប្រាកដតាមត្រចៀកប៉ុណ្ណោះ ដែលមិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ឯភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក៏មិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ត្រឹមតែជាធម៌តែមួយបែប ។ ដែលកើតឡើងព្រោះបច្ច័យផ្សេង ។ គ្នា ។

ការវង្វេងប្រកាន់នូវសភាវធម៌ទាំងឡាយ ថាជាតួខ្លួន ជាសត្វ ជាបុគ្គលនោះ ឧបមាដូចជាមនុស្សធ្វើដំណើរតាមផ្លូវ ដែលរមែងឃើញដូចជាមានស្រមោលទឹកនៅខាងមុខ តែពេលដែលទៅដល់ជិតត្រពាំងទឹក

[៤] ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ

ដែលឃើញក៏បាត់អស់ ព្រោះសេចក្តីពិតដែលថាមានទឹកនោះមិនមែនទេ ស្រមោលទឹកដែលឃើញនោះជាមាយា ជាសភាពលួងភ្នែកយ៉ាងណា ឯការយល់ខុសថា សភាវធម៌ទាំងឡាយថាជាតួខ្លួន ជាសត្វ ជាបុគ្គលនោះ ក៏ព្រោះដោយសេចក្តីមិនដឹង ក៏ព្រោះដោយការចាំ ក៏ព្រោះដោយសេចក្តីប្រកាន់ជាប់ជំពាក់ ក៏យ៉ាងដូច្នោះដែរ ។

ពាក្យថាសត្វ បុគ្គល ស្រី ប្រុស ជាដើមនោះ គឺត្រឹមតែជាពាក្យបញ្ញត្តិឱ្យដឹងសេចក្តីសម្គាល់នៃរបស់ដែលឃើញ ដែលឮ ដែលធុំក្លិន ដែលក្រេបជញ្ជក់ ដែលប៉ះត្រូវ ដែលនឹកគិតប៉ុណ្ណោះឯង ។ ប្រការ ១ ទៀតរមែងនឹងឃើញបានថា វត្ថុ របស់របរទាំងឡាយ សំឡេងទាំងឡាយ ក្លិនទាំងឡាយ រសទាំងឡាយ ក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ និងរឿងផ្សេង ។ នោះ ទោះជានឹងវិចិត្រ ឆើតឆាយ ល្អស្អាត ដល់កម្រិតត្រឹមណាក៏ដោយ ក៏នឹងប្រាកដឱ្យដឹងមិនបានដែរ បើមិនមានសភាវធម៌ដែលជាធាតុដឹងទេនោះ ។ ធាតុដឹងនោះ បានដល់ការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការដឹងក្តៅត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ ការដឹងសេចក្តី សម្គាល់វត្ថុផ្សេង ។ និងការនឹកគិត ។

សភាវធម៌ដែលដឹងសភាវៈផ្សេង ។ នោះ ដូចជាសភាវធម៌ដែលដឹងពណ៌ សភាវធម៌ដែលដឹងសំឡេង សភាវធម៌ដែលដឹងក្លិន សភាវធម៌ដែល

ដឹងរស សភាវធម៌ដែលដឹងត្រជាក់ ក្តៅ ទន់ រឹង តឹង ញ័រ សភាវធម៌ដែល ដឹងការសម្គាល់វត្ថុផ្សេង ៗ នោះ និងសភាវធម៌ដែលនឹកគិតផ្សេង ៗ ជាដើមនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិហៅសភាពដឹង សភាវធម៌ផ្សេង ៗ នោះថាគឺចិត្ត ។

បរមត្ថធម៌មាន ៤ ប្រភេទ

ចិត្ត ជាសភាវធម៌ដែលជាធំក្នុងការដឹងសភាវៈដែលប្រាកដ ដូចជា ឃើញ ឮជាដើម ។ **ចិត្តទាំងអស់មាន ៨៩ ឬ ១២១ ប្រភេទដោយពិស្តារ ។**

ចេតសិក ជាសភាវធម៌ ១ ប្រភេទទៀត ដែលកើតរួមនឹងចិត្ត ដឹងនូវ អ្វី ។ ជាមួយនឹងចិត្ត រលត់ព្រមជាមួយនឹងចិត្ត និងកើតត្រង់កន្លែង ជាមួយនឹងចិត្ត ។ ចេតសិកនីមួយ ។ មានលក្ខណៈនិងកិច្ចផ្សេង ។ គ្នា តាមប្រភេទនៃចេតសិកនោះ ។ ។
ចេកសិកទាំងអស់ មាន ៥២ ប្រភេទ ។

រូប ជាសភាវធម៌ដែលមិនមែនជាសភាពដឹង ធាតុដឹង ដូចជា ពណ៌ សំឡេង ក្លិន រស ជាដើម ។ **រូបទាំងអស់មាន ២៨ ប្រភេទ ។**

និព្វាន ជាធម៌ដែលរំលត់កិលេស រំលត់ទុក្ខ ។ និព្វានមិនមាន បច្ច័យប្រជុំតាក់តែងឱ្យកើតឡើងទេ ទើបនិព្វានមិនកើតរលត់ ។

ចិត្តបរមត្ថ

ខណៈដែលឃើញពណ៌ផ្សេង ។ តាមផ្លូវភ្នែកនោះ ភ្នែកមិនឃើញអ្វីទេ ភ្នែកត្រឹមតែជាបច្ច័យដែលធ្វើឱ្យកើតការឃើញ គឺជាចិត្តតែប៉ុណ្ណោះ ។ កាលណា សំឡេងប៉ះខ្ចប់នឹងត្រចៀក ត្រចៀកគឺមិនមែនចិត្ត ព្រោះសំឡេង និងត្រចៀកមិនដឹងនូវអ្វីទាំងអស់ ។ ប៉ុន្តែសភាវធម៌ដែលឮសំឡេងឬដឹងសំឡេងនោះ គឺជាចិត្ត ។ ដូច្នោះ **ចិត្តបរមត្ថ ទើបជាសភាវធម៌ដែលដឹងពណ៌ ដឹងសំឡេង ដឹងវត្ថុផ្សេង ។ ។** បរមត្ថធម៌ គឺសភាវធម៌ដែលមានពិត នេះជាអភិធម្ម គឺធម៌ដែលជាអនត្តា មិននៅក្នុងអំណាច បង្គាប់បញ្ជារបស់អ្នកណាទាំងអស់ឡើយ គឺជាសភាវធម៌ ដែលប្រព្រឹត្តតាមហេតុបច្ច័យ ។ សូម្បីតែព្រះសម្មាសម្ពុទ្ធ នឹងមិនប្រសូតិ ឬមិនត្រាស់ដឹងក្តីសភាវធម៌ទាំងឡាយនោះ ក៏រមែងនៅតែប្រព្រឹត្តទៅតាមហេតុបច្ច័យរួចស្រេចហើយដែរ[៥] ។ ព្រះសម្មាសម្ពុទ្ធទ្រង់ ជាព្រះបរមសាស្តា ព្រោះព្រះអង្គទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួង ដោយព្រះអង្គឯងថា ធម៌ទាំងពួងមិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល និងធម៌ទាំងពួងមិននៅក្នុងអំណាចបង្គាប់បញ្ជានៃបុគ្គលណា ។ ទាំងអស់ ។

[៥] អង្គុត្តរនិកាយ ឧប្បទសូត្រ បទ ៥៧៦

ពាក្យថា **អតិ** ប្រែថា ធំដ៏ក្រៃលែង ។ **អភិធម្ម គឺធម៌ដែលធំដ៏ក្រៃលែង ព្រោះជាអនត្តាមិននៅក្នុងអំណាច បង្គាប់បញ្ជា នៃបុគ្គលណាឡើយ** ។ កាលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងហើយ ព្រះអង្គក៏ទ្រង់ទេសនាធម៌ទាំងពួង ដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះ តាមសភាវៈជាសេចក្តីពិតនៃធម៌នោះ ។ ។ ព្រះអង្គទ្រង់គោរពធម៌ដែលព្រះអង្គទ្រង់ត្រាស់ដឹង[៦] ព្រះអង្គទ្រង់ពុំបានទេសនាថា ធម៌ទាំងពួងនោះនៅក្នុងអំណាចរបស់ព្រះអង្គឡើយ ។ ប៉ុន្តែ ព្រះអង្គទេសនាថា សូម្បីតែព្រះអង្គក៏មិនអាចញុំាងឱ្យអ្នកណាមួយ ផុតទុក្ខ ឬសម្រេច មគ្គផល និព្វានបានឡើយ គឺមានតែការប្រព្រឹត្តប្រតិបត្តិធម៌ប៉ុណ្ណោះ ដែលជាបច្ច័យឱ្យអ្នកបដិបត្តិសម្រេចមគ្គ ផល និព្វាន និងផុតទុក្ខបាន ។ បរមត្ថធម៌ ឬអភិធម្មនោះ មិនមែនជាធម៌ដែលហួសវិស័យ ដែលនឹងយល់បាននោះទេ ព្រោះបរមត្ថធម៌ គឺជាធម៌ដែលមានពិត ។ ដូច្នោះ ការឃើញត្រូវ ការយល់ត្រូវ ទើបជាការដឹងសេចក្តីពិតនៃបរមត្ថធម៌ តាមសភាវៈលក្ខណៈ នៃបរមត្ថធម៌នោះ ។ ។ ចិត្ត ជាបរមត្ថធម៌ ដែលកើតឡើងដឹងពណ៌ ដឹងសំឡេង ដឹងក្លិន ដឹងរស ដឹងសម្ផស្ស ដឹងនូវអ្វីផ្សេង ។ តាមប្រភេទនៃចិត្តនោះ ។ ដូចចិត្តដែលកើតឡើង ឃើញពណ៌តាមផ្លូវភ្នែក ជាចិត្តមួយប្រភេទ ចិត្តដែលកើតឡើង បានឮសំឡេងតាមត្រចៀក ជាចិត្តមួយប្រភេទទៀត ចិត្តដែលកើតឡើងដឹងត្រជាក់ ក្តៅ ទន់ រឹង តឹង កម្រើក ញ័រ តាមកាយជាចិត្តមួយប្រភេទ

---

[៦] សំយុត្តនិកាយ គារវសូត្រ បទ ៥៦០

និងចិត្តនឹកគិតដែលកើតឡើងដឹងរឿងផ្សេង ។ តាមផ្លូវចិត្ត ជាចិត្តមួយប្រភេទ ដូចនេះ ជាដើម ទាំងនេះតាមប្រភេទនៃចិត្ត និងតាមបច្ច័យដែលធ្វើឱ្យកើតចិត្តប្រភេទនោះ ។ ។

ក្នុងខណៈ ដែលចិត្តកំពុងឃើញនូវអ្វីណាមួយនោះ ខណៈនោះមិនមែនមានតែចិត្តដែលឃើញប៉ុណ្ណោះទេ ឬមិនមែនមានតែចំពោះអ្វីដែលចិត្តឃើញប៉ុណ្ណោះទេ **គឺត្រូវតែមានទាំងចិត្តឃើញផង និងអ្វីដែលចិត្តឃើញផង** ។ កាលណាមានអ្វីដែលត្រូវឃើញខណៈណា ក៏ស្តែងថាខណៈនោះ ត្រូវមានសភាពឃើញ ធាតុឃើញ គឺចិត្តឃើញផងដែរ ។ ប៉ុន្តែបើគិតតែចាប់អារម្មណ៍សំដៅចំពោះតែវត្ថុ ឬអ្វីដែលត្រូវឃើញប៉ុណ្ណោះនោះ ក៏នឹងអាចធ្វើមិនឱ្យដឹងនូវសេចក្តីពិតថា អ្វីដែលត្រូវឃើញនោះនឹងប្រាកដបាន ក៏ព្រោះចិត្តកើតឡើងធ្វើកិច្ចឃើញនូវអ្វីនោះ ក្នុងខណៈនឹកគិតក៏ដូចគ្នា កាលណាចិត្តនឹកគិតរឿងរ៉ាវណា រឿងរ៉ាវនោះក៏ជាពាក្យដែលចិត្តកំពុងនឹកគិតក្នុងខណៈនោះ **កាលណា ចិត្តកើតឡើងដឹងនូវអ្វីណា អ្វីណាដែលចិត្តដឹងនោះ ភាសាបាលី ហៅថា អារម្មណៈ ។**

ពាក្យថាអារម្មណៈ ឬអារម្មណ៍ ក្នុងព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធនោះ សំដៅដល់អ្វីដែលចិត្តដឹង ខណៈណា ដែលចិត្តកើតឡើងឃើញនូវអ្វីដែលប្រាកដតាមផ្លូវភ្នែក អ្វីដែលប្រាកដតាមផ្លូវភ្នែក

នោះ ក៏ជាអារម្មណ៍នៃចិត្តខណៈនោះ ខណៈណាដែលចិត្តកើតឡើងបាន ឮសំឡេង សំឡេងក៏ជាអារម្មណ៍របស់ចិត្តខណៈនោះ ខណៈណាដែល ចិត្តកើតឡើងដឹងក្លិន ក្លិនក៏ជាអារម្មណ៍របស់ចិត្តខណៈនោះ ខណៈណា ដែលចិត្តកើតឡើងដឹងក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ ក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ ក៏ជាអារម្មណ៍របស់ចិត្តខណៈនោះ ខណៈណា ដែល ចិត្តកើតឡើងនឹកគិតរឿងរ៉ាវផ្សេង ៗ រឿងរ៉ាវផ្សេង ៗ ក៏ជាអារម្មណ៍ របស់ចិត្តដែលកំពុងនឹកគិតខណៈនោះ ដូចនេះ ជាដើម ។ កាលណាមាន ចិត្ត គឺត្រូវមានអារម្មណ៍ជាគូគ្នាប្រព្រឹត្តទៅគ្រប់ ៗ ខណៈ ។ ចិត្តកើត ខណៈណា ក៏ត្រូវដឹងអារម្មណ៍ខណៈនោះ កាលណាចិត្តកើតឡើងហើយ នឹងមិនដឹងអារម្មណ៍ គឺមិនបាន ឬនឹងមានតែចិត្តដែលជាសភាពដឹង ដោយ មិនមានអារម្មណ៍ ដែលជាអ្វី (របស់ វត្ថុ សភាវៈ) ដែលត្រូវដឹង ក៏មិនបាន ។

ចិត្តដែលជាសភាវធម៌ដែលដឹងអារម្មណ៍នោះ មិនមែនមានតែក្នុង ព្រះពុទ្ធសាសនា ឬចំពោះតែក្នុងមនុស្សនោះប៉ុណ្ណោះទេ ចិត្តឃើញ ចិត្តឮ ចិត្តធុំក្លិន ជាដើមនោះ ជាបរមត្ថធម៌ មិនមែនជាតិណា ៗ ទាំងអស់ ។ ការដែលបញ្ញត្តិថាបុគ្គលនេះឃើញ សត្វនោះឮ ជាដើមនោះ ក៏អាស្រ័យ ដោយរូប និងការចាំដែរ តែបើមិនមានរូប និងការចាំទេ ក៏រមែងនឹងបញ្ញត្តិ ចិត្តឃើញ ចិត្តឮនោះ ៗ ថាជាបុគ្គលនេះ ឬសត្វនោះឃើញ ឬឮមិន បានឡើយ ។ ចិត្ត ជាបរមត្ថធម៌ មិនថា ជាចិត្តឃើញនៃសត្វណា បុគ្គលណាឡើយ ចិត្តឃើញដែលកើតឡើងនោះ គឺត្រូវឃើញនូវអ្វីដែល

ប្រាកដតាមផ្លូវភ្នែក ។ ចិត្តឮ គឺត្រូវឮសំឡេង ។ ចិត្តឃើញ នឹងត្រូវទៅដឹងសំឡេងមិនបាន ចិត្តឮ នឹងត្រូវទៅដឹងរូបដែលប្រាកដតាមផ្លូវភ្នែក ក៏មិនបាន ។ គឺមិនមានអ្នកណាមួយ មានអំណាច បង្គាប់បញ្ជាឱ្យបរមត្ថធម៌ផ្លាស់ប្តូរលក្ខណៈ និងសភាវៈនៃបរមត្ថធម៌នោះ ។ ឱ្យទៅជាយ៉ាងដទៃបាននោះ គឺមិនមានឡើយ ។ ចិត្តដែលជាបរមត្ថធម៌ កើតឡើងដឹងអារម្មណ៍នោះ កើតឡើងបាន ព្រោះមានហេតុបច្ច័យធ្វើឱ្យកើតឡើង កាលណាមិនមានបច្ច័យ ចិត្តក៏កើតមិនបាន ដូចជា ពេលណាសំឡេងមិនកើតឡើងមកប៉ះខ្ទប់នឹងត្រចៀក ចិត្តឮក៏កើតមិនបាន កាលណាក្លិនមិនកើតប៉ះខ្ទប់នឹងច្រមុះ ចិត្តដឹងក្លិនក៏កើតមិនបាន ។ ចិត្តតែមួយប្រភេទ នឹងកើតឡើងបាន ក៏ព្រោះតែមានបច្ច័យធ្វើឱ្យកើតចិត្តប្រភេទនោះ ។ ដូច្នេះហើយទើបចិត្តដែលកើតឡើងផ្សេងគ្នា ៨៩ ឬ ១២១ ប្រភេទ ដោយពិស្តារ (ដែលហៅថា ៨៩ ដួង ឬ ១២១ ដួង) និងបច្ច័យដែលធ្វើឱ្យកើតចិត្តមួយប្រភេទ ។ នោះ ក៏មិនមែនមានត្រឹមតែបច្ច័យមួយនោះទេ គឺមានច្រើនបច្ច័យដូចជា

ចិត្តឃើញកើតឡើងព្រោះមានបច្ច័យ គឺភ្នែក បានដល់ ចក្ខុបសាទ និងរូបដែលជាសភាវៈប្រាកដតាមផ្លូវភ្នែក ជាដើម ។

ចិត្ត ជាបរមត្ថធម៌ដែលមិនមែនរូប ។ បរមត្ថធម៌ណាមិនមែនរូប បរមត្ថធម៌នោះ ជានាមធម៌ ។ ចិត្ត ចេតសិក និព្វានជានាមធម៌ រូបជារូបធម៌ ។

ចេតសិកបរមត្ថ

ក្នុងខណៈដែលចិត្តកើតឡើងដឹងនោះ **មាននាមបរមត្ថមួយប្រភេទទៀត កើតរួមជាមួយចិត្ត ហើយដឹងអារម្មណ៍ដូចចិត្តដែរ នាមបរមត្ថនោះគឺចេតសិក** ។ ចេតសិក បានដល់ សេចក្តីក្រោធ សេចក្តីស្រឡាញ់ សេចក្តីសុខ សេចក្តីទុក្ខ សេចក្តីកំណាញ់ សេចក្តីឫស្សា សេចក្តីមេត្តា សេចក្តីករុណា ជាដើម ។ សភាវធម៌ទាំងនេះ ជាចេតសិកបរមត្ថ មិនមែនជាចិត្តបរមត្ថ ។

សេចក្តីក្រោធ សេចក្តីស្រឡាញ់ សេចក្តីសុខ សេចក្តីទុក្ខ ជាដើមនោះ ជាសភាវធម៌ដែលមានពិត មិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ជាសភាវធម៌ដែលត្រូវកើតជាមួយនឹងចិត្ត បើមិនមានចិត្ត ចេតសិក សេចក្តីក្រោធ សេចក្តីស្រឡាញ់ សេចក្តីទុក្ខ ជាដើមនោះ ក៏កើតមិនបាន ។ ចេតសិកបរមត្ថ មាន ៥២ ប្រភេទ ឬហៅថា ៥២ ដួង ដូចជា សេចក្តីក្រោធ (ទោសៈ) ក៏ជាចេតសិកមួយបែប មានលក្ខណៈ ប្រទូស្ត កាចសាហាវ សេចក្តីស្រឡាញ់ក៏ជាចេតសិកមួយបែប គឺលោភចេតសិក មានលក្ខណៈជាប់ជំពាក់ប្រកាន់ស្អិតមិនលែង និងប្រាថ្នាក្នុងអារម្មណ៍ នេះអាចឱ្យឃើញបានថា ចេតសិកមួយប្រភេទ ជាសភាវធម៌មួយបែប មិនមែនជាសភាវធម៌ដូចៗ គ្នាទេ ។ ក្រៅពីមានលក្ខណៈផ្សេងគ្នា

កិច្ចការងារនៃចេតសិកនីមួយ ។ ក៏ផ្សេងគ្នាដែរ ផល គឺអាការដែលប្រាកដក៏ផ្សេងគ្នា និងហេតុបច្ច័យដែលធ្វើឱ្យកើតប្រភេទចេតសិកនីមួយ ។ ក៏ផ្សេងគ្នា ។

ចិត្តបរមត្ថ និងចេតសិកបរមត្ថ ជានាមធម៌ដែលដឹងអារម្មណ៍ និងកើតរួមគ្នា ។ ចេតសិកកើតព្រមនឹងចិត្ត រលត់ព្រមនឹងចិត្ត ដឹងអារម្មណ៍តែមួយជាមួយនឹងចិត្ត និងកើតត្រង់កន្លែងតែមួយជាមួយចិត្ត គឺចិត្តកើតរលត់ទីណា ចេតសិកកើតរលត់ទីនោះ ។ ចិត្តបរមត្ថ និងចេសិកបរមត្ថនោះ មិនញែកដាច់ពីគ្នាឡើយ គឺមិនកើត រលត់ តែបរមត្ថមួយ ។ ទេ ។ ចិត្តជាប្រធាន ជាធំក្នុងការដឹងអារម្មណ៍ ចំណែកចេតសិកផ្សេង ។ ដែលកើតរួមនឹងចិត្ត ក៏ដឹងអារម្មណ៍ដូចចិត្តដែរ តែមានលក្ខណៈ និងនាទីក្នុងការដឹងអារម្មណ៍នោះផ្សេងគ្នា ទៅតាមលក្ខណៈ និងកិច្ចការងារនៃប្រភេទចេតសិកនីមួយ ។ ។ ព្រោះហេតុដែលចិត្តដួងនីមួយ ។ ដែលកើតឡើងនោះ មានចេតសិកកើតរួម តិចច្រើនផ្សេង ។ និងជាប្រភេទចេតសិកផ្សេងគ្នា ទើបធ្វើឱ្យចិត្តផ្សេងគ្នាជា ៨៩ ឬ ១២១ ប្រភេទដោយពិស្តារ ។ ចិត្តប្រភេទនីមួយ ។ នោះមិនដូចគ្នាដោយដឹងអារម្មណ៍ផ្សេងគ្នាខ្លះ ដោយធ្វើកិច្ចផ្សេងគ្នាខ្លះ ដោយចេតសិកដែលកើតរួមផ្សេងគ្នាខ្លះ ។ ដូចជា ចិត្តដួងខ្លះ មានអ្វីមកប្រាកដតាមផ្លូវភ្នែកជាអារម្មណ៍ ចិត្តដួងខ្លះមានសំឡេងជាអារម្មណ៍ជាដើម ។ ចិត្តដួងខ្លះធ្វើកិច្ចឃើញ ចិត្តដួងខ្លះធ្វើកិច្ចឮជាដើម ។ ចិត្តដួងខ្លះ មានលោភ

ចេតសិកកើតរួមផង ចិត្តដួងខ្លះមានទោសចេតសិកកើតរួមផង ដូចនេះ ជាដើម ។

កាលវេនេយ្យសត្វស្តាប់ព្រះធម៌ ក៏ពិចារណានូវសភាពបរមត្ថធម៌ ដែលកំពុងប្រាកដ ដោយបញ្ញាដែលបានអប់រំសន្សំ មកហើយក្នុង អតីតជាតិ ទើបដឹងសេចក្តីពិតនៃសភាពបរមត្ថក្នុងខណៈនោះបាន ។ ដោយអាស្រ័យហេតុនេះហើយ ក្នុងសម័យពុទ្ធកាល ពេលព្រះបរមសាស្តាទ្រង់សម្តែងធម៌ចប់កាលណា ទើបមានអ្នកសម្រេចមគ្គ ផល និព្វានជាចំនួនច្រើន ព្រោះលោកទាំងនោះស្តាប់ព្រះធម៌យល់ និងពិចារណា ដឹងសេចក្តីពិតនៃសភាវៈបរមត្ថធម៌ ដែលកំពុងប្រាកដក្នុងខណៈនោះ ។ ដូចជាពេលព្រះអង្គទ្រង់ទេសនាថា ចក្ខុវិញ្ញាណ គឺចិត្តដែលធ្វើកិច្ចឃើញនោះ មិនទៀង លោកទាំងនោះក៏មានសតិសម្បជញ្ញៈ ដឹងសភាវៈលក្ខណៈនៃចិត្តក្នុងខណៈដែលកំពុងឃើញនោះបានត្រឹមត្រូវ ថាជាសភាវធម៌ ដែលជានាមធម៌ មិនមែនតួខ្លួន មិនមែនសត្វ មិនមែនបុគ្គល ។ ក្នុងខណៈដែលកំពុងឮ លោកទាំងនោះមានសតិសម្បជញ្ញៈ ដឹងលក្ខណៈនៃសភាវធម៌ ក្នុងខណៈដែលកំពុងបានឮនោះ ។ កាលណាបញ្ញាដឹងច្បាស់លក្ខណៈមិនទៀង កើត រលត់ ជាទុក្ខនៃបរមត្ថធម៌ ដែលប្រាកដក្នុងខណៈនោះហើយ ក៏លះបង់សេចក្តីត្រេកអរ ឃើញខុស ក្នុងការដែលប្រកាន់ស្អិតនូវបរមត្ថធម៌ទាំងនោះ ថាជាតួខ្លួន ទៀង និង ជាសុខ ។ ដូច្នោះ គប្បីយល់ឱ្យច្បាស់ ត្រឹមត្រូវថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់ដឹង និងទ្រង់ទេសនាទូន្មានប្រៀនប្រដៅ ដែលបានប្រមែប្រមូលចងក្រងទុកជាក្បួនច្បាប់ ក្នុងព្រះត្រៃបិដកនោះ ជារឿងពិតប្រាកដនៃសភាវធម៌ទាំងពួង ។ ការសិក្សាបានយល់បរមត្ថធម៌ ហើយក៏គួរពិចារណាបរមត្ថធម៌ដែលកំពុងប្រាកដ ដើម្បីដឹងច្បាស់នូវលក្ខណៈពិតរបស់បរមត្ថធម៌ដែលកំពុងប្រាកដ នោះទើបនឹងអាចលះបង់នូវសេចក្តីសង្ស័យ និងសេចក្តីមិនដឹងក្នុងសភាវៈលក្ខណៈនៃបរមត្ថធម៌ បានយ៉ាងពិតប្រាកដ ។

ការសិក្សាដើម្បីឱ្យយល់បរមត្ថធម៌នោះ គឺត្រូវពិចារណាហេតុផលទើបនឹងយល់បានជាក់ច្បាស់ ដូចជាត្រូវដឹងថា សភាពដែលឃើញ សភាពដែលឮ នោះដូចគ្នាឬទេ ? បើដូចគ្នា ដូចគ្នាយ៉ាងណាខ្លះ ? បើមិនដូចគ្នា តើមិនដូចគ្នាយ៉ាងណាខ្លះ ? សភាពឃើញ សភាពឮ ជាចិត្តបរមត្ថពិត តែមិនមែនចិត្តដូចគ្នា ព្រោះហេតុបច្ច័យដែល ធ្វើឱ្យកើតនោះផ្សេងគ្នា ។ ចិត្តឃើញនោះ ត្រូវអាស្រ័យអ្វីដែលប៉ះខ្ទប់នឹងចក្ខុបសាទជាបច្ច័យ ទើបអាចកើតឡើងបាន ចំណែកចិត្តឮ ត្រូវអាស្រ័យសំឡេងប៉ះខ្ទប់នឹងសោតបសាទជាបច្ច័យ ទើបអាចកើតឡើងបាន ចិត្តឃើញ និងចិត្តឮ មានកិច្ចផ្សេងគ្នា ហើយនឹងកើតអំពីបច្ច័យផ្សេងគ្នា។

រូបបរមត្ថ

រូបបរមត្ថ ជាសភាវធម៌ដែលមិនដឹងអារម្មណ៍[៧] មានបច្ច័យតាក់តែង ទើបកើតឡើង និងរលត់ទៅវិញដូចជាចិត្ត និងចេតសិកដែរ ។ រូបបរមត្ថមាន ២៨ រូប ឬ ២៨ ប្រភេទ និងមានសេចក្តីសម្គាល់មិនដូចនឹងការនាំគ្នាយល់ថា តុជារូបមួយ កៅអីជារូបមួយ សៀវភៅជារូបមួយ ដូច្នេះជាដើមទេ ។ ក្នុងរូបបរមត្ថ ២៨ ប្រភេទនោះ មានរូបដែលចិត្តដឹងបាន តាមផ្លូវភ្នែក គឺមើលឃើញបានត្រឹមតែរូបមួយ គឺអ្វីដែលប្រាកដតាមផ្លូវភ្នែកប៉ុណ្ណោះ ចំណែក ២៧ រូបទៀតនោះ ចិត្តឃើញមិនបាន តែដឹងបានផ្លូវដទៃ តាមប្រភេទនៃរូបនោះ ។ ដូចសំឡេងដឹង បានតាមផ្លូវត្រចៀកជាដើម ។

សូម្បីតែនឹងឃើញចិត្ត និងចេតសិកដោយភ្នែក ក៏មិនបានដូចជារូប ២៧ ដែលមើលមិនឃើញដែរ ។ ចិត្ត និងចេតសិកមិនមែនជារូបបរមត្ថ ព្រោះចិត្ត និងចេតសិកជាបរមត្ថធម៌ដែលដឹងអារម្មណ៍ ចំណែករូបជាបរមត្ថធម៌ដែលមិនដឹងអារម្មណ៍[២]។ រូបបរមត្ថ ជាសង្ខារធម៌ មានបច្ច័យតាក់តែងទើបកើតឡើងបាន ។ រូបនីមួយៗ ត្រូវអាស្រ័យរូបដទៃ ទើបកើតឡើងបាន ។ ដូច្នេះនឹងមានរូបកើតឡើង ត្រឹមតែរូបមួយ ៗ នោះមិនបាន គឺត្រូវមានរូបដែលកើតព្រមគ្នា និងអាស្រ័យគ្នាកើតឡើងច្រើនរូប

---

[៧] ធម្មសង្គណីបករណ រូបកំណ្ឌ

[២] ធម្មសង្គណីបករណ វត្ថុទ្វារកណ្ឌ មហន្តរទុក្ក

រួមគ្នា ១ ក្រុមតូច ៗ ដែលភាសាបាលីហៅថា ១ កលាប ។ រូបជាសភាវធម៌ដែលតូចល្អិតណាស់ កើតឡើងហើយរលត់ទៅយ៉ាងឆាប់រហ័សគ្រប់ពេល ។ រូបមួយកលាបដែលកើតឡើងហើយ និងរលត់ទៅក្នុងកាលណាចិត្តកើតរលត់បាន ១៧ ខណៈ ដែលប្រព្រឹត្តទៅ យ៉ាងឆាប់រហ័សពេកណាស់ គឺចិត្តរលត់ ១៧ ដង ទើបរូបរលត់ម្តង ៗ ។ ដោយចិត្តឃើញ និងចិត្តដែលឮខណៈនេះ ដែលប្រាកដហាក់ដូចជាព្រមគ្នានោះ គឺកើត រលត់រយៈឆ្ងាយលើសជាង ១៧ ខណៈចិត្តទៅទៀត ដូច្នោះ រូបដែលកើតព្រមនឹងចិត្តឃើញរលត់ទៅមុនពេលចិត្តដែលឮ នឹងកើតឡើង ។ រូបមួយ ៗ តូចល្អិតណាស់ កាលណាធ្វើការវិភាគបំបែករូបដែលកើត រលត់ព្រមគ្នានោះឱ្យដាច់ពីគ្នារហូតដល់ចំណែកតទៅទៀតមិនបានហើយនោះ **ក្នុងក្រុមនៃរូបដែលតូចជាទីបំផុត ឬតិចជាទីបំផុត (១ កលាប) ដែលចំណែក បំបែកទៅទៀតមិនបានសោះនោះ គឺមានរូបរួមគ្នាយ៉ាងតិចបំផុត ៨ រូប ហៅថា អវិនិព្ភោគរូប ៨ គឺ**

មហាភូតរូប (រូបដែលជាធំ ជាប្រធាន) ៤ បានដល់

បឋវីធាតុ (ធាតុដី) ជារូបដែលទន់ ឬរឹង ១ រូប

អាបោធាតុ (ធាតុទឹក)ជាធាតុដែលរឹងជ្រួតជ្រាបឬប្រមូលផ្តុំ ១ រូប

តេជោធាតុ (ធាតុភ្លើង) ជារូបដែលក្តៅ ឬត្រជាក់ ១ រូប

វាយោធាតុ (ធាតុខ្យល់) ជារូបដែលកម្រើក តឹង ឬ ញ័រ ១ រូប ។

មហាភូតរូប ៤ នេះ អាស្រ័យគ្នានឹងគ្នាកើតឡើង ទើបបែកពីគ្នាពុំបានឡើយ និងមហាភូតរូប ៤ នេះ ជាបច្ច័យ ជាទីអាស្រ័យកើតនៃរូប ៤ ដទៃទៀត ដែលកើតរួមនឹងមហាភូតរូប ក្នុងកលាបតែមួយគឺ

វណ្ណៈ (ពណ៌) ជារូបដែលប្រាកដតាមផ្លូវភ្នែក ១ រូប

គន្ធៈ (ក្លិន) ជារូបដែលប្រាកដតាមផ្លូវច្រមុះ ១ រូប

រស (រស) ជារូបដែលប្រាកដតាមផ្លូវអណ្តាត ១ រូប

ឱជា (អាហារ) ជារូបដែលជាបច្ច័យឱ្យកើតរូប ១ រូប ។

រូប ៨ រូបនេះ បែកគ្នាពុំបានឡើយ ជាក្រុមនៃរូបដែលតូចបំផុតដែលកើតព្រមគ្នា រលត់ព្រមគ្នាយ៉ាងរហ័ស និងថាមានតែមហាភូតរូប ៤ ដោយមិនមាន **ឧបាទាយរូប** (រូបដែលអាស្រ័យមហាភូតរូបកើត) ៤ រូបនេះប៉ុណ្ណោះពុំបានឡើយ ។

មហាភូតរូប ៤ ជាបច្ច័យ ជាទីអាស្រ័យនៃឧបាទាយរូប ដែលកើតរួមគ្នាក្នុងកលាបតែមួយ ។ ថ្វីដ្បិតតែឧបាទាយរូបអាចកើតព្រមនឹងមហាភូតរូប ក្នុងកលាបតែមួយក៏ដោយ តែឧបាទាយរូបក៏មិនបានជាបច្ច័យឱ្យមហាភូតរូបកើតដែរ ។ ដូច្នោះ **មហាភូតរូប ៤** ទើបកើតព្រមនឹង **ឧបាទាយរូប ដោយមហាភូតរូបជាបច្ច័យ គឺជាទីអាស្រ័យនៃឧបាទាយរូប**

និងឧបាទាយរូបកើតព្រមនឹងមហាភូតរូប ដោយអាស្រ័យមហាភូតរូប តែមិនបានជាបច្ច័យឱ្យមហាភូតរូបកើតទេ ។

រូបទាំងអស់មាន ២៨ រូប ជាមហាភូតរូប ៤ ឧបាទាយរូប ២៤ ។ កាលណាមហាភូតរូប ៤ មិនកើត ឧបាទាយរូប ២៤ ក៏មិនមានដែរ ។

បើពោលដល់រូប ២៨ នោះ គឺពោលបានច្រើនន័យ តែសូមពោលដោយន័យដែលសម្ព័ន្ធគ្នា ដើម្បីស្រួលដល់ការយល់ និងការចាំ ដូចនេះគឺ

ក្រុមនៃរូបមួយក្រុម គឺមួយកលាបនោះ កាលណា កើតឡើងហើយ នៅមិនទាន់រលត់ទៅភ្លាមនោះ **សភាវរូប** មានអាយុស្មើនឹងចិត្តកើតរលត់ ១៧ ខណៈ ។

ពេលរូបកើតឡើងខណៈដំបូងនោះ ជា**ឧបចយរូប ១** ។

ខណៈដែលរូបចម្រើនឡើង ជា**សន្តតិរូប ១** ។

ខណៈដែលរូបគ្រាំគ្រាចុះ ជា**ជរតារូប ១** ។

ខណៈដែលរូបរលត់ ជា**អនិច្ចតារូប ១ រួមជាលក្ខណៈរូប ៤** ។

លក្ខណៈរូប ៤ នេះ ជាអសភាវរូប គឺជារូបដែលមិនមានសភាវៈចំពោះនៃខ្លួនមួយចំណែកទៀត ។ ប៉ុន្តែសភាវរូបគ្រប់រូបនោះ រមែងមានលក្ខណៈដែលផ្សេងពីគ្នាជា ៤ លក្ខណៈ គឺខណៈដែលរូបកើតឡើង មិនមែន ខណៈដែលរូបចម្រើនឡើង និងខណៈដែលរូបទ្រុឌទ្រោមគ្រាំគ្រា ក៏មិនមែនខណៈដែលកំពុងចម្រើនឡើង និងខណៈដែលរលត់ ក៏មិនមែនជាខណៈ

ដែលទ្រុឌទ្រោមគ្រាំគ្រា គឺពោលបានថា ឧបចយរូប និងសន្ដតិរូប គឺខណៈដែលកើតហើយមិនទាន់រលត់ ចំណែក ជរតារូប និងអនិច្ចតារូបនោះ គឺខណៈដែលជិតនឹងរលត់ និងខណៈរលត់ ។

រួមអរិនិព្ភោគរូប ៨ + លក្ខណៈរូប ៤ ជា ១២ រូប ក្រៅពីនេះនៅមាន

បរិច្ឆេទរូប គឺអាកាសរូប នៅខណ្ឌចន្លោះគ្រប់ ៗ កលាបដែលតូចបំផុតមួយទៀត ធ្វើឱ្យរូបកលាបនីមួយ ៗ មិនជាប់គ្នា ។ មិនថារូបនឹងប្រាកដតូច ធំខ្នាតណាក៏ដោយ រមែងតែងមានអាកាសរូបនៅខណ្ឌចន្លោះគ្រប់ ៗ កលាបយ៉ាងល្អិតបំផុតធ្វើឱ្យរូបកលាបនីមួយ ៗ បែកចេញពីគ្នាបាន ។ បើមិនមានបរិច្ឆេទរូបខណ្ឌកលាបមួយៗទេ រូបទាំងឡាយ គឺត្រូវជាប់គ្នាទាំងអស់បែកញែកខ្ចាត់ខ្ចាយពីគ្នាពុំបានឡើយ ។ សូម្បីតែរូបដែលប្រាកដធំធេងយ៉ាងណាក៏អាចញែកបែកចេញបានល្អិតជាទីបំផុតនោះក៏ព្រោះមានអាកាសធាតុ គឺបរិច្ឆេទរូបនៅខណ្ឌគ្រប់ ៗ កលាបនោះឯង ។ ដូច្នោះ បរិច្ឆេទរូបទើបជាអសភាវរូប ១ ទៀតដែលមិនមានលក្ខណៈ ចំពោះនៃខ្លួនកើតឡើងមួយចំណែកទៀត ប៉ុន្តែកើតខណ្ឌចន្លោះកលាប ផ្សេង ៗ ដែលកើតព្រមគ្នានោះឯង ។

រួមអរិនិព្ភោគរូប ៨ + លក្ខណៈរូប ៤ + បរិច្ឆេទរូប ១ ជា ១៣ រូប ។

មិនថារូបកើតត្រង់ណាឡើយ ភពភូមិណាក៏ដោយ ជារូបមានចិត្តគ្រប់គ្រង ឬមិនមានចិត្តគ្រប់គ្រងក៏ដោយ នឹងប្រាសចាករូប ១៣ នេះ

មិនបានឡើយ ។ ចំណែករូបដែលមានចិត្តគ្រប់គ្រង ដែលជារូបរបស់សត្វបុគ្គលផ្សេង ។ ក្នុងភពភូមិដែលមានខន្ធ ៥ នោះមានបសាទរូប ដែលកើតពីកម្មជាសមុដ្ឋាន (បច្ច័យ) មានដូចនេះ គឺ

ចក្ខុបសាទរូប ជារូបដែលប៉ះខ្ទប់នឹងសភាវៈដែលប្រាកដ តាមផ្លូវភ្នែក ១ រូប

សោតបសាទរូប ជារូបដែលប៉ះខ្ទប់នឹងសំឡេងបាន ១ រូប

ឃានបសាទរូប ជារូបដែលប៉ះខ្ទប់នឹងក្លិនបាន ១ រូប

ជិវ្ហាបសាទរូប ជារូបដែលប៉ះខ្ទប់នឹងរសបាន ១ រូប

កាយបសាទរូប ជារូបដែលប៉ះខ្ទប់នឹងត្រជាក់ ក្តៅ (ធាតុភ្លើង) ១ ទន់ រឹង (ធាតុដី) ១ តឹង កម្រើក ញ័រ(ធាតុខ្យល់)១

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ ជា ១៨ រូប ។

រូបដែលមានចិត្តគ្រប់គ្រងនោះ ខណៈចិត្តគ្រប់ខណៈ ដែលនឹងត្រូវកើតត្រង់រូបតាមប្រភេទនៃចិត្តនោះ ។ គឺចក្ខុវិញ្ញាណធ្វើកិច្ចឃើញ កើតត្រង់ចក្ខុបសាទរូប សោតវិញ្ញាណធ្វើកិច្ចឮ កើតត្រង់សោតបសាទ ឃានវិញ្ញាណធ្វើកិច្ចធុំក្លិន កើតត្រង់ឃានបសាទរូប ជិវ្ហាវិញ្ញាណធ្វើកិច្ចក្រេបជញ្ជក់រស កើតត្រង់ជិវ្ហាបសាទរូប កាយវិញ្ញាណធ្វើកិច្ចដឹងនូវផោដ្ឋព្វៈ (ធាតុដី ភ្លើង ខ្យល់) កើតត្រង់កាយបសាទរូប ។

ចិត្តដទៃ (ក្នុងភូមិដែលមានខន្ធ ៥) ក្រៅពីនេះ កើតត្រង់រូបមួយ ហៅថា ហទយរូប ព្រោះជារូបដែលជាទីកើតនៃចិត្ត ។ ដូច្នោះ វត្ថុរូបដែលជារូបជាទីកើតរបស់ចិត្តទើបមាន ៦ រូប

រួមអវិនិព្ភោគរូប ៨ + លក្ខណៈរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ ជារូប ១៩ ។

រូបដែលកើតអំពីកម្ម ជាសមុដ្ឋានគ្រប់កលាប នឹងត្រូវមាន ជីវិតិន្ទ្រិយរូបកើតរួមដែរគ្រប់កលាបៈ ។ **ជីវិតិន្ទ្រិយរូប** រក្សារូបដែលកើតរួមគ្នាក្នុងកលាបមួយ ។ ឱ្យជារូបមានជីវិតទ្រទ្រង់នៅ ដូច្នេះ រូបរបស់សត្វបុគ្គលដែលជីវិតទ្រទ្រង់នៅ ទើបផ្សេងពីរូបទាំងឡាយ ដែលគ្មានចិត្តគ្រប់គ្រង ។

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ + ជីវិតិន្ទ្រិយរូប ១ ជា ២០ រូប ។

ការដែលសត្វបុគ្គលទាំងឡាយដោយទូទៅផ្សេងគ្នាជាស្រី ជាប្រុសនោះ ព្រោះភាវរូប ២ គឺ

ឥត្ថីភាវរូប ជារូបដែលជ្រាបសាយសព្វកាយ ធ្វើឱ្យប្រាកដជា ទ្រង់ទ្រាយ សណ្ឋាន អាការ កិរិយា មារយាទជាស្ត្រីភេទ ។

បុរិសភាវរូប ជារូបដែលជ្រាបសាយទៅសព្វកាយធ្វើឱ្យប្រាកដជាទ្រង់ទ្រាយ សណ្ឋាន អាការ កិរិយាមារយាទជាបុរសភេទ ដែលក្នុងម្នាក់មានតែភាវរូបណាមួយ គឺឥត្ថីភាវរូប ឬ បុរិសភាវរូបប៉ុណ្ណោះ និងបុគ្គលខ្លះ

ក៏មិនមានភាវរូបឡើយ ដូចជា ព្រហ្មបុគ្គលក្នុងព្រហ្មលោក និងអ្នកដែលខ្វើយ ។

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ + ជីវិតិន្ទ្រិយរូប ១ + ភាវរូប ២ ជា ២២ រូប ។

ការដែលរូបនៃសត្វបុគ្គលទាំងឡាយមានចលនាទៅបាន ព្រោះមានចិត្តនោះ ក៏ត្រូវមានរូបដែលកើតអំពីចិត្តជាសមុដ្ឋានដែរ ព្រោះបើមានត្រឹមតែរូបដែលកើតអំពីកម្មប៉ុណ្ណោះទេ នឹងធ្វើចលនាទៅមកដោយកិច្ចធុរៈអ្វីមួយមិនបានឡើយ ។ ការដែលរូបរាងកាយធ្វើចលនាទៅមកដោយកិច្ចការងារផ្សេង ៗ បាននោះ នឹងត្រូវមានវិការរូប ៣ គឺរូបលហុតា ១ រូបមុទុតា ១ រូបកម្មញ្ញតា ១ ។

រូបលហុតា ជាអាការរូបស្រាល រហ័សមិនធ្ងន់នៃរូប ដូចជា អាការនៃមនុស្សដែលមិនមានរោគ ។

រូបមុទុតា ជាភាវនៃរូបទន់ រូបមិនរឹង ឧបមាដូចស្បែកដែលទំពាហ្មត់ទុកល្អហើយ ។

រូបកម្មញ្ញតា ជាភាវនៃរូបគួរដល់ការងារ ឧបមាដូចជាមាសដែលរំលាយទុកល្អហើយ ។

វិការរូប ៣ នេះជារូបដែលកើតក្នុងសត្វបុគ្គលប៉ុណ្ណោះ រូបដែលមិនមានចិត្តគ្រប់គ្រងមិនមានវិការរូប ៣ នេះឡើយ និងវិការរូប ៣ នេះ

មិនបែកគ្នាទេ ក្នុងកលាបៈណាមានលហុតារូប កលាបៈនោះ ក៏មានមុទុតារូប និងកម្មញ្ញតារូបដែរ ។ ក្រៅពីនេះ កាលណាចិត្តត្រូវការចលនាចំណែកណាមួយនៃរាងកាយ រាងកាយចំណែកនោះ នឹងត្រូវមានវិការរូបដែលកើតអំពីឧតុ (សេចក្តីដូចនៃធាតុក្តៅត្រជាក់) ជាសមុដ្ឋាន និងមានវិការរូបដែលកើតអំពីអាហារ (ឱជារូប) ជាសមុដ្ឋានដែរ បើពុំដូច្នោះទេ សូម្បីចិត្តនឹងត្រូវការចលនា រូបក៏ធ្វើចលនាមិនបាន ដូចជា អ្នកដែលអាពាធ គ្រេចថ្លោះ ជាដើម ។

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ + ជីវិតិន្ទ្រិយរូប ១ + ភាវរូប ២ + វិការរូប ៣ ជារូប ២៥ ។

រូបដែលមានចិត្តគ្រប់គ្រងនោះ កាលណាចិត្តត្រូវការឱ្យរូបសម្តែងឱ្យដឹងការសម្គាល់តាមកាយ តាមដែលចិត្តដឹងក្នុងអាការនៅខណៈណាខណៈនោះចិត្ត ជាសមុដ្ឋានឱ្យ**កាយវិញ្ញត្តិរូប** គឺអាការពិសេស ដែលមានការសម្គាល់នៃរូបកើតឡើង តាមដែលចិត្តដឹងក្នុងអាការនោះ ។ ការសម្គាល់នៃភ្នែក នៃមុខដូចជាប៉ប្រិចភ្នែក ញញឹម ឬឱនក្រាបជាដើម កាលណាចិត្តមិនត្រូវការឱ្យរូបសម្តែងចេញការសម្គាល់ កាយវិញ្ញត្តិរូប ក៏មិនកើត ។

ខណៈណាដែលចិត្តជាបច្ច័យឱ្យកើតសំឡេងតាមផ្លូវវាចា ដែលជាការនិយាយ ការបញ្ចេញសំឡេងឱ្យដឹងនៃការសម្គាល់ ខណៈនោះចិត្ត ជា

សមុដ្ឋាន គឺជាបច្ច័យឱ្យ**វចីវិញ្ញត្តិ** កើតឡើងប៉ះខ្ទប់នឹងទីឋានដែលកើត នៃសំឡេងផ្សេង ។ ដូចជាកម្រើកបបូរមាត់ជាដើម ។ បើវចីវិញ្ញត្តិរូប មិនកើត ការនិយាយ ឬការបញ្ចេញសំឡេងផ្សេងៗ ក៏មិនបាន ។

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ + ជីវិតិន្ទ្រិយរូប ១ + ភាវរូប ២ + វិការរូប ៣ + វិញ្ញត្តិរូប ២ ជារូប ២៧ ។

ក្នុងកន្លែងខ្លះនឹងហៅវិការរូប ៣ និងវិញ្ញត្តិរូប ២ រួមគ្នាជាវិការរូប ៥។ សំឡេង ឬ**សទ្ទរូប** មិនមែនវចីវិញ្ញត្តិរូប ។ សំឡេងជារូបដែលប៉ះខ្ទប់នឹងសោតបសាទរូប ជាបច្ច័យឱ្យកើតសោតវិញ្ញាណ ។ សំឡេងខ្លះក៏កើតអំពីចិត្ត និងសំឡេងខ្លះក៏មិនបានកើតអំពីចិត្ត ដូចជា សំឡេងផ្គរលាន់ សំឡេងខ្យល់ព្យុះ សំឡេងគ្រឿងយន្ត សំឡេងស្គរ សំឡេងវិទ្យុ សំឡេងទូរទស្សន៍ ជាដើម ។

រួមអវិនិព្ភោគរូប ៨ + លក្ខណរូប ៤ + បរិច្ឆេទរូប ១ + បសាទរូប ៥ + ហទយរូប ១ + ភាវរូប ២ + វិការរូប ៣ + វិញ្ញត្តិរូប ២ + ជីវិតិន្ទ្រិយរូប ១ + សទ្ទរូប ១ ជារូប ២៨ ។

ក្នុងកន្លែងខ្លះ សម្តែងចំនួននៃរូបផ្សេងគ្នា ដូចក្នុងអដ្ឋសាលិនីរូបកំណ្ឌ បកិណ្ណកកថា សម្តែងរូប ២៥ គឺរួមធាតុដី ភ្លើង ខ្យល់ ជាជោដ្ឋព្វាយតនៈ (រូបដែលប៉ះខ្ទប់នឹងកាយបសាទ) ជារូប ១ រួមនឹងហទយរូប ១ ទៀតទើបជារូប ២៦ ។ កាលណារូប ១ កើតឡើង

គឺកើតព្រមនឹងរូបប៉ុន្មានទៀត រួមគ្នាជា កលាប មួយ ។ នោះ រមែងផ្សេងគ្នាទៅតាមប្រភេទនៃរូបនោះ ។ ហើយការបែងចែករូប ២៨ រូប មានច្រើនន័យដែលនឹងពោលបន្ថែមទៀតនៅក្នុងភាគបន្ថែម ។

និព្វានបរមត្ថ

បរមត្ថធម៌ មួយប្រភេទទៀត គឺនិព្វានបរមត្ថ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅថា និព្វាន ព្រោះចេញចាកតណ្ហា ជាគ្រឿងដោតក្រង គឺ **វាន**[៩] ។

និព្វានបរមត្ថ ជាសភាវធម៌ដែលរំលត់ទុក្ខ ។ ចិត្ត ចេតសិក រូប ជាទុក្ខ ព្រោះមិនទៀង កើតឡើងហើយក៏រលត់ទៅ ។ ការដែលអាចនឹងរំលត់ទុក្ខទៅបាននោះ គឺត្រូវរំលត់តណ្ហា ព្រោះតណ្ហាជាសមុទយៈ ជាហេតុឱ្យកើតទុក្ខ ជាសមុទយៈឱ្យកើតខន្ធ ដែលបានដល់ ចិត្ត ចេតសិក រូប ។ ការដែលនឹងអាចរំលត់តណ្ហាបាននោះ ក៏ដោយសារការអប់រំចម្រើនបញ្ញារហូតដល់ដឹងជាក់ច្បាស់ក្នុងលក្ខណៈកើត រលត់នៃចិត្ត ចេតសិក រូប ដែលជាសភាវធម៌ ដែលមិនទៀង ជាទុក្ខ ជាអនត្តានៃចិត្ត ចេកសិក រូប ហើយក៏លះបង់សេចក្តីត្រេកអរ ប្រកាន់មាំ ឃើញខុសក្នុងចិត្ត ចេតសិក រូប ហើយ បញ្ញាចាស់ក្លា ក៏រំលត់សេចក្តីត្រេកអរ ប្រកាន់មាំ ឃើញខុសក្នុងចិត្ត

[៩] អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តក ធាតុសូត្រ

ចេតសិក រូប បានដោយការដឹងច្បាស់នូវនិព្វាន ដែលជាសភាវធម៌ដែលរំលត់តណ្ហា រំលត់ទុក្ខ រំលត់ខន្ធ ។ ដូចនេះ និព្វានទើបជាធម៌ដែលមានពិត ជាបរមត្ថធម៌ ជាសភាវធម៌ដែលដឹងច្បាស់បាន ។

និព្វានបរមត្ថ ដោយបរិយាយនៃហេតុ មាន ២ យ៉ាង[៩] គឺ

សឧបាទិសេសនិព្វានធាតុ ១

អនុបាទិសេសនិព្វានធាតុ ១ ។

ពាក្យថា **ឧបាទិ** នេះជាឈ្មោះនៃខន្ធ ៥ គឺចិត្ត ចេតសិក រូប ។ សឧបាទិសេសនិព្វាន គឺនិព្វានដែលនៅមានសល់ខន្ធ គឺសភាពនៃចិត្ត ចេតសិក នៃព្រះអរហន្ត ដែលរំលត់កិលេសទាំងអស់ អស់ហើយ តែនៅមិនទាន់បរិនិព្វាន ។ អនុបាទិសេសនិព្វាន គឺនិព្វានដែលមិនមានខន្ធនៅសល់ គឺការរំលត់ខន្ធមិនកើតទៀតនៃចិត្ត ចេតសិក រូប ជាការបរិនិព្វាននៃព្រះអរហន្ត ។

ពាក្យថា ដោយបរិយាយនៃហេតុ គឺអាងដល់ការនៅមានខន្ធសល់ និងមិនមានខន្ធសល់ ដែលជាហេតុនៃការបញ្ញត្តិនិព្វាន ២ ។

កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងក្រោមម្លប់ព្រះពោធិព្រឹក្សានោះ ព្រះអង្គទ្រង់សម្រេចសឧបាទិសេសនិព្វានធាតុ ។ កិលេស និងធម៌

[៩] ខុទ្ទកនិកាយ ឥតិវុត្តក ធាតុសូត្រ និង អដ្ឋកថា

(ដែលបានដល់ ចិត្ត និងចេតសិកដទៃ ។) ដែលកើតរួម និងកិលេសនោះ រលត់អស់ និងមិនកើតទៀតឡើយ ។ ប៉ុន្តែនៅមានខន្ធ គឺចិត្ត ចេតសិក ដែលប្រាសចាកកិលេស និងរូបកើតរលត់បន្តគ្នាគ្រប់ពេល ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តើសឧបាទិសេសនិព្វាននោះដូចម្តេច ? ភិក្ខុក្នុងធម្មវិន័យនេះ ជាព្រះអរហន្តខីណាស្រព មានព្រហ្មចារ្យនៅចប់ហើយ មានកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ គឺអស់រវល់ដោយកិលេស ១០ និងខន្ធ ៥ តទៅទៀត មានសំយោជនប្រកបក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃនូវវដ្តរបស់ខ្លួន ភិក្ខុនោះរមែងសោយនូវអារម្មណ៍ គួរជាទីប្រាថ្នា និងមិនគួរជាទីប្រាថ្នាទាន់ពេល នៅសោយសុខ និងទុក្ខ ព្រោះសេចក្តីដែលឥន្ទ្រិយទាំង ៥ ណា ជាធម្មជាតិមិនទ្រុឌទ្រោម ឥន្ទ្រិយទាំង ៥ នោះ របស់លោក តាំងនៅនុ៎ះពិត ម្នាលភិក្ខុទាំងឡាយ សេចក្តីអស់ទៅនៃរាគៈ សេចក្តីអស់ទៅនៃទោសៈ សេចក្តីអស់ទៅនៃមោហៈរបស់ភិក្ខុនោះ នេះយើងហៅថាសឧបាទិសេសនិព្វានធាតុ [១០] ។ អនុបាទិសេសនិព្វាន គឺនិព្វានដែលមិនមានខន្ធសេសសល់ ។ ក្នុងពេលដែលព្រះដ៏មានព្រះភាគ ទ្រង់រំលត់ខន្ធបរិនិព្វានចន្លោះដើមសាលៈទាំងគូ[២] ជាអនុបាទិសេសនិព្វាន រំលត់ទាំងអស់ដោយប្រពៃ រំលត់ភពទាំងឡាយ ដដ

---

[១០] ឧទ្ទកនិកាយ ឥតិវុត្តក ធាតុសូត្រ និង អដ្ឋកថា

(២) ទីឃនិកាយ បាសាទិកសូត្រ

ដោយប្រការទាំងពួង រំលត់ចិត្ត ចេតសិក រូប ទាំងអស់មិនមានការកើតទៀតឡើយ ។

ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ជា**ព្រះសេក្ខបុគ្គល** ព្រោះនៅសិក្សាចម្រើនធម៌ ឱ្យច្រើនក្រៃលែងឡើងទៀត ដើម្បី**បហាន** (ប្រហារ) កិលេសដែលនៅសល់ឱ្យអស់ទៅទាំងអស់ ។ ចំណែក ព្រះអរហន្តជា**ព្រះអសេក្ខបុគ្គល** ព្រោះបហានកិលេសទាំងអស់ ជាសមុច្ឆេទហើយ មិនត្រូវសិក្សាដើម្បីលះកិលេសតទៅទៀតឡើយ [១១] ។

និព្វានបរមត្ថ ពោលដោយសេចក្តីផ្សេងនៃអាការ មាន ៣ យ៉ាងគឺ

សុញ្ញត ១

អនិមិត្ត ១

អប្បណិហិត ១[២]

ព្រះនិព្វាន ឈ្មោះថាសុញ្ញត ព្រោះជាសភាពសូន្យចាកសង្ខារទាំងពួង ។ ឈ្មោះថាអនិមិត្ត ព្រោះមិននិមិត្ត គឺសង្ខារទាំងពួង ។ ឈ្មោះថាអប្បណិហិត ព្រោះមិនមានទីតាំង គឺសង្ខារទាំងពួង [៣] ។

កាលណាបុគ្គលមនសិការ សភាវធម៌ដោយសភាពមិនទៀង រមែងផុតស្រឡះទៅ (គឺដឹងច្បាស់នូវអរិយសច្ចធម៌) ដោយអនិមិត្តវិមោក្ខ ។ កាលណាមនសិការដោយសភាពជាទុក្ខ រមែងផុតស្រឡះទៅដោយអប្ប-

---

[១១] ខុទ្ទកនិកាយ ចូឡនិទ្ទេស

(២) អភិធម្មត្ថសង្គហបាលី ទំព័រ ៣៩

(៣) ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ វិមោក្ខកថា

ណិហិតវិមោក្ខ ។ កាលណាមានមនសិការដោយសភាពជាអនត្តា រមែង
ផុតស្រឡះទៅដោយសុញ្ញតវិមោក្ខ ។

វិមោក្ខ ៣ រមែងមានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ គឺ

១ ដោយភាពជាធំ កាលណាបុគ្គល មានមនសិការ ដោយសេចក្តី
ជាសភាពមិនទៀង អនិមិត្តវិមោក្ខរមែងជាធំ ។ ដោយសេចក្តីជាសភាព
ជាទុក្ខ អប្បណិហិតវិមោក្ខរមែងជាធំ ។ កាលណា មានមនសិការ ដោយ
សេចក្តីជាអនត្តា សុញ្ញតវិមោក្ខរមែងជាធំ ។

២ ដោយភាពតាំងមាំ បុគ្គលណាមានមនសិការ ដោយសេចក្តី
ជាសភាពមិនទៀង រមែងតាំងចិត្តទុកមាំដោយអំណាច នៃអនិមិត្តវិមោក្ខ ។
កាលណា មានមនសិការ ដោយសេចក្តីជាទុក្ខ រមែងតាំងចិត្តទុកមាំ
ដោយអំណាចនៃអប្បណិហិតវិមោក្ខ ។ កាលណា មានមនសិការ ដោយ
សេចក្តីជាអនត្តា រមែងតាំងចិត្តទុកមាំដោយអំណាច នៃសុញ្ញតវិមោក្ខ ។

៣ ដោយភាពបង្អោនចិត្តទៅ បុគ្គលកាលណាមាន មនសិការ
ដោយសេចក្តីជាសភាពមិនទៀង រមែងបង្អោនចិត្តទៅ ដោយអំណាចនៃ
អនិមិត្តវិមោក្ខ ។ កាលណា មានមនសិការ ដោយសភាពជាទុក្ខ រមែង
បង្អោនចិត្តទៅ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ។ កាលណាមាន
មនសិការ ដោយសេចក្តីជាអនត្តា រមែងបង្អោនទៅដោយអំណាច នៃ
សុញ្ញតវិមោក្ខ ។

៤ ដោយភាពនាំចេញទៅ បុគ្គលកាលណា មានមនសិការដោយសេចក្តីជាសភាពមិនទៀង រមែងនាំចិត្តចេញទៅដល់និព្វាន ដែលជាទីរំលត់ ដោយអំណាចនៃអនិមិត្តវិមោក្ខ ។ កាលណា មានមនសិការដោយសភាពជាទុក្ខ រមែងនាំចិត្តចេញទៅដល់និព្វាន ដែលជាទីរំលត់ដោយអំណាចនៃអប្បណិហិតវិមោក្ខ ។ កាលណា មានមនសិការដោយសភាពជាអនត្តា រមែងនាំចិត្តចេញទៅដល់និព្វាន ដែលជាទីរំលត់ដោយអំណាចនៃសុញ្ញតវិមោក្ខ [១២] ។

សង្ខេបបរមត្ថធម៌ ៤

ចិត្ត ចេតសិក រូប និព្វាន ជាបរមត្ថធម៌ ជាសភាវធម៌ដែលមានពិតដែលដឹងថា ចិត្ត ចេតសិក រូបជាសភាវធម៌ដែលមានពិត ព្រោះចិត្ត ចេតសិក រូប កើត រលត់បន្តគ្នា ទើបប្រាកដឱ្យដឹងបានដូចខណៈ ដែលឃើញរូប បានឮសំឡេង និងនឹកគិត ជាដើម ។ ចិត្តកើត រលត់ បន្តគ្នាធ្វើកិច្ចការងារផ្សេង ។ ដូចជា ចិត្តដួងខ្លះឃើញពណ៌ ដួងខ្លះឮសំឡេង ដួងខ្លះនឹកគិត ជាដើម ទាំងនេះតាមប្រភេទនៃចិត្ត និងហេតុបច្ច័យ ដែលធ្វើឱ្យកើតចិត្តនោះ ។ ។ ការកើត រលត់បន្តគ្នានៃចិត្ត ចេតសិក រូប នោះប្រព្រឹត្តទៅយ៉ាងរហ័សក្រៃពេក រហូតដល់ធ្វើមិនឱ្យឃើញការកើត រលត់

[១២] ខុទ្ទកនិកាយ បដិសម្ភិទាមគ្គវិមោក្ខកថា

ទាំងធ្វើឱ្យយល់ថា រូបប្រែប្រួលទៅសន្សឹម ៗ ព្រមទាំងធ្វើឱ្យយល់ថា ចិត្តនោះកើតឡើង កាលណាមនុស្សសត្វកើត ចិត្តនោះរលត់ទៅ កាលណាមនុស្ស ឬសត្វនោះស្លាប់ ។ បើមិនសិក្សា មិនពិចារណា និងមិនអប់រំចម្រើនសតិ និងបញ្ញាឱ្យដឹងលក្ខណៈនៃចិត្ត ចេតសិក រូប ដែលកំពុងប្រាកដនោះទេ ក៏នឹងមិនដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ គឺ ចិត្ត ចេតសិក រូប ដែលកើត រលត់បន្តគ្នាទៅគ្រប់ពេលវេលាដែរ ។

សភាវធម៌ណាកើតឡើង សភាវធម៌នោះត្រូវមានបច្ច័យតាក់តែង ឱ្យកើតឡើង បើមិនមានបច្ច័យទេក៏មិនកើតឡើយ ។ ព្រះសារីបុត្រ កើត សេចក្តីជ្រះថ្លា ក្នុងពាក្យពន្យល់របស់ព្រះដ៏មានព្រះភាគ ក៏ព្រោះបាន ឃើញព្រះអស្សជិ ដែលជាភិក្ខុមួយអង្គក្នុងភិក្ខុបញ្ចវគ្គីយ ។ ព្រះសារីបុត្រ ឃើញព្រះអស្សជិ មានសេចក្តីគួរជ្រះថ្លាខ្លាំងណាស់ ទើបតាមព្រះអស្សជិ ទៅ និងបានសួរព្រះអស្សជិថា តើអ្នកណាជាសាស្តារបស់លោកម្ចាស់ ហើយព្រះសាស្តាអង្គ នោះមានវាទដូចម្តេចខ្លះ ? ព្រះអស្សជិ តបថា

យេធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោនិរោធោ ឯវំវាទី មហាសមណោតិ[๑๓] ។

ធម៌ទាំងឡាយកើតពីហេតុ ព្រះតថាគតទ្រង់សម្តែងនូវហេតុនៃធម៌ ទាំងឡាយនោះ និងការរំលត់នៃធម៌ទាំងនោះ ព្រះមហាសមណៈ ជាព្រះ បរមគ្រូ ទ្រង់បង្រៀនយ៉ាងនេះឯង ។

---

๑๓ ព្រះវិន័យបិដក មហាវគ្គ ភាគ ๑ មហាខន្ធក

បើព្រះដ៏មានព្រះភាគទ្រង់មិនសម្តែងធម៌ ដែលព្រះអង្គទ្រង់ត្រាស់ដឹង ព្រមទាំងហេតុបច្ច័យនៃធម៌នោះ ។ ទេ ក៏នឹងមិនមានបុគ្គលណា ដឹងថាធម៌ណាកើតពីហេតុបច្ច័យយ៉ាងណាបានឡើយ មិនមានអ្នកណាអាចដឹងថា ចិត្តបរមត្ថ ចេតសិកបរមត្ថ រូបបរមត្ថ តែមួយប្រភេទនោះ កើតឡើងព្រោះមានធម៌ណាជាបច្ច័យឡើយ ។ ក្នុងពេលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងធម៌ទាំងពួងហើយ ព្រះអង្គទើបទ្រង់បានសម្តែងថា ធម៌ទាំងឡាយដែលកើតឡើងនោះ មានហេតុបច្ច័យតាក់តែងឱ្យកើត ទើបកើតឡើង ហើយទ្រង់សម្តែងពីហេតុបច្ច័យដែលធ្វើឱ្យកើតធម៌នោះ ។ ។ ធម៌ទាំងពួងដែលកើតឡើងនោះ នឹងកើតឡើងដោយមិនមានបច្ច័យ មិនបានឡើយ ។

ដែលពោលថា មនុស្សកើត សត្វកើត ទេវតាកើតជាដើមនោះ គឺចិត្ត ចេតសិក រូប កើតនោះឯង ។ ពេលចិត្ត ចេតសិក មួយប្រភេទកើតឡើង ព្រមទាំងរូប ក៏បញ្ញត្តិថាមនុស្សកើត ពេលណាចិត្ត ចេតសិកមួយប្រភេទទៀតព្រមទាំង រូបកើតឡើង ក៏បញ្ញត្តិថាសត្វកើត ពេលណាចិត្ត ចេតសិកកើតឡើង ព្រមទាំង រូបនៃទេវតា ក៏បញ្ញត្តិថា ទេវតាកើតជាដើម ។ ការកើតនៃមនុស្ស សត្វ ទេវតាជាដើមនោះផ្សេងគ្នា ព្រោះហេតុបច្ច័យដែលតាក់តែងធ្វើឱ្យកើតនោះផ្សេងគ្នា ។ ហេតុបច្ច័យដែលធ្វើឱ្យកើតនោះមានច្រើនពេកណាស់ ហើយច្របូកច្របល់ណាស់ ។ តែដោយព្រះសព្វញ្ញុតញ្ញាណ នៃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងធម៌

ទាំងពួង ព្រមទាំងហេតុបច្ច័យនៃធម៌ទាំងពួងនោះ ព្រះអង្គទើបបាន សម្តែងធម៌ តាមសភាពពិតនៃធម៌តែមួយប្រភេទថា ធម៌ណាកើតឡើង ធម៌នោះ មានបច្ច័យធ្វើឱ្យកើតឡើង ធម៌ដែលកើតឡើងជាសង្ខារធម៌ ដែលដឹងបានថា មានចិត្ត ចេតសិក រូប ក៏ព្រោះចិត្ត ចេតសិក រូប កើតឡើង ហើយដែលកើតឡើងនោះ ព្រោះមានបច្ច័យ **ចិត្ត ចេតសិក** និង**រូប ជាសង្ខារធម៌** ។

ព្រះធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគនោះ សម្បូរ ទៅដោយអត្ថ និងព្យញ្ជនៈ ។ ធម៌ ខ ណាដែលនឹងអាចមានអ្នកយល់ ខុសបាន ព្រះអង្គក៏ទ្រង់បញ្ញត្តិពាក្យបញ្ចូលជាមួយ ឱ្យជាក់ច្បាស់ក្រៃលែង ឡើង ។ ដើម្បីមិនឱ្យអ្នកដែលយល់លក្ខណៈនៃបទធម៌នោះខុស ។ កាល ណាព្រះអង្គទ្រង់បញ្ញត្តិថា ធម៌ដែលកើតឡើង មានបច្ច័យធ្វើឱ្យកើតឡើង **ជាសង្ខារធម៌** គឺដើម្បីមិនឱ្យអ្នកណាមួយយល់ខុសក្នុងធម៌ ដែលកើត ឡើងនោះថា កាលណាកើតឡើងហើយក៏តាំងនៅ រហូតរឿយ ។ ទៅ ទើបព្រះអង្គទ្រង់បញ្ញត្តិថា ធម៌ដែលជា **សង្ខារធម៌** នោះជា **សង្ខតធម៌** ។ **សង្ខតធម៌** គឺធម៌ដែលកើតឡើង ហើយរលត់ទៅ[១៤] ។ ព្រះអង្គទ្រង់ បញ្ញត្តិពាក្យថាសង្ខតធម៌ និងពាក្យថាសង្ខារធម៌ ដើម្បីឱ្យដឹងថា ធម៌ណា ដែលកើតឡើង ធម៌នោះមានបច្ច័យ ធ្វើឱ្យកើតឡើង កាលណា

[១៤] អង្គុត្តរនិកាយ តិកនិបាត ចូឡវគ្គទី ៥ សង្ខតសូត្រ

បច្ច័យរលត់ ធម៌ដែលកើតឡើងព្រោះបច្ច័យនោះ ក៏ត្រូវរលត់ទៅដែរ ។ សង្ខតធម៌ គឺធម៌ដែលកើតឡើងហើយរលត់ទៅ ។ ព្រោះហេតុដូច្នេះ សង្ខារធម៌ គឺធម៌ដែលមានបច្ច័យតាក់តែងនោះ ទើបជា សង្ខតធម៌[១៥]។ ចិត្តបរមត្ថ ចេតសិកបរមត្ថ រូបបរមត្ថ ជាសង្ខារធម៌ ជាសង្ខតធម៌ ។

សព្វេ សង្ខារ អនិច្ចា សង្ខារទាំងពួងមិនទៀង

សព្វេ សង្ខារ ទុក្ខា សង្ខារទាំងពួងជាទុក្ខ

សព្វេ ធម្មា អនត្តា ធម៌ទាំងពួងជាអនត្តា[៣]

សង្ខារទាំងពួងមិនទៀង

សង្ខារធម៌ទាំងអស់មិនទៀង ។ សេចក្តីទ្រុឌទ្រោម សេចក្តីមិនទៀង នៃរូបធម៌នោះ ល្មមនឹងឱ្យឃើញប្រាកដបាន ប៉ុន្តែការមិនទៀងនៃនាមធម៌នោះ គឺដឹងបានដោយលំបាក ។ ដូចដែលព្រះដ៏មានព្រះភាគ ត្រាស់ នឹងភិក្ខុទាំងឡាយក្នុងព្រះវិហារជេតពនអារាមរបស់អនាថបិណ្ឌិក សេដ្ឋីថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន ដែលមិនបានស្តាប់ ក៏នឹងគប្បីនឿយណាយខ្លះ បោះបង់ការកំណត់ខ្លះ កន្លងផុតខ្លះ នៅក្នុងរាងកាយដែលជាទីប្រជុំ នៃមហាភូតទាំង ៤ នេះ ខ នោះព្រោះហេតុអ្វី ព្រោះថាសេចក្តីចម្រើនក្តី សេចក្តីទ្រុឌទ្រោមក្តី ការកើតក្តី ការស្លាប់ក្តីនៃរាងកាយ ដែលជា

---

[១៥] ធម្មសង្គណីបករណ និក្ខេបកណ្ឌ ចូឡន្តរទុក្កៈ

[៣] ខុទ្ទកនិកាយ មហានិទ្ទេស សុទ្ធដ្ឋកសុត្តនិទ្ទេស

ទីប្រជុំនៃមហាភូតរូបទាំង ៤ នេះរមែងប្រាកដ ..... តែបុថុជ្ជនជាអ្នកពុំបានស្តាប់ មិនអាចនឹងនឿយណាយ បោះបង់ការកំណត់ កន្លងផុតក្នុងចិត្ត ជាដើមនោះបានឡើយ ប្រការនេះព្រោះហេតុអ្វី ព្រោះហេតុថាចិត្ត ជាដើមនេះ ដែលបុថុជ្ជនពុំបានស្តាប់ រួបរិតក្តាប់ទុកដោយតណ្ហា ប្រកាន់មាំដោយទិដ្ឋិថា នុ៎ះជាយើង នុ៎ះជាខ្លួនរបស់យើង នុ៎ះជារបស់យើង ដូច្នេះគ្រប់ ៗ កាលជាយូរអង្វែងមកហើយ ។ ល ។ ចិត្តជាដើមនោះ ដួងមួយកើតឡើង ដួងមួយរលត់ទៅរាល់យប់ រាល់ថ្ងៃ[១៦] ។

សូម្បីថាចិត្ត ចេតសិក រូប នឹងនៅកើតរលត់រាល់ ៗ ពេល ក៏ពិបាកនឹងដឹងហើយនឿយណាយ លះសេចក្តីត្រេកអរ លះសេចក្តីប្រកាន់មាំក្នុងនាមរូបបាន ។ ការដែលនឹងនឿយណាយ លះសេចក្តីត្រេកអរ លះសេចក្តីប្រកាន់ក្នុងនាមរូបនោះ គឺត្រូវពិចារណាឃើញដោយបញ្ញា ដូចដែលទ្រង់បានសម្តែងថា

សព្វេ សង្ខារ អនិច្ចាតិ យថាបញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារ ទុក្ខាតិ យថា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ យថា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។(១)

---

[១៦] សំយុត្តនិកាយ អស្សុត្វតាសូត្រ ទី ២ ។ (១) ខុទ្ទកនិកាយ គាថាធម្មបទ

កាលណា បុគ្គលពិចារណាឃើញដោយបញ្ញា ថាសង្ខារទាំងពួងមិនទៀង
កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។
កាលណា បុគ្គលពិចារណាឃើញដោយបញ្ញាថា សង្ខារទាំងពួងជាទុក្ខ
កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ[១៧]។
កាលណា បុគ្គលពិចារណាឃើញដោយបញ្ញាថា ធម៌ទាំងពួងជាអនត្តា
កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

អ្នកណាដែលមិនឃើញសេចក្តីកើតឡើង និងរលត់ទៅនៃនាមធម៌ និងរូបធម៌ រហូតដល់លះបង់ អ្នកនោះនឹងបន្លុះអរិយសច្ច ៤ ជាអរិយបុគ្គលមិនបាន ។ ព្រះអរិយបុគ្គលឃើញសេចក្តីជា **ពុទ្ធ** នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដោយឃើញធម៌ដែលព្រះអង្គទ្រង់ត្រាស់ដឹង មិនមែន គ្រាន់តែសិក្សាព្រះធម៌ដែលព្រះអង្គទ្រង់ទេសនាប៉ុណ្ណោះទេ ។ ព្រះអរិយបុគ្គលអស់សេចក្តីសង្ស័យក្នុងព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងព្រោះ ព្រះអរិយបុគ្គលបានសម្រេចធម៌នោះ[១៨] និងបានប្រចក្សក្នុងសេចក្តីជា **ពុទ្ធ** ថាព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងនោះ មិនមែនដោយការទស្សន៍ទាយ ដៅ កំណត់នោះទេ គឺដោយត្រាស់ដឹងធម៌ទាំងពួងតាម

---

[១៧] ខុទ្ទកនិកាយ គាថាធម្មបទ

[១៨] សំយុត្តនិកាយ សេខសូត្រ

សេចក្តីពិតមែននៃធម៌នោះ ៗ ។ អ្នកណាឃើញធម៌ អ្នកនោះរមែងឃើញ តថាគត[២] ។ អ្នកណាសិក្សា និងបដិបត្តិដើម្បីឱ្យដឹងច្បាស់ធម៌ អ្នកនោះ រមែងអាចដឹងច្បាស់ធម៌ និងរំលត់កិលេស ជាព្រះអរិយបុគ្គលតាមលំដាប់ គឺតាំងតែពីព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី រហូតដល់ ព្រះអរហន្ត[៣] ។

---

(២) សំយុត្តនិកាយ វក្កលិសូត្រ

(៣) ខុទ្ទកនិកាយ ឧទាន ឧបោសថសូត្រ

សង្ខារទាំងពួងជាទុក្ខ

សង្ខារធម៌ទាំងឡាយកើតឡើង ហើយក៏រលត់ទៅវិញ មិនថាជាចិត្ត ប្រភេទល្អ ឬចិត្តប្រភេទមិនល្អអ្វីឡើយ ឬរូបស្អាត ឬមិនស្អាត អ្វីឡើយ ពេលកើតឡើងហើយក៏រលត់ទៅវិញដូចគ្នាទាំងអស់ ។ ការកើត រលត់ មិនទៀងនេះហើយ ជាទុក្ខ ព្រោះទ្រាំនៅមិនបាន ។ សង្ខារធម៌ទាំងឡាយ ជាទុក្ខនោះ មិនមែនចំពោះតែទុក្ខផ្លូវកាយដែលឈឺចុកចាប់នោះទេ ឬក៏ ទុក្ខដែលលំបាកក្តៅក្រហាយ ទុក្ខដែលព្រាត់ប្រាស់ពីវត្ថុដែលស្រឡាញ់ ឬទុក្ខដែលប្រសព្វនឹងវត្ថុដែលជាទីមិនស្រឡាញ់នោះប៉ុណ្ណោះទេ សង្ខារ ធម៌ទាំងឡាយជាទុក្ខនោះ ព្រោះសង្ខារធម៌ទាំងឡាយមិនទៀង កាលកើត ឡើងហើយក៏រលត់ទៅវិញ ទើបមិនគួរប្រកាន់ថាជាសុខ ។ លោកខ្លះ

អាចនឹងសង្ស័យថា ចិត្ត ដែលភ្លើតភ្លើន ត្រេកអរ ជាសុខក៏មាន តើហេតុអ្វីទើបថាសង្ខារធម៌ទាំងឡាយជាទុក្ខ ? ត្រង់ដែលថាជាទុក្ខនោះ ព្រោះចិត្ត ដែលភ្លើតភ្លើន ត្រេកអរ ជាសុខនោះក៏មិនទៀងដែរ ដូច្នេះ សង្ខារធម៌គឺចិត្ត ចេតសិក រូប ទាំងអស់ជាទុក្ខ ព្រោះចិត្ត ចេតសិក រូប ទាំងអស់ មិនទៀង ។

ធម៌ទាំងពួងជាអនត្តា

ធម៌ទាំងពួង បានដល់បរមត្ថធម៌ទាំង ៤ គឺ ចិត្ត ចេតសិក រូប និព្វាន ។ ធម៌ទាំងពួងជាអនត្តា គឺមិនមែនតួខ្លួន មិននៅក្នុងអំណាចបង្គាប់បញ្ជារបស់បុគ្គលណាឡើយ ។

និព្វាន ជាបរមត្ថធម៌ ជាធម៌ដែលមានពិត ។ និព្វាន មិនមែនជាសង្ខារធម៌ ជាវិសង្ខារធម៌ គឺជាធម៌ដែលមិនកើត[១៩] ហើយទំនាស់ប្រឆាំងនឹងសង្ខារធម៌ ។ សង្ខារធម៌ គឺជាធម៌ដែលកើតឡើងមានបច្ច័យតាក់តែង ។ និព្វានជាអសង្ខតធម៌ មិនមែនជាសង្ខតធម៌[២] ។ សង្ខតធម៌ គឺធម៌ដែលកើត រលត់ អសង្ខតធម៌ គឺជាធម៌ដែលមិនកើតរលត់ ។ និព្វានមិនមានបច្ច័យទើបមិនកើតរលត់ ។ ចិត្ត ចេតសិក រូប ជាសង្ខារធម៌ ជាលោកិយ ។

---

[១៩] ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ញាណកថា

[២] ធម្មសង្គណីបករណ និក្ខេបកំណ្ឌ

ពាក្យថាលោកិយ សំដៅដល់ការបែកធ្លាយរលត់វិនាស ។ ចំណែកនិព្វាន ជាលោកុត្តរ ពាក្យថា លោកុត្តរ សំដៅដល់ការឆ្លងផុតចេញពីលោក ។



[២០] ធម្មសង្គណីបករណ និក្ខេបកំណ្ឌ

ខន្ធ ៥

ខន្ធ ៥ គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ [២១]

បរមត្ថ ៤ ដោយខន្ធ គឺ

ចិត្ត ជាវិញ្ញាណក្ខន្ធ

ចេតសិក ជាវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ

រូប ជារូបក្ខន្ធ

និព្វាន មិនមែនជាខន្ធ ។ និព្វានជាខន្ធវិមុត្តិ គឺផុតចាកខន្ធ ។

ពាក្យថា **ខន្ធ** សំដៅដល់សភាវធម៌ ដែលចំណែកជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុង ខាងក្រៅ គ្រោតគ្រាត ល្អិត ថោកទាប ប្រណីត ឆ្ងាយ ជិត [២២] ។ ដូច្នោះ ខន្ធ ទើបបានដល់សង្ខារធម៌ គឺជាធម៌ដែលមានបច្ច័យតាក់តែងកើត រលត់ទើបជា អតីត អនាគត បច្ចុប្បន្ន ជាដើម ។ ចំណែកវិសង្ខារធម៌ជានិព្វាននោះ ជាធម៌ដែលមិនកើត មិនមានបច្ច័យតាក់តែង នឹងពោលថាជាធម៌បានកើតឡើងហើយមិនបាន ជាធម៌មិនទាន់កើតឡើងក៏មិនបាន ជាធម៌កំពុងតែកើតឡើងក៏មិនបាន នឹងពោលថាជា អតីត អនាគត បច្ចុប្បន្ន ក៏មិនបាន ហេតុដូច្នេះហើយ វិសង្ខារធម៌ គឺនិព្វាន ទើបមិនមែនខន្ធ ជាខន្ធវិមុត្តិ គឺផុតចាកខន្ធ ។

---

[២១] វិភង្គបករណ ខន្ធវិភង្គ

[២២] វិភង្គបករណ ខន្ធវិភង្គ

ព្រះដ៏មានព្រះភាគទ្រង់សម្តែងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ យ៉ាងនេះ គឺម្នាលភិក្ខុទាំងឡាយ យើងនឹងសម្តែងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ អ្នកទាំងឡាយចូរស្តាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះខន្ធ ៥ ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ រូបយ៉ាងណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាប ឬប្រណីត នៅក្នុងទីជិត ឬឆ្ងាយ នេះហៅថារូបក្ខន្ធ ។ វេទនាយ៉ាងណាមួយ ។ ល ។ សញ្ញាយ៉ាងណាមួយ ។ ល ។ សង្ខារទាំងឡាយណាមួយ ។ ល ។ វិញ្ញាណយ៉ាងណាមួយជាអតីត អនាគត និងបច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាប ឬប្រណីត នៅក្នុងទីជិត ឬឆ្ងាយនេះ ហៅថា វិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាខន្ធ ៥ ។

ម្នាលភិក្ខុទាំងឡាយ ចុះឧបាទានក្ខន្ធ ៥ ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ រូបយ៉ាងណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាប ឬប្រណីត នៅក្នុងទីជិត ឬឆ្ងាយ **ប្រព្រឹត្តប្រកបនឹងអាសវៈ ជាបច្ច័យដល់ឧបាទាន នេះហៅថា ឧបាទានក្ខន្ធ** គឺរូបណាមួយ ។ ល ។ វេទនាណាមួយ ។ ល ។ សញ្ញាណាមួយ ។ ល ។ សង្ខារទាំងឡាយណាមួយ ។ ល ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាបឬប្រណីត នៅក្នុងទីជិត ឬឆ្ងាយ ដែលប្រព្រឹត្តប្រកបដោយនឹងអាសវៈ ជាបច្ច័យដល់

ឧបាទាន នេះហៅថា ឧបាទានខន្ធ គឺវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ ទាំងនេះហៅថា ឧបាទានខន្ធ ៥[២៣] ។

[២៣] សំយុត្តនិកាយ ខន្ធវារវគ្គ បញ្ចខន្ធសូត្រ

បរមត្ថធម៌ ៣ ជាខន្ធ ៥

ចិត្តបរមត្ថ	៨៩-១២១ ដួង គ្រប់ដួងជាវិញ្ញាណក្ខន្ធ ។
ចេតសិកបរមត្ថ	៥២ ប្រភេទ វេទនាចេតសិក ១ ជាវេទនាខន្ធ
	សញ្ញាចេតសិក ១ ជាសញ្ញាខន្ធ
	ចេតសិក ៥០ ជាសង្ខារក្ខន្ធ ។
រូបបរមត្ថ	២៨ ប្រភេទ គ្រប់រូប ជារូបក្ខន្ធ ។

ខន្ធ ៥ ជាបរមត្ថធម៌ ៣

រូបក្ខន្ធ	បានដល់ រូបបរមត្ថ ២៨	
វេទនាខន្ធ	បានដល់ វេទនាចេតសិក ១ ដួង	ចេតសិក បរមត្ថ ៥២
សញ្ញាខន្ធ	បានដល់ សញ្ញាចេតសិក ១ ដួង	
សង្ខារក្ខន្ធ	បានដល់ ចេតសិក ៥០ ដួង	
វិញ្ញាណក្ខន្ធ	បានដល់ ចិត្តបរមត្ថ ៨៩ ឬ ១២១ ដួង	

សំណួរសាឡើងវិញ

១- បរមត្ថធម៌អ្វីខ្លះ ជាសង្ខារធម៌ ?

២- សង្ខារធម៌ ជាសង្ខារក្ខន្ធ ឬទេ ?

៣- វិសង្ខារធម៌ ជាសង្ខតធម៌ឬទេ ?

៤- អសង្ខតធម៌ ជាខន្ធអ្វី ?

៥- អសង្ខតធម៌ ជាលោកិយ ឬលោកុត្តរៈ ?

៦- ចិត្តជាសង្ខារក្ខន្ធ ឬទេ ?

៧- ចេតសិក ជាសង្ខារក្ខន្ធ ឬទេ ?

៨- វេទនាខន្ធ ជាបរមត្ថធម៌អ្វី ?

៩- ខន្ធអ្វី មិនមែនបរមត្ថធម៌ ?

១0- បរមត្ថធម៌អ្វី មិនមែនខន្ធ ?

ចិត្តសង្ខេប

មេរៀនទី ១

សំយុត្តនិកាយ សគាថវគ្គ អន្ធវគ្គ ចិត្តសូត្រ

-ទេវតាទូលសួរថា

លោកនៃអ្វីរមែងនាំទៅ គឺអ្វីហ្ន៎ រមែងស្ទុះទៅ លោកទាំងអស់ ប្រព្រឹត្តទៅតាមអំណាចនៃធម៌តែមួយ គឺអ្វី ?

-ព្រះដ៏មានព្រះភាគត្រាស់តបថា

លោកនៃចិត្តរមែងនាំទៅ គឺចិត្តរមែងស្ទុះទៅ លោកទាំងអស់ ប្រព្រឹត្តទៅតាមអំណាចនៃធម៌តែមួយ គឺចិត្ត ។

សម្តែងឱ្យឃើញពីសេចក្តីសំខាន់របស់ចិត្ត ដែលជាធាតុដឹង ស-ភាពដឹង ដែលជាធំ ជាប្រធាន ក្នុងការដឹងនូវអ្វីដែលកំពុងប្រាកដ ដែលមិនត្រឹមតែឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ប៉ុណ្ណោះទេ គឺនៅមាននឹកគិតវិចិត្រផ្សេង ៗ នានា ។ ដូច្នោះ លោកនៃមនុស្សម្នាក់ ទើបប្រព្រឹត្តទៅតាមអំណាចចិត្តនៃមនុស្សតែម្នាក់ប៉ុណ្ណោះ ។ ចិត្តនៃមនុស្សក៏សន្សំទុកកុសលច្រើនទៅ ទោះជានឹងឃើញបុគ្គលណា ដែលជាអ្នកច្រើនទៅដោយអកុសលធម៌ក៏ដោយ ចិត្តនៃបុគ្គលដែលសន្សំកុសលច្រើននោះ ក៏នៅតែកើតមេត្តា ឬករុណា ឬឧបេក្ខាបាន ក្នុងខណៈដែលលោកនៃអ្នកដទៃ ជាលោកនៃសេចក្តីស្អប់ខ្ពើម សេចក្តីមិនអបអរសាទរ សេចក្តីក្រោធ សេចក្តីក្តៅក្រហាយចិត្ត ។ ដូច្នោះ មនុស្សម្នាក់ ៗ

ទើបជាលោករបស់ខ្លួនឯង តែលោកមួយ ។ គ្រប់ខណៈប៉ុណ្ណោះ តាមសេចក្តីពិត ។

មើលទៅហាក់ដូចជា យើងទាំងឡាយរស់នៅរួមលោកតែមួយដូចគ្នា ប៉ុន្តែតាមសេចក្តីពិតនោះអ្វីផ្សេង ។ ដែលជា**រូបធម៌ ដែលអាចជ្រាកដបានតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះ បើមិនមានចិត្តដែលជាសភាពដឹងទេ សភាវៈផ្សេង ។ ទាំងនោះ ក៏រមែងមិនជ្រាកដដល់នូវសេចក្តីសម្គាល់ថាជាយ៉ាងណាឡើយ ។** ប៉ុន្តែ ដោយចិត្តដឹងនូវអ្វីដែលជ្រាកដតាមផ្លូវភ្នែកខ្លះ ផ្លូវត្រចៀកខ្លះ ផ្លូវច្រមុះខ្លះ ផ្លូវអណ្តាតខ្លះ ផ្លូវកាយខ្លះ ផ្លូវចិត្តខ្លះ លោកនៃមនុស្សម្នាក់ ទើបប្រព្រឹត្តទៅ តាមអំណាចនៃចិត្តតែមនុស្សម្នាក់ប៉ុណ្ណោះ ។ លោកឯណាដែលល្អ គឺលោកដែលសន្សំកុសលច្រើន ។ ដែលកើតព្រមដោយមេត្តា ករុណា មុទិតា ឧបេក្ខា ។ លោកឯណាដែលមិនល្អ មិនស្អាតបរិសុទ្ធ គឺលោកដែលសៅហ្មង ស្អប់ខ្ពើម ខឹងក្រោធ ក្តៅក្រហាយ គំនុំគុំគួន ។ ទោះជានឹងឃើញបុគ្គលតែមួយដូចគ្នាក្តី ដឹងរឿងបុគ្គលតែមួយដូចគ្នាក្តី តែលោកនៃមនុស្សម្នាក់ ។ នឹងជាមេត្តា ឬជាស្អប់ខ្ពើមនោះ ក៏រមែងប្រព្រឹត្តទៅតាមអំណាចចិត្តនៃមនុស្សម្នាក់ ។ ដែលសន្សំមកផ្សេងៗ គ្នា ។

អ្វីដែលជ្រាកដតាមផ្លូវភ្នែក ធ្វើហាក់បីដូចជា មានមនុស្សយើងរស់នៅរួមគ្នា កុះករ ក្នុងលោកតែមួយ គឺលោកមនុស្ស ។ **ប៉ុន្តែ បើប្រត្យក្ស**

ច្បាស់ក្នុងលក្ខណៈ នៃធាតុដឹងដោយឡែកអំពីធាតុមិនដឹង សភាពដឹង ដែលកើតឡើងឃើញសភាពប្រាកដតាមផ្លូវភ្នែក ក្នុងខណៈនោះ បញ្ញានឹង បានដឹងថា ជាលោកនៃការឃើញ គឺខណៈនោះ ត្រឹមតែជាការឃើញ ដែលមិនមែនមនុស្ស មិនមែនសត្វ មិនមែនវត្ថុ របស់ផ្សេង ។ ឡើយ ព្រោះខណៈនោះ ត្រឹមតែឃើញ នៅមិនទាន់បាននឹកដល់រូបរាង សណ្ឋាន និងរឿងរ៉ាវណា ។ នៃសភាវៈដែលឃើញនោះនៅឡើយទេ ។

ដូច្នោះ ទើបគួរយល់ឱ្យបានត្រឹមត្រូវថា **ខណៈដែលនឹកគិតថា ជាលោក ជាសត្វ បុគ្គល វត្ថុ សម្ភារៈផ្សេង ។ នោះ ជាមួយខណៈ ដែលចិត្តនឹកគិតរឿងសភាវៈដែលប្រាកដឱ្យឃើញ តែខណៈដែលកំពុងឃើញ នោះ ជាខណៈមួយផ្សេង មិនមែនខណៈដែលកំពុងនឹកគិតរឿងនូវអ្វី ដែលកំពុងប្រាកដឡើយ** ។ មនុស្សម្នាក់ ។ គឺមានចិត្តកើតឡើង ត្រឹមតែ មួយខណៈ ។ បន្តគ្នាទៅរហូតដល់ប្រាកដ ដូចជាថា លោកមួយដ៏ធំធេង មានមនុស្ស និងវត្ថុផ្សេង។ សន្ធឹកសន្ធាប់ ។ តែដែលនឹងអាចយល់ត្រឹមត្រូវ នូវលោកបានពិតប្រាកដនោះ ត្រូវបញ្ញាដឹងថាសភាវធម៌ ប្រាកដត្រឹមតែ ខណៈចិត្តមួយ ។ ប៉ុណ្ណោះកើតឡើង ។ ប៉ុន្តែអាស្រ័យការកើត រលត់បន្តគ្នា យ៉ាងរហ័សក្រៃពេក ទើបធ្វើឱ្យប្រាកដ ជាលោកដែលហាក់ដូចជាមិន បែកធ្លាយ ជាលោកដែលប្រាកដ ហាក់ដូចជាបិតថេរ មានសត្វ បុគ្គល វត្ថុ របស់របរច្រើនសន្ធឹកសន្ធាប់សព្វគ្រប់ តែតាមសេចក្តីពិតនោះ លោក

ខណៈមួយ ។ ក៏គឺការកើតឡើងនៃចិត្ត ដែលកើតឡើងដឹងអារម្មណ៍ត្រឹមតែ ១ ជួរខណៈ ហើយក៏រលត់ទៅវិញប៉ុណ្ណោះ ។

ក្នុងខុទ្ទកនិកាយមហានិទ្ទេស បសូរសុត្តនិទ្ទេស មានសេចក្តីថា ឈ្មោះថា « ចិត្ត (មនោ) » ក្នុងពាក្យថាគិត ទិដ្ឋិទាំងឡាយ ដោយចិត្ត ។ សេចក្តីថាចិត្ត គឺ ចិត្ត មនោ មនសៈ ហទយ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីផស្សៈ ជាដើមនោះ ។

ព្រះដ៏មានព្រះភាគទ្រង់ប្រើព្យញ្ជនៈច្រើនពាក្យ ក៏ដើម្បីឱ្យយល់ចូលចិត្តលក្ខណៈនៃចិត្តដែលគ្រប់មនុស្សមានប៉ុណ្ណោះ ប៉ុន្តែព្រោះអាស្រ័យ ចិត្តជាអ្នកដឹង ជាអាការដឹង ទើបពិបាកនឹងដឹងបានថាលក្ខណៈដែលត្រឹមតែជាធាតុដឹងនោះ គឺជាយ៉ាងណា ? ទូទៅដែលមនុស្សគង់នឹងយល់សេចក្តីសម្គាល់ប្រការខ្លះរបស់ចិត្តដែលថា « ចិត្ត » ដែលគ្រប់គ្នាមានគឺត្រឹមតែដឹងថាមានប៉ុណ្ណោះ កាលណាមិនបានពិចារណា ក៏រមែងមិនជ្រាបថា ពេលណា ឬខណៈណាដែលជាចិត្ត ។

ក្នុងអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ ចិត្តុប្បាទកណ្ឌ អធិប្បាយចិត្តនិទ្ទេស មានសេចក្តីថា ធម្មជាតិដែលឈ្មោះថាចិត្ត ព្រោះចិត្តជាធម្មជាតិវិចិត្រ ។

ធាតុដឹងមានច្រើន មិនមែនមានតែម៉្យាងឡើយ ចិត្តជាធម្មជាតិដែលវិចិត្រ ។ ការវិចិត្រនៃចិត្តប្រាកដ កាលណានឹកគិតរឿងផ្សេង ។

ដែលមិនចាំបាច់អ្នកណានឹងធ្វើអ្វីក្នុងមួយថ្ងៃ ។ នោះឡើយ ។ កាលណាពិចារណាហើយ ក៏រមែងដឹងថាជាការប្រព្រឹត្តទៅតាមការវិចិត្រ របស់ចិត្តទាំងអស់ ។

ថ្ងៃនេះធ្វើអ្វីខ្លះមកហើយ និងបន្តដល់ល្ងាចនេះ ស្អែកនេះ នឹងធ្វើអ្វីទៀត តែបើមិនមានចិត្តទេ ក៏ធ្វើមិនបាន ។ ហេតុដែលមនុស្សគ្រប់គ្នាមានការធ្វើមួយថ្ងៃ ។ ផ្សេង ។ គ្នាតាមវិថីជីវិតនៃមនុស្សម្នាក់ ។ នោះនឹងបានឃើញថា ការធ្វើទាំងអស់រមែងប្រព្រឹត្តទៅតាមការវិចិត្រ នៃចិត្តរបស់មនុស្សម្នាក់ ។ ដែលជាហេតុឱ្យកើតការធ្វើទាំងផ្លូវកាយ ទាំងផ្លូវវាចាផ្សេង ។ គ្នាក្នុងជីវិតប្រចាំថ្ងៃ ។ ចិត្តជាធម្មជាតិដែលគិត សឹងគិតច្រើនហួសប្រមាណ តែបើមិនពិចារណាទេ ក៏មិនដឹងថាគិតត្រូវ ឬគិតខុសមនុស្សម្នាក់ ។ គឺគិតផ្សេង ។ គ្នា ក្នុងបណ្តាអ្នកយកចិត្តទុកដាក់សិក្សាធម៌ ក៏ពិចារណាធម៌ផ្សេង ។ គ្នាដែរ សេចក្តីគិតឃើញក្នុងថ្នាក់នៃការប្រព្រឹត្តបដិបត្តិធម៌ក៏ផ្សេងគ្នា និងសូម្បីតែក្នុងរឿងនៃលោក សេចក្តីប្រព្រឹត្តនៃក្រុមបុគ្គលមួយក្រុម ។ មួយប្រភេទ ។ បើកាលប្រជុំគ្នាហើយ ក៏កើតហេតុការណ៍ផ្សេង ។ នៃលោក ខណៈនីមួយៗ នោះក៏រមែងកើតឡើងប្រព្រឹត្តទៅតាមការវិចិត្រនៃសេចក្តីគិតរបស់បុគ្គលម្នាក់ ។ ។ លោកក្នុងយុគនេះជាយ៉ាងនេះ តាមសេចក្តីគិតរបស់បុគ្គលម្នាក់ ។ ក្នុងយុគសម័យនេះ ហើយតទៅ លោកនឹងជាយ៉ាងណា ស្អែកនេះនឹងជាយ៉ាងណានោះ ក៏រមែងកើតឡើងប្រព្រឹត្តទៅតាមចិត្តដែលគិតវិចិត្រផ្សេង ។ នោះឯង ។

ដោយហេតុនេះ ទើបបានឃើញថា **ចិត្តជាធម្មជាតិដែលវិចិត្រ** ។ ចិត្តដែលឃើញតាមផ្លូវភ្នែក ជាចិត្តប្រភេទមួយ ផ្សេងអំពីចិត្តដែលឮ តាមត្រចៀកដែលជាចិត្តប្រភេទមួយទៀត និងផ្សេងអំពីចិត្តដែលនឹកគិត ជាដើម ។

ត្រង់ (**ចិត្ត**) **ឈ្មោះថា មនោ** ព្រោះដឹងអារម្មណ៍ ។

ពាក្យថា អារម្មណៈ (អារម្មណ៍) សំដៅដល់អ្វីដែលចិត្តដឹង ។ កាលណាចិត្តដែលជាសភាវៈដឹង ឬលក្ខណៈដឹងកើតឡើង អ្វីដែលចិត្តកំពុងដឹងខណៈនោះ ឈ្មោះថា « អារម្មណ៍ » ។

សំឡេងមានពិតឬទេ ? កាលសភាវៈដែលរឹងប៉ះខ្ទប់គ្នា ក៏ជាបច្ច័យឱ្យសំឡេងកើតឡើង ។ តែបើក្នុងខណៈនោះ ចិត្តមិនកើតឡើងដឹងសំឡេងនោះទេ សំឡេងនោះក៏មិនជាអារម្មណ៍ ដូច្នេះ មិនថាអ្វី ៗ កើតឡើង ព្រោះហេតុបច្ច័យ តែបើខណៈណាដែលចិត្តមិនដឹង នូវអ្វីនោះទេ អ្វីនោះក៏មិនមែនជាអារម្មណ៍ ។

ត្រង់ (**ចិត្ត**) **ឈ្មោះថា ហទយ** ព្រោះសម្គាល់ថា ជាសភាវៈនៅខាងក្នុង ។

ចិត្ត ជាចំណែកខាងក្នុង ព្រោះជាសភាពដឹងអារម្មណ៍ដែលប្រាកដ ។ អារម្មណ៍ដែលជាចំណែកខាងក្រៅ ព្រោះជាអ្វីដែលចិត្តកំពុងដឹង ។

ដូច្នោះ ការសិក្សារឿងចិត្ត ទើបជាការពិចារណាសភាវធម៌ដែលកំពុងប្រាកដក្នុងខណៈនេះ ទាំងខាងក្នុង និងខាងក្រៅ ទើបនឹងដឹងលក្ខណៈរបស់ចិត្តបាន ។ ចិត្តមានពិត តែចិត្តនៅទីណា ? ចិត្ត ជាសភាវធម៌ដែលជាខាងក្នុង ។ ក្នុងខណៈឃើញ ចិត្តមិនបាននៅខាងក្រៅទេ ពណ៌វណ្ណៈកំពុងប្រាកដ គឺជាខាងក្រៅ ។ ចិត្តជាសភាវធម៌ ដែលនៅខាងក្នុង គឺជាសភាវធម៌ ដែលកំពុងដឹងនូវអ្វីដែលកំពុងប្រាកដតាមផ្លូវភ្នែក ។

ការអប់រំចម្រើនបញ្ញានោះ គឺត្រូវដឹងលក្ខណៈនៃសភាវធម៌ ត្រង់តាមសេចក្តីពិត ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង និងទ្រង់សម្តែង ។ ដូច្នេះ ចិត្តានុបស្សនាសតិប្បដ្ឋាន គឺខណៈណាដែលឃើញហើយរលឹកបានមិនវង្វេងភ្លេច និងពិចារណាសិក្សា សង្កេតសន្សឹមៗ បង្អោនទៅដឹង **សភាវៈឃើញ គឺជាសភាពដឹង ជាធាតុដឹងនូវអ្វីដែលកំពុងប្រាកដផ្លូវភ្នែក** ។

ក្នុងខណៈដែលកំពុងបានឮសំឡេង សតិអាចកើតឡើងរលឹកដឹងថា សភាវៈដែលកំពុងឮសំឡេង ជាសភាពដឹង ជាអាការដឹង ជាសភាវធម៌ដែលនៅខាងក្នុង ទើបពិបាកនឹងពិចារណាឱ្យដឹងបាន និងសភាវៈដែលបានឮសំឡេងនោះ ក៏កើតឡើងដឹងសំឡេងដែលកំពុងប្រាកដ ហើយរលត់ទៅភ្លាម ចិត្តដែលជាសភាពដឹងនោះ កើតឡើង ហើយរលត់ទៅយ៉ាងលឿនរហ័សណាស់ ។ នៅពេលយល់ត្រូវថា ចិត្តកំពុងឃើញ ចិត្ត

កំពុងឮ ចិត្តកំពុងនឹកគិត ជាដើម សតិប្បដ្ឋានក៏រមែងកើតឡើងរលឹកដឹងនូវលក្ខណៈនៃចិត្តដែលជាសភាពដឹង ជាធាតុដឹងក្នុងខណៈនោះ ៗ បាន ។

ដូច្នេះ ការអប់រំចម្រើនបញ្ញា ទើបអាចដឹងលក្ខណៈនៃសភាវធម៌ត្រង់តាមនឹងព្រះធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង រហូតដល់ប្រត្យក្សច្បាស់អរិយសច្ចធម៌ រំលត់កិលេសបាន ជាព្រះអរិយបុគ្គល សោតាបន្ន សកទា អនាគា ព្រះអរហន្ត តាមលំដាប់ ។

ត្រង់ (ចិត្ត) ឈ្មោះថា បណ្ឌរៈ ព្រោះមានសេចក្តីសម្គាល់ថា បរិសុទ្ធ ។ ព្រោះចិត្តមានលក្ខណៈដឹងអារម្មណ៍តែម៉្យាង ។ ដោយសភាវៈទើបជាធម្មជាតិបរិសុទ្ធ ។ សេចក្តីក្នុង **អដ្ឋសាលិនី អដ្ឋកថា ឧទ្ធកនិកាយ បដិសម្ភិទាមគ្គ អានាបានកថា** មានសេចក្តីថា ចិត្តនោះដែលឈ្មោះថា បណ្ឌរៈ (មានន័យថា ស) ព្រោះអត្ថថា បរិសុទ្ធ លោកសម្តែងយកត្រង់ភវង្គចិត្ត ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះស្រស់ថ្លា ថ្លាស្អាត ប៉ុន្តែចិត្តនោះសៅហ្មង ព្រោះដោយសារតែឧបក្កិលេសទាំងឡាយដែលចរមក ។ ម៉្យាងវិញទៀតសូម្បីតែចិត្តអកុសលលោកក៏សម្តែងថា បណ្ឌរៈ ដូចគ្នា ព្រោះអកុសលចេញពីចិត្តនោះហើយ ដូចជា ទន្លេគង្គាហូរចេញពីទន្លេគង្គា និងដូចទន្លេគោធាវរីហូរចេញពីទន្លេគោធាវរី ។ ម៉្យាងវិញទៀតព្រោះចិត្តមានលក្ខណៈដឹងច្បាស់នូវអារម្មណ៍ ទើបមិនមានជាកិលេសដោយភាពសៅហ្មងឡើយ ។ ដោយ

សភាវៈចិត្ត គឺបរិសុទ្ធតែម៉្យាង ។ តែនៅពេលដែលប្រកបជាមួយកិលេស ទើបសៅហ្មង ព្រោះហេតុដូច្នេះ ទើបគួរនឹងដើម្បីពោលថា **បណ្ឌរៈ ។**

ចិត្តជាសភាវៈដែលកើតឡើងហើយក៏រលត់ទៅភ្លាម ។ ការរលត់ទៅនៃចិត្តដួង (ខណៈ) មុន ជាបច្ច័យឱ្យចិត្តកើតដួង (ខណៈ) បន្ទាប់កើតឡើង ។ ចិត្តឃើញកើតឡើងក៏រលត់ទៅ ទើបមិនមានចិត្តដែលឃើញនៅរហូតបាន និងមិនមានចិត្តដែលឮនៅរហូតបាន មិនមានចិត្តដែលដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សនៅរហូតបាន និងមិនមានចិត្តដែលនឹកគិតនៅរហូតបាន ដោយមិនរលត់នោះបានឡើយ ។ ក្នុងខណៈដែលដេកលក់យ៉ាងស៊ប់ មិនយល់សប្តិ ចិត្តកើត រលត់បន្តគ្នារឿយ ៗ តែមិនដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ឡើយ ។ ចិត្តណាដែលមិនដឹងអារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ចិត្តនោះជាភវង្គចិត្ត គឺតម្រង់រក្សាភពជាបុគ្គលនោះ បន្តទុក រហូតដល់ចិត្តដទៃកើតឡើង ដឹងអារម្មណ៍តាមផ្លូវភ្នែក ឬផ្លូវត្រចៀក ឬផ្លូវច្រមុះ ឬផ្លូវអណ្តាត ឬផ្លូវកាយ ឬផ្លូវចិត្ត ផ្លាស់ប្តូរគ្នាទៅរឿយ ៗ រហូតទម្រាំនឹងផុតចាកភាពជាបុគ្គលនោះ ។

ភវង្គចិត្ត មិនដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ខណៈដែលដេកលក់យ៉ាងស៊ប់ មិនមានសេចក្តីដឹងខ្លួនថា ស្រឡាញ់ ស្អប់ ច្រណែន កំណាញ់ មានៈ ប្រកាន់ខ្លួនឡើយ ព្រោះមិនឃើញ មិនឮ មិនដឹងនូវអ្វីដែលប៉ះខ្ទប់សម្ផស្ស មិននឹកគិតអ្វី ៗ

ទាំងអស់ ។ ប៉ុន្តែ ខណៈណាដែលចិត្តកើតឡើងដឹងអារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត នឹងដឹងបានថា អកុសលចិត្តកើត ព្រោះសន្សំកិលេសផ្សេង ។ ទុកមកច្រើនហើយ ទើបធ្វើឱ្យកើតសេចក្តី ត្រេកអរ ជាប់ជំពាក់ ពេញចិត្ត កាលណាឃើញរបស់ដែលជាទីពេញចិត្ត ហើយមានអារម្មណ៍ ថ្នាំងថ្នាក់ អាក់អន់ មិនរីករាយ កាលដែលឃើញ របស់ដែលមិនគួរជាទីពេញចិត្តនោះ ។

ខណៈដែលចិត្តកើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែក តាមផ្លូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះ តើដឹងខ្លួនយ៉ាងណា សេចក្តីដឹងខ្លួន ជាសុខ សប្បាយ ជាទុក្ខក្រៀមក្រំ ជាព្រងើយ ។ នោះ មិនមែនចិត្ត គឺជា ចេតសិកមួយប្រភេទ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ញត្តិ ហៅថា វេទនាចេតសិក ។ **ចិត្តជានាមធម៌ដែលជាធំ ជាប្រធានក្នុងការដឹងអារម្មណ៍** តែចិត្តមិនមែនជាវេទនាចេតសិកដែលដឹងខ្លួន ជាសុខ សប្បាយ ជាទុក្ខ ក្រៀមក្រំ ឬជាព្រងើយ ។ ក្នុងអារម្មណ៍ដែលកំពុងប្រាកដនោះទេ ។ សភាវធម៌ទាំងឡាយ ដែលកើតឡើង នឹងកើតឡើងតែឯកឯងនោះ មិន បានឡើយ ត្រូវអាស្រ័យសភាវធម៌ដទៃជាបច្ច័យកើតឡើងរួមគ្នា ។ **ចិត្ត ត្រូវកើតរួមនឹងចេតសិក ចេតសិកត្រូវកើតរួមនឹងចិត្ត ចិត្តនិងចេតសិក ដែលកើតរួមគ្នានោះរលត់ទៅព្រមគ្នា ដឹងអារម្មណ៍តែមួយដូចគ្នា និងកើត រលត់ត្រង់ទីតែមួយដូចគ្នា ។** ចិត្តមួយខណៈ។ ដែលកើតឡើងមាន ចេតសិកជាបច្ច័យកើតរួមផងដែរ ផ្សេង ។ គ្នា និងធ្វើកិច្ចផ្សេង ។ គ្នា ។

ដូច្នេះ ទើបចិត្តផ្សេងគ្នាជាច្រើនប្រភេទ មិនមានបុគ្គលណាពេញចិត្ត ត្រង់ចិត្តដែលថ្នាំងថ្នាក់ ក្រវល់ក្រវាយ រសាប់រសល់ សោកសៅ ក្តៅក្រហាយនោះទេ ប៉ុន្តែពេញចិត្តខណៈដែលជាសុខ ស្រណុក សប្បាយ ភ្លើតភ្លើនទៅវិញ ។ តែខណៈដែលស្រណុក សុខ សប្បាយ ភ្លើតភ្លើននោះ ចិត្តមិនបរិសុទ្ធ ព្រោះកើតរួមនឹងលោភៈចេតសិក ដែលជាសភាវធម៌ត្រេកអរជាប់ជំពាក់ភ្លើតភ្លើនក្នុងអារម្មណ៍ ។ ការសិក្សាព្រះធម៌ ដែលព្រះដ៏មានព្រះភាគសម្តែងនោះ ដើម្បីឱ្យសតិប្បដ្ឋាន (គឺសតិ) រលឹកដឹងលក្ខណៈនៃសភាវធម៌ដែលប្រាកដ និងអប់រំចម្រើនបញ្ញាដោយសិក្សា គឺពិចារណា សង្កេតរហូតដឹងច្បាស់សភាវធម៌នោះ ត្រឹមត្រូវតាមសេចក្តីពិត ថាសភាវធម៌ណាជាកុសល សភាវធម៌ណាជាអកុសល និងសភាវធម៌ណាមិនមែនកុសល មិនមែនអកុសល ។ មិនថាអកុសលណា ៗ ទេ ទោះជាគ្រោតគ្រាតក្តី ឬល្អិតក្តី ក៏ជាអកុសលធម៌ទាំងអស់ មិនមែនជាអកុសលធម៌ ចំពោះតែខណៈដែលកើតទោសៈប៉ុណ្ណោះទេ ។

លោកខ្លះសួរថា ធ្វើយ៉ាងណាទើបនឹងមិនក្រោធខឹង ។ សភាវធម៌ទាំងឡាយជាអនត្តា ទោសៈក៏ជាអនត្តា ទោសៈកើតឡើងព្រោះហេតុបច្ច័យ ។

អ្នករំលត់សេចក្តីក្រោធខឹងបានដោយសមុច្ឆេទ ទោសចេតសិក មិនកើតទៀតឡើយនោះ ជាអ្នកដែលអប់រំចម្រើនបញ្ញា ដឹងច្បាស់នូវ អរិយធម៌[២៤] សម្រេចជាព្រះអរិយបុគ្គលថ្នាក់ព្រះអនាគាមិបុគ្គល ។

ការដឹងច្បាស់នូវអរិយធម៌ ជាព្រះអរិយបុគ្គលមាន ៤ ថ្នាក់ ។

អ្នកដឹងច្បាស់អរិយសច្ចធម៌ ប្រត្យក្សច្បាស់សភាពព្រះនិព្វាន គ្រាដំបូងជា ព្រះសោតាបន្នបុគ្គល រំលត់សេចក្តីយល់ខុស និងសេចក្តីសង្ស័យក្នុងលក្ខណៈនៃសភាវធម៌ទាំងឡាយ ។ កាលព្រះសោតាបន្នបុគ្គលចម្រើនបញ្ញាឡើងដឹងច្បាស់ អរិយសច្ចធម៌ប្រត្យក្សច្បាស់និព្វានម្តងទៀត រំលត់សេចក្តីត្រេកអរ ពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈយ៉ាងគ្រោតគ្រាត ជាព្រះសកទាគាមិបុគ្គល ។ កាលព្រះសកទាគាមិបុគ្គលចម្រើនបញ្ញាឡើង ដឹងច្បាស់អរិយសច្ចធម៌ ប្រត្យក្ស និព្វានម្តងទៀត រំលត់សេចក្តីត្រេកអរ ពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈទើបរំលត់ទោសៈបាន ជាព្រះអនាគាមិបុគ្គល ។ កាលព្រះអនាគាមិបុគ្គល

---

[២៤] អរិយសច្ចធម៌ ៤ នោះគឺ

១. **ទុក្ខអរិយសច្ច** សង្ខារធម៌ទាំងឡាយមិនទៀងកើតឡើងហើយរលត់ទៅវិញ ទើបជាសភាពជាទុក្ខ គឺមិនគួរនឹងជាប់ជំពាក់ឡើយ ។

២. **ទុក្ខសមុទយអរិយសច្ច** តណ្ហា គឺជាលោភៈ ការពេញចិត្ត ជាប់ជំពាក់ជាសមុទ័យ គឺជាហេតុឱ្យកើតទុក្ខ ។

៣. **ទុក្ខនិរោធអរិយសច្ច** ព្រះនិព្វាន ជាសភាវធម៌រលត់ទុក្ខ ព្រោះរំលត់កិលេស ដែលជាហេតុនាំឱ្យកើតទុក្ខ ។

៤. **ទុក្ខនិរោធគាមិនីបដិបទា** អរិយមគ្គមានអង្គ ៨ គឺការអប់រំចម្រើនបញ្ញាឱ្យដឹងច្បាស់នូវអរិយសច្ចធម៌ ជាផ្លូវបដិបត្តិដើម្បីរំលត់ទុក្ខ ។

ចម្រើនបញ្ញាឡើង ដឹងច្បាស់អរិយសច្ចធម៌ ប្រត្យក្សច្បាស់និព្វានម្តងទៀត រំលត់អកុសលធម៌ទាំងអស់ជាព្រះអរហន្ត កាលព្រះអរហន្តរំលត់ខន្ធបរិនិព្វានហើយ គឺមិនកើតតទៅទៀតឡើយ ។ នៅពេលដែលយល់ថា លោកុត្តរបញ្ញារបស់ព្រះអរិយបុគ្គលមួយថ្នាក់ ។ រំលត់កិលេសមួយថ្នាក់ ។ យ៉ាងណានោះ ក៏នឹងត្រូវសិក្សាឱ្យយល់ចូលចិត្ត នូវគន្លងបដិបត្តិ ដែលនឹងអប់រំចម្រើនបញ្ញា ឱ្យដឹងច្បាស់សភាវធម៌ដែលប្រាកដ និងរំលត់កិលេសបានពិត ។ តាមដែលព្រះដ៏មានព្រះភាគបានទ្រង់សម្តែងទុក ។

សូម្បីព្រះដ៏មានព្រះភាគ ទ្រង់បានសម្តែងលក្ខណៈនៃចិត្ត ក្នុងសេចក្តីសម្គាល់របស់ពាក្យថា **បណ្ឌរៈ** ហើយក៏ដោយ ដើម្បីឱ្យយល់ចូលចិត្ត លក្ខណៈនៃចិត្តក្រៃលែងឡើងទៀត ទើបទ្រង់សម្តែង ក្នុងសេចក្តីសម្គាល់នៃពាក្យថា **មនាយតនៈ** ។

ត្រង់ (**ចិត្ត**) **ឈ្មោះថា មនាយតនៈ** អធិប្បាយនូវពាក្យថា មនាយតនៈ នោះ ។ **មនៈ** គប្បីជ្រាបថា អាយតនៈ ព្រោះសេចក្តីសម្គាល់ថាជាទីនៅអាស្រ័យ ជាអណ្តូងកើត ជាទីប្រជុំ និងជាហេតុ ។ ដូច្នោះ សូម្បីផស្សៈជាដើម រមែងកើតក្នុង មនៈ នេះ ។ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ចំណែកខាងក្រៅ ក៏រមែងប្រជុំត្រង់ មនៈ ដោយសេចក្តីជាអារម្មណ៍ សូម្បីសម្គាល់ថាជាហេតុ ព្រោះជាហេតុនៃផស្សៈជាដើម ដោយអត្ថថា ជាសហជាតប្បច្ច័យ ។

ចិត្តគ្រប់ខណៈជាសភាពដឹង ជាធាតុដឹង ជាអាការដឹង ដើម្បីនឹងយល់លក្ខណៈដែលជាអនត្តានៃចិត្ត បានក្រៃលែងឡើងនោះ ក៏ដោយដឹងថា ចិត្តជាមនាយតនៈ ព្រោះជាទីនៅអាស្រ័យ ជាអណ្តូងកើត ជាទីប្រជុំ និងជាហេតុ ។

ចំពោះរូបនឹងមានក៏ពិត ចំពោះសំឡេងនឹងមានក៏ពិត ចំពោះក្លិននឹងមានបច្ច័យកើតឡើងក៏ពិត ចំពោះរសផ្សេង ។ នឹងមានក៏ពិត ចំពោះក្តៅ ឬត្រជាក់ ទន់ ឬរឹង កម្រើក ឬញ័រផ្សេង ។ នឹងមានក៏ពិត តែបើចិត្តមិនកើតឡើងដឹងទេ បើចិត្តមិន ជាទីប្រជុំរបស់ធម៌ទាំងនេះទេ វត្ថុដែលប្រាកដតាមផ្លូវភ្នែក ក៏ប្រាកដមិនបាន សំឡេងក៏ប្រាកដមិនបាន ក្លិនក៏ប្រាកដមិនបាន រសផ្សេង ។ ក៏ប្រាកដមិនបាន ក្តៅ ត្រជាក់ ទន់ រឹង កម្រើក ញ័រ ក៏ប្រាកដមិនបាន ។ ប៉ុន្តែថាព្រោះចិត្តជាសភាវៈដឹង ទើបជាទីអាស្រ័យ ជាទីប្រជុំ ជាហេតុ ត្រង់អាចឱ្យសភាវធម៌ប្រាកដ ។ វណ្ណៈ គឺពណ៌ខាងក្រោយមិនបានប្រាកដ ព្រោះមិនបានប្រជុំ គឺមិនប៉ះខ្ទប់នឹងចក្ខុបសាទ មិនប៉ះខ្ទប់នឹងចិត្ត ទើបចិត្តមិនកើតឡើងឃើញ វត្ថុដែលនៅខាងក្រោយបាន សូម្បីថាកម្មជាបច្ច័យធ្វើឱ្យចក្ខុបសាទកើតឡើង និងរលត់វិញបន្តរឿយ ។ ជាដរាបណាដែលមិនទាន់ភ្នែកខ្វាក់ក៏ដោយ តែចិត្តដែលឃើញក៏មិនបានកើតឡើងគ្រប់ពេលដែរ ។ ដូច្នេះ ខណៈណាដែលវណ្ណៈ គឺពណ៌ប្រាកដខណៈនោះចិត្ត ជាមនាយតនៈ ជាទីប្រជុំនៃរូបដែលប៉ះខ្ទប់នឹងចក្ខុបសាទ ខណៈនោះ រូបដែលប៉ះខ្ទប់នឹងចក្ខុ

បសាទ ក៏ជារូបាយតនៈ ចក្ខុបសាទដែលប៉ះខ្ទប់នឹងរូបក៏ជាចក្ខាយតនៈ ។ សភាវធម៌ណាដែលប្រជុំរួមគ្នា ក្នុងខណៈនោះ ជាអាយតនៈ នីមួយ ៗ ទាំងអស់ ។

សំឡេងប៉ះខ្ទប់នឹងសោតបសាទ ហើយប៉ះខ្ទប់នឹងចិត្ត ចិត្តទើបកើតឡើងដឹងសំឡេងដែលប្រាកដបាន ។ ដូច្នេះ ចិត្តទើបជាមនាយតនៈ ជាទីប្រជុំនៃសភាវធម៌ដែលកំពុងប្រាកដ ។

សេចក្តីក្នុងអដ្ឋសាលិនីថា សូម្បីតែព្រោះសេចក្តីសម្គាល់ថា (ចិត្ត) ជាហេតុនោះ គឺព្រោះចិត្តជាហេតុនៃផស្សៈ ជាដើម ។

ផស្សៈជាចេតសិកប្រភេទមួយក្នុងចេតសិក ៥២ ប្រភេទ ផស្សចេតសិក ជានាមធម៌ដែលប៉ះខ្ទប់អារម្មណ៍ ។ ខណៈដែលរូបប៉ះខ្ទប់នឹងរូប ដូចជា ដើមឈើរលំខ្ទប់នឹងផែនដី ការប៉ះខ្ទប់គ្នានៃដើមឈើ និងដីនោះ មិនមែនជាផស្សចេតសិកទេ ។ ខណៈដែលសំឡេងប៉ះខ្ទប់នឹងសោតបសាទ សោតបសាទជារូប សំឡេងក៏ជារូប តែបើសិនជាផស្សចេតសិកមិនកើតឡើងប៉ះខ្ទប់សំឡេង ដែលប៉ះខ្ទប់សោតបសាទទេ ចិត្តឮក៏កើតឡើងមិនបានឡើយ ។

ផស្សចេតសិក ជានាមធម៌ដែលកើតឡើងជាមួយនឹងចិត្ត រលត់ព្រមគ្នាជាមួយចិត្ត ដឹងអារម្មណ៍តែមួយជាមួយចិត្ត និងកើតត្រង់កន្លែងតែមួយជាមួយចិត្ត ។ ដូច្នេះ ចិត្តជាហេតុនៃផស្សៈ ក្នុងភូមិដែលមានខន្ធ ៥ ចិត្ត និងចេតសិកត្រូវកើតត្រង់រូបណាមួយជានិច្ច ។ **រូបណា ដែលជាទីកើត**

នៃចិត្ត និងចេតសិក រូបនោះ ជាវត្ថុរូប (**ចក្ខុបសាទ ជាវត្ថុរូប**) ព្រោះជាទីកើតនៃចក្ខុវិញ្ញាណ និងចេតសិកដែលកើតព្រមជាមួយចក្ខុវិញ្ញាណនោះ ។ សភាវធម៌ដែលកើតឡើង និងកើតឡើងតែឯកឯងម៉្យាងនោះ មិនបានឡើយ ចាំបាច់ត្រូវតែមានសភាវធម៌ដទៃជាបច្ច័យកើតរួមជាមួយ ព្រមគ្នាក្នុងខណៈនោះទើបកើតឡើងបាន ។

សភាវធម៌ណា ជាបច្ច័យឱ្យសភាវធម៌ដទៃកើតឡើងព្រមនឹងខ្លួន សភាវធម៌នោះ ជាសហជាតប្បច្ច័យ ។

សហ ប្រែថា រួមគ្នា ព្រមគ្នា

ជាតិ ប្រែថា កើត

បច្ច័យ គឺធម៌ដែលជាឧបការទំនុកបម្រុងឱ្យសភាវធម៌ដទៃកើតឡើង ឬតម្រង់នៅ សម្តែងថា សភាវធម៌គ្រប់យ៉ាងដែលកើតជាសង្ខារធម៌ ព្រោះអាស្រ័យធម៌ដទៃជាបច្ច័យ ទើបកើតឡើង បើប្រាសចាកបច្ច័យសភាវធម៌ទាំងឡាយ ក៏កើតឡើងមិនបាន និងសភាវធម៌ប្រភេទនីមួយ ៗ ក៏ជាបច្ច័យផ្សេង ៗ គ្នា ។ សភាវធម៌បែបខ្លះ ជាសហជាតប្បច្ច័យ ធ្វើឱ្យសភាវធម៌ដទៃកើតឡើងព្រមជាមួយនឹងខ្លួន ។ សភាវធម៌បែបខ្លះ ជាបច្ច័យដោយកើតមុន សភាវធម៌ដែលខ្លួនជាបច្ច័យឱ្យកើតឡើង និងសភាវធម៌ខ្លះក៏ជាបច្ច័យដោយកើតខាងក្រោយ ។

ដូច្នេះ ចិត្តទើបជាសហជាតប្បច្ច័យដល់ចេតសិក ដែលកើតព្រមនឹងចេតសិកនោះ និងចេតសិក ក៏ជាសហជាតប្បច្ច័យដល់ចិត្ត ដែល

កើតព្រមនឹងចេតសិកនោះ ។ កាលណាផស្សចេតសិកកើតឡើងប៉ះខ្ទប់អារម្មណ៍ណា ចិត្តដែលកើតព្រមនឹងផស្សៈចេតសិកនោះ ក៏ដឹងអារម្មណ៍ដែលផស្សៈចេតសិកនោះប៉ះខ្ទប់ **មិនមែនជាផស្សៈចេតសិក ប៉ះខ្ទប់អារម្មណ៍មួយ ហើយចិត្តដែលកើតព្រមនឹងផស្សៈចេតសិកនោះ ទៅដឹងអារម្មណ៍មួយទៀតបានឡើយ ។** ខណៈណាដែលផស្សៈចេតសិកដែលកើតឡើងប៉ះខ្ទប់សំឡេងណា សោតវិញ្ញាណ ដែលកើតព្រមនឹងផស្សៈចេតសិកដែលប៉ះខ្ទប់សំឡេងនោះ ក៏មានសំឡេងនោះជាអារម្មណ៍ ។

បរមត្ថធម៌មាន ៤ គឺ ចិត្ត ចេតសិក រូប និព្វាន ។ បរមត្ថធម៌ប្រភេទនីមួយ ។ ជាបច្ច័យឱ្យបរមត្ថធម៌ដទៃ ដែលជាសង្ខារធម៌កើតឡើង គឺចិត្តជាបច្ច័យឱ្យកើតចេតសិក និងជាបច្ច័យឱ្យកើតរូប (រៀរខណៈខ្លះ) ។ ចេតសិកជាបច្ច័យឱ្យកើតចិត្ត និងជាបច្ច័យឱ្យកើតរូប (រៀរខណៈខ្លះ) ។ រូបជាបច្ច័យឱ្យកើតរូប និងជាបច្ច័យឱ្យកើតចិត្ត ខណៈដែលរូបជាវត្ថុ គឺជាទីកើតនៃចិត្ត និងខណៈដែលរូបជាអារម្មណ៍របស់ចិត្ត តាមសមគួរដល់សភាពនៃបរមត្ថធម៌នោះ ដោយបច្ច័យផ្សេង ៗ គ្នា ដូចជា សហជាតប្ប-ច្ច័យ ជាដើម ។

ចិត្ត និងចេតសិក ជាសហជាតប្បច្ច័យឱ្យកើតរូបព្រមនឹងចិត្តទាន់ពេលដែលចិត្តកើតឡើងក្នុងឧប្បាទខណៈ ។ ចិត្តគ្រប់ដួងមាន ៣ អនុខណៈ (ខណៈតូច) គឺ ឧប្បាទខណៈ (ខណៈកើតឡើង) ឋិតិខណៈ (ខណៈមិនទាន់រលត់) ភង្គខណៈ (ខណៈរលត់) ។ ចិត្តមិនបាន

បញ្ជាឱ្យរូបកើត ។ ចិត្តជរូប គឺរូបដែលកើតព្រោះចិត្តជាបច្ច័យនោះ កើតព្រមទាន់នឹងចិត្តភ្លាមដែលចិត្តកើតឡើង ក្នុងឧប្បាទខណៈនោះឯង ។ **ប៉ុន្តែទាំងអស់នេះត្រូវវៀរបដិសន្ធិចិត្ត ព្រោះក្នុងខណៈដែលបដិសន្ធិចិត្តកើតឡើងនោះ មានតែកម្មជរូប គឺរូបដែលកើតព្រោះកម្មកើតរួមប៉ុណ្ណោះ មិនមានចិត្តជរូប ។** កាលណាបដិសន្ធិចិត្តរលត់ទៅហើយ ចិត្តជាបច្ច័យឱ្យរូបកើតឡើងព្រមជាមួយនឹងចិត្ត តាំងតែបឋមភវង្គ គឺភវង្គដួងដើមដំបូងទៅ **វៀរទ្វិបញ្ចវិញ្ញាណ** (បញ្ចវិញ្ញាណ ៥ x ២) គឺចិត្តឃើញ ២ ដួង ចិត្តឮ ២ ដួង ចិត្តដឹងក្លិន ២ ដួង ចិត្តដឹងរស ២ ដួង ចិត្តដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សតាមផ្លូវកាយ ២ ដួង **និងចុតិចិត្តរបស់ព្រះអរហន្ត** ។ ក្រៅអំពីនោះ ហើយគ្រប់ខណៈដែលចិត្តកើតឡើង ក្នុងភូមិដែលមានខន្ធ ៥ មានចិត្តជរូបកើតព្រមនឹងឧប្បាទខណៈនៃចិត្តគ្រប់គ្រា ។

បុគ្គលម្នាក់ ៗ សន្សំសភាវធម៌មកវិចិត្រផ្សេង ៗ គ្នា ។ អ្នកខ្លះមានអកុសលច្រើន អ្នកខ្លះមានកុសលច្រើន ។ ប៉ុន្តែអ្នកដែលយល់រឿងហេតុការណ៍ចម្រើនសតិប្បដ្ឋាន ហើយអប់រំចម្រើនសតិប្បដ្ឋាន កុសលទាំងឡាយក៏នឹងជាបារមី ជាឧបការឧបត្ថម្ភ ក៏ឱ្យសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលមិនមែនសត្វ បុគ្គល តួខ្លួន រហូតដល់អាចប្រត្យក្ស ច្បាស់អរិយសច្ចធម៌រំលត់កិលេសបានជាសមុច្ឆេទ ជាលំដាប់ ៗ ។ ប៉ុន្តែអ្នកដែលផ្តើមចម្រើនសតិប្បដ្ឋាននោះ សតិប្បដ្ឋាននៅមិនទាន់មានកម្លាំងទើបភាពជាតួខ្លួន នៅមានកម្លាំងណាស់ មិនថាក្នុងខណៈឃើញ ខណៈឮ

ខណៈដែលមិនពេញចិត្ត អកុសល ខណៈបំពេញកុសល ក៏នៅតែប្រកាន់សភាវធម៌នោះ ។ ថាជាយើង ជាកុសលរបស់យើង ។

ដូច្នេះ គោលបំណងនៃការសិក្សាបរមត្ថធម៌ រឿងផ្លូវចិត្ត ក៏គឺដើម្បីជា បច្ច័យឧបត្ថម្ភឱ្យយល់លក្ខណៈនៃចិត្ត ដែលកំពុងមានក្នុងខណៈនេះ ដែលកំពុងឃើញ កំពុងឮ កំពុងនឹកគិត ជាដើម ដើម្បីឱ្យសតិប្បដ្ឋានកើតឡើង រលឹកដឹងលក្ខណៈនៃសភាវធម៌ ដែលជាសភាវធម៌ដឹង ធាតុដឹងដែលកំពុងដឹងនូវអ្វីណាមួយ ដែលកំពុងប្រាកដ ។

ខណៈដែលសិក្សារឿងផ្លូវចិត្ត ក៏កុំគប្បីគិតថា ដឹងលក្ខណៈនៃចិត្តប្រាកដជាក់ច្បាស់លាស់ហើយ និង**គោលបំណងនៃការសិក្សារឿងផ្លូវចិត្តនោះ មិនមែនដើម្បីត្រូវការ ជាអ្នកដែលមានសេចក្តីដឹងរឿងផ្លូវចិត្តច្រើន ។ នោះទេ គឺដើម្បីជាសង្ខារក្ខន្ធតាក់តែងឱ្យសតិកើតឡើង រលឹកដឹងសភាវៈនៃចិត្ត ដែលជានាមធម៌ ដែលជាធាតុដឹង ដែលកំពុងដឹង ក្នុងខណៈនេះ ដើម្បីបញ្ញាដែលអប់រំចម្រើនឡើងហើយនោះ នឹងបានលះបង់ការប្រកាន់សភាវធម៌ទាំងឡាយថាជាតួខ្លួន ។**

សំណួរសាឡើងវិញ

១ - ភវង្គចិត្ត គឺអ្វី ? តើភវង្គចិត្តដឹងអារម្មណ៍ ឬទេ ?

២ - ខណៈណាចិត្តឈ្មោះថាបណ្ដុរៈ ? ព្រោះអ្វី ?

៣ - ចិត្ត ចេតសិក ជាបច្ច័យឱ្យកើតអ្វីខ្លះ ?

៤ - រូបជាបច្ច័យឱ្យកើតអ្វីខ្លះ ?

៥ - ការដឹងច្បាស់អរិយសច្ចធម៌ ជាព្រះអរិយបុគ្គលមានប៉ុន្មានថ្នាក់ ? អ្វីខ្លះ ?

៦ - វត្ថុរូប គឺអ្វី ?

៧ - អាយតនៈ គឺអ្វី ? អ្វីខ្លះជាអាយតនៈ ?

៨ - សហជាតប្បច្ច័យ គឺអ្វី ?

៩ - ចិត្តជ្ជរូប គឺអ្វី ? កើតពេលណា ? ក្នុងភូមិដែលមានខន្ធ ៥ ចិត្តណាមិនជាបច្ច័យឱ្យកើតចិត្តជ្ជរូបខ្លះ ?

១០ - គោលបំណងដែលត្រឹមត្រូវនៃការសិក្សាព្រះធម៌ គឺអ្វី ?

មេរៀនទី ២

សេចក្តីអធិប្បាយពាក្យថា **ចិត្ត** ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ មានដូចតទៅនេះ

នឹងអធិប្បាយពាក្យថា **ចិត្តំ** ត្រង់ឈ្មោះថា « ចិត្ត » ព្រោះអត្ថថា គិត អធិប្បាយថា ដឹងច្បាស់អារម្មណ៍ ។ ម៉្យាងទៀត ព្រោះហេតុតាមសព្ទថា « ចិត្តំ » នេះទូទៅដល់ចិត្តគ្រប់ដួង ។ ដូច្នេះក្នុងពាក្យថា « ចិត្តំ » នេះកុសលចិត្ត និងមហាកិរិយាចិត្តចំណែកលោកិយទើបឈ្មោះថា « ចិត្ត » ព្រោះសន្សំសន្តាននៃខ្លួន ដោយអំណាចនៃជវនវិថី ។ ឈ្មោះថា « ចិត្ត » ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។ ចិត្តគ្រប់ដួងឈ្មោះថា« ចិត្ត» ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ។ ឈ្មោះថា« ចិត្ត» ព្រោះធ្វើឱ្យវិចិត្រ ។ ប្រសិនបើសិក្សាតម្រាសម័យក្រោយ ។ ដែលអ្នករៀបរៀងទុកមក ក៏នឹងបានជ្រាបថា អត្ថនៃចិត្តមាន ៦ យ៉ាង ដែលពោលទុកក្នុងគម្ពីរអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ បានអធិប្បាយពាក្យថា « ចិត្ត » ដែលអាចបំបែកចេញបានជា ខ ។ គឺ

ឈ្មោះថា « ចិត្ត » ព្រោះអត្ថថា គិត អធិប្បាយថា ព្រោះដឹងច្បាស់អារម្មណ៍ ១ ។

ឈ្មោះថា « ចិត្ត » ព្រោះសន្សំសន្តាននៃខ្លួន ដោយអំណាចនៃជវនវិថី ១ ។

ឈ្មោះថា« ចិត្ត» ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ១ ។

ឈ្មោះថា « ចិត្ត » ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ១ ។

(ខ នេះ ភាគច្រើន ក្នុងតម្រាសម័យក្រោយចែកជា ២ គឺព្រោះវិចិត្រដោយអារម្មណ៍ ១ និងព្រោះវិចិត្រដោយសម្បយុត្តធម៌ ១) ។

ឈ្មោះថា « ចិត្ត » ព្រោះធ្វើឱ្យវិចិត្រ ១ ។

សូមពោលដោយលំដាប់ ដើម្បីធ្វើឱ្យងាយយល់លក្ខណៈនៃចិត្ត តាមដែលបានពោល ទុកក្នុងអដ្ឋសាលិនី ។

ត្រង់ឈ្មោះថា ចិត្ត ព្រោះអត្ថថា គិត អធិប្បាយថា ដឹងច្បាស់អារម្មណ៍ ។

គ្រប់លោកអ្នកទាំងអស់គិតជានិច្ច បើសង្កេតពិចារណាសេចក្តីគិតក៏នឹងឃើញបានថា មានការគិតពិត និងគិតផ្សេង ។ នានា មិនមានផ្លូវឈប់នូវការគិតឡើយ រហូតដល់លោកអ្នកខ្លះមិនចង់នឹងគិត ចង់តែស្ងប់ ។ គឺឈប់គិតព្រោះយល់ឃើញថា កាលណាបើគិត នាំឱ្យក្តៅក្រហាយចិត្ត ហួងហែង កង្វល់ រសាប់រសល់ ដោយលោភៈខ្លះ ទោសៈខ្លះ ហើយក៏យល់ថា បើមិនគិតអ្វីទាំងអស់បាន គឺជាការល្អ តែសូមឱ្យជ្រាបថា ចិត្តនោះឯងជាសភាវធម៌ដែលគិត ចំពោះរូបធម៌គិតអ្វីមិនបាន ដល់កាលណាពិចារណារឿងដែលចិត្តគិត ក៏នឹងដឹងបានថា ព្រោះហេតុដូចម្តេចទើបចិត្តគិតរឿងរ៉ាវយ៉ាងនោះ ។ ក្នុងគ្រាខ្លះមិនគួរនឹងគិតយ៉ាងនោះឡើយ តាមប្រក្រតីចិត្តរមែងកើតឡើងគិតទៅក្នុងរឿងនៃសភាវៈដែលប្រាកដតាមផ្លូវភ្នែកខ្លះ ផ្លូវត្រចៀកខ្លះ ផ្លូវច្រមុះខ្លះ ផ្លូវអណ្តាតខ្លះ ផ្លូវកាយខ្លះ ផ្លូវចិត្តខ្លះ

ជារឿង ។ រហូតដល់ឃើញថា ជារឿងរ៉ាវពិតមែន ។ តែត្រង់ដែលឃើញថា ជារឿងរ៉ាវពិតមែនទាំងអស់នោះ ក៏ត្រឹមតែដោយសារចិត្តកើតឡើង គិតរឿងនោះហើយក៏រលត់ទៅប៉ុណ្ណោះឯង ប្រសិនបើចិត្តមិនគិតដល់រឿងនោះទេ នោះរឿងនោះ ក៏នឹងមិនមាន ។

ខ សេចក្តីក្នុងអដ្ឋសាលិនីថា ត្រង់ឈ្មោះថា « ចិត្ត » ព្រោះអត្ថថា គិត អធិប្បាយថា ដឹងច្បាស់អារម្មណ៍ ។

សភាព « ដឹង » មានលក្ខណៈផ្សេងគ្នា តាមប្រភេទនៃសភាវធម៌នោះ ។ ដូចជាចេតសិក ក៏ជាសភាវធម៌ដែលដឹងអារម្មណ៍ តែមិនជាធំក្នុងការដឹងអារម្មណ៍ ។ ចេតសិកមួយប្រភេទ ។ កើតព្រមនឹងចិត្ត ដឹងអារម្មណ៍ជាមួយនឹងចិត្ត តែថាធ្វើកិច្ចចំពោះតែចេតសិកនោះ ។ ដូចជាផស្សចេតសិកកើតរួមនឹងចិត្ត ព្រមនឹងចិត្ត តែផស្សចេតសិក ជាសភាវធម៌ដឹងអារម្មណ៍ ដោយប៉ះខ្ទប់អារម្មណ៍ ។ ដូច្នេះ ផស្សចេតសិក ទើបដឹងអារម្មណ៍ត្រឹមតែប៉ះខ្ទប់អារម្មណ៍ តែមិនមែនដឹងច្បាស់អារម្មណ៍ ។ បញ្ញាចេតសិក ជាសភាវធម៌ដែលដឹងធម៌ ឃើញធម៌ត្រឹមត្រូវ តាមសេចក្តីពិត ដូចដឹងលក្ខណៈដែលមិនមែនតួខ្លួន សត្វ បុគ្គល នៃសភាវៈដែលកំពុងប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ តែចិត្តដែលជាសភាពដឹងនោះ មានសេចក្តីថាដឹងច្បាស់អារម្មណ៍ ទើបមិនមែនជាការដឹង ដូចយ៉ាងផស្សៈ ដែលប៉ះខ្ទប់អារម្មណ៍ មិនមែនជាការដឹង ដូចជាសញ្ញា ដែលចាំសំគាល់លក្ខណៈនៃអារម្មណ៍ និង

មិនមែនជាការដឹងដូចបញ្ញា ។ តែចិត្តជាសភាពដែលដឹងច្បាស់ក្នុង លក្ខណៈផ្សេង ៗ នៃអារម្មណ៍ដែលប្រាកដ ។ វត្ថុដែលកំពុងប្រាកដ តាមផ្លូវភ្នែកក្នុងខណៈនេះផ្សេងគ្នាដែរទេ ? សភាវធម៌ ជាសច្ចធម៌ ជា សភាវៈដែលពិសោធន៍បាន ។ ខណៈនេះឃើញវត្ថុមួយ តែមួយពណ៌ ទាំងអស់ ឬក៏ឃើញវត្ថុ ដែលកំពុងប្រាកដជាពណ៌ច្រើនយ៉ាង ៗ ល្អិត ៗ រហូតធ្វើឱ្យដឹងសេចក្តីប្លែកគ្នាបានថា វត្ថុដែលឃើញនោះ ជាពេជ្រសុទ្ធ ឬពេជ្រក្លែងក្លាយ ជាដើម ។ **ចិត្តជាសភាវៈដែលឃើញច្បាស់ គឺដឹងច្បាស់សូម្បីលក្ខណៈ ដែលល្អិតប្លែក ៗ នៃអារម្មណ៍ផ្សេង ៗ ក៏ដោយ ឧបមាដូចកញ្ចក់ឆ្លុះ ដែលថ្លាស្អាត មិនថាវត្ថុណាមកកាត់ក៏ដោយ ក៏រមែងប្រាកដ ស្រមោលក្នុងកញ្ចក់នោះយ៉ាងណា** ខណៈនេះចក្ខុបសាទ ជារូប ដែលមានលក្ខណៈថ្លាស្អាតពិសេស ក៏អាចប៉ះខ្ទប់នឹងសភាវៈដែល ប្រាកដតាមផ្លូវភ្នែកយ៉ាងនោះដែរ សោតបសាទអាចប៉ះខ្ទប់ចំពោះតែ សំឡេង ឃានបសាទអាចប៉ះខ្ទប់ចំពោះក្លិន ជិវ្ហាបសាទអាចប៉ះខ្ទប់ចំពោះ តែរស កាយបសាទអាចប៉ះខ្ទប់ចំពោះតែរូបដែលប៉ះខ្ទប់នឹងកាយ ។ ដូច្នេះ ទោះបីនឹងជាពណ៌ វណ្ណៈយ៉ាងណា ៗ ក៏ដោយ ក៏ប្រាកដឱ្យចិត្តឃើញបាន ទាំងអស់ ។ ខណៈនោះវត្ថុកំពុងប្រាកដតាមផ្លូវភ្នែក ប្រាកដនឹងចិត្ត ដែលដឹងច្បាស់ មិនថាវត្ថុដែលប្រាកដនោះ មានលក្ខណៈយ៉ាងណា ឡើយ ចិត្តក៏ដឹងច្បាស់ក្នុងលក្ខណៈ ដែលកំពុងប្រាកដនោះ ៗ គឺឃើញពណ៌ ផ្សេង ៗ ទាំងអស់ នៃវត្ថុផ្សេង ៗ ដែលប្រាកដ ទើបធ្វើឱ្យដឹងសេចក្តី

សំគាល់ដឹងរូបរាង សណ្ឋាន និងនឹកគិតដល់វត្ថុដែលប្រាកដតាមផ្លូវភ្នែកបាន ។

សំឡេងដែលប្រាកដតាមផ្លូវត្រចៀក ជាសំឡេងតែមួយដូចគ្នាទាំងអស់ ឬផ្សេងគ្នា ជាសំឡេងមួយ ។ តាមបច្ច័យដែលធ្វើឱ្យសំឡេងនោះ ។ កើតឡើង ។ មនុស្សមានប៉ុន្មាន សំឡេងនៃមនុស្សម្នាក់ ។ ក៏ខុសគ្នាប៉ុណ្ណោះដែរ ចិត្តដឹងច្បាស់ គ្រប់សំឡេងដែលមកប្រាកដខុស ។ គ្នានោះ សំឡេងចំអកឡកឡាយ សំឡេងគ្រាប់បែក សំឡេងខ្យល់បក់ សំឡេងទឹកធ្លាក់ សំឡេងសត្វយំ សត្វទាំងឡាយក៏យំផ្សេង ។ គ្នា ឬសូម្បីតែមនុស្ស ដែលមានសំនៀងជាសំឡេងសត្វ ចិត្តក៏ដឹងច្បាស់លក្ខណៈនៃសំឡេងដែលខុសគ្នានោះបានដែរ ចិត្តឮសំឡេងដឹងច្បាស់ គឺឮសំឡេង គ្រប់សំឡេងដែលខុសគ្នា ។ សភាវធម៌គ្រប់យ៉ាងប្រាកដបានក៏ព្រោះចិត្តកើតឡើងដឹងច្បាស់អារម្មណ៍នោះ ។ ដែលប្រាកដ ចិត្តដែលដឹងច្បាស់តាមផ្លូវច្រមុះកើតឡើងដឹងច្បាស់ក្លិនផ្សេង ។ ដែលប្រាកដ ។ ក្លិនសត្វគ្រប់បែប ក្លិនលំអងផ្កាគ្រប់បែប ក្លិនអាហារ ក្លិនសម្ល ក្លិននំ ទោះជាមិនឃើញក៏ដោយ ត្រឹមតែបានក្លិន ក៏ដឹងថាជាក្លិនអ្វី ។ នោះបាន ។

ចិត្តដែលដឹងច្បាស់តាមផ្លូវអណ្តាតកើតឡើងក្រេបរសផ្សេង ។ ។ រសអាហារមានសន្ទឹកសន្ធាប់ រសសាច់ រសផ្លែឈើ រសតែ រសកាហ្វេ រសអំបិល រសស្ករ រសក្រូច រសផ្លែមៀន រសស្វាយ ជារសដែលមិនដូចគ្នាសោះឡើយ តែចិត្តដែលក្រេបរសក៏ដឹងច្បាស់រសផ្សេង ។

ដែលប្រាកដ ។ សូម្បីតែថានឹងខុសគ្នាយ៉ាងល្អិតត្រឹមណាក៏ដោយ ចិត្ត ក៏អាចដឹងច្បាស់លក្ខណៈដែលខុសគ្នាយ៉ាងល្អិតនោះ ។ បានដែរ ដូចជា ខណៈ ភ្លក់អាហារ ចិត្តដែលដឹងរស ដឹងច្បាស់ក្នុងរសនោះ ទើបដឹង ថានៅខ្ទះរសអ្វី និងត្រូវផ្សំអ្វី ដាក់អ្វី បន្ថែមអ្វី ជាដើម ។

ចិត្តដែលដឹងច្បាស់សភាវៈដែលប៉ះខ្ទប់សម្ផស្សកាយ ដឹងលក្ខណៈ ផ្សេង ។ ដែលប៉ះខ្ទប់នឹងកាយ ដូចជាលក្ខណៈនៃខ្យល់ត្រជាក់ ទឹកត្រជាក់ ឬអាកាសត្រជាក់ ។ ដឹងលក្ខណៈនៃសំពត់ឬទេ មានសំពត់រោមសត្វ ជាដើម ដែលប៉ះខ្ទប់នឹងកាយ ។

លោកម្នាក់និយាយឱ្យស្តាប់ថា លោកកំពុងឈរនៅត្រង់ថ្នល់ ក៏ កើតការរលឹកដឹង លក្ខណៈរឹងដែលប្រាកដ ហើយបន្ទាប់មកគិតថា រឹងនេះ ជាថ្នល់ និងតមកក៏គិតថា រឹងនេះជាស្បែកជើង ហើយតមកទៀតក៏គិតថា រឹងនេះជាស្រោមជើង នេះជាសេចក្តីគិតរឿងលក្ខណៈរឹងដែលប្រាកដ ។ ចិត្តដែលកើតឡើងព្រោះហេតុបច្ច័យ កាលណាប៉ះខ្ទប់នឹងរឹងហើយ ទើប គិតថា រឹងនេះ ជាអ្វី រឹងនេះជាថ្នល់ ហើយបន្ទាប់មករឹងនេះ ជាស្បែកជើង ហើយបន្ទាប់មករឹងនេះជា ស្រោមជើង នេះនឹងឃើញបាន ថាមិនមាន អ្នកណា អាចនឹងស្ទាក់ស្ទើរក្នុងការនឹកគិតរឿងវត្ថុផ្សេង ។ បានឡើយ តែការដែលនឹងដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិតបាននោះ ចាំបាច់ បញ្ញាដែលដឹងថា ចិត្តកើតឡើងដឹងច្បាស់អារម្មណ៍មួយខណៈ ។ ហើយ

ក៏រលត់ទៅភ្លាមយ៉ាងរហ័ស ខណៈដែលកំពុងគិតដល់ផ្លូវថ្នល់ ស្បែកជើង ស្រោមជើង មិនមែនជាខណៈដែលដឹងច្បាស់លក្ខណៈ ដែលរឹងទេ ។

ដូច្នេះ ការដែលបញ្ញាដឹងជាក់ច្បាស់ ក្នុងលក្ខណៈនៃសភាវធម៌ តាមសេចក្តីពិតនោះ នឹងត្រូវដឹងច្បាស់ថា ខណៈដែលគិតមិនមែនជាតួខ្លួន គឺជាចិត្តដែលកំពុងដឹងរឿងដែលគិត ចិត្តដែលគិត មិនមែនចិត្តដែលឃើញ ។ ចិត្តដែលដឹងអារម្មណ៍តាមផ្លូវភ្នែក ចិត្តគិតដឹងអារម្មណ៍តាមផ្លូវចិត្ត តាមប្រក្រតី ខណៈដែលសភាវធម៌ណាប្រាកដតាមផ្លូវកាយ ជាលក្ខណៈដែល ទន់ ឬ រឹងក៏ដោយ លក្ខណៈនោះមិនទាន់ដឹងថាជាអ្វីឡើយ បើនៅក្នុងទីងងឹត លោកខ្លះក៏អាចនឹងត្រូវបើកភ្នែក បើកភ្លើងមើលថាតើកំពុងប៉ះខ្ទប់សម្ផស្សអ្វី ។ ដូច្នេះ តាមសេចក្តីពិតស្រេចហើយនោះ ខណៈដែលចិត្តដឹងរឹងនោះ មិនមែនជាចិត្តនឹកគិត ។ ខណៈដែលចិត្តកំពុងដឹងរឹងនោះ មិនមែនលោកនៃស្រោមជើង ស្បែកជើង ឬផ្លូវថ្នល់ទេ មិនមានលោក នៃសម្មតិបញ្ញត្តិណា ។ ឡើយ មានតែសភាពដឹង ដែលកំពុងដឹងលក្ខណៈ ដែលរឹងប៉ុណ្ណោះ សូម្បីតែសភាវៈដែលដឹងរឹងនោះ ក៏មិនមែនសត្វ បុគ្គល គឺត្រឹមតែជាសភាពដឹងរឹងដែលកើតឡើង ហើយក៏រលត់ទៅរួចហើយ ទើបចិត្តជាចំណែកខាងក្រោយ នឹកគិតរឿងសភាវៈដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ជារឿងរ៉ាវផ្សេង ។ ជាសម្មតិបញ្ញត្តិនៃសភាវៈដែលប្រាកដ រហូតដល់ភ្លេចថា ចិត្តដែលកើតឡើងដឹងរឹង និងសភាវៈរឹងនោះរលត់ទៅហើយ

និងចិត្តដែលគិតរឿងសភាវៈដែលរឹងនោះក៏រលត់ទៅ ។ សភាវធម៌ទាំងនាមធម៌ និងរូបធម៌កើតឡើង ហើយរលត់ទៅបន្តគ្នាយ៉ាងរហ័សនោះ ទើបធ្វើឱ្យមិនដឹងថាសភាវធម៌ទាំងនាមធម៌ និងរូបធម៌នោះកើត រលត់ មិនមែនតួខ្លួន ។

ចិត្តជាសភាវធម៌ដែលដឹងច្បាស់អារម្មណ៍ដែលប្រាកដ មិនថានឹងតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តឡើយ កាលណាផស្សៈចេតសិកប៉ះខ្ទប់អារម្មណ៍ណា ចិត្តដែលកើតព្រមនឹងផស្សៈនោះ ក៏ដឹងច្បាស់លក្ខណៈផ្សេង ៗ នៃអារម្មណ៍នោះ ។ ដូច្នេះ សូម្បីតែពាក្យថា ដឹងច្បាស់អារម្មណ៍ដែលជាលក្ខណៈនៃចិត្ត ដែលជាធាតុដឹង ក៏នឹងត្រូវយល់ថា **ដឹងច្បាស់អារម្មណ៍ គឺដឹងលក្ខណៈផ្សេង ៗ នៃអារម្មណ៍ផ្សេងដែលប្រាកដ** មិនថាជាតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តឡើយ ។ កាលណាចិត្តជាសភាវៈដែលដឹងច្បាស់អារម្មណ៍ អារម្មណ៍ទើបជាបច្ច័យមួយ ដែលធ្វើឱ្យចិត្តប្រភេទនីមួយៗ កើតឡើងដឹងអារម្មណ៍នោះ ។ **ដូច្នេះ អារម្មណ៍ទើបជាអារម្មណប្បច្ច័យ គឺជាបច្ច័យឱ្យចិត្តកើតដោយជាអារម្មណ៍នៃចិត្ត** ។ ខណៈចិត្តនីមួយៗ ដែលកើតឡើងមានច្រើនបច្ច័យដទៃទៀត តែចិត្តនឹងកើតឡើងដោយមិនដឹង អារម្មណ៍មិនបានឡើយ ។ ដូច្នេះ អារម្មណ៍ទើបជាបច្ច័យមួយក្នុងបច្ច័យជាច្រើន ដែលធ្វើឱ្យខណៈចិត្តនីមួយ ៗ កើតឡើង ។

សំណួរសាឡើងវិញ

១ - ផស្សចេតសិក សញ្ញាចេតសិក បញ្ញាចេតសិក និងចិត្ត ដឹងអារម្មណ៍ផ្សេងគ្នាយ៉ាងណា ?

២ - អារម្មណប្បច្ច័យ គឺអ្វី ?

៣ - អ្វីជាអារម្មណប្បច្ច័យខ្លះ ?

មេរៀនទី ៣

ប្រការតទៅទៀត

ម៉្យាងទៀតព្រោះហេតុត្រង់សព្ទថា « ចិត្តំ » នេះជាទូទៅដល់ចិត្តគ្រប់ដួង ។ ដូច្នេះ ក្នុងពាក្យថា « ចិត្តំ » នេះ លោកិយកុសលចិត្ត អកុសលចិត្ត និងមហាកិរិយាចិត្ត ឈ្មោះថា **ចិត្ត ព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថី** ។

ការដែលយល់អត្ថថា ឈ្មោះថា « ចិត្ត » ព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថីនោះ និងត្រូវយល់រឿងនៃចិត្តដែលកើតរលត់ៗបន្តគ្នាយ៉ាងរហ័សថា នាមធម៌ដែលកើតជាមួយខណៈចិត្ត ហើយរលត់ទៅក្នុងមួយខណៈ សន្សំបន្តក្នុងចិត្តខណៈក្រោយ ៗ ដែលកើត រលត់បន្តគ្នានោះឯង ។

ពេលចិត្តកើតឡើងឃើញសភាវៈដែលប្រាកដតាមភ្នែក ឬសំឡេងដែលប្រាកដតាមផ្លូវត្រចៀក ជាដើម តាមប្រក្រតីនឹងមិនដឹងថា ខណៈដែលឃើញ ឬបានឮនោះជាលក្ខណៈនៃចិត្តឡើយ ប៉ុន្តែហាក់បីដូចជាដឹងថា ខណៈណាដែលចិត្តជាទុក្ខ សោកសៅ កករល្អក់ ខណៈណាចិត្តសប្បាយជ្រះថ្លា ខណៈណាជាមិត្តមេត្រីនឹងអ្នកដទៃ ។ ខណៈចិត្តនីមួយ ៗ ដែលកើតរលត់បន្តគ្នាយ៉ាងរហ័សនោះ ក៏សន្សំសន្តាននៃខ្លួនគឺមិនថាជាកុសល អកុសល ខណៈនីមួយ ៗ ដែលកើតឡើងហើយរលត់ទៅនោះ ជាបច្ច័យសន្សំបន្តក្នុងចិត្តដួង (ខណៈ) បន្តបន្ទាប់ ។

ព្រោះកាលណាចិត្តដួង ១ កើតឡើងហើយរលត់ទៅ ការរលត់ទៅ នៃចិត្តដួងមុន ជាបច្ច័យឱ្យចិត្តដួងបន្ទាប់កើតឡើងបន្តភ្លាម ។ ដូច្នេះ ចិត្តដែលកើតបន្ទាប់ ទើបមានសភាវធម៌ដែលចិត្តដួងមុនសន្សំទុក ហើយបន្តទៅក្នុងចិត្តដួងក្រោយ ។ ដែលកើតបន្ទាប់ ។ ទៅទៀតជារឿយ ។ ។

លោកអ្នកម្នាក់ ។ នឹងសង្កេតបានថា បុគ្គលម្នាក់ ។ មានអធ្យាស្រ័យផ្សេង ។ គ្នា មានឧបនិស្ស័យផ្សេង ។ គ្នា តាមការសន្សំនៃខណៈចិត្តនីមួយ ។ ដែលកើតរលត់បន្ត ។ គ្នា ។ លោកអ្នកខ្លះ ជាអ្នកចិត្តបុណ្យកុសលទៅ ព្រោះចិត្តដែលជាបុណ្យកុសលនោះបានកើតឡើងហើយក៏រលត់ទៅ ហើយចិត្តដែលកើតបន្ត ក៏សន្សំបុណ្យកុសលនោះ ។ ជាបច្ច័យបន្ត ។ ទៅខាងមុខទៀត ។ ចំណែកអកុសលក៏ដូចគ្នា មិនថាជាចិត្តប្រកបដោយលោភៈ ឬទោសៈ មោហៈឡើយ កាលណាអកុសលចិត្តប្រភេទនោះ ។ រលត់ទៅហើយ ក៏ជាបច្ច័យឱ្យចិត្តដួងតទៅកើតឡើងបន្តពីសភាវធម៌ដែលសន្សំនៅក្នុងដួងចិត្តមុន ។ តទៅទៀត ។ ការដែលចិត្តដួងក្រោយ កើតអំពីចិត្តដួងមុនជារឿយ ។ នោះ ព្រោះចិត្តគ្រប់ដួង ជាអនន្តរប្បច្ច័យ គឺជាបច្ច័យធ្វើឱ្យចិត្តខណៈបន្ទាប់កើតឡើងបន្តភ្លាម ពេលចិត្តដួងនោះរលត់ទៅ ។ ចិត្តគ្រប់ដួងជាអនន្តរប្បច្ច័យ ធ្វើឱ្យចិត្តដួងបន្ទាប់កើតឡើង វៀរចុតិចិត្តរបស់ព្រះអរហន្តប៉ុណ្ណោះ ដែលមិនជាអនន្តរប្បច្ច័យ ។ ពេលចុតិចិត្តនៃព្រះអរហន្តរលត់ទៅហើយ ទើបហៅថា បរិនិព្វាន មិនមានបដិសន្ធិចិត្ត ឬចិត្តដទៃណា ។ កើតបន្តទៅទៀតឡើយ ។

ដូច្នេះ បច្ច័យដែលបានពោលមកហើយ មាន ៣ បច្ច័យគឺ សហជាតប្បច្ច័យ អារម្មណប្បច្ច័យ និងអនន្តរប្បច្ច័យ ។

អត្ថនៃចិត្តប្រការទី ២ ដែលមានសេចក្តីក្នុងអដ្ឋសាលិនីថា ម្យ៉ាងទៀតព្រោះហេតុមានសព្ទថា « ចិត្តំ » ទូទៅដល់ចិត្តគ្រប់ដួង ។ ដូច្នេះ ក្នុងពាក្យចិត្តំនេះ កុសលចិត្ត អកុសលចិត្ត និងមហាកិរិយាចិត្ត ចំណែកលោកិយទើបឈ្មោះថា **ចិត្តំ** ព្រោះសន្សំសន្តាននៃខ្លួនដោយអំណាច នៃជវនវិថី ។

ស្តាប់មើលទៅហាក់ដូចជារឿងយ៉ាប់លំបាក តែជារឿងពិតក្នុងជីវិតប្រចាំថ្ងៃ ។ ចំណែកលោកអ្នកភាគច្រើនក៏បានឮពាក្យថា កុសលចិត្ត អកុសលចិត្តជាធម្មតាហើយ តែនៅមិនទាន់ជ្រាបអំពី មហាកិរិយាចិត្ត ចំណែកលោកិយ និងជវនវិថីទេ ។ ចិត្តទាំងអស់ទោះជាមានច្រើនប្រភេទ ច្រើនប្រការយ៉ាងណាក៏ដោយ កាលបើចំណែកដោយការកើត ដោយជាតិ មាន ៤ ជាតិ គឺជាកុសលចិត្ត ១ ជាអកុសលចិត្ត ១ ជាវិបាកចិត្ត ១ ជាកិរិយាចិត្ត ១ (ភាសាបាលី គឺ**កុសលចិត្តំ អកុសលចិត្តំ វិបាកចិត្តំ កិរិយាចិត្តំ**) ។

ភាគច្រើនលោកអ្នករាល់គ្នាជ្រាបអំពីពាក្យថា កុសលចិត្ត និងអកុសលចិត្ត តែនៅមិនទាន់ជ្រាបពី វិបាកចិត្ត និងកិរិយាចិត្ត ។ កុសលចិត្ត ជាចិត្តដែលល្អ ដែលជាហេតុឱ្យកើតផល គឺកុសលវិបាក ក្នុងអនាគតខាងមុខ ។ ពេលកុសលចិត្ត និងកុសលចេតសិកកើតរួមគ្នា ដែលជាហេតុ

រលត់ទៅហើយ ធម៌ដែលជាកុសលក៏សន្សំបន្តក្នុងចិត្តដួង ត ៗ ទៅ ជាបច្ច័យឱ្យចិត្ត និងចេតសិកដែលជាកុសលវិបាកចិត្ត កុសលវិបាកចេតសិកកើតឡើងរួមគ្នាដោយផលនៃកុសលនោះៗ ។ ក្នុងអដ្ឋកថាមានសេចក្តីថា សូម្បីវិបាកចេតសិកកើតរួមនឹងចិត្ត តែព្រោះថា ចិត្តជាប្រធាន ទើបប្រើតែពាក្យថា វិបាកចិត្តប៉ុណ្ណោះ ដែលក៏សំដៅរួមដល់វិបាកចេតសិកដែលកើតរួមជាមួយដែរ និងសូម្បីពាក្យថាចិត្តជ្ជរូប គឺរូបដែលកើតព្រោះចិត្តជាបច្ច័យក៏ដូចគ្នា ។ ចិត្តជ្ជរូបកើតឡើងព្រោះចិត្ត និងចេតសិក កើតរួមគ្នាជាបច្ច័យ តែដែលប្រើពាក្យថា « ចិត្តជ្ជរូប » នោះក៏គឺសំដៅរួមដល់ចេតសិកដែលរួមនឹងចិត្តនោះ ។ ជាបច្ច័យឱ្យរូបនោះកើតដែរ ដូច្នេះ កាលណាពោលដល់វិបាកចិត្ត គឺរួមទាំងវិបាកចេតសិកដែលកើតរួមដែរ ។

អកុសលចិត្ត ជាសភាវធម៌ដែលជាទោស ជាសភាវធម៌ដែលជាហេតុឱ្យកើតផលជាទុក្ខ មិនជាទីពេញចិត្ត គឺអកុសលវិបាកចិត្តផ្សេង ៗ ។ ក្រៅពីកុសលចិត្ត និងអកុសលចិត្ត និងវិបាកចិត្តហើយ នៅមានចិត្តមួយប្រភេទទៀត **គឺកិរិយាចិត្ត មិនមែនជាហេតុដែលនឹងឱ្យកើតវិបាកឡើយ ទើបមិនមែនជាកុសលចិត្ត មិនមែនជាអកុសលចិត្ត មិនមែនជាវិបាកចិត្តផងដែរ ព្រោះកិរិយាចិត្តមិនមែនជាផលនៃកុសលចិត្ត ឬអកុសលចិត្តទេ ។**

ចិត្តទាំងអស់ចំណែកជាជាតិណាមួយក្នុង ៤ ជាតិ គឺ ជាកុសល ១ ជាអកុសល ១ ជាវិបាក ១ ឬ ជាកិរិយា ១ ។ បើមិនសិក្សាឱ្យ

ល្អិតល្អន់ឡើងទេក៏មិនអាចនឹងដឹងបានថា ខណៈណា ជាកុសលចិត្ត អកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ដូចខណៈបដិសន្ធិ ដែលជាចិត្តខណៈដំបូងដែលកើតឡើងក្នុងភពនេះ ក្នុងជាតិនេះ ដែលគ្រប់គ្នាមានជីវិតរស់នៅក្នុងខណៈនេះ ។ បដិសន្ធិចិត្ត ជាកុសលចិត្តមិនបាន ជាអកុសលចិត្តមិនបាន ខណៈដែលបដិសន្ធិចិត្តកើតឡើងនោះ មិនបានធ្វើកម្មណា ។ តាមផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្តឡើយ ។ **បដិសន្ធិចិត្តជាវិបាកចិត្តដែលកើតឡើង ព្រោះកម្មណាមួយជាបច្ច័យ** សូម្បីតែថាកម្មដែលបានធ្វើហើយក្នុងភពជាតិនីមួយ ។ និងច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណាក៏ដោយ **កម្មណាជាបច្ច័យឱ្យបដិសន្ធិចិត្ត ឬវិបាកចិត្តណាកើតឡើង កម្មនោះជាកម្មប្បច្ច័យ ដល់បដិសន្ធិចិត្ត និងវិបាកចិត្តនោះ** ។ បើកើតក្នុងមនុស្ស ជាសុគតិភូមិជាផលនៃកុសលកម្ម ឯចិត្តដែលបដិសន្ធិ គឺជាកុសលវិបាក ។ បើកើតក្នុងអបាយភូមិ គឺកើតក្នុងនរក ឬកើតជាប្រេតកើតជាអសុរកាយ កើតជាសត្វតិរច្ឆាន គឺជាផលនៃអកុសលកម្ម ចិត្តដែលបដិសន្ធិក្នុងអបាយភូមិ ក៏ជាអកុសលវិបាក ។

កាលណាបដិសន្ធិចិត្តរលត់ទៅកម្មនោះមិនគ្រាន់តែឱ្យបដិសន្ធិចិត្តកើតឡើងប៉ុណ្ណោះទេ ។ កាលណាបដិសន្ធិចិត្តរលត់ទៅ **កម្មតែមួយ ដែលជាបច្ច័យឱ្យបដិសន្ធិចិត្តកើតនោះ ក៏ជាកម្មប្បច្ច័យធ្វើឱ្យវិបាកចិត្ត ដួងតទៅកើតឡើង ធ្វើភវង្គកិច្ចបន្តពីបដិសន្ធិចិត្ត** ។ បដិសន្ធិចិត្ត គឺចិត្តដែលធ្វើកិច្ចបន្តពីចុតិចិត្តក្នុងជាតិមុនភ្លាម ។ នោះ ដែលចុតិចិត្តនៃជាតិមុនរលត់

កម្មមួយដែលធ្វើហើយនោះ ជាបច្ច័យឱ្យបដិសន្ធិចិត្តកើត ជាខណៈចិត្តដំបូងក្នុងជាតិនេះ បន្តពីចុតិចិត្តនៃជាតិមុន ហើយក៏រលត់ទៅ ហើយកម្មតែមួយនោះក៏ជាបច្ច័យឱ្យវិបាកចិត្តដួងត ៗ ទៅកើតឡើង ធ្វើភវង្គកិច្ច គឺកិច្ចតម្រង់ភពជាតិនៃភាពជាបុគ្គលនោះ បន្តទៅរហូតដល់ចុតិ គឺប្រែពីភពភូមិនេះ ផុតអស់នូវសភាពជាបុគ្គលនេះ ក្នុងជាតិនេះ និងកម្មដទៃ ៗ ក៏ជាបច្ច័យឱ្យវិបាកចិត្តផ្សេង ៗ កើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយបាន ។

កុសល គឺជាសភាវធម៌ដែលល្អស្អាត មិនជាទោសភ័យ ។ លោកអ្នកខ្លះយល់ថា លោកអាចនឹងធ្វើកុសលបានតែក្នុងពេលដែលមានទ្រព្យរបស់ មាសប្រាក់ប៉ុណ្ណោះ តែភ្លេចនូវសេចក្តីសន្តោសករុណា សូម្បីដល់មិនមានប្រាក់ ប៉ុន្តែបើមានរបស់របរដែលល្មមនឹងបែងចែក រំលែកឱ្យដើម្បីជួយសង្គ្រោះអ្នកដទៃនោះបាន តើលោកនឹងរំលែកឱ្យដើម្បីជួយអ្នកដទៃនោះបានឬទេ ? បើលះបង់ឱ្យមិនបាន ខណៈនោះ តើជាកុសល ឬអកុសល ? អ្នកដែលមិនដឹងថា កុសលចិត្តជាចិត្តដែលល្អស្អាត មិនមានទោស ក៏អាចនឹងគិតដោយសៅហ្មងចិត្តថា លោកអត់មានប្រាក់លោកធ្វើបុណ្យមិនបាន ។ ប៉ុន្តែតាមសេចក្តីពិតនោះ សូម្បីដល់ថា មិនមានប្រាក់នឹងធ្វើកុសល ក៏មានកុសលដទៃទៀតជាច្រើនដែលអាចធ្វើបានដែរ ដូចខណៈដែលមានសភាពជាមិត្តភាព មេត្តានឹងបុគ្គលដទៃ មានចិត្តទន់ភ្លន់ មានការនិយាយ ពាក្យផ្អែមល្ហែមដោយសុទ្ធចិត្ត ។ ពេលសង្គ្រោះ

សន្តោសករុណា ជួយយកអាសា ចែករំលែក ខណៈនោះ ជាកុសល ជាសភាវធម៌ដែលមិនមានទោស ភយន្តរាយណា ។ ឡើយ ។

ខណៈណាដែលមានមាន: ប្រកាន់ខ្លួនថា ខ្ពស់ជាង ល្អជាង ពូកែ ឬប្រសើរជាងបុគ្គលដ៏ទៃ ឬសូម្បីតែមានការបែងចែកជាគេ ជាយើង មិនជួយសង្គ្រោះ មិនករុណា ឧបត្ថម្ភ ខណៈនោះជាអកុសលចិត្ត ជាចិត្តដែលមិនល្អស្អាត ជាសភាវធម៌ដែលជាទោស ។

កាលណាយល់លក្ខណៈនៃកុសលពិត ។ ហើយ ក៏ចម្រើនកុសល គ្រប់ប្រការបាន សូម្បីមិនមានទ្រព្យសម្បត្តិ មាសប្រាក់ របស់អ្វីនឹងឱ្យ ក៏ដោយ ក៏នៅមានវត្ថុបន្តិចបន្តួច ដែលល្មមនឹងបរិច្ចាគឱ្យបានដែរ ។ តែ បើពិតជាបរិច្ចាគឱ្យមិនបានទេនោះ គឺជាមនុស្សដែលហួងហែង ប៉ុន្តែគិត ឱ្យចិត្តស្ងប់ ឬចង់អស់កិលេស ជាព្រះសោតាបន្ន តើនឹងអាចលះបង់ ឱ្យរបស់របរដល់អ្នកដទៃបានខ្លះទេ ? បុគ្គលម្នាក់ ។ សន្សំកុសល និងអកុសលមកផ្សេង ។ គ្នា ដូច្នេះ ទើបគួរពិចារណាចិត្តនៃខ្លួនឯងថា ជាអ្នកនៅហួងហែងទ្រព្យសម្បត្តិខ្លាំង ឬក៏ថាផ្តើមបរិច្ចាគលះបង់ទ្រព្យ សម្បត្តិឱ្យជាប្រយោជន៍ដល់អ្នកដទៃខ្លះ ។ ហើយ បន្តិចម្តង ។ រហូតដល់ មានឧបនិស្ស័យ ជាបច្ច័យឱ្យមានកម្លាំង ធ្វើឱ្យលះបង់ការប្រកាន់ស្អិត នូវនាមធម៌ និងរូបធម៌ជាតួខ្លួន រហូតដល់បញ្ញាចម្រើនចាស់ក្លាហើយនោះ ក៏ដឹងច្បាស់នូវនិព្វានបាន ។ អ្នកដែលគិតថាចង់អស់កិលេសនោះ ពេល ដែលកិលេសកើតឡើង ក៏នៅតែពេញចិត្តនឹងឱ្យកិលេសនោះមាននៅជា

និច្ច ដូចខណៈដែលមានមានៈ សេចក្តីប្រកាន់ខ្លួន ភាពឫស្យា បើមានអ្នក ណានឹងប្រាប់ឱ្យលះបង់ទៅ គួរត្រេកអរនឹងសេចក្តីសុខ អ្នកដទៃគួរមេត្តា ដល់បុគ្គលអាក្រក់ តើលោកនឹងធ្វើបានទេ ? អ្នកដែលមានឆន្ទៈ គឺពេញចិត្ត នឹងខឹងក្រោធ មើលងាយ វាយឫក ឫស្យាក៏រមែងមិនអាចនឹងធ្វើបានដែរ ។ ដូច្នេះ ការលះកិលេស ទើបមិនមែនសភាវៈដែលនឹងធ្វើបានភ្លាម ។ នោះទេ គឺត្រូវប្រព្រឹត្ត ប្រតិបត្តិ ទៅសន្សឹម ។ អប់រំឱ្យកើតឡើងបន្តិចម្តង ។ ទើបបាន ។ អ្វីដែលត្រូវការរំលត់កិលេសពិត ។ នោះ គឺត្រូវដឹងថាត្រូវ អប់រំចម្រើនកុសល គ្រប់ប្រការមិនមែនបំពេញតែទានម្យ៉ាង ហើយហួង ហែងរក្សាទុកនូវអកុសលដទៃទៀតនោះទេ ។ លោកអ្នកខ្លះក៏ចង់ស្ងប់ ព្រោះដឹងថាមួយថ្ងៃ ។ រសាប់រសល់ ក្រវល់ក្រវាយពេក គិតរឿងនោះក៏ខឹង គិតរឿងនេះ ក៏កង្វល់ មានតែរឿងក្តៅក្រហាយ រំខានចិត្តពីព្រោះអ្វី ? ពី ព្រោះមិនបានពិចារណាចិត្តក្នុងខណៈនោះ តែទៅជាពិចារណា បុគ្គល ដែលលោកអ្នកខឹងក្រោធវិញ ការពិចារណាបុគ្គលដទៃ ក៏ធ្វើឱ្យកើត អកុសល ចិត្តក៏រមែងរសាប់រសល់ ក្រវល់ក្រវាយ ក្តៅក្រហាយ បានដឹង ដែរថាកំពុងក្តៅក្រហាយ គឺពិបាកនឹងស្ងប់ តែមិនដឹងថា បើមិនក្រោធខឹង ខណៈនោះ ក៏មិនក្តៅក្រហាយដែរ ។ ខណៈក្រោធខឹងមិនសប្បាយចិត្ត ក្តៅក្រហាយចិត្ត កង្វល់ចិត្តនោះ ជាអកុសល ជាសភាវៈដែលជាទោស ។

ដូច្នេះ បើខណៈណាក្រោធខឹង ហើយរលឹកបាន ពិចារណាបុគ្គល ដទៃក្នុងផ្លូវដែលធ្វើឱ្យកើតមេត្តាខ្លះ ករុណាខ្លះ មុទិតាខ្លះ ឧបេក្ខាខ្លះ

ក៏រមែងស្ងប់បានភ្លាម ព្រោះខណៈដែលចិត្តមានមេត្តា លោភៈ ទោសៈ មោហៈមិនមាន ឬខណៈដែលចិត្តមានករុណា មុទិតា ឬឧបេក្ខានោះ ជាកុសល ប្រាសចាកលោភៈ ទោសៈ មោហៈ ទើបស្ងប់ កុសលចិត្ត គ្រប់ខណៈស្ងប់ ។ ដូច្នេះ នៅពេលដែលត្រូវការរំលត់កិលេស ទើបត្រូវចម្រើនកុសលគ្រប់ប្រការ មិនមែនត្រឹមតែទានកុសលប៉ុណ្ណោះទេ ។

សេចក្តីក្នុងអដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណីបករណ ចិត្តុប្បាទកណ្ឌ សម្តែងលក្ខណៈនៃចិត្តប្រការទី ២ ថា ម្យ៉ាងទៀត ព្រោះហេតុ សព្ទថា **ចិត្តំ** នេះទូទៅដល់ចិត្តគ្រប់ដួង ដូច្នេះ ក្នុងពាក្យថា « ចិត្តំ » នេះជាលោកិយ កុសលចិត្ត អកុសលចិត្ត និងមហាកិរិយាចិត្ត ទើបឈ្មោះ ថា « ចិត្ត » ព្រោះសន្សំសន្តានរបស់ខ្លួនដោយអំណាចនៃជវនវិថី ។

ពាក្យថា **សន្តាន** ក្នុងភាសាខ្មែរមកពីពាក្យក្នុងភាសាបាលីថា « សន្តាន » ឬ « សន្តតិ » ដែលសំដៅដល់ការកើត រលត់បន្តគ្នា ។ ចិត្តឃើញ ចិត្តឮ ចិត្តធុំក្លិន ចិត្តដឹងរស ចិត្តដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ជាវិបាកចិត្ត មិនមែនកុសលចិត្ត និងមិនមែនអកុសលចិត្ត ទើបមិនសន្សំសន្តាន ។ ចិត្តឃើញ ចិត្តឮ ចិត្តធុំក្លិន ចិត្តដឹងរស ចិត្តដឹងនូវអ្វីដែលប៉ះខ្ទប់សម្ផស្ស គឺជាផលនៃអតីតកម្ម ។ ពេលកម្មណាទុំជោរព្រមល្មមនឹងឱ្យផល គឺប្រកបព្រមដោយបច្ច័យផ្សេង ៗ ក៏ធ្វើឱ្យវិបាកចិត្តប្រភេទផ្សេង ៗ កើតឡើង ធ្វើកិច្ចផ្សេង ៗ ដូចឃើញ ឮ ជាដើម ។ វិបាកចិត្តមិនសន្សំសន្តាន ព្រោះក្នុងខណៈវិបាកចិត្តនីមួយ ៗ កើតឡើង គឺដោយកុសលកម្ម ឬ

អកុសលកម្ម ដែលសន្សំមកហើយនោះ ជាបច្ច័យឱ្យកើតឡើង ។ **កាលវិបាកចិត្តកើតឡើង និងរលត់ទៅហើយ ក៏មិនជាហេតុឱ្យវិបាកណា ៗ កើតឡើងឡើយ ។**

ដើម្បីនឹងយល់លក្ខណៈនៃចិត្ត ប្រការទី ២ ដែលថាលោកិយកុសលចិត្ត អកុសលចិត្ត និងមហាកិរិយាចិត្ត ទើបឈ្មោះថា ចិត្តព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថីនោះ ក៏ត្រូវយល់នូវវិថីចិត្តមុនថា វិថីចិត្ត គឺចិត្តប្រភេទណាកើតឡើងពេលណា ហើយនឹងត្រូវយល់នូវ**ជវនវិថី ដែលជាខណៈនៃចិត្តសន្សំសន្តាននៃខ្លួន ដែលជាកុសលខ្លះ អកុសលខ្លះ និងសម្រាប់ព្រះអរហន្ត ក៏ជាមហាកិរិយាចិត្តផ្នែកលោកិយ** ព្រោះសូម្បីថាជាព្រះអរហន្តហើយ ក៏ជាព្រះអរហន្ត ដែលមានកាយ វាចា ចិត្តផ្សេង ៗ គ្នា តាមការសន្សំសន្តាននៃខ្លួនដែរ ។

ដូច្នេះ ទើបត្រូវយល់អត្ថន័យនៃវិថីចិត្តជាមុនថា វិថីចិត្ត គឺជាចិត្តដែលមិនមែនបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត **ចិត្តណាក៏ដោយដែលមិនមែនបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្តហើយ ជាវិថីចិត្តទាំងអស់ ។** ក្នុងមួយជាតិ បដិសន្ធិចិត្តកើតឡើងតែមួយខណៈ គឺខណៈដែលធ្វើបដិសន្ធិកិច្ចបន្តពីចុតិចិត្តនៃជាតិមុន ត្រឹមតែមួយខណៈប៉ុណ្ណោះ ដែលជាបដិសន្ធិចិត្ត ។ ខណៈដែលចិត្តធ្វើបដិសន្ធិកិច្ចនោះមិនឃើញ មិនបានឮ មិនបានធុំក្លិន មិនដឹងរស មិនដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សណា ៗ

ទាំងអស់ ។ បដិសន្ធិ ជាវិបាកចិត្ត ជាផលនៃកម្ម បដិសន្ធិចិត្ត ដែលកើត ក្នុងភូមិមនុស្ស ជាកុសលវិបាកចិត្ត ជាផលនៃកុសលកម្ម ។

កាលណាបដិសន្ធិចិត្តរលត់ទៅហើយ កម្មមិនបានឱ្យផល ត្រឹមតែ ធ្វើឱ្យបដិសន្ធិចិត្ត កើតឡើងប៉ុណ្ណោះទេ តែជាបច្ច័យឱ្យវិបាកចិត្តប្រភេទតែ មួយដូចគ្នាកើតឡើងធ្វើភវង្គកិច្ច បន្តតម្រង់ភពជាតិនៃភាពជាបុគ្គលនោះ លុះរហូតដល់ចុតិ ។

ខណៈដែលនៅមិនទាន់ចុតិនោះ **ភវង្គចិត្ត កើតរលត់ ៗ ធ្វើ កិច្ចបន្តតម្រង់ទុកភាពជា បុគ្គលនោះ ក្នុងខណៈដែលមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈប៉ះខ្ទប់សម្ផស្ស និងមិននឹកគិត ។** ដូច្នេះ ខណៈណាដែលជាបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្តនោះ ខណៈនោះមិនមែនវិថីចិត្ត ។ ខណៈដេកលក់យ៉ាងស៊ប់ មិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈប៉ះខ្ទប់សម្ផស្ស មិនបានគិតនឹក អ្វីឡើយ តែភវង្គចិត្តកើត រលត់បន្តគ្នាទៅជារឿយ ៗ ទម្រាំនឹងដល់យល់ សប្តិ ឬភ្ញាក់ឡើងឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស នឹកគិតអារម្មណ៍ផ្សេង ៗ ក្នុងលោកនេះក៏ប្រាកដឡើង ។ **ខណៈ វិបាកចិត្តកើតឡើង ធ្វើបដិសន្ធិកិច្ច និងភវង្គកិច្ចនោះ អារម្មណ៍ផ្សេង ៗ ក្នុង លោកនេះមិនប្រាកដឡើយ ។** លោកនេះជាលោកមនុស្ស លក្ខណៈយ៉ាង ណាក៏មិនប្រាកដទាំងអស់ ។ បើខណៈនេះ អ្នកណាកំពុងដេកលក់ ក៏នឹងមិនអាចដឹង មិនអាចឃើញទេថាក្នុងទីនេះមានអ្នកណាខ្លះ មាន

សំឡេងអ្វីខ្លះ មានក្លិនអ្វីខ្លះ ក្តៅ ត្រជាក់ ដោយប្រការណាឡើយ លោកនេះមិនប្រាកដជាមួយនឹងបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្តឡើយ ។ ពេលមិនដេកលក់ ក៏ចាំរឿងលោកនេះ ចាំបុគ្គលផ្សេង ។ រឿងរ៉ាវផ្សេង ។ ក្នុងលោកនេះតែខណៈដែលលក់ស៊ប់ហើយជាភវង្គចិត្ត កាត់ផ្តាច់ចាកពីអារម្មណ៍ផ្សេង ។ ដែលប្រាកដក្នុងលោកទាំងអស់ សូម្បីថា ខ្លួនឯងជានរណា នៅទីណា ជាញាតិមិត្តនឹងអ្នកណា មានទ្រព្យសម្បត្តិ យសសក្តិ សុខ ទុក្ខយ៉ាងណា ក៏មិនដឹងដែរ ។

ខណៈឃើញ មិនមែនភវង្គចិត្ត ជាវិថីចិត្តដែលកើតឡើងឃើញ នូវអ្វីដែលប្រាកដតាមផ្លូវភ្នែក ។ ចិត្តណាក៏ដោយ ដែលកើតឡើងឃើញ ឬដឹង ឬត្រេកអរពេញចិត្ត ក្នុងសភាវៈដែលកំពុងប្រាកដ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ចិត្តខណៈនោះ ។ ជាវិថីចិត្ត ។ ខណៈណាឮសំឡេង ហើយពេញចិត្ត ឬមិនពេញចិត្ត ខណៈនោះមិនមែនជាភវង្គចិត្ត ខណៈនោះជាវិថីចិត្ត ។ ចិត្តគ្រប់ខណៈដែលកើតឡើងដឹងរូបដែលប្រាកដតាមផ្លូវភ្នែក ជាចក្ខុទ្វារវិថីចិត្ត ចិត្តគ្រប់ខណៈដែលកើតឡើងដឹងសំឡេងតាមផ្លូវត្រចៀក ជាសោតទ្វារវិថីចិត្ត ចិត្តគ្រប់ខណៈដែលកើតឡើងដឹងក្លិនតាមផ្លូវច្រមុះ ជាឃានទ្វារវិថីចិត្ត ចិត្តគ្រប់ខណៈដែលកើតឡើងដឹងរសតាមផ្លូវអណ្តាត ជាជិវ្ហាទ្វារវិថីចិត្ត ចិត្តគ្រប់ខណៈដែលកើតឡើងដឹងអារម្មណ៍ដែលប៉ះខ្ទប់កាយ ជាកាយទ្វារវិថី

ចិត្ត ចិត្តគ្រប់ខណៈដែលកើតឡើងដឹងអារម្មណ៍តាមផ្លូវចិត្ត ជាមនោទ្វារ វិថីចិត្ត ។

នាមធម៌ដែលកើត រលត់ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ជាភវង្គចិត្ត ដែលកើត រលត់ផ្លាស់ប្តូរ នឹងវិថីចិត្ត ដែលកើតឡើងដឹងអារម្មណ៍ តាមទ្វារ ផ្សេង ៗ ។

កាលបដិសន្ធិក្នុងភូមិដែលមានខន្ធ ៥ គឺក្នុងភូមិដែលមានទាំង រូបក្ខន្ធ និងនាមខន្ធ កម្ម ជាបច្ច័យធ្វើឱ្យកម្មជ្ជរូប គឺចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូបជាដើម កើត រលត់ បន្តតម្រង់សភាពដែលមិនមែនជាបុគ្គលខ្វាក់ភ្នែក ត្រចៀកថ្លង់ ជាដើម ។ តែបើខណៈណាកម្មមិនជាបច្ច័យឱ្យចក្ខុបសាទរូបកើតទេ បុគ្គល នោះក៏ខ្វាក់ភ្នែកមើលមិនឃើញអ្វីឡើយ ដូច្នេះ ចិត្តឃើញ និងចិត្ត ដទៃគ្រប់ខណៈ នឹងកើតឡើងបាន ក៏ត្រូវអាស្រ័យបច្ច័យ ដែលធ្វើឱ្យ កើតចិត្តនោះ ៗ ។ ខណៈដែលវិថីចិត្តមិនទាន់កើតឡើងនោះ ភវង្គចិត្តកើត រលត់បន្តគ្នានៅជារឿយ ៗ ។

នៅពេលរូបណាកើតឡើងប៉ះខ្ទប់នឹងបសាទរូបណា និងខណៈ នៃភវង្គណា វិថីចិត្តនឹងកើតឡើងភ្លាម ៗ នោះមិនបានឡើយ ។ **ប៉ុន្តែដើម្បី កំណត់ឱ្យដឹងថា រូបកើតឡើងប៉ះខ្ទប់ភវង្គចិត្តខណៈណា ទើបបញ្ញត្តិ ភវង្គចិត្ត ដែលរូបកើតឡើងប៉ះខ្ទប់នោះថា អតីតភវង្គ** គឺជាភវង្គដែល ដូចនឹងភវង្គមុន ៗ សូម្បីតែថា រូបកើតរលត់រហ័សយ៉ាងណា ក៏ដោយ

តែចិត្តក៏កើត រលត់រហ័សជាងរូបទៅទៀត ។ សភាវរូប ១ កើត រលត់ ស្មើនឹងចិត្តកើត រលត់ ១៧ ខណៈ ។ ដូច្នេះ អតីតភវង្គ គឺខណៈដែលរូបកើតឡើងប៉ះខ្ទប់នឹងបសាទរូប ។ **ទាំងនេះ ដើម្បីឱ្យដឹងថា រូបដែលប៉ះខ្ទប់បសាទរូប ហើយនិងប៉ះខ្ទប់នឹងអតីតភវង្គនោះ នឹងរលត់នៅពេលណា** ព្រោះរូប ១ មានអាយុត្រឹមតែចិត្ត កើត រលត់ ១៧ ខណៈប៉ុណ្ណោះ ។ កាលណាអតីតភវង្គរលត់ទៅហើយ ក៏ជាបច្ច័យឱ្យភវង្គចិត្តដួងតទៅញ៉ាំរជា **ភវង្គចលនៈ** ដែលនៅតែជាភវង្គ ព្រោះវិថីចិត្តនឹងកើតឡើងខណ្ឌខ្សែនៃភវង្គភ្លាមមិនបានឡើយ កាលភវង្គចលនៈរលត់ទៅហើយ ភវង្គចិត្តដែលកើត ត ជា**ភវង្គុប្បច្ឆេទៈ គឺជាភវង្គចិត្តដួងដែលកាត់ផ្តាច់ខ្សែនៃភវង្គ ព្រោះជាភវង្គចិត្តដួងក្រោយបំផុតនៃក្រសែភវង្គ ។** នៅពេលភវង្គុប្បច្ឆេទៈរលត់ទៅហើយ វិថីចិត្តកើតឡើងដឹងអារម្មណ៍ដែលប្រាកដតាមផ្លូវភ្នែក ឬតាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តបាន ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវភ្នែកជាចក្ខុទ្វារវិថីចិត្ត ព្រោះដឹង**រូបារម្មណ៍** (សភាវៈដែលប្រាកដតាមផ្លូវភ្នែក) ដែលប៉ះខ្ទប់នឹងចក្ខុបសាទដែលនៅមិនទាន់រលត់ ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវត្រចៀកជាសោតទ្វារវិថីចិត្ត ព្រោះដឹង **សទ្ទារម្មណ៍** (សំឡេង) ដែលប៉ះខ្ទប់នឹងសោតបសាទ និងដែលនៅមិនទាន់រលត់ ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវច្រមុះជាឃានទ្វារវិថីចិត្ត ព្រោះដឹង **គន្ធារម្មណ៍** (ក្លិន) ដែលប៉ះខ្ទប់នឹងឃានបសាទ និងដែលនៅមិនទាន់រលត់ ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវអណ្តាតជាជិវ្ហាទ្វារវិថីចិត្ត ព្រោះដឹង **រសារម្មណ៍** (រស) ដែលប៉ះខ្ទប់នឹងជិវ្ហាបសាទ និងដែលនៅមិនទាន់រលត់ ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវកាយជាកាយទ្វារវិថីចិត្ត ព្រោះដឹង **ផោដ្ឋព្វារម្មណ៍** (ក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ) ដែលប៉ះខ្ទប់នឹងកាយបសាទ និងដែលនៅមិនទាន់រលត់ ។

វិថីចិត្តគ្រប់ខណៈ តាមផ្លូវចិត្តដែលជាមនោទ្វារវិថីចិត្ត ដឹង **អារម្មណ៍ បានគ្រប់អារម្មណ៍** គឺដឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ តអំពីវិថីចិត្តដែលដឹងតាមផ្លូវបញ្ចទ្វារ និងដឹង**ធម្មារម្មណ៍ គឺអារម្មណ៍ដែលអាចដឹងបានចំពោះតែតាមផ្លូវចិត្ត គឺមនោទ្វារ ទ្វារតែមួយប៉ុណ្ណោះ ។**

អារម្មណ៍ទាំងអស់ចែកជា ៦ អារម្មណ៍ដែលចិត្តដឹងបានតាម ទ្វារ ៦ ដូច្នេះ គឺ

រូបារម្មណ៍ ចិត្តដឹងបានតាមចក្ខុទ្វារ និងតាមមនោទ្វារ
សទ្ទារម្មណ៍ ចិត្តដឹងបានតាមសោតទ្វារ និងតាមមនោទ្វារ
គន្ធារម្មណ៍ ចិត្តដឹងបានតាមឃានទ្វារ និងតាមមនោទ្វារ
រសារម្មណ៍ ចិត្តដឹងបានតាមជិវ្ហាទ្វារ និងតាមមនោទ្វារ
ផោដ្ឋព្វារម្មណ៍ ចិត្តដឹងបានតាមកាយទ្វារ និងតាមមនោទ្វារ
ធម្មារម្មណ៍ ចិត្តដឹងបានតាមមនោទ្វារ ត្រឹមតែ ១ ទ្វារ ។

មនោទ្វារវិថីចិត្ត ដឹងអារម្មណ៍បានទាំង ៦ អារម្មណ៍ តែ ធម្មារម្មណ៍នោះ ដឹងបានចំពោះតែមនោទ្វារវិថីចិត្តប៉ុណ្ណោះ ។

ចិត្តគ្រប់ដួងកើតឡើងធ្វើកិច្ចណាមួយ ហើយក៏រលត់ទៅ គឺបដិសន្ធិចិត្តធ្វើបដិសន្ធិកិច្ច បន្តពីចុតិចិត្តនៃជាតិមុន ត្រឹមតែ ១ ខណៈប៉ុណ្ណោះ ។ ភវង្គចិត្តគ្រប់ដួង ទាំងអតីតភវង្គ ភវង្គចលនៈ ភវង្គុប្បច្ឆេទៈ ធ្វើភវង្គកិច្ច បន្តតម្រង់ទុកភពជាតិនោះ ។ កាលភវង្គុប្បច្ឆេទរលត់ទៅហើយ វិថីចិត្តដួងដំបូងដែលកើតតអំពីភវង្គុប្បច្ឆេទៈធ្វើ**អាវជ្ជនកិច្ច** ប្រែដោយសព្ទ គឺរំពឹងនូវអារម្មណ៍ដែលប្រាកដត្រង់ទ្វារ គឺដឹងអារម្មណ៍ដែលប៉ះខ្ទប់ទ្វារ ។ ឈ្មោះថា អាវជ្ជនៈ ព្រោះអត្ថថា នាំចេញទៅពីសន្តាន (ការកើត រលត់បន្ត) ដែលជាភវង្គ គឺបង្អោនទៅដល់អារម្មណ៍ដែលប៉ះខ្ទប់ទ្វារ ។ **បើជាផ្លូវបញ្ចទ្វារ គឺ**

ផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ បញ្ចទ្វារវជ្ជនចិត្ត ដែលជាចិត្ត ១ ដួង (**មួយប្រភេទ**) **កើតឡើងធ្វើអាវជ្ជនកិច្ច** រំពឹងដល់អារម្មណ៍ដែលប៉ះខ្ទប់ទ្វារណាមួយ ក្នុងទ្វារទាំង ៥ តែនៅមិនទាន់ ឃើញ មិនទាន់ឮ មិនទាន់ធុំក្លិន មិនទាន់ដឹងរស មិនទាន់ដឹងសភាវៈប៉ះខ្ទប់កាយទេ ។ បើជាផ្លូវមនោទ្វារ គឺផ្លូវចិត្ត ដែលមិនមែនជាផ្លូវចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ « **មនោទ្វារវជ្ជនចិត្ត** » ដែលជាចិត្ត ១ ដួងទៀត (**មិនមែនបញ្ចទ្វារវជ្ជនចិត្ត**) **កើតឡើងធ្វើអាវជ្ជនកិច្ច ចំពោះតែផ្លូវមនោទ្វារ ទ្វារតែមួយប៉ុណ្ណោះ** ។

តួយ៉ាងដូចពេលរសកើតឡើងប៉ះខ្ទប់នឹងជិវ្ហាបសាទ ហើយនិងប៉ះខ្ទប់នឹងភវង្គ ជា**អតីតភវង្គ** រលត់ទៅ **ភវង្គចលនៈ** កើតហើយរលត់ទៅ **ភវង្គុប្បច្ឆេទៈ** កើតតហើយរលត់ទៅ **បញ្ចទ្វារវជ្ជនចិត្ត** កើតរំពឹង គឺដឹងថាអារម្មណ៍ប៉ះខ្ទប់ជិវ្ហាទ្វារតែនៅមិនទាន់ដឹងរសនោះទេ ឧបមា ដូចខណៈដែលដឹងថាមានភ្ញៀវមកត្រង់ទ្វារ តែនៅមិនទាន់ឃើញភ្ញៀវ ទើបនៅមិនទាន់ដឹងថាជាអ្នកណា ត្រឹមតែដឹងថាមានភ្ញៀវមកប៉ុណ្ណោះ ។ លោកគ្រប់គ្នារមែងមានភ្ញៀវមករក ពេលគិតដល់ភ្ញៀវ ក៏រមែងតែងនឹកគិតដល់មនុស្ស តែតាមសេចក្តីពិតភ្ញៀវគឺអារម្មណ៍ផ្សេង ៗ ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត នោះឯង ។ ខណៈឃើញសភាវៈ (អ្វី) ដែលប្រាកដតាមផ្លូវភ្នែក ឯសភាវៈដែលប្រាកដតាមផ្លូវភ្នែកជាភ្ញៀវ ខណៈណាបានឮសំឡេង សំឡេងនោះជាភ្ញៀវ ខណៈមិនបានឮ

សំឡេងនោះមិនប្រាកដ ភ្ញៀវតាមផ្លូវត្រចៀក ទើបនៅមិនទាន់មក ។ ខណៈដែលរសប្រាកដ រសជាភ្ញៀវប្រាកដតាមផ្លូវអណ្តាត ១ ជួរខណៈ ហើយក៏រលត់ទៅ ។ ខណៈណាដែលអារម្មណ៍ប្រាកដតាមទ្វារណា ខណៈនោះអារម្មណ៍នោះគឺជាភ្ញៀវនៃទ្វារនោះ ១ ជួររយៈដ៏ខ្លីជាទីបំផុត ហើយក៏រលត់អស់ទៅមិនត្រឡប់មកកើតទៀតឡើយ ក្នុងសង្សារវដ្ត ។ លោកតាចាស់ ។ ខ្លះ មានភាពអផ្សុក ព្រោះកាលពីនៅក្មេងមិនទាន់ចាស់ លោកធ្លាប់ជួបប្រសព្វនឹងបុគ្គល មិនចន្លោះមុខ ឬថាគ្រប់ប្រភេទ តែងសប្បាយរីករាយនឹងញាតិមិត្តសំឡាញ់ តែដល់ពេលចាស់ឡើង ភ្ញៀវមិត្តសំឡាញ់ទាំងនោះស្លាប់ បាត់បង់ទៅម្តងម្នាក់ ។ ពេលសួរលោក តាចាស់ ។ ថា លោកតាចូលចិត្តអ្វីជាងគេបំផុត លោកតាខ្លះក៏ឆ្លើយថា គាត់ចូលចិត្តមនុស្ស គឺមនុស្សដែលមកនិយាយ ជជែកគ្នាលេង គ្រាន់បានសប្បាយរីករាយ ។ តែសេចក្តីពិតមនុស្សគ្រប់គ្នាមានភ្ញៀវគ្រប់ខណៈ ។ ដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងសម្ផស្ស និងតាមធម្មតានោះ ពេលភ្ញៀវមក លោភមូលចិត្តក៏កើតឡើង ត្រេកអរ ពេញចិត្ត ក្នុងអ្វីដែលកំពុងប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ នោះ ។ ។

ភ្ញៀវមានច្រើនប្រភេទ បើជាចោរកាចសាហាវ ក៏មិនមាននរណាត្រូវការភ្ញៀវប្រភេទនោះដែរ តែបើជាញាតិមិត្ត សំឡាញ់ក៏ទន្ទឹងរង់ចាំថាកាលណានឹងមក តែសេចក្តីពិតអារម្មណ៍ទាំងឡាយដែលប្រាកដតាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ត្រឹមតែជារូបធម៌ មិនមានចេតនាអាក្រក់

ជាមួយនរណាឡើយ ព្រោះរូបធម៌មិនមែនជាសភាពដឹង ។ ដូច្នេះ ភ្ញៀវ ដែលនឹងជាចោរ ឬជាញាតិមិត្តនោះក្នុងខណៈណា ? ក្នុងខណៈដែលអារម្មណ៍ណាប្រាកដ ហើយត្រេកអរពេញចិត្តជាប់ជំពាក់ក្នុងអារម្មណ៍នោះ ចោរក៏នៅត្រង់ទីនោះ ព្រោះសេចក្តីត្រេកអរ ពេញចិត្ត ជាប់ជំពាក់ ជាអកុសលធម៌ មិនមែនជាមិត្តនឹងអ្នកណាឡើយ ។ កុសលធម៌ហាក់ដូចជាញាតិ មិត្តដ៏ជិតស្និទ្ធដែលចាំតែឧបការឧបត្ថម្ភ ទ្រទ្រង់ អនុគ្រោះជួយសង្គ្រោះមិនថាក្នុងយាមណាទាំងអស់ ដូច្នេះ ទើបត្រូវដឹងលក្ខណៈនៃចិត្តដែលផ្សេង ៗ គ្នា គឺអកុសលចិត្តជាទោស ជាចោរ មិនមែនជាមិត្ត ។

កាលណាគិតដល់ចោរកាចសាហាវរមែងខ្លាច និងមិនចង់ឱ្យមកជាភ្ញៀវឡើយ តែចោរ គឺអកុសលចិត្តដែលជាហេតុឱ្យមានភ្ញៀវ ដែលជាចោរក្នុងថ្ងៃមុខ ចំណែកកុសលចិត្ត ក៏ប្រៀបដូចជាញាតិមិត្តដែលជាហេតុនាំមកភាពជាញាតិមិត្តសំឡាញ់ក្នុងថ្ងៃមុខផងដែរ ។

ដូច្នេះ រូបធម៌ទើបមិនមែនជាហេតុ រូបធម៌មិនមែនជាសភាពដឹង ទើបមិនមានចេតនាណា ៗ ទាំងអស់ ។ សំឡេងដែលប្រាកដ មិនមែនសភាពដឹងដែលត្រូវការឱ្យអ្នកណាឮ ឬមិនត្រូវការឱ្យអ្នកណាឮនោះទេ មិនអាចជ្រើសរើសដោយស្រឡាញ់ច្រើន ដោយស្អប់ថា ឱ្យអ្នកនេះឮ មិនឱ្យអ្នកនេះឮនោះឡើយ ។ សំឡេង ជារូបធម៌ដែលកើតឡើង តាមបច្ច័យដែលធ្វើឱ្យកើតសំឡេងនោះ និងស្រេចតែសោតបសាទនៃអ្នកណាដែលប៉ះខ្ទប់នឹងសំឡេងណាប៉ុណ្ណោះ ។ ជួនអ្នកខ្លះដេកលក់ស៊ប់មិនបាន

ឮសំឡេងផ្គរលាន់ក្នុងក្តាំងគួរឱ្យខ្លាចឡើយ សំឡេងផ្គរលាន់នោះ ទើបមិនមែនជាភ្ញៀវរបស់បុគ្គលនោះ ប៉ុន្តែជាភ្ញៀវរបស់អ្នកដែលសន្សំហេតុដែលធ្វើឱ្យសោតបសាទប៉ះខ្ទប់នឹងសំឡេងនោះ ។ ដូច្នេះ ខណៈណាដែលអារម្មណ៍ណាកើតឡើងជាភ្ញៀវនៃបុគ្គលណា តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រមែងប្រព្រឹត្តតាមហេតុបច្ច័យ គឺកម្មដែលបុគ្គលសន្សំមកជាបច្ច័យឱ្យវិបាកចិត្តកើតឡើងដឹងអារម្មណ៍នោះ ។ ។

ដូច្នេះ ភ្ញៀវដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនោះ គឺជារូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលកើតឡើងប្រាកដ ១ ជួរខណៈ ហើយក៏រលត់សូន្យអស់ទៅមិនត្រឡប់មកទៀតឡើយ រកថាជាសត្វ បុគ្គល តួខ្លួន វត្ថុណា ។ មិនបានទេ និងក្នុង ១ ថ្ងៃ ។ ក៏មិនមានអ្នកណាដឹងបានថា ភ្ញៀវណានឹងមកតាមផ្លូវណា និងពេលណាដែរ ។

ខណៈណាដែលចិត្តកំពុងដឹងអារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ខណៈនោះជាវិថីចិត្ត ។ បញ្ចទ្វារវជ្ជនចិត្ត ជាវិថីប-ដិបាទក គឺជាវិថីចិត្តដំបូង ដែលកើតឡើងតពីភវង្គុប្បច្ឆេទៈ ធ្វើអាវជ្ជនកិច្ច គឺ ត្រឹមតែដឹងថាអារម្មណ៍ណាមួយ ប៉ះខ្ទប់ទ្វារណាមួយ ក្នុងទ្វារទាំង ៥ ប៉ុណ្ណោះ ទើបមិនមែនចិត្តដែលធ្វើកិច្ចឃើញ ។ល។ **វិថីចិត្តដទៃ ។ នឹងកើតឡើងតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត ផ្លូវកាយមិនបានឡើយ បើបញ្ចទ្វារវជ្ជនចិត្តមិនកើតឡើង ហើយរលត់ទៅមុនទេនោះ** ។ ដូច្នេះ

បញ្ចទ្វារាវជ្ជនចិត្ត ទើបជាវិថីចិត្តដំបូងដែលកើតតាមផ្លូវទ្វារណាមួយ ក្នុងទ្វារទាំង ៥ ពេលចិត្តដួងនេះ ធ្វើកិច្ចនេះបាន ៥ ទ្វារ ទើបឈ្មោះថាបញ្ចទ្វារាវជ្ជនចិត្ត (បញ្ច + ទ្វារ + អាវជ្ជនៈ) ។ បើចែកជាទ្វារនីមួយ ៗ គឺខណៈដែលកើតតាមចក្ខុទ្វារ ក៏ជាចក្ខុទ្វារាវជ្ជនៈ ខណៈដែលកើតតាមផ្លូវត្រចៀក ក៏ជាសោតទ្វារាវជ្ជនៈ ខណៈដែលកើតតាមផ្លូវច្រមុះ ក៏ជាឃានទ្វារាវជ្ជនៈ ខណៈដែលកើតតាមអណ្តាត ក៏ជាជិវ្ហាទ្វារាវជ្ជនៈ ខណៈដែលកើតតាមកាយ ក៏ជាកាយទ្វារាវជ្ជនៈ ប៉ុន្តែនៅពេលចិត្តដួងនេះ ធ្វើអាវជ្ជនកិច្ចបាន ៥ ទ្វារ ទើបហៅរួមថា **បញ្ចទ្វារាវជ្ជនចិត្ត** ។

សម្រាប់វិថីចិត្តដែលកើតឡើងដឹងអារម្មណ៍ផ្សេង ៗ តាមផ្លូវចិត្តនោះ មុនដែលវិថីចិត្ត គឺកុសលចិត្ត ឬអកុសលចិត្តជាដើម នឹងកើតឡើងនឹកគិតរឿងរ៉ាវផ្សេង ៗ ក៏គឺនឹងត្រូវមានអាវជ្ជនចិត្តកើតមុនដែរ ។ ចិត្តដែលធ្វើអាវជ្ជនកិច្ច គឺដឹងថាអារម្មណ៍ប៉ះខ្ទប់តាមផ្លូវចិត្តនោះ **គឺមនោទ្វារាវជ្ជនចិត្ត ។ មនោទ្វារាវជ្ជនចិត្ត ជាវិថីចិត្តដួងដំបូង ដែលកើតតាមផ្លូវមនោទ្វារ ។ បើមនោទ្វារាវជ្ជនចិត្តមិនកើតទេ វិថីចិត្តដទៃ ៗ នឹងកើតឡើងដឹងអារម្មណ៍តាមផ្លូវចិត្ត គឺតាមផ្លូវមនោទ្វារមិនបាន** ។ មនោទ្វារាវជ្ជនចិត្ត មិនមែនជាបញ្ចទ្វារាវជ្ជនចិត្ត ជាប្រភេទចិត្តមួយ ។ **បញ្ចទ្វារាវជ្ជនចិត្តកើតបាន ចំពោះតែតាមផ្លូវទ្វារទាំង ៥ កើតតាមផ្លូវមនោទ្វារមិនបានឡើយ ។ មនោទ្វារាវជ្ជនចិត្ត ក៏ធ្វើអាវជ្ជនកិច្ចតាម**

បញ្ចទ្វារមិនបានឡើយ ។ មនោទ្វារវជ្ជនចិត្តធ្វើអាវជ្ជនកិច្ច ចំពោះបានតែផ្លូវមនោទ្វារតែមួយប៉ុណ្ណោះ ។

ដូច្នេះ **វិថីចិត្តដែលធ្វើអាវជ្ជនចិត្ត ៦ ទ្វារ ទើបមាន ២ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង ធ្វើអាវជ្ជនកិច្ច តាមផ្លូវទ្វារទាំង ៥ មនោទ្វារាវជ្ជនចិត្ត ១ ដួង ធ្វើអាវជ្ជនកិច្ចចំពោះតែតាមផ្លូវមនោទ្វារតែ ១ ទ្វារ ។**

ខណៈនេះមាន បញ្ចទ្វារាវជ្ជនចិត្តទេ ? - មាន បើមិនមាន គឺមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សកាយ ។

ខណៈនេះមាន មនោទ្វារាវជ្ជនចិត្ត ទេ ? - មាន នៅពេលវិថីចិត្តផ្សេង ៗ កើតឡើងដឹងអារម្មណ៍តាមផ្លូវបញ្ចទ្វាររលត់ទៅហើយ ភវង្គចិត្តក៏កើតខណ្ឌច្រើនខណៈ ហើយមនោទ្វារវិថីចិត្ត ក៏កើតឡើងបន្តដឹងអារម្មណ៍នោះ តតាមផ្លូវចិត្តទៀត គឺអាស្រ័យចិត្ត (ភវង្គុប្បច្ឆេទៈ) ជាមនោទ្វារកើតឡើងដឹងអារម្មណ៍ដូចនឹងចិត្តដែលដឹងអារម្មណ៍តាមបញ្ចទ្វារដែលរលត់ទៅហើយនោះដដែលទៀត ។

ខណៈដេកលក់ស៊ប់មិនដឹងអារម្មណ៍ណាមួយឡើយ តើមានបញ្ចទ្វារាវជ្ជនចិត្តទេ ? - មិនមាន ។ តើមានមនោទ្វារាវជ្ជនចិត្តទេ ? - មិនមាន ។ ខណៈមិនដេកលក់ តែមិនដឹងអារម្មណ៍តាមទ្វារណាមួយឡើយ តើខណៈនោះមានបញ្ចទ្វារាវជ្ជនចិត្តទេ ? - មិនមាន ។

មានមនោទ្វារវជ្ជនចិត្តទេ ? - មិនមាន ។ បើដូច្នេះ ខណៈនោះ ជាចិត្តអ្វី ? ជាភវង្គចិត្ត ដែលកើតខណ្ឌរវាងវិថីចិត្តតាមបញ្ចទ្វារ និងវិថីដែលដឹងអារម្មណ៍តាមមនោទ្វារ ។

តាមបញ្ចទ្វារមានវិថីចិត្ត ៧ វិថីតាមលំដាប់

នៅពេលវិថីចិត្តទី ១ គឺបញ្ចទ្វារវជ្ជនចិត្តកើតឡើង ធ្វើអាវជ្ជនកិច្ច ហើយរលត់ទៅ ក៏ជាបច្ច័យឱ្យវិថីចិត្តទី ២ កើតឡើង គឺ

បើតាមផ្លូវភ្នែក ចក្ខុវិញ្ញាណកើតឡើងធ្វើទស្សនកិច្ច គឺកិច្ចឃើញ ១ ខណៈហើយរលត់ទៅ ។

បើតាមផ្លូវត្រចៀក សោតវិញ្ញាណកើតឡើងធ្វើសវនកិច្ច គឺកិច្ចឮ ១ ខណៈហើយរលត់ទៅ ។

បើតាមផ្លូវច្រមុះ ឃានវិញ្ញាណកើតឡើងធ្វើឃាយនកិច្ច គឺកិច្ចធុំក្លិន ១ ខណៈហើយរលត់ទៅ ។

បើតាមផ្លូវអណ្តាត ជិវ្ហាវិញ្ញាណកើតឡើងធ្វើសាយនកិច្ច គឺកិច្ចដឹងរស ១ ខណៈហើយរលត់ទៅ ។

បើតាមផ្លូវកាយ កាយវិញ្ញាណកើតឡើងធ្វើផុស្សនកិច្ច គឺកិច្ចដឹងអារម្មណ៍ដែលប៉ះខ្ទប់កាយ ១ ខណៈហើយរលត់ទៅ ។

កាលបញ្ចទ្វារវជ្ជនចិត្តរលត់ទៅ ចិត្តដទៃក្រៅអំពីចិត្ត ១០ ដួងនេះនឹងកើតមិនបានឡើយ (បញ្ចវិញ្ញាណតាមទ្វារ ៥ ទ្វារ ទ្វារមួយមាន ២ ដួង គឺ កុសលវិបាក ១ ដួង និង អកុសលវិបាក ១ ដួង) ។

បញ្ចទ្វារវជ្ជនចិត្តជា **វិថីចិត្តទី ១** ចក្ខុវិញ្ញាណ ឬសោតវិញ្ញាណ ឬ ឃានវិញ្ញាណ ឬជិវ្ហាវិញ្ញាណ ឬកាយវិញ្ញាណជា **វិថីចិត្តទី ២** កាលចិត្តណាមួយក្នុងបញ្ចវិញ្ញាណ ១០ ដួងនេះរលត់ទៅហើយ **វិថីចិត្តទី ៣** ជាសម្បដិច្ឆន្នចិត្តកើតឡើងធ្វើសម្បដិច្ឆន្នកិច្ច គឺកិច្ចទទួលអារម្មណ៍នោះ តពីបញ្ចវិញ្ញាណ ។ កាលសម្បដិច្ឆន្នចិត្តរលត់ទៅហើយ **វិថីចិត្តទី ៤** ជាសន្តីរណចិត្ត កើតឡើងធ្វើសន្តីរណកិច្ច គឺកិច្ចពិចារណាអារម្មណ៍នេះ ១ ខណៈ ហើយក៏រលត់ទៅ **វិថីចិត្តទី ៥** គឺ វោដ្ឋព្វនចិត្ត (បានដល់ មនោទ្វារវជ្ជនចិត្ត ដែលកើតឡើងធ្វើវោដ្ឋព្វនកិច្ចតាមផ្លូវបញ្ចទ្វារ) កើត ឡើងធ្វើកិច្ចកំណត់ គឺធ្វើផ្លូវឱ្យលោកិយកុសលចិត្ត ឬអកុសលចិត្ត ឬ មហាកិរិយាចិត្តកើតត ។

នៅពេលវោដ្ឋព្វនចិត្តរលត់ហើយ **វិថីចិត្តទី ៦** គឺលោកិយ កុសលចិត្ត ឬអកុសលចិត្ត ឬកិរិយាចិត្ត ប្រភេទណាមួយ កើតឡើង ធ្វើជវនកិច្ច (**៧ ខណៈទើបសន្សំសន្តាន**) ដោយប្រការដែលក្នុងពាក្យថា « ចិត្តំ » នេះ លោកិយកុសលចិត្ត ឬអកុសលចិត្ត និងមហាកិរិយាចិត្ត ឈ្មោះថា « ចិត្ត » ព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថី ។

ការកើតឡើង ការប្រព្រឹត្តនៃវិថីចិត្តតាមលំដាប់ក្នុងខណៈនីមួយ ៗ ដែលដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះ ជាចិត្តនិយាមប្រព្រឹត្តតាមហេតុបច្ច័យ មិននៅក្នុងអំណាចបង្គាប់បញ្ជា របស់អ្នកណាឡើយ ។

វិថីចិត្តទី ១ គឺបញ្ចទ្វារាវជ្ជនចិត្តកើតឡើង ១ ខណៈហើយ រលត់ទៅក៏ប្រព្រឹត្តទៅតាមហេតុបច្ច័យ ។

វិថីចិត្តទី ២ គឺបញ្ចវិញ្ញាណកើតឡើង ១ ខណៈ ។

វិថីចិត្តទី ៣ គឺសម្បដិច្ឆន្នចិត្តកើតឡើង ១ ខណៈ ។

វិថីចិត្តទី ៤ គឺសន្តីរណចិត្តកើតឡើង ១ ខណៈ ។

វិថីចិត្តទី ៥ គឺវោដ្ឋព្វនចិត្តកើតឡើង ១ ខណៈ ។

វិថីចិត្តទី ៦ គឺលោកិយកុសលចិត្ត ឬអកុសលចិត្ត ឬមហាកិរិយាចិត្ត កើតឡើងធ្វើជវនកិច្ច ៧ ខណៈក៏ប្រព្រឹត្តទៅតាមបច្ច័យ ដែល **ជវនវិថីសន្សំសន្តាននៃខ្លួន ព្រោះជាវិថីចិត្តដែលកើតរលត់ដដែល ។ ផ្ទួន ។ គ្នាដល់ ៧ ខណៈ** អ្នកដែលមិនមែនជាព្រះអរហន្តនោះ ចិត្តដែលធ្វើជវនកិច្ច គឺជាកុសលចិត្ត ឬជាអកុសលចិត្ត តែបុគ្គលដែលជាព្រះអរហន្តរំលត់កិលេសអស់ហើយ ទើបមិនមែនកុសលចិត្ត និងអកុសលចិត្តទេ ដូច្នេះ មហាកិរិយាចិត្ត ទើបធ្វើជវនកិច្ចដោយព្រះអរហន្តមិនមានកុសលចិត្ត និងអកុសលចិត្ត ព្រះអរហន្តទើបមានតែវិបាកចិត្ត និងកិរិយាចិត្ត ។ កិរិយាចិត្តមានច្រើនប្រភេទ វារៈណាដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វារម្មណ៍និងនឹកគិត **ជវនវិថីរបស់ព្រះអរហន្ត ជាកិរិយាចិត្ត** គឺជាចិត្តដែលដឹងអារម្មណ៍ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។

ត្រឹមតែឃើញ ១ ខណៈហើយ ក៏ត្រេកអរពេញចិត្តក្នុងអ្វីដែលឃើញ អកុសលចិត្ត ដែលជាលោភមូលចិត្ត ក៏កើត ៧ ខណៈ ដែល

ស្មើនឹង ៧ ដងនៃចក្ខុវិញ្ញាណដែលកើតឡើងឃើញត្រឹមតែ ១ ខណៈប៉ុណ្ណោះ ។ នេះគឺការសន្សំអកុសល ដែលគ្រប់មនុស្សកំពុងរស់នៅតាមសេចក្តីពិតក្នុងជីវិតប្រចាំថ្ងៃ ។ ដូច្នេះ ការរំលត់កិលេស ទើបមិនងាយទេ និងមិនមែនមិនចាំបាច់ត្រូវដឹងអ្វី ។ នោះទេ ។ អ្នកដែលយល់ថានឹងអាចរំលត់កិលេសបានងាយ ។ នោះ គួរដឹងសេចក្តីពិតដែលសន្សំអវិជ្ជា លោភៈ ទោសៈ និងកិលេសដទៃ ។ ទុក ៧ ដងនៃចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណមួយវារៈ ។ ។ អ្នកដែលសង្ឃឹមរង់ចាំថាពេលណាទៅ នឹងដឹងច្បាស់អរិយសច្ចធម៌នោះ មិនបានគិតដល់ហេតុ និងផលតាមសេចក្តីពិត ដែលបានសន្សំមកក្នុងសង្សារវដ្តថា នឹងត្រូវអប់រំចម្រើនបញ្ញាដឹងច្បាស់ក្នុងលក្ខណៈនៃសភាវធម៌ទាំងឡាយតាមសេចក្តីពិតឱ្យក្រៃលែងឡើង រហូតដល់ដឹងច្បាស់អរិយសច្ចធម៌ ទើបនឹងរំលត់កិលេសបានតាមលំដាប់ថ្នាក់ ។

ខណៈដែលកំពុងស្តាប់ ឬសិក្សារឿងនៃចិត្តនោះ បើសតិប្បដ្ឋានរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដ ខណៈនោះ ក៏កំពុងបដិបត្តិអប់រំចម្រើនតាមគន្លងផ្លូវដែលនឹងធ្វើឱ្យដឹងច្បាស់នូវព្រះនិព្វាន ដែលជាសភាវធម៌រំលត់កិលេសបាន ។ ខណៈណាដែលសតិមិនរលឹកដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិតទេ ខណៈនោះសូម្បីដល់ថាជាកុសល ក៏មិនមែនជាគន្លងផ្លូវរំលត់កិលេស ដែលមានសេចក្តីក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ អធិប្បាយពាក្យថា **អចយគាមី** ថា

អកុសល និងកុសលដែលមិនមែនមគ្គ ឈ្មោះថា **អចយគាមី** ព្រោះអត្ថថា បង្កសន្សំកពូននូវធម៌ដែលប្រព្រឹត្ត ដូចជាងឥដ្ឋកពូននូវកំផែងដូច្នោះដែរ ។ ខណៈណាដែលមិនរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដតាមសេចក្តីពិត មិនថាជាកុសល ឬអកុសលណា ។ ឡើយក៏សន្សំកពូនកសាងភព ជាតិ ដូចជាជាងឥដ្ឋដែលកសាងកំផែងដោយឥដ្ឋមួយដុំ ។ រៀបតម្រួតលើគ្នា រហូតដល់បានសម្រេចជាកំផែង ។ តែខណៈណា ដែលសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ តាមសេចក្តីពិត ខណៈនោះជាមគ្គជា **អបចយគាមី** ព្រោះអត្ថថាមិនសន្សំកពូននូវធម៌ដែលប្រព្រឹត្តនោះទេ ដូចបុរសរើរុះឥដ្ឋដែលជាងឥដ្ឋកពូនតម្រួតលើគ្នាដូច្នោះដែរ ។ តើខណៈនេះកំពុងតែជាបុរសរើរុះឥដ្ឋ ឬកំពុងតែជាជាងកពូនឥដ្ឋ ?

វិថីចិត្តទី ១ គឺអាវជ្ជនចិត្ត សន្សំសន្តានមិនបាន ព្រោះកើត ១ ខណៈ ។

វិថីចិត្តទី ២ គឺបញ្ចវិញ្ញាណ សន្សំសន្តានមិនបាន ព្រោះកើត ១ ខណៈ ។

វិថីចិត្តទី ៣ គឺសម្បដិច្ឆន្នចិត្ត សន្សំសន្តានមិនបាន ព្រោះកើត ១ ខណៈ។

វិថីចិត្តទី ៤ គឺសន្តីរណចិត្ត សន្សំសន្តានមិនបាន ព្រោះកើត ១ ខណៈ ។

វិថីចិត្តទី ៥ គឺវោដ្ឋព្វនចិត្ត សន្សំសន្តានមិនបាន ព្រោះកើត ១ ខណៈ (ឬសូម្បីថាកើត ២ - ៣ ខណៈ ពេលរូបរលត់មុន ជវនវិថីកើតក៏ដោយ) ។

វិថីចិត្តទី ៦ គឺជវនចិត្ត សន្សំសន្តានព្រោះកើតរលត់បន្តច្រំដែល ៗ ៧ ខណៈតាមប្រក្រតី ។ ក្នុងរយៈកាលសន្លប់ ជវនចិត្តនឹងកើតរលត់បន្តច្រំដែល ៗ ៦ ខណៈ ។ ក្នុងខណៈមុននឹងចុតិ ជវនចិត្តនឹងកើត រលត់បន្តគ្នាច្រំដែល ៗ ៥ ខណៈ ។ ដោយជវនចិត្តកើតរលត់បន្តគ្នាច្រំដែល ៗ ដល់ ៧ ខណៈ ដែលច្រើនជាងវិថីចិត្តដទៃៗ ដូច្នេះហើយ ជវនវិថីចិត្តទើបសន្សំសន្តាននៃខ្លួន ។

សំណួរសាឡើងវិញ

១ - អនន្តរប្បច្ច័យ គឺអ្វី ?

២ - ចិត្ត និងចេតសិកមានប៉ុន្មានជាតិ អ្វីខ្លះ ?

៣ - វិថីចិត្តគឺអ្វី ? ចិត្តខណៈណាមិនមែនវិថីចិត្ត ?

៤ - អតីតភវង្គ គឺអ្វី ?

៥ - ខណៈដេកមិនលក់មានភវង្គចិត្ត ឬទេ ?

៦ - បញ្ចទ្វារវិថីចិត្ត ដឹងអារម្មណ៍អ្វី តាមទ្វារណា ?

៧ - មនោទ្វារវិថីចិត្ត ដឹងអារម្មណ៍ តាមទ្វារណា ?

៨ - ចិត្តដឹងធម្មារម្មណ៍បានប៉ុន្មានទ្វារ ?

៩ - បញ្ចទ្វារាវជ្ជនចិត្តធ្វើកិច្ចអ្វី តាមទ្វារណា ?

១០ - មនោទ្វារាវជ្ជនចិត្តធ្វើកិច្ចអ្វី តាមទ្វារណា ?

មេរៀនទី ៤

ពេលឃើញកើតឡើង លោភៈ ត្រេកអរ ពេញចិត្ត ក្នុងរូបារម្មណ៍ ដែលកំពុងប្រាកដ មើលទៅហាក់ដូចជាមិនជាទោស ព្រោះមើលទៅ ត្រឹមតែជាសេចក្តីពេញចិត្តធម្មតា ។ ខណៈនោះក៏ជាធម៌ ដែលជាទោស ឱ្យផលជាទុក្ខ ដោយសន្សំទុកសន្សឹម ។ បន្តិចម្តង ។ ឡើងទៅ ។ មិនថាទុក្ខនឹងប្រាកដភ្លាម ។ ដែលមានលោភៈសេចក្តីពេញចិត្តសូម្បីតែបន្តិចបន្តួច តែពេលណាជាលោភៈ សេចក្តីពេញចិត្តមានកម្លាំងខ្លាំងឡើងដល់ថ្នាក់នីវរណធម៌ រួមរឹតចិត្ត ខណៈនោះ លក្ខណៈអាការនៃសភាវធម៌ដែលធ្ងន់ព្រោះជាអកុសល ការរសាប់រសល់ មិនស្ងប់ក៏ប្រាកដ ។

ដូច្នេះ នឹងឃើញបានថា តាំងតែពីភ្ញាក់រហូតដល់លក់នោះ ជវនវិថីសន្សំសន្តានជាកុសលច្រើន ឬជាអកុសលច្រើន ហើយនឹងធ្វើយ៉ាងណាល្អ ។ គ្រប់លោកអ្នកកំពុងពិសាថ្នាំពិស បើដឹងខ្លួន ក៏គួរស្វែងរកថ្នាំបន្សាបពិស បើមិនដឹងខ្លួន ក៏នៅតែពិសាថ្នាំពិស សន្សំថ្នាំពិសនោះ រមែងឱ្យផលជាទុក្ខ ទោសភ័យបន្តិចម្តង ។ រឿយ ។ ។ ថ្នាំដែលនឹងបន្សាបពិសបាននោះ មានតែម៉្យាងប៉ុណ្ណោះ គឺអប់រំចម្រើនសតិប្បដ្ឋាន ។

ខណៈណាសតិប្បដ្ឋានមិនកើត គឺមិនមានគន្លងផ្លូវដែលនឹងផុតចាកការសន្សំនៃអកុសលឡើយ ព្រោះកុសលដទៃ ។ ក៏កើតតិចតួច ។ នៅពេលអប់រំចម្រើនសតិប្បដ្ឋាន សតិប្បដ្ឋានក៏កើតជំនួសអកុសលបាន ព្រោះវោដ្ឋព្វនវិថីចិត្ត ជាអនន្តរប្បច្ច័យធ្វើផ្លូវឱ្យកុសលកើតតាមការសន្សំ

កុសលចិត្តក៏កើតព្រមដោយសតិ ដែលរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដបាន ព្រោះជវនវិថីចិត្ត ដែលជាកុសល និងអកុសលកើតរលត់សន្សំបន្តគ្នាមករឿយ ៗ ទើបជាបច្ច័យឱ្យបុគ្គលម្នាក់ ៗ មានអធ្យាស្រ័យផ្សេង ៗ គ្នា សូម្បីព្រះអរហន្តទាំងឡាយ ក៏មានអធ្យាស្រ័យមិនដូចគ្នាដែរ ។ ការសន្សំនៃចិត្តរបស់បុគ្គលនីមួយ ៗ ល្អិតណាស់ ដូច្នេះ ព្រះអរហន្តទាំងឡាយ ទើបមានអធ្យាស្រ័យផ្សេង ៗ គ្នា ជាឯតទគ្គៈខាងផ្លូវផ្សេង ៗ គ្នា ដូចជា ព្រះសារីបុត្រ ជាឯតទគ្គៈខាងផ្លូវបញ្ញា ព្រះមោគ្គល្លាន ជាឯតទគ្គៈខាងផ្លូវឥទ្ធិបាដិហារិយ ព្រះមហាកស្សបជាឯតទគ្គៈខាងផ្នែករក្សាធុតង្គ និងការពោលសរសើរធុតង្គ ព្រះអនុរុទ្ធ ជាឯតទគ្គៈខាងផ្លូវចក្ខុទិព្វ ។ ការសន្សំនៃជវនវិថីចិត្តដែលផ្សេង ៗ គ្នាទៅក្នុងកុសលចិត្ត និងអកុសលចិត្តយ៉ាងណា ក្នុងផ្លូវកិរិយាចិត្ត នៃព្រះអរហន្តទាំងឡាយក៏ផ្សេងគ្នាទៅយ៉ាងនោះដែរ ។ ខណៈនេះ គ្រប់គ្នាគិតមិនដូចគ្នា និយាយក៏មិនដូចគ្នា ការប្រព្រឹត្តតាមផ្លូវកាយ វាចា ក៏រមែងមិនដូចគ្នាឡើយតាមការសន្សំ ។

ការសន្សំលោកិយកុសល អកុសល និងមហាកិរិយាដោយអំណាចនៃជវនវិថីចិត្តនោះសន្សំទៅគ្រប់ខណៈរហូតធ្វើឱ្យកើតជា ឧបនិស្ស័យផ្សេង ៗ ការធ្វើអាការកិរិយាតាមផ្លូវកាយ តាមផ្លូវវាចាផ្សេង ៗ ។ លោកខ្លះពេលឃើញព្រះអរហន្ត ក៏ញ៉ាំងសេចក្តីមើលងាយ ដោយសន្និដ្ឋានតាមអាការដែលប្រាកដខាងក្រៅ ដូចជាវស្សការព្រាហ្មណ៍មហាមាត្យនៃដែន

មគធៈ ឃើញព្រះមហាកច្ចាយនៈ និមន្តចុះពីលើភ្នំ ក៏ពោលតិះដៀលថា លោកនេះមានអាការដូចស្វា ។ ការសន្សំនៃជវនវិថីចិត្តនៃវស្សការព្រាហ្មណ៍ ធ្វើឱ្យប្រកាន់ខ្លួន សូម្បីតែព្រះមានព្រះភាគត្រាស់ប្រើឱ្យទៅសុំទោស ឱ្យព្រះកច្ចាយនៈអត់ទោសឱ្យយ៉ាងណាក៏ដោយ តែមានៈសេចក្តីប្រកាន់ខ្លួនដែលសន្សំមក ក៏ធ្វើឱ្យវស្សការព្រាហ្មណ៍មិនអាចនឹងធ្វើយ៉ាងនោះបានឡើយ សូម្បីព្រះមានព្រះភាគនឹងទ្រង់ព្យាករណ៍ថា កាលណាវស្សការព្រាហ្មណ៍អស់ជីវិតទៅ នឹងកើតជាស្វានៅព្រៃឬស្សី ឯវស្សការព្រាហ្មណ៍ ក៏ឱ្យគេទៅដាំចេក និងអាហាររបស់សត្វស្វាទុក ពេលស្លាប់ទៅ ក៏កើតជាសត្វស្វាមែន ។

ដូច្នេះ ទើបគួរឃើញទោសនៃការសន្សំនៃអកុសល ព្រោះសូម្បីថានឹងជាព្រះអរហន្តហើយក្តី ការសន្សំនៃចិត្តខណៈនីមួយ ។ ដោយអំណាចនៃជវនវិថីដែលកើត រលត់បន្តគ្នា ដដែល ។ ដល់ទៅ ៧ ខណៈនោះ ក៏ធ្វើឱ្យ បុគ្គលនីមួយ ។ មាន កាយ វាចា ផ្សេង ។ គ្នាជាវាសនា ។ ពាក្យថា « **វាសនា** » សំដៅដល់សេចក្តីប្រព្រឹត្តតាមផ្លូវ កាយ វាចា ដែលសន្សំមករហូតដល់ ធ្លាប់ ។ វាសនាដែលប្រើក្នុងភាសាខ្មែរ សំដៅសេចក្តីថាបុណ្យភ័ព្វផ្សេង ។ តែ « វាសនា » ក្នុងព្រះពុទ្ធសាសនាសំដៅដល់ការសន្សំនៃអកុសល រហូតជាការប្រព្រឹត្តទៅជាទម្លាប់ជាប់តាម ដោយអាការ ដែលប្រាកដតាមផ្លូវកាយ តាមផ្លូវវាចា ។ អ្នកដែលលះបង់« **វាសនា** » មានតែបុគ្គលម្នាក់ប៉ុណ្ណោះ គឺព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។ ព្រះអរហន្ត

ទាំងឡាយរំលត់កិលេសបានជាសមុច្ឆេទ ដោយមិនមានកិលេសណាសេសសល់ឡើយ តែនៅពេលនោះ លោកក៏នៅមិនទាន់លះបង់វាសនាបានដែរ ព្រោះការសន្សំក្នុងសង្សារវដ្តយូរយារអស់កាលជាអង្វែងមកហើយ ដោយអំណាចនៃជវនវិថី ។

វិថីចិត្តតាមផ្លូវបញ្ចទ្វារមាន ៧ វិថី

វិថីចិត្តទី ១ គឺអាវជ្ជនវិថី បានដល់ **បញ្ចទ្វារាវជ្ជនចិត្ត**

វិថីចិត្តទី ២ គឺទ្វិបញ្ចវិញ្ញាណ ដួងណាមួយ គឺ ចក្ខុវិញ្ញាណ ឬ សោតវិញ្ញាណ ឬ ឃានវិញ្ញាណ ឬ ជិវ្ហាវិញ្ញាណ ឬ កាយវិញ្ញាណ ។

វិថីចិត្តទី ៣ គឺសម្បដិច្ឆន្នចិត្ត កើតឡើងទទួលអារម្មណ៍តអំពីទ្វិបញ្ចវិញ្ញាណដួងណាមួយរលត់ទៅ

វិថីចិត្តទី ៤ គឺសន្តីរណចិត្ត ពិចារណាអារម្មណ៍

វិថីចិត្តទី ៥ គឺវោដ្ឋព្វនចិត្ត ធ្វើកិច្ចធ្វើផ្លូវឱ្យកុសលចិត្ត ឬអកុសលឬកិរិយាចិត្ត (ចំពោះតែព្រះអរហន្ត) កើតបន្ត ។

វិថីចិត្តទី ៦ គឺជវនវិថីចិត្ត ដោយសព្ទ « **ជវនៈ** » ប្រែថា « ស្ទុះទៅ » គឺទៅយ៉ាងរហ័សក្នុងអារម្មណ៍ ដោយកុសលចិត្ត អកុសលចិត្ត ឬកិរិយាចិត្ត (ចំពោះតែព្រះអរហន្ត)

វិថីចិត្តទី ៧ គឺតទាលម្ពណវិថី ឬ **តទារម្មណវិថី** តទាលម្ពណវិថីចិត្តកើតឡើងធ្វើកិច្ចដឹងអារម្មណ៍ទទួលតអំពីជវនវិថីចិត្ត នៅពេល

ដែលអារម្មណ៍នោះនៅពុំទាន់រលត់ទៅ ព្រោះរូបនីមួយ ៗ មានអាយុ ១៧ ខណៈចិត្ត គឺខណៈដែលរូបកើតឡើងប៉ះខ្ទប់ទ្វារ និងប៉ះខ្ទប់អតីតភវង្គ ជាខណៈចិត្តទី ១

ភវង្គចលនៈ	ជាខណៈចិត្តទី ២	
ភវង្គុប្បច្ឆេទៈ	ជាខណៈចិត្តទី ៣	
បញ្ចទ្វារាវជ្ជនៈ	ជាខណៈចិត្តទី ៤	
(ទ្វិ) បញ្ចវិញ្ញាណ	ជាខណៈចិត្តទី ៥	
សម្បដិច្ឆន្នៈ	ជាខណៈចិត្តទី ៦	
សន្តីរណៈ	ជាខណៈចិត្តទី ៧	
វោដ្ឋព្វនៈ	ជាខណៈចិត្តទី ៨	
ជវនទី ១	ជាខណៈចិត្តទី ៩	ជវនចិត្ត ៧ ខណៈ
ជវនទី ២	ជាខណៈចិត្តទី ១០	
ជវនទី ៣	ជាខណៈចិត្តទី ១១	
ជវនទី ៤	ជាខណៈចិត្តទី ១២	
ជវនទី ៥	ជាខណៈចិត្តទី ១៣	
ជវនទី ៦	ជាខណៈចិត្តទី ១៤	
ជវនទី ៧	ជាខណៈចិត្តទី ១៥	

រួមជាអាយុនៃរូបដែលកើតតាំងតែពីអតីតភវង្គចិត្ត ដល់ជវនចិត្តដួងចុងក្រោយបំផុត បាន ១៥ ខណៈ រូបទើបនៅមិនទាន់រលត់ អាយុរបស់រូប

នៅសល់ ២ ខណៈចិត្តទៀត ។ វិស័យនៃអ្នកដែលជាកាមបុគ្គលនោះ កាលជវនចិត្តស្ទុះទៅក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈហើយ តែរូបនោះមិនទាន់រលត់ ការសន្សំនៃកម្ម ក្នុងអតីតដែលជាប់ជំពាក់នៅក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ក៏ញុាំងជាបច្ច័យឱ្យកើតនូវវិបាកចិត្តឡើង ជា **តទាលម្ពណវិថីចិត្ត** ទទួលដឹងអារម្មណ៍នោះ ត ២ ខណៈទៀត ។ តទាលម្ពណវិថីចិត្ត ដែលធ្វើកិច្ចដឹងអារម្មណ៍ តពីជវនវិថីនោះ ជាវិថីចិត្តក្រោយបំផុត ដែលកើតឡើងដឹងអារម្មណ៍តាមទ្វារនីមួយ ។ ហើយតពីវិថីចិត្តក្រោយបំផុតតាមទ្វារនីមួយ ។ ហើយភវង្គចិត្តក៏កើត រលត់បន្តគ្នាទៅរហូតទម្រាំវិថីចិត្តវារៈបន្ទាប់ នឹងកើតឡើងដឹងអារម្មណ៍តាមទ្វារណាមួយ ។ ខណៈណាដែលជាភវង្គចិត្ត លោកនេះមិនប្រាកដ សេចក្តីចងចាំទាំងអស់ទាក់ទងរឿងរ៉ាវនៃបុគ្គលផ្សេង ។ ហេតុការណ៍ផ្សេង ។ ក្នុងលោកនេះមិនប្រាកដឡើយ ។

ខណៈដែលដេកលក់យ៉ាងស៊ប់ជាភវង្គចិត្តជានិច្ចនោះ មិនមានការដឹង ការចាំអ្វី ។ ក្នុងរឿងលោកនេះឡើយ និងកាលចុតិចិត្តកើត ធ្វើកិច្ចឃ្លាតចាកសភាពជាបុគ្គលនេះ បដិសន្ធិចិត្តក៏កើតបន្តរួចហើយ វិថីចិត្តដែលនឹងកើតបន្តបន្ទាប់ក៏ជារឿងនៃលោកដទៃតទៅ ។ ប៉ុន្តែកាលចុតិចិត្តនៅមិនទាន់កើតសូម្បីភវង្គចិត្ត ក៏មិនដឹងរឿងរ៉ាវផ្សេង ។ នៃលោកនេះឡើយ តែកាលណាវិថីចិត្តកើតឡើងហើយ នឹងបង្ខាំងមិនឱ្យដឹងអារម្មណ៍

នៃលោកនេះក៏មិនបាន គឺ ពណ៌ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងរឿងរ៉ាវ ផ្សេង ៗ របស់លោកនេះបន្តទៅទៀត ។

លំដាប់ការកើតឡើងនៃវិថីចិត្តតាមបញ្ចទ្វារមាន ៧ វិថីដូចនេះ

អតីតភវង្គ	១ ខណៈ	មិនមែនជាវិថីចិត្ត
ភវង្គចលនៈ	១ ខណៈ	
ភវង្គុប្បច្ឆេទៈ	១ ខណៈ	
បញ្ចទ្វារាវជ្ជនចិត្ត	១ ខណៈ	ជាវិថីចិត្ត
(**ទ្វិ**) **បញ្ចវិញ្ញាណ**	១ ខណៈ	ជាវិថីចិត្ត
សម្បដិច្ឆន្នចិត្ត	១ ខណៈ	ជាវិថីចិត្ត
សន្តីរណចិត្ត	១ ខណៈ	ជាវិថីចិត្ត
វោដ្ឋព្វនចិត្ត	១ ខណៈ	ជាវិថីចិត្ត
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	ជាជវនចិត្ត៧ខណៈ
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	

តទាលម្ពណចិត្ត ១ ខណៈ } ជាតទាលម្ពណៈ
តទាលម្ពណចិត្ត ១ ខណៈ } វិថីចិត្ត ២ ខណៈ

អាយុរបស់សភាវៈរូប ១ រូបស្មើនឹងការរលត់របស់ចិត្ត ១៧ ខណៈ ។

កាលវិថីចិត្តកើតឡើងដឹងអារម្មណ៍តាមបញ្ចទ្វារដែលជាបសាទរូប ទ្វារណាមួយរលត់ទៅហើយ ភវង្គចិត្តក៏កើតរលត់ខណ្ឌបន្ត ហើយតពីនោះ មនោទ្វារាវជ្ជនចិត្ត គឺចិត្តដែលអាស្រ័យចិត្ត (ភវង្គុប្បច្ឆេទចិត្ត) ជាទ្វារដឹងអារម្មណ៍ក៏កើតឡើង ដឹងអារម្មណ៍តែមួយដូចជាវិថីចិត្តតាមបញ្ចទ្វារ ដែលទើបរលត់ទៅនោះក្នុងមួយវារៈ ។ **វិថីចិត្តដែលកើតឡើងដឹងអារម្មណ៍តាមមនោទ្វារនោះ មិនច្រើនដូចវិថីចិត្តដែលដឹងអារម្មណ៍តាមបញ្ចទ្វារទេ** ហើយតាមផ្លូវមនោទ្វារនោះ នៅពេលអារម្មណ៍មិនបានប៉ះខ្ទប់នឹងចក្ខុ-បសាទជាដើម ទើបមិនមានអតីតភវង្គ ប៉ុន្តែមុនដែលមានមនោទ្វា-រាវជ្ជនចិត្តរំពឹងដល់អារម្មណ៍ ដែលវិថីចិត្តដឹងតាមបញ្ចទ្វារហើយរលត់ទៅនោះ គឺភវង្គចលនៈត្រូវកើតឡើងញ័រតាមអារម្មណ៍នោះហើយរលត់ទៅ ទើបភវង្គុប្បច្ឆេទៈកើតឡើងហើយរលត់ទៅ ។ តពីនោះមនោទ្វារាវជ្ជនចិត្ត ទើបកើតឡើងជាមនោទ្វារវិថីចិត្តទី ១ ។ **ចិត្តដែលធ្វើអាវជ្ជនកិច្ចតាមផ្លូវមនោទ្វារនោះ មិនមែនជាបញ្ចទ្វារាវជ្ជនចិត្ត បញ្ចទ្វារាវជ្ជនកិច្ច ធ្វើអាវជ្ជនកិច្ច បានតែតាមបញ្ចទ្វារប៉ុណ្ណោះ ធ្វើអាវជ្ជនកិច្ចតាមមនោទ្វារ មិនបានឡើយ** ។ ចិត្តដែលធ្វើអាវជ្ជនកិច្ចតាមមនោទ្វារមាន ១ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ធ្វើកិច្ចរំពឹងតាមអារម្មណ៍ក្នុងមនោទ្វារ គឺនឹកដល់

អារម្មណ៍តាមមនោទ្វារ ។ ក្នុងមួយថ្ងៃ ៗ ដែលនឹកគិតរឿងផ្សេង ៗ នោះ ខណៈដែលគិតនោះ ចិត្តមិនដឹងអារម្មណ៍ណាមួយតាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយឡើយ ។ កាលភវង្គចលនៈកើតឡើងហើយរលត់ទៅ ភវង្គុប្បច្ឆេទៈ ក៏កើតបន្តហើយរលត់ទៅ មនោទ្វារាវជ្ជនចិត្តក៏កើតឡើងជា មនោទ្វារវិថីចិត្តទី ១ ។ កាលមនោទ្វារាវជ្ជនចិត្តរលត់ទៅហើយ សម្រាប់ អ្នកដែលមិនមែនជាព្រះអរហន្ត កុសលចិត្ត ឬអកុសលចិត្ត ដែលជាជវនវិថី ក៏កើតរលត់បន្តគ្នាដដែល ៗ ដូចគ្នា ៧ ខណៈ ។ កាលកុសលជវនវិថីចិត្ត ឬអកុសលជវនវិថីចិត្តរលត់ទៅហើយ បើជាអារម្មណ៍តាមផ្លូវចិត្តប្រាកដ ជាក់ច្បាស់ តទាលម្ពណវិថីចិត្តក៏កើតបន្ត ២ ខណៈទៀត ។ ដូច្នេះ វិថីចិត្តដែលកើតឡើងដឹងអារម្មណ៍តាមមនោទ្វារ ទើបមានតែត្រឹម ៣ វិថីប៉ុណ្ណោះ គឺ

វិថីទី ១ ជាអាវជ្ជនវិថី ១ ខណៈ

វិថីទី ២ ជាជវនវិថី ៧ ខណៈ

វិថីទី ៣ ជាតទាលម្ពណវិថី ២ ខណៈ ។

លំដាប់ការកើតនៃវិថីចិត្តតាមមនោទ្វារ មាន ៣ វិថី

ភវង្គចលនៈ	១ ខណៈ	មិនមែនវិថីចិត្ត
ភវង្គុប្បច្ឆេទៈ	១ ខណៈ	
មនោទ្វារាវជ្ជនចិត្ត	១ ខណៈ	ជាអាវជ្ជនវិថីចិត្ត

កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	ជាជវនវិថីចិត្ត ៧ ខណៈ
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
កុសលឬអកុសលឬកិរិយាចិត្ត	១ ខណៈ	
តទាលម្ពណៈ	១ ខណៈ	តទាលម្ពណវិថី ២ ខណៈ
តទាលម្ពណៈ	១ ខណៈ	

ខណៈឃើញសភាវៈដែលកំពុងប្រាកដតាមភ្នែក វិថីចិត្តដែលកើតឡើងដឹងអារម្មណ៍ ដែលមិនទាន់រលត់តាមចក្ខុទ្វារនោះ ជាចក្ខុទ្វារវិថីទាំងអស់ ៧ វិថី ព្រោះអាស្រ័យចក្ខុទ្វារ ទើបកើតឡើងដឹងអារម្មណ៍ដែលកំពុងប្រាកដតាមភ្នែក ដែលមិនទាន់រលត់ ។

ខណៈដែលកំពុងឮសំឡេង វិថីចិត្តដែលកើតឡើងដឹងសំឡេងដែលនៅមិនទាន់រលត់តាមសោតទ្វារទាំង ៧ វិថីនោះ ក៏ជាសោតទ្វារវិថីតាមផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ក៏មានន័យដូចគ្នា ។

ការដឹងអារម្មណ៍តាមបញ្ចទ្វារនីមួយ ៗ និងវារៈនីមួយ ៗ នោះ មានវិថីចិត្តកើតច្រើន តិចខុសផ្សេងគ្នាជា ៤ វារៈ គឺ មោឃវារៈ ភវង្គវារៈ ជវនវារៈ តទាលម្ពណវារៈ ។

វារៈ គឺវិថីចិត្ត ដែលកើត រលត់បន្តគ្នា ដោយដឹងអារម្មណ៍តែមួយដូចគ្នា និង តាមទ្វារតែមួយដូចគ្នា ដែលវារៈខ្លះវិថីចិត្តកើតទាំង ៧ វិថី វារៈខ្លះ វិថីចិត្តកើត ៦ វិថី វារៈខ្លះវិថីចិត្តកើត ៥ វិថី វារៈខ្លះវិថីចិត្តមិនកើតឡើយ មានតែអតីតភវង្គ និងភវង្គចលនៈប៉ុណ្ណោះ គឺពេលដែលរូបប៉ៈខ្ចប់ នឹងបសាទ នឹងប៉ៈខ្ចប់នឹងអតីតភវង្គនោះ អតីតភវង្គរលត់ទៅហើយ ភវង្គចលនៈ ក៏នៅមិនទាន់កើត ទើបបានជាអតីតភវង្គកើតរលត់ច្រើន ខណៈទៀត រួចហើយភវង្គចលនៈទើបកើតឡើងញ័រហើយរលត់ទៅច្រើន ខណៈ ពេលអារម្មណ៍ គឺរូបដែលប៉ៈខ្ចប់បសាទនោះជិតនឹងរលត់ ទើបមិន ជាបច្ច័យឱ្យវិថីចិត្តកើតឡើងដឹងអារម្មណ៍នោះ កាលវិថីចិត្តមិនកើតឡើង ដឹងអារម្មណ៍ដែលប៉ៈខ្ចប់បសាទទើបជា **មោឃវារៈ** ដូចខណៈដេកលក់ យ៉ាងស៊ប់ត្រូវគេដាស់ហើយក៏នៅមិនទាន់ភ្ញាក់ រហូតកេះយ៉ាងខ្លាំងក៏នៅ មិនភ្ញាក់ទៀត ខណៈនោះជាមោឃវារៈ ព្រោះអាវជ្ជនចិត្តមិនកើតមានតែ អតីតភវង្គ និងភវង្គចលនៈ ។ កាលវិថីចិត្តមិនកើតដឹងអារម្មណ៍ ដែល ប៉ៈខ្ចប់ទើបជា **មោឃវារៈ និងអារម្មណ៍នោះក៏ជាអតិបរិត្តារម្មណ៍ ជា អារម្មណ៍ដែលតិចតួចបំផុត គឺគ្រាន់តែប៉ៈខ្ចប់បសាទរូប និងភវង្គ តែមិន ធ្វើឱ្យវិថីចិត្តកើតបានឡើយ** ។

វារៈខ្លះ កាលអតីតភវង្គកើតឡើងហើយរលត់ទៅច្រើនខណៈ ភវង្គ ចលនៈក៏កើត និងរលត់ទៅច្រើនខណៈ ភវង្គុប្បច្ឆេទៈក៏កើត ហើយរលត់ ទៅ បញ្ចទ្វារាវជ្ជនចិត្តកើត ហើយរលត់ទៅ បញ្ចវិញ្ញាណដួងណាមួយកើត

ហើយរលត់ទៅ សម្បដិច្ឆន្នចិត្តកើតហើយរលត់ទៅ សន្តីរណចិត្តកើត ហើយរលត់ទៅ ភវង្គចិត្តកើតហើយរលត់ទៅ ២ - ៣ ខណៈ រូបក៏រលត់ ជវនចិត្តទើបកើតមិនបាន វារៈនោះ ទើបជា**ភវង្គវារៈ** ព្រោះវិថីចិត្ត ធ្លាក់ចុះអស់ត្រឹមភវង្គចិត្ត ។ សភាវធម៌ទាំងពួងតាមសេចក្តីពិត ជា យ៉ាងនេះ ដូច្នេះ **កាលអារម្មណ៍ប៉ះខ្ទប់នឹងបសាទវារៈនីមួយ ៗ នោះ មិនមែនវិថីចិត្តថានឹងត្រូវកើតរលត់បន្តគ្នារហូតទៅទាំង ៧ វិថីទេ** កាល វិថីចិត្តមិនកើតសោះ គឺជាមោឃវារៈ កាលវិថីចិត្តអស់ត្រឹមត្រង់ភវង្គៈ ក៏ជាភវង្គវារៈ ។ អារម្មណ៍នៃភវង្គវារៈជា **បរិត្តារម្មណ៍** គឺជាអារម្មណ៍ នៃវិថីចិត្តត្រឹមតែបន្តិចបន្តួច ជាអារម្មណ៍នៃវិថីចិត្តត្រឹមតែ ៥ វិថីប៉ុណ្ណោះ ។

ចំណែកវារៈណា ពេលដែលភវង្គចិត្តរលត់ហើយ ជវនចិត្តកើត រលត់បន្តគ្នា ៧ ខណៈ ហើយអារម្មណ៍ក៏រលត់ តទាលម្ពណវិថីចិត្ត កើតមិនបាន ការដឹងអារម្មណ៍នៃវិថីចិត្តវារៈនោះគឺជា **ជវនវារៈ** ព្រោះមាន វិថីចិត្តត្រឹមតែ ៦ វិថី គឺមានត្រឹមតែជវនវិថីប៉ុណ្ណោះ ហើយរូបក៏រលត់ទៅ ។ កាលវិថីចិត្តធ្លាក់ចុះអស់ត្រង់ជវនវិថី ការដឹងអារម្មណ៍វារៈនោះ ទើប ជាជវនវារៈ ។ អារម្មណ៍នៃជវនវារៈជា **មហន្តារម្មណ៍** គឺជាអារម្មណ៍ ដែល ជាក់ច្បាស់ ធ្វើឱ្យកុសល ឬអកុសល ឬមហាកិរិយាចិត្ត (ជំនួសកុសលចិត្ត) នៃព្រះអរហន្តកើតបាន ។

ចំណែកវារៈណា ដែលជវនចិត្តកើត រលត់ ៧ ដង ហើយអារម្មណ៍ នៅមិនទាន់រលត់ ទើបជាបច្ច័យឱ្យតទាលម្ពណវិថីចិត្តកើតឡើងដឹង

អារម្មណ៍ ដែលនៅមិនទាន់រលត់នោះ ២ ខណៈទៀត ការដឹងអារម្មណ៍នៃវិថីចិត្តវារៈនោះ ទើបជា **តទារម្មណវារៈ** ឬ **តទាលម្ពណវារៈ** ព្រោះវិថីចិត្តធ្លាក់ចុះអស់ត្រឹមតទាលម្ពណៈ អារម្មណ៍នៃតទាលម្ពណវារៈជា **អតិ-មហន្តារម្មណ៍** គឺជាអារម្មណ៍ដែលច្បាស់លាស់ខ្លាំង ព្រោះសូម្បីតែជវនវិថីចិត្ត ៧ ខណៈរលត់ទៅហើយ អារម្មណ៍ក៏នៅមិនទាន់រលត់ ទើបជាបច្ច័យឱ្យតទាលម្ពណវិថីចិត្តកើតបាន ។

ការដឹងអារម្មណ៍តាមមនោទ្វារវិថីមានត្រឹមតែ ២ វារៈ ប៉ុណ្ណោះ គឺជវនវារៈ និងតទាលម្ពណវារៈ ។

អារម្មណ៍នៃជវនវារៈតាមមនោទ្វារជា **អវិភូតារម្មណ៍** ព្រោះជាអារម្មណ៍ដែលច្បាស់តិចជាងតទាលម្ពណៈវារៈ ។

អារម្មណ៍នៃតទាលម្ពណៈវារៈតាមមនោទ្វារជា **វិភូតារម្មណ៍** ព្រោះជាអារម្មណ៍ដែលច្បាស់ជាងជវនវារៈ ។

ទ្វារ ៦

ទ្វារ គឺផ្លូវដែលចិត្តកើតឡើងដឹងអារម្មណ៍ដទៃ ដែលមិនមែនអារម្មណ៍ របស់ភវង្គចិត្ត ដូច្នេះ ទ្វារទើបជាផ្លូវដឹងអារម្មណ៍នៃវិថីចិត្ត ។ ទ្វារមាន ៦ ជារូប ៥ ទ្វារ និងជានាម ១ ទ្វារ គឺ

ចក្ខុទ្វារ	បានដល់	ចក្ខុបសាទ	១

សោតទ្វារ	បានដល់	សោតបសាទ ១
ឃានទ្វារ	បានដល់	ឃានបសាទ ១
ជិវ្ហាទ្វារ	បានដល់	ជិវ្ហាបសាទ ១
កាយទ្វារ	បានដល់	កាយបសាទ ១
មនោទ្វារ	បានដល់	ភវង្គុប្បច្ឆេទចិត្ត ១
		(ដែលកើតមុនមនោទ្វារាវជ្ជនចិត្ត) ១

ឥត្ថ ៦

រូបដែលជាទីកើតនៃចិត្តក្នុងភូមិមានខន្ធ ៥ នោះ មាន ៦ រូប ហៅថាវត្ថុរូប ៦ គឺ

ចក្ខុបសាទរូប ១	ជាចក្ខុវត្ថុ ជាទីកើតនៃចក្ខុវិញ្ញាណ ២ ដួង
សោតបសាទរូប ១	ជាសោតវត្ថុជាទីកើតនៃសោតវិញ្ញាណ ២ ដួង
ឃានបសាទរូប ១	ជាឃានវត្ថុជាទីកើតនៃឃានវិញ្ញាណ ២ ដួង
ជិវ្ហាបសាទរូប ១	ជាជិវ្ហាវត្ថុ ជាទីកើតនៃជិវ្ហាវិញ្ញាណ ២ ដួង
កាយបសាទរូប ១	ជាកាយវត្ថុ ជាទីកើតនៃកាយវិញ្ញាណ ២ ដួង

ហទយរូប ១ ជាហទយវត្ថុជាទីកើតនៃចិត្តដទៃទៀតទាំងអស់ ក្នុងភូមិមានខន្ធ ៥ វៀរតែទ្វិបញ្ចវិញ្ញាណ ១០ ដួងប៉ុណ្ណោះ ។

ដូច្នេះ បសាទរូប ៥ ទើបជាទ្វារទាំង ៥ និងវត្ថុ ៥ ដូចនេះ គឺ

ចក្ខុបសាទរូប ជាចក្ខុទ្វារនៃចក្ខុទ្វារវជ្ជនចិត្ត ចក្ខុវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទាលម្ពណចិត្ត ដែលដឹងរូបារម្មណ៍ប៉ះខ្ទប់ចក្ខុបសាទនោះ ហើយរូបារម្មណ៍នោះក៏នៅមិនទាន់រលត់ ។ ប៉ុន្តែចក្ខុបសាទរូបនោះ ជាចក្ខុវត្ថុ គឺជាទីកើតនៃចក្ខុវិញ្ញាណ ២ ដួងប៉ុណ្ណោះ ចំណែកវិថីចិត្តឯទៀត ៗ ក្នុងវារៈដូចគ្នានោះ គឺ ចក្ខុទ្វារវជ្ជនចិត្ត សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទាលម្ពណចិត្ត កើតត្រង់ហទយវត្ថុ ។

សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូប ក៏មានន័យដូចគ្នា ។

ចំណែកហទយរូបនោះ ជាវត្ថុ គឺជាទីកើតនៃចិត្ត ប៉ុន្តែមិនមែនជាទ្វារឡើយ ។

សំណួរសាឡើងវិញ

១ - ព្រោះហេតុអ្វី វិថីចិត្តតាមមនោទ្វារ ទើបតិចជាងវិថីចិត្តតាមបញ្ចទ្វារ ?

២ - លោភមូលចិត្ត កើតបានប៉ុន្មានទ្វារ ?

៣ - បញ្ចទ្វារាវជ្ជនចិត្ត និងមនោទ្វារាវជ្ជនចិត្ត កើតបានប៉ុន្មានទ្វារ ?

៤ - មោឃវារៈ ភោដ្ឋព្វនវារៈ ជវនវារៈ តទាលម្ពណវារៈ គឺអ្វី ?

៥ - វិភូតារម្មណ៍ និងអវិភូតារម្មណ៍ គឺអ្វី ?

៦ - បដិសន្ធិចិត្តក្នុងភូមិដែលមានខន្ធ ៥ កើតត្រង់រូបអ្វី ?

៧ - អកុសលចិត្តក្នុងភូមិដែលមានខន្ធ ៥ កើតត្រង់រូបអ្វី ?

៨ - កិរិយាចិត្តក្នុងភូមិដែលមានខន្ធ ៥ កើតត្រង់រូបអ្វី ?

៩ - សោតទ្វារវិថីចិត្ត កើតត្រង់រូបអ្វីខ្លះ ?

១0 - ចេតសិកក្នុងភូមិដែលមានខន្ធ ៥ កើតត្រង់រូបអ្វីខ្លះ ?

មេរៀនទី ៥

ការកើត រលត់បន្តគ្នារបស់ចិត្ត និងវិថីចិត្តផ្សេង ៗ នោះជាជីវិតប្រក្រតីប្រចាំថ្ងៃ ប៉ុន្តែកាលដែលមានសព្ទធម៌ដែលសម្តែងលក្ខណៈនិងកិច្ចនៃចិត្តផ្សេង ៗ ក៏ធ្វើឱ្យសង្ស័យ ព្រោះមិនយល់នូវអត្ថន័យនៃសព្ទនោះ ៗ ។ ប៉ុន្តែសព្ទនោះ ៗ សុទ្ធតែសម្តែងនូវលក្ខណៈនៃសភាវធម៌ផ្សេង ៗ ក្នុងជីវិតប្រក្រតីប្រចាំថ្ងៃនេះឯង ។ ដូច្នេះ ធម៌ទាំងឡាយទើបមិនបាននៅក្នុងតែសៀវភៅតម្រាឡើយ គឺជាជីវិតពិត ៗ តែមួយខណៈ ៗ ដែលកំពុងឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស នឹកគិត ។ ខណៈនេះគ្រប់លោកអ្នកកំពុងឃើញ ដឹងហើយថាជាវិថីចិត្តដែលមានអាវជ្ជនចិត្ត ចក្ខុវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្តកើត រលត់បន្តគ្នាតែមួយខណៈ ៗ ។ ការយល់ព្រះធម៌រមែងជាស់តឿនឱ្យរលឹកថា ជវនវិថីចិត្តដែលកើតក្នុងវារៈដែលឃើញ ឮ ធុំក្លិន ដឹងរស ជាដើមនោះជាកុសល ឬអកុសលដែលកើត រលត់សន្សំបន្តសន្តានខ្លួនឯង ។

ការសិក្សារឿងជាតិទាំង ៤ នៃចិត្ត គឺចិត្តកើតឡើងជាកុសល ១ ជាអកុសល ១ ជាវិបាក ១ ជាកិរិយា ១ ទើបធ្វើឱ្យដឹងថា ចិត្តខណៈណាជាហេតុអាចឱ្យកើតផល គឺវិបាកចិត្តទៅខាងមុខ និងចិត្តខណៈណាជាវិបាកគឺផលនៃហេតុដែលបានធ្វើហើយក្នុងអតីត ។ ដូច្នេះ ការសិក្សារឿងចិត្ត ដែលជាវិថីចិត្ត និងចិត្តដែលមិនមែនវិថីចិត្តនោះ នឹងត្រូវដឹងដែរថាចិត្តនោះ ៗ នឹងជាជាតិអ្វី ដូចជា **បដិសន្ធិចិត្ត ជាវិបាកចិត្ត** ជាផលរបស់

កម្មមួយក្នុងកម្មទាំងឡាយដែលបានធ្វើក្នុងអតីត ជាបច្ច័យធ្វើឱ្យបដិសន្ធិចិត្តកើតបន្តពីចុតិចិត្តនៃជាតិមុន ។ បដិសន្ធិចិត្ត ជាវិបាកចិត្ត ដែលធ្វើកិច្ចបដិសន្ធិក្នុងភពមួយ ជាតិមួយ ត្រឹមតែ ១ ជួរខណៈប៉ុណ្ណោះ និងធ្វើកិច្ចបដិសន្ធិក្នុងជាតិនោះមិនបានទៀតឡើយ គឺធ្វើបានតែត្រឹមជួរខណៈដំបូងតែ ១ ខណៈដែលកើតពីចុតិចិត្ត នៃជាតិមុនប៉ុណ្ណោះរួចហើយ បដិសន្ធិចិត្តក៏រលត់ទៅមិនឋិតថេរឡើយ ។

កាលបដិសន្ធិចិត្ត ដែលជាជាតិវិបាករលត់ទៅហើយ បដិសន្ធិចិត្តនោះ ជាអនន្តរប្បច្ច័យធ្វើឱ្យដួងបន្ទាប់កើតបន្តពីបដិសន្ធិចិត្តភ្លាម ។ ចិត្តដែលកើតតពីបដិសន្ធិចិត្តនោះ ធ្វើភវង្គកិច្ច ទើបមិនមែនវិថីចិត្ត ។ ភវង្គចិត្តក៏ជាវិបាកចិត្ត ដូច្នេះ កម្មទើបមិនបានត្រឹមតែធ្វើជាបច្ច័យឱ្យបដិសន្ធិចិត្តកើតហើយរលត់ទៅប៉ុណ្ណោះទេ តែកម្មនៅញុំាងឱ្យវិបាកចិត្ត កើតឡើងធ្វើភវង្គកិច្ចបន្ត ហើយភវង្គចិត្តដួងដំបូងដែលកើតបន្តពីបដិសន្ធិចិត្តនោះ ឈ្មោះថា **បឋមភវង្គ** ចំណែកភវង្គដួងត ៗ ទៅរហូតដល់ចុតិចិត្តនោះ មិនចាំបាច់នឹងត្រូវរាប់ឡើយ ។

ភវង្គចិត្តកើតបន្តគ្នាទៅរឿយ ៗ រហូតវិថីចិត្តនឹងកើត ។ វិថីចិត្តដំបូងដែលកើតមុនវិថីចិត្តដទៃ ៗ គឺចិត្តដែលធ្វើអាវជ្ជនកិច្ចបានដល់អាវជ្ជនចិត្ត ២ ដួង គឺបញ្ចទ្វារាវជ្ជនកិច្ច ធ្វើអាវជ្ជនកិច្ចតាមបញ្ចទ្វារណាមួយ និងមនោទ្វារាវជ្ជនចិត្តធ្វើអាវជ្ជនកិច្ចតាមមនោទ្វារ ១ ដួង ។ ចិត្តដែលធ្វើអាវជ្ជនកិច្ចទាំង ២ ដួងនេះ ជាកិរិយាចិត្ត គឺមិនមែនកុសលចិត្ត

មិនមែនអកុសលចិត្ត និងមិនមែនវិបាកចិត្ត ព្រោះចិត្ត ២ ដួងនេះ ដឹងបានទាំងឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលល្អគួរជាទីពេញចិត្ត និង អនិដ្ឋារម្មណ៍ គឺអារម្មណ៍ដែលមិនគួរពេញចិត្ត ។ បើជាវិបាកចិត្តហើយ អកុសលវិបាកដឹងបានតែអនិដ្ឋារម្មណ៍ និងកុសលវិបាកក៏ដឹងបានតែ ឥដ្ឋារម្មណ៍ប៉ុណ្ណោះ ។

សេចក្តីក្នុងអដ្ឋសាលិនី សម្តែងលក្ខណៈនៃកិរិយាចិត្តថា ត្រឹមតែជាការធ្វើ និងសម្តែងលក្ខណៈនៃកិរិយាចិត្តដែលខុសគ្នាដោយកិច្ចថា

គឺក្នុងបណ្តាកិរិយាចិត្តគ្រប់ដួងនីមួយ ។ កិរិយាចិត្តដួងណា មិនដល់សភាពជាជវនទេ កិរិយាចិត្តដួងនោះរមែងមិនមានផល ដូចផ្កាឈើជ្រុះ (វាតបុប្ផំ ដែលមូលដីកាចាស់ថា មោឃបុប្ផំ សំដៅផ្កាឈើដែលឥតផល) ព្រោះផ្កាឈើខ្លះ កាលណារុះរោយទៅហើយ ក៏មិនមានផលយ៉ាងណា កិរិយាចិត្តក៏ដូច្នោះដែរ គឺកិរិយាចិត្តដួងណាដែលមិនដល់សភាពជាជវន កិរិយាចិត្តដួងនោះ រមែងមិនមានផលដូចផ្កាឈើជ្រុះ ។ **កិរិយាចិត្ត ដែលមិនដល់ជវន គឺមិនជាជវនវិថីចិត្តនោះមាន ២ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង និងមនោទ្វារាវជ្ជនចិត្ត ១ ដួង** ។ បញ្ចទ្វារាវជ្ជនចិត្ត ធ្វើកិច្ចតែ ១ គឺធ្វើអាវជ្ជនកិច្ចតែ ១ គឺធ្វើអាវជ្ជនកិច្ចតាមបញ្ចទ្វារ ។ មនោទ្វារាវជ្ជនចិត្តធ្វើកិច្ច ២ គឺធ្វើអាវជ្ជនកិច្ច តាមមនោទ្វារ ១ និងធ្វើវោដ្ឋព្វនកិច្ចតាមបញ្ចទ្វារ ១ ។ ចំណែកកិរិយាចិត្តដទៃ ៗ ដែលដល់សភាពជាជវននោះ ជាចិត្តនៃព្រះអរហន្ត ដែលមានសេចក្តីក្នុង អដ្ឋសាលិនី ឧបមាថា

កិរិយាចិត្តដួងណា ដែលដល់សភាពជាជវន (គឺកិរិយាជវនវិថីចិត្តនៃព្រះអរហន្ត) កិរិយាចិត្តដួងនោះ ក៏មិនមានផល ដូចផ្កានៃដើមឈើដែលមានឬសខូចពុកផុយរលួយអស់ហើយ ទើបត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅក្នុងអំណាចឱ្យសម្រេចកិច្ចនោះ ។ ។

អ្នកដែលមិនមែនព្រះអរហន្ត មានកិរិយាចិត្តត្រឹមតែ ២ ដួង ប៉ុណ្ណោះ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ និងមនោទ្វារាវជ្ជនចិត្ត ១ ។

កិរិយាចិត្តដទៃទាំងអស់ក្រៅពីបញ្ចទ្វារាវជ្ជនចិត្ត និងមនោទ្វារាវជ្ជនចិត្ត ជាចិត្តនៃព្រះអរហន្តទាំងអស់ ។ ដូច្នេះ ព្រះអរហន្ត ទើបមានកិរិយាចិត្តដែលមិនមែនជវន ២ ដួង គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង មនោទ្វារាវជ្ជនចិត្ត ១ ដួង និងជវនវិថីដែលជាកិរិយាចិត្តប៉ុណ្ណោះ ។ ព្រោះព្រះអរហន្តរំលត់កុសល និងអកុសលទាំងអស់ ទើបមិនមានជវនចិត្តដែលជាកុសល និងអកុសលឡើយ ។

វិថីចិត្តដែលដឹងអារម្មណ៍តាមភ្នែកនោះ នៅពេលបញ្ចទ្វារាវជ្ជនចិត្តរលត់ទៅហើយ ចិត្តឃើញ គឺចក្ខុវិញ្ញាណជាវិបាកចិត្ត ជាផលរបស់កម្មដែលបានធ្វើហើយ ។ កុសលកម្មជាបច្ច័យឱ្យចក្ខុវិញ្ញាណកុសលវិបាកឃើញរូបផ្សេង ។ ដែលប្រាកដតាមភ្នែក ស្អាតល្អ គួរជាទីពេញចិត្ត ជាឥដ្ឋារម្មណ៍ ។ អកុសលកម្មជាបច្ច័យឱ្យចក្ខុវិញ្ញាណអកុសលវិបាកឃើញរូបដែលមិនស្អាតល្អ មិនជាទីពេញចិត្ត ជាអនិដ្ឋារម្មណ៍ ។ វិថីដែលឮសំឡេងតាមត្រចៀក គឺសោតវិញ្ញាណ ក៏ជាវិបាកចិត្តដែលមិនមានអ្នកណា

ដឹងថា ខណៈណាសោតវិញ្ញាណ នឹងបានឮសំឡេងអ្វី ។ ទាំងនេះ រមែងប្រព្រឹត្តទៅតាមហេតុ គឺកម្មដែលធ្វើហើយក្នុងអតីតទាំងអស់ ខណៈបានធុំក្លិនតាមច្រមុះ ឃានវិញ្ញាណដែលដឹងក្លិន ក៏ជាវិបាកចិត្ត ។ ខណៈទទួលរសតាមផ្លូវអណ្តាត ជិវ្ហាវិញ្ញាណ ក៏ជាវិបាកចិត្ត ខណៈប៉ះខ្ទប់សម្ផស្សតាមផ្លូវកាយ កាយវិញ្ញាណដែលដឹងត្រជាក់ ក្តៅ រឹង ទន់ តឹង កម្រើក ញ័រ ក៏ជាវិបាកចិត្ត ជាផលរបស់កម្ម ដែលជាបច្ច័យឱ្យវិបាកចិត្តទាំងនេះកើតឡើង ទទួលដឹងអារម្មណ៍ពីបញ្ចទ្វារវជ្ជនចិត្ត ។ ហើយពេលបញ្ចទ្វារវជ្ជនចិត្ត ដែលឃើញ ឮ ធុំក្លិន ទទួលរស ដឹងសម្ផស្សរលត់ទៅហើយ ក៏ជាអនន្តរប្បច្ច័យឱ្យសម្បដិច្ឆន្នចិត្តកើតឡើង ទទួលដឹងអារម្មណ៍នោះ ។ បន្ត សម្បដិច្ឆន្នចិត្តក៏ជាវិបាកចិត្ត ព្រោះជាផលរបស់កម្មតែមួយដែលជាបច្ច័យឱ្យចក្ខុវិញ្ញាណកើតឡើងនោះឯង ។ កាលសម្បដិច្ឆន្នចិត្តរលត់ទៅហើយ កម្មនោះឯងក៏ធ្វើឱ្យសន្តីរណចិត្ត ដែលជាវិបាកចិត្តកើតឡើងធ្វើសន្តីរណកិច្ចពីសម្បដិច្ឆន្នចិត្ត ។

ដូច្នេះ វិថីចិត្តដែលវិបាកចិត្ត កើតឡើងតាមបញ្ចទ្វារនោះ គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ ទើបមិនសន្សំសន្តានត្រឹមតែជាផលរបស់កម្ម ដែលកើតឡើងធ្វើកិច្ចនៃខ្លួន ហើយក៏រលត់ទៅ តពីនោះវោដ្ឋព្វនចិត្ត ដែលបានដល់មនោទ្វារវជ្ជនចិត្តនោះឯង ធ្វើវោដ្ឋព្វនកិច្ចតាមបញ្ចទ្វារ ។ វោដ្ឋព្វនចិត្ត ជាកិរិយាចិត្ត ធ្វើវោដ្ឋព្វនកិច្ច ហើយក៏រលត់ទៅមិនបានសន្សំ

សន្តានទេ ។ កាលវោដ្ឋព្វនកិច្ចរលត់ទៅហើយ ចិត្តដែលកើតត គឺជវនវិថីចិត្ត ដែលធ្វើកិច្ចស្ទុះទៅក្នុងអារម្មណ៍ ជាកុសល ឬ អកុសល សម្រាប់អ្នកដែលមិនមែនជាព្រះអរហន្ត និងសម្រាប់ព្រះអរហន្ត គឺជាកិរិយាចិត្ត ។ ជវនវិថីចិត្តកើត រលត់បន្តគ្នាដដែល ៗ ៧ ខណៈ ទើបជាខណៈដែលសន្សំសន្តានខ្លួនឯង ដែលក៏ប្រព្រឹត្តក្នុងខណៈនេះ នោះឯង ។

ក្នុងអដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណីបករណ ឧបមា ការកើតឡើងទទួលដឹងអារម្មណ៍នៃវិថីចិត្តតាមបញ្ចទ្វារថា ព្រះរាជា ១ អង្គ ផ្ទំលក់លើក្រឡាបន្ទំ មហាតឡិកម្នាក់គក់ច្របាច់ថ្វាយ នាយទ្វារម្នាក់ឈរយាមត្រង់ទ្វារ ទាហានយាម ៣ នាក់ នៅឈរតាមលំដាប់រៀងគ្នា ។ ទីនោះមានមនុស្សខាងក្រៅម្នាក់ កាន់គ្រឿងរាជបណ្ណាការ មកគោះទ្វារហៅ ។ នាយទ្វារមិនបានឮសំឡេងទេ មហាតឡិកទើបបានឱ្យសញ្ញានាយទ្វារទើបបើកទ្វារមើលដោយសញ្ញានោះ ទាហានទី ១ ទទួលគ្រឿងបណ្ណាការបញ្ជូនឱ្យទាហានទី ២ អ្នកទី ២ ក៏ហុចឱ្យទាហានទី ៣ អ្នកទី ៣ ក៏ពោលទូលថ្វាយព្រះរាជា ៗ សោយ ។ ពាក្យឧបមាប្រៀបធៀបនេះសម្តែងឱ្យឃើញ **វិថីចិត្ត** ដែលកើតឡើងទទួលដឹងអារម្មណ៍តែ ១ ខណៈ ៗ ថាខណៈដែលអារម្មណ៍ប៉ះខ្ទប់នឹងចក្ខុបសាទ អារម្មណ៍ប្រៀបដូចមនុស្សក្រៅផ្ទះដែលកាន់គ្រឿងបណ្ណាការគោះទ្វារហៅមហាតឡិក **គឺបញ្ចទ្វារាវជ្ជនចិត្ត** ជាខណៈដែលដឹងថាមានភ្ញៀវមកគោះទ្វារ ទើបឱ្យសញ្ញា គឺដឹងអារម្មណ៍ដែលប៉ះខ្ទប់ហើយក៏រលត់ទៅ **ចក្ខុវិញ្ញាណ** ក៏កើតឡើងបន្តធ្វើ

កិច្ចឃើញត្រង់ចក្ខុបសាទ ។ ហើយតពីនោះទាហានអ្នកយាមទី ១ គឺ **សម្បដិច្ឆន្នចិត្ត** ក៏ទទួលគ្រឿងបណ្ណាការហុចទៅឱ្យអ្នកទី ២ **គឺសន្តីរណ-ចិត្ត** អ្នកទី ២ ក៏ហុចឱ្យអ្នកទី ៣ **គឺវោដ្ឋព្វនចិត្ត** អ្នកទី ៣ ពោលទូលថ្វាយព្រះរាជា **គឺជវនចិត្ត** ព្រះរាជាក៏បានសោយគ្រឿងរាជបណ្ណាការ **គឺអារម្មណ៍នោះ** ។

មានពាក្យអធិប្បាយថា សេចក្តីប្រៀបធៀបនោះ មានអត្ថន័យយ៉ាងណា គឺមានអត្ថន័យថា **អារម្មណ៍មានកិច្ច គឺនាទីត្រឹមតែប៉ះខ្ទប់បសាទប៉ុណ្ណោះ** អ្នកខាងក្រៅផ្ទះ មិនបានចូលទៅគាល់ព្រះចៅផែនដីទេ តែគ្រឿងរាជបណ្ណាការហុចតពីអ្នកទី ១ ទី ២ ទី ៣ នេះហើយ ទើបដល់ព្រះរាជា ។

ចក្ខុវិញ្ញាណប៉ុណ្ណោះ ដែលធ្វើកិច្ចឃើញអារម្មណ៍ដែលប៉ះខ្ទប់ទ្វារ។ អារម្មណ៍អាចត្រឹមតែប៉ះខ្ទប់បសាទរូបប៉ុណ្ណោះ តែថាចិត្តកើតឡើងដឹងអារម្មណ៍បន្តគ្នា ដោយអារម្មណ៍មិនបានឆ្លងផុត ឬថាកន្លងរំលង បសាទចូលទៅដល់ទីដទៃឡើយ ។

កាលពិចារណានូវពាក្យឧបមានេះ ក៏យល់ដល់ការប្រៀបធៀបនឹងវិថីចិត្ត ដែលកើតឡើងធ្វើកិច្ចតែ ១ ខណៈ ។ ថា ចក្ខុវិញ្ញាណធ្វើកិច្ចឃើញត្រង់ចក្ខុបសាទរូប ដែលជាចក្ខុទ្វារ ដូចជានាយទ្វារដែលបើកទ្វារមើលត្រង់ទ្វារ ។ សម្បដិច្ឆន្នៈ ជាទាហានទី ១ ដែលទទួលគ្រឿងបណ្ណាការហុចទៅឱ្យអ្នកទី ២ ព្រោះចក្ខុវិញ្ញាណធ្វើកិច្ចឃើញហើយ ក៏រលត់ទៅ

ចក្ខុវិញ្ញាណ នឹងធ្វើកិច្ចទទួលអារម្មណ៍ ឱ្យដូចជាសម្បដិច្ឆន្នៈមិនបាន ព្រោះថា ចក្ខុវិញ្ញាណធ្វើទស្សនកិច្ចបានតែម៉្យាង គឺឃើញត្រង់ទ្វារ គឺបសាទទ្វារប៉ុណ្ណោះ ។ តែសម្បដិច្ឆន្នចិត្តដូចជាទាហានទី ១ ដែលធ្វើកិច្ចទទួលអារម្មណ៍ ហើយក៏បញ្ជូនទៅឱ្យទាហានទី ២ គឺសន្តីរណៈ ដែលពិចារណាអារម្មណ៍ហើយ បញ្ជូនទៅឱ្យវោដ្ឋព្វនចិត្តកាត់ក្តីសម្រេច ហើយបញ្ជូនបន្តទៅថ្វាយព្រះរាជា គឺជវនវិថីចិត្តធ្វើកិច្ចសោយ គឺសេពគ្រឿងបណ្តាការនោះ ។

ដូច្នេះ ដែលប្រើពាក្យថា សេព ឬសោយ ក៏ដើម្បីអាចនឹងឱ្យយល់ពិត ។ ក្នុងលក្ខណៈនៃកុសលចិត្ត ឬអកុសលចិត្ត ដែលធ្វើជវនកិច្ចតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ។ ជវនវិថីចិត្តជាចិត្តដែលសេពអារម្មណ៍ដោយ លោភៈ ទោសៈ មោហៈ ឬដោយកុសល ឬដោយកិរិយាចិត្តរបស់ព្រះអរហន្ត ។ ជវនចិត្ត ធ្វើកិច្ចស្ទុះទៅក្នុងអារម្មណ៍ដែលមិនមែនឃើញ មិនមែនទទួល មិនមែនពិចារណា មិនមែនសម្រេចទេ ព្រោះចិត្តដែលកើតមុនបានធ្វើកិច្ចទាំងនោះ ទៅអស់ហើយ ទើបជាបច្ច័យឱ្យកុសលចិត្ត ឬអកុសលចិត្ត ឬកិរិយាចិត្ត កើតឡើងសេព គឺស្ទុះទៅក្នុងអារម្មណ៍នោះដល់ ៧ ខណៈជវនវិថីចិត្ត ទើបជាវិថីចិត្តដែលសេពអារម្មណ៍ពិត ។ ។ បើជាមោឃវារៈ សូម្បីសំឡេងប៉ះសោតបសាទក៏ដោយ ក៏មិនបានឮដែរ ឬបើជាវោដ្ឋព្វនវារៈ កុសលចិត្ត អកុសលចិត្ត កិរិយាចិត្ត ក៏មិនកើត ។ តើនឹងសេពអារម្មណ៍នោះ បានទេ ក្នុងពេលជវនវិថីចិត្ត

មិនកើត ? ប៉ុន្តែពេលជវនវិថីចិត្តកើត ទើបសេពអារម្មណ៍នោះដោយចិត្ត ១ ប្រភេទដូចគ្នា កើត រលត់បន្តដដែល ៗ ដល់ ៧ ខណៈស្រេចហើយ តែថាជាកុសលជវនវិថីចិត្ត ឬអកុសលជវនវិថីចិត្ត ឬកិរិយាជវនវិថីចិត្ត ។

ការដែលជវនវិថីចិត្តកើត រលត់ សេពអារម្មណ៍ដដែល ៗ ដល់ ៧ ខណៈនោះ ប្រព្រឹត្តដោយបច្ច័យ គឺជវនវិថីចិត្តខណៈទី ១ ជាអាសេវនប្ប-ច្ច័យ ឱ្យជវនវិថីចិត្ត ខណៈទី ២ កើតឡើងសេពអារម្មណ៍នោះ ដដែលទៀត និងជវនវិថីចិត្តខណៈទី ២ ក៏ជាអាសេវនប្បច្ច័យឱ្យជវនវិថីចិត្តទី ៣ កើតឡើងសេពអារម្មណ៍នោះដដែលទៀតរឿយ ៗ ទៅរហូតដល់ជវនវិថីចិត្តទី ៧ ទើបមិនជាអាសេវនប្បច្ច័យ ។

អាសេវនប្បច្ច័យ គឺអកុសលជវនវិថីចិត្ត កុសលជវនវិថីចិត្ត ឬកិរិយាជវនវិថីចិត្ត ដែលធ្វើឱ្យចិត្តជាតិតែ ១ ដូចគ្នា កើតឡើងធ្វើជវនកិច្ចដដែលទៀតនោះ ទើបជាកម្លាំងធ្វើឱ្យកុសលចិត្ត និងអកុសលចិត្ត ជាកម្ម-ប្បច្ច័យឱ្យវិបាកចិត្ត ដែលជាផលកើតឡើងក្នុងអនាគត និងជាឧបនិស្ស-យប្បច្ច័យឱ្យកុសលជវនវិថី និង អកុសលជវនវិថីកើតឡើងទៀតក្នុងអនាគត ។ ការសន្សំអកុសលប្រភេទផ្សេង ៗ ច្រើនសន្ធឹកសន្ធាប់ កពូនឡើងនោះ ពេលបើកភ្នែកភ្ញាក់ឡើងឃើញហើយ ក៏ធ្វើឱ្យវង្វេងភ្លាម ៗ ។ ខណៈដែលជាភវង្គចិត្តនោះ មិនដឹងអារម្មណ៍ តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ព្រោះបើនឹកគិត ឬយល់សប្តិ ក៏ជាមនោទ្វារវិថីចិត្ត មិនមែនភវង្គចិត្ត ។ ដូច្នេះ គ្រប់វេលាដែលជាភវង្គចិត្ត

នោះ មិនដឹងអារម្មណ៍ណា ។ នៃលោកនេះឡើយ លោកនេះមិនប្រាកដឡើយ ប៉ុន្តែសូម្បីនៅក្នុងខណៈនោះក៏មានអនុស័យកិលេស មិនមែនថាកាលមិនដឹងអារម្មណ៍ណា ។ ក្នុងលោកនេះហើយនឹងមិនមានកិលេសនោះទេ ទាំងនេះព្រោះកិលេសមាន ៣ ថ្នាក់ គឺ

អនុស័យកិលេស ជាកិលេសយ៉ាងល្អិត ដែលសន្សំដេកពួនសម្ងំនៅក្នុងចិត្ត

បរិយុដ្ឋានកិលេស ជាកិលេសយ៉ាងកណ្តាល ដែលកើតរួមនឹងជវនវិថីចិត្ត

វីតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ដែលកើតរួមនឹងជវនវិថីចិត្ត

ដូច្នេះ សូម្បីចិត្តដែលមិនមែនជាជវនវិថីចិត្ត ក៏មានអនុស័យកិលេស វៀរតែចិត្តព្រះអរហន្តប៉ុណ្ណោះ ដែលមិនមានកិលេសណា ។ ទាំងអស់ សោះឡើយ ។

ដូច្នេះ សូមឱ្យជ្រាបថា ខណៈណាដែលវិថីចិត្តកើតឡើងឃើញ (នូវអ្វី) សភាវៈដែលប្រាកដតាមភ្នែក បានឮសំឡេង ដែលប្រាកដតាមផ្លូវត្រចៀក បានធុំក្លិនតាមផ្លូវច្រមុះ ទទួលរសតាមអណ្តាត ប៉ះខ្ទប់សម្ផស្សផោដ្ឋព្វៈតាមផ្លូវកាយ ឬនឹកគិតរឿងរ៉ាវផ្សេង ។ តាមផ្លូវចិត្ត ខណៈនោះ ជវនវិថីចិត្ត ក៏សន្សំសន្តាននៃខ្លួនកើនឡើងទាំងជាអកុសល និង កាមាវចរកុសល និង កាមាវចរកិរិយាជវនវិថី ។

មួយវារៈ ។ដែលឃើញ	វិថីចិត្តទាំង ៧ វិថី ជាចក្ខុទ្វារវិថី ។
មួយវារៈ ។ ដែលឮ	វិថីចិត្តទាំង ៧វិថី ជាសោតទ្វារវិថី ។
មួយវារៈ ។ ដែលធុំក្លិន	វិថីចិត្តទាំង ៧វិថី ជាឃានទ្វារវិថី ។

មួយវារៈ ៗ ដែលទទួលរស	វិថីចិត្តទាំង ៧ វិថី ជាជិវ្ហាទ្វារវិថី ។
មួយវារៈ ៗដែលដឹងផោដ្ឋព្វៈ	វិថីចិត្តទាំង ៧ វិថី ជាកាយទ្វារវិថី ។
មួយវារៈ ៗ ដែលនឹកគិត	វិថីចិត្តទាំង ៣វិថី ជាមនោទ្វារវិថី ។

សំណួរសាឡើងវិញ

១ - វិថីចិត្តណា តាមបញ្ចទ្វារ និងតាមមនោទ្វារ ជាវិបាកចិត្តខ្លះ ?

២ - អ្នកដែលមិនមែនព្រះអរហន្ត មានកិរិយាចិត្ត ប៉ុន្មានដួង ?

៣ - ព្រះអរហន្តមានកិរិយាចិត្តដែលមិនមែនជវនវិថីប៉ុន្មានដួង ?

៤ - អាសេវនប្បច្ច័យ គឺអ្វី ?

៥ - ចិត្តខណៈណាជាអាសេវនប្បច្ច័យ ?

មេរៀនទី ៦

ចិត្តទាំង ៨៩ ដួង ចំណែកចេញជា ៤ ជាតិ គឺ

ជាកុសល **២១ ដួង**

ជាអកុសល **១២ ដួង**

ជាវិបាក **៣៦ ដួង**

ជាកិរិយា **២០ ដួង**

ការសិក្សារឿងជាតិនៃចិត្ត ក៏នឹងដឹងបានថា បុគ្គលម្នាក់ ៗ មានចិត្តប្រភេទណាខ្លះ ដូចនេះ គឺ

បុថុជ្ជន មានចិត្ត ៤ ជាតិ គឺកុសល អកុសល វិបាក កិរិយា

ព្រះសោតាបន្ន មានចិត្ត ៤ ជាតិ គឺកុសល អកុសល វិបាក កិរិយា

ព្រះសកទាគាមី មានចិត្ត ៤ ជាតិ គឺកុសល អកុសល វិបាក កិរិយា

ព្រះអនាគាមី មានចិត្ត ៤ ជាតិ គឺកុសល អកុសល វិបាក កិរិយា

ព្រះអរហន្ត មានចិត្ត ២ ជាតិ គឺវិបាក កិរិយា

នៅពេលដឹងថាចិត្ត ១ ដួង ៗ មានជាតិជាអ្វី គឺជាកុសល ឬអកុសល ឬវិបាក ឬកិរិយា ហើយត្រូវដឹងអំពីកិច្ចការងាររបស់ចិត្តដួងនីមួយ ៗ នោះទៀត ដោយសេចក្តីថា ចិត្តនោះធ្វើកិច្ចអ្វី ? ដូច្នេះ ចិត្តទើបមានឈ្មោះតាមកិច្ចរបស់ខ្លួននោះដែរ ដូចខណៈបដិសន្ធិ ជាវិបាកចិត្តជាផលរបស់កម្ម ។ ចិត្តដែលធ្វើកិច្ចបដិសន្ធិក្នុងសុគតិភូមិ ជាកុសលវិបាក

គឺជាផលនៃកុសលកម្ម ។ ចិត្តដែលធ្វើកិច្ចបដិសន្ធិ ក្នុងទុគ្គតិភូមិ ក្នុងអបាយភូមិ ជាអកុសលវិបាក គឺជាផលរបស់អកុសលកម្ម ។

ប៉ុន្តែ កុសលវិបាកចិត្ត និងអកុសលវិបាកចិត្តមិនបានធ្វើបដិសន្ធិកិច្ចគ្រប់ដួងទេ **ដូច្នេះ ចំពោះតែកុសលវិបាកចិត្ត និងអកុសលវិបាកចិត្តដែលធ្វើបដិសន្ធិកិច្ចប៉ុណ្ណោះ ដែលឈ្មោះថា បដិសន្ធិចិត្ត ។**

កុសលវិបាកចិត្ត និងអកុសលវិបាកចិត្តណាដែលធ្វើភវង្គកិច្ច កុសលវិបាកចិត្ត និងអកុសលវិបាកចិត្តនោះ ក៏ឈ្មោះថា **ភវង្គចិត្ត ។**

ចក្ខុវិញ្ញាណជាវិបាកចិត្ត ដែលធ្វើបដិសន្ធិកិច្ចមិនបាន ធ្វើភវង្គកិច្ចមិនបាន ធ្វើបានតែ **ទស្សនកិច្ចប៉ុណ្ណោះ ទើបឈ្មោះថា ចក្ខុវិញ្ញាណ** ព្រោះជាចិត្តដែលដឹងច្បាស់ គឺឃើញអារម្មណ៍ដែលប្រាកដដោយអាស្រ័យភ្នែក ដូច្នេះ ទើបហៅឈ្មោះចិត្តតាមប្រភេទ នៃចិត្តដែលដឹងច្បាស់អារម្មណ៍តាមទ្វារផងដែរ ។

សំណួរ ហេតុអ្វី ? ចិត្តមានតែ ៤ ជាតិ មិនមាន ៥ ជាតិ គឺគួរតែជាកុសលចិត្តជាតិ ១ ជាអកុសលចិត្តជាតិ ១ ជាកុសលវិបាកចិត្តជាតិ ១ ជាអកុសលវិបាកចិត្តជាតិ ១ ជាកិរិយាចិត្តជាតិ ១ រួមជា ៥ ជាតិ ។

ឆ្លើយ ដែលសង្ស័យថា ហេតុអ្វី ទើបមិនមានចិត្ត ៥ ជាតិ ក្នុងកាលហេតុមាន ២ ជាតិ គឺអកុសលជាហេតុ ១ កុសលជាហេតុ ១ ដូច្នេះ វិបាកចិត្តក៏គួរមាន ២ ជាតិដែរ គឺគួរនឹងមានកុសលវិបាកជាតិ ១ និងអកុសលវិបាកជាតិ ១ ។ ប៉ុន្តែ ដែលចិត្តមាន ៤ ជាតិនោះក៏ព្រោះហេតុថា

វិបាកចិត្តនោះឯង មិនមែនជាធម្មជាតិដែលអាក្រក់ ថោកទាប កណ្តាល ឬប្រណីតនោះទេ តែចំពោះចិត្ត ដែលជាកុសល និងអកុសលនោះ មានប្រភេទផ្សេង ៗ ច្រើន ដូចជា ដោយភាពវិចិត្ររបស់អកុសលធម៌ ឬ កុសលធម៌ក្នុងខណៈនោះ ។ ដែលប្រព្រឹត្តទៅ តាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ តាមផ្លូវចិត្ត ដោយ ផ្សេងគ្នាដោយកម្មជាថ្នាក់ទានក៏មាន ដោយកម្មថ្នាក់សីលក៏មាន ។ ជាថ្នាក់ ការអប់រំចម្រើនបញ្ញា ដូចថ្នាក់ស្តាប់ធម៌ ថ្នាក់សម្តែងធម៌ ថ្នាក់អប់រំ ចម្រើនកុសល ដែលជាសេចក្តីស្ងប់រម្ងាប់កិលេស ជាសមថភាវនា និង ថ្នាក់ចម្រើនសតិប្បដ្ឋាន ដែលជាការអប់រំចម្រើនវិបស្សនាភាវនា និង ផ្សេងគ្នាដោយទ្វារ ដូចជាការសម្រេចដោយកាយ ឬដោយវាចា ឬ ដោយចិត្ត និងផ្សេងគ្នាដោយអធិបតី គឺសភាវធម៌ដែលជាសម្បយុត្តធម៌ ដែលជាធំ ឬដោយចេតសិកដែលកើតរួមជាមួយផ្សេងគ្នា ។

ដូច្នេះ នឹងឃើញបានថា សភាវធម៌ដែលជាហេតុ គឺកុសល និង អកុសលនោះ មានប្រភេទផ្សេង ៗ ច្រើន ប៉ុន្តែថាសេចក្តីផ្សេងទាំងឡាយ ទាំងពួងនោះ មិនមានក្នុងវិបាកចិត្ត ។ ដែលនឹងឱ្យវិបាកចិត្តប្រព្រឹត្តទៅ ក្នុងទាន សីលផ្សេង ៗ នោះមិនបានឡើយ ព្រោះថាវិបាកជាធម៌ដែល មិនមានវិបាក ។ វិបាកនោះឯងត្រឹមតែជាផលនៃកម្ម ដែលបានធ្វើហើយ ដល់កាលណាកម្មចាស់ទុំល្មមព្រមដោយបច្ច័យ ក៏ធ្វើឱ្យវិបាកចិត្តកើត ឡើងធ្វើកិច្ចបដិសន្ធិ កិច្ចភវង្គ ឬកិច្ចដទៃ ៗ ដឹងអារម្មណ៍ផ្សេង ៗ តាមភ្នែក

ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ខណៈឃើញក្នុងខណៈនេះ ជាវិបាកចិត្ត កើតហើយ ព្រោះអតីតកម្មជាបច្ច័យ តែវិបាកចិត្តដែលឃើញ នឹងជាហេតុឱ្យកើតវិបាកទៀតមិនបាន ។ ខណៈកំពុងឮ គឺខណៈដែល ចិត្តកំពុងដឹងសំឡេងនោះជាវិបាកចិត្ត តែថា សោតវិញ្ញាណ គឺចិត្តដែល បានឮសំឡេងនោះ នឹងជាហេតុឱ្យកើតវិបាកទៀតមិនបាន ។ កាលណា វិបាកចិត្ត មិនមែនជាហេតុឱ្យកើតវិបាកចិត្ត និងមិនអាចនឹងញុំាងការ សម្រេចតាមផ្លូវកាយ វាចាណា ។ ឱ្យកើតឡើង និងវិបាកចិត្តមិនប្រកប ដោយធម៌ ដូចជា ករុណាចេតសិក មុទិតាចេតសិក និងវិរតិចេតសិក ៣ (គឺ សម្មាវាចាចេតសិក សម្មាកម្មន្តចេតសិក សម្មាអាជីវចេតសិក) ដូច្នេះ វិបាកចិត្តនេះឯងមិនឈ្មោះថា ជាធម្មជាតិដែលចោកទាប កណ្តាល ប្រណីតឡើយ ។ ប៉ុន្តែវិបាកនៃកម្មអាក្រក់ ចាត់ជាអាក្រក់វិបាក នៃ កម្មកណ្តាល ចាត់ជាកណ្តាល វិបាកនៃកម្មប្រណីត ចាត់ជាប្រណីត ។

កាលណាវិបាកត្រឹមតែជាធម៌ ដែលជាផលនៃហេតុដែលជាកុសល ឬអកុសលប៉ុណ្ណោះ តែតួវិបាកនេះឯង មិនឈ្មោះថាជាសភាវធម៌ដែល អាក្រក់ កណ្តាល ប្រណីតទេ និងមិនជាហេតុដែលនឹងឱ្យកើតវិបាក ដូច្នេះ ទើបរួមជាជាតិវិបាក ១ ជាតិ ព្រោះមិនផ្សេងគ្នាដោយប្រការ ផ្សេង ។ ដូចជាសភាវធម៌ដែលជាហេតុ គឺកុសល និងអកុសល ដែលចែកចេញ ជាកុសល ១ ជាតិ និងអកុសល ១ ជាតិនោះទេ ។ វិបាកចិត្ត ទាំងអស់ជាផលរបស់កម្មពីអតីត ដែលបានធ្វើរួចមកហើយ ។

ចក្ខុវិញ្ញាណ ជាវិបាកចិត្ត
សម្បដិច្ឆន្នចិត្ត ជាវិបាកចិត្ត
សន្តីរណចិត្ត ជាវិបាកចិត្ត
តទាលម្ពណចិត្ត ជាវិបាកចិត្ត

ដូច្នេះ ត្រូវដឹងថា ខណៈណាជាវិបាក ខណៈណាជាកុសល ខណៈណាជាអកុសល និងខណៈណាជាកិរិយា ។

ខណៈដែលឃើញរូប ពណ៌វណ្ណៈដែលជាទីពេញចិត្ត ចក្ខុវិញ្ញាណដែលកើតឡើងឃើញនោះ ជាកុសលវិបាក សម្បដិច្ឆន្ន ក៏ជាកុសលវិបាក សន្តីរណៈ ក៏ជាកុសលវិបាក តទាលម្ពណៈ ក៏ជាកុសលវិបាក ។ កាលណារូបដែលប្រាកដតាមផ្លូវភ្នែករលត់ទៅ វិថីចិត្តតាមផ្លូវភ្នែករលត់អស់ហើយ ភវង្គចិត្តក៏កើត រលត់បន្តរហូតដល់វិថីចិត្តដទៃ តទៅកើតឡើងដឹងនូវអារម្មណ៍ ។ ដូច្នេះ គួរដឹងថាខណៈឃើញអ្វីណាតាមផ្លូវភ្នែក វិបាកចិត្តទាំងអស់ ដែលជាវិថីចិត្តវារៈនោះជាផលរបស់អតីតកម្មមួយដែលបានធ្វើហើយ ។

ខណៈឮសំឡេងដែលគួរជាទីពេញចិត្ត ឬមិនពេញចិត្ត ក៏ត្រឹមតែជាជួរខណៈកើតឡើងនៃវិបាកចិត្ត ជាវិថីចិត្ត ឮសំឡេងនោះ ហើយក៏រលត់អស់ទៅពិត ។ តែអកុសល ក៏មានបច្ច័យអាចនឹងកើតឡើងពេញចិត្ត មិនពេញចិត្តក្នុងរូបផ្សេង ។ ដែលប្រាកដតាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយនោះសន្ធឹកសន្ធាប់ច្រើនហួសពេក ។ ដែលថាច្រើន

គឺមួយថ្ងៃ ៗ មិនរៀរអ្វីពីសេចក្តីពេញចិត្តខ្លះ មិនពេញចិត្តខ្លះ ក្នុងសភាវៈដែលប្រាកដតាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្តឡើយ ដោយគ្រាន់តែថ្នាក់នៃការស្តាប់ព្រះធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងនោះ គឺមិនអាចនឹងរំលត់អកុសលបានឡើយ ។ ទាំងអស់គ្នាដែលដឹងថា ខណៈឃើញត្រឹមតែជាវិបាក ជាផលរបស់កម្មក្នុងអតីតតែក៏បញ្ឈប់សេចក្តីពេញចិត្ត គឺលោភៈ មិនឱ្យកើតមិនបាន ក្នុងខណៈដែលឃើញអ្វីជាទីពេញចិត្ត ។

ដូច្នេះ ទើបគួរសិក្សាឱ្យយល់សភាវធម៌ទាំងឡាយឱ្យត្រឹមត្រូវតាមសេចក្តីពិត ដើម្បីនឹងអប់រំចម្រើនបញ្ញា ដល់ថ្នាក់ដែលអាចប្រត្យក្សច្បាស់សភាវធម៌ដែលមិនមែនសត្វ បុគ្គល តួខ្លួនពិត ៗ ។ ការសិក្សាពិចារណាធម៌ដោយល្អិត រមែងធ្វើឱ្យឃើញទោសនៃអកុសលធម៌យ៉ាងក្រៃលែង និងរមែងធ្វើឱ្យអប់រំចម្រើនកុសលគ្រប់ថ្នាក់ក្រៃលែងឡើង ព្រោះដឹងថា បើមិនដូច្នោះទេ នឹងជាអ្នកដែលពេញណែនទៅដោយកិលេសច្រើនក្រៃពេក ជារឿយ ៗ ពុំខាន ។

លោកអ្នកប្រកាន់ថា គ្រប់យ៉ាងជារបស់លោកអ្នក ក្នុងខណៈដែលវិថីចិត្តកើតប៉ុណ្ណោះ ។ ពេលណាវិថីចិត្តមិនកើត មិនឃើញ មិនឮ មិនធុំក្លិន មិនទទួលរស មិនដឹងសភាវៈប៉ះខ្ទប់សម្ផស្ស តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយចិត្តហើយ ដូចខណៈដែលដេកលក់យ៉ាងស៊ប់ សូម្បីថានៅមិនទាន់អស់ជីវិតក៏ដោយ តែខណៈលក់យ៉ាងស៊ប់

នោះក៏មិនមានការព្រួយឹតប្រតោង មិនមានសេចក្តីអាណិតអាសូរ មិនមានសេចក្តីពាក់ព័ន្ធក្នុងអ្វីណា ។ ទាំងអស់ ។ មិនមានសេចក្តីប្រកាន់ស្អិតសូម្បីតែក្នុងខន្ធដែលធ្លាប់តែប្រកាន់ស្អិតថាជាយើង ជាតួខ្លួនក៏មិនមានព្រោះខណៈនោះវិថីចិត្តមិនកើតឡើង ទើបមិនដឹងអារម្មណ៍ណា ។ តាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ តាមផ្លូវចិត្តឡើយ ។ **ខណៈដែលមិនទាន់អស់ជីវិត ត្រឹមតែដេកលក់យ៉ាងស៊ប់នោះ ក៏អស់នូវការព្រួយឹតប្រតោង ទំនាក់ទំនង សេចក្តីទាក់ទងនឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងរឿងរ៉ាវផ្សេង ។ ទៅបាន ដូច្នេះហើយម្តេចក៏មិនអប់រំចម្រើនបញ្ញា ដើម្បីផ្តាច់ការព្រួយឹតប្រតោង និងការប្រកាន់មាំក្នុងសភាវៈផ្សេង ។ ដែលប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ និងតាមផ្លូវចិត្តដែលនឹងធ្វើឱ្យអកុសលថយចុះទៅ ? កាលដឹងថា សភាវធម៌ គ្រប់យ៉ាងប្រាកដត្រឹមតែ ១ ជួរខណៈ ដែលវិថីចិត្តកើតឡើងប៉ុណ្ណោះឯង** និងកាលណាចិត្តណាកើតឡើងហើយ រលត់ទៅ ចិត្តនោះក៏រលត់ទៅពិត ។ ។ រូបណាកើតហើយរលត់ទៅ រូបនោះក៏រលត់ទៅពិត ។ ។ រូបដែលប្រាកដតាមភ្នែកពេលនេះក៏រលត់អស់ពិត ។ ។ សំឡេងដែលប្រាកដតាមត្រចៀក ក៏រលត់អស់ពិត ។ ។ ឮក៏រលត់អស់ពិត ។ ។ ចិត្តគ្រប់ខណៈ និងរូបគ្រប់រូបកើតឡើងហើយក៏រលត់ទៅពិត ។ ។ តែដរាបណានៅមិនទាន់ប្រត្យក្សការកើតរលត់នៃនាមធម៌ និងរូបធម៌ពិត ។ ទេនោះ ក៏នៅមិនទាន់ចូលដល់អត្ថ

គឺសេចក្តីសម្គាល់ ឬអត្ថន័យ ឬលក្ខណៈ នៃពាក្យថា **រលត់** ដែរ ព្រោះមិនទាន់ប្រត្យក្សការរលត់ ។ ដូចពេលនេះប្រសិនបើនិយាយថា ចក្ខុវិញ្ញាណរលត់ សម្បដិច្ឆន្នចិត្តរលត់ សន្តីរណចិត្តរលត់ ជវនចិត្តរលត់ តទាលម្ពណចិត្តរលត់ តែក៏នៅមិនទាន់ ប្រត្យក្សការរលត់ទៅនៃសភាវធម៌ណា ។ ឡើយ ។ ដូច្នេះ ទើបត្រូវអប់រំចម្រើនបញ្ញារហូតដល់អាចប្រត្យក្សការកើតឡើង និងការរលត់ទៅនៃនាមធម៌ និងរូបធម៌ពិត ។ ហើយសូម្បីតែថាបញ្ញាថ្នាក់នោះ មិនទាន់កើតក៏ដោយ ។ ការស្តាប់ធម៌ និងការពិចារណាឱ្យកើតសេចក្តីយល់ត្រឹមត្រូវ ល្អិតក្រៃលែងនោះ ក៏នឹងជាប្រយោជន៍ឧបត្ថម្ភជាបច្ច័យ ដោយសង្ខារក្ខន្ធ តាក់តែងឱ្យសតិប្បដ្ឋានកើតឡើង រលឹកដឹង លក្ខណៈនៃសភាវធម៌ដែលកំពុងកើត រលត់ និងបញ្ញាបង្អោនសិក្សាពិចារណា រហូតផ្តើមសេចក្តីដឹងលក្ខណៈនៃសភាវធម៌ទាំងឡាយ ដែលមិនមែនសត្វ បុគ្គល តួខ្លួនឡើងបន្តិចម្តង ។ ជាលំដាប់ ។

ក្នុងអដ្ឋសាលិនី អតីតតិកៈ អធិប្បាយអតីតធម៌ ពោលដល់លក្ខណៈនៃធម៌ ដែលជាអតីតកន្លងទៅហើយ មានសេចក្តីថា

ពាក្យថា « កន្លងទៅហើយ » គឺកន្លងទៅហើយ ៣ ខណៈ ទាំងឧប្បាទខណៈ គឺខណៈដែលកើត ឋិតិខណៈ គឺខណៈតាំងនៅ និងភង្គខណៈ គឺខណៈដែលរលត់ ។

ចិត្តមានអាយុខ្លីតិចតួចពេកណាស់ កើតឡើងតាំងនៅ ហើយក៏រលត់ទៅ ។

ឧប្បាទខណៈ ជាខណៈដែលកើត មិនមែនខណៈដែលតាំងនៅ មិនមែនខណៈដែលរលត់ ។

ឋិតិខណៈ ជាខណៈដែលតាំងនៅ មិនមែនខណៈដែលកើត មិនមែនខណៈដែលរលត់ ។

ភង្គខណៈ ជាខណៈដែលរលត់ មិនមែនខណៈដែលកើត មិនមែនខណៈដែលតាំងនៅ ។

ចិត្តខណៈកើតឡើងហើយកំពុងតាំងនៅ **នៅមិនទាន់ឈ្មោះថាជាអតីតចំពោះ ឋិតិខណៈទេ តែជាអតីតហើយចំពោះឧប្បាទខណៈ ។**

នៅពេលសិក្សារឿងរូបតទៅ ក៏នឹងដឹងបានថារូបដែលកើតព្រោះកម្មជាសមុដ្ឋាននោះ ជាកម្មជរូប កើតគ្រប់អនុខណៈនៃចិត្ត គឺឧប្បាទខណៈនៃចិត្ត ឋិតិខណៈនៃចិត្ត និងភង្គខណៈនៃចិត្តគ្រប់ដួងវៀរមិនកើតមុនចុតិចិត្ត ១៦ ខណៈ ដូច្នេះ រូបកើត ព្រោះកម្មជាសមុដ្ឋាន ទើបរលត់អស់ព្រមទាំងនឹងចុតិចិត្តធ្វើឱ្យអស់ផុតនូវភាពជាបុគ្គលក្នុងជាតិនោះ ទាំង ខន្ធ ៥ ។

រូបដែលកើតព្រោះចិត្តជាសមុដ្ឋាន ជាចិត្តជរូប កើតព្រមនឹងឧប្បាទខណៈនៃចិត្ត (វៀរបដិសន្ធិចិត្ត ១ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង អរូបាវចរវិបាកចិត្ត ៤ ដួង និងចុតិចិត្តនៃព្រះអរហន្ត ១ ដួង) ។

រូបដែលកើតព្រោះឧតុជាសមុដ្ឋាន ជាឧតុជរូបដែលកើតក្នុង ឋិតិខណៈនៃឧតុជរូប ដែលជាសមុដ្ឋាននោះ ។

រូបដែលកើតព្រោះអាហារជាសមុដ្ឋាន ជាអាហារជ្ជរូប កើតចំពោះតែក្នុងឋិតិខណៈ នៃឱជារូបក្នុងអាហារដែលបរិភោគចូលទៅពេលឱជារូបក្នុងអាហារនោះជ្រួតជ្រាបហើយ ។

ចិត្តកើតរលត់យ៉ាងរហ័ស ដូច្នេះខណៈទាំង ៣ ក៏អស់ទៅយ៉ាងរហ័សដែរ តែធម៌ណាដែលជាអតីត គឺ "កន្លងទៅហើយ" នោះកន្លងទៅហើយទាំង ៣ ខណៈ មិនមានសល់ទាំង ឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ ។

ពាក្យអធិប្បាយតទៅថា

ពាក្យថា " **រលត់ហើយ** " **គឺដល់នូវសេចក្តីរលត់ហើយ** ដូចភ្លើងរលត់ រលត់ហើយមិនមានទៀត ។

ពាក្យថា " **ប្រាសទៅហើយ** " **គឺដល់នូវសេចក្តីប្រាសទៅហើយ** ឬទៅប្រាសហើយ ដូចមនុស្សស្លាប់ដែលប្រាសទៅហើយ ទៅប្រាសហើយ មិនសល់ឡើយនោះ គឺលក្ខណៈនៃសេចក្តីរលត់ ។

ពាក្យថា " **ប្រែទៅហើយ** " **គឺដល់នូវសេចក្តីប្រែទៅហើយ ទៅហើយ ដោយការលះបង់នូវភាពប្រក្រតី ។** ប្រក្រតី គឺមានតែ **ប្រែ** ទៅដោយការលះបង់នូវភាពប្រក្រតី គឺមិនមាន ។

ពាក្យថា " **អស្តង្គតហើយ** " **ដោយអត្ថថា ដល់នូវភាពតាំងនូវមិនបានពោល គឺសេចក្តីរលត់ ។**

" **អព្ភុត្តង្គតា** " **ប្រែថាដល់នូវសេចក្តីរលត់សូន្យហើយ** ទ្រង់ផ្តើមដោយបទឧបសគ្គ គឺមិនត្រឹមតែប្រើពាក្យថារលត់ទេ នៅផ្តើមដោយបទឧបសគ្គ គឺឱ្យឃើញថា ដល់នូវសេចក្តីរលត់សូន្យហើយ មិនមានសល់ជាប្រាកដ ។ ពាក្យថា " កើតឡើងហើយប្រាសទៅ " គឺកើតហើយប្រាសទៅ មិនមែនថាមិនមានទេ មានព្រោះកើតឡើង តែថាកើតឡើងហើយ ក៏ប្រាសទៅហើយសូន្យ **ប្រាកដមិនមានសេសសល់** ឡើយ ។ **ធម៌កន្លង ដែលកន្លងទៅប្រាសទៅហើយ ទាំងនោះអ្វីខ្លះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** បានដល់ធម៌ដែលជាសង្ខារធម៌ ដែលជាខន្ធ ៥ ទាំងនេះគឺ

រូបក្ខន្ធ រូបគ្រប់រូបកើតឡើងហើយ ក៏រលត់ទៅ

វេទនាខន្ធ សេចក្តីដឹងគ្រប់យ៉ាង គឺវេទនាចេតសិក កើតឡើងហើយ ក៏រលត់ទៅ

សញ្ញាខន្ធ សភាពចាំ គឺសញ្ញាចេតសិក កើតឡើងហើយ ក៏រលត់ទៅ

សង្ខារក្ខន្ធ បានដល់ចេតសិក ៥០ ប្រភេទ ដែលតាក់តែងដូចលោភៈ ទោសៈ ឥស្សា មច្ឆរិយៈ សទ្ធា វីរិយៈ និងបញ្ញា ជាដើមកើតឡើង ហើយក៏រលត់ទៅ

វិញ្ញាណក្ខន្ធ គឺចិត្តគ្រប់ដួង កើតឡើងហើយ ក៏រលត់ទៅ ។

នៅពេលគ្រប់យ៉ាង ដែលកើតឡើងជាសង្ខារធម៌ ជាខន្ធណាមួយក្នុងខន្ធ ៥ រលត់ទៅគ្រប់ខណៈ ។ យ៉ាងនេះ តើនៅអាល័យស្រណោះ

នៅប្រកាន់ នៅពាក់ព័ន្ធនឹងខន្ធណាខ្លះទេ ? ក្នុងពេលគ្រប់ខន្ធកើតហើយ ក៏រលត់ទៅ ។ សូន្យអស់ទៅដែរមិនមែនរលត់ហើយនៅសេសសល់ទេ គឺថារលត់សូន្យទៅ ប្រាសទៅដោយមិនសេសសល់ឡើយ ។

ត្រឹមតែថ្នាក់ការអាន ការស្តាប់ រំលត់កិលេសមិនបានឡើយ នៅតែពេញណែនដដែល ។ ដូច្នេះ ទើបត្រូវពិចារណាឱ្យយល់ចូលចិត្ត ដើម្បីជាសង្ខារក្ខន្ធ តាក់តែងឱ្យសតិរលឹក សង្កេត ពិចារណានូវអ្វីដែលបានឮ បានស្តាប់ យល់ចូលចិត្តហើយនោះ រហូតដល់ប្រត្យក្សច្បាស់ លក្ខណៈនៃសភាវធម៌ ដែលកើតឡើងប្រាកដ និងរលត់ទៅយ៉ាងនេះ ទើបអាចលះការប្រកាន់សភាវធម៌ថាជាសត្វ បុគ្គល តួខ្លួនបាន ។

ក្នុងមួយថ្ងៃ ។ ធ្លាប់តែស្រឡាញ់ពេញចិត្តនូវអ្វីដែលប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ និងតាមផ្លូវចិត្ត ធ្លាប់ប្រកាន់ថាជាខ្លួនយើង ជារបស់យើង ជាសម្បត្តិរបស់យើង តែសេចក្តីពិត គ្រប់យ៉ាងទាំងអស់ប្រាកដត្រឹមតែជាខណៈដែលជាវិថីចិត្ត ប៉ុណ្ណោះឯង ។ សភាវធម៌ណាដែលជាវិបាក ក៏ជាផលរបស់កម្ម តើនឹងមានផ្ទះសំបែង ទ្រព្យសម្បត្តិ សំពត់ អាវ សាវស្បែ គ្រឿងតុបតែង សន្ទឹកសន្ធាប់យ៉ាងណា ប្រណីតស្អាត ឆើតឆាយយ៉ាងណា វិបាកចិត្ត ដែលជាផលរបស់អតីតកម្ម ក៏ត្រឹមតែកើតឡើងដឹងអារម្មណ៍នោះ តាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ ត្រឹមតែ ១ ជួរខណៈដែលកើតឡើង ហើយរលត់ទៅ មិនបិតថេរឡើយ កើតឡើង ហើយក៏

រលត់ទៅ ។ ទាំងមិនមានអ្នកណាអាចដឹងថា កម្មណានឹងឱ្យផលក្នុង ខណៈតទៅខាងមុខ ព្រោះហេតុថាមនុស្សគ្រប់រូប តែងមានកុសលកម្ម និងអកុសលកម្ម ក្នុងអតីតដែលបានធ្វើហើយ កាលបច្ច័យគ្រប់គ្រាន់ល្មម ដែលកម្មណានឹងឱ្យផល ជាវិបាកណាកើតឡើង វិបាកនោះក៏កើតឡើង ដឹងអារម្មណ៍តាមភ្នែកខ្លះ តាមត្រចៀកខ្លះ តាមច្រមុះខ្លះ តាមអណ្តាតខ្លះ តាមកាយខ្លះ តាមចិត្តខ្លះ តែប៉ុណ្ណោះឯង ។

ការសិក្សាពិចារណារឿងសេចក្តីមិនទៀងនៃសភាវធម៌ រមែងជា វិរិយារម្ភកថា ដែលនឹងធ្វើឱ្យសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ដែល ប្រាកដ ហើយបង្អោនសិក្សាពិចារណា ទម្រាំនឹងដឹងលក្ខណៈនៃសភាវធម៌ ដែលមិនមែនតួខ្លួន ដែលត្រឹមតែជានាមធម៌ និងរូបធម៌ ១ លក្ខណៈ ដែល កំពុងប្រាកដតាមភ្នែក ឬតាមត្រចៀក ឬតាមច្រមុះ ឬតាម អណ្តាត ឬតាម កាយ ឬតាមចិត្ត ។

នៅពេលបានយល់ត្រឹមត្រូវក្នុងលក្ខណៈនៃសភាវធម៌ ជវនវិថី ដែលជាកុសលចិត្តក៏កើនឡើង តែបើមិនស្តាប់ មិនសិក្សាឱ្យយល់នូវរឿង នៃសភាវធម៌ទេ ក៏នឹងមិនដឹងថា ខណៈណាជាវិបាក ដែលជាផល របស់កម្មអតីត ខណៈណាជាជវនវិថីចិត្តសន្សំសន្តាន ដែលជាកុសល ឬអកុសលនោះឡើយ កាលបើមិនដឹងទេ ក៏មិនឃើញទោសរបស់ អកុសល និងមិនអប់រំចម្រើនកុសល សង្សារវដ្ត ក៏រមែងយឺតវែងអន្លាយ តទៅ មិនមានទីបំផុត ។ ក្នុងមួយថ្ងៃ ៗ នោះ តើអកុសលចិត្តកើតច្រើន ឬ

កុសលចិត្តកើតច្រើន ? ដូច្នេះ ផលខាងមុខ នឹងជាកុសលវិបាកច្រើន ឬ អកុសលវិបាកច្រើន ដែលលោកអ្នកទាំងអស់គ្នា ក៏រមែងពិចារណាដឹងនូវ សភាវធម៌ ដែលកើតនៅជាមួយលោកអ្នកបាន ក្នុងជីវិតប្រចាំថ្ងៃ តាម សេចក្តីពិត ។

សរុបកិច្ចនៃចិត្ត

កិច្ចនៃចិត្តមាន ១៤ កិច្ច គឺ

១ - **បដិសន្ធិកិច្ច គឺ**កិច្ចបន្តពីចុតិកិច្ច

ចិត្តដែលធ្វើបដិសន្ធិកិច្ច បានដល់វិបាកចិត្ត ១៩ ដួង គឺ

កាមាវចរវិបាក	១0 ដួង
រូបាវចរវិបាក	៥ ដួង
អរូបាវចរវិបាក	៤ ដួង

២ - **ភវង្គកិច្ច** គឺជាកិច្ចតម្រង់ភពជាតិ

ចិត្តដែលធ្វើភវង្គកិច្ច បានដល់វិបាកចិត្ត ១៩ ដួង គឺវិបាកចិត្តណាធ្វើបដិសន្ធិកិច្ច វិបាកចិត្តដូចគ្នានោះក៏កើតឡើងធ្វើភវង្គកិច្ចតអំពីបដិសន្ធិចិត្ត ដែលរលត់ទៅហើយទម្រាំដល់វិថីចិត្តទ្វារណាមួយនឹងកើតហើយពេលវិថីចិត្តទ្វារនោះរលត់ទៅ ភវង្គចិត្តក៏កើតបន្តរាល់ ៗ ពេលរហូតទម្រាំនឹងចុតិ ។

៣ - **អាវជ្ជនកិច្ច** គឺកិច្ចនឹករាវរកអារម្មណ៍ដែលប៉ះខ្ទប់ទ្វារ ជាវិថីចិត្ត ខណៈដំបូង ដែលកើតឡើងតាមទ្វារណាមួយក្នុងទ្វារទាំង ៦ ។ ចិត្តដែលធ្វើអាវជ្ជនកិច្ចជាកិរិយាកិច្ច ២ ដួង គឺ

បញ្ចទ្វារាវជ្ជនចិត្ត	១ ដួង
មនោទ្វារាវជ្ជនចិត្ត	១ ដួង

๔ - **ទស្សនកិច្ច** គឺកិច្ចឃើញ

ចិត្តដែលធ្វើទស្សនកិច្ច បានដល់វិបាកចិត្ត ២ ដួង គឺ

ចក្ខុវិញ្ញាណអកុសលវិបាក	១ ដួង
ចក្ខុវិញ្ញាណកុសលវិបាក	១ ដួង

๕ - **សវនកិច្ច** គឺកិច្ចឮ

ចិត្តដែលធ្វើសវនកិច្ច បានដល់វិបាកចិត្ត ២ ដួង គឺ

សោតវិញ្ញាណអកុសលវិបាក	១ ដួង
សោតវិញ្ញាណកុសលវិបាក	១ ដួង

៦ - **ឃាយនកិច្ច** គឺកិច្ចធុំក្លិន

ចិត្តដែលធ្វើឃាយនកិច្ច បានដល់វិបាកចិត្ត ២ ដួង គឺ

ឃានវិញ្ញាណអកុសលវិបាក	១ ដួង
ឃានវិញ្ញាណកុសលវិបាក	១ ដួង

៧ - **សាយនកិច្ច** គឺកិច្ចដឹងរស

ចិត្តដែលធ្វើសាយនកិច្ច បានដល់វិបាកចិត្ត ២ ដួង គឺ

ជិវ្ហាវិញ្ញាណអកុសលវិបាក	១ ដួង
ជិវ្ហាវិញ្ញាណកុសលវិបាក	១ ដួង

៨ - **ផុស្សនកិច្ច** គឺកិច្ចដឹងអារម្មណ៍ដែលប៉ះខ្ទប់កាយ ចិត្តដែលធ្វើ

ផុស្សនកិច្ចបានដល់វិបាកចិត្ត	២ ដួង គឺ
កាយវិញ្ញាណអកុសលវិបាក	១ ដួង

កាយវិញ្ញាណកុសលវិបាក ១ ដួង

៩ - **សម្បដិច្ឆន្នកិច្ច** គឺកិច្ចទទួលអារម្មណ៍តពីទ្វិបញ្ចវិញ្ញាណ ចិត្តដែលធ្វើសម្បដិច្ឆន្នកិច្ច បានដល់វិបាកចិត្ត ២ ដួង គឺ

សម្បដិច្ឆន្នចិត្តអកុសលវិបាក ១ ដួង

សម្បដិច្ឆន្នចិត្តកុសលវិបាក ១ ដួង

១០ - **សន្តីរណកិច្ច** គឺកិច្ចពិចារណាអារម្មណ៍ ដែលប្រាកដតាមទ្វារ ៥

ចិត្តដែលធ្វើសន្តីរណកិច្ច បានដល់វិបាកចិត្ត ៣ ដួង គឺ

ឧបេក្ខាសន្តីរណៈ អកុសលវិបាក ១ ដួង

ឧបេក្ខាសន្តីរណៈ កុសលវិបាក ១ ដួង

សោមនស្សសន្តីរណៈ កុសលវិបាក ១ ដួង

១១ - **វោដ្ឋព្វនកិច្ច** គឺកិច្ចកាត់ក្តីសម្រេចអារម្មណ៍ឱ្យជវនវិថីចិត្ត ណាមួយកើតតាមបញ្ចទ្វារ

ចិត្តដែលធ្វើកិច្ចនេះបានដល់ កិរិយាចិត្ត ១ ដួង គឺ

មនោទ្វារាវជ្ជនចិត្ត

១២ - **ជវនកិច្ច** គឺកិច្ចស្ទុះទៅក្នុងអារម្មណ៍ ឬសោយអារម្មណ៍

ចិត្តដែលធ្វើជវនកិច្ចមាន ៥៥ ដួង គឺ

អកុសលចិត្ត	១២ ដួង
អហេតុកៈ (ហសិតុប្បាទចិត្ត)	១ ដួង
កាមាវចរកុសលចិត្ត	៨ ដួង

កាមាវចរកិរិយាចិត្ត	៨ ដួង
រូបាវចរកុសលចិត្ត	៥ ដួង
រូបាវចរកិរិយាចិត្ត	៥ ដួង
អរូបាវចរកុសលចិត្ត	៤ ដួង
អរូបាវចរកិរិយាចិត្ត	៤ ដួង
លោកុត្តរចិត្ត	៨ ដួង

១៣ - **តទាលម្ពណកិច្ច** គឺកិច្ចដឹងអារម្មណ៍តពីជវនកិច្ច

ចិត្តដែលធ្វើតទាលម្ពណកិច្ច បានដល់វិបាកចិត្ត ១១ ដួង គឺ

សន្តីរណចិត្ត	៣ ដួង
កាមាវចរសហេតុកកុសលវិបាក	៨ ដួង

១៤ - **ចុតិកិច្ច** គឺកិច្ចឃ្លាតចាកភពជាតិ ។ ពេលចុតិចិត្តកើតធ្វើកិច្ចឃ្លាតចាកភពជាតិរលត់ទៅហើយ ក៏អស់ជីវិត អស់សភាពជាបុគ្គលនោះ សូន្យឈឹង ។

ចិត្តដែលធ្វើចុតិកិច្ច បានដល់វិបាកចិត្ត ១៩ ដួង ប្រភេទដូចគ្នានឹងបដិសន្ធិចិត្ត និងភវង្គចិត្ត នុះឯង ។ ពេលវិបាកចិត្តប្រភេទណា ធ្វើបដិសន្ធិកិច្ច វិបាកចិត្តប្រភេទដូចគ្នានោះឯង ក៏ធ្វើភវង្គកិច្ច និងចុតិកិច្ច ។
រួមជាចិត្ត ៨៩ ដួង ធ្វើកិច្ច ១៤ កិច្ច ។

បដិសន្ធិចិត្តប្រមូលមកនូវនាមធម៌ និងរូបធម៌ទាំងឡាយដែលមានបច្ច័យធ្វើឱ្យកើតឡើងប្រព្រឹត្តិទៅក្នុងភពជាតិនីមួយ ៗ តាមកម្លាំង និងប្រភេទនៃបដិសន្ធិចិត្តនោះ ៗ ។

ចិត្តដែលធ្វើបដិសន្ធិកិច្ច ក្នុងកាមភូមិ ១១ បានដល់ កាមាវចរវិបាកចិត្ត ១០ ដួង គឺ

ឧបេក្ខាសន្តីរណអកុសលវិបាក	១ ដួង
ឧបេក្ខាសន្តីរណកុសលវិបាក	១ ដួង
កាមាវចរសហេតុកកុសលវិបាក (មហាវិបាក)	៨ ដួង

ឧបេក្ខាសន្តីរណអកុសលវិបាក ១ ដួង ជាផលនៃអកុសលកម្ម យ៉ាងណាមួយ ធ្វើបដិសន្ធិកិច្ចក្នុងអបាយភូមិ ៤ គឺកើតក្នុងនរក កើតជាប្រេត កើតជាអសុរកាយ កើតជាតិរច្ឆាន ។

ឧបេក្ខាសន្តីរណកុសលវិបាក ១ ដួង ជាផលនៃកុសលកម្ម មានកម្លាំងខ្សោយ ទើបធ្វើបដិសន្ធិកិច្ចក្នុងមនុស្ស និងទេវតាជាន់ដំបូង គឺជាន់ទេវតាចាតុមហារាជិកា ដោយមានអកុសលកម្មបៀតបៀនធ្វើឱ្យជាបុគ្គលពិការ គ ថ្លង់ ខ្វាក់ ខ្វៃយ ជាដើម តាំងតែពីកំណើត ។

មហាវិបាកចិត្ត ៨ ដួង ធ្វើបដិសន្ធិកិច្ចក្នុងភូមិមនុស្ស និងទេវតា ៦ ជាន់ផ្សេង ៗគ្នា តាមលំដាប់កម្លាំង និងភាពប្រណីតរបស់កុសលកម្មនោះ ៗ ។

រូបាវចរវិបាក ៥ ដួង ធ្វើបដិសន្ធិកិច្ចក្នុងរូបព្រហ្ម ១៥ ភូមិ តាមលំដាប់នៃរូបាវចរកុសលនោះ ៗ ដែលជាហេតុ ។

អរូបាវចរវិបាកចិត្ត ៤ ដួង ធ្វើបដិសន្ធិកិច្ចក្នុងអរូបព្រហ្ម ៤ ភូមិ តាមលំដាប់នៃអរូបាវចរកុសលនោះ ៗ ដែលជាហេតុ ។

ចំពោះចិត្តដែលធ្វើតទាលម្ពណកិច្ច ១១ ដួងនោះ កើតពីកាមជវនវិថីក្នុងកាមភូមិប៉ុណ្ណោះ មិនកើតក្នុងភូមិដែលខ្ពស់ជាងនេះទេ គឺមិនកើតក្នុងរូបព្រហ្មភូមិ និងអរូបព្រហ្មភូមិឡើយ ។

ចិត្តដែលធ្វើបាន ៥ កិច្ចមាន ២ ដួង ឧបេក្ខាសន្តីរណអកុសលវិបាក ១ ដួង និងឧបេក្ខាសន្តីរណកុសលវិបាក ១ ដួង ។

ចិត្តដែលធ្វើបាន ៤ កិច្ច មាន ៨ ដួង គឺមហាវិបាក ៨ ដួង ។

ចិត្តដែលធ្វើបាន ៣ កិច្ច មាន ៩ ដួង គឺរូបាវចរវិបាកចិត្ត ៥ និងអរូបាវចរវិបាកចិត្ត ៤ ដួង ។

ចិត្តដែលធ្វើបាន ២ កិច្ច មាន ២ ដួង គឺមនោទ្វារាវជ្ជនកិច្ច ១ ដួង និងសោមនស្សសន្តីរណកុសលវិបាកចិត្ត ១ ដួង ។

ចិត្តដែលនៅសល់ធ្វើបានតែ ១ កិច្ច ចំពោះកិច្ចរៀង ៗ ខ្លួន ។

សំណួរសាឡើងវិញ

១ - តទាលម្ដណាចិត្តជាជាតិអ្វី ? ជាផលនៃកម្មអ្វី ?

២ - កម្មជ្ជរូបកើតខណៈណាខ្លះ ហើយវៀរមិនកើតពេលណា ?

៣ - ចិត្តជ្ជរូបកើតពេលណា ? វៀរមិនកើតខណៈណាខ្លះ ?

៤ - អកុសលចិត្តធ្វើកិច្ចអ្វី ?

៥ - ចិត្តដែលធ្វើជវនកិច្ច មានប៉ុន្មានជាតិ ?

៦ - កុសលចិត្ត កិរិយាចិត្ត ធ្វើតទាលម្ដណាកិច្ចបានទេ ?

៧ - ឧបេក្ខាសន្តីរណចិត្ត ធ្វើកិច្ចបានប៉ុន្មានកិច្ច អ្វីខ្លះ ?

៨ - សោមនស្សសន្តីរណចិត្ត ធ្វើកិច្ចបានប៉ុន្មានកិច្ច អ្វីខ្លះ ?

៩ - ព្រះអរហន្តមានចិត្តប៉ុន្មានជាតិ ?

១០ - អ្នកដែលមិនមែនព្រះអរហន្ត មានចិត្តប៉ុន្មានជាតិ ?

មេរៀនទី ៧

លក្ខណៈចិត្តដែលបានពោលហើយ នៅប្រការទី ១ គឺជាចិត្ត ដែលមានសភាពដឹងច្បាស់អារម្មណ៍ ហើយរមែងនឹងជាឧបការៈជ្រោមជ្រែងឱ្យសតិកើតរលឹកដឹងនូវលក្ខណៈនៃចិត្ត ក្នុងខណៈដែលកំពុងឃើញ ឬកំពុងឮ ធុំក្លិន ទទួលរស ដឹងផោដ្ឋព្វៈ ហើយក៏ពិចារណាដឹងថា សភាពដឹងនោះ ជាចិត្ត មិនមែនតួខ្លួន ព្រោះចិត្តជាសភាពដែលដឹងច្បាស់នូវអ្វីដែលកំពុងប្រាកដនោះ ។

លក្ខណៈចិត្តប្រការទី ២ គឺឈ្មោះថាចិត្តព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថី ហើយក៏ដឹងបានថា ដែលបុគ្គលម្នាក់ ៗ មានឧបនិស្ស័យផ្សេង ៗ គ្នានោះ ព្រោះសន្សំលោភៈ ទោសៈ មោហៈ ច្រើន ឬថា សន្សំកុសលធម៌ប្រភេទណាច្រើនមកហើយ ធ្វើឱ្យបុគ្គលម្នាក់ ៗ មានអធ្យាស្រ័យផ្សេង ៗ គ្នា ។

លក្ខណៈរបស់ចិត្តប្រការទី ៣ ឈ្មោះថាចិត្ត ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។ កាលយល់រឿងវិថីចិត្តហើយ ក៏នឹងយល់នូវសភាពដែលជាសង្សារវដ្ត គឺការកើតឡើងវិលទៅជាកិលេសវដ្ត កម្មវដ្ត វិបាកវដ្តបាន ព្រោះហេតុថាឈ្មោះថា ចិត្ត ព្រោះជាធម្មជាតិ ដែលកម្មកិលេសសន្សំវិបាក ។

កុសលធម៌ និងអកុសលធម៌ដែលកើតឡើង ជាជវនចិត្ត នឹងរលត់ទៅហើយនោះ មិនសូន្យបាត់ទៅណាឡើយ ព្រោះសូម្បីថាចិត្តនឹងកើតឡើងហើយរលត់ទៅមែន តែការរលត់នៃចិត្តដួងមុនជាបច្ច័យឱ្យចិត្តដួងបន្ទាប់កើតឡើង ដូច្នេះ ចិត្តដួងបន្ទាប់ដែលកើតឡើង ទើបបន្តគ្រប់យ៉ាងដែលសន្សំនៅក្នុងចិត្តដួងមុន ព្រោះចិត្តដែលកើតតនោះ កើតឡើង ព្រោះចិត្តដួងមុនជាបច្ច័យ ។ ដូច្នេះ អកុសលជវនវិថីចិត្ត និងកុសលជវនវិថីចិត្តដែលសន្សំសន្តាន ទើបជាបច្ច័យឱ្យកើតវិបាកបាន ។

សង្ខារវដ្តមាន ៣ យ៉ាង គឺកិលេសវដ្ត កម្មវដ្ត វិបាកវដ្ត ។

កិលេសវដ្ត កើតឡើងវិលវល់តាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ និងតាមផ្លូវចិត្ត ហើយនឹងសន្សំសន្តានបន្តជាហេតុឱ្យធ្វើនូវ**កម្មវដ្ត** គឺកុសលកម្ម និងអកុសលកម្មតាមផ្លូវកាយ វាចា ចិត្ត ។ **កម្មវដ្ត** ជាបច្ច័យឱ្យកើតនូវ **វិបាកវដ្ត** ហើយកាលវិបាកចិត្តកើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត និងផ្លូវកាយនោះ ក៏មិនប្រាសចាកផុតពីកិលេសវដ្តទៀតឡើយ ព្រោះនៅមានសេចក្តីប្រកាន់ សេចក្តីត្រេកអរ ស្រឡាញ់ ស្អប់ ក្នុងសភាវៈដែលប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ និងតាមផ្លូវចិត្តទៀត កាលបើមានកិលេសហើយ ក៏ជាហេតុឱ្យធ្វើកម្មដែលជាកុសលកម្មខ្លះ អកុសលកម្មខ្លះ ។ កុសលកម្ម និងអកុសលកម្មនោះ ក៏ជាហេតុឱ្យកើតអកុសលវិបាកចិត្ត និងកុសលវិបាកចិត្ត មិនចេះចប់

ដរាបណា ដែលបញ្ញានៅមិនទាន់បានអប់រំចម្រើន រហូតដល់ចាស់ក្លា ប្រត្យក្សក្នុងអរិយសច្ចធម៌ទេនោះ សង្សារវដ្តទាំង ៣ គឺ កិលេសវដ្ត កម្មវដ្ត វិបាកវដ្ត ក៏នឹងត្រូវកើតឡើងវិលជារឿយ ៗ ។

បដិច្ចសមុប្បាទ គឺធម៌ដែលអាស្រ័យគ្នាកើតឡើងនោះ ក៏ជា កិលេសវដ្ត កម្មវដ្ត វិបាកវដ្ត គឺអវិជ្ជាជាបច្ច័យឱ្យកើតសង្ខារ (កិលេសវដ្ត ជាបច្ច័យឱ្យកើតកម្មវដ្ត) សង្ខារជាបច្ច័យឱ្យកើតវិញ្ញាណ (កម្មវដ្តជាបច្ច័យ ឱ្យកើតវិបាកវដ្ត) ។

អវិជ្ជា គឺជាមោហចេតសិក ជាអកុសលធម៌ ដែលមិនដឹងសភាវធម៌ តាមសេចក្តីពិត ជាកិលេសវដ្ត ដែលជាបច្ច័យឱ្យកើតសង្ខារ ។

សង្ខារដែលជាផលរបស់អវិជ្ជាមាន ៣ គឺ បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ ។

បុញ្ញាភិសង្ខារ បានដល់ ចេតនាដែលធ្វើកុសលកម្ម ដែលជាប់ជំពាក់ទៅដោយរូប គឺកាមាវចរកុសលកម្ម និងរូបាវចរកុសលកម្ម ។

អបុញ្ញាភិសង្ខារ បានដល់ចេតនាដែលធ្វើអកុសលកម្ម ។

អនេញ្ជាភិសង្ខារ បានដល់ចេតនាដែលជា អរូបាវចរកុសលកម្ម គឺ អរូបជ្ឈានកុសល ៤ ។

បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ជាបច្ច័យឱ្យកើត **វិញ្ញាណ** គឺបដិសន្ធិក្នុងភូមិផ្សេង ៗ តាមសមគួរដល់ហេតុ គឺកម្មនោះ ៗ ។

ដូច្នេះ បដិច្ចសមុប្បាទ ដែលព្រះមានព្រះភាគទ្រង់សម្តែង គឺ សភាវធម៌ដែលកើតឡើងប្រព្រឹត្តទៅមួយខណៈ ។ នេះឯង មិនថាទ្រង់នឹង សម្តែងដោយន័យណាឡើយ ដូចជាទ្រង់សម្តែងដោយន័យបរមត្ថធម៌ ៤ ដោយន័យជាអរិយសច្ចធម៌ ៤ ឬដោយន័យជាបដិច្ចសមុប្បាទ ។

អត្ថដែលជាលក្ខណៈនៃចិត្តប្រការទី ៣ ដែលថា ឈ្មោះថាចិត្ត ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។ សម្តែងឱ្យឃើញថា ក្នុង ជីវិតតាមសេចក្តីពិត ខណៈខ្លះក៏ជាកិលេស ខណៈខ្លះក៏ជាកម្ម ខណៈ ខ្លះជាវិបាក ដែលថា បើយល់ច្បាស់នូវរឿងវិថីចិត្ត ក៏នឹងជាបច្ច័យឱ្យសតិ កើតឡើងពិចារណាដឹងថា ខណៈដែលឃើញ ឮ ធុំក្លិន ទទួលរស ដឹងផោដ្ឋព្វៈ និងនឹកគិតនោះ តើខណៈណាជាកិលេស ខណៈណាជាកម្ម ខណៈណាជាវិបាក ដូចខណៈដែលឃើញ

បញ្ចទ្វារាវជ្ជនចិត្ត	មិនមែនវិបាកចិត្ត
ចក្ខុវិញ្ញាណ	ជាវិបាកចិត្ត
សម្បដិច្ឆន្នចិត្ត	ជាវិបាកចិត្ត
សន្តីរណចិត្ត	ជាវិបាកចិត្ត
វោដ្ឋព្វនចិត្ត	មិនមែនជាវិបាកចិត្ត
ជវនចិត្ត	មិនមែនជាវិបាកចិត្ត
តទាលម្ពណចិត្ត	ជាវិបាកចិត្ត

តើមានប្រយោជន៍អ្វី ដែលនឹងដឹងដល់សេចក្តីល្អិតល្អន់ថា ខណៈដែលឃើញវារៈនីមួយ ៗ នោះ ខណៈណាជាវិបាក និងខណៈណាមិនមែនជាវិបាក ។ ប្រយោជន៍ គឺគួរដឹងថា ធម៌ណាដែលជាហេតុ ធម៌នោះមិនមែនជាផល ។ អកុសល និងកុសលទាំងឡាយជាហេតុ មិនមែនជាវិបាក ។ ខណៈណាដែលជាវិបាកចិត្ត ខណៈនោះ ជាផលដែលកើតអំពីហេតុ មិនមែនជាតួហេតុ ។ ក្នុងខណៈដែលកំពុងឃើញនេះ បើដឹងថា ខណៈណាជាវិបាក ជាផលរបស់កម្មពីអតីតដែលធ្វើឱ្យវិបាកចិត្តកើតឡើង នឹងគិតទេថា តើមានតួខ្លួន ដែលអាចបណ្តាលឱ្យវិបាកណា ៗ កើតឡើងបាន ? បើដឹងតាមសេចក្តីពិតនៃចិត្តដែលជាហេតុ និងចិត្តដែលជាផលហើយ ក៏នឹងឃើញភាពជាអនត្តា ហើយក្នុងខណៈដែលបានឃើញ បានឮ ធុំក្លិន ទទួលរស ដឹងផោដ្ឋព្វៈ និងគិតនឹកដែលជាបច្ច័យឧបការៈឱ្យសតិរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដ ក្នុងខណៈនោះបានថា ជាសភាវធម៌តែ ១ ប្រភេទ ដែលកើតឡើង ព្រោះបច្ច័យទាំងអស់ ។

តើមានអ្នកណាខ្លាចទេ ថាវិបាកនឹងមិនកើត ឬខ្លាចថានឹងអស់វិបាកហើយខ្លះ? គឺមិនបាច់ភ័យឡើយ ព្រោះមិនថាឡើយថ្ងៃនេះ ស្អែកនេះ ថ្ងៃត ៗ ទៅ ខែត ៗ ទៅ ឆ្នាំត ៗ ទៅជាតិត ៗ ទៅ ក៏មិនត្រូវហួងហែងរឿងដែលជាវិបាកថានឹងមិនកើតឡើយ ព្រោះកាលណាមិនទាន់ជាព្រះអរហន្តហើយក៏នៅមានបច្ច័យព្រមល្មម ដែលនឹងឱ្យវិបាកកើតឡើង បន្តទៅរឿយ ៗ ជានិច្ចនិរន្តរ៍ ។ ប៉ុន្តែគួររលឹកថា វិបាកដែលនឹងកើតនោះ

ជាវិបាកប្រភេទណា ជាផលនៃកម្មអ្វី ដែលនៅក្នុងជាតិនេះ ក៏ជាគ្រឿងពិសោធន៍វិបាក ហើយថា បុគ្គលម្នាក់ ៗ មានវិបាកនៃកុសលកម្ម ឬថាមានវិបាកនៃអកុសលកម្មតិចច្រើនយ៉ាងណា ។

សេចក្តីក្នុងមនោរថបូរណីអដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត បឋមបណ្ណាសក វគ្គទី ៤ និទានសូត្រ សម្តែងបរិយាយនៃព្រះអភិធម្ម **ចំណែកកម្មទុក ១៦ ប្រការ ជាអកុសលកម្ម ៨ និងកុសលកម្ម ៨ គឺអកុសលកម្ម និងកុសលកម្ម ដែលនឹងឱ្យផលបាននោះ ត្រូវដល់ព្រមដោយសម្បត្តិ និងវិបត្តិ គឺ**

កម្មសមាទានចំណែកបាបបែបខ្លះ

គតិសម្បត្តិ ហាមឃាត់ រមែងមិនឱ្យផលក៏មាន ១

កម្មសមាទានចំណែកបាបបែបខ្លះ

ឧបធិសម្បត្តិ ហាមឃាត់រមែងមិនឱ្យផលក៏មាន ១

កម្មសមាទានចំណែកបាបបែបខ្លះ

កាលសម្បត្តិ ហាមឃាត់រមែងមិនឱ្យផលក៏មាន ១

កម្មសមាទានចំណែកបាបបែបខ្លះ

បយោគសម្បត្តិ ហាមឃាត់រមែងមិនឱ្យផលក៏មាន ១

សម្តែងថា កាលបើបុគ្គលណាដល់ព្រមដោយគតិសម្បត្តិ ឧបធិសម្បត្តិ កាលសម្បត្តិ ឬបយោគសម្បត្តិ អកុសលកម្មបែបខ្លះ រមែងមិនមានឱកាសឱ្យផលឡើយ ។

ចំណែកអកុសលកម្មបែបខ្លះ
អាស្រ័យ **គតិវិបត្តិ** រមែងឱ្យផលក៏មាន ១

ចំណែកអកុសលកម្មបែបខ្លះ
អាស្រ័យ **ឧបធិវិបត្តិ** រមែងឱ្យផលក៏មាន ១

ចំណែកអកុសលកម្មបែបខ្លះ
អាស្រ័យ **កាលវិបត្តិ** រមែងឱ្យផលក៏មាន ១

ចំណែកអកុសលកម្មបែបខ្លះ
អាស្រ័យ **បយោគវិបត្តិ** រមែងឱ្យផលក៏មាន ១

ចំណែកខាងកុសលកម្ម ៨ ប្រការ គឺកាលបើបុគ្គលណា ដល់ព្រមដោយគតិវិបត្តិ ១ ឧបធិវិបត្តិ ១ កាលវិបត្តិ ១ បយោគវិបត្តិ ១ កុសលកម្មបែបខ្លះ រមែងមិនមានឱកាសឱ្យផល ។ ហើយកុសលកម្មដែលនឹង

ឱ្យផលបាននោះ ត្រូវអាស្រ័យ គតិសម្បត្តិ ១ ឧបធិសម្បត្តិ ១ កាលសម្បត្តិ ១ បយោគសម្បត្តិ ១ ។

គតិសម្បត្តិ គឺការកើតក្នុងភពភូមិដែលល្អ ជាសុគតិភូមិ គតិវិបត្តិ គឺការកើតក្នុងភពភូមិ ដែលមិនល្អ ជាទុគ្គតិភូមិ ជាអបាយភូមិ ។

លោកអ្នកគ្រប់គ្នានឹងត្រូវបដិសន្ធិភ្លាមពេលចុតិចិត្តរលត់ តែមិនមានអ្នកណាដឹងដែរថា " គតិ " គឺទីកន្លែងនឹងទៅនោះ នឹងជាសុគតិ ឬ ទុគ្គតិ ។ លោកខ្លះប្រាថ្នាឱ្យតែកើតក្នុងត្រកូលដែលមិនមាន សុរា ស្រាថ្នាំ ស្រវឹងខួបទេ ប៉ុន្តែកាលចុតិចិត្តមិនទាន់កើត ក៏មិនបានដឹងថា មុននឹងចុតិចិត្តកើតនោះ នឹងមានជវនវិថីអ្វី ។ កើតខ្លះ ។ ហើយពេលចុតិចិត្តកើតនិងរលត់ទៅហើយនោះ ក៏មិនដឹងថា តើកម្មណាដែលនឹងឱ្យផល ធ្វើឱ្យបដិសន្ធិក្នុងភូមិណា ។ ដែរ ។

ប្រសិនបើកុសលកម្មឱ្យផលធ្វើឱ្យបដិសន្ធិក្នុងសុគតិភូមិ ជាគតិសម្បត្តិ ។ កុសលកម្ម ដែលធ្វើឱ្យបដិសន្ធិក្នុងសុគតិភូមិនោះ រមែងប្រមូលមកនូវកម្មផ្សេង ។ ក្នុងសង្សារវដ្ត ដែលបានធ្វើទុកហើយ ដែលគួរដល់ការជាបច្ច័យ ឱ្យវិបាកចិត្តផ្សេង ។ ដែលកើតឡើងដឹងអារម្មណ៍ ដែលជាឥដ្ឋារម្មណ៍ គួរជាទីមនោរម្យ តាមហានៈនៃបដិសន្ធិចិត្តនោះ ។ ប៉ុន្តែដោយសារអកុសលកម្មក្នុងអតីត ដែលបានធ្វើទុកផងដែរ ដូច្នេះ គ្រប់លោកអ្នកទាំងអស់គ្នា ទើបមិនមានតែឥដ្ឋារម្មណ៍ប៉ុណ្ណោះទេ ខណៈណា អកុសលកម្មឱ្យផល ខណៈនោះ ក៏ដឹងអារម្មណ៍ដែលជាអនិដ្ឋារម្មណ៍តាមផ្លូវភ្នែក

ឬតាមត្រចៀក ឬតាមច្រមុះ ឬតាមអណ្តាត ឬតាមផ្លូវកាយដែរ ។ សូម្បីដល់ថា លោកគ្រប់គ្នានឹងមានទាំងកុសលកម្ម និងអកុសលកម្ម តែការដែលកម្មនីមួយ ៗ នឹងឱ្យផលបាននោះ ក៏ត្រូវអាស្រ័យគតិសម្បត្តិ ឬគតិវិបត្តិ ។

ក្រៅអំពីនោះ នៅអាស្រ័យនឹងឧបធិ **ឧបធិ គឺជាធម៌ដែលទ្រទ្រង់សភាពនៃទុក្ខ ។ ចំពោះឧបធិសម្បត្តិ និងឧបធិវិបត្តិ គឺចំណែកប្រកបផ្សេង ៗ នៃរាងកាយពេលដែលកើតជាមនុស្ស ជាសុគតិភូមិហើយក្តី ប៉ុន្តែអកុសលកម្ម ដែលបានធ្លើរចហើយ ក៏ជាបច្ច័យឱ្យអ្នកដែលវិកលវិការមានអវយវៈ មិនសមប្រកប ជាឧបធិវិបត្តិ ជាបច្ច័យឱ្យអកុសលកម្ម មានឱកាសឱ្យផលបានច្រើនជាងកុសលកម្ម ។**

ក្រៅអំពីនោះ **កម្មដែលបានធ្វើហើយក្នុងអតីត នឹងត្រូវអាស្រ័យកាលសម្បត្តិជាបច្ច័យផងដែរ ទើបឱ្យផលបាន ។ ក្នុងកាលសម័យដែលស្រូវ អង្ករ ត្រី សាច់ អាហារ ភោជន បរិបូណ៌ល្អ ក្នុងទឹកមានត្រី ក្នុងស្រែមានស្រូវ ស្រូវអង្ករមិនក្រ មិនថ្លៃ ម្ហូបមិនថ្លៃ ក្នុងខណៈដែលដែនប្រទេសប្រកបដោយសន្តិសុខ សម្បូរបែរគ្រប់ប្រការ** ក្នុងខណៈនោះ កុសលកម្ម ក៏ជាបច្ច័យឱ្យវិបាកចិត្តកើតឡើងដឹងឥដ្ឋារម្មណ៍ តាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ ។ តែប្រសិនបើជា **កាលវិបត្តិយុគសម័យណា ដែលដែនប្រទេសកើតអសន្តិសុខ រឹកវែចលាចល ស្រូវអង្ករក្រ មានតម្លៃហួសប្រមាណ កុសលកម្មក៏មិនជាបច្ច័យឱ្យវិបាកចិត្តកើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ**

ផ្លូវអណ្តាត ផ្លូវកាយ ដូចជាក្នុងសម័យកាលសម្បត្តិឡើយ ។ ក្នុងយុគសម័យនេះ មនុស្សល្អដែលមិនបានធ្វើនូវសេចក្តីក្តៅក្រហាយ ដុតរោលដល់អ្នកណាមួយសោះឡើយ ក៏នៅតែបានទទួលវិបត្តិ ដល់ការឈឺចាប់ឬអស់នូវជីវិតបាន ព្រោះជាកាលវិបត្តិ សូម្បីថានឹងបានសន្សំកុសលមកហើយក្តី តែកាលណាបើជាកាលវិបត្តិដែនប្រទេសនោះ ក៏ត្រូវរឹករវែ ចលាចល អកុសលកម្ម ដែលបានធ្វើហើយក្នុងអតីត ក៏ជាបច្ច័យឱ្យអកុសលវិបាកចិត្តកើតឡើងជាផលនៃអកុសលកម្មនោះ ។

ក្រៅអំពីនោះ កម្មណា ៗ ដែលនឹងឱ្យផល ឬមិនឱ្យផល នោះត្រូវនៅអាស្រ័យ បយោគសម្បត្តិ ឬបយោគវិបត្តិ ។ **បយោគសម្បត្តិ គឺ សមត្ថភាពក្នុងការខិតខំព្យាយាម ប្រកបការងារ ដោយការពិចារណាដ៏ប៉ិនប្រសប់ ស្ទាត់ជំនាញ ។** កិច្ចការគ្រប់យ៉ាងសូម្បីតែអំពើចោរកម្ម ក៏ត្រូវអាស្រ័យសេចក្តីប្រយ័ត្នប្រយែងល្អិតល្អន់ សិល្បៈ ការស្ទាត់ជំនាញ និងសមត្ថភាពក្នុងការដែលនឹងធ្វើកិច្ចការងារនោះ ៗ ឱ្យសម្រេច ។ សមត្ថភាពដែលអាចបំពេញកិច្ចការងារផ្សេង ៗ បានសម្រេចជាបយោគសម្បត្តិ មិនថានឹងជាកុសលកម្មក្តី អកុសលកម្មក្តី **មិនថាអាជីពណា កិច្ចការណា ក៏ត្រូវបំពេញដោយបយោគសម្បត្តិ គឺព្រមដោយការជំនាញ សមត្ថភាពទើបអាចនឹងសម្រេចបានតាមត្រូវការ** អកុសលកម្ម ដែលបានធ្វើរួចមកហើយ នៅមិនទាន់ដល់ព្រមដោយបច្ច័យ ដែលនឹងធ្វើឱ្យអកុសលវិបាកចិត្ត កើតឡើង ព្រោះខណៈបុគ្គលនោះនៅប្រកបដោយបយោគសម្បត្តិ

សមត្ថភាពក្នុងការងារនោះនៅមាន ។ សូម្បីនឹងដល់ថា ជាបុគ្គលល្អ តែគ្មានសិល្បៈ សេចក្តីចេះដឹង សមត្ថភាពក្នុងការប្រកបអាជីព ក្នុងកិច្ចធុរៈនៃការងារ ក៏ជាបយោគវិបត្តិ ទើបមិនជាបច្ច័យឱ្យកុសលវិបាកកើតឡើង ព្រោះគ្មានបយោគសម្បត្តិ ។

ដូច្នេះ រឿងរបស់ផលដែលនឹងត្រូវកើតអំពីហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងទុកដោយល្អិត ព្រមទាំងបច្ច័យផ្សេង ។ ដែលនឹងធ្វើឱ្យផលនោះ ។ កើតឡើងដែរ សុទ្ធសឹងតែជារឿងរបស់អនត្តាទាំងអស់ មិនមែនជាតួខ្លួន ដែលគិតដោយខ្លួនឯងថា នឹងបណ្តាលឱ្យគ្រប់យ៉ាងកើតឡើងបានតាមសេចក្តីត្រូវការនោះទេ ។ ចិត្តគ្រប់ខណៈដែលកើតឡើង ត្រូវប្រកបដោយបច្ច័យផ្សេង ។ សូម្បីខណៈដែលកុសលកម្ម ឬអកុសលកម្មនឹងឱ្យផល ក៏ត្រូវប្រកបដោយគតិសម្បត្តិ ឬគតិវិបត្តិ ឧបធិសម្បត្តិ ឬឧបធិវិបត្តិ កាលសម្បត្តិ ឬកាលវិបត្តិ បយោគសម្បត្តិ ឬបយោគវិបត្តិ ។

ការយល់រឿងហេតុ រឿងផល រឿងកិលេស រឿងកម្ម រឿងវិបាក រមែងជាបច្ច័យអាចធ្វើឱ្យបានទទួលទុក្ខសោក ក្នុងសង្សារវដ្ត ថយចុះបាន ។ ក្រៅអំពីនោះ នឹងត្រូវយល់វិថីចិត្តថា ក្នុងខណៈដែលឃើញ វារៈនីមួយ ។ នោះវិបាកចិត្ត ដូចជាចក្ខុវិញ្ញាណ ដែលកំពុងឃើញក្តី សម្បដិច្ឆន្នចិត្តដែលទទួលអារម្មណ៍តពីចក្ខុវិញ្ញាណក្តី សន្តីរណចិត្តដែលពិចារណាអារម្មណ៍តពីសម្បដិច្ឆន្នចិត្តក្តី វិបាកចិត្តទាំងអស់មិនអាចនឹងធ្វើកម្មណា ។ បាន

ឡើយ ខណៈដែលបានធ្វើកុសលកម្មណាមួយ ខណៈនោះជាកុសលជវនវិថីចិត្ត ខណៈដែលបានឮសំឡេងដែលគួរពេញចិត្ត សោតវិញ្ញាណក៏ត្រឹមតែកើតឡើងបានឮ ហើយសម្បដិច្ឆន្នចិត្តក៏ទទួលសំឡេងនោះត ហើយសន្តីរណចិត្តក៏ពិចារណាសំឡេងនោះ វិបាកចិត្តធ្វើ កុសលកម្ម អកុសលកម្មអ្វី ។ មិនបានឡើយ ។

ខណៈដែលក្លិនក្រអូបមកប៉ះខ្ទប់នឹងច្រមុះ ឃានវិញ្ញាណក៏កើតឡើងដឹងក្លិននោះ សម្បដិច្ឆន្នចិត្តទទួលដឹងក្លិននោះ សន្តីរណចិត្តពិចារណាក្លិននោះ តែសម្រេចជាកម្មណា ។ មិនបានធ្វើឱ្យរូបប្រែផ្លាស់សភាពធ្វើចលនាណា ។ មិនបានឡើយ ។

ខណៈដែលកំពុងនិយាយ ដើរ កាន់យកចលនា ធ្វើកិច្ចការងារណា ។ នោះមិនមែនជាវិបាកចិត្តដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈនោះទេ តែជាជវនវិថី ដែលជាបច្ច័យឱ្យរូបចលនាទៅដោយកុសលចិត្ត ឬអកុសលចិត្ត ។ ដូច្នេះ ចិត្តដែលធ្វើកម្មណា ។ ទើបមិនមែនជាវិបាកចិត្ត ។ ខណៈកំពុងបរិភោគអាហារ ចិត្តដែលឃើញជាវិបាកចិត្ត ចិត្តដែលពេញចិត្តក្នុងអាហារដែលឃើញជាលោភមូលចិត្ត ចិត្តដែលមិនពេញចិត្តក្នុងអាហារដែលឃើញជាទោសមូលចិត្ត ចិត្តដែលដឹងរសប្រៃ ឬផ្អែមជាវិបាកចិត្ត ចិត្តដែលធ្វើឱ្យរូបចលនាទៅដួសអាហារ ឬទំពារស៊ី ដោយសេចក្តីពេញចិត្តនោះជាលោភមូលចិត្ត សតិអាចនឹងកើតឡើង រលឹកដឹងលក្ខណៈនៃចិត្តតែមួយប្រភេទតាមសេចក្តីពិត ដូច្នេះ ទើបមិនមែនត្រូវ

គេចវាងនូវលោភៈទេ តែត្រូវដឹងលោភៈតាមសេចក្តីពិត ទើបអាចលះលោភៈបាន ។ តាំងតែពីកើតមក ក៏មានបច្ច័យធ្វើឱ្យលោភៈកើតឡើងជាប្រក្រតីប្រចាំថ្ងៃ ខណៈដែលប្រកបការងារ អាជីព ភាគច្រើន គឺជាលោភៈក្នុងមួយថ្ងៃ ។ នោះលោភៈតែម្យ៉ាងកើត **ប៉ុន្តែកុសលចិត្ត ក៏មានបច្ច័យអាចកើតបានដែរ ពេលឃើញប្រយោជន៍របស់កុសលចិត្ត ។** ក្នុងខណៈដែលទទួលទានអាហារ កាលលោភៈជវនវិថីចិត្តកើតហើយ រលត់ទៅ ជវនវិថីវារៈក្រោយពីនោះអាចជាកុសល ដោយរលឹកដឹងលក្ខណៈនៃចិត្តដែលត្រេកអរពេញចិត្ត ក្នុងអាហារនោះក៏បាន ឬសតិអាចនឹងកើតឡើងរលឹកដឹងលក្ខណៈនៃរូបធម៌ ដែលទន់ ឬរឹង ក្តៅ ឬ ត្រជាក់ តឹង ឬ ញ័រ ឬ រសជូរ ផ្អែម ប្រៃ ដែលប្រាកដក៏បាន ។

ការអប់រំចម្រើនសតិប្បដ្ឋាន ធ្វើឱ្យដឹងសភាពនៃចិត្តបាន សូម្បីក្នុងខណៈដែលនៅមិនទាន់មានការប្រព្រឹត្តធ្វើណា ។ តាមផ្លូវកាយ តាមផ្លូវវាចាក៏ដោយ ដូចសតិអាចរលឹកដឹងថាចិត្តដែលឃើញមិនមែនចិត្ត ដែលត្រេកអរ ពេញចិត្តក្នុងវត្ថុដែលប្រាកដជាដើម ។

អត្ថនៃចិត្តប្រការទី ៣ ដែលឈ្មោះថាចិត្ត ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។

កិលេសជាសភាវធម៌មិនបរិសុទ្ធ សៅហ្មង ។ សៅហ្មង គឺមិនជូរជង់ មិនបរិសុទ្ធ ដូចជា ខណៈដែលកើតសេចក្តីត្រេកអរ សេចក្តីជាប់

ជំពាក់ ត្រូវការ ខណៈដែលកំពុងប្រាថ្នាចង់បានរបស់ណាមួយនោះ សប្បាយចិត្ត ឬមិនសប្បាយចិត្ត ? បើមិនចង់បាន មិនកើតលោភៈ អាច សប្បាយចិត្តជាងនោះ ព្រោះមិនត្រូវរវែង ប្រកាន់ស្អិត មិនត្រូវជាប់ជំពាក់ មិនត្រូវគិតប្រាថ្នាចង់បាន ។ តែខណៈដែលកំពុងជាប់ជំពាក់ ប្រាថ្នាចង់ បាននោះ អវិជ្ជាមិនអាចនឹងឃើញបានថា ខណៈនោះជាសភាវធម៌ដែល សៅហ្មង មិនបរិសុទ្ធ មិនសប្បាយចិត្ត ក្តៅក្រហាយ ព្រោះតែ ដោយសារសេចក្តីជាប់ជំពាក់ត្រូវការប្រាថ្នា ចង់បាននោះឡើយ ។ មិន ថានឹងកើតសេចក្តីពេញចិត្តវត្ថុណាមួយ ខណៈនោះ ក៏ជាសេចក្តីជាប់ ជំពាក់ ជាសេចក្តីសៅហ្មង ជាសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ ហើយកន្លែងខ្លះ លោកអ្នកខ្លះ ក៏យល់ថាជាសទ្ធាដោយពិត បើសតិប្បដ្ឋាន មិនកើតទេ បញ្ញាមិនពិចារណាទេនោះ នឹងមិនដឹងថាខណៈនោះ ជា លោភៈ ដែលជាអកុសល ឬថាជាសទ្ធាដែលជាកុសលឡើយ ។

ក្នុងជីវិតប្រចាំថ្ងៃរបស់បព្វជិត និងគ្រហស្តជាអ្នកនៅមានកិលេស និងផុតចាកអំពីលោភៈមិនបានឡើយ ខណៈណាដែលពេញចិត្តនូវអ្វី ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ និងផ្លូវចិត្ត ជាលោភៈសម្រាប់គ្រហស្តយ៉ាងណា បព្វជិតដែលជាអ្នកនៅ មានកិលេស ក៏យ៉ាងដូច្នោះដែរ ។

កិលេសដែលកើតឡើងមួយខណៈនោះ កាលបើខណៈណាមាន កម្លាំង ខ្លាំងក្លា ក៏ជាអកុសលកម្មសម្រេចតាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ

បើមិនមានកិលេស អកុសលកម្មតាមផ្លូវកាយ ផ្លូវវាចា ក៏កើតឡើងមិនបានឡើយ និងពេលបានធ្វើកម្មទៅហើយ សូម្បីចាចិត្ត និងចេតសិក ដែលកើតរួមគ្នាធ្វើកម្មនោះ ។ សម្រេចទៅហើយ រលត់ទៅហើយក្តី តែការសន្សំនៃកម្មដែលនៅបន្តក្នុងចិត្តគ្រប់ ។ ខណៈដែលកើត រលត់បន្តគ្នាទៅរឿយ ។ នោះក៏ជា**កម្មប្បច្ច័យ គឺជាសភាវធម៌ដែលនាំឱ្យផល គឺវិបាកចិត្ត និងចេតសិកកើតឡើង ដូច្នេះ ទើបត្រូវដឹងថា ខណៈណាជាកិលេស ខណៈណាជាកម្ម ខណៈណាជាវិបាក** ចិត្តឃើញ ចិត្តឮ ចិត្តធុំក្លិន ចិត្តដឹងរស ចិត្តដឹងផោដ្ឋព្វៈ ជាវិបាកចិត្តជាផលរបស់កម្ម ។ គ្រប់បុគ្គលចង់តែឃើញនូវវត្ថុដែលពេញចិត្ត ទោះជាឃើញប៉ុណ្ណា ។ ក៏មិនអស់ចិត្ត សូម្បីតែថានឹងមានចក្ខុបសាទកើត ព្រោះកម្មជាបច្ច័យ តែអារម្មណ៍ដែលប៉ះខ្ទប់នឹងចក្ខុបសាទ ហើយប្រាកដដល់ចក្ខុវិញ្ញាណនោះ រមែងស្រេចតែកម្មប្បច្ច័យ កាលកុសលកម្មជាបច្ច័យ ក៏ធ្វើឱ្យចក្ខុវិញ្ញាណកុសលវិបាកកើតឡើងឃើញវត្ថុដែលគួរជាទីពេញចិត្ត ខណៈណាឮសំឡេងដែលគួរជាទីពេញចិត្ត ក៏ជាផលរបស់កុសលកម្ម ។ ខណៈណាឮសំឡេងដែលមិនជាទីពេញចិត្ត ក៏ជាផលរបស់អកុសលកម្ម ។ ខណៈនេះ និងខណៈតទៅ នឹងជាកុសលវិបាក ឬអកុសលវិបាក ក៏រមែងស្រេចតែកុសលកម្ម ឬអកុសលកម្ម នឹងជាបច្ច័យឱ្យវិបាកនោះ ។ កើតឡើងតាមទ្វារណា ។

បច្ច័យធំ ៗ ដែលធ្វើឱ្យសភាវធម៌ទាំងឡាយកើតឡើងនោះមាន ២៤ បច្ច័យ ។ កម្មជាបច្ច័យឱ្យវិបាកកើតឡើង ដូច្នេះ **កម្មទើបជាកម្មប្បច្ច័យ ជាបច្ច័យ ១ ក្នុង ២៤ បច្ច័យ ។** ខណៈឃើញ បានឮ បានធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈនោះ ជាវិបាកចិត្ត និងជាវិបាកចេតសិកដែលកើតឡើងព្រោះកម្មប្បច្ច័យ មិនមានអ្នកណាអាចបណ្តាលឱ្យកើតឡើងតាមអំពើចិត្តចង់នោះបានឡើយ ដូចខណៈនេះ ឃើញហើយ ឮហើយ តើអ្នកណាអាចមិនឱ្យឃើញ មិនឱ្យឮបានខ្លះ ក្នុងពេលឃើញកើតឡើងហើយ ព្រោះកម្មជាបច្ច័យ និងឮកើតឡើងហើយក៏ព្រោះកម្មជាបច្ច័យ ។

ចិត្ត និងចេតសិកដែលកំពុងដឹងអារម្មណ៍ ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ជាវិបាកចិត្ត និងជាវិបាកចេតសិកដែលកើតរួមគ្នា វិបាកចិត្ត ជាបច្ច័យដល់វិបាកចេតសិក និងវិបាកចេតសិកក៏ជាបច្ច័យដល់វិបាកចិត្ត ដោយជា**វិបាកប្បច្ច័យ** គឺត្រូវកើតជាវិបាក ជាយ៉ាងដទៃមិនបានឡើយ ទាំងចិត្ត ទាំងចេតសិកកើតឡើងព្រមគ្នាជាវិបាកទាំង ២ យ៉ាង ហើយជាវិបាកប្បច្ច័យនៃគ្នានឹងគ្នា ។ **រូបដែលកើតឡើងព្រោះកម្មជាបច្ច័យនោះ ជាផលរបស់កម្មតែមិនមែនជាវិបាក** ព្រោះរូបមិនមែននាមធម៌ រូបមិនមែនសភាវៈដឹង ទើបរូបមិនជាវិបាក **វិបាកត្រូវតែជានាមធម៌ ដែលជាសភាវៈដឹងប៉ុណ្ណោះ ។**

លក្ខណៈនៃចិត្តប្រការទី ៣ គឺឈ្មោះថា **ចិត្ត** ព្រោះជាធម្មជាតិដែលកម្មកិលេសសន្សំវិបាក ។

រឿងនៃអតីតកម្មជារឿងដែលដឹងបានដោយពិបាក ព្រោះជាការប្រព្រឹត្តដែលសម្រេចហើយ ស្រេចបាច់អស់ហើយក្នុងអតីត តែជាបច្ច័យគឺធ្វើឱ្យកើតវិបាកចិត្ត និងចេតសិកក្នុងបច្ចុប្បន្ន ដូច្នេះ ទើបគួរនឹងពិចារណាឱ្យយល់សភាវធម៌ដែលជាវិបាកឱ្យល្អិតឡើងថា សភាវៈធម៌ដែលជាវិបាកនោះ បានដល់នាមធម៌ គឺចិត្ត ចេតសិកដែលកើតឡើង ព្រោះកម្មដែលបានធ្វើរួចហើយជាបច្ច័យ ។

ជាទូទៅ នៅពេលដែលជួបប្រសព្វហេតុការណ៍ណាមួយ ក៏ច្រើនតែនិយាយគ្នាថាជាកម្មរបស់បុគ្គលនោះ តែបើនឹងឱ្យយល់ត្រឹមត្រូវតាមពិត ។ នោះ គួរនឹងនិយាយថាជាផលនៃកម្មដែលបុគ្គលនោះបានធ្វើរួចហើយដែលនឹងធ្វើឱ្យយល់កាន់តែជាក់ច្បាស់ឡើងថា ខណៈណាជាផលនៃកម្ម និងខណៈណាជាកម្ម ព្រោះបើនាំគ្នានិយាយកាត់ ។ ថា ជាកម្មរបស់បុគ្គលនោះ អ្នកដែលមិនធ្លាប់ដឹងនូវហេតុនៃផលរបស់សភាវធម៌ ក៏អាចនឹងយល់ឃ្លៀងឃ្លាតខុសទៅបាន ដោយអាចនឹងកាន់យកវិបាកនោះឯង ថាជាកម្មវិញ ។

កាលណាបានសិក្សា និងយល់រឿងរបស់ចិត្តដែលជាសភាវធម៌ដែលកម្មកិលេសសន្សំវិបាកហើយ ក៏អាចធ្វើឱ្យយល់នូវសភាវធម៌ទាំងឡាយតាមសេចក្តីពិតក្រៃលែងឡើង គឺបើប្រាសចាកនូវទ្វារភ្នែក ត្រចៀក

ច្រមុះ អណ្តាត កាយ ចិត្តដែលជាផ្លូវទទួលដឹងអារម្មណ៍ផ្សេង ៗ ហើយ ក៏រមែងនឹងមិនមានវិបាកចិត្ត ក្នុងជីវិតប្រចាំថ្ងៃកើតឡើង ទទួលផលនៃកម្ម ។ ខណៈដែលឃើញជាវិបាក ផលរបស់កម្ម សូម្បីថាមិនបានជួបឧប្បត្តិហេតុ ឬបានលាភ យសដទៃណា ។ ក្តី ខណៈបានឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃនោះ ជាផលរបស់អតីតកម្ម ដែលបានធ្វើរួចហើយទាំងអស់ វិបាកចិត្តមិនមែន ចំពោះខណៈឈឺចុកចាប់ បានលាភ ឬអត់លាភ បានយស ឬវិនាសយស តែប៉ុណ្ណោះទេ ហើយសតិអាចរលឹកដឹងនូវសភាវធម៌ ដែលជាវិបាកបានក្នុងខណៈដែលឃើញ ឮ ធុំក្លិន ដឹងរស ជោដ្ឋព្វៈ ក្នុងជីវិតប្រចាំថ្ងៃ ។

វិបាកចិត្តរមែងកើតឡើងជាផលរបស់កម្មប្បច្ច័យ ដែលបានធ្វើរួចហើយដែលលំបាកដល់ការដែលអាចដឹងបានថា វិបាកចិត្តដែលកើតឡើងតាមទ្វារនីមួយ ៗ នោះ ជាផលរបស់អតីតកម្មអ្វី ដូចជាវិបាកចិត្តដែលបានឮសំឡេងក្មេងលេងកីឡាបាល់ទាត់នោះ ជាផលរបស់អតីតកម្មអ្វី **រឿងរបស់កម្មជារឿងដែលលំបាកដឹងបាន ព្រោះជាអចិន្តេយ្យ គឺជាសភាវៈដែលមិនគួរគិត** ។ កម្មដែលបានធ្វើហើយជាហេតុក្នុងអតីត ដែលទោះជាបានធ្វើមកយូរយារហើយក្នុងសង្សារវដ្តក៏ដោយ ក៏នៅជាបច្ច័យឱ្យវិបាកចិត្តកើតបាន ។ ដូច្នេះ បើអ្នកណាគិតដៅថា ឃើញសភាវៈនេះជាផលរបស់កម្មអ្វី ឮសំឡេងនោះជាផលរបស់កម្មអ្វី ក៏នឹងមិនអាចផុតអំពីសេចក្តីមិនដឹង និងខ្វល់ខ្វាយចិត្តឡើង ព្រោះគិតដៅក្នុងសភាវៈដែល

មិនទាន់អាចមានបញ្ញាថ្នាក់ដែលអាចដឹងពិតបាន ប៉ុន្តែវិបាកដែលជាផលរបស់កម្មក៏កំពុងប្រាកដឱ្យដឹងបានតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

ក្នុងចិត្តានុបស្សនាសតិប្បដ្ឋាន សភាពនៃចិត្តប្រភេទទី ១ គឺ **សរាគ-ចិត្ត** សតិកើតឡើងរលឹកដឹង សភាពចិត្តដែលប្រកបដោយរាគៈ សេចក្តីពេញចិត្តត្រេកអរ ជាប់ជំពាក់ ដែលកើតឡើងជាប្រក្រតីធម្មតា ។ កាលណាសតិប្បដ្ឋានមិនកើត ក៏មិនអាចដឹងបានឡើយថា ពេលឃើញសភាវៈណា លោភមូលចិត្តដែលជាចិត្តត្រេកអរ ពេញចិត្តក្នុងសភាវៈដែលឃើញនោះ គឺកើតបន្តគ្នាយ៉ាងរហ័សបំផុត ។ ការដែលរំលត់កិលេសបាននោះ បញ្ញានឹងត្រូវដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដជាប្រក្រតីតាមសេចក្តីពិត គឺដឹងសភាពដែលផ្សេងគ្នានៃវិបាកចិត្តដែលជាផលរបស់អតីតកម្ម និងកុសលចិត្ត អកុសលចិត្ត ដែលជាកិលេស ឬកម្មបច្ចុប្បន្ន ដែលអាចជាបច្ច័យឱ្យកើតវិបាកចិត្តក្នុងអនាគត ។ ដូច្នេះ ការដឹងលក្ខណៈនៃវិបាកចិត្តនោះ ទើបមិនមែនជាការដឹងត្រឹមតែគ្រោតគ្រាត ។ ពេលមានឧប្បត្តិហេតុ មានរោគភ័យឈឺចុកចាប់ មានលាភ ឬវិនាសលាភ បានយស ឬវិនាសយសប៉ុណ្ណឹងទេ តែត្រូវដឹងថា វិបាកចិត្តគឺខណៈដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ក្នុងជីវិតប្រចាំថ្ងៃ ។

បើដឹងថា វិបាកចិត្តដែលកើតឡើងនោះ ជាផលនៃកម្មរបស់ខ្លួនឯងហើយ តើនឹងអាចខឹង ឬក្រោធអ្នកដទៃនោះទេ ថាអ្នកនោះ អ្នកនេះធ្វើឱ្យជាយ៉ាងនេះ ។

ក្នុងព្រះត្រៃបិដក មានហេតុការណ៍ក្នុងជីវិតនៃបុគ្គលដែលបានទទួលវិបាកផ្សេងគ្នា តាមយុគសម័យនោះ សម័យនេះ ក៏មានហេតុការណ៍ ផ្សេង ។ ដែលសម្តែងឱ្យឃើញថា បុគ្គលម្នាក់ ។ រមែងបានទទួលវិបាក គឺផលរបស់អតីតកម្ម ដោយមិននឹកគិតថា នឹងជាលក្ខណៈណា ។ ឡើយ ដូចអគារទាំងខ្ពងបាក់ចុះមកសង្កត់ម្ចាស់ផ្ទះស្លាប់ មិនមែនអាស្រ័យដោយគ្រាប់ផ្ទុះទេ មិនមែនត្រូវដោយអ្នកដទៃបាញ់ ឬបំផ្លាញទេ តែអតីតកម្មដែលធ្វើរួចហើយ ជាបច្ច័យឱ្យបានទទួលផលនៃកម្មតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយប៉ុណ្ណោះ ដូច្នេះ ទើបមិនគួរក្រោធ ឬមានទោសៈនឹងអ្នកដទៃឡើយ ប៉ុន្តែគួរដែលសតិរលឹកដឹងលក្ខណៈរបស់សភាវៈដែលជាវិបាកចិត្ត មិនមែនសត្វ បុគ្គល តួខ្លួនពិត ។ ហើយក៏នឹងដឹងបានថា ខណៈនោះ ជាផលរបស់កម្មអតីត មិនមែនខណៈដែលជាលោភៈ ទោសៈ មោហៈ ឬកុសល ដែលជាហេតុបច្ចុប្បន្នដែលនឹងឱ្យកើតផលក្នុងអនាគត ។

ទាំងវត្ថុខាងក្រៅ និងទាំងរូបកាយដែលប្រាកដឱ្យឃើញថា ខ្ពស់ ទាប ខ្មៅ ស ផ្សេង ។ នោះ ក៏ប្រាកដនៃជួរខណៈដែលប៉ះខ្ទប់នឹងចក្ខុបសាទប៉ុណ្ណោះ បើមិនមានភ្នែក ឬមិនឃើញ ក៏នឹងមិនបាននឹកគិត

រូបរាង សណ្ឋាន ខ្ពស់ ទាប ខ្មៅ ស ដែលប្រកាន់ស្អិតថា ជារាងកាយ របស់យើងឡើយ ។ ដូច្នេះ រូបរាងកាយរបស់ខ្លួនឯង និងវត្ថុខាងក្រៅ ទាំងអស់ តាមសេចក្តីពិតនោះ មិនមែនជារបស់អ្នកណាឡើយ គឺត្រឹមតែ ជាសភាវៈដែលប្រាកដក្នុងជួរខណៈ ដែលចក្ខុវិញ្ញាណកើតឡើងឃើញ ហើយ ក៏រលត់ទៅវិញយ៉ាងរហ័សតែប៉ុណ្ណោះឯង ។

សំឡេងដែលប្រាកដ ពេលប៉ះខ្ទប់នឹងត្រចៀកក៏ដូចគ្នា ត្រឹមតែជា សភាវៈដែលប្រាកដពេលប៉ះខ្ទប់នឹងត្រចៀក ហើយក៏រលត់ទៅអស់ មិន មែនរបស់អ្នកណាទាំងអស់ឡើយ ។ ការរលឹកដឹងលក្ខណៈនៃសភាវធម៌ ជាប្រក្រតីតាមសេចក្តីពិត នឹងអាចធ្វើឱ្យលះបង់នូវការប្រកាន់ស្អិត នូវ សភាវធម៌ទាំងឡាយទាំងពួង ថាជាសត្វ បុគ្គល តួខ្លួនបាន ។

ជួរខណៈដែលឃើញម្តង ឮម្តង ធុំក្លិនម្តង ដឹងរសម្តង ដឹងសភាវៈ ដែលប៉ះខ្ទប់សម្ផស្សម្តង ឬនឹកគិតផ្សេង ។ នោះ ជាសភាវធម៌ដែល មានពិត ជាសតិប្បដ្ឋានឱ្យបញ្ញាសិក្សាដឹងលក្ខណៈនៃសភាវធម៌នោះ តាម សេចក្តីពិតបានថា មិនមែនសត្វ បុគ្គល តួខ្លួន ណា ។ ឡើយ ។

សាកល្បងពិចារណាមើលទ្រព្យសម្បត្តិដែលយល់ថា មានច្រើន សន្ធឹកសន្ធាប់នោះ បើមិនឃើញទ្រព្យសម្បត្តិនោះទេ ក៏ត្រឹមតែគិតប៉ុណ្ណោះ ថាមាន ទ្រព្យសម្បត្តិផ្សេង ។ ច្រើន តែពេលមិនឃើញ មិនបានប៉ះខ្ទប់ សម្ផស្សទ្រព្យសម្បត្តិនោះ ។ ទេ តើនឹងមានប្រយោជន៍អ្វីទេ អំពីទ្រព្យ សម្បត្តិនោះ ។ ។ កាលណាដឹងលក្ខណៈរបស់សភាវៈបរមត្ថ ដែល

មិនមែនសត្វ បុគ្គល តួខ្លួនពិត ។ ហើយក៏ដឹងថាគ្រប់បុគ្គលស្មើគ្នា គឺ ចក្ខុវិញ្ញាណកើតឡើងខណៈណា ក៏ឃើញសភាវៈដែលប្រាកដហើយ ក៏ រលត់ទៅ ចក្ខុវិញ្ញាណ និងសភាវៈដែលប្រាកដឱ្យឃើញ ទើបមិនមែន សម្បត្តិរបស់អ្នកណាទាំងអស់ ដូច្នេះ ទើបមិនគួរប្រកាន់នូវសភាវៈណា ។ ថាជាយើង ជារបស់យើង ។ គ្រប់បុគ្គលស្មើគ្នាដោយសភាវៈ ដែលជា បរមត្ថដូចគ្នា តែកិលេសដែលប្រកាន់នូវសភាវៈធម៌ថាជាយើង ជារបស់ យើងនៅមាន រមែងច្រើនតិចផ្សេងគ្នា ។

លោកអ្នកដែលធ្លាប់ត្រេកអរក្នុងទ្រព្យសម្បត្តិច្រើន តិចរបស់លោក អ្នកនោះ ផ្តើមដឹងឬនៅថា លោកអ្នកមិនមានទ្រព្យសម្បត្តិណាឡើយ ព្រោះចក្ខុវិញ្ញាណកើតឡើងឃើញហើយ ក៏រលត់ទៅយ៉ាងរហ័ស បើចក្ខុ-វិញ្ញាណមិនកើតឡើង តើទ្រព្យសម្បត្តិរបស់លោកអ្នកនៅទីណា ? កាល ណា ទ្រព្យសម្បត្តិត្រឹមតែជាអ្វីដែលចក្ខុវិញ្ញាណកើតឡើងឃើញ ១ ជួរ ខណៈ ហើយប្រកាន់ថាជាទ្រព្យសម្បត្តិរបស់លោកអ្នកបានយ៉ាងណា ក្នុង ពេល សភាវៈដែលប្រាកដនោះ មិនអាចនឹងចូលមកដល់ខ្លួនរបស់លោក អ្នកបានឡើយ ត្រឹមតែអាចប្រាកដពេលដែលប៉ះខ្ទប់ចក្ខុទ្វារ ឬចក្ខុបសាទ ប៉ុណ្ណោះ ។

សំឡេង ក្លិន រស និង ផោដ្ឋព្វៈក៏ដូចគ្នា មានត្រឹមតែ ១ ជួរខណៈ ដែលប៉ះខ្ទប់សម្ផស្សប៉ុណ្ណោះ ទើបមិនគួរនឹងប្រកាន់នូវសភាវធម៌នោះ ។ ថាជាយើង ឬថាជារបស់យើង ។

សូម្បីដល់ទៅថា គ្រប់គ្នាទាំងអស់ចង់មានសម្បត្តិច្រើន ។ ឱ្យ ស្មើគ្នាដូច ។ គ្នាយ៉ាងណាក៏ដោយ តែតាមសេចក្តីពិតនោះ ផលដែល ប្រាកដក្នុងបច្ចុប្បន្នជាតិនេះ កើតអំពីហេតុក្នុងអតីត ដូច្នេះ ទើបមិននៅក្នុង អំណាចបង្គាប់បញ្ជានៃបុគ្គលណាឡើយ វិបាកគឺផលរបស់កម្ម ក្នុងខណៈ ដែលត្រឹមតែឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ដែលមិនមានអ្នកណាអាចព្យាករបានថា ខណៈដែលឃើញ ឬឮជាដើម វារៈនីមួយ ។ នោះជាផលនៃកម្មអ្វី ។

សេចក្តីក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ទុតិយបណ្ណាសក អបណ្ណកវគ្គទី ៣ អចិន្តេយ្យសូត្រ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ អចិន្ត្រៃយ៍ **៤ ប្រការនេះ ដែលបុគ្គលមិនគួរគិត** កាលណា បុគ្គលគិត **គប្បីជាអ្នកមានចំណែកនៃសេចក្តីឆ្កួត ក្តៅក្រហាយ** ។ អចិន្ត្រៃ-យ៍ ៤ ប្រការដូចម្តេច ម្នាលភិក្ខុទាំងឡាយ **ជាពុទ្ធវិស័យរបស់ព្រះពុទ្ធ ជាម្ចាស់ទាំងពួង ១ ជាឈានវិស័យរបស់អ្នកបានឈាន ១ វិបាកនៃកម្ម ១ សេចក្តីគិតរឿងលោក ១** ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ៍ ៤ ប្រការនេះ ឯងមិនគួរគិត កាលបើបុគ្គលគិត គប្បីជាអ្នកមានចំណែកនៃសេចក្តីជាឆ្កួត ក្តៅក្រហាយ ។

ខណៈនេះកំពុងឃើញ ជាវិបាកចិត្តតាមផ្លូវភ្នែក **សតិអាចរលឹកដឹង លក្ខណៈសភាវធម៌ គឺនាមធម៌ ដែលជាសភាពដឹង និងរូបធម៌ គឺសភាវៈ ដែលកំពុងប្រាកដប៉ុណ្ណោះ** ។ ហើយនឹងដឹងហួសរហូតដល់ថា ដែលកំពុង

ឃើញឥឡូវនេះ ជាផលរបស់អតីតកម្មអ្វីក្នុងជាតិណានោះ រមែងមិនអាចនឹងដឹងបាន តែខណៈដែលកំពុងឃើញនោះសតិប្បដ្ឋានអាចរលឹកដឹងបាន និងបញ្ញាអាចដឹងច្បាស់បានថា ខណៈដែលឃើញសុទ្ធតែជាវិបាកនោះ មិនមែនខណៈដែលពេញចិត្ត ឬមិនពេញចិត្ត ជាអកុសលដែលកើតឡើងតអំពីខណៈដែលឃើញនោះទេ ។

ម៉្យាងទៀត ចិត្តសូម្បីគ្រប់ដួងឈ្មោះថា ចិត្ត ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ដោយអំណាចនៃសម្បយុត្តធម៌ វិចិត្រ គឺផ្សេង ។ គ្នាទៅតាមសម្បយុត្តធម៌ គឺចេតសិកដែលកើតរួមផងដែរ ជាការសន្សំរបស់បុគ្គលម្នាក់ ។ ដូច្នេះដែលនឹងឱ្យបុគ្គលគ្រប់រូបមានសេចក្តីគិតដូចគ្នាកាន់លទ្ធិសាសនាដូចគ្នានោះ ទើបជាអ្វីដែលប្រព្រឹត្តទៅមិនបានឡើយ ព្រោះសូម្បីរូបរាងកាយក៏មិនដូចគ្នា សេចក្តីនឹកគិត ក៏រមែងមិនដូចគ្នា សេចក្តីយល់ឃើញ សេចក្តីជឿផ្សេង ។ ក៏រមែងមិនដូចគ្នា សូម្បីក្នុងសម័យដែលព្រះដ៏មានព្រះភាគទ្រង់មិនទាន់បរិនិព្វាន ព្រះមានព្រះភាគព្រះអង្គឯង ក៏ទ្រង់មិនអាចប្រោសឱ្យបុគ្គលទាំងឡាយ មានសេចក្តីយល់ឃើញត្រូវបានគ្រប់គ្នាឡើយ អ្នកដែលសន្សំហេតុបច្ច័យមក ហើយមានឱកាស វិបាកចិត្ត និងកុសលចិត្ត ក៏កើតឡើងបានឮ បានស្តាប់ បានសិក្សាបានពិចារណាព្រះធម៌ ដែលព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់សម្តែងនោះ ពេលបានឮ បានស្តាប់ហើយ ក៏ពិចារណាត្រិះរិះ ប្រៀបធៀបឱ្យកាន់តែល្អិតល្អន់

ឡើងហើយអប់រំបញ្ញារហូតអាចដឹងលក្ខណៈនៃសភាវធម៌ ត្រង់តាមដែលព្រះមានព្រះភាគទ្រង់សម្តែងទុក ។

សេចក្តីឃើញខុស យល់ខុសនោះ មិនមែនមានតែក្នុងសាសនាដទៃនោះទេ សូម្បីអ្នកដែលកាន់នូវព្រះពុទ្ធសាសនា ក៏ប្រតិបត្តិ ប្រព្រឹត្តផ្សេង ៗ គ្នា តាមតែសេចក្តីពិត សេចក្តីយល់ដែលសន្សំមកផ្សេង ៗ គ្នាដែរ ។ ក្នុងសម័យក្រោយការធ្វើសង្គាយនាគ្រាលើកទី ២ ភិក្ខុស្រុកវជ្ជី ជាអ្នកដើមហេតុធ្វើឱ្យសង្គាយនាលើកទី ២ នោះ ក៏បានតាំងនិកាយផ្សេង ៗ តាមសេចក្តីយល់របស់ខ្លួន ដូចជានិកាយមួយមានសេចក្តីយល់ឃើញថា អ្នកណាក៏ដោយដែលនឹងបន្លុះមគ្គផលប្រត្រក្សច្បាស់ព្រះនិព្វានបាន ត្រូវបន្លឺវាចាថា ទុក្ខហ្ន៎[២៥]។ ការយល់គន្លងផ្លូវប្រព្រឹត្តប្រតិបត្តិខុស ឃ្លៀងឃ្លាតនោះ មានមកតាំងពីសម័យបុរាណ ។ ដូច្នេះ សម័យនេះ អស់លោកគ្រប់គ្នាទើបត្រូវសិក្សា និងពិចារណាដោយល្អិតល្អន់ ព្រោះអ្នកនឹងដឹងច្បាស់នូវអរិយសច្ចធម៌សម័យនេះ មិនមែនឧគ្ឃដិតញ្ញបុគ្គល ឬវិបច្ចិតញ្ញបុគ្គលនោះទេ តែអ្នកដែលនឹងដឹងច្បាស់នូវអរិយសច្ចធម៌ ក្នុងសម័យនេះបាននោះរមែងជានេយ្យបុគ្គល និងអ្នកដែលមិនអាចនឹងដឹងច្បាស់អរិយសច្ចធម៌បាន សូម្បីនឹងថា បានស្តាប់ធម៌ច្រើនក៏ដោយ អានធម៌ច្រើនក៏ដោយ សន្ធនាធម៌ច្រើន ពោលធម៌ច្រើនក៏ដោយ ក៏ជាបទបរមបុគ្គល ។

[២៥]និទានគាថា កថាវត្ថុ បករណដ្ឋកថា

ដូច្នេះ ព្រះធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់ព្រះមហាករុណា សម្តែងរហូតដល់អស់ចំនួន ៤៥ វស្សានោះ ក៏ដើម្បីទ្រង់អនុគ្រោះអ្នក ដែលជានេយ្យបុគ្គល និងបទបរមបុគ្គល ។ គ្រប់គ្នាទើបត្រូវសិក្សាឱ្យដឹង ពិត ។ ថា **ការដឹងច្បាស់អរិយសច្ចធម៌នោះ គឺដឹងអ្វី ? និងគន្លងផ្លូវដែលនឹង ឱ្យដឹងការកើតឡើង និងរលត់ទៅនៃធម៌ដែលប្រាកដតាមផ្លូវភ្នែក តាមផ្លូវ ត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ និងផ្លូវចិត្តបានពិត ។ នោះ ត្រូវអប់រំ ចម្រើនអ្វី** ? ទើបនឹងជាអ្នកដែលយល់ប្រយោជន៍ពិតប្រាកដនៃការសិក្សា ដើម្បីឧបត្ថម្ភឧបការៈឱ្យសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ ដែលព្រះដ៏ មានព្រះភាគទ្រង់ត្រាស់ដឹង និងទ្រង់ព្រះមហាករុណាសម្តែងទុកដោយ ល្អិតល្អន់ សូម្បីតែលក្ខណៈនៃចិត្តដែលបានពោលដល់ហើយ និងចិត្ត ដែលកំពុងឃើញ ក៏ជាសតិប្បដ្ឋាន ជាសភាវៈធម៌ដែលបញ្ញាអាចនឹងអប់រំ ចម្រើនឡើង រហូតដល់ប្រត្យក្សច្បាស់សភាពដែលជាអនត្តា កើតឡើង រលត់ទៅ ក្នុងជីវិតប្រចាំថ្ងៃ មិនមែនសត្វ បុគ្គល តួខ្លួន វត្ថុ របស់ណា ។ ឡើយ ។

សំណួរសាឡើងវិញ

១ - កម្មប្បច្ច័យ គឺអ្វី ?

២ - វិបាកប្បច្ច័យ គឺអ្វី ?

៣ - រូបដែលកើតព្រោះកម្មជាបច្ច័យនោះ ជាវិបាកមែនឬ ? ព្រោះអ្វី ?

មេរៀនទី ៨

លក្ខណៈរបស់ចិត្ត ៤ ប្រការគឺ

១ - ដែលឈ្មោះថា « **ចិត្ត** » **ព្រោះជាសភាវធម៌ដែលដឹងច្បាស់អារម្មណ៍**

២ - ដែលឈ្មោះថា « **ចិត្ត** » **ព្រោះសន្សំសន្តាននៃខ្លួនដោយអំណាចនៃជវនវិថី**

៣ - ដែលឈ្មោះថា « **ចិត្ត** » **ព្រោះជាសភាវធម៌ដែលកម្មកិលេសសន្សំវិបាក**

៤ - ម្យ៉ាងទៀត ចិត្តសូម្បីគ្រប់ដួងឈ្មោះថា « **ចិត្ត** » **ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ដោយអំណាចនៃសម្បយុត្តធម៌** ។

វិចិត្រ គឺផ្សេង ៗ មិនដូចគ្នា ហើយដែលវិចិត្រ គឺផ្សេង ៗ គ្នានោះ ដោយអំណាចនៃសម្បយុត្តធម៌ ។

ត្រូវមានហេតុដែលធ្វើឱ្យចិត្តផ្សេងគ្នា ដូច្នេះ តើអ្វីដែលជាហេតុឱ្យចិត្តផ្សេងគ្នា ? ចិត្តជាសង្ខារធម៌ ជាសភាវដែលកើតឡើង ដោយមានចេតសិកជាបច្ច័យតាក់តែង ។ ចេតសិក ជាបរមត្ថ ១ ប្រភេទទៀត ដែលកើតព្រមជាមួយនឹងចិត្ត រលត់ព្រមនឹងចិត្ត ដឹងអារម្មណ៍ដូចគ្នាជាមួយនឹងចិត្ត និងកើតត្រង់កន្លែងជាមួយនឹងចិត្ត ដូច្នេះ ចេតសិកដែលជាសម្បយុត្តធម៌ ដែលកើតជាមួយចិត្តនោះឯង ធ្វើឱ្យចិត្តទៅជាផ្សេង ៗ គ្នា ។

ចិត្តរបស់លោកអ្នកម្នាក់ ៗ ផ្សេងគ្នាច្រើនណាស់ តាមដែលសន្សំមក ក្នុងអតីត ទើបជាហេតុឱ្យផល គឺវិបាកក្នុងបច្ចុប្បន្ននេះផ្សេងគ្នា ។ មិនថាមានសត្វបុគ្គលតិច ច្រើនប៉ុណ្ណាក្នុងលោក ក៏រមែងផ្សេងគ្នាទៅតាមកម្ម តាមការវិចិត្ររបស់ហេតុ តាំងអំពីរូបរាង មុខមាត់ រហូតដល់ការបានលាភ អត់លាភ បានយស អត់យស សុខ ទុក្ខ សរសើរ និន្ទា ដែលសុទ្ធតែជាផលដែលកើតឡើងអំពីហេតុក្នុងអតីតដែលផ្សេងគ្នា តាំងតែពីកើតរហូតដល់អស់ជីវិត មិនមាននរណាដឹងថាបុគ្គលម្នាក់ ៗ នឹងលាចាកលោកនេះទៅថ្ងៃណា ពេលណា ដោយអាការយ៉ាងណា ក្រៅផ្ទះ ឬក្នុងផ្ទះ លើគោក ឬក្នុងទឹក ឬកណ្តាលអាកាស ដោយរោគភ័យឈឺចាប់ ឬឧប្បត្តិហេតុយ៉ាងណា ក៏មិនមាននរណាអាចនឹងដឹងបានឡើយ ដែលរមែងតែងតែប្រព្រឹត្តទៅតាមកម្មដែលបានធ្វើមកហើយ ។ ហើយមិនមែនតែវិបាកក្នុងបច្ចុប្បន្នប៉ុណ្ណោះទេដែលផ្សេងគ្នា សូម្បីហេតុ **គឺសេចក្តីវិចិត្ររបស់ចិត្តដែលជាហេតុក្នុងបច្ចុប្បន្នជាតិនេះ ក៏នៅផ្សេងគ្នាទៀតធ្វើឱ្យវិបាក គឺផលខាងមុខដែលនឹងកើតឡើងនោះ ផ្សេងគ្នាតទៅទៀតដែរ ។** សេចក្តីវិចិត្រគឺសេចក្តីផ្សេងគ្នារបស់ចិត្តនោះ មិនមានទីបំផុតតាមសម្បយុត្តធម៌ គឺចេត-សិកដែលកើតរួមផង ដូច្នេះ ទើបគួរយល់សេចក្តីសំគាល់នៃសម្បយុត្តធម៌ ។ បរមត្ថធម៌មាន ៤ គឺ ចិត្តបរមត្ថ ១ ចេតសិកបរមត្ថ ១ រូបបរមត្ថ ១ និព្វានបរមត្ថ ១ ។ **ចិត្ត និងចេតសិក ជាសភាវធម៌ដែលកើតរួមគ្នា កើតព្រមជាមួយគ្នា ប្រាសចាកគ្នាមិនបាន បែកគ្នាមិនបាន កាលបើកើតឡើង**

ព្រមគ្នា ហើយក៏រលត់ព្រមគ្នា ដឹងអារម្មណ៍ជាមួយគ្នា អាស្រ័យវត្ថុរូប ជាមួយគ្នា (ក្នុងភូមិដែលមានខន្ធ ៥) នុ៎ះ គឺលក្ខណៈដែលជាសម្បយុត្តធម៌ ។

ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកំណ្ឌ មានសេចក្តីថា ប្រាកដណាស់ កាលបើរូបធម៌ និងអរូបធម៌កើតរួមគ្នា រូបរមែងកើតរួមជាមួយអរូប តែមិនទាក់ទង មិនសម្បយុត្តគ្នា អរូបក៏ដូចគ្នាគឺកើតរួមជាមួយរូប តែមិនទាក់ទង មិនសម្បយុត្តគ្នា ហើយរូបក៏កើតរួមជាមួយរូប តែមិនទាក់ទង មិនសម្បយុត្តគ្នាដែរ **ចំណែកអរូប ដោយនិយាមតែម្យ៉ាង កើតរួមជាមួយអរូប ទាក់ទង និងសម្បយុត្តតែម្យ៉ាង ។**

ដែលទ្រង់សម្តែងលក្ខណៈនៃសម្បយុត្តធម៌ទុកដោយល្អិតនោះ ក៏ដើម្បីប្រត្យក្សច្បាស់ពិត ។ ថា នាមធម៌មិនមែនរូបធម៌នោះឯង ។ ខណៈដែលសិក្សា និងស្តាប់ព្រះធម៌នោះ ជាសង្ខារក្ខន្ធ ដែលតាក់តែងសតិបញ្ញា សទ្ធឹម ។ ទម្រាំតែសតិប្បដ្ឋាននឹងកើតរលឹកពិចារណា ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌តែមួយលក្ខណៈ ។ រហូតដល់លក្ខណៈនៃនាមធម៌ និងរូបធម៌នឹងប្រាកដដោយសភាពដែលចែកដាច់អំពីគ្នា មិនសម្បយុត្តគ្នា ទោះជានឹងកើតរួមជាមួយគ្នាក៏ដោយ ។

ដូច្នេះ **សម្បយុត្តធម៌ទើបជាលក្ខណៈនៃនាមធម៌ គឺ ចិត្ត និងចេតសិក ដែលកើត រលត់រួមគ្នា និងដឹងអារម្មណ៍ជាមួយគ្នា ។**

នេះជាសេចក្តីផ្សេងគ្នារបស់នាមធម៌ និងរូបធម៌ ព្រោះថារូបធម៌កើតព្រមគ្នា រលត់ព្រមគ្នាពិត តែរូបធម៌មិនមែនជាសភាពដឹង រូបមិនដឹងអារម្មណ៍ឡើយ ។ រូបគ្រប់រូបដែលកើតរួមគ្នា ទើបមិនជាសម្បយុត្តធម៌ ព្រោះសភាវធម៌ដែលជាសម្បយុត្តធម៌នោះ ចាំបាច់ជាសភាវធម៌ដែលរួមគ្នាយ៉ាងស្និទ្ធ ដោយនាមធម៌ដែលជាធាតុដឹង ដែលកើតព្រមគ្នា រលត់ព្រមគ្នា ដឹងអារម្មណ៍ដូចគ្នា និងកើត រលត់កន្លែងជាមួយគ្នា ។

លក្ខណៈនៃចិត្តប្រការទី ៤ គឺចិត្តសូម្បីគ្រប់ដួងឈ្មោះថា « ចិត្ត » ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ដោយអំណាចនៃសម្បយុត្តធម៌ ។

ចេតសិកទាំងអស់មាន ៥២ ប្រភេទ **តែថាចិត្ត ១ ដួង ។ មិនបានប្រកបដោយចេតសិកព្រមគ្នាទាំង ៥២ ប្រភេទនោះទេ ទើបធ្វើឱ្យចិត្តផ្សេង ។ គ្នាទៅតាមចេតសិកដែលកើតរួម ដោយតិច ច្រើន ផ្សេង ។ គ្នា តាមចំនួននិងប្រភេទនៃចិត្តទាំងនោះ ។** ចិត្ត ៨៩ ដួង ដែលផ្សេងគ្នានោះ ចំណែកចេញជាប្រភេទនៃជាតិ គឺសភាពនៃចិត្តដែលកើតឡើងនោះផ្សេងគ្នាជា ៤ ជាតិ គឺជាកុសលចិត្ត ១ ជាអកុសលចិត្ត ១ ជាវិបាកចិត្ត ១ ជាកិរិយាចិត្ត ១ ។ ក្នុងមួយថ្ងៃ ។ នោះ មានកុសលចិត្តខ្លះ អកុសលចិត្តខ្លះ វិបាកចិត្តខ្លះ និងកិរិយាចិត្តខ្លះ ។ ចិត្តដែលចំណែកជាជាតិផ្សេង ។ នោះ ប្រព្រឹត្តទៅតាមសភាពនៃចិត្តមិនមែនជាជាតិវណ្ណៈ ដូចជាជាតិថៃ ជាតិខ្មែរ ឥណ្ឌា ចិននោះទេ តែសភាពចិត្តដែលជាកុសលនោះ មិនថានឹងកើតជាមួយអ្នកណាឡើយ ទីណាឡើយ ខណៈណាឡើយ ចិត្តក៏ជាកុសល ហើយចិត្តដែល

ជាអកុសលនោះ មិនថានឹងកើតជាមួយអ្នកណា និងជាសមណៈ ព្រាហ្មណ៍ ជាតិ ហានៈ វណ្ណៈ ពណ៌សម្បុរណាឡើយ ចិត្តដែលជាអកុសល ក៏ចាំបាច់ជាអកុសលផ្លាស់ប្តូរសភាពមិនបាននេះ គឺសភាពរបស់បរមត្ថ ។ កាលចិត្តប្រកបដោយសម្បយុត្តធម៌ គឺចេតសិកដែលជាអកុសល ចិត្តទើបជាអកុសល កាលចិត្តប្រកបដោយសោភណចេតសិក ចិត្តទើបជាកុសល ឬកុសលវិបាក ឬសោភណកិរិយា តាមជាតិរបស់ចិត្ត ។

ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ មានសេចក្តីដែរថា ព្រះមានព្រះភាគ កាលទ្រង់ចំណែកធម៌ជាផ្នែក ៗ ហើយទ្រង់លើកយកបញ្ញត្តិឡើងត្រាស់ ទ្រង់ធ្វើសភាវៈដែលធ្វើបានដោយលំបាក ។ ទឹក ឬប្រេងច្រើនបែបដែលហូរទៅស្រោចក្នុងភាជនៈតែមួយដូចគ្នា រហូតអស់ថ្ងៃ កាលបើពិនិត្យមើល ហិតក្លិន ឬលិឍរស ក៏អាចដឹងបានថាផ្សេងគ្នា ព្រោះពណ៌ ក្លិន និងរសផ្សេងគ្នា ទោះជាបានដឹងយ៉ាងនោះក៏ដោយ ការដូចនោះ លោកក៏ពោលថា ធ្វើបានដោយលំបាក ប៉ុន្តែព្រះសម្មាសម្ពុទ្ធទ្រង់ចំណែកធម៌ គឺចិត្ត និងចេតសិកក្នុងអារម្មណ៍ដូចគ្នា គឺរូបារម្មណ៍ តែមួយដូចគ្នាទាំងនេះចេញជាផ្នែក ៗ ហើយលើកយកបញ្ញត្តិឡើងត្រាស់ ឈ្មោះថាទ្រង់ធ្វើសភាវៈដែលធ្វើបានដោយលំបាកក្រៃលែងបំផុត ។

នាមធម៌ ជាសភាវៈដែលល្អិតក្រៃលែងជាងរូបដែលល្អិត តែសូម្បីយ៉ាងនោះក៏ដោយ ព្រះមានព្រះភាគក៏ទ្រង់ចំណែក លក្ខណៈរបស់នាមធម៌ តែមួយបែប ។ មួយប្រភេទ ។ ទុកដោយលក្ខណៈដែលប្រាកដដោយកិច្ច (រស) ដោយអាការដែលប្រាកដ (បច្ចុប្បដ្ឋានោ) និងដោយហេតុជិត (បទដ្ឋានោ) ឱ្យកើតនាមធម៌ប្រភេទនោះ ។ ។

ចិត្តជាធំ ជាប្រធានក្នុងការដឹង ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ ពោលថា ចិត្តជាភូមិ គឺជាទីកើតនៃសម្បយុត្តធម៌ ដូចសេចក្តីដឹងខ្លួនជាសុខ បើចិត្តមិនមានសេចក្តីដឹងខ្លួនជាសុខ ក៏នឹងមានមិនបាន ព្រោះមិនមានទីតាំង មិនមានទីកើតនៃសេចក្តីដឹងខ្លួនជាសុខ ប៉ុន្តែខណៈណាដែលសុខវេទនាកើត ខណៈនោះចិត្តជាភូមិ ជាទីតាំង ជាទីនៅអាស្រ័យសម្បយុត្ត គឺសុខវេទនា និងចេតសិកដទៃ ។ ។ ចិត្តចំណែកចេញជាជាតិមាន ៤ ជាតិ គឺកុសលចិត្ត អកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត មិនថានឹងពោលដល់ចិត្តអ្វី ចាំបាច់នឹងត្រូវដឹងថាចិត្តនោះ ។ ជាជាតិអ្វី គឺជាកុសល ឬ អកុសល វិបាក ឬ កិរិយា ។ សម្រាប់វិបាកចិត្ត ដែលជាផលរបស់កម្មនោះ **កាលកម្មមាន ២ ប្រភេទ គឺកុសលកម្ម ១ អកុសលកម្ម ១ វិបាកចិត្តក៏មាន ២ ប្រភេទ គឺកុសលវិបាកចិត្ត ១ និងអកុសលវិបាកចិត្ត ១ ។**

កាលណាពោលដល់ចិត្តដែលជាផលរបស់អកុសលកម្មនោះ ត្រូវប្រើពាក្យថា អកុសលវិបាកចិត្ត កុំពោលខ្លី ។ ថាអកុសល ព្រោះ

អកុសលវិបាកចិត្ត ជាផលរបស់អកុសលកម្ម និងកុសលវិបាកចិត្ត ជាផលរបស់កុសលកម្ម កុសលវិបាកចិត្តមិនមែនកុសលចិត្ត អកុសលវិបាកចិត្តមិនមែនអកុសលចិត្ត ហើយនិងចិត្តប្រភេទមួយទៀត គឺកិរិយាចិត្តនោះ មិនមែនជាកុសល មិនមែនអកុសល និងមិនមែនជាវិបាក ជាចិត្តដែលកើតឡើងព្រោះបច្ច័យដទៃ ដែលមិនមែនជាកម្មប្បច្ច័យ កិរិយាចិត្តមិនជាហេតុនឹងធ្វើឱ្យកើតវិបាកណា ។ ឡើយ កិរិយាចិត្តចំណែកច្រើនជាកិរិយាចិត្តរបស់ព្រះអរហន្ត ព្រះអរហន្តរំលត់អកុសលកម្ម និងកុសលកម្មទាំងអស់ ទើបគង់នៅមានតែវិបាកចិត្ត ដែលជាផលរបស់អតីតកម្ម និងកិរិយាចិត្តប៉ុណ្ណោះ ។

ក្រៅអំពីទ្រង់សម្តែងសភាពនៃចិត្ត និងចេតសិកដោយ ៤ ជាតិ គឺ **កុសល អកុសល វិបាក កិរិយា** ហើយព្រះមានព្រះភាគទ្រង់នៅចំណែកធម៌ដោយន័យដទៃ គឺដោយធម៌ពួក ៣ បានដល់

កុសលា ធម្មា ធម៌ដែលជាកុសល ១

អកុសលា ធម្មា ធម៌ដែលជាអកុសល ១

អព្យាកតា ធម្មា ធម៌ដែលជាអព្យាកត ១

អព្យាកតធម៌ គឺបរមត្ថធម៌ណា ។ ទាំងអស់ដែលមិនមែនជាកុសលធម៌ និងអកុសលធម៌ ដូច្នេះ កាលចំណែកចិត្ត និងចេតសិកដោយធម៌ ៣ ពួក គឺកុសលធម៌ អកុសលធម៌ និងអព្យាកតធម៌ ចិត្តនិងចេតសិកដែលជាអព្យាកតធម៌ បានដល់វិបាកចិត្ត និងវិបាកចេតសិក

កិរិយាចិត្ត និងកិរិយាចេតសិក ។ កាលបើចំណែក បរមត្ថធម៌ ៤ គឺ ចិត្ត ចេតសិក រូប និព្វាន ដោយប្រភេទនៃកុសលធម៌ អកុសលធម៌ និង អព្យាកតធម៌នោះ

កុសលចិត្តនិងចេតសិក	ជា	**កុសលធម៌**
អកុសលចិត្តនិងចេតសិក	ជា	**អកុសលធម៌**
វិបាកចិត្តនិងចេតសិក	ជា	**អព្យាកតធម៌**
កិរិយាចិត្តនិងចេតសិក	ជា	**អព្យាកតធម៌**
រូបទាំងអស់	ជា	**អព្យាកតធម៌**
និព្វាន	ជា	**អព្យាកតធម៌**

សំណួរសាឡើងវិញ

១ - រូបជាសម្បយុត្តធម៌ ជាមួយនឹងនាមបានឬទេ ?

២ - រូបជាសម្បយុត្តធម៌ ជាមួយនឹងរូបបានឬទេ ?

៣ - សភាវៈដែលប្រាកដផ្លូវភ្នែក ជាកុសលធម៌ ឬអព្យាកតធម៌ ព្រោះហេតុណា ?

៤ - ចិត្តឃើញជាកុសលធម៌ ឬអកុសលធម៌ ឬ អព្យាកតធម៌ ព្រោះហេតុណា ?

៥ - និព្វានជាកុសលធម៌មែនទេ ?

៦ - តើចិត្តប្រភេទណាមិនមានជាតិ ?

៧ - ចិត្តសម្បយុត្តធម៌ នឹងអ្វី ? ខណៈណា ?

៨ - ចិត្តដួងមួយជាសម្បយុត្តធម៌ ជាមួយនឹងដួងមួយទៀតបានទេ ?

៩ - អកុសលធម៌ ជាសម្បយុត្តធម៌ ជាមួយនឹងកុសលធម៌បានទេ ?

១០ - និព្វានសម្បយុត្តធម៌ ជាមួយនឹងអ្វី ?

មេរៀនទី ៩

ចិត្ត ៨៩ ដួង ដែលផ្សេងគ្នា ចំណែកដោយប្រភេទនៃភូមិ គឺលំដាប់ថ្នាក់នៃចិត្តជា ៤ ភូមិ គឺ

កាមាវចរភូមិ ១

រូបាវចរភូមិ ១

អរូបាវចរភូមិ ១

លោកុត្តរភូមិ ១

ចិត្តដែលជាកាមាវចរភូមិ បានដល់ កាមាវចរចិត្ត ៥៤ ដួង ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកំណ្ឌ អធិប្បាយអត្ថន័យរបស់កាមាវចរចិត្ត ជា ៤ ន័យ មានសេចក្តីថា

ន័យទី ១ បទថា កាមាវចរំ បានដល់ ចិត្ត ដែលរាប់បញ្ចូលក្នុងកាមាវចរធម៌ទាំងឡាយ គឺជាចិត្ត ដែលនៅក្នុងថ្នាក់នៃកាម (ពាក្យពេញសេចក្តី គឺកាមាវចរ តែកាត់បទក្រោយចេញសល់ត្រឹមតែកាមប៉ុណ្ណោះ) ដោយនៅប្រព្រឹត្តទៅក្នុងកាម គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ទើបជាចិត្តថ្នាក់កាម ជាកាមាវចរចិត្ត ។

គ្រប់ខណៈក្នុងជីវិតប្រចាំថ្ងៃជាកាមាវចរចិត្ត កាលបើមិនមែនជាចិត្តលំដាប់ដទៃដែលល្អិតជាង ប្រណីតជាងថ្នាក់កាម ពេលណាដែលអប់រំចម្រើនកុសលចិត្តដែលស្ងប់ឡើងដោយមានរូបជាអារម្មណ៍ រហូតដល់ចិត្ត

ស្ងប់ឥតកម្រើកឡើងដល់ថ្នាក់អប្បនាសមាធិជាឈានចិត្ត ដែលមានរូប ជាអារម្មណ៍ខណៈនោះ ក៏ជារូបាវចរភូមិ ឬរូបាវចរចិត្ត ផុតអំពីលំដាប់នៃកាម ។ ហើយពេលចិត្តស្ងប់មាំទាំក្រៃលែងជាងនោះទៅទៀត ដោយជាចិត្តដែលស្ងប់ដ៏ពិសេសក្នុងអារម្មណ៍ដែលផុតចាករូប ក៏ជាអរូបាវចរ-ចិត្ត ។ ហើយចិត្តដែលល្អិតប្រណីតជាងអរូបាវចរចិត្ត គឺលោកុត្តរចិត្តដែលប្រត្យក្សច្បាស់លក្ខណៈនៃព្រះនិព្វាន ទើបជាលោកុត្តរភូមិ ។ ដូច្នេះ ទើបចិត្តផ្សេងគ្នាដោយភូមិ គឺចិត្ត ៨៩ ដួង ចំណែកជា

កាមាវចរចិត្ត	៥៤ ដួង
រូបាវចរចិត្ត	១៥ ដួង
អរូបាវចរចិត្ត	១២ ដួង
លោកុត្តរចិត្ត	៨ ដួង

ខណៈណាដែលមិនមែនរូបាវចរចិត្ត អរូបាវចរចិត្ត លោកុត្តរចិត្ត ខណៈនោះ គឺជា កាមាវចរចិត្ត ។

ឈ្មោះថា **កាម** ព្រោះអត្ថថា ដែលសត្វស្រឡាញ់ត្រេកអរ ។ កាមមាន ២ យ៉ាង គឺកិលេសកាម ១ និងវត្ថុកាម ១ ។

កិលេសកាម បានដល់ឆន្ទរាគៈ គឺលោភចេតសិក ដែលជាសភាវធម៌ដែលត្រេកអរ ពេញចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ ។

វត្ថុកាម គឺសភាវធម៌ដែលជាទីតាំងនៃសេចក្តីត្រេកអរ ពេញចិត្ត សេចក្តីប្រាថ្នា ។ ដូច្នេះវត្ថុកាមបានដល់ វដ្ត ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣

គឺទាំងកាមភូមិ រូបភូមិ និងអរូបភូមិ ព្រោះមិនផុតអំពីវត្ថុដែលត្រេកអរ ពេញចិត្តរបស់កិលេសកាម ។ ដរាបណាដែលនៅពុំទាន់រំលត់លោភៈបាន គឺនៅមានវត្ថុកាម គឺសភាវធម៌ដែលជាទីត្រេកអរ ពេញចិត្ត នៃកិលេសកាម ។

កាមាវចរចិត្តដែលត្រេកអរពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះជាប់ណែន ស្និតស្អិតណាស់ សូម្បីថារូបនឹងប្រាកដត្រឹមតែ ១ ជួរខណៈដ៏ខ្លីហួសប្រមាណក៏ដោយ គឺត្រឹមតែជួរខណៈ ដែលប៉ះខ្ទប់ចក្ខុបសាទ គឺភ្នែក សំឡេងក៏ប្រាកដត្រឹមតែ ១ ជួរខណៈដ៏ខ្លីហួសប្រមាណដែរ គឺជួរខណៈខ្ទប់នឹងសោតបសាទ ក្លិន រស និង ផោដ្ឋព្វៈ ក៏ដូចតែគ្នា សុទ្ធតែជាបរិត្តធម៌ គឺជាសភាវធម៌ដែលប្រាកដត្រឹមតែបន្តិចបន្តួចដ៏ខ្លី ហើយក៏រលត់ទៅ តែចិត្តក៏ត្រេកអរ ពេញចិត្ត ជាប់ជំពាក់ក្នុងបរិត្តធម៌នោះនៅជានិច្ច ព្រោះការកើត រលត់បន្តគ្នាយ៉ាងរហ័សនៃបរិត្តធម៌នោះ ។ ទើបមើលទៅហាក់ដូចជាមិនរលត់ទៅ ។

សេចក្តីភ្លើតភ្លើន ត្រេកអរ ពេញចិត្ត ក្នុងកាមារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មិនចេះអស់ទេ សូម្បីតែថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះ ។ រលត់ទៅហើយក៏ដោយ តែរូប សំឡេង ក្លិន រស ផោដ្ឋព្វៈដទៃ ។ ក៏កើតបន្តធ្វើឱ្យវង្វេង ប្រកាន់ត្រេកអរ ពេញចិត្តក្នុងរូប សំឡេង ។ល។ បន្តគ្នានៅជារឿយ ។ ។ កាលបើឃើញរូបណាក៏ដោយ ដែលជាទីពេញចិត្ត ហើយក៏នឹងចង់តែឃើញ ញយ ។ ទៀត កាលបើឮសំឡេង

ដែលជាទីពេញចិត្តហើយ ក៏ចង់តែឮសំឡេងនោះទៀត ក្លិន រស ផោដ្ឋព្វៈ ក៏ដូចគ្នា កាលបើបរិភោគរសណាដែលពេញចិត្តហើយ ក៏ចង់តែបរិភោគរសនោះ តែដដែល ។ ទៀត ។ សេចក្តីត្រេកអរពេញចិត្ត ជាប់ជំពាក់ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កើតឡើងជាប្រចាំរាល់ ។ ថ្ងៃដដែលហើយ ដដែលទៀត តាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះឯង ។

កាលបើស្រឡាញ់ពេញចិត្តលើវត្ថុណាហើយ តើចង់នឹងឃើញវត្ថុនោះឱ្យនៅជារៀងរហូតគ្រប់ពេលបានឬទេ ? គឺមិនបានទេ ព្រោះសង្ខារធម៌ទាំងឡាយកើតឡើងហើយ ក៏រលត់ទៅវិញជាធម្មតា កាលបើរសឆ្ងាញ់កើតឡើងប្រាកដសេចក្តីពេញចិត្ត ក៏អាស្រ័យអណ្តាតកើតឡើង ខណៈនោះសេចក្តីពេញចិត្តតាមភ្នែក ត្រចៀក ច្រមុះ កាយមិនកើតឡើយ កាលបើកើតសេចក្តីពេញចិត្ត ក្នុងក្លិនដែលប្រាកដខណៈនោះ សេចក្តីពេញចិត្ត តាមភ្នែក ត្រចៀក អណ្តាត កាយក៏មិនកើតព្រោះចិត្តកើតឡើងតែ ១ ខណៈ ។ ប៉ុណ្ណោះនឹងមានចិត្ត ២ ដួងកើតឡើងព្រមគ្នាមិនបានឡើយ ។ គ្រប់បុគ្គលពេញចិត្តក្នុងសភាវៈផ្សេង ។ ដែលប្រាកដ ផ្លាស់ប្តូរគ្នាតាមផ្លូវភ្នែកខ្លះ ផ្លូវត្រចៀកខ្លះ ច្រមុះខ្លះ អណ្តាតខ្លះ កាយខ្លះ តាមផ្លូវចិត្តខ្លះ មិនមែនពេញចិត្តចំពោះតែពណ៌ម្យ៉ាង សំឡេងម្យ៉ាង ក្លិនម្យ៉ាង រសម្យ៉ាង និងផោដ្ឋព្វៈម្យ៉ាងប៉ុណ្ណោះទេ ទាំងនេះព្រោះសេចក្តីពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះ សន្សំបន្តនៅជារឿយ ។ តាំងតែអតីត បច្ចុប្បន្ន និងតទៅក្នុងអនាគត ។

ដូច្នេះ កាមាវចរចិត្ត គឺចិត្តថ្នាក់កាមដែលប្រព្រឹត្តទៅក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាចិត្តដែលត្រេកអរពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ លោកខ្លះក៏ប្រាប់ថា ធ្វើបុណ្យហើយចង់កើតក្នុងឋានសួគ៌ ឋានសួគ៌ក៏មិនផុតពីរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ តែជាកាមារម្មណ៍ប្រណីតជាងកាមារម្មណ៍ក្នុងលោកមនុស្ស ។

ដូច្នេះ តាំងតែពីកើតរហូតដល់ស្លាប់ ខណៈណាដែលចិត្តស្ងប់មិនដល់ថ្នាក់អប្បនាសមាធិ គឺមិនជាឈានចិត្ត និងមិនជាលោកុត្តរចិត្ត ខណៈនោះក៏ជាកាមាវចរចិត្ត ។ ខណៈបើកភ្នែក ហើយភ្ញាក់ ឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស នឹកគិតផ្សេង ។ នោះមិនមែនសត្វ បុគ្គល តួខ្លួនឡើយ តែជាចិត្តថ្នាក់កាម គឺកាមាវចរចិត្តទាំងអស់ ។

អ្នកដែលមិនមែនជាព្រះអនាគាមី និងព្រះអរហន្តនោះ នៅមានសេចក្តីពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ស្តែងថា សេចក្តីពេញចិត្តក្នុងកាមារម្មណ៍ដែលប្រាកដតាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះ លះបានដោយលំបាកយ៉ាងណា ? និងសូម្បីដល់ទៅថាអប់រំចម្រើនសេចក្តីស្ងប់ដល់ថ្នាក់ឈានចិត្ត ហើយកើតក្នុងព្រហ្មលោកក៏ដោយ ក៏នៅលះសេចក្តីពេញចិត្ត ត្រេកអរ ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មិនបានជាសមុច្ឆេទដែរ ។ កាលបើនៅមិនមែនជាព្រះអនាគាមិបុគ្គល ក៏នៅត្រឡប់មកដល់សេចក្តីជាយ៉ាងនេះទៀត គឺជាអ្នកត្រេកអរ

ពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ដូច្នេះ ទើបមិនគួរប្រមាទកិលេស ហើយនឹងត្រូវយល់នូវសភាវធម៌ត្រង់តាមសេចក្តីពិត តាមហេតុផល ទើបនឹងអាចអប់រំចម្រើនបញ្ញា ដែលរំលត់កិលេសបានដោយពិត ។ ជាសមុច្ឆេទ ។

បទថា **កាមាវចរំ** បានដល់ ចិត្តដែលរាប់បញ្ចូលក្នុងកាមាវចរធម៌ ។ សេចក្តីក្នុង អដ្ឋសាលិនី សម្តែងថា ភូមិរបស់កាមាវចរធម៌នោះ ខាងក្រោមតាំងតែអវីចីនរកឡើងមក ខាងលើតាំងពីជាន់ទេវតាបរនិម្មិតវសវត្តី ចុះមកភូមិទាំងនេះ ជាភូមិរបស់កាមារម្មណ៍ទាំងអស់ ។

ចំណែកពាក្យថា **វត្ថុកាម** នោះមានអត្ថន័យទូលំទូលាយជាងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ព្រោះនឹងមិនថាជាសភាវធម៌ណាទាំងអស់ កាលបើជាទីតាំងនៃសេចក្តីត្រេកអរ ពេញចិត្ត ក៏ជាវត្ថុកាម កាលបើកើតជាព្រហ្មបុគ្គលក្នុងរូបព្រហ្មភូមិ រូបព្រហ្មភូមិនោះ ក៏ជាវត្ថុកាម គឺជាទីតាំងនៃសេចក្តីត្រេកអរពេញចិត្តនៃរូបព្រហ្មបុគ្គលនោះ អ្នកដែលកើតក្នុងអរូបព្រហ្មភូមិ អរូបព្រហ្មភូមិក៏ជាវត្ថុកាម គឺជាទីតាំងនៃសេចក្តីត្រេកអរពេញចិត្តរបស់អរូបព្រហ្មបុគ្គលនោះ លោភចេតសិក ជាសភាវធម៌ដែលត្រេកអរ ពេញចិត្ត ជាប់ជំពាក់ក្នុងអារម្មណ៍គ្រប់យ៉ាង ក្រៅពីលោកុត្តរធម៌ប៉ុណ្ណោះ ។ ដូច្នេះ ក្រៅពីលោកុត្តរធម៌ហើយធម៌ដទៃ ។ ទើបជា **វត្ថុកាម គឺជាទីតាំងជាទីត្រេកអរពេញចិត្តនៃលោភៈបាន ។**

អត្ថន័យរបស់កាមាវចរចិត្តន័យទី ១ គឺជាចិត្តថ្នាក់កាមមិនផុតទៅអំពីកាម ។

ន័យទី ២ ជាចិត្តដែលប្រព្រឹត្តទៅក្នុងកាមភូមិ ១១ គឺអបាយភូមិ ៤ មនុស្ស ១ និងឋានសួគ៌ ៦ ជាន់ ។

ន័យទី ៣ ឈ្មោះថា កាមាវចរចិត្ត ព្រោះថារមែងប្រព្រឹត្តទៅដោយអំណាចការធ្វើឱ្យជាអារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ រមែងប្រព្រឹត្តទៅក្នុងចិត្តនោះ ។ ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍សូម្បីព្រោះហេតុនោះ ។ ក៏ឈ្មោះថា កាមាវចរ ។

បើនឹងឱ្យយល់បានងាយ គឺចិត្តណាក៏ដោយដែលប្រព្រឹត្តទៅ ទាក់ទងក្នុងកាម គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ ចិត្តនោះជាកាមាវចរ ។

សំណួរ តើព្រះអរហន្តមានកាមាវចរចិត្តទេ ?

ចម្លើយ មាន ពេលព្រះអរហន្តឃើញរូបារម្មណ៍ដែលប្រាកដតាមផ្លូវភ្នែក រូបារម្មណ៍ជាកាមារម្មណ៍ ចិត្តឃើញទើបជាកាមាវចរចិត្ត មិនថានឹងជាចិត្តរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ ឬព្រះអរហន្តសាវ័ក ឬក៏ចិត្តរបស់បុគ្គលណា ខណៈណា ។ ក៏ដោយ ដែលមានកាម គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ ចិត្តនោះ ជាកាមាវចរចិត្ត ។

ន័យទី ៤ ម៉្យាងទៀត ចិត្តណារមែងញុំាងបដិសន្ធិឱ្យប្រព្រឹត្តទៅក្នុងកាម ពោល គឺកាមភព (អបាយភូមិ ៤ មនុស្ស ១ សួគ៌ ៦) ហេតុនោះ ចិត្តនោះ ឈ្មោះថា កាមាវចរ ។

អស់លោកអ្នកដែលនៅក្នុងលោកមនុស្សនេះ ព្រោះកាមាវចរចិត្តធ្វើឱ្យកាមបដិសន្ធិចិត្ត កើតឡើងក្នុងភូមិមនុស្សដែលជាកាមភូមិ ។

អ្នកដែលចម្រើនសមថភាវនា ចិត្តស្ងប់ដល់ថ្នាក់អប្បនាសមាធិ ជារូបឈានចិត្ត ឬអរូបឈានចិត្ត បើឈានចិត្តមិនបាត់បង់ទេ និងឈានចិត្តកើតមុនចុតិចិត្ត ឈានកុសលចិត្តនោះ មិនជាបច្ច័យឱ្យកើតក្នុងលោកនេះទេ តែជាបច្ច័យឱ្យកើតក្នុងរូបព្រហ្មភូមិ ឬក្នុងអរូបព្រហ្មភូមិ តាមថ្នាក់នៃឈាននោះ ។ ។ ការកើតជាមនុស្សជាផលរបស់កាមាវចរកុសល គឺទាន សីល ការអប់រំចម្រើនសមថភាវនា ការអប់រំចម្រើនសតិប្បដ្ឋាន ដែលនៅមិនទាន់ផុតអំពីកាម ដូច្នេះ ទើបធ្វើឱ្យបដិសន្ធិក្នុងកាមភូមិ ។

ពាក្យថា **ភូមិ** មាន ២ អត្ថន័យ គឺសំដៅដល់ ចិត្តដែលជាភូមិរបស់សម្បយុត្តធម៌ **គឺចេតសិកធម៌ទាំងឡាយដែលកើតរួមគ្នា ១** និងសំដៅដល់ **ឱកាស គឺស្ថានទីកើតនៃសត្វលោក ១** ។ លោកមនុស្ស ជាភូមិគឺស្ថានទីកើតភូមិ ១ ក្នុងទីកើតទាំងអស់ ៣១ ភូមិ ។

កាលណាបើចិត្តផ្សេងគ្នាជាប្រភេទ ។ ហើយចិត្តតែមួយប្រភេទ ។ នោះ ក៏វិចិត្រផ្សេងគ្នាច្រើន ភូមិដែលជាទីកើតនៃសត្វលោក ក៏ផ្សេងគ្នា

មិនមែនមានតែមនុស្សភូមិ គឺលោកនេះមួយទេ ហើយសូម្បីនឹងថាជា កាមាវចរកុសល កម្លាំងនៃសទ្ធា បញ្ញា និងសម្បយុត្តធម៌ គឺចេតសិក ទាំងឡាយដែលកើតរួមផង ក្នុងខណៈនោះ ក៏ចិត្តផ្សេងគ្នាច្រើន ទើប ចំណែកឱ្យបានទទួលផល គឺកើតក្នុងសុគតិភូមិផ្សេង ។ មិនមែនតែក្នុង ភូមិមនុស្សប៉ុណ្ណោះទេ ។

សម្រាប់អកុសលកម្មក៏ដូចតែគ្នា ខណៈដែលធ្វើអកុសលកម្ម យ៉ាង ណាមួយនោះ បើសង្កេតនឹងដឹងសេចក្តីបែងចែកផ្សេងគ្នានៃអកុសលកម្ម ថា ធ្ងន់ស្រាលដោយអកុសលធម៌ត្រឹមណាហើយ គ្រាខ្លះក៏ប្រកបដោយ សេចក្តីព្យាបាទខ្លាំង គ្រាខ្លះក៏មិនមានសេចក្តីព្យាយាម មិនបានមានវីរិយៈ ឧស្សាហៈនឹងធ្វើអាក្រក់បៀតបៀនទេ គ្រាន់តែជាការប្រព្រឹត្តដែលប្រកប ដោយចេតនា ត្រឹមតែបន្តិចបន្តួចហើយសត្វតូចល្អិត ។ នោះក៏ស្លាប់ទៅ ។ កាលបើកម្មនីមួយ ។ ដែលបានធ្វើទៅនោះ ប្រកបដោយសម្បយុត្តធម៌ គឺចេតសិកថ្នាក់ផ្សេង ។ អកុសលកម្មនោះ ។ ក៏ជាបច្ច័យចំណែកឱ្យ អកុសលវិបាកចិត្ត ធ្វើកិច្ចបដិសន្ធិ គឺកើតក្នុងអបាយភូមិផ្សេង ។ ទាំង ៤ ភូមិ ។

កាលបើកុសលកម្ម និងអកុសលកម្ម ដែលជាហេតុនឹងឱ្យកើតផល វិចិត្រផ្សេង ។ គ្នា ភូមិដែលជាទីកើត ដ៏សមគួរដល់កម្មនោះ ។ ក៏រមែង ត្រូវមានច្រើនមិនបាន មានតែចំពោះមនុស្សភូមិ ១ កន្លែង ប៉ុណ្ណោះទេ ។

ពាក្យថា **ភូមិ** សំដៅដល់ឱកាសលោកដែលជាស្ថានទីកើតនៃសត្វលោកនោះមានទាំងអស់ ៣១ ភូមិ តាមលំដាប់ថ្នាក់នៃចិត្ត គឺកាមភូមិ ១១ រូបព្រហ្ម ១៦ ភូមិ អរូបព្រហ្ម ៤ ភូមិ រួមឱកាសលោក ដែលជាស្ថានទីកើតនៃសត្វលោកទាំងអស់ មាន ៣១ ភូមិ គឺ ៣១ លំដាប់ថ្នាក់ដែលស្ថានទីកើតថ្នាក់នីមួយ ៗ នោះ មានច្រើនជាងនោះ គឺសូម្បីតែភូមិរបស់មនុស្ស ក៏មិនបានមានតែលោកនេះមួយទេ នៅមានលោកមនុស្សដទៃ ៗ ទៀតដែរ ។

កាមភូមិ ១១ ភូមិនេះជាអបាយភូមិ ៤ មនុស្ស ១ និងសួគ៌ ៦ ដែលសូមពោលតែសង្ខេប ៗ គឺ

អបាយភូមិ ៤ បានដល់ នរក ១ ប្រេត ១ អសុរកាយ ១ សត្វតិរិច្ឆាន ១ ។

នរកមិនមែនមានត្រឹមតែមួយកន្លែង ឬ មួយក្រុមនោះទេ នរកក្រុមធំ ៗ មានច្រើនក្រុម ដូចសញ្ជីវនរក កាឡសុត្តនរក សង្ឃាតនរក រោរុវនរក មហារោរុវនរក តាបននរក មហាតាបននរក និងអវីចីនរក ។ ក្រៅពីនរកធំៗ ក៏នៅមាននរករាយរង ៗ ដែលក្នុងព្រះត្រៃបិដក ក៏មិនបានពោលដល់ដោយល្អិតល្អន់ដែរ ព្រោះបំណង ដែលព្រះមានព្រះភាគទ្រង់សម្តែងភូមិផ្សេង ៗ នោះ ក៏ដើម្បីទ្រង់សម្តែងឱ្យឃើញហេតុ និងផលនៃកុសលកម្ម និងអកុសលកម្ម ។ វត្ថុណាដែលមិនអាចនឹងឃើញប្រចក្សច្បាស់ ដោយ

ភ្នែក ក៏រមែងមិនជាវត្ថុដែលគួរសម្តែងស្មើនឹងសភាវធម៌ ដែលអាចនឹងពិសោធន៍ ដោយអប់រំចម្រើនបញ្ញាឱ្យដឹងបាន ។

កាលបើកើតក្នុងអបាយភូមិ ៤ នោះ បើជាផលរបស់អកុសលកម្មធ្ងន់ក៏កើតក្នុងនរក បើជាផលនៃអកុសលកម្មដែលធ្ងន់ខ្លាំងហួសពេកក៏កើតក្នុងមហានរកទីបំផុត គឺអវីចីនរក ហើយកាលបើផុតចាក ពពួកនរកក្រុមធំ ៗ ហើយ ក៏កើតក្នុងនរកក្រុមរាយរង ៗ ទៀត កាលបើនៅមិនអស់ផលរបស់អកុសលកម្ម ។ ខណៈដែលធ្វើអកុសលកម្មនោះមិនគិតឡើយថា ភូមិនរកនឹងរង់ចាំនៅខាងមុខ តែថានៅពុំទាន់ដល់ពេល ព្រោះថានៅរស់ក្នុងលោកនេះ ។ ដរាបណានៅមិនទាន់ផុតចាកសភាពនៃ ភាពជាបុគ្គលក្នុងលោកនេះ ក៏នៅមិនទាន់ទៅដល់ភូមិដទៃដែរ សូម្បីថាហេតុ គឺអកុសលកម្មមានហើយក៏ដោយ ។ កាលបើធ្វើអកុសលកម្មហើយ រមែងជាបច្ច័យឱ្យទៅដល់អបាយភូមិ ភូមិណាមួយ កាលបើអស់ជីវិតហើយ ។

ផលរបស់អកុសលកម្មដែលស្រាលជាងនោះ ក៏ជាបច្ច័យឱ្យកើតក្នុងអបាយភូមិឯទៀត ដូចកើតជាសត្វតិរច្ឆាន ដែលឃើញបានថា សត្វតិរច្ឆាននោះមានរូបរាងប្លែកផ្សេង ៗ បែបខ្លះមានជើងច្រើន បែបខ្លះមានជើងតិច បែបខ្លះមិនមានជើង មានស្លាបខ្លះ មិនមានស្លាបខ្លះ នៅក្នុងទឹកខ្លះ លើគោកខ្លះ មានរូបរាងលក្ខណៈផ្សេង ៗ សន្ធឹកសន្ធាប់ តាមសេចក្តីវិចិត្ររបស់ចិត្ត ។ មនុស្សមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ

តែពណ៌សម្បុរវណ្ណៈ ភាពខ្ពស់ទាបក៏នៅវិចិត្រផ្សេង ។ គ្នា មិនដូចគ្នាឡើយ មិនថាចំនួនមនុស្សក្នុងលោកនេះ ទោះបីសន្ធឹកសន្ធាប់ប៉ុណ្ណាក៏ដោយ រួមទាំងអតីត បច្ចុប្បន្ន និងអនាគតផង តែសត្វតិរច្ឆានក៏ក្រៃលែង វិចិត្រផ្សេងគ្នាកាន់តែខ្លាំងជាងមនុស្សទៅទៀត ទាំងសត្វទឹក ទាំងសត្វគោក និងសត្វដែលហើរបាន សុទ្ធតែរមែងប្រព្រឹត្តទៅតាមកម្ម ដែលជាហេតុឱ្យមានរូបរាងវិចិត្រនោះ ។ ។

ផលរបស់អកុសលកម្មដែលតិចជាងនោះ ជាបច្ច័យឱ្យកើតក្នុង ភូមិនៃប្រេត ដែលភាសាបាលីប្រើពាក្យថា បេតវិស័យ ទារុណកម្ម នៃប្រេត ដោយសេចក្តីស្រេកឃ្លាននៅជានិច្ច ហើយភូមិរបស់ប្រេតក៏វិចិត្រផ្សេង ។ គ្នាច្រើន ។

មនុស្សគ្រប់គ្នា មានរោគប្រចាំខ្លួន ប្រចាំថ្ងៃ គឺរោគឃ្លាន សឹងថានឹងមិនមានរោគមិនបាន ព្រោះសេចក្តីឃ្លានជារោគដ៏ក្រៃលែង ។ សាកល្បងឱ្យឃ្លានខ្លាំង ហើយប្រាកដជាដឹង បើមិនសូវឃ្លានទេ ហើយទទួលទានអាហារសឹងបើជាអាហារឆ្ងាញ់ ។ ក៏ភ្លេចសោះតែម្តងនូវការពិតនោះ ។ ការឃ្លានមិនមែនជាការសប្បាយកាយឡើយ ជាសភាវៈដែលត្រូវលែលកបន្ទូរបន្ថយឱ្យអស់ទៅ ។ បុគ្គលដែលឃ្លានខ្លាំង ពេលមិនបានទទួលទានអាហារ ប្រាកដជានឹងដឹងសភាពដែលជាសេចក្តីទុក្ខ នៃសេចក្តីឃ្លាន ថាបើឃ្លានខ្លាំង ។ ជាងនោះទៅទៀត តើនឹងជាយ៉ាងណា ។

លោកម្នាក់មានមិត្តសំឡាញ់ច្រើន ថ្ងៃមួយលោកទទួលទូរស័ព្ទ តាំងតែពីព្រឹករហូតដល់ល្ងាច មិនបានទទួលទានអាហារឡើយ ពេលយប់ក៏ជ្រុលដឹងថាសេចក្តីឃ្លានដ៏សែនលំបាក ដែលប្រើពាក្យថា ឈឺផ្សាពោះ ឬឈឺផ្សាពោះវៀននោះ ជាយ៉ាងណា ហើយលោកក៏មិនអាច ប្រញាប់ប្រញាល់ទទួលទានដើម្បីតែសម្រួលសេចក្តីស្រេកឃ្លានភ្លាម ។ បានដែរ ព្រោះបើធ្វើយ៉ាងនោះក៏នឹងទៅជាខ្យល់ ឬអន្តរាយដល់រាងកាយ លោកត្រូវ បរិភោគសន្សឹម ។ តែផ្សំសេចក្តីស្រេកឃ្លាននោះបន្តិចម្តង ។ តែទោះជា យ៉ាងនោះ ក៏នៅតែកើតខ្យល់ នេះគឺសម្តែងឱ្យឃើញថា សេចក្តី ស្រេកឃ្លានជារោគយ៉ាងក្រៃលែង ជារោគប្រចាំថ្ងៃ ដែលមិននិយាយដល់ រោគដទៃ ។ ។ ហើយបើជាយ៉ាងនេះ អ្នកដែលកើតជាប្រេត តើនឹង ស្រេកឃ្លានដល់កម្រិតណាទៅ ក្នុងភូមិប្រេតមិនមានការលក់ដូរជួញប្រែ មិនមានកសិកម្ម ភ្ជួររាស់ ដាំស្រូវធ្វើស្រែ ឬដាំស្ល ឬទិញដូរ ដោះដូរដោយ ប្រាក់អ្វីឡើយ ដើម្បីឱ្យបានអាហារបរិភោគក៏មិនបាន ។ ការកើតជាប្រេត នោះ ជាផលរបស់អកុសលកម្ម ប្រេតណាបានអនុមោទនាកុសលដែល បុគ្គលដទៃបានធ្វើហើយ ឧទ្ទិសទៅឱ្យ កុសលចិត្តដែលអនុមោទនានោះ ជាបច្ច័យឱ្យបានអាហារដែលសមគួរដល់ភូមិរបស់ខ្លួនបរិភោគ ឬអាចនឹង ផុតសភាពនៃប្រេតដោយចុតិហើយបដិសន្ធិក្នុងភូមិដទៃ កាលបើអស់ផល នៃកម្មដែលធ្វើឱ្យជាប្រេតតទៅទៀត ។

អបាយភូមិ ១ ទៀត **គឺអសុរកាយ** ។ ការកើតជាអសុរកាយ ជាផលរបស់អកុសលកម្មដែលស្រាលជាងអកុសលកម្មឯទៀត ព្រោះអ្នកកើតជាអសុរកាយនោះ មិនមានសេចក្តីសុខសប្បាយណា ។ ដូចជាក្នុងមនុស្សភូមិ និងឋានសួគ៌ទេ ។ ក្នុងភូមិមនុស្សមានសៀវភៅអាន មានកុនល្ខោនមើល មានភ្លេងតូរ្យតន្ត្រីផ្សេង ។ សម្រាប់មើល ស្តាប់ តែក្នុងអសុរកាយភូមិមិនអាចនឹងស្វែងរកសេចក្តីរីករាយក្សេមក្សាន្ត សប្បាយចិត្តបានដូចក្នុងសុគតិភូមិឡើយ ។

កាលបើអកុសលកម្មមានផ្សេងគ្នា ភូមិដែលជាទីកើត ក៏រមែងផ្សេងគ្នាទៅតាមហេតុ និងអកុសលកម្មនោះ ។ ។

សម្រាប់ភូមិដែលជាផលរបស់កាមាវចរកុសលមាន ៧ ភូមិ មនុស្ស ១ ភូមិសួគ៌ ៦ ភូមិ ។

ក្នុងព្រះត្រៃបិដក សម្តែងភូមិដែលកើតនៃមនុស្សថា **មនុស្សភូមិ** គឺដែលកើតនៃមនុស្សនោះ មាន ៤ ទ្វីប គឺ

១ បុព្វវិទេហទ្វីប នៅទិសខាងកើតនៃភ្នំសិនេរុ

២ អមរគោយានីទ្វីប នៅទិសខាងលិចនៃភ្នំសិនេរុ

៣ ជម្ពូទ្វីប (**គឺលោកនេះ**) នៅទិសខាងត្បូងនៃភ្នំសិនេរុ

៤ ឧត្តរកុរុទ្វីប នៅទិសខាងជើងនៃភ្នំសិនេរុ

អ្នកដែលកើតនៅក្នុងលោកនេះ ដែលជាជម្ពូទ្វីប ក៏ឃើញតែជម្ពូទ្វីប មិនថានឹងធ្វើដំណើរឆ្ពោះទៅទីណា ក៏ឃើញតែអារម្មណ៍ផ្សេង ៗ នៃជម្ពូ

ទ្វីបតែប៉ុណ្ណោះ នៅមិនអាចនឹងទៅដល់ទ្វីបដទៃដែលជាលោកនៃមនុស្ស ៣ លោកដទៃទៀតបានឡើយ ។

សួគ៌មាន ៦ ភូមិ តាមលំដាប់គឺ

សួគ៌ភូមិទី ១ គឺចាតុម្មហារាជិកា មានទេវតាដែលជាធំ ៤ អង្គ គឺ

ទេវភាធតរដ្ឋ ជាប្រធានទេវតា ទិសខាងកើត គ្រាខ្លះមានឈ្មោះថា ឥន្ទ ជាអ្នកគ្រប់គ្រងគន្ធព្វទេវតា (គន្ធព្វ)

ទេវតាវិរុឡ្ហក ជាប្រធានទេវតាទិសខាងត្បូង គ្រាខ្លះមានឈ្មោះថា យមៈ ជាអ្នកគ្រប់គ្រងកុម្ភ័ណ្ឌទេវតា

ទេវតាវិរូបក្ខ ជាប្រធានទេវតាទិសខាងលិច គ្រាខ្លះមានឈ្មោះថា ទេវតាវរុណ ជាអ្នកគ្រប់គ្រងនាគទេវតា

ទេវតាកុវេរៈ ជាប្រធានទេវតាទិសខាងជើង គ្រាខ្លះមានឈ្មោះថា វេស្សវ័ណ ជាអ្នកគ្រប់គ្រងយក្ស

ឋានសួគ៌ជាន់ចាតុម្មហារាជិកា ជាសួគ៌ជាន់ខាងដើមដែលមិនឆ្ងាយពីភូមិមនុស្ស ឋានសួគ៌ដែលជាភូមិនៃទេវតានោះ ខ្ពស់ឡើង ៗ តាមលំដាប់ថ្នាក់នៃសេចក្តីប្រណីតនៃសួគ៌ ។

ឋានសួគ៌ភូមិទី ២ គឺតាវតឹង្ស នៅខ្ពស់ជាងសួគ៌ជាន់ចាតុ-ម្មហារាជិកា មានព្រះឥន្ទជាស្តេចនៃទេវតា ។ អស់លោកគង់បាន ឮឈ្មោះសួគ៌ឧទ្យានក្នុងជាន់តាវតឹង្សជាញយ ៗ ។ សួគ៌ឧទ្យានក្នុងជាន់តាវតឹង្ស មាន ៤ គឺឧទ្យាននន្ទវ័ន នៅទិសខាងកើត ឧទ្យានចិត្រលតាវ័ន

នៅទិសខាងលិច ឧទ្យានមិស្សកវ័ន នៅទិសខាងជើង ឧទ្យានជារុសកវ័ន នៅទិសខាងត្បូង ។

សួគ៌ភូមិទី ៣ គឺយាមា

នៅខ្ពស់ជាងសួគ៌ជាន់តាវតឹង្ស

សួគ៌ភូមិទី ៤ គឺតុសិត

នៅខ្ពស់ជាងសួគ៌ជាន់យាមា

សួគ៌ភូមិទី ៥ គឺនិម្មានរតី

នៅខ្ពស់ជាងសួគ៌តុសិត

សួគ៌ភូមិទី ៦ គឺបរនិម្មិតវសវត្តី

នៅខ្ពស់ជាងសួគ៌ជាន់និម្មានរតី ។

នរណាចង់នៅសួគ៌ជាន់ណា កាលបើមិនមែនព្រះអរហន្ត ក៏ត្រូវនៅកើតទៀត តែនឹងកើតទីណាក៏គង់មិនដល់ព្រហ្មភូមិ ព្រោះការដែលនឹងកើតជាព្រហ្មបុគ្គលក្នុងព្រហ្មភូមិបាននោះ គឺជាផលរបស់ឈានកុសលដែលមិនសាបសូន្យ តាមដែលបានពោលហើយ ដូច្នេះ គឺត្រូវនឹងកើតក្នុងកាមភូមិនៃភូមិណាមួយ ជួនកាលជាអបាយភូមិ ឬសុគតិភូមិដោយសមតាមហេតុ គឺកម្មមួយដែលបានធ្វើហើយក្នុងសង្សារវដ្ត ។

រូបាវចរភូមិដែលជាទីកើតនៃរូបព្រហ្មបុគ្គលមាន ១៦ ភូមិ គឺ

បឋមជ្ឈានភូមិមាន ៣ ភូមិ គឺ

បារិសជ្ជាភូមិ ១ ជាទីកើតនៃអ្នកដែលសម្រេចបឋមជ្ឈានកុសលដែលមានកម្លាំងខ្សោយ

បុរោហិតាភូមិ ១ ជាទីកើតនៃអ្នកដែលសម្រេចបឋមជ្ឈានកុសលចិត្តដែលមានកម្លាំងមធ្យម

មហាព្រហ្មាភូមិ ១ ជាទីកើតនៃអ្នកដែលសម្រេចបឋមជ្ឈានកុសលចិត្តដែលមានកម្លាំងប្រណីត

ទុតិយជ្ឈានភូមិមាន ៣ ភូមិ ជាទីកើតនៃអ្នកដែលសម្រេចទុតិយជ្ឈានដោយចតុក្កន័យ និងតតិយជ្ឈានដោយបញ្ចកន័យ គឺ

បរិត្តាភាភូមិ ១

អប្បមាណាភូមិ ១

អាភស្សរាភូមិ ១

តតិយជ្ឈានភូមិមាន ៣ ភូមិ ជាទីកើតនៃអ្នកដែលសម្រេចតតិយជ្ឈានដោយចតុក្កន័យ និងចតុត្ថជ្ឈានដោយបញ្ចកន័យ គឺ

បរិត្តសុភាភូមិ ១

អប្បមាណសុភាភូមិ ១

សុភកីណ្ណាភូមិ ១

ចតុត្ថជ្ឈានភូមិមាន ៧ ភូមិ គឺ

វេហប្ផលាភូមិ ១ ជាទីកើតនៃអ្នកដែលសម្រេចចតុត្ថជ្ឈាន ដោយចតុក្កន័យ និងបញ្ចមជ្ឈាន ដោយបញ្ចកន័យ

អសញ្ញាសត្តាភូមិ ១ ជាទីកើតនៃអ្នកដែលសម្រេច បញ្ចមជ្ឈាន ដែលមានតែរូបបដិសន្ធិ មិនមានចិត្ត និងចេតសិកកើតឡើយ ។

អវេហាភូមិ ១
អតប្បាភូមិ ១
សុទស្សាភូមិ ១
សុទស្សីភូមិ ១
អកនិដ្ឋានភូមិ ១

សុទ្ធាវាស ៥ ភូមិជាទីកើតនៃព្រះអានាគាមិបុគ្គលអ្នកបានចតុត្ថជ្ឈានដោយចតុក្កន័យ ឬ បញ្ចមជ្ឈានដោយបញ្ចកន័យ

អរូបព្រហ្មភូមិមាន ៤ ភូមិ ជាភូមិដែលកើតនៃអ្នកសម្រេចអរូបជ្ឈាន (បញ្ចមជ្ឈានដែលកន្លងនូវរូបហើយមានអរូបជាអារម្មណ៍) តាមលំដាប់ថ្នាក់ គឺ

អាកាសានញ្ចាយតនភូមិ ១
វិញ្ញាណញ្ចាយតនភូមិ ១
អាកិញ្ញាយតនភូមិ ១
នេវសញ្ញានាសញ្ញាយតនភូមិ ១

ក្នុងអរូបព្រហ្ម ៤ ភូមិនេះ មានតែនាមខន្ធ គឺចិត្ត និងចេតសិក មិនមានរូបណា ៗ កើតឡើយ ។

ក្នុងអង្គុត្តរនិកាយ តិកនិបាត ចូឡនីសូត្រ ព្រះមានព្រះភាគទ្រង់បានសម្តែងរឿងរបស់លោក និងចក្រវាឡទុក សូម្បីនឹងថាមិនមែន ដោយល្អិតដូចដែលលោកអ្នកខ្លះសង្ស័យចង់ដឹង ប៉ុន្តែក៏សម្តែងឱ្យឃើញបញ្ញាបារមី នៃព្រះមានព្រះភាគ ព្រះអង្គជាលោកវិទូ គឺព្រះអង្គដឹងច្បាស់នូវលោកទាំងអស់ ។

លក្ខណៈនៃចិត្តប្រការទី ៤ គឺប្រការមួយទៀតចិត្តសូម្បីគ្រប់ដួងឈ្មោះថាចិត្ត ព្រោះជាធម្មជាតិវិចិត្រតាមសមគួរ ដោយអំណាចនៃសម្បយុត្តធម៌ (ចេតសិកដែលកើតរួមផង) ធ្វើឱ្យចំណែកចិត្តចេញជាប្រភេទផ្សេង ។ បានច្រើនន័យដោយ ៤ ជាតិ បានដល់ជាកុសល ១ អកុសល ១ វិបាក ១ កិរិយា ១ ដោយភូមិ ៤ គឺកាមាវចរចិត្ត រូបាវចរចិត្ត អរូបាវចរចិត្ត លោកុត្តរចិត្ត ។

កាមាវចរចិត្តមានទាំង ៤ ជាតិ គឺជាអកុសលក៏មាន ជាកុសលក៏មាន ជាវិបាកក៏មាន ជាកិរិយាក៏មាន ក្រៅអំពីកាមាវចរចិត្តហើយ លំដាប់ចិត្តដែលខ្ពស់ជាងនោះ មិនមែនជាអកុសលទេ គឺរូបាវចរចិត្តដែលជាអកុសលមិនមាន អរូបាវចរចិត្តដែលជាអកុសលមិនមាន លោកុត្តរចិត្តដែលជាអកុសលមិនមាន (និងជាកិរិយាមិនមាន) ។

ដូច្នេះ **រូបាវចរចិត្ត ទើបមាន ៣ ជាតិ គឺ កុសល វិបាក កិរិយា** ។ រូបាវចរកុសលចិត្ត ជាហេតុឱ្យរូបាវចរវិបាកចិត្តធ្វើកិច្ចបដិសន្ធិជាព្រហ្មបុគ្គលក្នុងព្រហ្មលោក ភូមិណាមួយក្នុងរូបព្រហ្ម ១៥ ភូមិ និង

រូបាវចរបញ្ចមជ្ឈានជាបច្ច័យឱ្យរូបបដិសន្ធិ ជាអសញ្ញសត្តាព្រហ្មបុគ្គល ក្នុងអសញ្ញសត្តាព្រហ្មភូមិ ១ ភូមិ រូបាវចរកិរិយាជាកិរិយាចិត្តនៃព្រះអរហន្ត ខណៈដែលជារូបជ្ឈានចិត្តថ្នាក់ផ្សេង ៗ ។

អរូបាវចរចិត្តក៏មាន ៣ ជាតិ គឺ កុសល វិបាក កិរិយា ដោយន័យដូចគ្នា ។

រូបាវចរចិត្ត និងអរូបាវចរចិត្ត ជាមហគ្គតចិត្ត ។ សេចក្តីក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ អធិប្បាយអត្ថន័យនៃ **មហគ្គត ថា ឈ្មោះថាមហគ្គត ព្រោះបានសេចក្តីថាសភាវៈជាធំ ព្រោះអាចសង្កត់សង្កិនកិលេសបានព្រោះមានផលដ៏ឧត្តមសម្បូរ ។**

កិលេសជាសភាវៈដែលសង្កត់សង្កិនមិនបានងាយ ។ នោះឡើយ ព្រោះពេលឃើញក៏កើតសេចក្តីពេញចិត្ត ឬមិនពេញចិត្ត ប៉ុន្តែក្នុងខណៈដែលចិត្តជាអប្បនាសមាធិ ជាឈានចិត្តនោះ ចិត្តស្ងប់ តាំងណែនមាំ ក្នុងអារម្មណ៍តាមមនោទ្វារ មិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងផោដ្ឋព្វៈឡើយ ។ **ខណៈដែលជាឈានចិត្ត មិនថាជារយៈពេលវែលាយូរប៉ុណ្ណាទេ ភវង្គចិត្តនឹងមិនកើតខណ្ឌជ្រែកបានឡើយ មិនដូចជាពេលវេលាដែលជាកាមាវចរចិត្តសឹងជាខណៈដែលបន្តិចបន្តួច ហើយដ៏ខ្លីបំផុត ជាបរិត្តធម៌នោះទេ** ព្រោះឃើញជួរវារៈខ្លី ៗ ឮជួរវារៈខ្លី ៗ នឹកគិតជួរវារៈខ្លី ៗ ។ ខណៈដែលជាកាមាវចរចិត្តនោះ ដឹងអារម្មណ៍ ១ ជួរវារៈ ៗ ដែលខ្លី ៗ ប្រាកដ ពេលចក្ខុទ្វារវិថីចិត្តកើតឡើងដឹងរូបារម្មណ៍

គឺសភាវៈដែលប្រាកដតាមភ្នែក រលត់ទៅភវង្គចិត្តក៏ត្រូវកើតទាន់ពេលភ្លាម មុនដែលមនោទ្វារវិថីចិត្ត នឹងទទួលដឹងសភាវៈដែលប្រាកដតាមភ្នែកតពី ចក្ខុទ្វារវិថីចិត្ត កាមាវចរធម៌ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ទើបជា បរិត្ត-ធម៌ ប៉ុន្តែមហគ្គតចិត្តដែលបានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្តនោះ ដល់នូវសេចក្តីជាភាវៈដ៏ធំ ព្រោះអាចសង្កត់កិលេសបាន ទើបជា មហគ្គតចិត្ត ។

ខណៈដែលជាអប្បនាសមាធិ គឺឈានចិត្តកើតរលត់បន្តគ្នានោះ មិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងផោដ្ឋព្វៈ តាមភ្នែក ច្រមុះ អណ្តាត កាយ និងនឹកគិតរឿងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ណា ។ ឡើយ ទើបឈ្មោះថាអាចសង្កត់កិលេសបាន តែពេលឈានចិត្តរលត់អស់ហើយ កាមាវចរចិត្តក៏កើតត ។ ពេលវិថីចិត្តកើតឡើងតាមទ្វារផ្សេង ។ អកុសល ជវនក៏កើតបាន បើមិនមែនកុសល ព្រោះកាលនៅមិនបានរលត់កិលេស ជាសមុច្ឆេទ លុះពេលបានឃើញហើយ អកុសលចិត្តក៏កើតឡើង ពេល ឮហើយអកុសលចិត្តក៏កើត ពេលកាយប៉ះខ្លប់សម្ផស្ស ហើយអកុសល ចិត្តក៏កើត ។ មាននរណាដឹងខ្លះទេថា អកុសលចិត្តនៅកើតរឿយ ។ កាលបើមិនដឹងក៏មិនបានសង្កត់ និងមិនបានអប់រំចម្រើនផ្លូវដែលនឹងរំលត់ កិលេស ។

កាលមុនការត្រាស់ដឹង របស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធជាម្ចាស់ អ្នកដែលឃើញទោសរបស់អកុសលចិត្ត ដែលកើតបន្តពីឃើញ ឮ ធុំក្លិន

ដឹងរស ដឹងផោដ្ឋព្វៈ ក៏បានព្យាយាម រកផ្លូវដែលនឹងសង្កត់កិលេស ហើយដឹងថាផ្លូវមួយដែលនឹងសង្កត់កិលេសបាន គឺត្រូវមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស និងមិនដឹងផោដ្ឋព្វៈ ព្រោះបើឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ក៏ហាមកិលេសមិនបាន ។ ពេលដឹងយ៉ាងនេះ ទើបអប់រំចម្រើនកុសលចិត្ត ដែលធ្វើឱ្យស្ងប់ចាក **លោភៈ ទោសៈ មោហៈ** រហូតដល់បានអប្បនាសមាធិដែលមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងផោដ្ឋព្វៈ ណា ។ ឡើយ ក្រៅពីអារម្មណ៍ដែលធ្វើឱ្យកុសលចិត្តស្ងប់តាំងមាំណែន តាមផ្លូវចិត្តត្រឹមតែអារម្មណ៍ម៉្យាងប៉ុណ្ណោះ អប្បនាសមាធិដែលជាឈានចិត្តនោះ មិនមែនគន្លងផ្លូវ ដែលនឹងរំលត់កិលេសទេ ព្រោះកាល ឈានចិត្តមិនកើត កិលេសក៏កើត ។ ជួរខណៈដែលជារូបាវចរចិត្ត និងអរូបាវចរចិត្តនោះ ជាសភាវៈដ៏ធំជាមហគ្គត ព្រោះសង្កត់កិលេសបាន ដោយមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ។ មិនដូចជាព្រះអនាគាមិបុគ្គល ដែលឃើញតែរំលត់សេចក្តីត្រេកអរពេញចិត្តក្នុងរូប បានឮ តែរំលត់សេចក្តីពេញចិត្តត្រេកអរក្នុងសំឡេង ដឹងក្លិន តែរំលត់សេចក្តីពេញចិត្តត្រេកអរក្នុងក្លិន ដឹងរស តែរំលត់សេចក្តីត្រេកអរពេញចិត្តក្នុងរស ប៉ះខ្ទប់សម្ផស្ស តែរំលត់សេចក្តីត្រេកអរពេញចិត្តក្នុងត្រជាក់ ក្តៅ រឹង ទន់ តឹង កម្រើក ញ័រ ដែលប្រាកដ ដូច្នេះ ចិត្តទើបផ្សេងគ្នាជា ៤ ភូមិ គឺ ៤ លំដាប់ថ្នាក់ ។

រូបាវចរចិត្ត និងអរូបាវចរចិត្ត មាន ៣ ជាតិ គឺកុសល ១ វិបាក ១ កិរិយា ១ ។

លោកុត្តរចិត្តមាន ២ ជាតិ គឺជាលោកុត្តរកុសល ១ ប្រភេទ ជាលោកុត្តរវិបាក ១ ប្រភេទ មិនមានលោកុត្តរកិរិយាចិត្ត ។

លោកុត្តរចិត្តមាន ៨ ដួងគឺ

សោតាបត្តិមគ្គចិត្តជាលោកុត្តរកុសល
សោតាបត្តិផលចិត្តជាលោកុត្តរវិបាក

សកទាគាមិមគ្គចិត្តជាលោកុត្តរកុសល
សកទាគាមិផលចិត្តជាលោកុត្តរវិបាក

អនាគាមិមគ្គចិត្តជាលោកុត្តរកុសល
អនាគាមិផលចិត្តជាលោកុត្តរវិបាក

អរហត្តមគ្គចិត្តជាលោកុត្តរកុសល
អរហត្តផលចិត្តជាលោកុត្តរវិបាក

លោកុត្តរកុសលចិត្ត ជាបច្ច័យឱ្យកើតលោកុត្តរវិបាកចិត្តបន្តភ្លាម មិនមានចិត្ត ដទៃកើតខណ្ឌរាំងបានឡើយ ។ កុសលដទៃទាំងអស់ មិនអាច នឹងឱ្យផលទាន់ពេលគឺ មិនធ្វើឱ្យវិបាកចិត្ត កើតបន្តពីកុសលចិត្ត បានទាន់ពេលភ្លាមឡើយ ប៉ុន្តែលោកុត្តរកុសលជាបច្ច័យឱ្យលោកុត្តរវិបាក កើតបន្តភ្លាម ដោយមិនមានចិត្តដទៃខណ្ឌរាំងរវាងលោកុត្តរកុសលចិត្ត ដែលជាហេតុ និងលោកុត្តរវិបាកចិត្តដែលជាផលឡើយ ។ ភ្លាមដែលសោតាបត្តិមគ្គចិត្ត ដែលជាលោកុត្តរកុសលរលត់ សោតាបត្តិផលចិត្ត ដែលជាលោកុត្តរវិបាក ក៏កើតបន្តភ្លាម ។ ភ្លាមដែលសកទាគាមិមគ្គចិត្ត ដែលជាលោកុត្តរកុសលរលត់ សកទាគាមិផលចិត្ត ដែលជាលោកុត្តរវិបាក ក៏កើតបន្តភ្លាម ។ ភ្លាមដែលអនាគាមិមគ្គចិត្ត ដែលជាលោកុត្តរកុសលរលត់ អនាគាមិផលចិត្ត ដែលជាលោកុត្តរវិបាក ក៏កើតបន្តភ្លាម ។ ភ្លាមដែលអរហត្តមគ្គចិត្ត ដែលជាលោកុត្តរកុសលរលត់ អរហត្តផលចិត្ត ដែលជាលោកុត្តរវិបាក ក៏កើតបន្តភ្លាម។

ដូច្នេះ លោកុត្តរវិបាកចិត្តទាំង ៤ ទើបមិនបានធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច មិនដូចលោកិយកុសលវិបាក និងអកុសលវិបាកទេ ។ កាលលោកុត្តរកុសលចិត្តរលត់ លោកុត្តរវិបាកចិត្ត ក៏កើតឡើង មាននិព្វាន ជាអារម្មណ៍ តពីលោកុត្តរកុសលភ្លាម ដូច្នេះ ផលចិត្ត ដែលជាលោកុត្តរ វិបាកចិត្តនោះ ទើបជាជវនវិថីចិត្ត ដូចនឹងលោកុត្តរកុសលចិត្ត **ផលចិត្តជា**

វិបាកចិត្ត ១ ប្រភេទប៉ុណ្ណោះ ដែលជាជវនវិថីចិត្តធ្វើជវនកិច្ច និងមាន និព្វានជាអារម្មណ៍ ។ លោកុត្តរកុសលចិត្តកើតឡើងត្រឹមតែ ១ ខណៈ ក្នុងសង្សារវដ្ត ដោយរំលត់កិលេសជាសមុច្ឆេទ តាមលំដាប់នៃលោកុត្តរ កុសលចិត្តនោះ ។ តែលោកុត្តរវិបាកចិត្ត ដែលកើតបន្តពីលោកុត្តរកុសល ចិត្តនោះ កើតរលត់បន្តគ្នាដោយមាននិព្វានជាអារម្មណ៍ ២ ឬ ៣ ខណៈ តាមប្រភេទនៃបុគ្គល ។

ព្រះសោតាបន្នបុគ្គលនៅកើតទៀតយ៉ាងច្រើនមិនហួស ៧ ជាតិ តែបដិសន្ធិចិត្ត របស់ព្រះសោតាបន្នមិនមែនសោតាបត្តិផលចិត្ត ធ្វើ បដិសន្ធិកិច្ចស្រេចតែថា ព្រះសោតាបន្នបុគ្គលនោះ នឹងកើតក្នុងភូមិណា វិបាកចិត្តកម្រិតលំដាប់ភូមិនោះ ។ ក៏ធ្វើកិច្ចបដិសន្ធិក្នុងភូមិនោះ គឺបើព្រះ សោតាបន្នបុគ្គលនោះ កើតក្នុងសួគ៌ កាមាវចរវិបាកចិត្តក៏ធ្វើកិច្ចបដិសន្ធិ បើព្រះសោតាបន្ន បុគ្គលនោះកើតក្នុងព្រហ្មភូមិណា រូបាវចរវិបាកចិត្ត ឬ អរូបាវចរវិបាកចិត្តក៏ធ្វើកិច្ចបដិសន្ធិក្នុងភូមិនោះ ។ ។

ដូច្នេះ ពាក្យថាភូមិមាន ២ ន័យ គឺសំដៅដល់លំដាប់ថ្នាក់នៃចិត្ត ១ និងសំដៅដល់ភូមិ ដែលជាទីកើតនៃសត្វលោក ១ ។

ភូមិដែលជាលំដាប់ថ្នាក់របស់ចិត្តមាន ៤ ភូមិ គឺ

កាមាវចរចិត្ត	១
រូបាវចរចិត្ត	១
អរូបាវចរចិត្ត	១

លោកុត្តរចិត្ត	១

ភូមិដែលជាទីកើតនៃសត្វលោក សំដៅដល់ឱកាសលោកដែលជាស្ថានទីកើតរបស់សត្វលោកមាន ៣១ ភូមិ តាមលំដាប់ថ្នាក់នៃចិត្ត គឺ

កាមភូមិ	១១ ភូមិ
រូបព្រហ្មភូមិ	១៦ ភូមិ
អរូបព្រហ្មភូមិ	៤ ភូមិ

សំណួរសាឡើងវិញ

១- តើកិលេសកាម និងវត្ថុកាមផ្សេងគ្នាយ៉ាងណា ?

២- តើបរិត្តធម៌ គឺអ្វី ?

៣- តើព្រះពុទ្ធជាម្ចាស់ មានកាមាវចរចិត្ត ឬទេ ?

៤- តើពាក្យថាភូមិសំដៅដល់អ្វីខ្លះ ?

៥- តើសុទ្ធាវាសភូមិ គឺអ្វី ? អ្នកណាកើតក្នុងសុទ្ធាវាសភូមិបាន ?

៦- តើរូបាវចរចិត្ត និងអរូបាវចរចិត្ត មានប៉ុន្មានជាតិ ?

៧- តើលោកុត្តរចិត្តមានប៉ុន្មានជាតិ ?

៨- តើមហគ្គតចិត្ត បានដល់ចិត្តអ្វី ?

៩- តើលោកុត្តរចិត្ត ជាវិថីចិត្តអ្វី ?

១0- តើលោកុត្តរចិត្ត ធ្វើកិច្ចអ្វី ?

មេរៀនទី ១០

ចិត្តផ្សេងគ្នាដោយសម្បយុត្តធម៌ គឺចេតសិកដែលកើតរួមផង **ទើបចំណែកចិត្តដោយ ន័យ នៃវេទនាភេទ** គឺដោយប្រភេទនៃវេទនាចេតសិកដែលកើតរួមជាមួយ ផ្សេងគ្នា គឺ

សោមនស្សសហគតំ ចិត្តកើតរួមនឹងសោមនស្សវេទនាចេតសិក (សេចក្តីដឹងខ្លួនសប្បាយចិត្ត)

ទោមនស្សសហគតំ ចិត្តកើតរួមនឹងទោមនស្សវេទនាចេតសិក (សេចក្តីដឹងខ្លួនខូចចិត្ត)

ឧបេក្ខាសហគតំ ចិត្តកើតរួមនឹងឧបេក្ខាវេទនាចេតសិក (សេចក្តីដឹងខ្លួនមិនសុខមិនទុក្ខ)

សុខសហគតំ ចិត្តកើតរួមនឹងសុខវេទនាចេតសិក (សេចក្តីដឹងខ្លួនជាសុខតាមផ្លូវកាយ)

ទុក្ខសហគតំ ចិត្តកើតរួមនឹងទុក្ខវេទនាចេតសិក (សេចក្តីដឹងខ្លួនជាទុក្ខតាមផ្លូវកាយ)

ខណៈណាដែលចិត្តកើតឡើង ខណៈនោះត្រូវមានវេទនាចេតសិកកើតរួមជាមួយគ្រប់ ៗ ដួង ដូច្នេះ វេទនាចេតសិក ១ ដួង កើតជាមួយចិត្តដួង ១ ស្រេចហើយតែថា នឹងជាវេទនាចេតសិកប្រភេទណា ។ ចិត្តជាធំជាប្រធានក្នុងការដឹងច្បាស់លក្ខណៈផ្សេង ៗ នៃអារម្មណ៍តែវេទនាចេតសិក

ជាសភាវធម៌ដែលដឹងខ្លួនសប្បាយចិត្ត ឬលំបាកចិត្ត សុខ ឬទុក្ខ ឬព្រងើយ ។ ក្នុងខណៈដែលដឹងអារម្មណ៍ ។ នៅពេលចិត្តផ្សេងគ្នាដោយជាតិ គឺជាកុសល ជាអកុសល ជាវិបាក ជាកិរិយា ចេតសិកដែលកើតជាមួយចិត្តណា ក៏ត្រូវជាជាតិដូចគ្នានឹងចិត្តនោះ ។ អកុសលចេតសិកនឹងកើតជាមួយកុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្តមិនបានឡើយ កុសលចេតសិកនឹងកើតជាមួយអកុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្តមិនបានឡើយ វិបាកចេតសិក ក៏កើតជាមួយអកុសលចិត្ត កុសលចិត្តនិងកិរិយាចិត្តមិនបានឡើយ ដូច្នេះវេទនាចេតសិកទើបផ្សេងគ្នាជាកុសល អកុសល វិបាក កិរិយាដូចនឹងចេតសិកដទៃ ។ ដែរ ។ ប៉ុន្តែបើព្រះមានព្រះភាគទ្រង់មិនបានសម្តែងលក្ខណៈនៃសភាវធម៌មួយប្រភេទ ។ ទុកដោយល្អិតល្អន់ទេនោះ ក៏នឹងមានអ្នកយល់ខុសក្នុងលក្ខណៈនៃវេទនាចេតសិក ដូចទុក្ខវេទនាតាមផ្លូវកាយ ដែលជាសេចក្តីដឹងមិនសប្បាយ ឈឺចុកចាប់ នោះកើតរួមនឹងកាយវិញ្ញាណ គឺជាចិត្តដែលដឹងនូវអ្វីដែលប៉ះខ្ទប់សម្ផស្សកាយ ដែលកើតឡើងជួរខណៈ ១ នៃចិត្តមួយ មិនមែនខណៈដែលដឹងខ្លួនទោមនស្ស មិនស្រស់ស្រាយក្នុងកាលប៉ះខ្ទប់នឹងអារម្មណ៍ដែលមិនគួរពេញចិត្តតាមផ្លូវកាយហើយនោះទេ ។ កាលចិត្ត ខណៈនីមួយ ។ ផ្សេងគ្នាដោយល្អិត តាមវេទនាចេតសិក ដែលកើតរួមនឹង ចិត្ត ១ ខណៈ ។ ព្រះមានព្រះភាគទើបបានទ្រង់សម្តែងទុកដោយល្អិតល្អន់ថា ចិត្តដែលជាអកុសលប្រភេទនីមួយ ។ នោះ មានវេទនាអ្វីកើតរួមផង ចិត្តដែលជា

កុសលប្រភេទនីមួយ ។ នោះមានវេទនាអ្វីកើតរួមផង ចិត្តដែលជាវិបាក ប្រភេទនីមួយ ។ នោះមានវេទនាអ្វីកើតរួមផង ចិត្តដែលជាកិរិយា ប្រភេទនីមួយ ។ នោះ មានវេទនាអ្វីកើតរួមផង ។

ជួរខណៈដែលដឹងខ្លួន ឈឺចុកចាប់នោះ ជាទុក្ខវេទនាតាមផ្លូវកាយ ជាអកុសលវិបាក ប៉ុន្តែខណៈដែលមិនពេញចិត្ត ក្តៅក្រហាយ ខ្វល់ខ្វាយ ព្រោះទុក្ខវេទនានោះមិនមែនវិបាកទេ ខណៈនោះជាអកុសលវេទនា កើតជាមួយអកុសលចិត្ត ទើបមិនសប្បាយចិត្ត ។

ការសិក្សាព្រះអភិធម្មដោយល្អិតល្អន់ ធ្វើឱ្យយល់សភាពនៃវេទនាចេតសិក ដែលកើតជាមួយចិត្តបានត្រឹមត្រូវ បើមិនដូច្នេះទេ ក៏នឹងពេញចិត្តវង្វេងឈ្លក់ក្នុងសោមនស្សវេទនា ក្នុងសុខវេទនា ឬក្នុងឧបេក្ខាវេទនា ដោយមិនដឹងថា វេទនាខណៈណា ជាកុសល ខណៈណា ជាអកុសល ខណៈណា ជាវិបាក ខណៈណា ជាកិរិយា ។

ក្នុងអង្គុត្តរនិកាយ ឯកនិបាត ទុតិយបណ្ណាសកសនិមិត្តវគ្គទី ៣ មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាបាបអកុសល មានវេទនាទើបកើតឡើង មិនមានវេទនាមិនកើតឡើង ព្រោះលះវេទនានោះអស់ ធម៌ដែលជាបាបអកុសលទាំងនោះ ទើបមិនមានដោយប្រការដូចនេះ ។

(ខ ដទៃ ។ ពោលដល់សញ្ញាចេតសិក ដែលជាសញ្ញាខន្ធ ចេតសិកឯទៀត ។ ដែលជាសង្ខារក្ខន្ធ និងចិត្តជាវិញ្ញាណក្ខន្ធ) ។

សម្តែងថា វេទនាចេតសិកដែលជាសេចក្តីដឹងខ្លួននោះ ជាទីតាំងនៃ សេចក្តីប្រកាន់មាំយ៉ាងណែន កាលបើមិនដឹងសេចក្តីពិតនៃវេទនាចេតសិក ក៏មិនអាចលះសេចក្តីដឹងខ្លួន ថាជាយើងបានឡើយ ។

ការដឹងសភាពនៃវេទនាចេតសិក នឹងជាឧបការៈឱ្យសតិផ្តើមរលឹកដឹងលក្ខណៈនៃវេទនាបាន បើមិនដូច្នោះទេ ក៏នឹងមិនរលឹកបានឡើយថា ក្នុងមួយថ្ងៃ ។ នោះ មានវេទនា ដូចគ្នានឹងក្នុងមួយថ្ងៃ ។ ក៏មានតែសភាពដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ព្រោះចិត្តកើតឡើងដឹងសភាវធម៌នោះ ។ ។ ប៉ុន្តែសាកល្បងគិតមើលថា បើឃើញហើយ មិនមានសេចក្តីដឹងខ្លួនអ្វីសោះទេ ក៏មិនក្តៅក្រហាយ បើឮហើយ មិនដឹងខ្លួនអ្វីសោះទេ ក៏មិនក្តៅក្រហាយដែរ ដូចគ្នាពេលធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ហើយមិនដឹងខ្លួនអ្វីសោះទេ ក៏មិនក្តៅក្រហាយ ក៏រមែងមិនមានបាបអកុសលកម្មណា ។ ទាំងអស់ ។ ប៉ុន្តែកាលបើមានសេចក្តីដឹងខ្លួនកើតឡើង ចិត្តជាប់ជំពាក់ និងប្រកាន់មាំក្នុងសេចក្តីដឹងខ្លួន និងចង់បាននូវអ្វីដែលធ្វើឱ្យដឹងខ្លួនជាសុខសប្បាយ ធ្វើឱ្យអកុសលធម៌ទាំងឡាយ កើតឡើងជារឿយ ។ ដោយមិនដឹងខ្លួន ។ ធម៌ទាំងឡាយជាអនត្តា មិនមាននរណា អាចបង្គាប់បញ្ជាមិនឱ្យវេទនាចេតសិកកើតឡើងបានឡើយ មិនថាចិត្តកើតឡើងខណៈណា ត្រូវតែមានចេតសិកជាវេទនាដែលដឹងខ្លួនក្នុងអារម្មណ៍ខណៈនោះ ខណៈនោះវេទនាចេតសិករមែងនឹងជាយ៉ាងណាមួយ គឺឧបេក្ខាវេទនា សុខវេទនា ទុក្ខវេទនា

សោមនស្សវេទនា ទោមនស្សវេទនា ។ ការសិក្សាធម៌ មិនមែនត្រឹមតែដើម្បីឱ្យដឹងចំនួន ឬដឹងឈ្មោះនោះទេ គឺដើម្បីដឹងលក្ខណៈនៃសេចក្តីដឹងខ្លួនដែលកំពុងមានក្នុងខណៈនេះ ដែលថាបើសតិមិនកើតរលឹកដឹងលក្ខណៈនៃសេចក្តីដឹងខ្លួន ដែលកំពុងមានក្នុងខណៈនេះទេ សូម្បីសេចក្តីដឹងខ្លួននោះ មានពិតកើតឡើងក៏ដោយ តែក៏បានរលត់ទៅ ហើយកាលបើមិនដឹងលក្ខណៈដែលពិតប្រាកដនៃសេចក្តីដឹងខ្លួនទេ ក៏រមែងប្រកាន់នូវសេចក្តីដឹងខ្លួននោះថាជាយើង ដែលសុខ ដែលទុក្ខ សប្បាយចិត្ត លំបាកចិត្ត ឬព្រងើយ ៗ ។

ដូច្នេះ ដរាបណា ដែលសតិមិនកើតឡើងរលឹកដឹងលក្ខណៈនៃសេចក្តីដឹងខ្លួន រមែងមិនមានផ្លូវ ដែលនឹងលះបង់ការប្រកាន់សភាវធម៌ថាជាសត្វ បុគ្គល តួខ្លួនបានឡើយ ព្រោះបុគ្គលទាំងឡាយប្រកាន់មាំណាស់ក្នុងសេចក្តីដឹងខ្លួន ថាជាសភាវៈសំខាន់ក្នុងជីវិត គ្រប់គ្នាត្រូវការ សេចក្តីដឹងខ្លួនដែលជាសុខ មិនមាននរណាត្រូវការសេចក្តីដឹងខ្លួនជាទុក្ខឡើយ ។ ដូច្នោះ មិនថានឹងមានផ្លូវណាដែលនឹងឱ្យកើត សុខវេទនា សោមនស្សវេទនា ក៏រមែងនឹងព្យាយាម ខ្វល់ខ្វាយឱ្យកើតសេចក្តីដឹងខ្លួននោះ ដោយមិនដឹងថាខណៈនោះ ជាការជាប់ជំពាក់ ជាសេចក្តីពេញចិត្ត ប្រកាន់មាំក្នុងសេចក្តីដឹងខ្លួនដែលកើតឡើងព្រោះហេតុបច្ច័យ ហើយក៏រលត់ទៅវិញប៉ុណ្ណោះ ។ កាលសេចក្តីដឹងខ្លួនជាសភាវៈសំខាន់ ដែលបុគ្គលទាំងឡាយប្រកាន់ស្អិត ព្រះមានព្រះភាគទ្រង់បានសម្តែង វេទនាចេតសិក ១ ដួង

ជាវេទនាខន្ធ ព្រោះជាសភាវធម៌ ដែលជាទីប្រកាន់មាំថា ជាតួខ្លួន សត្វ បុគ្គល យ៉ាងសំខាន់មួយបែប ។ ការដែលសតិនឹងកើតឡើងរលឹកដឹង លក្ខណៈនៃសភាវធម៌ដែលមានពិត ដែលកើតឡើងប្រាកដនោះ និងត្រូវ អាស្រ័យការសិក្សា ការស្តាប់រឿងនៃសភាវធម៌ឱ្យបានល្អិតល្អន់ ក្រៃលែង ឡើង ហើយពិចារណាពិសោធន៍ សភាវធម៌ដែលមានពិតនោះ ក្នុងជីវិត ប្រចាំថ្ងៃផងដែរ ។

វេទនាចេតសិកមាន ៤ ជាតិ គឺវេទនាដែលជាកុសល ១ វេទនា ដែលជាអកុសល ១ វេទនាដែលជាវិបាក ១ វេទនាដែលជាកិរិយា ១ ។ វេទនាដែលជាសង្ខតធម៌កើតឡើង ព្រោះហេតុបច្ច័យតាក់តែងវេទនា ដែលជាវិបាករមែងកើតឡើងព្រោះកម្មជាបច្ច័យ វេទនា ដែលជាកុសល អកុសល កិរិយា មិនមែន ជាវិបាកទើបមិនបានកើតឡើង ព្រោះកម្មជា បច្ច័យ ក៏ប៉ុន្តែនឹងត្រូវកើតព្រោះបច្ច័យដទៃ ។

ដោយន័យនៃវេទនា ៥ នោះ សុខវេទនាតាមផ្លូវកាយ និងទុក្ខ វេទនាតាមផ្លូវកាយ ជាជាតិវិបាក ជាផលរបស់កម្ម ។ វេទនាចេតសិក ដែលជាវិបាកនោះមានកម្មដែលបានធ្វើហើយ ជាបច្ច័យឱ្យកើតឡើងដឹង អារម្មណ៍ដែលប៉ះខ្ទប់ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត តាម ប្រភេទនៃវិបាកនោះ ៗ ។

ខណៈឃើញ ចក្ខុវិញ្ញាណជាវិបាកចិត្តកើតរួមជាមួយឧបេក្ខាវេទនា ដែលជាវិបាកចេតសិក និងវិបាកចេតសិកដទៃ ៗ ទៀត សោតវិញ្ញាណ

ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណក៏មានន័យដូចគ្នា ប៉ុន្តែកាយវិញ្ញាណអកុសលវិបាក ដែលដឹងច្បាស់លក្ខណៈផ្សេង ។ នៃជោដ្ឋព្វារម្មណ៍ ដែលប៉ះខ្ជប់សម្ផស្ស កាយនោះកើតរួមជាមួយទុក្ខវេទនា និងកាយវិញ្ញាណ កុសលវិបាកកើតរួមជាមួយសុខវេទនា មិនមាននរណាអាចផ្លាស់ប្តូរ កែប្រែវេទនាដែលកើតជាមួយចិត្តប្រភេទផ្សេង ។ បានឡើយ ។ កាយវិញ្ញាណកើតឡើងព្រោះកម្មជាបច្ច័យ កាលបើកាយបសាទរូបប៉ះខ្ជប់នឹងមហាភូត-រូប (ក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ) ដែលជាឥដ្ឋារម្មណ៍ សុខវេទនាក៏កើត កាលបើកាយបសាទរូបប៉ះខ្ជប់នឹងមហាភូតរូប ដែលជាអនិដ្ឋារម្មណ៍ ទុក្ខវេទនាក៏កើត សេចក្តីដឹងខ្លួន ដែលកើតឡើងប្រាកដត្រង់កាយ ជាទុក្ខវេទនា ឬសុខវេទនាប៉ុណ្ណោះ និងជាឧបេក្ខាវេទនា ឬសោមនស្សវេទនា ឬទោមនស្សវេទនាមិនបានឡើយ ។ ត្រូវញែកវេទនាផ្លូវកាយ និងផ្លូវចិត្ត ខណៈដែលជាកាយវិញ្ញាណ សុខវេទនា ឬទុក្ខវេទនាជាជាតិវិបាក ជាផលរបស់អតីតកម្ម តែខណៈដែលក្តៅក្រហាយ ជារឿងកង្វល់នោះ ជាសេចក្តីដឹងខ្លួនមិនសប្បាយចិត្ត ខណៈនោះ ទើបមិនមែនផលរបស់អតីតកម្ម តែជាផលនៃការសន្សំរបស់អកុសលធម៌ ទើបកើតសេចក្តីដឹងខ្លួនមិនសប្បាយចិត្ត មិនរីករាយ ។

ក្រៅពីសុខវេទនា និងទុក្ខវេទនាដែលជាជាតិវិបាកម៉្យាងប៉ុណ្ណោះ និងទោមនស្សវេទនា ដែលជាជាតិអកុសលម៉្យាងប៉ុណ្ណោះ វេទនាដទៃគឺសោមនស្សវេទនា និងឧបេក្ខាវេទនានោះ ជាកុសលក៏បាន ជាអកុសល

ក៏បាន ជាវិបាកក៏បាន ជាកិរិយាក៏បាន នេះជាសេចក្តីផ្សេងគ្នា ដែលសម្តែងឱ្យឃើញថា សភាវធម៌ទាំងឡាយ រមែងកើតឡើងតាមហេតុបច្ច័យ ។

តើធ្លាប់រលឹកដឹងលក្ខណៈនៃវេទនាខ្លះហើយឬនៅ ? ខណៈនេះវេទនាកំពុងកើតឡើង និងកំពុងរលត់ទៅ លោកខ្លះអាចនឹងផ្តើមរលឹកដឹងលក្ខណៈនៃរូបដែលកំពុងប្រាកដតាមផ្លូវភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ អស់លោកខ្លះទៀតអាចនឹងផ្តើមរលឹកដឹងលក្ខណៈនៃនាមធម៌ ដែលជាសភាពដឹងក្នុងខណៈដែលកំពុងឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងនឹកគិត តែនោះមិនទាន់ល្មមគ្រប់គ្រាន់ទេ ព្រោះសតិនឹងត្រូវរលឹកដឹង លក្ខណៈនៃសភាវធម៌ដែលមានពិតដែលកំពុងប្រាកដទាំង ៥ ខន្ធ គឺទាំងរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ។ កាលបើសតិនៅមិនទាន់រលឹកដឹងលក្ខណៈនៃសភាវធម៌ទាំងនោះពិត ៗ ទេ ក៏មិនអាចរំលត់កិលេសបាន ព្រោះកិលេសមិនមែនសភាវៈដែលនឹងត្រូវរំលត់បានដោយសេចក្តីមិនដឹងនោះទេ ឬដោយមិនមានសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ជាទូទៅតាមពិត ៗ នោះដែរ ។ ខណៈដែលកំពុងដេកលក់មានវេទនាចេតសិកឬទេ ? ធម៌ជារឿងដែលគួរគិត គួរពិចារណា ព្រោះគិតច្រើនពិចារណាច្រើន ក៏ធ្វើឱ្យយល់ច្រើននូវធម៌កាន់តែជាក់ច្បាស់ឡើង ដូច្នេះទើបគួរពិចារណាថា ក្នុងខណៈដែលកំពុងដេកលក់នោះ មានសេចក្តីដឹងខ្លួនទេ ? ខណៈដែលកំពុងដេកលក់យ៉ាងស៊ប់មិនដឹងអារម្មណ៍នៃ

លោកនេះឡើយ មិនថាតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត មិនបាននឹកគិត មិនបានស្តាប់ ប៉ុន្តែកាលបើនៅជាអ្នកមានជីវិត ក៏រមែងនឹងត្រូវមានចិត្តកើត រលត់ ជាភវង្គចិត្តតម្រង់ភពជាតិ ភាពជាបុគ្គលនោះរហូតទម្រាំភ្ញាក់ឡើង ហើយទើបនឹងឃើញលោកនេះតទៅទៀត រហូតទម្រាំនឹងដល់ពេលដេកលក់ទៀត ខណៈលក់យ៉ាងស៊ប់នោះមិនដឹងអ្វីក្នុងលោកនេះយ៉ាងណាមួយសោះឡើយ មិនថាតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ដែលធ្លាប់ឃើញ ធ្លាប់ឮ ធ្លាប់ពេញចិត្ត ធ្លាប់នឹកគិតដល់ ។ ក្នុងខណៈដែលដេកលក់យ៉ាងស៊ប់នោះ មិនមានអារម្មណ៍ណា ។ ប្រាកដឡើយ តែចិត្តក៏នៅកើតរលត់បន្តគ្នាជារឿយ ។ ។ នាមខន្ធ ទាំង ៤ គឺចិត្ត និងចេតសិក ត្រូវកើតរួមគ្នា បែកគ្នាមិនបានឡើយ ខណៈដែលដេកលក់យ៉ាងស៊ប់ ជាវិបាកចិត្ត ជាផលរបស់អតីតកម្ម ទើបធ្វើឱ្យបុគ្គលដែលដេកលក់ស៊ប់នោះនៅមិនស្លាប់ ព្រោះវិបាកចិត្តកើតឡើងបន្តគ្នា នៅតម្រង់ភពជាតិ និងកាលបើចិត្តកើតឡើងក៏ត្រូវមានចេតសិកកើតរួមផងគ្រប់ពេល ។ វេទនាចេតសិក កើតជាមួយចិត្តគ្រប់ដួង វេទនាចេតសិកដែលកើតជាមួយភវង្គចិត្ត ជាវិបាកចេតសិកដែលដឹងអារម្មណ៍ដូចនឹងភវង្គចិត្ត គឺមិនមែនអារម្មណ៍នៃលោកនេះ ទើបមិនដឹងខ្លួន ដូចយ៉ាង ខណៈដែលចិត្តកំពុងឃើញតាមភ្នែក កំពុងឮតាមត្រចៀក ជាដើម មិនមាននរណាអាចដឹងលក្ខណៈនៃវេទនាចេតសិកដែលកើត ក្នុងខណៈដែលកំពុងដេកលក់បាន

ឡើយ ។ តែពេលភ្ញាក់ឡើងក៏គួរនឹងគិតទៀតថា អ្វីភ្ញាក់ ? ពេលដេកលក់ក៏គួរនឹងគិតថា អ្វីលក់ ? រូបមិនមែនជាសភាវៈដឹង ទើបរូបមិនភ្ញាក់ មិនដេកលក់ តែនាមធម៌ជាសភាពដឹង កាលបើមិនដឹងអារម្មណ៍ដែលប្រាកដក្នុងលោកនេះទើបឈ្មោះថាដេកលក់ តែចិត្តក៏នៅកើត រលត់បន្តតម្រង់ភពជាតិនៅជានិច្ចទើបមិនស្លាប់ ។

ខណៈដែលភ្ញាក់នោះ តើអ្វីភ្ញាក់ ? ចិត្ត ចេតសិក ភ្ញាក់ដោយកើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្ត ។ ខណៈណាដែលដឹងអារម្មណ៍នៃលោកនេះ ខណៈនោះភ្ញាក់ តែក៏គួរនឹងពិចារណាឱ្យល្អិតឡើងទៅទៀត ដើម្បីប្រយោជន៍ដល់ការចម្រើនសតិប្បដ្ឋាន ព្រោះការសម្តែងធម៌នោះ គោលបំណង គឺដើម្បីឧបការៈឱ្យសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដ និងជាវិរិយារម្ភកថា គឺពាក្យពោលដែលជាឧបការៈ ទ្រទ្រង់ជ្រោមជ្រែងឱ្យកើតវិរិយៈ ដែលនឹងរលឹកដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដ ។ ដូច្នេះ ក៏គួរពិចារណាថា ខណៈដែលភ្ញាក់នោះ ចិត្ត ចេតសិកកើតឡើងដឹង អារម្មណ៍នៃលោកនេះ តាមដែលនាំគ្នា យល់ចូលចិត្ត តែក៏គួរគិតឱ្យជ្រៅ ៗ ទៀតថា តើអ្វីភ្ញាក់ ? ចិត្ត ចេតសិកកើតភ្ញាក់ឡើងព្រមគ្នាវិបាកចិត្តកើតឡើង ឃើញសភាវៈដែលប្រាកដតាមផ្លូវភ្នែកខ្លះ តាមផ្លូវត្រចៀកខ្លះ តាមច្រមុះខ្លះ តាមអណ្តាតខ្លះ តាមផ្លូវកាយខ្លះ ដោយបង្គាប់បញ្ជាមិនបានឡើយ ។ វិបាកចិត្តជាផលរបស់កម្ម កើតឡើងហើយរលត់

ទៅ និងនៅដេកលក់រហូតមិនបាន មិនមានផ្លូវដែលនឹងប្រព្រឹត្តបានឡើយ កម្មមិនបានធ្វើឱ្យកើតក្នុងជាតិនេះ ហើយដេកលក់រហូតទៅដល់ស្លាប់ នោះទេ តែថាកម្មជាបច្ច័យឱ្យមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដើម្បីជាបច្ច័យឱ្យចិត្តកើតឡើងឃើញនូវអ្វី ដែលគួរពេញចិត្ត ជាផលនៃកុសលកម្ម ឃើញអ្វីដែលមិនគួរពេញចិត្ត ជាផលរបស់អកុសលកម្ម ឮសំឡេងដែលល្អ ជាផលរបស់កុសលកម្ម ឮសំឡេងដែលមិនល្អ ជាផលរបស់អកុសលកម្ម ជាដើម ។

ដូច្នេះ វិបាកចិត្ត និងចេតសិកកើតភ្ញាក់ឡើង ដឹងអារម្មណ៍តាមទ្វារភ្នែក តាមទ្វារត្រចៀក តាមទ្វារច្រមុះ តាមទ្វារអណ្តាត តាមទ្វារកាយ តាមទ្វារចិត្តក្នុងជីវិតប្រចាំថ្ងៃ ។ ក្រៅពីនោះហើយនៅមានអ្វីទៀត កាលភ្ញាក់ហើយ ក្រៅពីវិបាកចិត្តកើតឡើង ឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈប៉ះខ្ទប់សម្ផស្សហើយ អកុសលធម៌ ឬកិលេសទាំងឡាយក៏ផ្តើមភ្ញាក់ ព្រោះខណៈនៅលក់នោះមានអនុស័យកិលេស គឺកិលេសដែលនៅមិនទាន់បានរំលត់ សន្សំនៅក្នុងភវង្គចិត្តគ្រប់ដួង ដែលកើត រលត់ ក្នុងខណៈលក់នោះ កិលេសមិនបានកើតឡើងធ្វើកិច្ចត្រេកអររីករាយ ព្រោះមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងប៉ះខ្ទប់សម្ផស្ស អារម្មណ៍ណា ៗ នៃលោកនេះឡើយ ។

ខណៈនៅដេកលក់យ៉ាងស៊ប់នោះ កិលេសទាំងឡាយក៏នៅលក់ដែរ តែពេលភ្ញាក់ឡើងហើយកិលេសភ្ញាក់ឡើងដែរ គឺក្រោយពីឃើញ ឮ

ធុំក្លិន ដឹងរស ដឹងនូវអ្វីដែលប៉ះខ្ទប់សម្ផស្សកាយហើយ កិលេសទាំងឡាយ ក៏កើតរួមនឹងអកុសលចិត្ត តាមហេតុបច្ច័យ ដែលនឹងឱ្យកើតអកុសលធម៌ តាម ប្រភេទនោះ ។ ។

ចំណែកចិត្តដោយភូមិ ៤ គឺ កាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ លោកុត្តរភូមិនោះ ចិត្តប្រណីតឡើងតាមលំដាប់ថ្នាក់ តែចិត្តរបស់បុគ្គលភាគច្រើនក៏ជាកាមាវចរភូមិ គឺប្រព្រឹត្តទៅនៅក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ កាមាវចរចិត្ត ជាភូមិថ្នាក់ដើមនៃលំដាប់ចិត្ត គឺពេលភ្ញាក់ឡើងក៏ឃើញ ឮ ផ្លាស់ប្តូរវិលទៅតាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្ត ។

ក្នុងមួយថ្ងៃ ។ ចិត្តដែលកើតឡើងនោះ ក្រៅពីភូមិថ្នាក់ដើមហើយ ដោយជាតិ នៅជាជាតិដែលអាក្រក់ទៀត គឺជាអកុសលចិត្តដែលភ្ញាក់ឡើងជាប្រចាំ ខណៈដែលកុសលចិត្តមិនកើត ។ ពេលឃើញក៏ត្រេកអរជាប់ជំពាក់ ពេលឮក៏ពេញចិត្ត ជាប់ជំពាក់ក្នុងសំឡេង ដែលឮជាប្រក្រតីធម្មតា ព្រោះភាគច្រើនលោភមូលចិត្តកើតញឹកញាប់ជាងទោសមូលចិត្ត ដែលជាសភាពចិត្តដែលគ្រោតគ្រាត មិនរីករាយ ។

ក្នុងមួយថ្ងៃ ។ ត្រូវព្រមទទួលតាមសេចក្តីពិតថា មានអកុសលចិត្តច្រើនជាងកុសលចិត្ត បើមិនដឹងក៏នឹងអប់រំចម្រើនកុសលឱ្យផុតពីសភាពនៃចិត្តដែលអាក្រក់មិនបាន គង់នៅជាអកុសលចិត្តច្រើនដូចដើម ហើយនឹងនៅមានសេចក្តីត្រេកអរ ពេញចិត្តក្នុងអកុសលនោះ ។ ដោយមិន

ឃើញថាជាទោស ដូច្នោះ ក៏គួរជ្រាបថា ដែលភ្ញាក់ឡើងមកនោះ ភាគច្រើន គឺកិលេសភ្ញាក់ទាំងអស់ទាំងតាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ តាមផ្លូវចិត្តដល់កម្រិតណា ។ ស្រេចហើយ តែកិលេសនៃអ្នកណាដែលនឹងកង្វល់ នឹងធ្វើឱ្យកើតការក្តៅក្រហាយចិត្ត និងកាយដល់កម្រិតនោះ ។

កាលបើដឹងយ៉ាងនេះហើយ ក៏គួរតែខ្នះខ្នែងអប់រំចម្រើនកុសលឱ្យ ក្រៃលែងឡើង មិនថានឹងជាថ្នាក់ទាន សីល សេចក្តីស្ងប់របស់ចិត្ត ឬថ្នាក់សតិប្បដ្ឋានដែលរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ក៏ដោយ ។

មិនមែននរណាអាចនឹងលះលោភៈបានមុនសិន ហើយទើបអប់រំ ចម្រើនបញ្ញាជាសោតាបន្ន ក្នុងពេលក្រោយនោះទេ សូម្បីដល់ថា លោភៈ នឹងកើតក៏ជាសភាវធម៌មួយបែប ដែលកើតឡើងព្រោះហេតុបច្ច័យ មិន មែនសត្វ បុគ្គល តួខ្លួនដែរ បញ្ញានឹងត្រូវរលឹកដឹងលក្ខណៈនៃសភាវធម៌ គឺលោភៈតាមសេចក្តីពិតថាជាសភាវធម៌មួយបែបដែលកើត រលត់ ។

វេទនា ៥ កើតជាមួយចិត្តផ្សេង ៗ ដូចនេះ គឺ

សុខវេទនាកើតជាមួយនឹងកាយវិញ្ញាណកុសលវិបាកចិត្ត ១ ដួង

ទុក្ខវេទនាកើតជាមួយនឹងកាយវិញ្ញាណអកុសលវិបាកចិត្ត ១ ដួង

ទោមនស្សវេទនាកើតជាមួយនឹងទោសមូលចិត្ត ២ ដួង

សោមនស្សវេទនា និងឧបេក្ខាវេទនាកើតជាមួយនឹងចិត្ត ដែលជាកុសលក៏បាន អកុសលក៏បាន កិរិយាក៏បាន ។

ទោមនស្សវេទនាកើតជាមួយចិត្តដែលជាកុសល វិបាក កិរិយា មិនបាន កើតបានចំពោះតែនឹងចិត្តដែលជាអកុសល គឺទោសមូលចិត្តត្រឹមតែ ២ ដួងប៉ុណ្ណោះ ។ បើមិនដឹងយ៉ាងនេះទេ លោកខ្លះអាចនឹងយល់ថា អកុសល ជាកុសល ដូចពេលដែលអាណិតអាសូរបុគ្គលដែលមានទុក្ខលំបាក ក្តៅក្រហាយប្រាថ្នាចង់នឹងជួយសង្គ្រោះគេឱ្យផុតពីសេចក្តីទុក្ខលំបាក ខណៈចិត្តដែលកើតករុណានោះ ជាកុសលចិត្តដែលមានករុណាចេតសិកកើតរួមផងដែរ ដែលនឹងត្រូវដឹងលក្ខណៈនៃវេទនាផងថា ដឹងខ្លួនមិនរីករាយខ្លះឬទេ ? បើដឹងខ្លួនទោមនស្សតូចចិត្ត មិនរីករាយ ក៏ជាអកុសលចិត្ត មិនមែនខណៈដូចចិត្តដែលកើតរួមនឹងករុណាចេតសិកទេ កាលបើដឹងយ៉ាងនេះ ក៏នឹងលះបង់សេចក្តីដឹងខ្លួន តូចចិត្ត ទោមនស្ស មិនស្រស់ស្រាយដែលជាអកុសល ហើយអាចជួយបុគ្គលដទៃឱ្យផុតពីសេចក្តីទុក្ខលំបាកបានដោយរីករាយ មិនទោមនស្ស មិនខូចចិត្ត ។ ដូច្នេះ

ទើបត្រូវដឹងថា ខណៈណាជាអកុសល ទើបនឹងលះបង់បាន ព្រោះដោយច្រើនយល់តាមគ្នាថា កាលបើអាណិតអាសូរបុគ្គលដែលកំពុងទទួលនូវសេចក្តីទុក្ខលំបាក ក្តៅក្រហាយ ត្រូវបញ្ចេញនូវការសោកសៅក្រៀមក្រំចិត្តជាទុក្ខនឹងបុគ្គលនោះផងដែរ ។ បើសួរថា ខណៈនេះដឹងខ្លួនយ៉ាងណា ? បុគ្គលខ្លះក៏ឆ្លើយថាព្រងើយ ។ បុគ្គលខ្លះក៏សប្បាយចិត្ត សូម្បីតែពេលដែលសតិរលឹកត្រង់លក្ខណៈនៃសេចក្តីដឹងខ្លួននោះ ក៏លំបាកនឹងដឹងតាមសេចក្តីពិតដែរថា សេចក្តីដឹងខ្លួននោះ ។ ត្រឹមតែជាសភាពដឹង ជានាមធម៌ ១ បែបដែលកើតជាមួយចិត្តគ្រប់ខណៈ ។

ខណៈដែលសំឡេងប្រាកដ សោតវិញ្ញាណជាសភាពដឹង ដែលឮសំឡេងនោះ ខណៈនោះមានវេទនាចេតសិក ដែលដឹងខ្លួនកើតព្រមជាមួយនឹងសោតវិញ្ញាណ កាលផស្សចេតសិកកើតឡើងប៉ះខ្ទប់អារម្មណ៍នោះ នឹងមិនឱ្យវេទនាចេតសិកកើតក៏មិនបានឡើយ កាលបើសតិអាចផ្តើមរលឹកដឹងលក្ខណៈនៃចិត្តខ្លះ វេទនាចេតសិកខ្លះ ក៏រមែងជាបច្ច័យសន្សំឧបការៈឱ្យមិនវង្វេងភ្លេច ដូច្នោះ នៅពេលដឹងខ្លួនព្រងើយ ។ សប្បាយចិត្ត សុខ ទុក្ខនោះ ជំនួសនូវសេចក្តីក្រៀមក្រំចិត្តដ៏ក្រៃលែង សតិក៏រលឹកបានថា ខណៈនោះក៏ត្រឹមតែជាសេចក្តីដឹងខ្លួន ដែលកើតឡើង ព្រោះហេតុបច្ច័យ ដូច្នេះ សតិប្បដ្ឋានទើបមានគុណប្រយោជន៍ដល់ការលះបង់សេចក្តីទុក្ខក្នុងខណៈដែលដឹងខ្លួនមិនរីករាយបាន ។

សំណួរសាឡើងវិញ

១ - តើឧបេក្ខាវេទនា សោមនស្សវេទនា ជាជាតិអ្វី ?

២ - តើទុក្ខវេទនា សុខវេទនា ជាជាតិអ្វី ?

៣ - តើទោមនស្សវេទនា ជាជាតិអ្វី ?

៤ - តើខណៈដេកលក់ស៊ប់ វេទនាចេតសិក ជាជាតិអ្វី ?

៥ - រូបភ្ញាក់ ឬ ដេកលក់បានឬទេ ? ព្រោះអ្វី ?

មេរៀនទី ១១

សម្បយុត្តធម៌ គឺចេតសិកដែលចំណែកចិត្តឱ្យផ្សេងគ្នាដោយប្រភេទតទៅ គឺដោយសម្បយុត្ត ឬ វិប្បយុត្ត ។

អកុសលសម្បយុត្ត ៤ គឺ

ទិដ្ឋិគតសម្បយុត្ត ចិត្តកើតរួមនឹងទិដ្ឋិចេតសិក គឺការយល់ឃើញខុស ។

បដិឃសម្បយុត្ត ចិត្តកើតរួមនឹងទោសចេតសិក ។

វិចិកិច្ឆាសម្បយុត្ត ចិត្តកើតរួមនឹងវិចិកិច្ឆាចេតសិក គឺសេចក្តីសង្ស័យក្នុងសភាវធម៌ ។

ឧទ្ធច្ចសម្បយុត្ត ចិត្តកើតរួមនឹងឧទ្ធច្ចចេតសិក គឺសភាវធម៌ដែលមិនស្ងប់ ។

សោភណសម្បយុត្ត ១ គឺ

ញាណសម្បយុត្ត ចិត្តកើតរួមនឹងបញ្ញាចេតសិក

អកុសលចិត្ត ១២ ដួង ចំណែកដោយសម្បយុត្ត

លោភមូលចិត្ត ៨ ដួង កើតរួមនឹងទិដ្ឋិចេតសិក ការយល់ឃើញខុស ជាទិដ្ឋិសម្បយុត្ត ៤ ដួង ហើយមិនកើតរួមនឹងការយល់ឃើញខុសជាទិដ្ឋគតវិប្បយុត្ត ៤ ដួង ។

ទោសមូលចិត្ត ២ ដួង ជាបដិឃសម្បយុត្ត គឺកើតរួមនឹងទោសចេតសិក ដែលជាសភាវធម៌គ្រោតគ្រាតទាំង ២ ដួង ។

មោហមូលចិត្ត ២ ដួង កើតរួមនឹងវិចិកិច្ឆាចេតសិក
ជាវិចិកិច្ឆាសម្បយុត្ត ១ ដួង
កើតរួមនឹងឧទ្ធច្ចចេតសិក
ជាឧទ្ធច្ចសម្បយុត្ត ១ ដួង ។

រួមអកុសលចិត្ត ១២ ដួង ជាសម្បយុត្ត ៨ ដួង ជាវិប្បយុត្ត ៤ ដួង

លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត (និងទិដ្ឋិគតវិប្បយុត្ត) នោះ ផ្សេងគ្នាជា ៤
គឺកើតរួមនឹងសោមនស្សវេទនា ២ ដួង
កើតរួមនឹងឧបេក្ខាវេទនា ២ ដួង ។

រួមលោភមូលចិត្ត ៨ ដួង គឺ

សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ
សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ
សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ
ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ
ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ
ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ
ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

ទោសមូលចិត្ត ២ ដួងនោះ គឺកើតរួមនឹងបដិឃៈ គឺទោសចេតសិក ទើបជាបដិឃសម្បយុត្ត ទាំង ២ ដួង ព្រោះកាលណាបើទោមនស្សវេទនាកើតឡើងនោះ ត្រូវមានទោសចេតសិក សុទ្ធសឹងជាសភាវធម៌ ដែលគ្រោតគ្រាត ប្រទូសរ៉ាយកើតរួមជាងគ្រប់ពេល មិនដូច សោមនស្សវេទនា និងឧបេក្ខាវេទនា ដែលកើតរួមនឹងលោភមូលចិត្ត ឬកុសលចិត្ត ឬវិបាកចិត្ត ឬកិរិយាចិត្តក៏បាន ។ ដូច្នេះ កាលបើទោសមូលចិត្ត ២ ដួង កើតរួមនឹងទោមនស្សវេទនា ទើបត្រូវជាបដិឃសម្បយុត្ត ទាំង ២ ដួង និង**ទោសមូលចិត្តផ្សេងគ្នាជា ២ ដួង** ក៏ព្រោះជា**អសង្ខារិក** គឺកើតឡើងឯង ៗ ដោយមិនអាស្រ័យការដឹកនាំ ១ និងជា**សសង្ខារិក** គឺកើតឡើងដោយ អាស្រ័យការដឹកនាំ ១ ដូចនោះ ទោសមូលចិត្ត ២ ដួង គឺ

ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ
ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

មោហមូលចិត្ត ផ្សេងគ្នាជា ២ ដួង គឺមួយដួង គឺជា**វិចិកិច្ឆាសម្បយុត្ត** កើតរួមនឹងវិចិកិច្ឆាចេតសិក ដែលសង្ស័យក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ខន្ធ ធាតុ អតីត បច្ចុប្បន្ន អនាគត ជាដើម ។ មួយដួងទៀត ជា**ឧទ្ធច្ចសម្បយុត្ត** ។

មោហចេតសិក ជាចេតសិកដែលមិនដឹងសភាវធម៌តាមសេចក្តីពិត សូម្បីថា កំពុងប្រឈមមុខនឹងអារម្មណ៍ ក៏មិនអាចដឹងលក្ខណៈ ដែលពិតប្រាកដនៃអារម្មណ៍ដែលប្រាកដបានឡើយ ។ ដូចក្នុងខណៈដែលកំពុងឃើញនេះ មិនដឹងថា អ្វីដែលប្រាកដតាមផ្លូវភ្នែក ជាសភាវៈមួយបែបប៉ុណ្ណោះ ។ កាលមិនដឹងក៏សង្ស័យថា លក្ខណៈនៃសភាវធម៌ ដែលត្រឹមតែប្រាកដតាមផ្លូវភ្នែកនោះ ផ្សេងគ្នាយ៉ាងណា ដែលធ្លាប់យល់ថា អ្វីដែលឃើញ ជាបុគ្គល ឬជាវត្ថុ របស់របរនោះ ។ ខណៈណាដែលសង្ស័យ ខណៈនោះជាមោហមូលចិត្តវិចិកិច្ឆាសម្បយុត្ត ប៉ុន្តែក៏មិនមែនថាសេចក្តីសង្ស័យនឹងកើតរាល់ ។ វេលានោះទេ ខណៈណាដែលសង្ស័យក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ក្នុងលក្ខណៈនៃសភាវធម៌ដែលប្រាកដ ខណៈនោះជាមោហមូលចិត្ត ដែលកើតរួមនឹងវិចិកិច្ឆាចេតសិក ។

ដោយប្រក្រតី នៅពេលឃើញ បានឮ បានធុំក្លិន ដឹងរស ដឹងអ្វីដែលប៉ះខ្ទប់សម្ផស្សកាយហើយ បើខណៈនោះចិត្តដែលកើតតមិនជាកុសលចិត្ត ឬអកុសលចិត្តប្រភេទដទៃ ។ ទេ ក៏ជាមោហមូលចិត្ត ឧទ្ធច្ចសម្បយុត្ត ព្រោះខណៈនោះមិនបានមានសេចក្តីសង្ស័យកើតរួមផង

មិនមានលោភចេតសិកកើតរួមផង មិនមានទោសចេតសិកកើតរួមផងទេ ដូច្នេះ ទើបដឹងលក្ខណៈនៃមោហមូលចិត្ត ឧទ្ធច្ចសម្បយុត្តបានថា ខណៈដែលវង្វេងភ្លេចសតិ ខណៈនោះកំពុងមិនដឹងក្នុងសភាវនៃអារម្មណ៍ដែលប្រាកដ និងក្នុងខណៈដែលអកុសលចិត្តមិនកើតរួមជាមួយនឹងលោភចេតសិក ឬទោសចេតសិក និងវិចិកិច្ឆាចេតសិក **អកុសលចិត្តខណៈនោះក៏ជាមោហមូលចិត្តឧទ្ធច្ចសម្បយុត្ត** ដូចនោះមោហមូលចិត្ត ២ ដួង គឺ

ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ ១ ដួង
ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ ១ ដួង
រួមអកុសលចិត្ត ១២ ដួង ជាសម្បយុត្ត ៨ ដួង ជាវិប្បយុត្ត ៤ ដួង ។

សំណួរសាឡើងវិញ

១ - តើទិដ្ឋិចេតសិក កើតជាមួយនឹងចិត្តប៉ុន្មានដួង ?

២ - តើទិដ្ឋិចេតសិក កើតរួមនឹងវេទនាអ្វី ?

៣ - តើទោសចេតសិក កើតរួមនឹងវេទនាអ្វី ?

៤ - តើសោមនស្សវេទនា កើតជាមួយនឹងអកុសលចិត្តប្រភេទណា ?

៥ - តើឧបេក្ខាវេទនា កើតនឹងអកុសលចិត្តអ្វីខ្លះ ?

មេរៀនទី ១២

ចិត្តផ្សេងគ្នាដោយប្រភេទនៃសង្ខារ គឺជាអសង្ខារិក ឬសសង្ខារិក ។

ពាក្យថា **សង្ខារ** ក្នុងព្រះត្រៃបិដកមានអត្ថន័យច្រើនន័យគឺ

សង្ខារធម៌ ១

សង្ខារក្ខន្ធ ១

អភិសង្ខារ ១

អសង្ខារិក និងសសង្ខារិក ១

សង្ខារធម៌ គឺសភាវធម៌ដែលកើតឡើង ព្រោះបច្ច័យតាក់តែង កាលបើកើតឡើងហើយ ក៏រលត់ទៅវិញ ។ សង្ខារធម៌ទាំងឡាយមិនទៀង កើតឡើងត្រឹមតែជួរខណៈដ៏ខ្លីជាទីបំផុត ហើយក៏រលត់ទៅវិញទាំងអស់ ។

សង្ខារធម៌ បានដល់ចិត្ត ចេតសិក និងរូប

បរមត្ថធម៌មាន ៤ គឺ ចិត្ត ចេតសិក រូប និព្វាន បរមត្ថធម៌ ៣ គឺ ចិត្ត ចេតសិក រូប ជាសង្ខារធម៌ មានបច្ច័យតាក់តែងឱ្យកើតឡើង និងតាំងនៅជួរខណៈដ៏ខ្លីបំផុត ហើយក៏រលត់ទៅ ។ និព្វានមិនមានបច្ច័យតាក់តែង **និព្វានទើបជាសភាវធម៌ដែលមិនកើត រលត់ និព្វានជាវិសង្ខារធម៌** ។

សង្ខារធម៌ ៣ គឺ ចិត្ត ចេតសិក រូប ចំណែកជាខន្ធ ៥ គឺ

គ្រប់រូបទាំងអស់ ជា រូបក្ខន្ធ

វេទនាចេតសិក ១ ដួង ជា វេទនាខន្ធ

សញ្ញាចេតសិក ១ ដួង ជា សញ្ញាខន្ធ

ចេតសិកដែលសល់ ៥០ ដួង ជា សង្ខារក្ខន្ធ

ចិត្តគ្រប់ដួង ជា វិញ្ញាណក្ខន្ធ

ដូច្នេះ **សង្ខារក្ខន្ធ បានដល់ចេតសិក ៥០ ដួង រៀរតែវេទនាចេត-សិក និងសញ្ញាចេតសិក ចំណែកសង្ខារធម៌បានដល់ចិត្ត ចេតសិក រូប គឺ ចិត្តទាំងអស់ ៨៩ ដួង ចេតសិក ទាំងអស់ ៥២ ដួង រូបទាំងអស់ ២៨ រូប ។**

អត្ថន័យនៃសង្ខារធម៌ទូលំទូលាយជាងសង្ខារក្ខន្ធ ព្រោះចិត្ត ចេត-សិក រូប ជាសង្ខារធម៌ ប៉ុន្តែចំពោះចេតសិក ៥០ ប៉ុណ្ណោះ ដែលជា សង្ខារក្ខន្ធ ហើយក្នុងចេតសិក ៥០ ដួង ដែលជាសង្ខារក្ខន្ធនោះ ចំពោះ ចេតនាចេតសិកតែ ១ ដួង ប៉ុណ្ណោះដែលជាអភិសង្ខារក្នុងបដិច្ចសមុប្បាទ អវិជ្ជាជាបច្ច័យដល់សង្ខារ សង្ខារជាបច្ច័យដល់វិញ្ញាណ ។ ល ។ **សង្ខារ ក្នុងបដិច្ចសមុប្បាទ សំដៅដល់ចេតនាចេតសិកដែលជាអភិសង្ខារ ជា សភាវៈដែលតាក់តែងយ៉ាងក្រៃលែង គឺជាកុសលកម្ម ឬអកុសលកម្ម ដែលនឹងធ្វើឱ្យកើតផល គឺវិបាកចិត្ត និងចេតសិក** សូម្បីថាចេតសិកដទៃ ៗ ក៏តាក់តែងឱ្យចិត្តកើតឡើង ដូចជាផស្សចេតសិក បើមិនមានផស្ស ចេតសិកដែលជាសភាវធម៌មកប៉ះខ្ទប់អារម្មណ៍ ចិត្តឃើញក៏មានមិនបាន ចិត្តឮ ចិត្តធុំក្លិន ចិត្តដឹងរស ចិត្តដឹងនូវអ្វីដែលប៉ះខ្ទប់សម្ផស្ស ចិត្ត

នឹកគិតផ្សេង ។ ក៏មានមិនបាន តែផស្សចេតសិកក៏មិនមែនអភិសង្ខារ **ព្រោះត្រឹមតែ** ប៉ះខ្ទប់អារម្មណ៍ហើយរលត់អស់ទៅវិញ ។

ដូច្នេះ ក្នុងសង្ខារក្ខន្ធ ៥០ ដួង នេះ ចំពោះចេតនាចេតសិក តែ ១ ដួងប៉ុណ្ណោះដែលជាអភិសង្ខារ គឺជាសភាវៈដែលតាក់តែងយ៉ាងក្រៃលែង ដោយជាកុសលកម្ម ឬជាអកុសលកម្ម ជាកម្មប្បច្ច័យ ដែលធ្វើឱ្យផល គឺ វិបាកចិត្តកើតឡើង ។

សង្ខារក្នុងបដិច្ចសមុប្បាទ មាន ៣ គឺបុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ ។

បុញ្ញាភិសង្ខារ បានដល់ ចេតនាចេតសិកដែលកើតជាមួយនឹង កាមាវចរកុសលចិត្ត និងរូបាវចរកុសលចិត្ត ។

អបុញ្ញាភិសង្ខារ បានដល់ ចេតនាចេតសិកដែលកើតជាមួយនឹង អកុសលចិត្ត ។

អនេញ្ជាភិសង្ខារ បានដល់ ចេតនាចេតសិកដែលកើតជាមួយនឹង អរូបជ្ឈានកុសលចិត្ត ដែលជាកុសលមិនកម្រើកញាប់ញ័រ ។

កាមាវចរកុសលចិត្ត កើតឡើងជួរខណៈខ្លី ៗ ហើយញ័រ ព្រោះកើត ឡើង ១ វារៈ ។ ត្រឹមតែជួរ ៧ ខណៈប៉ុណ្ណោះ ។ ការឱ្យទាន ការវិរតិទុច្ចរិត ការចម្រើនកុសលដទៃ ។ រមែងកើតឡើងម្តងម្កាល ក្រៅពីនោះអកុសល ចិត្តក៏កើតសន្ធឹកសន្ធាប់ច្រើនវារៈ ។

រូបាវចរកុសលចិត្ត ជាកុសលញាណសម្បយុត្ត ប្រកបដោយបញ្ញាចេតសិក ជាបញ្ញា ដែលស្ងប់ដល់ថ្នាក់អប្បនាសមាធិ ដែលមានរូបជាអារម្មណ៍ ទើបជាមហគ្គតកុសល ដែលជិតគ្នានឹងកាមាវចរកុសល ព្រោះនៅមានរូបជាអារម្មណ៍ ។ អនេញ្ជាភិសង្ខារ ជាអរូបជ្ឈាន គឺជាបញ្ចមជ្ឈាន ដែលមិនមានរូបជាអារម្មណ៍ ចិត្តខណៈនោះមិនញាប់ញ័រ ព្រោះមិនមានរូបជាអារម្មណ៍ ទើបឱ្យផលយ៉ាងសម្បើមក្រៃលែង គឺធ្វើឱ្យអរូបជ្ឈានវិបាកចិត្ត កើតក្នុងអរូបព្រហ្មភូមិ សុទ្ធសឹងតែមានអាយុយូរអង្វែងណាស់តាមកម្លាំងនៃអរូបជ្ឈានកុសល ។ ការកើតក្នុងសុគ៌ជាសុខ ព្រោះមិនមានរោគភ័យឈឺចាប់ទុក្ខលំបាកកាយដូចយ៉ាងក្នុងភូមិមនុស្ស និងក្នុងអបាយភូមិនោះទេ ប៉ុន្តែមានអាយុមិនវែងដូចនឹងរូបព្រហ្មភូមិឡើយ ។ ហើយរូបព្រហ្មភូមិ ក៏មានអាយុមិនវែងដូចនឹងអរូបព្រហ្មភូមិដែរ ព្រោះអរូបព្រហ្មភូមិ ជាផលរបស់អរូបជ្ឈានកុសលដែលជាអនេញ្ជាភិសង្ខារ ។

សង្ខារធម៌ បានដល់ ចិត្ត ចេតសិក រូប

សង្ខារក្ខន្ធ បានដល់ចេតសិក ៥០ ដួង
(វៀរតែវេទនាចេតសិក និងសញ្ញាចេតសិក)

អភិសង្ខារ បានដល់ចេតនាចេតសិក ១ ដួង (សង្ខារក្ខន្ធ ១ ក្នុងសង្ខារក្ខន្ធ ៥០ ដួង)

ការចែកសេចក្តីផ្សេងគ្នានៃចិត្ត ដោយប្រភេទអសង្ខារិក និងស-សង្ខារិកនោះ សម្តែងឱ្យឃើញថា សូម្បីកុសលចិត្ត ឬអកុសលចិត្ត

ឬវិបាកចិត្ត ឬកិរិយាចិត្តដែលកើតរួមនឹងចេតនាចេតសិកនោះក៏ដោយ ក៏នៅផ្សេងគ្នាទៅដោយប្រភេទដែលជាអសង្ខារិកខ្លះ និងសសង្ខារិកខ្លះ ។ ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ មានសេចក្តីអធិប្បាយថា ឈ្មោះថា **សសង្ខារ ព្រោះប្រព្រឹត្តទៅជាមួយសង្ខារ (គ្រឿងដឹកនាំ) សង្ខារក្នុងទីនេះសំដៅដល់ដឹកនាំដោយខ្លួនឯង ឬអ្នកដទៃដឹកនាំ ឬបញ្ជាឱ្យធ្វើ** នេះជាសភាពនៃចិត្តក្នុងជីវិតប្រចាំថ្ងៃដែលមិនថាជាកុសលក្តី ឬអកុសលក្តី គ្រាខ្លះក៏កើតឡើងឯង ។ ដោយអាស្រ័យការសន្សំមកក្នុងអតីតជាបច្ច័យ ក៏មានកម្លាំងដែលធ្វើឱ្យកុសល ឬអកុសលប្រភេទណាមួយមានកម្លាំងកើតឡើងឯង ។ មិនចាំបាច់អាស្រ័យការដឹកនាំណា ។ ឡើយ ។ **សភាពចិត្តដែលកើតដោយមិនអាស្រ័យការដឹកនាំនោះ ជាអសង្ខារិក** គឺ មិនអាស្រ័យការដឹកនាំ ប៉ុន្តែថាគ្រាខ្លះ ខណៈខ្លះ មិនថាជាកុសលក្តី អកុសលក្តីដែលកើតឡើងនោះ មានកម្លាំងខ្សោយកើតឡើងបានព្រោះអាស្រ័យការដឹកនាំខ្លួនឯង ឬការដឹកនាំរបស់បុគ្គលដទៃក៏មាន អកុសល និងកុសលដែលមានកម្លាំងខ្សោយ ដែលអាស្រ័យការដឹកនាំនោះ ជាសសង្ខារិកចិត្ត ។ នេះក៏សម្តែងឱ្យឃើញថា សូម្បីជាកុសល ឬអកុសលក៏នៅតែផ្សេងគ្នាត្រង់ខណៈខ្លះ ជាកុសល ឬអកុសលដែលមានកម្លាំងខ្លាំងកើតឡើងដោយមានការសន្សំនៃខ្លួនឯងជាបច្ច័យ និងគ្រាខ្លះ ខណៈខ្លះ ក៏ជាកុសលឬអកុសល ដែលមានកម្លាំងខ្សោយ ចាំបាច់ត្រូវអាស្រ័យការដឹកនាំរបស់ខ្លួនឯង ឬការដឹកនាំរបស់បុគ្គលដទៃ ទើបកើតឡើងបាន ។

គ្រាខ្លះអកុសលចិត្តមានកម្លាំងកើតឡើងទាន់ពេលតាមការសន្សំ ដែលពេញចិត្ត ឬមិនពេញចិត្តចំពោះអារម្មណ៍ខណៈនោះ តែគ្រាខ្លះមិនជាយ៉ាងនោះទេ ដូចមិនសូវចង់ទៅមើលកុន ឬល្ខោន តែពេលដែលញាតិ បងប្អូន មិត្តភ័ក្ត្រ បបួលទៅ តើចិត្តក្នុងខណៈនោះចង់នឹងទៅឬទេ ? ទៅមើលក៏បាន មិនមើលក៏បាន តែមានគេបបួលក៏ទៅ បើចំពោះតែម្នាក់ឯងក៏មិនទៅ ឬគ្រាខ្លះ ក៏នឹកថារឿងកុននេះនឹងគង់សប្បាយគួរឱ្យទស្សនា ។ ជីវិតប្រចាំថ្ងៃពិត ។ នោះដឹងបានថា ខណៈណាជាចិត្តដែលមានកម្លាំងខ្លាំង ឬខណៈណាជាចិត្តដែលមានកម្លាំងខ្សោយ មិនថា ជាចំណែកអកុសលដែលជាលោភៈក្តី ទោសៈក្តី ឬចំណែកកុសលក្តី ។ បុគ្គលខ្លះកាលបើដឹង ដំណឹងថា មានការធ្វើកឋិនទានក៏ចង់នឹងទៅភ្លាម ថែមទាំងបបួលអ្នកដទៃទៅផង ប៉ុន្តែអ្នកខ្លះនោះ សូម្បីដល់ថានឹងត្រូវ បបួលហើយ តែបើអ្នកនេះមិនទៅ អ្នកនោះមិនទៅខ្លួនឯងក៏មិនទៅដែរ ដូច្នេះ សភាពនៃកុសលចិត្ត និងអកុសលចិត្តក៏មានកម្លាំងផ្សេងគ្នាតាមហេតុបច្ច័យ ដែលតាក់តែងឱ្យកើតឡើងប្រព្រឹត្តទៅក្នុងខណៈនោះ សូម្បីនឹងថាមានចេតសិកប្រកបស្មើគ្នាក៏ដោយ ។

ព្រះដ៏មានព្រះភាគទ្រង់សម្តែង អសង្ខារិកចិត្ត និង សសង្ខារិកចិត្ត ដើម្បីឱ្យឃើញសេចក្តីល្អិតល្អន់នៃចិត្ត ទោះជាចិត្តដែលមានចំនួន ចេតសិកកើតរួមស្មើគ្នាមិនខុសគ្នាសោះក៏ដោយ តែសភាពនៃចិត្តក៏ផ្សេងគ្នាជាអសង្ខារិក និងសសង្ខារិក តាមកម្លាំងនៃចេតសិក ដែលកើតរួមជាមួយ

ដើម្បីឱ្យឃើញព្រះមហាករុណាទិគុណរបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់ព្រះមហាករុណា សម្តែងព្រះធម៌ដោយល្អិតល្អន់ ។ សេចក្តីក្នុងអដ្ឋសាលិនីអដ្ឋកថា ធម្មសង្គណីបករណ ចិត្តុប្បាទកណ្ឌ សម្តែង "អនន្ត" សេចក្តីទូលំទូលាយមិនមានទីបំផុត ៤ យ៉ាងថា

ក្នុងទីនេះលោកសំដៅយក "អនន្ត" ៤ យ៉ាង ហើយអនន្ត ៤ យ៉ាងគឺ អាកាសជាអនន្តមិនមានទីបំផុត ១ ចក្រវាឡជាអនន្តមិនមានទីបំផុត ១ សត្តនិកាយ គឺពួកសត្វជាអនន្តមិនមានទីបំផុត ១ ពុទ្ធញាណជាអនន្តមិនមានទីបំផុត ១ ។

ប្រាកដណាស់ការកំណត់អាកាសថា ក្នុងទិសបូព៌ា ឬក្នុងទិសបស្ចិម ទិសឧត្តរ ទិសទក្សិណ មានប៉ុណ្ណោះរយយោជន៍ ឬមានប៉ុណ្ណោះពាន់យោជន៍រមែងមិនបាន (សាកល្បងកំណត់ផ្លូវអាកាស ទិសខាងកើត ថាមានប៉ុន្មានយោជន៍ ប៉ុន្មានរយយោជន៍ ប៉ុន្មានពាន់យោជន៍ ក៏មិនមានអ្នកណាកំណត់បានសូម្បីទិសឯទៀតក៏ដោយមានន័យដូចគ្នា) សូម្បីនឹងយកញញ្ជរដែកប៉ុនភ្នំសិនេរុ ដំផែនដីចែកជា ២ ចំណែក ហើយគ្រវែងញញ្ជរដែកនោះ ធ្លាក់ចុះទៅក្រោមតាមចន្លោះកណ្តាលដោយពិតរក អ្វីទ្រទ្រួលមិនមាន ឈ្មោះថាអាកាសជាអនន្ត គឺមិនមានទីបំផុតឡើយយ៉ាងនេះ ។

ការកំណត់ចក្រវាឡទាំងឡាយថា មានប៉ុន្មានរយ ប៉ុន្មានពាន់ ឬប៉ុន្មានសែនចក្រវាឡ រមែងមិនបាន ពិតណាស់សូម្បីបើថាទេវតា

មហាព្រហ្មទាំង ៤ កើតក្នុងអកនិដ្ឋភព (រូបព្រហ្មភូមិជាន់សុទ្ធាវាសជាន់ទី ៥ ដែលជារូបព្រហ្មភូមិជាន់ខ្ពស់បំផុត) អ្នកមានល្បឿន រហ័ស អាចហោះរំលងដល់សែនចក្រវាឡ ទៅបានត្រឹមតែ ១ រយៈពេល ស្មើនឹងកូនសរដែលល្បឿនយ៉ាងរហ័សនៃនាយខ្មាន់ធ្នូដ៏មានកម្លាំងខ្លាំងរំលងម្លប់នៃដើមត្នោតខាងទទឹងតែប៉ុណ្ណោះ និងគប្បីហោះដោយល្បឿននោះដោយគិតថា យើងនឹងមើលព្រំដែននៃចក្រវាឡ ទេវមហាព្រហ្មទាំងនោះ មិនទាន់ទាំងបានឃើញព្រំដែននៃចក្រវាឡផង គឺគប្បីនឹងបរិនិព្វានមុនដោយពិត ចក្រវាឡទាំងឡាយទើបឈ្មោះថាជាអនន្ត មិនមានទីបំផុតយ៉ាងនេះ ។

ក៏ប្រមាណនៃសត្វដែលនៅក្នុងទឹក និងដែលនៅលើគោក ក្នុងចក្រវាឡទាំងឡាយថា មានប្រមាណប៉ុណ្ណោះ រមែងមិនបាន សត្តនិកាយទើបឈ្មោះថា អនន្ត (មិនមានទីបំផុត) យ៉ាងនេះ ។

ពុទ្ធញ្ញាណ ឈ្មោះថា អនន្តប្រាកដជាងអនន្តទាំង ៣ នោះទៅទៀត ។

អាកាសក៏ឃើញស្រាប់ហើយថា មិនមានទីបំផុត មិនមាននរណាអាចនឹងវាស់ថាប៉ុន្មានរយ ប៉ុន្មានពាន់ ប៉ុន្មានសែនយោជន៍បានឡើយ ឬសូម្បីចក្រវាឡក៏មិនមាននរណាអាចនឹងរាប់បានថា ទាំងអស់មានប៉ុណ្ណា អ្នកណាចង់នឹងរាប់ផ្តាយ រាប់ចក្រវាឡ ក៏មិនមានថ្ងៃបានសម្រេចបានឡើយ ព្រោះថាចក្រវាឡវាអនន្តមិនមានទីបំផុត ឬសូម្បីសត្តនិកាយ គឺពពួកសត្វទាំងឡាយ ដែលនៅក្នុងចក្រវាឡ ក៏មិនមាននរណាអាចធ្វើស្តិតិថាមានចំនួនប៉ុណ្ណាបានឡើយ ទាំងមនុស្ស ទាំងទេវតា ទាំងព្រហ្ម

ទាំងសត្វគោក ទាំងសត្វទឹក ទាំងសត្វក្នុងអបាយ តែពុទ្ធញាណឈ្មោះ ថាជាអនន្ត គឺមិនមានទីបំផុតក្រៃលែងជាងអនន្តទាំង ៣ នោះគឺបណ្តាសត្វ ដែលរកប្រមាណមិនបាន ក្នុងចក្រវាឡដែលរកប្រមាណមិនបាន ក្នុង អាកាសដែលរកប្រមាណមិនបាន យ៉ាងនេះ ។

នៅពេលគិតដល់សត្វទាំងឡាយ ដែលមាននៅក្នុងចក្រវាឡយ៉ាង សន្ធឹកសន្ធាប់រាប់មិនអស់ហើយ ចិត្តរបស់សត្វទាំងឡាយទាំងនោះ តើនឹងវិចិត្រផ្សេង ៗ គ្នាច្រើនដល់ត្រឹមណា ?

កុសលចិត្តដែលជាកាមាវចរ សហគតដោយសោមនស្ស (កើត ព្រមនឹងសោមនស្សវេទនា) ជាញាណសម្បយុត្ត ជាអសង្ខារិក (កើត ឡើងដោយមិនអាស្រ័យការដឹកនាំ) រមែងកើតដល់សត្វនីមួយ ៗ សន្ធឹក សន្ធាប់ កាលសត្វមានចំនួនច្រើន ចិត្តក៏កើតឡើងកាន់តែច្រើនដួង ។

កុសលចិត្តមិនមែនមានតែ ១ ដួងទេ កុសលចិត្តដែលកើត សូម្បីដោយប្រភេទ ជាកាមាវចរកុសលដែលកើតព្រមនឹងបញ្ញា គឺញាណ សម្បយុត្ត និងជាអសង្ខារិក គឺមានកម្លាំងខ្លាំងក្លានោះ ក៏មិនមែនមាន ចំពោះតែ ១ ដួងទេ ត្រូវប្រព្រឹត្តទៅផ្សេង ៗ តាមចំនួននៃសត្វទាំងឡាយ ដែលចិត្តរបស់ម្នាក់ ៗ កើតឡើងត្រឹមតែ ១ ខណៈ ។ ទោះជាកុសលចិត្ត នឹងកើតឡើងច្រើនដួងតាមចំនួននៃសត្វទាំងឡាយក៏ដោយ តែកុសលចិត្ត ទាំងពួងនោះដូចតែគ្នា ដោយអត្ថថា ជាកាមាវចរ ដោយអត្ថថា សហគត

ដោយសោមនស្ស ដោយអត្ថថា ជាញាណសម្បយុត្ត ដោយអត្ថថា ដោយហានៈជាអសង្ខារិក ដូចគ្នា ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គកំណត់កាមាវចរកុសលចិត្ត ទាំងពួងដែលកើតដល់សត្វទាំងឡាយ រកប្រមាណមិនបាន ក្នុងចក្រវាឡទាំងឡាយ ហើយដែលរកប្រមាណមិនបានយ៉ាងនេះ ដោយព្រះសព្វញ្ញុតញ្ញាណ តែព្រះអង្គទ្រង់បង្រួមឱ្យត្រឹមតែជា ៨ ចំណែកប៉ុណ្ណោះ ព្រះអង្គសម្តែងថាចិត្តទាំងនោះ (កាមាវចរកុសលចិត្ត) មាន ៨ ដួង មិនលើសមិនខ្វះដោយអត្ថ ដែលបណ្ឌិតគប្បីឃើញផងដែរ (គឺទំនាស់មិនបាន) ។

សម្តែងថាសូម្បីដល់កាមាវចរកុសលចិត្ត នឹងមានច្រើនយ៉ាងណាក៏ដោយ តែព្រះសម្មាសម្ពុទ្ធក៏ព្រះអង្គទ្រង់រាប់ និងទ្រង់ចាត់កាមាវចរកុសលជាមហាកុសល ៨ ដួង ឬ ៨ ប្រភេទប៉ុណ្ណោះ ដែលនរណាក៏មិនអាចនឹងជំទាស់បាន ដោយសេចក្តីផ្សេងគ្នាត្រង់ឧបេក្ខាវេទនា និងសោមនស្សវេទនា ដោយសេចក្តីផ្សេងគ្នាត្រង់ប្រកបដោយបញ្ញា និងមិនប្រកបដោយបញ្ញា ដោយសេចក្តីផ្សេងគ្នាត្រង់ជាអសង្ខារិក និងសសង្ខារិក ។

ដូច្នេះ កាមាវចរកុសល ឬមហាកុសល ៨ ដួង គឺ

ដួងទី ១ សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ

ដួងទី ២ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ

ដួងទី ៣ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ដួងទី ៤ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
ដួងទី ៥ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
ដួងទី ៦ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
ដួងទី ៧ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ដួងទី ៨ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

តើធ្លាប់ងងុយដេកទេ ធ្លាប់អស់កម្លាំងទេ ធ្លាប់ធុញទ្រាន់ទេ ? ខណៈខ្លះចិត្តគិតនឹងធ្វើកុសលយ៉ាងនេះ យ៉ាងនោះ ហើយក៏ស្រាប់តែអស់កម្លាំងទៅ ឬថាក៏ងងុយដេកឡើង តើសតិនឹងរលឹកលក្ខណៈសភាពនៃចិត្តក្នុងខណៈនោះទេ ? បើមិនរលឹកទេ ក៏ជាយើង ។ សេចក្តីងងុយដេកមានពិត សេចក្តីរួញរា សេចក្តីអស់កម្លាំងចិត្ត សេចក្តីនឿយណាយ សេចក្តីដឹងខ្លួន ខ្សោយ មានពិត បើសតិមិនរលឹកដឹងលក្ខណៈនៃសភាវធម៌ទាំងនោះតាមសេចក្តីពិតទេ ក៏មិនដឹងថា សភាវធម៌នោះ ។ មិនមែនសត្វ បុគ្គល តួខ្លួន មិនមែនយើងដែរ ដែលត្រឹមតែជាលក្ខណៈនៃចិត្ត ដែលកើតឡើង ព្រោះហេតុបច្ច័យហើយរលត់ទៅប៉ុណ្ណោះ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងចិត្តដោយប្រភេទផ្សេង ។ ដូចគ្នា ដោយប្រភេទដែលជាអសង្ខារិក និងសសង្ខារិក លោភមូលចិត្តដែលជាអសង្ខារិកក៏មាន ជាសសង្ខារិកក៏មាន ទោសមូលចិត្តដែលជាអសង្ខារិកក៏មាន សសង្ខារិកក៏មាន កុសលចិត្តដែលជាអសង្ខារិកក៏មាន សសង្ខារិកក៏មាន ខណៈដែល

សតិរលឹកដឹងលក្ខណៈនៃសភាវធម៌ទាំងនោះ ក៏ដឹងថាជានាមធម៌ មិនមែនជារូបធម៌ ។

សំណួរសាឡើងវិញ

១-សង្ខារធម៌ សង្ខារក្ខន្ធ អភិសង្ខារ អសង្ខារិក សសង្ខារិក គឺអ្វី ?

២-លោកមូលចិត្ត ៨ ដួង និងមហាកុសលចិត្ត ៨ ដួងមានអ្វីដូចគ្នា និងមានអ្វីផ្សេងគ្នា ?

មេរៀនទី ១៣

ចិត្តផ្សេងគ្នាដោយសម្បយុត្តធម៌ដែលជា " ហេតុ "

សភាវធម៌ដែលជាសង្ខារធម៌នោះ នឹងកើតឡើងមកងាយ ។ ខ្លួនឯង ដោយមិនអាស្រ័យបច្ច័យអ្វីណាឡើយ នោះមិនបានឡើយ ។ បរមត្ថធម៌ដែលជាសង្ខារធម៌មាន ៣ គឺចិត្ត ចេតសិក រូប ។ ចិត្តអាស្រ័យចេតសិកជាបច្ច័យ ទើបកើតឡើង និងចិត្តដួងខ្លះក៏អាស្រ័យចេតសិក និងរូបជាបច្ច័យកើតឡើង ។ រូបអាស្រ័យរូបជាបច្ច័យទើបកើតឡើង និងរូបក៏អាស្រ័យចិត្ត និងចេតសិក និងរូបជាបច្ច័យទើបកើតឡើង ។ ដូច្នេះ ចិត្តផ្សេងគ្នាដោយហេតុ គឺចិត្តដួងខ្លះក៏រួមនឹងចេតសិកដែលជាហេតុកើតឡើង និងចិត្តដួងខ្លះក៏កើតរួមនឹងចេតសិក ដែលមិនមែនហេតុ ។

បរមត្ថធម៌ដែលជាហេតុនោះ បានដល់ចេតសិក ៦ ដួង ប៉ុណ្ណោះ គឺ

លោភចេតសិក ជាលោភហេតុ ១
ទោសចេតសិក ជាទោសហេតុ ១
មោហចេតសិក ជាមោហហេតុ ១
} រួមជាអកុសលហេតុ ៣



ក្រៅពីចេតសិក ៦ ដួង នេះហើយ សភាវធម៌ដទៃទៀតទាំងអស់ មិនមែនហេតុប្បច្ច័យ ។ ចេតសិកដទៃ ៗ ដែលកើតរួមនឹងចិត្តនោះ ៗ ក៏ជាបច្ច័យឱ្យចិត្តកើតឡើងដែរ តែមិនមែនហេតុប្បច្ច័យ គឺមិនមែនជាបច្ច័យដោយជាហេតុ ព្រោះហេតុប្បច្ច័យ ត្រឹមតែជាបច្ច័យមួយក្នុងសភាវធម៌ទាំងឡាយ ដែលជាបច្ច័យផ្សេង ៗ គ្នាដល់ ២៤ បច្ច័យ (ដោយប្រភេទបច្ច័យធំ ៗ) ។ ចេតសិក ៦ ដួង ដែលជាហេតុនោះ ឧបមាដូចជាឫសកែវនៃដើមឈើដែលជាហេតុឱ្យដើមឈើនោះចម្រើនលូតលាស់ធំធាត់ មានផ្កា មានផ្លែសន្ធឹកសន្ធាប់ យ៉ាងណា ចេតសិកដែលជាហេតុ ៦ ហេតុនេះ កាលកើតឡើងក៏ធ្វើឱ្យសភាវធម៌ទាំងឡាយ ចម្រើន លូតលាស់ និងផលិតផលផ្សេង ៗ ចម្រើនឡើងជារឿយ ៗ ។ អ្នកដែលមិនមែនជាព្រះអរហន្ត នៅមានអកុសលហេតុ និងកុសលហេតុ កាលជាព្រះអរហន្តហើយ រំលត់ទាំងអកុសលហេតុ និងទាំងកុសលហេតុ អលោភចេតសិក និងអទោសចេតសិក និងបញ្ញា (អមោហៈ) ចេតសិកដែលកើតនឹងចិត្តរបស់

ព្រះអរហន្ត ទើបជាអព្យាកតហេតុ គឺមិនមែនអកុសលហេតុ និង កុសលហេតុ ។

សភាវធម៌ដែលជាអព្យាកតធម៌នោះ ជាសភាវធម៌ដែលមិនមែន កុសល មិនមែនអកុសល ដូច្នេះ វិបាកចិត្ត កិរិយាចិត្ត វិបាកចេតសិក កិរិយាចេតសិក រូប និងនិព្វាន ទើបជាអព្យាកតធម៌ ព្រោះមិនមែនកុសល មិនមែនអកុសល ។

ហេតុ ៦ ចំណែកជា ២ ប្រភេទ គឺ

អកុសលហេតុ ៣ បានដល់ លោភចេតសិក ១ ទោសចេតសិក ១ មោហចេតសិក ១

សោភណហេតុ ៣ បានដល់ អលោភចេតសិក ១ អទោសចេតសិក ១ បញ្ញាចេតសិក ១

គួរសង្កេតថា មិនប្រើពាក្យថា កុសលហេតុ ៣ ទៅជាប្រើពាក្យថា សោភណហេតុ ៣ ព្រោះកុសលហេតុជាហេតុឱ្យកើតកុសលវិបាក ដែលជាផល តែសោភណហេតុ ដែលជាហេតុដែលល្អនោះ កើតនឹងកុសលចិត្តក៏មាន កុសលវិបាកចិត្តក៏មាន និងសោភណកិរិយាចិត្តក៏មាន **សោភណហេតុ ទើបមិនកើតមានចំពោះតែនឹងកុសលចិត្តប៉ុណ្ណោះទេ** ។

បរមត្ថធម៌ ៤ គឺចិត្ត ចេតសិក រូប និព្វាន នៅពេលពោលដោយហេតុ

ចិត្ត មិនមែនហេតុ

ចេតសិក ដែលជាហេតុមាន ៦ ចេតសិកដទៃទៀតទាំងអស់ (៤៦ ចេតសិក) មិនមែនហេតុ

រូប មិនមែនហេតុ

និព្វាន មិនមែនហេតុ

ធម៌ដែលមិនមែនហេតុនោះ ភាសាបាលីហៅថានហេតុ ដូច្នោះ ធម៌ទាំងឡាយទើបចំណែកជា ២ ពួក គឺហេតុ និងនហេតុ ។

ចេតសិក ៦ ដួង ជាហេតុ ចិត្ត រូប និព្វាន និងចេតសិក ៤៦ ដួងទៀត ជានហេតុ ។

ចិត្ត និងចេតសិក ៤៦ ដួងទៀត ជានហេតុ គឺមិនមែនហេតុ តែចិត្ត និងចេតសិកដួងខ្លះ ក៏មានចេតសិក ដែលជាហេតុកើតរួមដែរ ចិត្ត និងចេតសិក ក៏មិនមានចេតសិក ដែលជាហេតុកើតរួមដែរ ចិត្ត និងចេតសិកណាមិនមានចេតសិកដែលជាហេតុ ៦ ដួង កើតរួមផងទេ ចិត្ត ចេតសិកនោះ ជា**អហេតុកចិត្ត និងជាអហេតុកចេតសិក** ចិត្ត និងចេតសិកណាមានចេតសិកដែលជាហេតុកើតរួមផង ចិត្ត និងចេតសិកនោះជា **សហេតុ-កចិត្ត និងសហេតុកចេតសិក** ។

ចក្ខុវិញ្ញាណ ដែលកំពុងឃើញនូវអ្វីដែលប្រាកដនោះ មានចេត-សិកកើតជាមួយត្រឹមតែ ៧ ដួង **គឺផស្សចេតសិក** ធ្វើកិច្ចប៉ះខ្ទប់រូបារម្មណ៍ ដែលប៉ះខ្ទប់ចក្ខុបសាទ **វេទនាចេតសិក** ធ្វើកិច្ចដឹងខ្លួនព្រងើយ ។ ជាឧបេក្ខាវេទនា (**អទុក្ខមសុខ**) **សញ្ញាចេតសិក** ធ្វើកិច្ចចាំរូបារម្មណ៍ **ចេតនាចេតសិក** ធ្វើកិច្ចតាំងចិត្ត ដឹកនាំចិត្ត តឿនចិត្ត និងចេតសិកដែលកើតរួមជាមួយគ្នាឱ្យសម្រេចកិច្ចនោះ ។ **ជីវិតិន្ទ្រិយចេតសិក** ធ្វើកិច្ចទំនុកបម្រុងចិញ្ចឹមសហជាតធម៌ គឺចិត្ត និងចេតសិកទាំងឡាយឱ្យតម្រង់នៅក្នុងបិតិខណៈ **ឯកគ្គតាចេតសិក** ធ្វើកិច្ចតាំងមាំក្នុងអារម្មណ៍ដែលប្រាកដ **មនសិការចេតសិក** ធ្វើកិច្ចដាក់ចិត្ត តម្រង់ចិត្តក្នុងរូបារម្មណ៍នោះ ។ ចេតសិក ៧ ដួងនេះមិនមែនចេតសិកដែលជាហេតុ ៦ ដូច្នោះ ចក្ខុវិញ្ញាណ ទើបជាអហេតុកចិត្ត ចំណែកលោភមូលចិត្ត ដែលកើតក្រោយពីចក្ខុវិញ្ញា-ណនោះ មានហេតុចេតសិកកើតរួមផង ២ ហេតុ គឺមាន លោភចេតសិក សភាពដែលពេញចិត្ត ជាប់ជំពាក់ក្នុងសភាវៈដែលប្រាកដកើតរួមផង និងមានមោហចេតសិកកើតរួមផងដែរ លោភមូលចិត្ត ទើបជាសហេតុកចិត្ត ។

នៅពេលពោលដោយហេតុ ធម៌ទាំងឡាយចំណែកបានជា ២ ពួក គឺហេតុ និងនហេតុ សហេតុក និង អហេតុក បានដូចនេះ គឺ

និព្វាន និងរូប ជានហេតុ និងអហេតុក

ចិត្ត ជានហេតុ និងដួងខ្លះជាសហេតុក ដួងខ្លះ ជាអហេតុក

ចេតសិក ៤៦ ជានហេតុ និងដួងខ្លះជាសហេតុក ដួងខ្លះ ជាអហេតុក

ចេតសិក ៦ គឺលោភចេតសិក ទោសចេតសិក មោហចេតសិក អលោភចេតសិក អទោសចេតសិក បញ្ញាចេតសិក ជាហេតុ និងជាសហេតុក វៀរមោហចេតសិក ដែលកើតជាមួយនឹងមោហមូលចិត្ត ព្រោះ**មោហចេតសិក ដែលកើតនឹងមោហមូលចិត្ត ជាអហេតុក ។**

លោភចេតសិក ជាសហេតុក ព្រោះត្រូវមានមោហចេតសិកកើតរួមជាមួយគ្រប់ពេល បើមោហចេតសិកមិនកើត លោភចេតសិកក៏កើតមិនបាន ដូច្នេះ លោភចេតសិកទើបជាសហេតុក ព្រោះមានមោហចេតសិកកើតរួមជាមួយគ្រប់ពេល ។

ទោសចេតសិក ក៏ជាសហេតុក ដោយន័យតែមួយដូចលោភចេត-សិក ។

មោហចេតសិក ដែលកើតនឹងលោភចេតសិកក្នុងលោភមូលចិត្ត ជាសហេតុក ព្រោះមានលោភចេតសិក ដែលជាហេតុកើតរួមជាមួយផងដែរ ។

មោហចេតសិក ដែលកើតនឹងទោសចេតសិកក្នុងទោសមូលចិត្ត ជាសហេតុក: ព្រោះមានទោសចេតសិក ជាហេតុកើតរួមជាមួយផងដែរ ។

មោហចេតសិកដែលកើតនឹងមោហមូលចិត្ត ជាអហេតុក: ព្រោះមិនមានលោភចេតសិក និងទោសចេតសិកកើតរួមផង ។

ផស្សចេតសិក ជានហេតុ តែផស្សចេតសិកកើតជាមួយនឹងចិត្ត គ្រប់ដួង ប្រសិនបើចិត្តដួងណាកើតរួមជាមួយនឹងចេតសិកដែលជាហេតុណាមួយក្នុងហេតុ ៦ ផស្សចេតសិកនោះក៏ជាសហេតុកៈ បើចិត្តដួងណាជាអហេតុកៈ គឺមិនមានចេតសិក ៦ ដែលជាហេតុកើតរួមផង ផស្សចេតសិកដែលកើតនឹងអហេតុកចិត្តនោះក៏ជាអហេតុកៈដែរ ដូច្នេះ ផស្សចេតសិកទើបជានហេតុ និងខណៈខ្លះក៏ជាសហេតុកៈ ខណៈខ្លះក៏ជាអហេតុកៈ ។

ជីវិតរបស់អស់លោកអ្នកគ្រប់គ្នាក្នុងមួយថ្ងៃ ៗ នោះ មានទាំងសហេតុកចិត្ត និងអហេតុកចិត្ត តែកាលមិនបានស្តាប់ព្រះធម៌ ក៏មិនជ្រាបថា ខណៈណាជាសហេតុកចិត្ត និងខណៈណាជាអហេតុកចិត្ត ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងសភាពចិត្តមួយខណៈ ៗ ទុកយ៉ាងណ្ហិតថា ចិត្តខណៈណាជាអហេតុកចិត្ត ខណៈណាជាសហេតុកចិត្ត និងចិត្តដែលជាសហេតុកចិត្តនោះ កើតរួមនឹងហេតុប៉ុន្មានហេតុ និងមានចេតសិកកើតរួមជាមួយផងប៉ុន្មានដួង ។

មោហមូលចិត្តមានមោហហេតុកើតរួមផងតែមួយហេតុ ទើបជាឯកហេតុកៈ ។

លោភមូលចិត្តកើតរួមនឹង ២ ហេតុ គឺមោហហេតុ និងលោភហេតុ ទើបជាទ្វិហេតុកៈ ។

ទោសមូលចិត្តកើតរួមនឹង ២ ហេតុ គឺមោហហេតុ និងទោសហេតុ ទើបជាទ្វិហេតុកៈ ។

សម្រាប់កុសលចិត្តនោះ ក៏ត្រូវមានសោភណហេតុកើតរួមផងដែរ បើមិនដូច្នោះទេ ក៏ជាកុសលចិត្តមិនបាន ។ កុសលចិត្តមាន ២ ប្រភេទ គឺកុសលចិត្តដែលមិនកើតរួមជាមួយនឹងបញ្ញាចេតសិក និងកុសលចិត្តដែលកើតរួមជាមួយនឹងបញ្ញាចេតសិក ដូច្នោះ កុសលចិត្តដែលមិនកើតរួមនឹងបញ្ញា នឹងមានចេតសិកដែលជាហេតុកើតរួមផង ២ ហេតុ គឺ អលោភហេតុ និងអទោសហេតុទើបជាទ្វិហេតុកៈ និងកុសលចិត្តដែលកើតរួមនឹងបញ្ញានឹងមានចេតសិកដែលហេតុកើតរួមជាមួយផង ៣ ហេតុ គឺ អលោភហេតុ អទោសហេតុ និងអមោហហេតុ ទើបជាតិហេតុកៈ កុសលចិត្ត មិនជាឯកហេតុកៈឡើយ ព្រោះត្រូវមានទាំងអលោភចេតសិក និងអទោសចេតសិកកើតរួមផងគ្រប់ពេល ទើបនឹងជាកុសលចិត្តបាន ។

ពាក្យថា **ហេតុ** និងពាក្យថា **បច្ច័យ** តើផ្សេងគ្នាយ៉ាងណា ?

បច្ច័យ ជាសភាវធម៌ដែលមានឧបការៈទំនុកបម្រុង ឱ្យសភាវធម៌ដទៃកើតឡើង ឬតម្រង់តាំងនៅតាមសមគួរដល់ប្រភេទនៃបច្ច័យនោះ ។ ដូចជា ផស្សចេតសិក មិនមែនលោភចេតសិក តែផស្សចេតសិកក្តី លោភចេតសិកក្តី ជាបច្ច័យទំនុកបម្រុងឱ្យធម៌ដទៃ គឺចិត្ត ចេតសិក និងរូបកើតឡើងបាន តែកាលណាសភាពលក្ខណៈ និងកិច្ចនៃផស្សចេតសិក ផ្សេងពីសភាព

លក្ខណៈ និងកិច្ចរបស់លោភចេតសិក ផស្សចេតសិកទើបជាសភាពបច្ច័យ ដែលផ្សេងពីលោភចេតសិក ។

ផស្សចេតសិក ជាបច្ច័យដោយ ជា**អាហារប្បច្ច័យ** អាហារជាសភាវធម៌ដែលនាំមកនូវផល តែមិនមាំទាំដល់ការធ្វើឱ្យលូតលាស់ សម្បូរដូចយ៉ាងឫសកែវនៃដើមឈើទេ ចំណែកសភាវធម៌ដែលជាហេតុ នោះជាបច្ច័យដោយភាពជាហេតុ ដែលឧបមាដូចឫសកែវ ដើមឈើនឹងចម្រើនធំធាត់ដោយមានតែឫសកែវម្យ៉ាងប៉ុណ្ណោះ មិនបាន ត្រូវមានដី ទឹក ជាអាហារ ប៉ុន្តែប្រសិនបើដាច់ឫសកែវហើយនោះ ដី ទឹក ក៏ធ្វើឱ្យដើមឈើចម្រើនធំធាត់មិនបាន ។ ដើមឈើដែលមានឫសកែវ ព្រមនឹងពូជ ដែលមិនមានឫសកែវនោះ រមែងចម្រើនលូតលាស់សម្បូរ ព្រោះបច្ច័យផ្សេងគ្នាយ៉ាងណា ចេតសិកដទៃ និងសភាវធម៌ដទៃ ក្រៅពីចេតសិកដែលជាហេតុ ៦ ក៏ជាបច្ច័យដោយជាបច្ច័យដទៃ មិនមែនដោយជាហេតុបច្ច័យ ។

ក្នុងគម្ពីរបដ្ឋាន ដែលជាគម្ពីរទី ៧ ជាគម្ពីរចុងក្រោយនៃព្រះអភិធម្មបិដកនោះ សម្តែងសភាវធម៌ទាំងឡាយដោយភាពជាបច្ច័យដល់គ្នានឹងគ្នា ដោយប្រភេទនៃបច្ច័យផ្សេង ៗ ។ បច្ច័យដំបូង គឺហេតុប្បច្ច័យ សម្តែងឱ្យឃើញសេចក្តីសំខាន់ នៃសភាវធម៌ដែលជាហេតុ ។ ក្នុងបុណ្យសព នៅពេលព្រះសង្ឃ លោកសូត្រធម៌ព្រះអភិធម្ម ផ្តើមដំបូងដោយ **ហេតុប្បច្ចយោ** គឺលោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ

អទោសហេតុ អមោហហេតុ ដើម្បីដាស់តឿនឱ្យដឹងថា សភាវធម៌ដែលជាតួហេតុ ដែលនឹងឱ្យកើតផល កើតភព កើតជាតិនោះ បានដល់ចេតសិក ៦ ដួង គឺលោភចេតសិក ទោសចេតសិក មោហចេតសិក អលោភចេតសិក អទោសចេតសិក និងបញ្ញាចេតសិក ។

ការពិតសភាវធម៌មួយប្រភេទ ៗ មានភាពសំខាន់ចំពោះនៃខ្លួនព្រះដ៏មានព្រះភាគទ្រង់មិនបានសម្តែង ចំពោះហេតុប្បច្ច័យត្រឹមតែមួយបច្ច័យនោះទេ ទ្រង់មិនបានសម្តែងចំពោះអារម្មណ៍ដែលជាបច្ច័យឱ្យចិត្តកើតឡើង ដឹងអារម្មណ៍នោះ ដោយអារម្មណ៍នោះ ជា**អារម្មណប្បច្ច័យ** ដល់ចិត្តត្រឹមតែមួយបច្ច័យនោះទេ ព្រះមានព្រះភាគទ្រង់សម្តែង បច្ច័យផ្សេង ៗ ដោយល្អិតគ្រប់គ្រាន់ ដោយប្រភេទបច្ច័យធំ ៗ ២៤ បច្ច័យ និងទ្រង់សម្តែងបច្ច័យតូច ៗ ខ្លះ ក្នុងបច្ច័យធំ ២៤ បច្ច័យនោះផងដែរ ។

ចក្ខុបសាទរូបកើតឡើងព្រោះបច្ច័យដទៃ ៗ មិនមែនដោយហេតុ-ប្បច្ច័យ និងចក្ខុបសាទក៏ជាបច្ច័យដែរ ដោយជាសភាវៈដែលជាធំ ជាឥន្ទ្រិយប្បច្ច័យ គឺជាបច្ច័យដោយជាសភាវៈដែលជាធំក្នុងកិច្ចនាទីនៃខ្លួន ។ ចក្ខុបសាទជាចក្ខុន្ទ្រិយ ជារូបដែលមានសភាពជាធំក្នុងការធ្វើជាបច្ច័យឱ្យចក្ខុវិញ្ញាណកើតឡើងឃើញសភាវៈដែលប្រាកដតាមផ្លូវភ្នែក បើមិនមានចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ និងកាយបសាទ រូបរាងកាយនេះនឹងដូចជាអ្វី គឺដូចជាដើមឈើ មិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ដូច្នេះ បសាទរូបទាំង ៥

នេះ ទើបជាបច្ច័យដោយជាឥន្ទ្រិយប្បច្ច័យ គឺជាធំចំពោះក្នុងកិច្ចនៃខ្លួន ដូច ចក្ខុបសាទរូប ជាធំក្នុងការប៉ះខ្ទប់រូបារម្មណ៍ ជាបច្ច័យឱ្យចក្ខុវិញ្ញាណកើត ឡើងឃើញសភាវដែលប្រាកដតាមផ្លូវភ្នែក ព្រោះរូបដទៃមិនអាចធ្វើកិច្ច នេះបាន និងអ្វីដែលប្រាកដតាមផ្លូវភ្នែក នឹងប្រាកដជាក់ច្បាស់ ឬមិន ច្បាស់ក៏ស្រេចតែសភាពថ្លានៃចក្ខុបសាទរូប ដែលមិនសម្រេចដោយ ចេតនា ឬសេចក្តីត្រូវការ សេចក្តីប្រាថ្នារបស់អ្នកណាឡើយ តែសម្រេច ដោយឥន្ទ្រិយប្បច្ច័យនៃការឃើញ គឺចក្ខុបសាទរូប ។

សភាវធម៌គ្រប់ប្រភេទ ជាបច្ច័យឱ្យសភាវធម៌ដទៃកើត ដោយជា បច្ច័យផ្សេង ។ លោភចេតសិក ទោសចេតសិក មោហចេតសិក និង អលោភចេតសិក អទោសចេតសិក បញ្ញាចេតសិក ជាបច្ច័យដោយជា ហេតុ ។ ក្នុងមួយថ្ងៃ ។ នោះ មានអកុសលហេតុកើតច្រើន កុសលហេតុ ក៏មានខ្លះ តែតាមការប្រៀបធៀបនោះ កុសលហេតុតិចជាងអកុសលហេតុ ណាស់ ។

តើកាលណាទៅ កុសលហេតុនឹងសន្សឹម ។ ចម្រើនឡើង ។ រហូត ដល់មានកម្លាំងខ្លាំងជាងចំណែកអកុសលហេតុអស់នោះ ? គឺត្រូវអប់រំ ចម្រើនបញ្ញាដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិត ព្រោះការដឹងលក្ខណៈ នៃ សភាវធម៌តាមសេចក្តីពិតនោះ ជាបញ្ញាចេតសិក ជាអមោហហេតុ ។ ដរាប ណាដែលបញ្ញានោះមិនទាន់ដឹងច្បាស់ក្នុងលក្ខណៈ នៃសភាវធម៌តាម សេចក្តីពិត ហើយអាចមិនឱ្យលោភហេតុ ទោសហេតុ ឬមោហហេតុ

ចម្រើនលូតលាស់សម្បូរទេនោះ ជាការដែលប្រព្រឹត្តទៅមិនបាន មិនមានធម៌ដទៃណាឡើយ ដែលនឹងលះបង់និងរំលត់អកុសលហេតុបានក្រៅពីបញ្ញាដែលជាអមោហហេតុ ។ កាលសិក្សាព្រះធម៌ហើយយល់លក្ខណៈនៃសភាវធម៌ដែលប្រាកដតាមផ្លូវភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្ត ហើយនិងជាអ្នកដែលអប់រំចម្រើនសតិប្បដ្ឋាន កុសលដែលជាអមោហៈ គឺបញ្ញានឹងសន្សឹម ។ ចម្រើនឡើងនៅពេលដឹងច្បាស់អរិយសច្ចធម៌ ជាព្រះសោតាបន្នបុគ្គលពេលណា ពេលនោះ ទើបរំលត់អកុសលធម៌ជាប្រភេទ ។ បាន រហូតទាល់តែនឹងដល់ភាពជាព្រះអរហន្ត ។

អ្នកដែលជាព្រះអរិយបុគ្គល ថ្នាក់ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីនោះ ជា**ព្រះសេក្ខបុគ្គល** ដែលនឹងត្រូវអប់រំចម្រើនបញ្ញាតទៅទៀត ទម្រាំនឹងរំលត់អស់ទាំងអកុសលហេតុ និងកុសលហេតុ ព្រោះបើនៅមានកុសលហេតុ ក៏ជាបច្ច័យឱ្យកើតកុសលវិបាកមិនចេះចប់ ព្រះអរហន្តរំលត់អកុសលហេតុ និងកុសលហេតុហើយនោះ សូម្បីដល់ទៅថា ចិត្តដែលកើតរួមនឹងអលោភៈ អទោសៈ អមោហៈ ក៏ជាអព្យាកតហេតុមិនជាហេតុដែលនឹងឱ្យកើតវិបាកតទៅទៀត តើកាលណានឹងដល់ថ្ងៃនោះ រមែងដល់បានក្នុងថ្ងៃណាមួយ កាលណាព្យាយាមអប់រំចម្រើនបញ្ញាទៅរឿយ ។ អ្នកដែលបន្លុះផល ដូច្នោះ ក្នុងអតីតមានជាច្រើន ប្រសិនបើជាអ្វីដែលប្រព្រឹត្តទៅមិនបានសោះនោះ ក៏នឹងមិនមានអ្នកណា

អាចបន្លុះផល ដូច្នេះបានឡើយ តែផលនោះរមែងមិនសម្រេច តាមដែលសង្ឃឹមប្រាថ្នាបានរហ័សនោះទេ ត្រូវតែសមគួរដល់ហេតុ គឺកាលបញ្ញានៅមិនទាន់កើត នៅមិនទាន់ចម្រើនឡើង ក៏រំលត់កិលេសមិនបាន ហើយបញ្ញា គឺត្រូវកើតឡើង ចម្រើនឡើងតាមលំដាប់ថ្នាក់ ដែលអាចប្រចក្សច្បាស់លក្ខណៈនៃសភាវធម៌តាមសេចក្តីពិត រហូតទាល់តែរលត់កិលេសបានពិត ។ ។

ដូច្នោះ គួររលឹកជានិច្ចថាការសិក្សាឱ្យយល់រឿងចិត្ត ចេតសិក រូបនោះ ក៏ដើម្បីអប់រំចម្រើនសតិប្បដ្ឋានដឹងលក្ខណៈនៃសភាវធម៌ដែលជាចិត្ត ចេតសិក រូប ដែលកើតឡើងប្រាកដមួយខណៈ ។ តាមសេចក្តីពិតដោយមិនឃ្លៀងឃ្លាតចេញពីព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង និងទ្រង់សម្តែង ។ បើសិក្សាយល់ចូលចិត្តម្យ៉ាង តែបដិបត្តិផ្សេងម្យ៉ាងទៀត ដោយមិនដឹងត្រង់លក្ខណៈនៃសភាវធម៌តាមសេចក្តីពិតដែលបានសិក្សា ដូច្នោះក៏នឹងមិនអាចរំលត់កិលេសបានឡើយ ។

សម្រាប់អកុសលហេតុនោះ នឹងជាជាតិដទៃមិនបានឡើយ មិនថាលោភចេតសិក ទោសចេតសិក មោហចេតសិក កើតឡើងខណៈណាខណៈនោះក៏ជាជាតិអកុសល ជាបច្ច័យឱ្យកើតអកុសលចិត្តក្នុងខណៈនោះ ហើយសន្សំបន្តទៅក្នុងអនាគតផងដែរ ។ តែសោភណហេតុ ៣ គឺ អលោភចេតសិក ១ អទោសចេតសិក ១ បញ្ញាចេសិក ១ នោះជាជាតិកុសលក៏មាន ជាជាតិវិបាកក៏មាន ជាជាតិកិរិយាក៏មាន

ព្រោះអលោភចេតសិក អទោសចេតសិក បញ្ញាចេតសិកកើតជាមួយនឹងកុសលចិត្តក៏បាន កើតជាមួយនឹងកុសលវិបាកក៏បាន កើតជាមួយនឹងសោភណកិរិយាចិត្តក៏បាន ។ ពាក្យថា **សោភណ** មានអត្ថន័យទូលំទូលាយជាងពាក្យថា កុសល ព្រោះសោភណធម៌បានដល់សភាវធម៌ដែលជាកុសល ឬជាកុសលវិបាក ឬជាសោភណកិរិយា ។ ដូច្នោះ កាលចំណែកធម៌ទាំងឡាយដោយពួក ៣ ជាកុសលាធម្មា អកុសលធម្មា អព្យាកតាធម្មា ក៏ចំណែកចេតសិកដែលជាហេតុ ៦ ចេញជាហេតុ ៩ គឺ

អកុសលហេតុ ៣ បានដល់	លោភចេតសិក ១
	ទោសចេតសិក ១
	មោហចេតសិក ១
កុសលហេតុ ៣ បានដល់	អលោភចេតសិក ១
	អទោសចេតសិក ១
	បញ្ញាចេតសិក ១
អព្យាកតហេតុ ៣ បានដល់	អលោភចេតសិក ១
	អទោសចេតសិក ១
	បញ្ញាចេតសិក ១

សំណួរសាឡើងវិញ

១ - ហេតុប្បច្ច័យ បានដល់បរមត្ថធម៌អ្វី ?

២ - អព្យាកតហេតុ គឺអ្វី ? បានដល់អ្វី ?

៣ - អព្យាកតធម៌ គឺអ្វី ? បានដល់អ្វី ?

៤ - កុសលហេតុ និងសោភណហេតុ តើផ្សេងគ្នាយ៉ាងណា ?

៥ - តើអ្វីជានហេតុខ្លះ ? តើអ្វីជាសហេតុកៈខ្លះ ?

៦ - ហេតុចេតសិកដួងណាជាអហេតុកៈ ដួងណាជាសហេតុកៈ ?

៧ - អកុសលចិត្តណាជាឯកហេតុកៈ និងអកុសលចិត្តណាជាទ្វិហេតុកៈ ?

៨ - កុសលចិត្តជាឯកហេតុកៈ បានទេ ?

៩-ផស្សចេតសិកជាហេតុ ឬនហេតុ ជាអហេតុកៈ ឬសហេតុកៈ
ជាឯកហេតុកៈ ឬទ្វិហេតុកៈ ឬតិហេតុកៈ ?

១០ - ហេតុ ៩ បានដល់អ្វី ?

មេរៀនទី ១៤

ចំណែកចិត្តដោយន័យនៃ **សោភណៈ និងអសោភណៈ**

សោភណធម៌ ជាសភាវធម៌ដែលល្អស្អាត ដែលមិនមែនចំពោះតែកុសលធម៌ប៉ុណ្ណោះទេ សភាវធម៌ដែលល្អស្អាតតែមិនមែនកុសលកម្ម គឺ កុសលវិបាកដែលជាផលរបស់កុសលកម្ម និងសោភណកិរិយា ដែលជាចិត្ត និងចេតសិកចំពោះព្រះអរហន្តរំលត់កុសល និងអកុសលជាសមុច្ឆេទហើយ ។

អសោភណធម៌ ជាសភាវធម៌ដែលផ្ទុយអំពីសោភណធម៌ គឺ មិនមែនសភាវធម៌ដែលល្អស្អាត ដែលមិនមែនចំពោះតែអកុសលប៉ុណ្ណោះទេ ។ **ចិត្ត និងចេតសិកណាដែលមិនមានសោភណចេតសិក កើតរួមជាមួយផងទេ ចិត្ត និងចេតសិកនោះជាអសោភណៈ** ។ ដូច្នោះ ដោយន័យនៃសម្បយុត្តធម៌ដែលចំណែកឱ្យចិត្តផ្សេងគ្នា ជាចិត្តប្រភេទដែលល្អស្អាតជាសោភណៈ និងជាចិត្តប្រភេទដែលមិនល្អស្អាតជាអសោភណនោះ ក៏ចំណែកដោយចេតសិកដែលជាហេតុ ៦ នោះឯង ចេតសិកដែលល្អស្អាតបានដល់អលោភចេតសិក អទោសចេតសិក បញ្ញាចេតសិក ដែលជាសោភណចេតសិកដែលធ្វើឱ្យចិត្តបានល្អស្អាត ។ ដូច្នេះ ការចំណែកចិត្តដោយប្រភេទដែលជាសោភណនិងអសោភណៈ គិតអំពីការចំណែកចិត្ត

ដោយហេតុនុ៎ះឯង ចិត្តណាដែលប្រកបដោយចេតសិក ដែលជាសោភណហេតុ ចិត្តនោះជាសោភណចិត្ត ចិត្តណាមិនប្រកបដោយចេតសិកដែលជាសោភណហេតុ ចិត្តនោះ ជាអសោភណចិត្ត ។

ការសិក្សាបរមត្ថធម៌នោះត្រូវគិត ត្រូវពិចារណាហេតុផល ដោយខ្លួនឯង កាលយល់ហេតុផលដែលត្រឹមត្រូវជាក់ច្បាស់ ក៏នឹងមិនភាន់ច្រឡំឃ្លៀងឃ្លាត សូម្បីក្នុងរឿងសោភណធម៌ និងអសោភណធម៌ ។

អកុសលចិត្តកើតរួមនឹងអកុសលចេតសិក គឺលោភៈ ទោសៈ មោហៈ ដូច្នេះ អកុសលចិត្តមិនមែនសោភណចិត្តយ៉ាងពិតប្រាកដ ។

ចក្ខុវិញ្ញាណ មិនបានកើតរួមនឹងលោភៈ ទោសៈ មោហៈ និងសោភណចេតសិកណា ។ ឡើយ ចក្ខុវិញ្ញាណកើតរួមនឹងចេតសិកតែ ៧ ដួង **គឺផស្សចេតសិក វេទនាចេតសិក សញ្ញាចេតសិក ចេតនាចេតសិក ឯកគ្គតាចេតសិក ជីវិតិន្ទ្រិយចេតសិក មនសិការចេតសិក ដែលចេតសិកទាំង ៧ ដួងនេះ ជាសព្វចិត្តសាធារណចេតសិក គឺជាចេតសិកដែលត្រូវកើតជាមួយចិត្តគ្រប់ដួង ចិត្តនឹងកើតឡើងដោយប្រាសចាកចេតសិក ៧ ដួងនេះ មិនបានឡើយ** មិនថាជាអកុសលចិត្ត កុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត លោកុត្តរចិត្ត ឬចិត្តណា ។ ក្តី ក៏ត្រូវមានចេតសិក ៧ ដួងនេះ កើតរួមផងដែរ ។ ចេតសិក ៧ ដួង ដែលជាសព្វចិត្តសាធារណចេតសិកនេះ ជាអញ្ញសមានាចេតសិក គឺជាចេតសិកដែលកើតនឹងចិត្តណា ក៏ស្មើនឹងចិត្តនោះ ។ កាលកើតជាមួយនឹងអកុសលចិត្ត សព្វចិត្តសាធារណ-

ចេតសិក ៧ ដួងនេះក៏ជាអកុសល កាលកើតជាមួយនឹងកុសលចិត្ត សព្វចិត្តសាធារណចេតសិក ៧ ដួងនេះ ក៏ជាកុសលចេតសិកជាដើម ។

ចក្ខុវិញ្ញាណជាវិបាកចិត្ត ដែលមានសព្វចិត្តសាធារណចេតសិក កើតរួមផងត្រឹម ៧ ដួង ប៉ុណ្ណោះ មិនមានសោភណចេតសិក ឬអកុសលចេតសិកណា ។ កើតរួមផងឡើយ ដូច្នោះ ចក្ខុវិញ្ញាណទើបជាអសោភណចិត្ត តែមិនមែនជាអកុសលចិត្ត ។

ការសិក្សាធម៌នោះ នឹងត្រូវយល់ដោយល្អិតល្អន់ម៉ត់ចត់ សូម្បីតែអកុសលធម៌ និងអសោភណធម៌ ផ្សេងគ្នាយ៉ាងណា ។

អកុសលធម៌ជាសភាវធម៌ដែលអាក្រក់ជាទោស ជាហេតុដែលឱ្យកើតផលជាវិបាក ដែលមិនគួរជាទីពេញចិត្ត ជាទុក្ខ ។ អសោភណធម៌ជាចិត្ត និងចេតសិកដែលមិនមានសោភណចេតសិកកើតរួមជាមួយផង ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងព្រះធម៌ដោយន័យផ្សេង ៗ តាមសភាពនៃធម៌នោះ ។ ដែលអ្នកសិក្សាក៏នឹងត្រូវពិចារណាដោយល្អិតល្អន់ ម៉ត់ចត់ ឱ្យយល់ត្រឹមត្រូវតាមសភាវធម៌នោះ ។ ។ កាលព្រះអង្គទ្រង់សម្តែងដោយប្រភេទរបស់ពួក ៣ គឺកុសលធម៌ អកុសលធម៌ និងអព្យាកតធម៌ ក៏នឹងត្រូវដឹងថា កុសលធម៌ជាសភាវធម៌ដែលជាហេតុឱ្យកើតកុសលវិបាក អកុសលធម៌ ជាសភាវធម៌ដែលជាហេតុឱ្យកើតអកុសលវិបាក និងអព្យាកតធម៌ជាសភាវធម៌ដែលមិនមែនកុសល មិនមែនអកុសល ដូច្នេះ អព្យាកតធម៌ទើបបានដល់ វិបាកចិត្ត និងចេតសិក កិរិយាចិត្ត និងចេតសិក រូប និព្វាន

ដូច្នោះ អព្យាកតធម៌ទើបមិនមែនចំពោះតែចិត្ត និងចេតសិក ដែលជាវិបាក និងកិរិយានោះទេ រូបបរមត្ថ និងនិព្វានបរមត្ថ ក៏ជាអព្យាកតធម៌ ។ រូប និងនិព្វានជាកុសល ឬអកុសលមិនបានព្រោះរូប និងនិព្វាន មិនមែនជាចិត្ត និងចេតសិក ។ ការព្រះអង្គទ្រង់សម្តែងប្រភេទនៃធម៌ ដោយពួក ៣ ទ្រង់សម្តែងបរមត្ថធម៌ទាំង ៤ តែកាលបើព្រះអង្គសម្តែង ដោយជាតិ ៤ សំដៅចំពោះចិត្ត និងចេតសិកប៉ុណ្ណោះ ។

ដោយជាតិ ៤ នោះ អកុសលចិត្ត និងចេតសិក ដែលកើតរួមគ្នាជាអសោភណៈ កុសលចិត្ត និងចេតសិកដែលកើតរួមគ្នាជាសោភណៈ វិបាកចិត្ត និងកិរិយាចិត្តណាមិនមានសោភណចិត្ត ដូចជាអលោភចេតសិក និងអទោសចេតសិកជាដើមកើតរួមផង វិបាកចិត្ត និងកិរិយាចិត្តនោះ ជាអសោភណៈ គឺមិនកើតរួមនឹងសោភណចេតសិក ចំណែកវិបាកចិត្ត និងកិរិយាចិត្តណាមានសោភណចេតសិកកើតរួមជាមួយ វិបាកចិត្ត និងកិរិយាចិត្តនោះ ជាសោភណៈ ។

ចក្ខុវិញ្ញាណកុសលវិបាក ១ ដួង និងចក្ខុវិញ្ញាណអកុសលវិបាក ១ ដួង មានតែសព្វចិត្តសាធារណចេតសិក កើតរួមជាមួយផង ៧ ដួង ប៉ុណ្ណោះ ។

សោតវិញ្ញាណកុសលវិបាក ១ ដួង និងសោតវិញ្ញាណអកុសលវិបាក ១ ដួង មានតែសព្វចិត្តសាធារណចេតសិកកើតរួមជាមួយផង ៧ ដួង ប៉ុណ្ណោះ ។

ឃានវិញ្ញាណកុសលវិបាក ១ ដួង និងឃានវិញ្ញាណអកុសលវិបាក ១ ដួង មានតែសព្វចិត្តសាធារណចេតសិកកើតរួមជាមួយផង ៧ ដួង ប៉ុណ្ណោះ ។

ជិវ្ហាវិញ្ញាណកុសលវិបាក ១ ដួង និងជិវ្ហាវិញ្ញាណអកុសលវិបាក ១ ដួង មានតែសព្វចិត្តសាធារណចេតសិក កើតរួមជាមួយផង ៧ ដួង ប៉ុណ្ណោះ ។

កាយវិញ្ញាណកុសលវិបាក ១ ដួង និងកាយវិញ្ញាណអកុសលវិបាក ១ ដួង មានតែសព្វចិត្តសាធារណចេតសិកកើតរួមជាមួយផង ៧ ដួង ប៉ុណ្ណោះ ។

ទ្វិបញ្ចវិញ្ញាណ ១០ ដួង ទើបជាអសោភណចិត្ត និងចិត្តដ៏ទៃ (ក្រៅពីចិត្ត ១០ ដួងនេះ) ដែលមិនមានសោភណចេតសិកកើតរួមផង ក៏ជាអសោភណចិត្តទាំងអស់ ។ **ដូច្នោះ កុសលវិបាកចិត្តទើបមិនមែនជាសោភណចិត្តគ្រប់ដួង កុសលវិបាកចិត្តដែលមានសោភណចេតសិកកើត**

រួមជាមួយផង ក៏ជាសោភណចិត្ត កុសលវិបាកចិត្តដែលមិនមាន សោភណចេតសិកកើតរួមជាមួយផង ក៏មិនមែនជាសោភណចិត្ត នេះជាភាពផ្សេងគ្នានៃចិត្តមួយ ខណៈ ។ ក្នុងជីវិតប្រចាំថ្ងៃ ។ បដិសន្ធិចិត្តនៃភូមិមនុស្ស និងបដិសន្ធិចិត្តនៃអបាយភូមិ ជាផលរបស់កម្មផ្សេងគ្នា អ្នកដែលបដិសន្ធិក្នុងអបាយភូមិនោះ បដិសន្ធិចិត្តជាអកុសលវិបាកចិត្ត ជាផលរបស់អកុសលកម្ម ទើបកើតក្នុងនរកភូមិ ឬកើតក្នុងបេតវិស័យភូមិ (ប្រេត) ឬកើតក្នុងអសុរកាយភូមិ ឬកើតក្នុងតិរច្ឆានភូមិ បដិសន្ធិចិត្តនៃអ្នកដែលកើតជាមនុស្ស ឬទេវតាជាន់ផ្សេង ។ ជាកុសលវិបាកចិត្តជាផលរបស់កុសលកម្មមួយ ទើបធ្វើឱ្យកើតក្នុងសុគតិភូមិ ។

សូម្បីថា ការកើតក្នុងមនុស្សភូមិ ជាកុសលវិបាកក៏ពិតមែន តែបុគ្គលខ្លះក៏ពិការពីកំណើត ព្រោះកុសលវិបាកចិត្ត ដែលធ្វើកិច្ចបដិសន្ធិនោះ ជាផលរបស់កុសលកម្មដែលមិនមានបញ្ញាចេតសិកកើតរួមជាមួយផង និងជាកុសលកម្មយ៉ាងខ្សោយបំផុត កុសលវិបាកចិត្តដែលធ្វើកិច្ចបដិសន្ធិនោះ ទើបមិនប្រកបដោយសោភណចេតសិក គឺមិនកើតរួមជាមួយនឹងអលោភចេតសិក អទោសចេតសិក ជាដើម ។ នៅពេលជាផលរបស់កុសលកម្មយ៉ាងខ្សោយបំផុត អកុសលកម្មដែលធ្វើទុកទើបបៀតបៀនឱ្យជាអ្នកពិការពីកំណើតបាន ។

អ្នកដែលកើតជាមនុស្ស ដែលមិនពិការពីកំណើតនោះ សុទ្ធតែកើតមកផ្សេង ។ គ្នា ដោយត្រកូល យសសក្តិ បរិវារ ព្រោះកុសលវិបាក

ដែលធ្វើកិច្ចបដិសន្ធិនោះ ផ្សេងគ្នាតាមកម្លាំង របស់កុសលកម្ម ដែលជាហេតុ ។ បើបដិសន្ធិចិត្តជាផលរបស់កុសលកម្ម ដែលប្រកបដោយបញ្ញាចេតសិកយ៉ាងខ្សោយ ឬមិនមានបញ្ញាចេតសិកកើតរួមផង បដិសន្ធិចិត្តដែលជាកុសលវិបាកនោះ ក៏កើតរួមនឹងសោភណចេតសិក និងហេតុ ២ គឺ អលោភចេតសិក និងអទោសចេតសិក ជាទ្វិហេតុកបុគ្គល គឺជាបុគ្គលបដិសន្ធិចិត្តមិនមានបញ្ញាចេតសិកកើតរួមជាមួយផង បុគ្គលនោះទើបមិនអាចបន្លុះឈាន ឬលោកុត្តរធម៌ក្នុងជាតិនោះ ។

អ្នកដែលបដិសន្ធិចិត្តជាផលរបស់កម្ម ដែលប្រកបដោយបញ្ញា និងបដិសន្ធិចិត្តមានបញ្ញាចេតសិកកើតរួមជាមួយផងនោះ ជាតិហេតុក បុគ្គលព្រោះមានហេតុ ៣ គឺមានអលោភចេតសិក អទោសចេតសិក និងបញ្ញា (អមោហ) ចេតសិកកើតរួមជាមួយផង បុគ្គលនោះកាលបានស្តាប់ព្រះធម៌ ក៏អាចពិចារណាយល់ព្រះធម៌ ហើយអាចអប់រំចម្រើនបញ្ញារហូតដល់បន្លុះឈានចិត្ត ឬឃើញច្បាស់ ដឹងច្បាស់នូវអរិយសច្ចធម៌ទាំង ៤ បន្លុះមគ្គ ផល និព្វាន ជាព្រះអរិយបុគ្គលក្នុងជាតិនេះបាន តាមគួរដល់ការសន្សំនៃបច្ច័យ ប៉ុន្តែក៏មិនគួរប្រមាទ ព្រោះលោកខ្លះជាអ្នកមានសតិបញ្ញា បដិសន្ធិចិត្តជាតិហេតុកក៏ពិតមែន តែបើប្រមាទក្នុងការចម្រើនកុសល ប្រមាទក្នុងការស្តាប់ធម៌ ក៏នឹងជាអ្នកដែលឆ្ងាតតែក្នុងផ្លូវលោក ក្នុងវិជ្ជាការផ្សេង ។ តែបើមិនអប់រំចម្រើនបញ្ញាក្នុងផ្លូវធម៌ទេ ក៏មិនអាចដឹងនូវលក្ខណៈរបស់សភាវធម៌តាមសេចក្តីពិតបានឡើយ ។

ក្នុងអតីតកាលយូរយារមកហើយក្នុងជាតិមុន ។ លោកខ្លះអាចជាអ្នកធ្លាប់យកចិត្តទុកដាក់ក្នុងព្រះធម៌ អាចជាអ្នកដែលសិក្សា រៀនសូត្រព្រះធម៌ ឬអាចដល់ជាបព្វជ្ជា ឧបសម្បទាជាភិក្ខុ សាមណេរ តែការដឹងច្បាស់នូវអរិយសច្ចធម៌នោះ មិនមានអ្នកណាដឹងបានថា នឹងដឹងច្បាស់នូវអរិយសច្ចធម៌ក្នុងភេទណាឡើយ ក្នុងភេទបព្វជិត ឬឃរាវាស គ្រប់បុគ្គលត្រូវអប់រំចម្រើនបញ្ញាដឹងលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដតាមសេចក្តីពិតគ្រប់ ។ ជាតិ រហូតទាល់តែដល់ជាតិដែលបញ្ញាចាស់ក្លាអាចចាក់ធ្លុះអរិយសច្ចធម៌បាន ។

ហើយសូម្បីថាក្នុងកាលមួយគ្រាអាចនឹងធ្លាប់ចូលចិត្តធម៌ យកចិត្តទុកដាក់ក្នុងការសិក្សា ក្នុងការបដិបត្តិធម៌មែន តែក៏កុំភ្លេចថា មុននឹងបានដឹងច្បាស់នូវអរិយសច្ចធម៌ក៏នៅមានអកុសល ដែលសន្សំមកសន្ធឹកសន្ធាប់ ណែនណាន់ តាន់តាប់ដែលបានធ្វើឱ្យវង្វេង ភ្លើតភ្លើន ត្រែកត្រអាលក្នុងអកុសលបានដែរ បើជាអ្នកដែលប្រមាទ ។ ដូច្នេះ សូម្បីដល់ទៅថា បដិសន្ធិចិត្តនឹងជាតិហេតុកៈក៏ដោយ ប៉ុន្តែនៅពេលណាជាអ្នកប្រមាទ បញ្ញាចេតសិកក្នុងជាតិនោះក៏នឹងមិនចម្រើនឡើង ព្រោះមិនបានអប់រំដោយការស្តាប់ ដោយការពិចារណា និងដោយការជាប់បដិបត្តិធម៌ ដូច្នេះ គួរឱ្យស្តាយជាតិដែលបដិសន្ធិចិត្តជាតិហេតុកៈ ពេលមិនបានអប់រំបញ្ញាឱ្យចម្រើនឡើង ហើយជាតិបន្ទាប់តទៅនោះ កម្មណានឹងធ្វើឱ្យបដិសន្ធិចិត្តប្រភេទណាកើតជាប់គ្នា ក៏មិនប្រាកដ អាចនឹងជាអកុសល

វិបាកចិត្តធ្វើកិច្ចបដិសន្ធិក្នុងអបាយភូមិ ឬអហេតុកកុសលវិបាកចិត្ត ធ្វើកិច្ច បដិសន្ធិជាបុគ្គលពិការតាំងពីកំណើត ឬទ្វិហេតុកកុសលវិបាក ធ្វើកិច្ច បដិសន្ធិ ជាទ្វិហេតុកបុគ្គលក្នុងសុគតិភូមិ ដែលមិនអាចអប់រំចម្រើនបញ្ញា ឱ្យដឹងច្បាស់នូវអរិយសច្ចធម៌បាន ។

ដូច្នោះ ទើបគួរស្តាយក្នុងមួយភពក្នុងមួយជាតិ ដែលមិនបានអប់រំបញ្ញាឱ្យចម្រើនក្រៃលែងឡើងនោះ ហើយសូម្បីដល់ទៅថានឹងជាតិហេតុកបដិសន្ធិហើយក៏ដោយ តែបើកាលអប់រំចម្រើនបញ្ញានៅមិនទាន់ល្មមគ្រប់គ្រាន់ ក៏មិនអាចដឹងច្បាស់នូវអរិយសច្ចធម៌ក្នុងជាតិនេះបានដែរ មិនមែនថា អ្នកដែលជាតិហេតុកបុគ្គលហើយ នឹងត្រូវដឹងច្បាស់នូវអរិយសច្ចធម៌បានក្នុងបច្ចុប្បន្នជាតិគ្រប់ ៗ គ្នាទាំងអស់នោះទេ ។

អ្នកដែលកើតជាមនុស្សមិនពិការពីកំណើតនោះ ខណៈដេកលក់ស៊ប់ ភវង្គចិត្តជាសោភណចិត្ត ព្រោះបដិសន្ធិចិត្តជាទ្វិហេតុកៈ មានអលោភចេតសិក អទោសចេតសិក កើតរួមជាមួយផង ។ លោកអ្នកខ្លះបដិសន្ធិចិត្តក៏ជាតិហេតុកៈ មានអលោភចេតសិក អទោសចេតសិក និងបញ្ញាចេតសិកកើតរួមជាមួយផង ។ ខណៈដេកលក់កិលេសមិនកើត មិនមានសេចក្តីត្រេកអរ មិនពេញចិត្តអ្វីទេ ព្រោះមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិននឹកគិតរឿងរ៉ាវអ្វីផ្សេង ៗ តាមផ្លូវចិត្ត ប៉ុន្តែដល់ពេលភ្ញាក់ឡើងនោះ នឹងសប្បាយចិត្ត ឬអន់ចិត្ត សុខ ឬទុក្ខ ក៏ប្រព្រឹត្តទៅតាមអកុសលចិត្តផ្សេង ៗ ដែលកើត ឡើងក្នុងមួយថ្ងៃ ៗ ដោយច្រើន ។

នៅពេលភ្ញាក់ហើយក៏ជា អសោភណៈច្រើនជាងជាកុសល ។ ចក្ខុវិញ្ញាណ កើតឡើងឃើញអ្វី (សភាវៈ) ដែលប្រាកដតាមផ្លូវភ្នែកមួយខណៈ ហើយ ក្រោយពីនោះ ភាគច្រើនអកុសលវិថីចិត្តក៏កើត ៧ ខណៈ ដែលស្មើ នឹង ៧ ដងនៃចក្ខុវិញ្ញាណដែលធ្វើកិច្ច ឃើញមួយខណៈ ។ ។ ការសន្សំ បន្តនូវអកុសលធម៌ក្នុងមួយថ្ងៃ ។ នោះច្រើនហួសប្រមាណ ដូច្នោះមិនគួរ ប្រមាទឡើយ ពេលបានស្តាប់ ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ សម្តែងដោយល្អិតថា ចិត្តខណៈណាជាសោភណៈ ចិត្តខណៈណាជា អសោភណៈ ហើយអសោភណចិត្តនោះ ជាអកុសល ឬថាជាវិបាក ឬថា ជាកិរិយា ។

សំណួរ តើព្រះអរហន្តមានអសោភណចិត្តទេ?

ចម្លើយ មាន

សំនួរ តើព្រះអរហន្តមានអកុសលចិត្តទេ ?

ចម្លើយ មិនមាន

ព្រះអរហន្តមានអសោភណចិត្ត តែព្រះអរហន្តមិនមានអកុសល ចិត្ត ព្រោះថា ព្រះអរហន្តមានចក្ខុវិញ្ញាណ សោតវិញ្ញាណ ជាដើម ដែលជា អសោភណចិត្ត តែព្រះអរហន្តមិនមានអកុសលចិត្ត និងកុសលចិត្ត ។

ចេតសិកទាំងអស់មាន ៥២ ប្រភេទ ជាអញ្ញសមានាចេតសិក គឺចេតសិកដែលស្មើនឹងចិត្តនិងចេតសិកដទៃដែលកើតរួមផង ១៣ ប្រភេទ

ជាអកុសលចេតសិក ១៤ ប្រភេទ ជាសោភណចេតសិក ២៥ ប្រភេទ បើមិនប្រើពាក្យថា សោភណៈ អសោភណៈ តែប្រើភាសាខ្មែរ អត្ថន័យនឹងមិនត្រូវនឹងសភាវធម៌ដែលជាសោភណៈ និងអសោភណៈ ។ ដូចជាសួរថា វេទនាចេតសិកល្អទេ ? មានលោកម្នាក់ឆ្លើយតបថា បើជាសុខវេទនាក៏ល្អ សុខវេទនាដោយន័យវេទនា ៥ សំដៅដល់វេទនាចេតសិក ដែលកើតចំពោះតែនឹងកាយវិញ្ញាណជាប់គ្នាដែលជាកុសលវិបាក ក្នុងខណៈដែលប៉ះខ្ជប់នឹងអារម្មណ៍គួរជាទីសប្បាយកាយ **សុខសហគតំ កាយ វិញ្ញាណំ កុសលវិបាកំ** មិនមានសោភណចេតសិក គឺអលោភចេតសិក អទោសចេតសិក បញ្ញាចេតសិក ជាដើមកើតរួមជាមួយផងទេ ដូច្នោះ ដោយសភាវធម៌ សុខវេទនាដែលកើតនឹងកាយវិញ្ញាណ កុសលវិបាកនោះ ជាអសោភណៈ មិនមែនសោភណៈ ។ ដោយហេតុនេះ ការសិក្សាធម៌ ទើបត្រូវយល់សភាវធម៌ឱ្យត្រឹមត្រូវតាមព្រះបាលី បើមិនដូច្នោះទេ នឹងធ្វើឱ្យយល់សភាវធម៌ខុសបាន ។

បើមានពាក្យសួរថា រូបដែលកំពុងប្រាកដតាមផ្លូវភ្នែកនេះល្អ ឬមិនល្អ? ពាក្យឆ្លើយតប ជាភាសាខ្មែរក៏មិនជាក់ច្បាស់ព្រោះសូម្បីដល់ទៅថា រូបស្អាតផូរផង់គួរជាទីរីករាយ ពេញចិត្ត យ៉ាងណាក៏ដោយ តែរូបក៏មិនមែនសោភណធម៌ ព្រោះរូបមិនមែនសភាពដឹង មិនមែនកុសល អកុសល រូបមិនមានមេត្តា ករុណា មុទិតា ឬសភាវធម៌ណា ។ ដែលជាសភាវធម៌ដែលល្អស្អាតកើតរួមជាមួយផងឡើយ ចិត្ត និងចេតសិកប៉ុណ្ណោះ ដែលជា

សោភណៈ ឬអសោភណៈ រូបជាអារម្មណ៍ដែលជាបច្ច័យឱ្យចិត្តកើតឡើង ពេញចិត្ត ឬមិនពេញចិត្តរូបនោះ ។ ប៉ុណ្ណឹង ដោយរូបនេះឯងជា អព្យាកត ធម៌ រូបមិនដឹងអ្វីឡើយ រូបមិនដឹងថា ចិត្តពេញចិត្ត ឬមិនពេញចិត្ត នឹងរូបនោះទេ ហើយរូបខ្លួនឯងក៏មិនមានចេតនានឹងឱ្យចិត្តពេញចិត្ត ឬមិន ពេញចិត្តចំពោះរូបនោះដែរ ព្រោះរូបមិនមែនសភាពដឹង តែចិត្តត្រូវការ ឃើញរូប ត្រូវការឮសំឡេង ត្រូវការធុំក្លិនក្រអូប ។ ត្រូវការប៉ះខ្ទប់សម្ផស្ស អ្វីដែលជាទីពេញចិត្ត ដើម្បីសេចក្តីដឹងខ្លួនដែលជាសុខ បានកើតឡើង ហើយកើតឡើងដដែល ។ ទៀត នៅពេលឃើញសភាវៈដែលប្រាកដតាម ភ្នែក ឮសំឡេងដែលប្រាកដតាមផ្លូវត្រចៀក ធុំក្លិន តាមផ្លូវច្រមុះ ដឹងរស តាមផ្លូវអណ្តាត ដឹងប៉ះខ្ទប់សម្ផស្សតាមផ្លូវកាយ ឬសូម្បីតែនឹកគិតដល់រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ តាមផ្លូវចិត្ត រាល់ ។ ថ្ងៃក៏ដោយ ដូច្នោះ ទើបមានពាក្យឧបមាប្រៀបធៀបខន្ធ ៥ ថារូបក្ខន្ធដូចភាជនៈ ដែលដាក់ ដោយវត្ថុ ដែលនាំមកនូវសេចក្តីត្រេកអរ វេទនាខន្ធ ដូចអាហារដែលនៅ ក្នុងភាជនៈនោះ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ដូចជាអ្នកដាំស្លរ និងអ្នកជំនួយ តាក់តែងអាហារ វិញ្ញាណខន្ធ ជាអ្នកបរិភោគអាហារ ព្រោះចិត្តជាធំ ជា ប្រធានក្នុងការដឹងនូវអារម្មណ៍ នាមខន្ធទាំង ៤ ត្រូវកើតព្រមគ្នា ដឹង អារម្មណ៍ដូចគ្នា ហើយមិនបែកគ្នាសោះឡើយ មានតែនាមខន្ធ ១ ខ្វះ នាមខន្ធ ៣ មិនបាន មានតែនាមខន្ធ ២ ខ្វះនាមខន្ធ ២ មិនបាន

មានតែនាមខន្ធ ៣ ខ្វះ នាមខន្ធ ១ មិនបាន ។ ហើយក្នុងភូមិដែលមានខន្ធ ៥ នោះ នាមខន្ធត្រូវអាស្រ័យរូបក្ខន្ធទើបនឹងកើតឡើងបាន ។

ការសិក្សាធម៌រឿងចិត្តប្រភេទផ្សេង ៗ នោះដើម្បីដឹងច្បាស់នូវលក្ខណៈនៃចិត្តដែលចំណែកដោយប្រភេទផ្សេង ៗ គឺចំណែកដោយជាតិ ៤ ដោយពួក ៣ ដោយហេតុ ដោយអសង្ខារ សសង្ខារ ដោយសោភណៈ អសោភណៈ ដោយប្រកបនឹងចេតសិកផ្សេងគ្នា យ៉ាងណាខ្លះនោះ ក៏ដើម្បីឱ្យសតិកើតឡើង រលឹកពិចារណា ដឹងសភាពដែលជាអនត្តា នៃធម៌ទាំងឡាយដែលមិនមែនតួខ្លួន សត្វ បុគ្គល និងលក្ខណៈនៃសភាវធម៌តែមួយបែបនោះ គឺជាលក្ខណៈនៃរូបធម៌តែមួយបែប នាមធម៌តែមួយបែប ដូចលក្ខណៈនៃរូបដែលប្រាកដតាមផ្លូវភ្នែកក៏មួយបែប តាមផ្លូវត្រចៀក ក៏មួយបែប តាមផ្លូវច្រមុះក៏មួយបែប តាមផ្លូវអណ្តាតក៏មួយបែប តាមផ្លូវកាយក៏មួយបែប លក្ខណៈរបស់ចិត្តដែលជាកុសលមួយបែប លក្ខណៈរបស់ចិត្ត ដែលជាអកុសលក៏មួយបែប លក្ខណៈរបស់ចិត្ត ដែលជាអព្យាកតចិត្តក៏មួយបែប ។ សេចក្តីដឹង សេចក្តីយល់ក្នុងលក្ខណៈនៃសភាវធម៌ទាំងឡាយកើនឡើង រមែងជាបច្ច័យតាក់តែងឱ្យសតិកើត ឡើងរលឹកដឹងពិចារណាលក្ខណៈនៃសភាវធម៌ ដែលប្រាកដ រហូតទាល់តែនឹងប្រចក្សលក្ខណៈនៃសភាវធម៌តែមួយបែប ។ ត្រង់តាមសេចក្តីពិតនៃសភាវធម៌នោះ ។ ។

សំណួរសាឡើងវិញ

១- តើរូបជាសោភណធម៌បានទេ ព្រោះអ្វី ?

២- បុគ្គលដែលបដិសន្ធិចិត្តជាកុសលវិបាក តែមិនមានសោភណចេតសិក-កើតរួមជាមួយផង ខុសពីបុគ្គលដែលបដិសន្ធិចិត្ត ជាកុសលវិបាក ដែលមានសោភណចេតសិកកើតរួមជាមួយផងយ៉ាងណា ?

៣- តើទ្វិហេតុកបដិសន្ធិចិត្ត ជាផលរបស់កម្មអ្វី ?

៤- តើទ្វិហេតុកបុគ្គល និងតិហេតុកបុគ្គល ផ្សេងគ្នាយ៉ាងណា ?

៥- តើខណៈដេកលក់ស៊ប់ ជាសោភណចិត្ត ឬអសោភណចិត្ត ?

មេរៀនទី ១៥

ចំណែកចិត្ត ដោយ **លោកិយចិត្ត និងលោកុត្តរចិត្ត**

មុនដំបូងបង្អស់គួរយល់សេចក្តីនៃពាក្យថា « លោក » ក្នុងវិន័យនៃព្រះអរិយៈជាម្ចាស់ តាមដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ឆន្នវគ្គ ទី ៤ បលោកសូត្រ ដែលមានសេចក្តីថា

គ្រានោះឯង ព្រះអានន្ទដ៏មានអាយុចូរទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ រួចហើយបានក្រាបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា លោក ។ យ៉ាងនេះដោយហេតុត្រឹមប៉ុណ្ណាហ្ន៎ ទើបហៅថា « លោក » ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្វីណាមានសេចក្តីបែកធ្លាយជាធម្មតា នេះហៅថា « លោក » ក្នុងអរិយវិន័យ ក៏អ្វីទៅមានសេចក្តីបែកធ្លាយជាធម្មតា ចក្ខុនេះឯងមានសេចក្តីបែកធ្លាយជាធម្មតា រូបមានសេចក្តីបែកធ្លាយជាធម្មតា ចក្ខុវិញ្ញាណ មានសេចក្តីបែកធ្លាយជាធម្មតា ចក្ខុសម្ផស្សមានសេចក្តីបែកធ្លាយជាធម្មតា សុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនាដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ មានសេចក្តីបែកធ្លាយជាធម្មតា ។ ល ។ រហូតទៅដល់ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ។

ជាធម្មតារបស់ព្រះអរិយៈជាម្ចាស់ តែមិនមែនធម្មតា សម្រាប់អ្នក ដែលមិនទាន់ប្រចក្សការកើតឡើងនិងការរលត់ទៅនៃសភាវធម៌ទេ ដូច្នោះ នឹងឃើញបានថា អ្នកដែលនឹងជាព្រះអរិយបុគ្គលត្រូវប្រចក្សការកើត រលត់នៃសភាវធម៌ដែលប្រាកដពិត ។ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាល អានន្ទ សភាវៈណាមានសេចក្តីបែកធ្លាយជាធម្មតានេះ ហៅថា « លោក » ក្នុងអរិយវិន័យ លោកគឺគ្រប់សភាវៈដែលកើត រលត់ ដូច្នោះ មានតែ សភាវធម៌ ដែលមិនកើត រលត់ប៉ុណ្ណោះ ដែលមិនមែនលោក ជាសភាវធម៌ ដែលផុតចាកលោក ផ្ទុយអំពីលោក ជាលោកុត្តរ គឺព្រះនិព្វាន ។

កាលចំណែកចិត្តជាប្រភេទលោកិយ និងលោកុត្តរនោះ **ចិត្តណា ដែលមិនប្រចក្សច្បាស់លក្ខណៈនៃនិព្វាន គឺមិនមាននិព្វានជាអារម្មណ៍ ចិត្តនោះជា « លោកិយចិត្ត » ចិត្តណាមាននិព្វានជាអារម្មណ៍ ដោយរំលត់កិលេស ឬមាននិព្វានជាអារម្មណ៍ ដោយរំលត់កិលេសរួចហើយ ចិត្តនោះជា « លោកុត្តរចិត្ត »**

អ្នកដែលនឹងត្រូវជាព្រះអរិយបុគ្គលនោះ ត្រូវអប់រំចម្រើនលោកិយ បញ្ញាដែលដឹងច្បាស់នូវលក្ខណៈនៃនាមធម៌ និងរូបធម៌ ។

លោកិយបញ្ញា មិនមែនចំណេះ ចេះកសាងបញ្ចេញស្មាដៃវិទ្យាសាស្ត្រផ្សេង ។ នោះទេ ការចេះដឹងបែបណា ។ ក៏ដោយ ដែលមិនមែនការដឹងនូវលក្ខណៈនៃនាមធម៌ និងរូបធម៌នោះ គឺមិនមែនលោកិយបញ្ញាក្នុងព្រះពុទ្ធសាសនា ។

លោកិយបញ្ញាដឹងលក្ខណៈនៃលោក គឺសភាវធម៌ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ដែលមិនមែននិព្វាន ។ ដូច្នោះ ក្រៅពីមគ្គចិត្ត ៤ ដួង ដែលជាលោកុត្តរកុសលចិត្ត ដែលមាននិព្វានជាអារម្មណ៍ ដោយរំលត់កិលេស និងផលចិត្ត ៤ ដួង គឺលោកុត្តរវិបាកចិត្ត ដែលមាននិព្វានជាអារម្មណ៍ ដោយរំលត់កិលេសហើយ ចិត្តដទៃទៀត ទាំងអស់ជាលោកិយចិត្ត ។

លោកុត្តរចិត្តទាំងអស់មាន ៨ ដួង ៤ គូ គឺ

សោតាបត្តិមគ្គចិត្ត	១	សោតាបត្តិផលចិត្ត	១
សកទាគាមិមគ្គចិត្ត	១	សកទាគាមិផលចិត្ត	១
អនាគាមិមគ្គចិត្ត	១	អនាគាមិផលចិត្ត	១
អរហត្តមគ្គចិត្ត	១	អរហត្តផលចិត្ត	១

នៅពេល**សោតាបត្តិមគ្គចិត្តកើតឡើងធ្វើកិច្ចរំលត់កិលេស** ដោយមាននិព្វានជាអារម្មណ៍រលត់ទៅហើយ សោតាបត្តិផលចិត្តក៏កើតបន្តហើយមាននិព្វានជាអារម្មណ៍ដោយរំលត់កិលេសហើយ ។ សោតាបត្តិមគ្គ-ចិត្ត ជាលោកុត្តរចិត្ត ជាបច្ច័យឱ្យលោកុត្តរវិបាកចិត្ត គឺសោតាបត្តិផលចិត្តកើតបន្តពីសោតាបត្តិមគ្គចិត្តភ្លាម ។ ដោយមិនមានចិត្តណាដទៃ កើតខណ្ឌបានឡើយ ។ ការឱ្យផលនៃលោកុត្តរកុសលនោះឱ្យផលភ្លាម ជាអកាលិកោ មិនបាច់រង់ចាំដល់ជាតិមុខ ។

អកុសល និងកុសលឯទៀត ។ នោះ ឱ្យផលភ្លាមដែលរលត់ទៅដូច លោកុត្តរកុសលមិនបានឡើយ ។ អ្នកដែលអប់រំចម្រើនសមថភាវនារហូតដល់ឈានកុសលចិត្តកើតហើយ ក៏មិនទាន់មានឈានវិបាកចិត្តកើតក្នុងខណៈដែលជាមនុស្សដែរ ព្រោះឈានវិបាកចិត្តធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ក្នុងព្រហ្មលោក ។ អ្នកដែលឈានចិត្តមិនវិនាសទៅនោះ ឈានកុសលចិត្តនឹងកើតមុនចុតិចិត្ត កាលចុតិចិត្តរលត់ ឈានកុសលចិត្តដែលកើតមុនចុតិចិត្តនោះ ជាបច្ច័យឱ្យឈានវិបាកចិត្ត ធ្វើកិច្ចបដិសន្ធិក្នុងព្រហ្មលោកភូមិណាមួយ ដូចបឋមជ្ឈានកុសលចិត្ត ជាបច្ច័យឱ្យបឋមជ្ឈានវិបាកចិត្តធ្វើកិច្ចបដិសន្ធិក្នុងបឋមជ្ឈានព្រហ្មភូមិខ្ពស់ឡើង តាមលំដាប់រហូតទៅដល់អរូបឈានកុសល គឺអាកាសានញ្ចាយតនកុសលចិត្ត ជាបច្ច័យឱ្យអាកាសានញ្ចាយតនវិបាកចិត្ត បដិសន្ធិក្នុងអាកាសានញ្ចាយតនភូមិខ្ពស់ឡើងតាមលំដាប់រហូតទៅដល់ នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ជាបច្ច័យឱ្យនេវសញ្ញានាសញ្ញាយតនវិបាកចិត្តធ្វើកិច្ចបដិសន្ធិក្នុង នេវសញ្ញា-នាសញ្ញាយតនភូមិ ។

កម្មឯទៀត ។ នោះត្រូវមានចិត្តដទៃកើតខណ្ឌច្រើនណាស់ ទម្រាំនឹងដល់កាលវេលាដែលនឹងឱ្យផល តែកម្មមួយប្រភេទដែលឱ្យផលដោយចិត្តដទៃកើតខណ្ឌមិនបានទាល់តែសោះ គឺលោកុត្តរកុសលកម្ម ។ ពេលដែលលោកុត្តរកុសលចិត្តរលត់ហើយភ្លាម លោកុត្តរវិបាកចិត្តក៏កើតភ្លាម

ព្រោះលោកុត្តរវិបាកចិត្ត មិនធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និងកិច្ចដទៃ ។ ដូចវិបាកចិត្តដទៃ ។ ឡើយ ។

ក្នុងអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ ចិត្តុប្បាទកណ្ឌ អធិប្បាយ ចូឡន្តរទុក្កៈ មានសេចក្តីថា

ឈ្មោះថា « **លោកិយធម៌** » ព្រោះប្រកបក្នុងលោក ដោយហេតុដែលទាក់ទងនៅក្នុងលោកនោះ ឈ្មោះថា « **ឧត្តរធម៌** » គឺធម៌ដ៏ក្រៃលែងដ៏ប្រសើរ ព្រោះឆ្លងផុតពីលោកនោះ ឈ្មោះថា « **លោកុត្តរធម៌** » ព្រោះឆ្លងឡើងផុតពីលោកនោះ ដោយហេតុដែលមិនទាក់ទងនៅក្នុងលោក ។

ចិត្ត ចេតសិក រូប ជាសង្ខារធម៌ ជាសភាវធម៌ដែលកើតរលត់ សូម្បីលោកុត្តរចិត្ត និងចេតសិក ដែលមាននិព្វានជាអារម្មណ៍នោះក៏កើតរលត់ ប៉ុន្តែដែលចំណែកចិត្ត ជាលោកិយចិត្ត និងលោកុត្តរចិត្តនោះ ក៏ព្រោះលោកុត្តរចិត្តមាននិព្វានជាអារម្មណ៍ដោយរំលត់កិលេស (មគ្គចិត្ត) និងដោយកិលេសរំលត់ហើយ (ផលចិត្ត) ។

សេចក្តីក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេសភាគ ២ មោឃរាជមាណវកប្បញ្ហានិទ្ទេស ត្រូវនឹងសំយុត្តនិកាយ សឡាយតនវគ្គ សុញ្ញសូត្រ ដែលមានសេចក្តីថា

គ្រានោះឯង ព្រះអានន្ទដ៏មានអាយុបានក្រាបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថាលោកសូន្យ ។ ដូចនេះ ដោយហេតុត្រឹមណាហ្ន៎ ទើបហៅថាលោកសូន្យ ។ ព្រះដ៏មានព្រះភាគ

ត្រាស់ថា ម្នាលអានន្ទ ព្រោះសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ដូច្នោះ ទើបហៅថាលោកសូន្យ ។ អ្វីទៅសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ចក្ខុនោះឯងសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន រូបសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ចក្ខុវិញ្ញាណសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ចក្ខុសម្ផស្សសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន សុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យក៏សូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ។ ល ។ ចិត្តសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ធម្មារម្មណ៍សូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន មនោវិញ្ញាណសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន មនោសម្ផស្សសូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ដែលកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ក៏សូន្យចាកខ្លួន ឬសូន្យចាករបស់នៃខ្លួន ដូច្នោះទើបហៅថាលោកសូន្យ ។

ចប់សុញ្ញសូត្រទី ២

មិនមែនថា មិនដឹងអ្វីសោះ ក៏នឹងធ្វើឱ្យសូន្យបាន ដោយមិនដឹងថាអ្វីសូន្យ សូន្យចាកអ្វី សូន្យយ៉ាងណានោះទេ ប៉ុន្តែនឹងត្រូវដឹងតាមសេចក្តីពិតថា ដែលសូន្យចាកខ្លួន ឬសូន្យចាកភាពជារបស់នៃខ្លួន ព្រោះជាសភាវធម៌មួយបែប ។ ដែលកើតឡើងហើយក៏រលត់ទៅ តាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ។ លោកអ្នកខ្លះ

អាចនឹងមានសេចក្តីដឹងខ្លួនថា ថ្ងៃខ្លះដូចជាមិនមានអ្វីជារបស់នៃយើងឡើយ ហើយតើដូចម្តេចទើបមិនដឹងខ្លួនយ៉ាងនេះមកពីមុន ពីមុនធ្លាប់ប្រកាន់ថាជាយើង និងជារបស់យើង តែនៅមួយថ្ងៃ ។ បានស្តាប់ធម៌ញយ ។ ច្រើន ។ បានយល់ ក៏កើតសេចក្តីនឹកថា មិនឃើញមានអ្វីមួយជារបស់នៃយើងទាល់តែសោះ មិនគួរនឹងទៅវង្វេងប្រកាន់ថាជារបស់នៃយើងនោះឡើយ ត្រឹមតែគិតប៉ុណ្ណោះ មិនទាន់គ្រប់គ្រាន់ទេ ព្រោះរំលត់កិលេសមិនបាន ហើយបើមិនដឹងក៏អាចគិតថា បានបញ្ញាច្រើនណាស់ហើយ ជិតបាននឹងជាអរិយបុគ្គលហើយ ព្រោះថាពេលមុននេះមិនធ្លាប់គិត មិនធ្លាប់ដឹងយ៉ាងនេះ បុគ្គលខ្លះក៏កើតសេចក្តីដឹងខ្លួនថា អស្ចារ្យណាស់ដែលគិតបានយ៉ាងនោះ តែសូមឱ្យជ្រាបថា នោះមិនមែនគន្លងផ្លូវនឹងទៅរំលត់កិលេសទេ ព្រោះនៅមិនទាន់ដឹងថាលក្ខណៈនៃនាមធម៌ ដែលជាធាតុដឹងជាសភាពដឹងដែលកំពុងឃើញ កំពុងឮ កំពុងធំក្លិន កំពុងដឹងរស កំពុងដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស និងនឹកគិតជាដើមនោះ មិនមែនតួខ្លួនយ៉ាងណានៅឡើយ កាលនៅមិនទាន់រលឹកសិក្សា ពិចារណា សង្កេត អប់រំចម្រើនបញ្ញា ដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ក៏នៅមិនទាន់ចូលដល់អត្ថ គឺលក្ខណៈដែលពិតប្រាកដរបស់នាមធម៌ ឬរូបធម៌ ទើបមិនអាចប្រចក្សលក្ខណៈដែលកើតឡើង និងរលត់ទៅរបស់នាមធម៌ និងរូបធម៌ដែលកំពុងជាលោក ដែលកើត រលត់នៅក្នុងខណៈនេះបានឡើយ ។ ដូច្នោះ មិនថានឹងគិត នឹងយល់លក្ខណៈនៃនាមធម៌ និងរូបធម៌ យ៉ាងណា

ក៏កុំវង្វេងគិតថា ជាបញ្ញាដែលអាចរំលត់កិលេសហើយនោះ ព្រោះបើសតិមិនកើត មិនរលឹក មិនដឹង មិនពិចារណា លក្ខណៈនៃសភាវធម៌ដែលប្រាកដរហូតទាល់តែប្រចក្សលក្ខណៈដែលផ្សេងគ្នានៃរូបធម៌ និងនាមធម៌ពិត ។ តាមផ្លូវមនោទ្វារមួយលក្ខណៈ ។ ឱ្យជាក់ច្បាស់ទេ បញ្ញានៅតែមិនបានចម្រើនឡើងរហូតអាចដឹងថា **សភាវធម៌ទាំងឡាយត្រឹមតែជាលោកដែលសូន្យទទេ សូន្យចាកការដែលនឹងប្រកាន់មាំថា ជាតួខ្លួន សត្វ បុគ្គលបានដែរ ។**

ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេសភាគ ២ មោឃរាជមាណវក បញ្ហានិទ្ទេស ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសំគាល់សេចក្តីនោះយ៉ាងណា ស្មៅ ឈើ មែកឈើ ស្លឹកឈើ ដែលមាននៅក្នុងទីវិហារនេះ ជនគប្បីនាំស្មៅ ឈើ មែកឈើ ស្លឹកឈើ នោះទៅចោល ដុតចោល ឬគប្បីធ្វើតាមគួរដល់ហេតុ តើអ្នកទាំងឡាយគប្បីមានសេចក្តីគិតយ៉ាងនេះថា ជននាំយើងទាំងឡាយទៅចោល ដុតចោល ឬធ្វើតាមគួរដល់ហេតុខ្លះ ឬហ្ន៎

ភិ. មិនមែនយ៉ាងនោះទេ ព្រះអង្គ

ព. នោះព្រោះដោយហេតុអ្វី

ភិ. ព្រោះវត្ថុទាំងនោះមិនមែនខ្លួន ឬវត្ថុដែលជាប់នឹងខ្លួនរបស់ខ្ញុំព្រះករុណាទាំងឡាយ យ៉ាងនោះព្រះអង្គ

៣. ម្នាលភិក្ខុទាំងឡាយ ដូច្នោះដូចគ្នាដែរ វត្ថុណាមិនមែនរបស់អ្នកទាំងឡាយ អ្នកទាំងឡាយចូរលះវត្ថុនោះចេញ វត្ថុនោះដែលអ្នកទាំងឡាយលះចេញហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយ អ្នកទាំងឡាយចូរលះបង់រូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ.... វេទនា .... សញ្ញា ....សង្ខារ .... វិញ្ញាណ ដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ បុគ្គលរមែងពិចារណាឃើញ លោកដោយសេចក្តីជារបស់សូន្យ សូម្បីយ៉ាងនេះ ។

សេចក្តីនៃវគ្គខាងចុង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគាមណិ កាលបុគ្គលឃើញនូវការកើតឡើងព្រមនៃធម៌ទាំងអស់ នូវតំណរនៃសង្ខារទាំងអស់ តាមសេចក្តីពិត ភ័យនោះរមែងមិនមាន កាលណាបុគ្គលរមែងពិចារណាឃើញលោក ទុកស្មើនឹងស្មៅ និងឈើ ដោយបញ្ញាកាលនោះ បុគ្គលនោះក៏មិនគប្បីប្រាថ្នានូវភព ឬអត្តភាពណា ។ ដទៃឡើយ រៀវលែងតែនិព្វាន ដែលមិនមានបដិសន្ធិ ។ បុគ្គលរមែងពិចារណាឃើញលោកដោយសេចក្តីជារបស់សូន្យយ៉ាងនេះ ។

កាលនៅមិនទាន់ដឹងថា រូប ដែលធ្លាប់ប្រកាន់ជារបស់ខ្លួន វេទនា សេចក្តីដឹងខ្លួនផ្សេង ។ ដែលធ្លាប់ដឹងថាជារបស់ខ្លួន សញ្ញា សេចក្តីចាំ

ផ្សេង ។ ថាជាឈ្មោះយើងនៅក្នុងលោកនេះ មានកិច្ចនាទីយ៉ាងនេះ សង្ខារទាំងឡាយមិនថានឹងជាកុសលធម៌ ឬអកុសលធម៌ទាំងឡាយទុក ស្មើដូចស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើនោះទេ ក៏នៅមិនអាចលះបង់ការប្រកាន់សភាវធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បានឡើយ ។

កាលមិនបានសិក្សា ពិចារណាព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង ព្រមទាំងការអប់រំចម្រើនសតិប្បដ្ឋាន ក៏មិនឈ្មោះថា ដឹងច្បាស់នូវលោក សូម្បីថាបានរស់នៅក្នុងលោកនេះយូរយារមកហើយ ប៉ុន្មានឆ្នាំ ប៉ុន្មានជាតិក៏ដោយ កាលមិនដឹងច្បាស់លោកទេ តើនឹងផុតចាកលោកបានយ៉ាងណា ? ទោះជានឹងសុខប៉ុណ្ណា ក៏មិនបានសុខរហូតរាល់កាលដែរ ព្រោះសេចក្តីដឹងខ្លួនជាសុខកើតឡើងត្រឹមមួយជួរខណៈចិត្ត ដែលកើតឡើងហើយក៏រលត់ទៅ ។ កាលមិនសិក្សាសភាវធម៌តាមសេចក្តីពិត និងមិនដឹង សូម្បីតែថាលោកគឺអ្វី និងលោកមានអ្វីខ្លះ ។ គ្រប់គ្នាដឹងថាមានសភាវៈដែលប្រាកដតាមផ្លូវភ្នែក មានសំឡេង ។ល។ ព្រោះសំឡេងប្រាកដពេលឮសំឡេង តែបើមិនមានសភាពដឹង មិនមានធាតុដឹងដែលកំពុងឮ សំឡេងក៏ប្រាកដមិនបាន ។ ដូច្នោះ អារម្មណ៍ផ្សេង ៗ ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តនោះរមែង សម្តែងឱ្យឃើញថា មានចិត្តដែលជាសភាពដឹង ធាតុដឹងដែលជាលោកកើត រលត់គ្រប់ខណៈ ហើយបើមិនមានអារម្មណ៍ផ្សេង ។

ប្រាកដ ក៏មិនមាននរណាអាចដឹងលក្ខណៈនៃចិត្តដែលជាសភាពដឹង ដែលកំពុងកើត រលត់បានឡើយ ។

កាលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ តែមិនដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិតដែលកើតឡើង រលត់ទៅបន្តគ្នាយ៉ាងរហ័ស ក៏ប្រកាន់អាការសណ្ឋាននៃសភាវៈដែលប្រាកដថាជា សត្វ ជាបុគ្គល ផ្សេង ៗ ជាវត្ថុរបស់ផ្សេង ៗ ។ ដរាបណាដែលនៅមិនទាន់ប្រចក្សច្បាស់លក្ខណៈដែលកើត រលត់នៃសភាវធម៌តែមួយខណៈ ។ តាមសេចក្តីពិតទេ ក៏មិនឈ្មោះថាដឹងច្បាស់នូវលោកតាមសេចក្តីពិត ទោះជានឹងបានសិក្សារឿងរបស់លោកដោយវិជ្ជាការផ្សេង ៗ តាមផ្លូវភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សូម្បីច្រើនសែន លានកោដិឆ្នាំក៏ដោយវិជ្ជាការទាំងឡាយនោះ ក៏មិនអាចធ្វើឱ្យផុតចាកពីលោកនេះបានឡើយ ព្រោះកាលណាមិនស្គាល់នូវលោក ក៏រមែងផុតចាកលោកមិនបាន ។

លោកមួយថ្ងៃ ។ នោះមានសារៈអ្វីខ្លះ សុខវេទនាកើតឡើង ហើយក៏រលត់អស់ទៅគ្រប់ខណៈ ហើយនឹងឱ្យសុខវេទនានោះ ត្រឡប់មកវិញទៀតមិនបានឡើយ ចំណែកអ្នកដែលទុក្ខលំបាកដ៏សែនក្រៃលែង សូម្បីនឹងចង់ផុតចាកលោកប៉ុណ្ណាក៏ដោយ ក៏ផុតមិនបាន កាលណាមិនស្គាល់នូវលោកតាមសេចក្តីពិតទេនោះ។

សេចក្តីសំខាន់ គឺអ្នកព្រមឬនៅ ? ក្នុងការលះបង់សេចក្តីប្រកាន់ថាមានសត្វ បុគ្គល តួខ្លួន សូម្បីតែតួខ្លួនអ្នកខណៈនេះក៏មិនមាន ព្រមនឹង

លះបង់ចោលលោកឬនៅ ? ត្រូវដឹងច្បាស់ថា មិនមានតួខ្លួន សត្វ បុគ្គល ជាមុនសិន ទើបនឹងអាចរលត់លោក និងផុតចាកលោកបាន ។

អ្នកខ្លះត្រឹមតែនឹកគិត ក៏អត់ធន់មិនញាប់ញ័រមិនបាន ក្នុងការដែលនឹងមានតួខ្លួនកំពុងឃើញ ឮ ជាដើម មិនមានញាតិវង្សានុវង្ស មិនមានមិត្តសម្លាញ់ មិនមានទ្រព្យសម្បត្តិវត្ថុផ្សេង ។ ដែលជាទីពេញចិត្តមួយចំណែកធំហើយ ក៏នៅតែមិនចង់ផុតចាកលោកពិត ។ ។ ដូច្នេះ ការដែលនឹងលះបង់សេចក្តីពេញចិត្តប្រកាន់ថា ជាតួខ្លួនរបស់យើងនោះ គឺត្រូវអប់រំចម្រើនបញ្ញារហូតទម្រាំដល់ប្រចក្សច្បាស់ សភាវធម៌ទាំងឡាយដែលប្រាកដជាលោកតាមសេចក្តីពិតនៃសភាវធម៌នោះ ។ ។

ការដែលនឹងស្គាល់នូវលោក តាមសេចក្តីពិតនោះ មិនងាយឡើយ ។ អ្នកដែលស្តាប់ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង រឿងលោកតាមដែលព្រះដ៏មានព្រះភាគត្រាស់ដឹង គួរនឹងពិចារណាបង្អោនប្រព្រឹត្តបដិបត្តិអប់រំចម្រើនបញ្ញា ទម្រាំនឹងបញ្ញាកើតឡើង ទើបដឹងលក្ខណៈនៃលោកតាមសេចក្តីពិតបាន មិនមែនដឹងលោកក្នុងខណៈដទៃឡើយ គឺដឹងលោកខណៈកំពុងឃើញ ឮ ធុំក្លិន ដឹងរស និងជោដ្ឋព្វៈ នឹកគិតក្នុងខណៈនេះឯង ។ មានគន្លងផ្លូវដែលនឹងធ្វើឱ្យបញ្ញាចម្រើនឡើងរហូតដឹងលោកដែលកំពុងកើតរលត់ក្នុងខណៈនេះបាន ដោយសិក្សា ស្តាប់ព្រះធម៌ ដើម្បីឱ្យយល់ និងពិចារណាដឹងលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដតាម

ផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត បើមិនដូច្នោះទេ គឺមិនមានផ្លូវដែលនឹងប្រចក្សដឹងច្បាស់លោកបានឡើយ ។

ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ សមិទ្ធិសូត្រ ព្រះសមិទ្ធិដ៏មានអាយុ ក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថាលោក ។ ដូចនេះ ដោយហេតុត្រឹមប៉ុណ្ណាទើបជាលោក ឬ បញ្ញត្តិថាលោក ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលសមិទ្ធិ ចក្ខុ រូប ចក្ខុវិញ្ញាណ ធម៌ដែលនឹងគប្បីដឹងច្បាស់ដោយចក្ខុវិញ្ញាណមាននៅក្នុងទីណា លោកឬ ការបញ្ញត្តិថាលោកក៏មាននៅក្នុងទីនោះ ។ល។

ការដែលនឹងស្គាល់លោកបាននោះ ក៏ព្រោះមានភ្នែកទើបឃើញ ពណ៌សម្បុរវណ្ណៈនៃលោក ។ មានត្រចៀក ទើបឮលោកសំឡេង មានច្រមុះ ទើបធុំលោកក្លិន មានអណ្តាត ទើបដឹងលោករស មានកាយទើបដឹងត្រជាក់ ក្តៅ រឹង ទន់ តឹង ញ័រនៃលោក បើមិនមានផ្លូវទាំងនេះទេ តើលោកនឹងបានប្រាកដទេ ? កាលមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងផោដ្ឋព្វៈ មិននឹកគិត តើលោកណាប្រាកដ លោកណា ។ ក៏រមែងមិនប្រាកដដែរ ។ ដូច្នោះ ដែលប្រកាន់ថាជាលោកដែលកំពុងប្រាកដ ក៏ព្រោះឃើញ ឃើញអ្វី ឃើញលោក អ្វីដែលប្រាកដតាមផ្លូវភ្នែកជាលោក ។ ឮសំឡេងអ្វី សំឡេងជាលោកទៀតដូចគ្នា បើមិនមានសំឡេងទេ មិនមានឮឡើយ លោកសំឡេងក៏មិនមាន ។ ដូច្នោះ លោកដែលប្រកបដោយ

រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះ ប្រាកដបានព្រោះ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទើបមិនត្រូវទៅស្វែងរកលោកទីដទៃ ។ មិនថានឹងនៅក្នុងលោកណា លោកនោះ ។ នឹងប្រាកដបានក៏ព្រោះភ្នែក ជាបច្ច័យឱ្យឃើញ ត្រចៀកជាបច្ច័យឱ្យឮ ច្រមុះជាបច្ច័យឱ្យធុំក្លិន អណ្តាតជាបច្ច័យឱ្យដឹងរស កាយជាបច្ច័យឱ្យដឹងផោដ្ឋព្វៈ និងចិត្តនឹកគិតរឿងនៃអ្វីដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តនោះឯង ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសមិទ្ធិ ចក្ខុ រូប ចក្ខុវិញ្ញាណ ធម៌ដែលគប្បីដឹងច្បាស់ដោយចក្ខុវិញ្ញាណមិនមាន ក្នុងទីណា លោកឬការបញ្ញត្តិថាលោកក៏មិនមានក្នុងទីនោះ ។ល។ ចិត្ត ធម្មារម្មណ៍ មនោវិញ្ញាណ ធម៌ដែលនឹងគប្បីដឹងច្បាស់ដោយមនោវិញ្ញាណមិនមានក្នុងទីណា លោក ឬការបញ្ញត្តិថា លោកក៏មិនមានក្នុងទីនោះ ។

កាលមិនស្គាល់នូវលោកតាមសេចក្តីពិត ប៉ុន្តែទោះជាចង់ផុតចាកលោកយ៉ាងណាក៏ដោយ ក៏ផុតមិនបាន ។ រស់នៅក្នុងលោកមកយូរយារណាស់ហើយ មិនចំពោះតែក្នុងលោកនេះប៉ុណ្ណោះទេ គឺក្នុងអតីតអនន្តជាតិរស់នៅក្នុងលោកដទៃ ។ មកយូរហើយ កាលណាមិនស្គាល់ច្បាស់នូវលោក ក៏ត្រូវនៅក្នុងលោកអស់កាលដ៏យូរតទៅទៀត ហើយរស់នៅទាំងមិនស្គាល់នូវលោក ទាំងមិនឃើញលោកតាមសេចក្តីពិត ជាសុខខ្លះ ជាទុក្ខខ្លះ វិលទៅវិលមក ។ សម័យនេះ អ្នកខ្លះពោលថា ព្រះមាន

ព្រះភាគបរិនិព្វានហើយ ក៏នៅមានតួខ្លួនព្រះអង្គដែរថែមទាំងពោលថា បានចូលទៅគាល់ និងថ្វាយភត្តាហារដល់ព្រះអង្គទៀត ។ នេះគួរតែពិចារណាសេចក្តីក្នុងព្រះត្រៃបិដក គឺក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ផគ្គុណៈសូត្រ ។

គ្រានោះឯង ព្រះផគ្គុណៈចូលទៅគាល់ ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ រួចហើយបានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលកាលនឹងបញ្ញត្តិ គប្បីបញ្ញត្តិព្រះពុទ្ធជាម្ចាស់ អ្នកកាត់ផ្តាច់តណ្ហាជាគ្រឿងធ្វើឱ្យយឺតយូរបានហើយ កាត់ផ្តាច់នូវផ្លូវបានហើយ គ្របសង្កត់វដ្តៈបានហើយ កន្លងផុតនូវទុក្ខទាំងពួងបរិនិព្វានកន្លងទៅហើយ ដោយចក្ខុណា ចក្ខុនោះមាន នៅឬ ហ្ន៎ ។ល។ ... បុគ្គលកាលនឹងបញ្ញត្តិ គប្បីបញ្ញត្តិព្រះពុទ្ធជាម្ចាស់ជាអ្នកកាត់ផ្តាច់នូវតណ្ហាជាគ្រឿងធ្វើឱ្យយឺតយូរបានហើយ កាត់ផ្តាច់នូវផ្លូវបានហើយ គ្របសង្កត់វដ្តៈបានហើយ កន្លងផុតនូវទុក្ខទាំងពួង បរិនិព្វានកន្លងទៅហើយ ដោយចិត្តណា ចិត្តនោះមាននៅឬហ្ន៎ ព្រះពុទ្ធជាម្ចាស់ ?

(**គឺទូលសួរថា កាលព្រះពុទ្ធជាម្ចាស់បរិនិព្វានហើយ តើនឹងនៅមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទៀតឬទេ**)

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលផគ្គុណៈ បុគ្គលកាលនឹងបញ្ញត្តិ គប្បីបញ្ញត្តិ ព្រះពុទ្ធជាម្ចាស់ អ្នកបានផ្តាច់តណ្ហាជាគ្រឿងធ្វើឱ្យយឺតយូរហើយ ផ្តាច់នូវផ្លូវបានហើយ គ្របសង្កត់វដ្តៈបានហើយ កន្លងផុត

នូវទុក្ខទាំងពួង បរិនិព្វានកន្លងទៅហើយ ដោយចក្ខុណា ចក្ខុនោះមិនមាន ឡើយ ។ល។ ... បុគ្គលកាលនឹងបញ្ញត្តិ គប្បីបញ្ញត្តិព្រះពុទ្ធជាម្ចាស់ អ្នកបានកាត់ផ្តាច់តណ្ហាជាគ្រឿងធ្វើឱ្យយឺតយូរហើយ ផ្តាច់នូវផ្លូវបាន ហើយ គ្របសង្កត់វដ្តៈបានហើយ កន្លងផុតទុក្ខទាំងពួង បរិនិព្វានកន្លងទៅ ហើយ ដោយចិត្តណា ចិត្តនោះមិនមានឡើយ ។

កាលណាបរិនិព្វានហើយ ទាំងភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនមានទៀតឡើយ មិនមែនថា បរិនិព្វានហើយក៏នៅកាន់ស្ថាន ទីណាមួយ ហើយមកជាប្រមុខនៃការធ្វើបុណ្យថ្វាយទាននោះទេ បើជា យ៉ាងដូច្នោះ ក៏មិនផុតអំពីលោកដែរ ព្រោះនៅមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត កើត រលត់ទើបត្រូវនៅមានទុក្ខ គឺផុតចាកទុក្ខមិន បានឡើយ ។

លោកជាសភាវៈដែលកំពុងប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត បើចិត្តមិនកើតឡើងឃើញ ឮ ធុំក្លិន ដឹងរស សម្ផស្ស នឹកគិតទេ លោករមែងមិនប្រាកដ ។ ខណៈណាដែល សតិបានរលឹក ក៏ពិចារណាសិក្សាអារម្មណ៍ គឺលក្ខណៈនៃលោកដែលកំពុង ប្រាកដតាមភ្នែក តាមត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត តែបើខណៈណា នឹកគិតរឿងលោក ខណៈនោះមិនមែនជាការដឹងលក្ខណៈពិតប្រាកដនៃ សភាវធម៌ ដែលមិនមែន សត្វ បុគ្គល តួខ្លួន នោះទេ ខណៈនោះជាការ

ដឹងលោកដោយសម្មតិ ជាសត្វ បុគ្គល តួខ្លួន វត្ថុរបស់ផ្សេង ។ ជាលោកដោយន័យនៃសម្មតិសច្ចៈ មិនមែនបរមត្ថសច្ចៈ ។

ក្នុងមួយថ្ងៃ ។ អ្នកគ្រប់គ្នាមានដឹងទេថា តើអ្នករស់នៅក្នុងលោកជាសម្មតិសច្ចៈឬ លោកបរមត្ថសច្ចៈ ? ទោះបីចិត្តជាសភាពដឹងមែន តែខណៈណាដែលមិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស មិននឹកគិត ខណៈនោះលោកនេះក៏មិនប្រាកដ ។ បដិសន្ធិចិត្ត គឺចិត្តខណៈដំបូងនៃលោកនេះជាវិបាកចិត្ត ជាផលរបស់កម្មមួយ ដែលធ្វើឱ្យបដិសន្ធិចិត្តកើតបន្តពីចុតិចិត្ត ដែលជាចិត្តខណៈចុងក្រោយបំផុតនៃជាតិមុន ។

បដិសន្ធិចិត្តដឹងអារម្មណ៍មួយជាមួយគ្នានឹងចិត្តជិតនឹងចុតិនៃជាតិមុន កាលបដិសន្ធិចិត្តមិនដឹងអារម្មណ៍នៃលោកនេះ លោកនេះទើបមិនទាន់ប្រាកដ ហើយកាលបដិសន្ធិចិត្តរលត់ទៅហើយ កម្មដែលធ្វើឱ្យបដិសន្ធិចិត្តកើតនោះ ក៏ធ្វើឱ្យភវង្គចិត្តកើតបន្តពីបដិសន្ធិចិត្ត ។ ភវង្គចិត្តមានអារម្មណ៍មួយជាមួយគ្នានឹងបដិសន្ធិចិត្ត ។ ខណៈដែលភវង្គចិត្តកើតរលត់ ។ បន្តគ្នា នៅតម្រង់ភពជាតិនេះ មិនដឹងអារម្មណ៍របស់លោកនេះ មិនឃើញ មិនឮ មិនធុំក្លិន មិនដឹងរស មិនដឹងផោដ្ឋព្វៈ មិននឹកគិតឡើយ ។ ខណៈដែលភវង្គចិត្តកើតឡើង និងរលត់ទៅជារឿយ ។ នោះ លោកនេះមិនប្រាកដ ។

ទ្វារ គឺផ្លូវដែលចិត្តកើតឡើង ដឹងលោកដែលប្រាកដ មានទាំងអស់ ៦ ទ្វារ ជារូប ៥ ទ្វារ និងជានាម ១ ទ្វារ គឺ

ចក្ខុបសាទរូប	ជា	ចក្ខុទ្វារ	១
សោតបសាទរូប	ជា	សោតទ្វារ	១
ឃានបសាទរូប	ជា	ឃានទ្វារ	១
ជិវ្ហាបសាទរូប	ជា	ជិវ្ហាទ្វារ	១
កាយបសាទរូប	ជា	កាយទ្វារ	១
ភវង្គុបច្ឆេទចិត្ត	ជា	មនោទ្វារ	១

បសាទរូបនីមួយ ៗ មានលក្ខណៈពិសេសដែលប៉ះខ្ទប់នឹងរូបបានចំពោះរូបខ្លះ ហើយទើបជាផ្លូវធ្វើឱ្យចិត្តកើតឡើង ដឹងអារម្មណ៍ដែលប៉ះខ្ទប់នោះបានចំពោះទ្វារនៃខ្លួន ៗ ប៉ុន្តែក្នុងមួយថ្ងៃ ៗ ក៏មិនមានតែឃើញ ឮ ធុំក្លិន ដឹងរស និងដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្សកាយប៉ុណ្ណោះទេ នៅនឹកគិតរឿងផ្សេង ៗ ផងដែរ ។ ខណៈដែលចិត្តទទួលដឹងអារម្មណ៍តអំពីផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ឬនឹកគិតរឿងរ៉ាវផ្សេង ៗ នោះ ចិត្តមិនបានអាស្រ័យចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូបឡើយ ប៉ុន្តែអាស្រ័យភវង្គុបច្ឆេទចិត្តដែលកើតមុនមនោទ្វារវាវជ្ជនចិត្តនោះឯងជាទ្វារ គឺជាផ្លូវដែលចិត្ត នឹងកើតឡើងនឹកគិតរឿងរ៉ាវផ្សេង ៗ ព្រោះបើថាភវង្គុបច្ឆេទចិត្តមិនកើត វិថីចិត្តដំបូងដែលដឹងអារម្មណ៍តាមផ្លូវចិត្ត គឺមនោទ្វារវាវជ្ជនចិត្តក៏កើតមិនបាន ។ ដូច្នោះ

មនោទ្វារ និងមនោទ្វាររាវជ្ជនចិត្តក៏កើតមិនបាន ។ ដូច្នោះ មនោទ្វារ និងមនោទ្វារាវជ្ជនចិត្តទើបផ្សេងគ្នា **គឺភវង្គុបច្ឆេទចិត្ត ជាមនោទ្វារ ជាវិចារចិត្ត មិនមែនវិថីចិត្ត មនោទ្វារាវជ្ជនចិត្ត មិនមែនមនោទ្វារ ជាកិរិយាចិត្ត ជាវិថីចិត្តដំបូងដែលកើតឡើង ដឹងអារម្មណ៍តាមមនោទ្វារ** ។

នេះជាជីវិតប្រក្រតីប្រចាំថ្ងៃ ដែលគួរតែនឹងយល់លក្ខណៈនៃទ្វារ ដើម្បីនឹងបានពិចារណាដឹងនូវសភាវធម៌ តាមសេចក្តីពិតថា សភាវធម៌ មួយខណៈ ។ ដែលកើតរលត់នោះ តើមិនមែនសត្វ បុគ្គល តួខ្លួន យ៉ាងណា ?

ខណៈនេះគង់នឹងមិនមានអ្នកណាគិតដល់ ចក្ខុបសាទរូបសុទ្ធតែជារូបដែលមានពិត ហើយកំពុងកើតរលត់ត្រង់កណ្តាលភ្នែក ។ ក្នុងអដ្ឋសាលិនី រូបកណ្ឌ សេចក្តីក្នុងព្រះបាលី ចក្ខាយតននិទ្ទេស មានសេចក្តី ថា

រូប ដែលហៅថា **ចក្ខាយតនៈ** នោះយ៉ាងណា ចក្ខុណាជាចក្ខុបសាទរូប អាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តក្នុងអត្តភាព ជាសភាវដែលឃើញមិនបាន តែប៉ះខ្ទប់បាន ។

ចក្ខាយតនៈ ជាពាក្យរួមគ្នានៃចក្ខុ និងអាយតនៈ

ចក្ខុ គឺភ្នែក **អាយតនៈ** គឺទីប្រជុំ ទីកើត ដូច្នោះ **ចក្ខាយតនៈគឺចក្ខុដែលជាទីប្រជុំ ជាទីកើតនោះឯង** ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នៅពេលវិថីចិត្តផ្សេង ។ កើតឡើងឃើញហើយដឹងនូវរូបារម្មណ៍តាមចក្ខុទ្វារមួយវារៈ រលត់ទៅហើយ

ភវង្គចិត្តក៏កើតរលត់បន្តច្រើនខណៈ ហើយចិត្តក៏កើតឡើងដឹងរូបារម្មណ៍ដែលប្រាកដតាមចក្ខុទ្វាររលត់ទៅហើយនោះ តតាមផ្លូវមនោទ្វារទៀត ។ មនោទ្វារវិថីចិត្ត កើតឡើងដឹងអារម្មណ៍តាមផ្លូវមនោទ្វារតអំពីចក្ខុទ្វារវិថីចិត្តដែលរលត់អស់ទៅហើយនោះ យ៉ាងរហ័សណាស់ទោះជាមានភវង្គចិត្តកើតខណ្ឌក៏ដោយ ។ ដូច្នោះទើបគួរជ្រាបនូវប្រយោជន៍ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងរឿងនៃទ្វារដោយល្អិតល្អន់ ដើម្បីមិនឱ្យច្រឡំចិត្តដែលដឹងអារម្មណ៍ តាមផ្លូវចក្ខុទ្វារ និងចិត្តដែលដឹងអារម្មណ៍នោះតមកផ្លូវមនោទ្វារ តាមផ្លូវសោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ និងកាយទ្វារ ក៏ដោយន័យតែមួយដូចគ្នា **គឺកាលវិថីចិត្តផ្សេងគ្នាកើតឡើងដឹងអារម្មណ៍ណាមួយតាមទ្វារណាមួយក្នុងទ្វារទាំង ៥ រលត់ទៅហើយ និងភវង្គចិត្តកើតខណ្ឌច្រើនខណៈហើយ ចិត្តក៏កើតឡើងដឹងអារម្មណ៍តែមួយដូចគ្នានោះ តមកតាមផ្លូវមនោទ្វារគ្រប់ពេល** ។

នាមធម៌ គឺចិត្ត និងចេតសិក កើត រលត់បន្តគ្នាយ៉ាងរហ័សនៅខណៈដែលអង្គុយយ៉ាងនេះ មើលទៅដូចជាទាំងឃើញផង ឮផង ប៉ុន្តែសេចក្តីពិត វិថីចិត្តអាស្រ័យទ្វារមួយកើតឡើងដឹងអារម្មណ៍តាមទ្វារមួយនោះហើយ ក៏រលត់ទៅយ៉ាងរហ័សនៃទ្វារវារៈមួយ ។ (វារៈគឺចិត្តច្រើនខណៈ ដែលកើតរលត់បន្តគ្នាតាមទ្វារតែមួយដូចគ្នា) ។ ការកើត រលត់បន្តយ៉ាងរហ័សនៃចិត្ត រហូតដល់មិនអាចដឹងលក្ខណៈពិត ។ នៃចិត្តដែលកើតឡើងតាមចក្ខុទ្វារថា ត្រឹមតែដឹងអ្វីដែលប្រាកដតាមផ្លូវភ្នែកប៉ុណ្ណោះ

កាលមនោទ្វារវិថីចិត្តកើតឡើងបន្តទទួលដឹងរូបារម្មណ៍ ដែលប្រាកដតាមភ្នែកហើយ ក៏ចាំរូបរាង សណ្ឋាននៃអ្វីដែលប្រាកដ រហូតដល់ភ្លេចថា អ្វីដែលប្រាកដតាមផ្លូវភ្នែកនោះ ត្រឹមតែជាអ្វីដែលប្រាកដតាមភ្នែកនោះ ប៉ុណ្ណោះយ៉ាងពិតប្រាកដ ។

ចក្ខុទ្វារប្រៀបដូចសមុទ្រដ៏ធំធេង ទូលំទូលាយពិត ។ មិនចេះពេញ អាចឃើញព្រះច័ន្ទ ព្រះអាទិត្យ ដួងផ្កាយផ្សេង ។ ដែលប៉ះខ្ទប់នឹងចក្ខុបសាទហើយក៏ប្រាកដដល់ចក្ខុទ្វារវិថីចិត្តបាន ហើយក៏ធ្វើឱ្យមើលទៅដូចជាថា ជាលោកដែលពោរពេញទៅដោយវត្ថុ ចក្រវាឡ សត្វ បុគ្គល ផ្សេង ។ ពេញទាំងអស់ ប៉ុន្តែតាមសេចក្តីពិតនោះ ចិត្តនឹកគិតដល់រូបរាង សណ្ឋានរបស់ដី ទឹក ភ្លើង ខ្យល់ ដែលប្រាកដឱ្យឃើញជាសត្វខ្លះ ជាបុគ្គលផ្សេង ។ ខ្លះ ជាព្រះច័ន្ទ ព្រះអាទិត្យ ដួងតារា និងវត្ថុផ្សេង ។ បើមកប៉ះខ្ទប់នឹងកាយសម្ផស្ស សភាពត្រជាក់ ឬក្តៅ ទន់ ឬរឹង តឹង ឬញ័រ ក៏ប្រាកដ ។ អ្នកដែលដឹងច្បាស់នូវសភាវធម៌តាមសេចក្តីពិត ទើបប្រកាសថាលោក គឺធម៌ដែលបែកធ្លាយ កើត រលត់យ៉ាងរហ័ស ដោយមនោទ្វារវិថីចិត្តកំណត់ចាំនូវសណ្ឋាននូវអ្វីដែលប្រាកដតាមផ្លូវភ្នែក ចាំនូវសំឡេងខ្ពស់ ទាប ដែលប្រាកដតាមផ្លូវត្រចៀក ។ ល ។ ជាសេចក្តីសម្គាល់នូវពាក្យបញ្ញត្តិ នៃអ្វីផ្សេង ។ សុទ្ធតែមិនមានសភាវធម៌ណាឡើយ ដែលកើតឡើងហើយមិនរលត់ទៅវិញ ។

សំណួរសាឡើងវិញ

១ - តើលោក គឺអ្វី ?

២ - តើលោកិយបញ្ញា គឺអ្វី ?

៣ - តើបដិសន្ធិចិត្ត ដឹងអារម្មណ៍នៃលោកនេះឬទេ ព្រោះហេតុអ្វី ?

៤ - តើភវង្គចិត្ត ដឹងអារម្មណ៍អ្វី ?

៥ - មនោទ្វារាវជ្ជនចិត្ត ជាមនោទ្វារមែនឬ ?

៦ - មនោទ្វារ ជាជាតិអ្វី ?

៧ - តើមនោទ្វារាវជ្ជនចិត្ត ជាជាតិអ្វី ?

មេរៀនទី ១៦

លក្ខណៈនៃចិត្តប្រការទី ៥ ឈ្មោះថា **ចិត្ត** ព្រោះធ្វើឱ្យវិចិត្រ ។

សេចក្តីក្នុងអដ្ឋសាលិនីអដ្ឋកថា មានថា ឈ្មោះថា **ចិត្ត** ព្រោះធ្វើឱ្យវិចិត្រយ៉ាងណា ។ ពិតណាស់ ធម្មតាការវិចិត្រដទៃនឹងក្រៃលែងជាងចិត្រកម្មរមែងមិនមានក្នុងលោក ។ ធម្មតារូបចម្លាក់ក្នុងចិត្រកម្មនោះ ។ ក៏ជាការវិចិត្រ គឺជាសម្រស់យ៉ាងក្រៃលែងបំផុត ។ ពួកជាងចម្លាក់ កាលធ្វើកិច្ចកម្មនោះរមែងកើតចិត្តសញ្ញាថា រូបដ៏ច្រើនប្រភេទទាំងឡាយ គេគប្បីធ្វើក្នុងត្រង់នេះ ដោយឧបាយយ៉ាងនេះ ការធ្វើឱ្យវិចិត្រទាំងឡាយដែលឱ្យសម្រេចកិច្ច មានការគូរ ការដាក់ពណ៌ ការធ្វើពណ៌ឱ្យស្រស់ និងការលាយពណ៌ជាដើម រមែងកើតឡើងដោយសញ្ញាដែលវិចិត្រ ។ រូបដែលវិចិត្រយ៉ាងណាមួយក្នុងការវិចិត្រ គឺរូបចម្លាក់រមែងសម្រេចមកអំពីការធ្វើដែលវិចិត្រនោះ ។ ព្រោះដូច្នោះ សិល្បៈដែលវិចិត្រគ្រប់បែបក្នុងលោក ដែលចិត្តនោះឯងគិតថា រូបនោះត្រូវនៅលើរូបនេះ រូបនេះត្រូវនៅក្រោមរូបនេះ រូបនេះត្រូវនៅទាំងពីរខាងនេះ ដូចនេះហើយ ទើបធ្វើដូចរូបដែលវិចិត្រហើយ រមែងគប្បីសម្រេចបានដោយកម្មដែលជាងគិតទុក សូម្បីចិត្តដែលសម្រេចការវិចិត្រនោះ ក៏ឈ្មោះថាចិត្តយ៉ាងនោះដូចគ្នា ព្រោះជាធម្មជាតិវិចិត្រដោយការធ្វើនេះ ដូចពណ៌នាមកយ៉ាងនេះ ។

ម្យ៉ាងទៀត ចិត្តនោះឯងឈ្មោះថា វិចិត្រជាងរូបចម្លាក់ក្នុងចិត្រកម្មនោះ ព្រោះឱ្យសម្រេចចិត្រកម្មតាមដែលចិត្ត គិតគ្រប់បែបយ៉ាង ។

នេះត្រឹមតែជាចំណែកបន្តិចបន្តួច គឺជាការវិចិត្ររបស់ចិត្តកម្ម ប៉ុណ្ណោះ ប៉ុន្តែការវិចិត្ររបស់កម្ម ដែលអស់លោកគ្រប់គ្នាធ្វើក្នុងមួយថ្ងៃ ។ តាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ តាមផ្លូវចិត្តខ្លះ ដែលជាកុសលកម្ម ជាទានខ្លះ សីលខ្លះ ជាការអប់រំចម្រើនភាវនាខ្លះ ឬក៏ជាអកុសលកម្ម ជាបាណាតិបាតខ្លះ អទិន្នាទានខ្លះ ក៏រមែងនឹងវិចិត្រសន្ធឹកសន្ធាប់ណាស់ សុទ្ធតែសម្តែងឱ្យឃើញថា ជាលក្ខណៈនៃចិត្តដែលវិចិត្រ ។ រូបធាតុខាងក្រៅ ដែលវិចិត្រដោយពូជធញ្ញាហារផ្សេង ។ ជាផ្កា ស្លឹកឈើ ជាវត្ថុ ភ្នំ ទន្លេផ្សេង ។ សុទ្ធតែជាវត្ថុដែលកើតព្រោះចំណែកផ្សំរបស់ធាតុដី ទឹក ភ្លើង ខ្យល់ ដែលមានលក្ខណៈរឹង ទន់ ហូរជ្រាប ឬប្រមូលផ្តុំ ត្រជាក់ ក្តៅ តឹង ញ័រ តាមលំដាប់ផ្សេង ។ ធ្វើឱ្យប្រាកដជាសភាវៈដែលវិចិត្រផ្សេង ។ ប៉ុន្តែ សភាវៈដែលវិចិត្រជាងរូបធាតុខាងក្រៅនោះទៅទៀត គឺចិត្ត ព្រោះថាចិត្ត ជាសភាពដែលធ្វើឱ្យវិចិត្រ ។

អកុសលកម្មដែលវិចិត្រ ជាបច្ច័យឱ្យសត្វតិរច្ឆានមានរូបរាង វិចិត្រផ្សេង ។ គ្នាណាស់ ប្រភេទខ្លះក៏មានជើង ២ ប្រភេទខ្លះក៏មានជើង ៤ ប្រភេទខ្លះក៏មានជើងច្រើន ប្រភេទខ្លះក៏មិនមានជើងសោះ ប្រភេទខ្លះ ក៏រស់នៅក្នុងទឹក ប្រភេទខ្លះក៏រស់នៅលើគោក និងកុសលកម្មដែលវិចិត្រ ក៏ធ្វើឱ្យមនុស្ស វិចិត្រផ្សេងគ្នាទៅដោយភេទ ដោយរូបរាង មុខមាត់ ដែលធ្វើឱ្យកើតវោហារ គឺពាក្យនិយាយ ដែលសម្តែងលក្ខណៈអាការនៃ

សភាវធម៌ទាំងឡាយតាមដែលប្រាកដ ពាក្យនិយាយមានច្រើនណាស់ ភាសាដែលនិយាយដល់សភាវៈផ្សេង ។ សម្តែងឱ្យឃើញថា ព្រោះមានវត្ថុផ្សេង ។ ដែលវិចិត្រច្រើនត្រឹមណា ក៏ធ្វើឱ្យកើតរោហារដើម្បីនឹងហៅ នូវអ្វីដែលប្រាកដ ដែលវិចិត្រត្រឹមនោះដែរ ហើយពាក្យនិយាយក៏មិនមានថ្ងៃណានឹងអស់ និងចប់ដែរ ព្រោះថាមានអ្វីដែលចិត្តធ្វើឱ្យវិចិត្រ កើតឡើងរឿយ ។ ដូច្នោះ ហើយ ទើបត្រូវបញ្ញត្តិពាក្យនិយាយហៅ អ្វីដែលចិត្តធ្វើឱ្យវិចិត្រច្រើនឡើង ។ ។

ក្នុងមួយថ្ងៃ ។ សូមជ្រាបថា មិនថានឹងនៅទីណា មិនថានឹងឃើញអ្វី ឬនឹងនិយាយអ្វី រមែងសម្តែងឱ្យឃើញសេចក្តីវិចិត្ររបស់ចិត្ត ដែលធ្វើរបស់ផ្សេង ។ ទាំងនោះឱ្យវិចិត្រ ព្រះដ៏មានព្រះភាគត្រាស់ឱ្យរលឹកដល់លក្ខណៈនៃចិត្តក្នុងខណៈនេះ កាលឃើញការវិចិត្រផ្សេង ។ ដែលចិត្តធ្វើវិចិត្រ ចិត្តក្នុងខណៈនេះឯងកំពុងធ្វើឱ្យវិចិត្រទៅខាងមុខទៀត ហើយមិនគួរគិតដល់ការវិចិត្ររបស់អ្វីខាងក្រៅ ដែលចិត្តធ្វើឱ្យវិចិត្រប៉ុណ្ណោះឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ឱ្យរលឹកដឹងនូវលក្ខណៈនៃចិត្តដែលកំពុងប្រព្រឹត្តខណៈនេះ ជាចិត្តានុបស្សនាសតិប្បដ្ឋាន ការដែលដឹងលក្ខ-ណៈនៃចិត្ត ត្រូវដឹងក្នុងខណៈដែលកំពុងឃើញ កំពុងឮ កំពុង ដឹងក្លិន កំពុង ដឹងរស កំពុងនឹកគិត ដែលត្រូវអាស្រ័យទ្វារណាមួយ ក្នុងទ្វារទាំង ៦ ។

អស់លោកទាំងអស់គ្នាគិត ខណៈដែលចិត្តគិតដល់រឿងណា រឿងនោះក៏មានត្រឹមមួយជួរខណៈដែលចិត្តកំពុងគិតនឹកដល់រឿងនោះ ។ ចិត្តជាសភាពគិតបើមិនពិចារណាចិត្តក្នុងខណៈដែលកំពុងឃើញឥឡូវនេះ ឬកំពុងឮឥឡូវនេះ កំពុងធំក្លិនឥឡូវនេះ កំពុងដឹងរសឥឡូវនេះ កំពុងប៉ះខ្ទប់សម្ផស្សផោដ្ឋព្វៈ ឬកំពុងនឹកគិតឥឡូវនេះទេនោះ ហើយតើនឹងដឹងលក្ខណៈនៃចិត្តបានខណៈណាវិញ ។

សេចក្តីក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ គទ្ទូលសូត្រ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយរមែងសៅហ្មងព្រោះចិត្តសៅហ្មង សត្វទាំងឡាយរមែងបរិសុទ្ធព្រោះចិត្តផូរផង់ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលឈ្មោះថាចរណៈ (ត្រាច់ទៅ) អ្នកទាំងឡាយឃើញហើយឬ ? ភិក្ខុទាំងឡាយក្រាបទូលថា ឃើញហើយព្រះអង្គ ។

ចិត្តត្រាច់ទៅយ៉ាងណា តាមផ្លូវភ្នែកឃើញ តាមផ្លូវត្រចៀកឮ តាមផ្លូវច្រមុះធុំក្លិន តាមផ្លូវអណ្តាតដឹងរស តាមផ្លូវកាយប៉ះខ្ទប់សម្ផស្ស តាមផ្លូវចិត្តនឹកគិត លោកអ្នកគ្រប់គ្នាដឹងខ្លួនថា ចូលចិត្តដើរលេង មិនមានអ្នកណាចូលចិត្តនៅតែមួយកន្លែងដដែល ។ នោះទេ ព្រោះថាត្រូវការឃើញរូប ឮសំឡេង ធុំក្លិន ដឹងរស ដឹងសម្ផស្សផោដ្ឋព្វៈផ្សេង ។ ដូច្នោះទើបចិត្តកើតឡើងត្រាច់ទៅក្នុងអារម្មណ៍តាមទ្វារផ្សេង ។ តាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ តាមផ្លូវចិត្ត មិននៅស្ងៀមឡើយ មានចិត្តអ្នកណានៅនឹងថ្កល់បានខ្លះ បើដឹងលក្ខណៈ

នៃសភាវធម៌តាមសេចក្តីពិត នឹងត្រូវដឹងថាចិត្តកើតឡើង ដឹងអារម្មណ៍ណាមួយហើយ ក៏រលត់ទៅ នោះគឺការដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិត ។

សេចក្តីតទៅ ព្រះមានព្រះភាគត្រាស់ថា ចិត្តឈ្មោះថា ចរណៈ យ៉ាងដូច្នោះអ្នកទាំងឡាយគិតស្រេចដោយចិត្តនោះឯង ចិត្ត (ជាគ្រឿងគិត) នោះឯងវិចិត្រជាងចរណៈចិត្តយ៉ាងនោះ ព្រោះហេតុនោះអ្នកទាំងឡាយគប្បីពិចារណាចិត្តនៃខ្លួនឯងជារឿយ ។ ថា ចិត្តនោះ សៅហ្មងស្រេចហើយដោយ រាគៈ ទោសៈ មោហៈ អស់កាលដ៏យូរ ។ សត្វទាំងឡាយរមែងសៅហ្មង ព្រោះចិត្តសៅហ្មង សត្វទាំងឡាយរមែងបរិសុទ្ធ ព្រោះចិត្តផូរផង់ ម្នាលភិក្ខុទាំងឡាយ យើងរមែងមិនពិចារណាឃើញសូម្បីពពួកដទៃណាមួយ ដែលវិចិត្រដូចយ៉ាងសត្វតិរច្ឆាន ទាំងឡាយនេះឡើយ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆានពួកទាំងអស់នេះ គិតស្រេចហើយដោយចិត្តនេះឯង ចិត្តនោះឯងវិចិត្រជាងសត្វតិរច្ឆានអស់ទាំងនោះទៀត ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីពិចារណាចិត្តនៃខ្លួនរឿយ ។ ថាចិត្តនោះ សៅហ្មងហើយដោយ រាគៈ ទោសៈ មោហៈ អស់កាលដ៏យូរ សត្វទាំងឡាយរមែងសៅហ្មង ព្រោះចិត្តសៅហ្មង សត្វទាំងឡាយរមែងបរិសុទ្ធ ព្រោះចិត្តស្អាតផូរផង់ ។ ម្នាលភិក្ខុទាំងឡាយ ជាងលាបឬជាងគូរ កាលមានគ្រឿងលាបគ្រប់គ្រាន់ហើយ ពណ៌លឿងក្តី ពណ៌ខៀវក្តី ពណ៌ក្រហមក្តី គប្បីគូររូបស្ត្រី ឬបុរសមានអវយវៈតូច ធំសព្វគ្រប់ចំណែក

ដាក់ត្រង់ផ្ទៃក្តារដ៏ស្អាត ឬត្រង់ជញ្ជាំង ឬត្រង់ផ្ទាំង ក្រណាត់យ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនបានស្តាប់ មិនបានសិក្សានូវធម៌ របស់សប្បុរសក៏យ៉ាងនោះដូចគ្នា កាលនឹងឱ្យកើតរមែងញុំាងរូបនោះឯង ឱ្យកើត កាលនឹងឱ្យកើត រមែងញុំាងវេទនានោះឯងឱ្យកើត កាលនឹង ឱ្យកើតរមែងញុំាង សញ្ញានោះឯងឱ្យកើត កាលនឹងឱ្យកើតរមែងញុំាង សង្ខារនោះឯងឱ្យកើត កាលនឹងឱ្យកើត រមែងញុំាង វិញ្ញាណនោះឯង ឱ្យកើត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសំគាល់ សេចក្តីនោះយ៉ាង ណារូបទៀង ឬមិនទៀង ។

ភិ. មិនទៀងទេ ព្រះអង្គ

ព. វេទនា សញ្ញា សង្ខារ វិញ្ញាណ ទៀងឬមិនទៀង

ភិ. មិនទៀងទេ ព្រះអង្គ

ព. ព្រោះហេតុដូច្នោះ ។ល។ អរិយសាវ័កជាអ្នកបានស្តាប់ ឃើញ រឿយ ។ យ៉ាងនោះ ។ល។ ដឹងច្បាស់ថាកិច្ចដទៃ ដើម្បីសេចក្តីជាយ៉ាងនេះ មិនបានមានឡើយ ។

(ចប់សូត្រទី ៨)

ជាងគូររូបអាស្រ័យពណ៌គូររូបផ្សេង ។ ធ្វើឱ្យវិចិត្រកើតឡើងជារូប ផ្សេង ។ យ៉ាងណា ខណៈនេះចិត្តរបស់លោកអ្នកម្នាក់ ។ ក៏នឹងដូច នឹងជាងគំនូរដែរ ដែលកំពុងគូររូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលនឹងកើតតទៅក្នុងអនាគតនោះ ។

ខណៈនេះលោកអ្នកគ្រប់គ្នាលោកអ្នកផ្សេង ៗ គ្នា តាមកម្ម ដែលវិចិត្រដែលបានធ្វើទុក តាំងពីយូរយារមកហើយយ៉ាងណា ចិត្តដែលកំពុងធ្វើឱ្យវិចិត្រនៅក្នុងខណៈនេះ ក៏នឹងធ្វើឱ្យគតិ ភេទ រូបរាង សណ្ឋាន លាភ យស សុខ ទុក្ខ និន្ទា សរសើរ វិចិត្រផ្សេង ៗ ក្នុងកាលខាងមុខក៏យ៉ាងនោះដែរ ។ ដោយហេតុនេះទើបគួរពិចារណាលក្ខណៈនៃចិត្ត ដែលកំពុងប្រាកដ ដែលកំពុងគួរសភាវធម៌ទាំងឡាយ ដែលនឹងកើតឡើងនៅពេលខាងមុខ សឹងបើមិនរលឹកដឹង លក្ខណៈនៃចិត្តក្នុងខណៈនេះទេ រមែងនឹងមិនជ្រាបទាល់តែសោះថាវិចិត្រពិត ៗ ទាំងដែលកំពុងនៅអង្គុយ ចិត្តក៏កើតរលត់បន្តយ៉ាងរហ័សហួសប្រមាណ ។ អង្គុយនៅទីនេះ តែពេលខ្លះ ក្រៅពីចិត្តឃើញតាមភ្នែក ឮសំឡេងតាមត្រចៀកហើយ ក៏នៅមានចិត្តដែលនឹកគិតចេញទៅឆ្ងាយ ៗ ស្រេចតែថា នឹងគិតត្រាច់រង្គាត់ទៅទីណាខ្លះ ឬអាចនឹងកំពុងគិត ធ្វើអ្វីដែលវិចិត្រឱ្យកើតឡើងក្នុងខណៈនោះ ។

សេចក្តីក្នុងគម្ពូលសូត្រទី ១ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុនខដែលគេចងទុកដោយខ្សែត្រួវលាមត្រង់បង្គោល ឬសសរដ៏មាំ រមែងរត់ជុំវិញតែនឹងបង្គោល ឬសសរនោះឯង វេលាឈរក៏រមែងឈរជិតតែនឹងបង្គោល ឬនឹងសសរនោះឯង ឯបុថុជ្ជនជាអ្នកមិនបានស្តាប់ មិនបានសិក្សាធម៌របស់សប្បុរសក៏យ៉ាងនោះដូចគ្នាដែរ ។

ជាងគំនូរប្រកាន់នូវចិត្រកម្ម ដែលគួរហើយថាជាវត្ថុណាមួយយ៉ាងណាចិត្តរបស់បុថុជ្ជនដែលនៅប្រកាន់ក្នុងរូបថាជាសត្វ បុគ្គល តួខ្លួន

ក៏នឹងគង់នៅ ប្រកាន់ស្អិតទៅគ្រប់ភព គ្រប់ជាតិ ដូចនឹងជាងគំនូរ ដែលប្រកាន់ក្នុងចិត្រកម្មដែលខ្លួនគូរហើយក៏យ៉ាងនោះ ។ ដរាបណាដែលនៅតែមិនដឹងលក្ខណៈនៃរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលសុទ្ធតែជាសភាពធម៌ដែលកើតឡើង ហើយរលត់ទៅតាមសេចក្តីពិតទេ អ្នកដែលជាបុថុជ្ជនកាលឈរ ក៏រមែងឈរនៅជិតនឹងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសេចក្តីជាតួខ្លួន ដរាបនោះដែរ ។

សេចក្តីក្នុងសារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ មារសំយុត្ត ទុតិយវគ្គ បត្តសូត្រទី ៦ ធ្វើឱ្យយល់ព្យញ្ជនៈ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ដើម្បីឱ្យព្រះភិក្ខុទាំងឡាយឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យឱ្យគប្បីជ្រាប បត្តសូត្រទី ៦ ក៏គឺសម័យនោះព្រះមានព្រះភាគទ្រង់ញុាំងភិក្ខុទាំងឡាយ ឱ្យឃើញច្បាស់ ឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយជាមួយធម៌ដែលមានកថាទាក់ទង ដោយឧបាទានក្ខន្ធ ៥ ហើយភិក្ខុទាំងនោះក៏ធ្វើឱ្យចិត្តសម្រេចប្រយោជន៍ បង្អោនមកគិតនឹកដោយពេញចិត្ត ផ្ទៀងនូវសោតបសាទ ត្រងត្រាប់ ស្តាប់ធម៌ ។

ពាក្យថា **ឱ្យសមាទាន** គឺការឱ្យកាន់យក ឱ្យយល់ ឱ្យពិចារណាបានត្រឹមត្រូវ នេះគឺការសម្តែងធម៌របស់ព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ឱ្យកើតសេចក្តីយល់ត្រឹមត្រូវ គឺកាលស្តាប់ហើយក៏ឱ្យសមាទាន ឱ្យយល់ ឱ្យពិចារណា ឱ្យបានត្រឹមត្រូវថា កុសលធម៌ជាកុសលធម៌

អកុសលធម៌ជាអកុសលធម៌ ប្រសិនបើព្រះមានព្រះភាគទ្រង់មិនបានសម្តែងឱ្យល្អិតល្អន់ទេ លោកអ្នកគ្រប់គ្នាទាំងឡាយ ក៏នឹងអាចប្រកាន់នូវអកុសលធម៌ ថាជាកុសលធម៌ក៏បាន ប៉ុន្តែដោយសារថា សភាវៈលក្ខណៈនៃអកុសលធម៌ មិនមែនកុសលធម៌យ៉ាងដូច្នេះ ទើបព្រះមានព្រះភាគទ្រង់សម្តែងធម៌ដោយល្អិតល្អន់ជានិច្ចទាក់ទង ដោយឧបាទានក្ខន្ធ ៥ គឺ ចិត្ត ចេតសិក រូប ដែលចែកចេញជារូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលមិនថានៅទីណា ។ ក៏ដោយ ក៏មិនផុតប្រាសចាកពីខន្ធ ៥ ឡើយ ដូច្នោះ ទើបគួរនឹងសិក្សារឿងរបស់ខន្ធ ៥ និងពិចារណារឿងនៃខន្ធ ៥ ដោយប្រាជ្ញាដ៏ប្រពៃ ដើម្បីនឹងបានកាន់យកនូវសេចក្តីត្រឹមត្រូវ និងការមិនយល់ខុស ។

ពាក្យថា **ឱ្យអាចហ៊ាន** គឺឱ្យកើតសេចក្តីឧស្សាហៈក្នុងការសមាទាន ។

ការដែលនឹងយល់បាននូវសភាវធម៌តាមសេចក្តីពិតនោះ មិនមែននឹងប្រព្រឹត្តទៅបាន ដោយរហ័សស្រួល ។ ងាយ ។ នោះទេ ប៉ុន្តែព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងនោះ គឺដើម្បីឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យកើតសេចក្តីព្យាយាម និងពិចារណាទម្រាំតែនឹងយល់រហូតទាល់តែនឹងសតិកើតរលឹកដឹងនូវលក្ខណៈនៃសភាវធម៌រហូតទាល់តែនឹងប្រចក្សច្បាស់នូវលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដជាប្រក្រតីតាមសេចក្តីពិត ព្រោះព្រះមានព្រះភាគមិនបានសម្តែង នូវរឿងដទៃផ្សេង

ដែលពិសោធន៍មិនបានឡើយ ឬដែលមិនបានកំពុងប្រាកដចំពោះមុខឡើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងរឿងចក្ខុវិញ្ញាណ រឿងនៃការឃើញ រឿងនៃសភាវៈដែលប្រាកដតាមផ្លូវភ្នែក ទ្រង់សម្តែងរឿង នៃសោតវិញ្ញាណ រឿងនៃសភាវធម៌ដែលដឹងសំឡេង រឿងនៃសំឡេង ដែលប្រាកដតាមផ្លូវត្រចៀក ទ្រង់សម្តែងធម៌ដែលកំពុងមាននៅឱ្យពិសោធន៍ ។ ដូច្នោះ អ្នកដែលបានស្តាប់ព្រះធម៌ហើយ ក៏អាចហ៊ាន គឺឧស្សហៈ ក្នុងការដែលនឹងសិក្សាពិចារណាដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដរហូតទាល់តែដល់បានប្រចក្សសភាវធម៌នោះ ។ ត្រង់តាមសេចក្តីពិតតាមដែលព្រះមានព្រះភាគទ្រង់សម្តែង ។

ពាក្យថា **រីករាយ** គឺឱ្យថ្លាផូរផង់ ឱ្យរុងរឿង ដោយគុណ ដែលខ្លួនចាក់ធ្លុះជានិច្ចហើយ ។

តើមិនជ្រាបថា លោកសមាទាន អាចហ៊ាន រីករាយខ្លះឬ ? តែឱ្យបានជ្រាបថា លោកអាចនឹងរីករាយបាន ក្នុងខណៈដែលកុសលចិត្តកើត ។ លោកខ្លះកើតទុក្ខព្រោះខ្វល់ខ្វាយថា អាយុច្រើនណាស់ហើយ សតិប្បដ្ឋានក៏នៅមិនទាន់កើតបន្តិចបន្តួចទាល់តែសោះ ខណៈនោះ គឺជាអកុសល ។ ព្រះមានព្រះភាគទ្រង់មិនបានសម្តែងព្រះធម៌ឱ្យបុគ្គលណាមានអកុសលច្រើន ។ ឬកើតកង្វល់ច្រើន ។ នោះទេ តែទ្រង់សម្តែងធម៌ដើម្បីឱ្យសមាទាន ឱ្យអាចហ៊ាន ឱ្យរីករាយ ។ អកុសលទាំងអស់កើតឡើងព្រោះហេតុបច្ច័យបញ្ឈប់មិនបាន កាលអកុសលចិត្តប្រភេទ

ណាមួយកើតឡើង អកុសលនោះក៏កើតឡើងហើយ ប៉ុន្តែរីករាយបានក្នុងខណៈដែលសតិរលឹកដឹងលក្ខណៈនៃអកុសល ដែលប្រាកដនិងសិក្សាពិចារណាលក្ខណៈនៃអកុសលធម៌ដែលប្រាកដ ដើម្បីនឹងបានដឹងថា សូម្បីអកុសលធម៌នោះក៏មិនមែនសត្វ បុគ្គល តួខ្លួន ។ កាលសតិកើតរលឹកដឹងលក្ខណៈនៃអកុសលដែលកំពុងប្រាកដ រមែងនឹងបានឃើញច្បាស់ពិត ។ ថា ខណៈដែលសតិកំពុងរលឹកនោះ មិនសៅហ្មងឡើយ ព្រោះកាលណាមិនប្រកាន់ អកុសលធម៌ដែលកំពុងប្រាកដ នៅក្នុងខណៈនោះជាតួខ្លួន ជាយើងទេ ក៏មិនកង្វល់ក្តៅក្រហាយ ខ្វល់ខ្វាយឡើយ ។

ផ្លូវតែមួយគត់ដែលនឹងបន្ថយ លះបង់អកុសលធម៌ដែលកើតឡើងមិនឱ្យសេចក្តីកង្វល់ កើតឡើងបន្ថែមនោះ ក៏ដោយសារសតិរលឹក ហើយសង្កេតពិចារណាដឹងថា សភាវធម៌ដែលជាអកុសលផ្សេង ។ នោះមិនមែនយើង មិនមែនតួខ្លួន សត្វ បុគ្គលណា ។ ឡើយ ។

ដូច្នោះ កាលអប់រំចម្រើនសតិប្បដ្ឋាន ក៏យល់ដល់សេចក្តីសំគាល់នៃពាក្យថា ឱ្យរីករាយ គឺឱ្យថ្លាផូរផង់ និងឱ្យរុងរឿងដោយគុណ ដែលខ្លួនចាក់ឆ្លុះជានិច្ចហើយ គឺអាចប្រចក្សលក្ខណៈនៃសភាវធម៌តាមសេចក្តីពិតថា មិនមែនសត្វ បុគ្គល តួខ្លួន ។

ពាក្យថា **ធ្វើឱ្យសម្រេចប្រយោជន៍** គឺពិចារណាដឹងយ៉ាងនេះថា ប្រយោជន៍នេះ យើងទាំងឡាយគួរបន្តុះបាន ដូចនេះហើយក៏ឈ្មោះថា មានប្រយោជន៍ដល់ទេសនានោះ ។

ការចម្រើនសតិប្បដ្ឋាននោះ មិនមែនជារឿងឱ្យរួញរាថយក្រោយនោះឡើយ សភាវធម៌ដែលកំពុងប្រាកដ ជាសភាវៈដែលអាចនឹងចាក់ធ្លុះជានិច្ច ក្នុងសភាវៈដែលកើតឡើងហើយរលត់ទៅវិញ មិនមែនតួខ្លួនសត្វ បុគ្គលបាន ។ ក្នុងខណៈដែលពិចារណាដឹងយ៉ាងនេះថាប្រយោជន៍នេះយើងទាំងឡាយគួរបន្តុះបាន ហើយក៏រមែងមិនអស់សង្ឃឹម កាលដឹងថាជាសភាវៈដែលគួរបន្តុះបាននៅថ្ងៃណាមួយ សូម្បីមិនទាន់បានក្នុងថ្ងៃនេះក៏ដោយ កុំព្រួយបារម្ភនឹងមិនអាចដឹងច្បាស់នូវសភាវធម៌ បាននៅក្នុងថ្ងៃនេះ ព្រោះសតិអាចធ្វើមរលឹកបានក្នុងថ្ងៃនេះ ចំណែកការដែលនឹងប្រចក្សច្បាស់ និងចាក់ធ្លុះលក្ខណៈនៃសភាវធម៌ រមែងនឹងត្រូវបានថ្ងៃណាមួយ ក្នុងថ្ងៃម្សិលមិញនេះសតិក៏អាចនឹងកើត រលឹកដឹងបាន ។

កាលបានឃើញហើយថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងថានេះប្រយោជន៍ គឺឱ្យដឹងថា **យើងគួរបន្តុះបាន** ក៏មិនរួញរាថយ ហើយក៏ស្តាប់សិក្សារឿងនៃសភាវធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយល្អិតល្អន់ជានិច្ចត ៗ ទៅ ដើម្បីនឹងមិនបានវង្វេងភ្លេចសតិ ។ សេចក្តីក្នុងអដ្ឋកថា គម្ពីរកថាវត្ថុ សាសនកថាវណ្ណនា មាន ខ សេចក្តីថា អស់លោក លោកអ្នកទាំងអស់គ្នាសាសនារបស់ព្រះដ៏មានព្រះភាគ តែងឡើងសាជាថ្មី ថ្លែងឡើងសាជាថ្មីតើបានឬ ?

(នេះជាសេចក្តីដែលលោកអ្នកទាំងអស់គ្នាគួរពិចារណា)

អរិយធម៌ទាំងឡាយ មានសតិជាដើមក្តី ទេសនានូវកុសលធម៌ជាដើមក្តីឈ្មោះថា សាសនា ។ ក្នុងសាសនានោះវៀរធម៌ទាំងឡាយមានសតិប្បដ្ឋានជាដើម ដែលព្រះមានព្រះភាគទ្រង់សម្តែង ដល់ជនឯណាហើយ សាសនាឈ្មោះថាដែលបុគ្គលនោះធ្វើឡើងថ្មី ដោយធ្វើធម៌ពួកដទៃឱ្យជាសតិប្បដ្ឋានជាដើម ឬធ្វើអកុសលធម៌ឱ្យជាកុសលធម៌ ជាដើម ឬថាមានសាសនាដែលអ្នកណា ។ ធ្វើហើយយ៉ាងនោះ ឬគប្បីអាចដើម្បីធ្វើសភាពនោះបាន តើមានឬ ?

បានសេចក្តីថា ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយនោះ បុគ្គលដទៃអាចនឹងតាក់តែង បំប្លែងប្រែសាជាថ្មី និងដូរផ្លាស់នូវសភាវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ថាសតិប្បដ្ឋាន ជាដើម ឬថាទេសនានូវកុសលធម៌ទាំងឡាយជាដើម ទាំងអស់នេះ បុគ្គលដទៃ អាចនឹងយកអកុសលធម៌ មកជាកុសលធម៌ ធ្វើឡើងប្រែជាថ្មីដោយការធ្វើធម៌ដទៃឱ្យជាសតិប្បដ្ឋាន ជាដើមតើបានឬ ?

កាលពិចារណាហើយយល់នូវហេតុ ផល ក៏នឹងបានដឹងថា ព្រះធម៌ពាក្យប្រៀនប្រដៅ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយ និងទ្រង់សម្តែងនោះមិនមាននរណាអាចនឹងក្លែង កែប្រែសភាវធម៌ទាំងឡាយដែលព្រះអង្គត្រាស់ដឹង និងទ្រង់សម្តែងឱ្យទៅជាយ៉ាងដទៃបានឡើយ មានអ្នកយល់ខុសបាន តែកែប្រែលក្ខណៈដែលពិតរបស់ធម៌ទាំងឡាយមិនបាន ។

អត្ថ គឺសេចក្តីសំគាល់របស់ចិត្ត ៥ ប្រការនោះក្នុងអភិធម្មត្ថវិភាវិនី បានសម្តែងទុក ៦ ប្រការ គឺសម្តែងថា ចិត្តវិចិត្រព្រោះអារម្មណ៍ដែលវិចិត្រផងទៀត ប្រការ ១ ទាំងនេះព្រោះចិត្តអាចនឹងដឹងអារម្មណ៍បានគ្រប់យ៉ាង មិនថាជាសភាវធម៌ដែលវិចិត្រត្រឹមណាសោះឡើយ ក៏រមែងជាអារម្មណ៍របស់ចិត្តបាន ហើយសូម្បីអារម្មណ៍នោះមិនមែនជាបរមត្ថធម៌ដូចពាក្យបញ្ញត្តិភាសាផ្សេង ៗ ក៏ដោយ ចិត្តក៏រមែងដឹងបាន គឺមានឈ្មោះ មានពាក្យ មានរឿងរ៉ាវផ្សេង ៗ ជាអារម្មណ៍បាន ដូច្នោះ ចិត្តទើបវិចិត្រព្រោះអារម្មណ៍ដែលវិចិត្រ ។

លក្ខណៈរបស់ចិត្តមាន ២ ប្រការ គឺសាមញ្ញលក្ខណៈ និងសភាវលក្ខណៈ ១

សាមញ្ញលក្ខណៈរបស់ចិត្ត គឺ អនិច្ចំ ទុក្ខំ អនត្តា ។

សភាវលក្ខណៈរបស់ចិត្ត ជាលក្ខណៈចំពោះចិត្តប៉ុណ្ណោះគឺ

អារម្មណាភិជានន្តលក្ខណំ មានការដឹងច្បាស់អារម្មណ៍ជាលក្ខណៈ ។

បុព្វង្គម រសំ មានការដល់មុន គឺមានភាពជាប្រធាន គឺជាធំក្នុងការដឹងអារម្មណ៍ ជារស គឺជាកិច្ច ។

សន្ធាន បច្ចុប្បដ្ឋានំ មានការបន្តគ្នា គឺកើតរលត់បន្តគ្នាជាបច្ចុប្បដ្ឋាន គឺអាការប្រាកដ ។

នាមរូបបច្ចយំ មាននាមធម៌ និងរូបធម៌ជាបទដ្ឋាន គឺជាហេតុជិតឱ្យកើត ។

ចិត្ត ជាសង្ខារធម៌ ជាសភាវធម៌ដែលត្រូវអាស្រ័យហេតុបច្ច័យ កើតឡើង ធម៌ទាំងឡាយនឹងកើតឡើងស្រេចតែតាមទំនើងនៃខ្លួនមិនបាន ក្នុងខ្លួនមានខន្ធ ៥ ចិត្តអាស្រ័យនាមធម៌ និងរូបធម៌ជាបទដ្ឋាន គឺជាហេតុជិតឱ្យកើត ។ ក្នុងភូមិដែលមានតែនាមធម៌ គឺក្នុងអរូបព្រហ្មភូមិនោះមិនមានរូបឡើយក្នុងភូមិនោះ ចិត្តទើបមានតែនាមធម៌ គឺចេតសិកប៉ុណ្ណោះ ជាបទ-ដ្ឋាន គឺជាហេតុជិតឱ្យកើត ។

សំណួរសាឡើងវិញ

១- អ្វីដែលធ្វើឱ្យរូបធម៌ ដូចជា ពូជនៃធញ្ញហារផ្សេង ៗ វត្ថុ ភ្នំ ទន្លេ គ្រឿង ឧបភោគ បរិភោគផ្សេងគ្នា ?

២- ក្រៅពីបរមត្ថធម៌ហើយ ចិត្តមានអ្វីជាអារម្មណ៍ទៀត ឬ មិនមាន ?

បញ្ញត្តិ

បញ្ញត្តិ

បរមត្ថធម៌ ជាសភាវធម៌ដែលមានពិត តែមិនមែនសត្វ បុគ្គល តួខ្លួនឡើយ ។ បរមត្ថធម៌ដែលកើតឡើងត្រឹមតែជាចិត្ត ចេតសិក រូប តែមួយលក្ខណៈ ។ តែមួយអាការ ។ ដែលកើតឡើងព្រោះហេតុបច្ច័យហើយក៏រលត់ទៅយ៉ាងរហ័ស ។ ខណៈណា ដែលមិនដឹងលក្ខណៈនៃចិត្ត ចេតសិក រូប ជាបរមត្ថធម៌ដែលកើតឡើងហើយរលត់ទៅវិញបន្តគ្នាយ៉ាងរហ័ស ខណៈនោះជាការដឹងបញ្ញត្តិ គឺការកាន់យកអាការនៃរូប និងនាមដែលកើតរលត់បន្តគ្នាយ៉ាងរហ័ស ថាជាវត្ថុណាមួយ ។ ដូច្នោះ អ្នកដែលមិនដឹងលក្ខណៈបរមត្ថធម៌ ទើបនៅក្នុងលោកនៃសម្មតិសច្ចៈ ព្រោះប្រកាន់សភាវធម៌ដែលប្រាកដដោយអាការ ដោយសណ្ឋានថា ជាវត្ថុណាមួយថាពិតប្រាកដ ប៉ុន្តែកាលបានសិក្សាបរមត្ថធម៌ហើយ និងដឹងគន្លងផ្លូវធម៌ដែលនឹងអប់រំចម្រើនបញ្ញា សិក្សាលក្ខណៈនៃសភាវធម៌ដែលកើតប្រាកដ រហូតទាល់តែបញ្ញាចម្រើនឡើង ដល់ថ្នាក់ដែលនឹងអាចប្រចក្សការកើតឡើង និងរលត់ទៅនៃសភាវធម៌ដែលកំពុងកើត រលត់ទៅនៃសភាវធម៌ ដែលកំពុងកើតរលត់ក្នុងខណៈនេះ ទើបដឹងជាក់ច្បាស់ថា មិនមែនសត្វ មិនមែនបុគ្គល តួខ្លួនឡើយ ត្រឹមតែជាបរមត្ថធម៌តែមួយលក្ខ-ណៈ ។ ពិត ។ ដូចតាមដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងទុក ។

ជម្រៅ និងសេចក្តីស្អិតរមួតរបស់អវិជ្ជា ដែលធ្វើឱ្យប្រកាន់ក្នុង សម្មតិសច្ចៈ ថាជាវត្ថុ ជាសត្វ បុគ្គល ផ្សេង ។ នោះ ផ្តើមតាំងពីពេល បដិសន្ធិចិត្តកើតឡើងក៏មាននាមធម៌ និងរូបធម៌កើត រលត់បន្តគ្នាមកជា រឿយ ។ ការកើតចេញចាកគក៌មាតាមកហើយ រមែងឃើញសភាវៈដែល ប្រាកដ ឮសំឡេងដែលប្រាកដ ធុំក្លិនដែលប្រាកដ ដឹងរសដែលប្រាកដ ដឹងក្តៅត្រជាក់ដែលប៉ះខ្ទប់សម្ផស្សកាយ ប៉ុន្តែមិនដឹងថាអ្វី(សភាវៈ)ដែល ប្រាកដតាមភ្នែកត្រឹមតែជា សភាវធម៌មួយបែប ហើយក៏ប្រកាន់ក្នុងអាការ នៃសភាវធម៌ដែលកើត រលត់បន្តគ្នា ជាដរាបប្រាកដដូចជាមិនកើត រលត់ ថាជាវត្ថុណាមួយ ខណៈនោះក៏មានឃនបញ្ញត្តិ គឺការប្រកាន់អាការនៃ សភាវធម៌ដែលរួមគ្នាជាដុំ ជាកង ដោយនៅពុំទាន់ថាសន្ទតិហៅវត្ថុនោះ ថាជាអ្វី ។ ក្មេង ។ ដែលមិនទាន់ដឹងសេចក្តី និងមិនទាន់ចេះនិយាយ និង សត្វតិរិច្ឆានរមែងដឹងឃនបញ្ញត្តិដូចគ្នា ទម្រាំនឹង ធំឡើង យល់សេចក្តីនៃ សំឡេង ទើបដឹងសម្មតិសច្ចៈ គឺការសន្ទតិ បញ្ញត្តិ ហៅសភាវធម៌ផ្សេង ។ ដើម្បីឱ្យយល់ត្រឹមត្រូវតាមគ្នា ។ ដូច្នោះ កាលនៅក្មេងធ្លាប់ឃើញអាការ នៃសភាវធម៌ដែលប្រាកដដូចជាមិនកើតរលត់យ៉ាងណា ពេលធំឡើង ហើយ ក៏នៅតែឃើញជាយ៉ាងនោះ ជាវត្ថុនោះ ដូចឃើញជាវត្ថុ ជាសត្វ បុគ្គល ផ្សេង ។ ដែរ ។ តាមសេចក្តីពិតនោះ សភាពដែលរឹងមិនថាជាចាន ឬស្លាបព្រា សមឡើយ ក៏ត្រឹមតែជាធាតុរឹង ជាបឋវីធាតុ តែក្នុងមួយថ្ងៃ ។ នោះតើឃើញអ្វី តើប៉ះខ្ទប់សម្ផស្សអ្វី ។ ក្នុងខណៈដែលប៉ះសម្ផស្ស

មិនធ្លាប់គិតថា ត្រឹមតែការប៉ះខ្ទប់សម្ផស្ស សភាវៈ(អ្វី)ដែលមានពិតដែល ជាសភាពរឹងទេ តែគួរមានសេចក្តីដឹងខ្លួនថា សម្ផស្សស្លាបព្រា សម្ផស្ស សម ឬចាន ឬពែង តាមដែលធ្លាប់ប្រកាន់ក្នុងអាការដែលកើត រលត់ បន្តគ្នាយ៉ាងរហ័ស រហូតដល់ប្រាកដជារូបរាង សណ្ឋានផ្សេង ។ ទាំង អស់នោះ នោះពេលដែលសម្ផស្សស្លាបព្រា ក៏រឹង សមក៏រឹង ពែងក៏រឹង ចានក៏រឹង ព្រោះលក្ខណៈដែលពិតត្រឹមតែជាសភាវធម៌រឹងប៉ុណ្ណោះ តែ ដោយការចាំរូបរាង ផ្សេង ។ ទើបធ្វើឱ្យដឹងថាពែងមិនមែនចាន ស្លាបព្រា មិនមែនសម ដូច្នោះ ដែលថាសភាវធម៌មានពិតនោះ ជារូបធម៌ដែល មានលក្ខណៈរឹងប៉ុណ្ណោះ ។ ប៉ុន្តែក៏នៅចាំសម្មតិ សភាវៈ នោះថាចាន សម្រាប់ដាក់បាយ ពែងសម្រាប់ដាក់ទឹក ស្លាបព្រាសម្រាប់ដួសអាហារ ចាំសម្មតិសភាវៈដែលជាធាតុរឹងផ្សេង ។ ដូចជាដែក សម្ភារៈដែលនាំ មកផ្សំគ្នាជាវិទ្យុ ជាទូរទស្សន៍ ជាវត្ថុរបស់របរផ្សេង ។ ដោយមិនប្រចក្ស លក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកើតឡើងប្រាកដតែមួយលក្ខណៈ ។ ហើយក៏រលត់ទៅវិញ ។

នេះគឺការចាំសម្មតិបញ្ញត្តិនូវសភាវៈដែលប្រាកដតាមភ្នែក ដែល មានច្រើនណាស់ជារឿយ ។ តាមការប្រតិស្ឋានថ្មី ។ រាល់ ។ ថ្ងៃ ។ ខណៈ ដែលដឹងរូបរាង សណ្ឋាន អាការដែលប្រាកដរួមគ្នា ជាសភាវៈផ្សេង ។ ខណៈនោះជាការដឹងបញ្ញត្តិជាសម្មតិសច្ចៈ មិនមែនបរមត្ថសច្ចៈ ។

ក្រៅពីដឹងឃនបញ្ញត្តិតាមផ្លូវភ្នែកហើយ នៅដឹងសទ្ទបញ្ញត្តិ គឺដឹងសេចក្តីសំគាល់នៃសំឡេងផងដែរ នេះជារឿងជីវិតប្រចាំថ្ងៃ ដែលដឹងត្រូវដឹងច្បាស់ថាសភាវធម៌ណាជាបរមត្ថធម៌ សភាវធម៌ណាជាសម្មតិ ។ សម្មតិសំដៅដល់អ្វីដែលមិនមែនបរមត្ថធម៌ ពេលដឹងរូបរាង សណ្ឋាន អាការផ្សេង ។ ដែលប្រាកដជាពែង ចាន ស្លាបព្រា សម វិទ្យុ ទូរទស្សន៍ រថយន្ត ។ល។ ហើយមនុស្សអាចបន្លឺសំឡេង ជាពាក្យ បញ្ញត្តិសម្មតិ ហៅសភាវៈដែលប្រាកដឱ្យយល់បាន សំដៅដល់សភាវៈណា ដែលកំណើតសត្វតិរច្ឆាន មិនមានសមត្ថភាពនឹងធ្វើដូចមនុស្សបានដោយល្អិតសុខុម ។ សំឡេង ជាសភាវធម៌ដែលមានពិត ហើយសំឡេង ឈ្មោះថា **នាម** ព្រោះថាបើមិនមានសំឡេង នាម (គឺឈ្មោះ) ឬ ពាក្យទាំងឡាយ ក៏មានមិនបាន ។ ដែលថាមានភ្នែក ទើបឃើញវត្ថុផ្សេង ។ តែបើមិនមានសំឡេងក៏នឹងមិនមានឈ្មោះ មិនមានពាក្យសម្រាប់ហៅវត្ថុ ដែលក្រឡេកឃើញនោះឡើយ ដូច្នោះ ការដឹងសេចក្តីសំគាល់នៃសំឡេង ទើបជាសទ្ទបញ្ញត្តិធ្វើឱ្យមានពាក្យនិយាយមានឈ្មោះ ជារឿងរ៉ាវផ្សេង ។ ។

មនុស្សគ្រប់គ្នាតែងជាប់នៅក្នុងឈ្មោះ ត្រង់សម្មតិបញ្ញត្តិផ្សេង ។ ដូច្នោះហើយ គួរដឹងលក្ខណៈនូវសំឡេងដែលជាសភាវធម៌មួយបែប ។ ពាក្យថា **សំឡេង** មិនមាននៅក្នុងភាសាបាលី សភាវធម៌ដែលជាសំឡេងនោះ ភាសាបាលីបញ្ញត្តិហៅថា **សទ្ទរូប** ។ សំឡេងជាសភាវៈ ដែលមាន

ពិត សំឡេងមិនមែនជាសភាវៈដឹង សំឡេងជារូបធម៌ ជាសភាវៈដែលប្រាកដតាមផ្លូវត្រចៀក ។

ក្នុងអភិធម្មត្ថវិភាវិនីដីកា អដ្ឋកថា អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៨ មានសេចក្តីអធិប្បាយរឿងបរមត្ថធម៌ និងសម្មតិបញ្ញត្តិដែលជាជីវិតប្រចាំថ្ងៃដ៏ជ្រាលជ្រៅ ហើយគួរនឹងយល់ឱ្យបានត្រឹមត្រូវ សូម្បីក្នុងរឿងផ្សេង ។ ដែលអាចមានបានក៏ព្រោះតែមានសំឡេង ។

មានសេចក្តីក្នុងអភិធម្មត្ថវិភាវិនីដីកា សទ្ទរូប (សំឡេង) ដែលឈ្មោះថា « នាម » (ក្នុងទីនេះ សំដៅដល់ឈ្មោះ មិនមែនសំដៅ ដល់នាមធម៌ដែលជាសភាពដឹងទេ) ព្រោះអត្ថថាបង្ហោនទៅក្នុងអត្ថទាំងឡាយ ។ នាមនោះមាន ២ យ៉ាងដោយអំណាចនៃនាម (គឺឈ្មោះ) ដែលយោលទៅតាមអត្ថ ១ និងនាម (គឺឈ្មោះ) តាមនិយាម ១ ។

មួយថ្ងៃ ។ និយាយរឿងអ្វី និយាយធ្វើអ្វី និយាយដើម្បីឱ្យអ្នកដទៃយល់រឿង យល់ន័យនូវអ្វីដែលសំដៅដល់ ដូច្នោះ សទ្ទរូបឈ្មោះថានាម ព្រោះអត្ថថា បង្ហោនទៅក្នុងអត្ថ គឺរឿងរ៉ាវទាំងឡាយ ។

ការដែលនឹងឱ្យអ្នកណាយល់ន័យ និងរឿងរ៉ាវ ផ្សេង ។ នោះក៏រមែងស្រេចហើយតែអ្នកណា និយមប្រើពាក្យអ្វី ភាសាអ្វី ដើម្បីឱ្យយល់ន័យសេចក្តីនោះ ។ រឿងរ៉ាវនោះ ។ ឬឈ្មោះនោះ ។ ។

ក្រៅពីនោះ សេចក្តីក្នុងអភិធម្មត្ថវិភាវិនី នៅពោលដល់នាម គឺឈ្មោះច្រើនន័យទៀត គឺឈ្មោះមាន ៤ យ៉ាង ដោយអំណាចនៃ

សាមញ្ញនាម គឺឈ្មោះជាទូទៅ ដូចជា មេឃ ភ្លៀង ខ្យល់ ស្រូវ ជាដើម **គុណនាម** គឺឈ្មោះ តាមគុណសេចក្តីល្អ ដូចព្រះអរហន្តសម្មាសម្ពុទ្ធ ដែលអ្នកមិនមែនព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ នឹងមានឈ្មោះយ៉ាងនេះមិនបានឡើយ ព្រោះថាមិនបានប្រកបដោយគុណធម៌នៃព្រះអរហន្តសម្មាសម្ពុទ្ធ **កិរិយានាម** ជាឈ្មោះ នៃការធ្វើផ្សេង ។ និង**យថិច្ឆនាម** គឺឈ្មោះតាមពេញចិត្ត ចូលចិត្ត ។

ការសិក្សាព្រះធម៌ ជារឿងល្អិតល្អន់ណាស់ ព្រោះជាការសិក្សាសភាវធម៌ទាំងឡាយ ទាំងពួងដែលព្រះមានព្រះភាគទ្រង់ត្រាស់ដឹង និងទ្រង់សម្តែងទុកដោយមហាករុណា ដើម្បីអនុគ្រោះឱ្យពុទ្ធបរិស័ទឱ្យបានយល់សភាវធម៌ដែលប្រាកដតាមសេចក្តីពិត ។

ក្នុងអភិធម្មត្ថវិភាវិនីដីកា បរិច្ឆេទទី ៧ មានសេចក្តីថា

សួរថា ព្រោះហេតុអ្វីសូម្បីតែព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សម្តែងធម៌ទុកដ៏ច្រើនយ៉ាងនោះ ?

អធិប្បាយថា ព្រោះព្រះអង្គបំណងដល់ការអនុគ្រោះសត្វ ៣ ពួក ។ ពិតណាស់សត្វ ៣ ពួក ដោយអំណាចសេចក្តីវង្វេង មិនយល់ក្នុងនាម ១ ក្នុងរូប ១ និងក្នុងនាម និងរូបទាំង ២ នោះ ១ ដោយអំណាចនៃឥន្ទ្រិយចាស់ក្លា ១ មិនចាស់ក្លាណាស់ពេក ១ ខ្សោយ ១ ហើយនិងដោយអំណាចនៃសេចក្តីពេញចិត្តពាក្យសង្ខេប ១ ពេញចិត្តពាក្យកណ្តាល ១ ពេញចិត្តពាក្យពិស្តារ (ល្អិត) ១ ។

បណ្តាសត្វ ៣ ជំពូកទាំងនោះ សត្វដែលឈ្លក់វង្វេងក្នុងនាម និងយល់ ដឹងនូវខន្ធបាន ដោយចែកនាមទុក ៤ យ៉ាង ក្នុងខន្ធនោះ ។ ។

សត្វអ្នកឈ្លក់វង្វេងក្នុងរូប នឹងយល់ដឹងអាយតនៈបានដោយ ចែករូបទុក ១០ យ៉ាង និងកន្លះអាយតនៈទៀត ។ (ព្រោះធម្មាយតនៈមានទាំងនាមធម៌ និងរូបធម៌)

សត្វអ្នកដែលឈ្លក់វង្វេងក្នុងនាម និងរូបទាំង ២ នឹងយល់ដឹងធាតុបាន ដោយចែកនាម និងរូប ទាំង ២ ទុកក្នុងជំពូកធាតុនោះ ដោយពិស្តារ ។

អាយតនៈ ១២

អាយតនៈខាងក្នុង ៦		**អាយតនៈខាងក្រៅ ៦**	
ចក្ខាយតនៈ	១	រូបាយតនៈ	១
សោតាយតនៈ	១	សទ្ទាយតនៈ	១
ឃានាយតនៈ	១	គន្ធាយតនៈ	១
ជិវ្ហាយតនៈ	១	រសាយតនៈ	១
កាយាយតនៈ	១	ផោដ្ឋព្វាយតនៈ	១
មនាយតនៈ	១	ធម្មាយតនៈ	១

អាយតនៈ គឺសភាវៈបរមត្ថធម៌ដែលប្រជុំគ្នា កាលចិត្តកើតឡើងដឹងអារម្មណ៍មួយខណៈ ។ ដែលចំណែកជាអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ ។

បសាទរូប ៥ និងចិត្ត ១ ជាអាយតនៈខាងក្នុង ៦ ព្រោះចិត្តជាសភាវៈដឹង និងបសាទរូប ៥ ជាទីអាស្រ័យឱ្យចិត្តដឹងអារម្មណ៍ទើបជាខាងក្នុង បរមត្ថធម៌ក្រៅពីនោះជាខាងក្រៅទាំងអស់ ។

អាយតនៈ ១២ ជារូប ១០ អាយតនៈ + កន្លះ (ធម្មាយតនៈ) គឺរូបជាអាយតនៈខាងក្នុង ៥ + រូបជាអាយតនៈខាងក្រៅ ៥ និងកន្លះធម្មាយតនៈទៀត (សុខុមរូប) ។

អាយតនៈ ១២ ជានាម ១ អាយតនៈ + កន្លះ (ធម្មាយតនៈ) គឺមនាយតនៈខាងក្នុង ១ + កន្លះធម្មាយតនៈ (ចេតសិក និងនិព្វាន) ។

ធាតុ ១៨

សភាវៈបរមត្ថធម៌ទាំងអស់ជាធាតុមួយប្រភេទ ។ កាលប្រមូលមកតាមទ្វារទាំង ៦ ក៏ជាធាតុ ១៨ ដូចនេះ គឺ

ចក្ខុធាតុ	១	រូបធាតុ	១	ចក្ខុវិញ្ញាណធាតុ	១
សោតធាតុ	១	សទ្ទធាតុ	១	សោតវិញ្ញាណធាតុ	១
ឃានធាតុ	១	គន្ធធាតុ	១	ឃានវិញ្ញាណធាតុ	១
ជិវ្ហាធាតុ	១	រសធាតុ	១	ជិវ្ហាវិញ្ញាណធាតុ	១
កាយធាតុ	១	ផោដ្ឋព្វធាតុ	១	កាយវិញ្ញាណធាតុ	១
មនោធាតុ	១	ធម្មធាតុ	១	មនោវិញ្ញាណធាតុ	១

វិញ្ញាណធាតុ បានដល់ចិត្ត ១០ ដួងដែលដឹងបានចំពោះតែអារម្មណ៍របស់ខ្លួនត្រឹមតែ ១ ប៉ុណ្ណោះគឺ

ចក្ខុវិញ្ញាណ	២ ដួង	ដឹងបានតែរូបារម្មណ៍មួយយ៉ាង
សោតវិញ្ញាណ	២ ដួង	ដឹងបានតែសទ្ទារម្មណ៍មួយយ៉ាង
ឃានវិញ្ញាណ	២ ដួង	ដឹងបានតែគន្ធារម្មណ៍មួយយ៉ាង
ជិវ្ហាវិញ្ញាណ	២ ដួង	ដឹងបានតែរសារម្មណ៍មួយយ៉ាង
កាយវិញ្ញាណ	២ ដួង	ដឹងបានតែផោដ្ឋព្វារម្មណ៍មួយយ៉ាង

មនោធាតុ បានដល់ចិត្ត ៣ ដួង ដែលដឹងអារម្មណ៍ ៥ អារម្មណ៍តាមទ្វារ ៥ ប៉ុណ្ណោះ ។ មនោធាតុ ៣ ដួង គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង និងសម្បដិច្ឆន្នចិត្ត ២ ដួង ។

មនោវិញ្ញាណធាតុ ជាចិត្តដែលដឹងអារម្មណ៍តាមផ្លូវមនោទ្វារ បានហើយ ដួងខ្លះក៏ដឹងអារម្មណ៍ ដោយមិនអាស្រ័យទ្វារឡើយ ។

មនោវិញ្ញាណធាតុ បានដល់ចិត្ត ៧៦ ដួង (រៀរទ្ធិបញ្ចវិញ្ញាណ ១០ ដួង និងមនោធាតុ ៣ ដួង)

ប្រមូលចិត្ត ៨៩ ជាវិញ្ញាណធាតុ ៧ ប្រភេទ គឺ

ចក្ខុវិញ្ញាណធាតុ	១
សោតវិញ្ញាណធាតុ	១
ឃានវិញ្ញាណធាតុ	១
ជិវ្ហាវិញ្ញាណធាតុ	១

កាយវិញ្ញាណធាតុ ១
មនោធាតុ ១
មនោវិញ្ញាណធាតុ ១

ដូច្នោះ គួរពិចារណាថា លោកអ្នកជាបុគ្គលដែលឈ្លក់វង្វេងក្នុងនាមប៉ុណ្ណោះ ឬថាជាអ្នកដែលឈ្លក់វង្វេងក្នុងរូបប៉ុណ្ណោះ ឬថាជាអ្នកដែលឈ្លក់វង្វេងក្នុងទាំងនាម និងទាំងរូប បើសិនមិនយល់ទាំងក្នុងនាម និងទាំងរូប ក៏ចាំបាច់ត្រូវអាស្រ័យការស្តាប់ព្រះធម៌ និងការសិក្សាព្រះធម៌ប្រការផ្សេង ។ ដោយល្អិតល្អន់ ដើម្បីឱ្យយល់បានយ៉ាងត្រឹមត្រូវនូវសភាវធម៌ទាំងឡាយ ដើម្បីអប់រំចម្រើនកុសលគ្រប់ប្រការ និងដើម្បីជាបច្ច័យឱ្យសតិប្បដ្ឋានកើតឡើងរលឹកដឹងលក្ខណៈនូវសភាវធម៌ ដែលប្រាកដជាប្រក្រតីតាមសេចក្តីពិត ។

សេចក្តីក្នុងអភិធម្មត្ថវិភាវិនីដីកា បរិច្ឆេទទី ៨ មានសេចក្តីថា **នាមបញ្ញត្តិមាន ៦ យ៉ាង គឺ**

១-វិជ្ជមានប្បញ្ញត្តិ ជាពាក្យបញ្ញត្តិហៅសភាវធម៌ ដែលមានពិតដូចពាក្យថា រូប នាម វេទនា សញ្ញា ជាដើម ។

២-អវិជ្ជមានប្បញ្ញត្តិ ជាពាក្យបញ្ញត្តិដែលមិនមានសភាវធម៌ ដូចខ្មែរ ថៃ បារាំង ជាដើម ។ ថៃ ខ្មែរ បារាំង មិនមាន មានតែសភាវធម៌ គឺចិត្តចេតសិក និងរូប ប៉ុណ្ណោះ ថៃ ខ្មែរ បារាំង ជាសម្មតិមិនមែនសភាវធម៌ ។

អកុសលចិត្តជាបរមត្ថធម៌ ជាសភាវធម៌ដែលមានពិត មិនមែនថៃ ខ្មែរ បារាំង ដូច្នេះ អកុសលចិត្តមាន កុសលចិត្តមាន តែខ្មែរ ថៃ បារាំងមិនមាន ពាក្យថាថៃ ខ្មែរ បារាំង ទើបជាអវិជ្ជមានបញ្ញត្តិ ។

៣-**វិជ្ជមាននាវិជ្ជមានប្បញ្ញត្តិ** បញ្ញត្តិនូវអ្វីដែលមិនមានជាមួយ នឹងសភាវៈដែលមាន ដូចនិយាយថា បុគ្គលឈ្មោះថាឆឡភិញ្ញា ព្រោះ អត្ថថាមានអភិញ្ញា ៦ អភិញ្ញាមាន តែបុគ្គលមិនមាន ដូច្នោះ ទើបជាបញ្ញត្តិ នូវអ្វីដែលមិនមាន ជាមួយនឹងសភាវៈ (អ្វី) ដែលមាន ។

៤-**អវិជ្ជមាននវិជ្ជមានប្បញ្ញត្តិ** បញ្ញត្តិសភាវៈដែលមាន ជាមួយនឹងអ្វីដែលមិនមាន ដូចសំឡេងស្រី សំឡេងមានពិត តែស្រីមិនមាន ។

៥- **វិជ្ជមាននវិជ្ជមានប្បញ្ញត្តិ** បញ្ញត្តិសភាវៈដែលមាន ជាមួយនឹងសភាវៈដែលមានដូចជាពាក្យថា ចក្ខុវិញ្ញាណ ចក្ខុ មានពិតជាចក្ខុបសាទ វិញ្ញាណមានពិត ជាសភាវៈដឹង ។

៦-**អវិជ្ជមាននាវិជ្ជមានប្បញ្ញត្តិ** បញ្ញត្តិនូវអ្វីដែលមិនមាន ជាមួយនឹងអ្វីដែលមិនមាន ដូចជា ព្រះឱរសនៃព្រះរាជា (ព្រះឱរស និងព្រះរាជា ជា សម្មតិបញ្ញត្តិ) ។

អារម្មណ៍ ៦

១- **រូបារម្មណ៍** គឺសភាវៈដែលប្រាកដតាមភ្នែក ជាអារម្មណ៍របស់ចក្ខុទ្វារវិថីចិត្ត ដែលអាស្រ័យចក្ខុបសាទកើតឡើង ។ នៅពេលរូបារម្មណ៍រលត់ទៅហើយ ភវង្គចិត្តកើតឡើង ហើយរលត់ទៅច្រើនខណៈ រួច

ហើយ មនោទ្វារវិថីចិត្ត ក៏កើតឡើង តាមផ្លូវមនោទ្វារទទួលដឹងបន្តនូវ រូបារម្មណ៍ដែលរលត់តាមផ្លូវចក្ខុទ្វារ ដូច្នោះ រូបារម្មណ៍ទើបដឹងបាន ២ ទ្វារ គឺផ្លូវចក្ខុទ្វារ និងផ្លូវមនោទ្វារ ដោយមានភវង្គចិត្តកើតខណ្ឌ ។

២- **សទ្ទារម្មណ៍** គឺសំឡេង ជាសភាវធម៌ ដែលប្រាកដបានតាមផ្លូវ ត្រចៀក ជាអារម្មណ៍របស់សោតទ្វារវិថីចិត្ត ដែលអាស្រ័យសោតបសាទ កើតឡើង រួចហើយជាអារម្មណ៍របស់មនោទ្វារវិថីចិត្ត ក្រោយពីភវង្គចិត្ត កើតខណ្ឌវារៈនីមួយ ។ នៃការដឹងអារម្មណ៍តាមទ្វារនីមួយ ។ ចាំបាច់ ត្រូវមានភវង្គចិត្តកើតខណ្ឌរវាងវិថីចិត្តតាមផ្លូវបញ្ចទ្វារ និងវិថីចិត្តតាមផ្លូវ មនោទ្វារ ខណៈដែលបានឮសំឡេង និងកំពុងដឹងពាក្យនោះ ខណៈដែល កំពុងដឹងពាក្យ ជាមនោទ្វារវិថីចិត្ត ដែលកំពុងគិតដល់ពាក្យ មិនមែន សោតទ្វារវិថីចិត្ត ដែលកំពុងឮសំឡេង ដែលមិនទាន់រលត់នោះទេ ។

៣- **គន្ធារម្មណ៍** គឺក្លិន ជាសភាវធម៌ដែលប្រាកដតាមផ្លូវច្រមុះ ជាអារម្មណ៍របស់ឃានទ្វារវិថីចិត្ត ដែលអាស្រ័យឃានបសាទកើតឡើង ហើយតអំពីនោះមនោទ្វារវិថីចិត្ត ក៏ដឹងក្លិននោះបន្ត ក្រោយអំពីដែលភវង្គ ចិត្តកើតខណ្ឌហើយ ។

៤- **រសារម្មណ៍** គឺរស ជាសភាវធម៌ដែលប្រាកដត្រង់អណ្តាត ជាអារម្មណ៍របស់ជិវ្ហាទ្វារវិថីចិត្តដែលអាស្រ័យជិវ្ហាបសាទកើតឡើង ហើយ កាលជិវ្ហាទ្វារវិថីចិត្តរលត់ទៅអស់ហើយ ភវង្គចិត្តកើតខណ្ឌវិថីចិត្ត ក៏កើត ឡើងដឹងរសារម្មណ៍នោះបន្តតាមផ្លូវមនោទ្វារ ។

៥- **ផោដ្ឋព្វារម្មណ៍** គឺសភាវៈដែលក្តៅ ឬ ត្រជាក់ ទន់ ឬ រឹង តឹង ឬ ញ័រ ដែលប្រាកដតាមផ្លូវកាយជាអារម្មណ៍ របស់កាយទ្វារវិថីចិត្ត ដែលអាស្រ័យកាយបសាទកើតឡើងហើយ មនោទ្វារវិថីចិត្តក៏កើតឡើងដឹងផោដ្ឋព្វារម្មណ៍នោះបន្តតាមផ្លូវមនោទ្វារ ក្រោយពីដែលភវង្គចិត្តកើតខណ្ឌហើយ ។

អារម្មណ៍ទាំង ៥ នេះហៅថា **បញ្ចារម្មណៈ** ឬ បញ្ចារម្មណ៍ អារម្មណ៍ទាំង ៥ នេះប្រាកដ បាន ៦ ទ្វារ គឺកាលចក្ខុទ្វារវិថីចិត្តកើតឡើងដឹងរូបារម្មណ៍តាមផ្លូវចក្ខុទ្វារហើយ មនោទ្វារវិថីចិត្តក៏កើតឡើងទទួលដឹងរូបារម្មណ៍បន្តតាមផ្លូវមនោទ្វារ កាលណាភវង្គចិត្តកើតខណ្ឌរួចហើយ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ក៏មានន័យដូចគ្នា ។ ដូច្នោះ អារម្មណ៍ទាំង ៥ នេះ ទើបជាអារម្មណ៍របស់ចិត្តបាន ៦ ទ្វារ គឺតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត តែអារម្មណ៍មួយទៀត គឺ **ធម្មារម្មណៈ** ឬធម្មារម្មណ៍នោះដឹងបានចំពោះតែផ្លូវមនោទ្វារ គឺផ្លូវចិត្តតែប៉ុណ្ណោះ ។

៦- **ធម្មារម្មណ៍ ជាអារម្មណ៍ដែលចិត្តដឹងបានចំពោះតែផ្លូវចិត្តមួយប៉ុណ្ណោះ មាន ៦ យ៉ាង គឺ បសាទរូប ៥ សុខុមរូប ១៦ ចិត្ត ចេតសិក និព្វាន បញ្ញត្តិ ។**

ធម្មារម្មណ៍ ៥ គឺបសាទរូប ៥ សុខុមរូប ១៦ ចិត្ត ៨៩ ចេតសិក ៥២ និព្វាន ជាបរមត្ថធម៌ ធម្មារម្មណ៍ ១ គឺបញ្ញត្តិមិនមែនបរមត្ថធម៌ ។

ក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ មានពាក្យអធិប្បាយថា ដែលឈ្មោះថា បញ្ញត្តិ **បញ្ញត្តិ** ព្រោះឱ្យបានដឹងដោយប្រការនោះ ។ ។

ចក្ខុទ្វារវិថីចិត្តគ្រប់ដួង គឺចក្ខុទ្វារាវជ្ជនចិត្ត ចក្ខុវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទាលម្ពណចិត្តដឹងរូបារម្មណ៍ដែលមិនទាន់រលត់ **ចក្ខុទ្វារវិថីចិត្ត ទើបមិនមានបញ្ញត្តិជាអារម្មណ៍ ។**

សោតទ្វារវិថីចិត្ត គឺសោតទ្វារាវជ្ជនចិត្ត សោតវិញ្ញាណ សម្បដិច្ឆនចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទាលម្ពណចិត្ត ដឹងសំឡេងដែលនៅមិនទាន់រលត់ **សោតទ្វារវិថីចិត្ត ទើបមិនមានបញ្ញត្តិជាអារម្មណ៍ ។**

ឃានទ្វារវិថីចិត្ត ជិវ្ហាទ្វារវិថីចិត្ត កាយទ្វារវិថីចិត្ត ក៏ដោយន័យតែមួយ ។ នៅពេលវិថីចិត្តតាមផ្លូវបញ្ចទ្វារ (**ទ្វារណាមួយ**) រលត់អស់ហើយភវង្គចិត្តកើតខណ្ឌច្រើនខណៈហើយ មនោទ្វារវិថីចិត្តក៏កើតបន្ត មនោទ្វារវិថីចិត្តវារៈដំបូងមានអារម្មណ៍ណាមួយ ក្នុងអារម្មណ៍ទាំង ៥ ដែលទើបរលត់ទៅតាមបញ្ចទ្វារនុ៎ះឯង ជាអារម្មណ៍មនោទ្វារវិថីចិត្តវារៈដំបូងដែលកើតបន្តពីបញ្ចទ្វារវិថីចិត្តនោះ មិនទាន់មានបញ្ញត្តិជាអារម្មណ៍ទេ ។

វារៈមនោទ្វារវិថីចិត្តនីមួយ ។ មានវិថីចិត្ត ២ ឬ ៣ វិថីចិត្ត គឺ មនោទ្វារាវជ្ជនចិត្ត ១ ខណៈ ជវនវិថីចិត្ត ៧ ខណៈ តទាលម្ពណវិថីចិត្ត ២ ខណៈ (វារៈខ្លះក៏មិនមានតទាលម្ពណវិថីចិត្ត) ។ នៅពេលមនោទ្វារវិថីចិត្តវារៈទី ១ រលត់ទៅហើយ ភវង្គចិត្តក៏កើតខណ្ឌច្រើនខណៈ

ហើយ មនោទ្វារវិថីចិត្តវារៈតទៅ ក៏កើតបន្តមានបញ្ញត្តិ គឺរូបរាង សណ្ឋាន អារម្មណ៍ណាមួយក្នុងអារម្មណ៍ទាំង ៥ នោះជាអារម្មណ៍ ។ ដោយនៅពេលមនោទ្វារវិថីចិត្តក្នុងមួយវារៈរលត់ទៅហើយ ភវង្គចិត្តក៏កើតខណ្ឌ ហើយមនោទ្វារវិថីចិត្តវារៈត ។ ទៅ ក៏កើតឡើងមាន អត្ថ គឺន័យ ឬពាក្យ ផ្សេង ។ ជាអារម្មណ៍ក្នុងវារៈមួយ ។ ដោយមានភវង្គចិត្តកើតខណ្ឌ ខណៈដែលដឹងថាជាមនុស្ស ជាវត្ថុ ជារបស់ផ្សេង ។ ខណៈនោះ ចិត្តដឹងបញ្ញត្តិ មិនមែនដឹងបរមត្ថអារម្មណ៍ បរមត្ថអារម្មណ៍ដែលប្រាកដតាមផ្លូវភ្នែក ជាពណ៌វណ្ណៈផ្សេង ។ ប៉ុណ្ណោះ តែខណៈដែលមនោទ្វារវិថីចិត្តដឹងថាជាសត្វ បុគ្គល វត្ថុ របស់របរផ្សេង ។ ខណៈនោះ មនោទ្វារវិថីចិត្តមានបញ្ញត្តិជាអារម្មណ៍ ទើបដឹងថារបស់នោះជាអ្វី ។

ដូច្នោះ ព្រះធម៌ដែលថាបរមត្ថធម៌មិនមែនបញ្ញត្តិ ក៏ព្រោះតែបរមត្ថធម៌ជាសភាវធម៌ដែលមានពិត សូម្បីមិនប្រើពាក្យបញ្ញត្តិណា ។ ហៅបរមត្ថធម៌ទាល់តែសោះក៏ដោយ សភាវធម៌ដែលកើតឡើងនោះ ក៏មានលក្ខណៈយ៉ាងនោះពិត ។ ចំណែកបញ្ញត្តិមិនមែនបរមត្ថធម៌ព្រោះមិនមែនសភាវធម៌ដែលមានពិត និងដែលឈ្មោះថាបញ្ញត្តិ ព្រោះឱ្យបានដឹងដោយប្រការនោះ ។ ។

នៅពេលឃើញរូបភាព ភ្នំ ទន្លេ ដើមឈើ ក៏ដឹងថាជារូបភាព ឬជាគំនូរ មិនមែនភ្នំ ទន្លេ ដើមឈើពិត ។ និងនៅពេលដែលឃើញភ្នំ ឃើញទន្លេ ឃើញដើមឈើពិត ។ នោះ តើអ្វីជាបញ្ញត្តិ ?

នៅពេលឃើញរូបភាព ទំពាំងបាយជូរ សាវម៉ាវ មង្ឃុត ហើយនិង ឃើញផ្លែទំពាំងបាយជូរ សាវម៉ាវ មង្ឃុត ពិត ។ តើអ្វីជាបញ្ញត្តិ ?

ធម៌រមែងពិតតាមធម៌ ដែលជាបញ្ញត្តិ ព្រោះជាពាក្យដែលសម្តែងឱ្យដឹងលក្ខណៈ ឬអត្ថនៃសភាវធម៌បាន សូម្បីតែមិនហៅ ឬនៅមិនទាន់មានឈ្មោះអ្វីឡើយ ក៏មានយនបញ្ញត្តិ ហើយមិនចាំបាច់ត្រូវដឹងភាសាណាឡើយ តែក៏មានបញ្ញត្តិក្នុងរបស់ដែលប្រាកដ មិនដូច្នោះ ក៏នឹងមិនដឹងថារបស់ដែលប្រាកដនោះជាអ្វី ខណៈដែលដឹងថារបស់អ្វីដែលប្រាកដ ជាអ្វីនោះខណៈដឹងបញ្ញត្តិ ព្រោះបញ្ញត្តិ គឺឱ្យដឹងបានដោយប្រការនោះ ។ ទោះជាមិនហៅឈ្មោះត្រឹមតែឃើញគំនូរ និងផ្លែឈើពិត ។ តើអ្វីជាបញ្ញត្តិ ? ឬជាបញ្ញត្តិទាំង ២ យ៉ាង ។

បញ្ញត្តិមិនមែនបរមត្ថ ផ្លែឈើពិត ។ និងគំនូរផ្លែឈើ មានអ្វីផ្សេងគ្នាក្នុងខណៈដែលឃើញតាមផ្លូវភ្នែក អ្វីដែលប្រាកដតាមផ្លូវភ្នែក ទាំងអស់មិនមែនសត្វ បុគ្គល តួខ្លួន ឬវត្ថុណាមួយទាំងអស់ ទាំងក្នុងខណៈដែលឃើញរូបភាពទំពាំងបាយជូរ និងទាំងក្នុងខណៈដែលឃើញផ្លែទំពាំងបាយជូរ លោកខ្លះអាចនឹងយល់ថាចំពោះរូបភាពជាបញ្ញត្តិ និងផ្លែទំពាំងបាយជូរមិនមែនបញ្ញត្តិ តែតាមសេចក្តីពិតនោះទាំងរូបភាព និងផ្លែទំពាំងបាយជូរដែលប្រាកដតាមផ្លូវភ្នែកនោះ ជាបញ្ញត្តិអារម្មណ៍របស់មនោទ្វារវិថីចិត្តដែលកើតបន្តមកហើយ ព្រោះចក្ខុទ្វារវិថីចិត្ត នឹងដឹងត្រឹមតែពណ៌វណ្ណៈដែលប្រាកដប៉ុណ្ណោះ ចំណែកមនោទ្វារវិថីចិត្ត ដឹងបញ្ញត្តិ គឺអត្ថ

ដែលជាទំពាំងបាយជូរ ព្រោះឱ្យបានដឹងដោយប្រការនោះ ។ ថាទំពាំងបាយជូរ មិនថានឹងជាផ្លែទំពាំងបាយជូរ ឬជារូបភាពទំពាំងបាយជូរក្តី ដែលដឹងថាជាទំពាំងបាយជូរនោះ ជាបញ្ញត្តិអារម្មណ៍ មិនមែនបរមត្ថអារម្មណ៍ ។

ក្នុងខណៈដែលកំពុងឃើញជាមនុស្សនេះនោះ ក៏គួរនឹងដឹងនូវសេចក្តីពិតថា ដូចនឹងរូបភាព ឬគំនូរដែលជាបញ្ញត្តិហើយ ។ លំបាកនឹងដោះចេញនូវបញ្ញត្តិបាន ខណៈដែលដឹងនូវបញ្ញត្តិថា ឃើញកៅអីនោះ បរមត្ថអារម្មណ៍ដែលប្រាកដតាមផ្លូវភ្នែក និងបរមត្ថអារម្មណ៍ដែលប្រាកដតាមផ្លូវកាយ ពេលប៉ះខ្ទប់សម្ផស្សនោះមិនមែនបញ្ញត្តិ ។

សំណួរ- នៅមិនទាន់សូវយល់ ឧទាហរណ៍ងាយ ។ ថាដូចក្នុងពេលនេះឃើញ ប៊ិក លោកអាចារ្យប្រាប់ថា កាលឃើញជាប៊ិកហើយ ក៏គឺស្តែងថាឆ្លងផ្លូវបញ្ចទ្វារទៅដល់មនោទ្វារហើយ ត្រង់នេះមិនជ្រាប មានការសិក្សា ឬបដិបត្តិយ៉ាងណា ទើបនឹងមិនឱ្យឆ្លងផ្លូវបញ្ចទ្វារជាមុន ?

សុចិន្ត- ត្រូវស្តាប់រហូតទាល់តែយល់ពិត ។ ថាខណៈណាមានបញ្ញត្តិជាអារម្មណ៍ និងចិត្តដឹងបញ្ញត្តិជាអារម្មណ៍តាមទ្វារណា ។ ខណៈដែលចិត្តមានបរមត្ថធម៌ជាអារម្មណ៍នោះ មិនមានសត្វ បុគ្គល តួខ្លួន វត្ថុណាឡើយ ។ ខណៈនេះសភាវធម៌កើត រលត់បន្តគ្នាយ៉ាងរហ័ស រហូតធ្វើឱ្យឃើញដូចកង្ហារកំពុងវិល ការដែលរូបណានឹងប្រាកដជាអាការ ចលនានោះ ត្រូវមានរូបកើត រលត់បន្តច្រើនសន្ធឹកសន្ធាប់ ទើបធ្វើឱ្យឃើញ ជា

មានចលនាបាន ដូច្នោះ មនោទ្វារវិថីចិត្ត ដែលមានបញ្ញត្តិជាអារម្មណ៍កើត ច្រើនវារៈណាស់រហូតដល់បិទបាំង ធ្វើមិនឱ្យដឹងត្រង់ចំពោះលក្ខណៈនៃបរមត្ថធម៌តាមសេចក្តីពិតឡើយ ។

សំណួរ - បើយ៉ាងនោះ តើនឹងឱ្យយកពាក្យថា បញ្ញត្តិ បោះចោលទៅឯណា ?

សុចិន្ត - មិនមែនឱ្យបោះចោលទេ តែឱ្យដឹងតាមសេចក្តីពិតថា ខណៈដែលកំពុងដឹងថាជាសត្វ ជាបុគ្គលណាមួយ ជាវត្ថុណាមួយនោះ ខណៈនោះមនោទ្វារវិថីចិត្តកំពុងដឹងបញ្ញត្តិ ។

សំណួរ - ជាសភាវៈនឹកគិតពាក្យ

សុចិន្ត - ខណៈដែលមិនបានគិតពាក្យ តែដឹងរូបសណ្ឋាន ឬដឹងសេចក្តីអាការប្រាកដក៏ជាបញ្ញត្តិ មិនមែនបរមត្ថ គឺត្រូវដឹងយ៉ាងត្រឹមត្រូវត្រង់លក្ខណៈនៃសភាវៈពិត ។ ទើបប្រចក្សការកើតឡើង និងរលត់ទៅនៃបរមត្ថធម៌បាន លោកអ្នកដែលប្រាប់ថា មិនឃើញកៅអីរលត់សោះ ពេលនៅមិនទាន់បានញែកចែកលក្ខណៈនៃបរមត្ថធម៌មួយបែប ។ ដែលរួមគ្នាចេញទេ ក៏ឃើញថាជាកៅអី ខណៈនោះគឺជាការដឹងបញ្ញត្តិ ហើយតើនឹងរលត់បានដូចម្តេចកើត ។ តួយ៉ាងដូចរូបគំនូរទំពាំងបាយជូរ និងទំពាំងបាយជូរពិតនោះ កាលប៉ះខ្ទប់សម្ផស្សផ្លូវកាយទ្វារ តើខុសគ្នាទេ ? ធាតុរឹងមិនដូចគ្នាឬ ? ធាតុរឹងកើតពីសមុដ្ឋានផ្សេង ។ គ្នា ធ្វើឱ្យដឹងរឹងខ្លាំង រឹងតិច ទន់ខ្លាំង ទន់តិចក៏ពិតមែន តែរឹងក៏ជាសភាវធម៌ដែលប្រាកដតាម

ផ្លូវកាយ ទាំងរូបភាពទំពាំងបាយជូរ ទាំងផ្លែទំពាំងបាយជូរ តែទំពាំងបាយជូរជាគំនូរមិនមានរសទំពាំងបាយជូរទេ ។ រូបដែលកើតរួមគ្នាធ្វើឱ្យដឹងថាជាផ្លែទំពាំងបាយជូរនោះ សេចក្តីពិតរស ក៏ជារូប ១ ក្លិនក៏ជារូប ១ ត្រជាក់ ឬក្តៅក៏ជារូប ១ ទន់ ឬរឹងក៏ជារូប ១ តឹង ឬញ័រក៏ជារូប ១ កាលរួមគ្នាហើយកើត រលត់ដ៏យ៉ាងរហ័ស ក៏ធ្វើឱ្យបញ្ញត្តិដឹងតាមអាការនោះ ។ ថាជាវត្ថុនេះ នោះ ដែលមើលទៅដូចមិនរលត់ តែតាមសេចក្តីពិតនោះ បរមត្ថធម៌តែមួយលក្ខណៈ ។ កើតឡើងហើយក៏រលត់ទៅយ៉ាងរហ័ស ។ រូបនៃផ្លែទំពាំងបាយជូរ មិនថាត្រជាក់ ឬក្តៅ រឹង ឬទន់ក៏រលត់ រសក៏រលត់ សភាវរូបគ្រប់រូបមានអាយុត្រឹម ១៧ ខណៈ ចិត្តប៉ុណ្ណោះ ។ មិនថាជាពណ៌វណ្ណៈអ្វី សំឡេង ក្លិន រសអ្វីក៏ដោយ បញ្ញាត្រូវពិចារណា ចែកញែកឃនសញ្ញាចេញ រហូតដល់ដឹងតាមសេចក្តីពិតថា ដែលបញ្ញត្តិថាវត្ថុណាមួយនោះ សេចក្តីពិតនោះ គឺត្រឹមតែជាបរមត្ថធម៌មួយលក្ខណៈ ។ ដែលកើត រលត់រួមគ្នា កាលរួមគ្នាជាអាការ សណ្ឋាន ហើយមនោទ្វារវិថីចិត្តក៏កំណត់ដឹងតាមអាការនោះ ។ ខណៈណា ខណៈនោះក៏មានបញ្ញត្តិគឺអាការសណ្ឋាននោះ ។ ជាអារម្មណ៍ ។

សំណួរ - ប៉ុន្តែបើមនោទ្វារជ្រាបថា ជាបិក តើខុស ឬ ត្រូវ ?

សុចិន្ត - មិនខុសទេ ព្រោះថាខណៈមានធម្មារម្មណ៍ គឺបញ្ញត្តិជាអារម្មណ៍ ប៉ុន្តែ **បញ្ញាត្រូវដឹងត្រឹមត្រូវថា ជួរខណៈដែលជាមនោទ្វារវិថី ខុសពីខណៈដែលជាចក្ខុទ្វារវិថី** អ្នកដែលមិនបានអប់រំចម្រើនបញ្ញា រមែង

តែងដឹងរួមគ្នាច្របូកច្របល់ ទាំងផ្លូវចក្ខុទ្វារវិថី និងមនោទ្វារវិថីថាជាវត្ថុណាមួយ ដូចជាសត្វ បុគ្គល វត្ថុផ្សេងៗ ។ ក្នុងមួយថ្ងៃ ៗ មនុស្សទាំងអស់ចូលចិត្តអ្វី ? លោភៈចូលចិត្តអ្វី ? ចូលចិត្តគ្រប់យ៉ាង រួមទាំងអ្វី ?

សំណួរ - វត្ថុដែលជាទីពេញចិត្តគ្រប់ប្រភេទ

សុចិន្ត - លោភៈចូលចិត្តគ្រប់យ៉ាង រួមទាំងបញ្ញត្តិផង លោកពេញទៅដោយបញ្ញត្តិ ទើបបដិសេធមិនបាន ត្រូវពេញចិត្តទាំងបរមត្ថផង និងបញ្ញត្តិផង ។ ពេលពេញចិត្តវត្ថុណាមួយ ខណៈនោះពេញចិត្តបញ្ញត្តិផងដែរ មិនមែនពេញចិត្តចំពោះតែបរមត្ថប៉ុណ្ណោះទេ បើពេញចិត្តខ្សែក្រវាត់ ១ ខ្សែហើយ ក៏ពេញចិត្តពណ៌ដែលប្រាកដតាមផ្លូវភ្នែកដែរ ។

សំណួរ - ពេញចិត្តផ្លាក យីហោ ផងដែរ

សុចិន្ត - ពេញចិត្តទាំងអស់ បើប្រាប់ថាពេញចិត្តពណ៌ ពណ៌អ្វី ពណ៌ដែលជាចិញ្ចើម ជាភ្នែក ជាច្រមុះ ជាមាត់ បើមិនមានពណ៌ប្រាកដទេ តើនឹងមានចិញ្ចើម ភ្នែក ច្រមុះ មាត់ បានឬទេ ? មិនបាន តែពេលឃើញពណ៌ ពណ៌ក៏ត្រឹមតែជាសភាវៈដែលប្រាកដតាមភ្នែកនុ៎ះឯង មិនថាក្រហម ខៀវ ផ្ទៃមេឃ ទឹកប្រាក់ សទេ ប៉ុន្តែយ៉ាងនោះក៏ដោយ ក៏នៅតែពេញចិត្តពណ៌ដែលជាចិញ្ចើម ពណ៌ដែលជាភ្នែក ពណ៌ដែលជាច្រមុះ ពណ៌ដែលជាមាត់ដែរនោះ គឺពេញចិត្តបញ្ញត្តិ ។

បរមត្ថធម៌មានពិត តែពេលពេញចិត្តវត្ថុណា ខណៈនោះក៏ពេញចិត្តទាំងបរមត្ថធម៌ដែលកំពុងប្រាកដផង និងពេញចិត្តបញ្ញត្តិនៃបរមត្ថធម៌នោះផង ។

ក្នុងអដ្ឋសាលិនី និក្ខេបកណ្ឌ អធិប្បាយនិទ្ទេស ឥន្ទ្រិយអគុត្តទ្វារតាទុកៈ អធិប្បាយក្នុងនិទ្ទេស ក្នុងភាពជាអ្នកមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដែលមានសេចក្តីថា

ពាក្យថាជាអ្នកកាន់យកនិមិត្ត គឺរមែងកាន់និមិត្តថា ស្រី ប្រុស

ប្រើពាក្យថា និមិត្ត (រូបរាង សណ្ឋាន) ក្នុងខណៈដែលកាន់យកថាជាស្រី ប្រុស សម្តែងថាមិនមែនបរមត្ថធម៌ ។ ខណៈណាដែលដឹងថាឃើញស្រី ឃើញប្រុស ខណៈនោះកាន់យកនូវនិមិត្ត ឬបញ្ញត្តិនៃសភាវៈដែលប្រាកដតាមផ្លូវភ្នែក មិនមែនដឹងតែបរមត្ថដែលប្រាកដតាមផ្លូវភ្នែកប៉ុណ្ណោះទេ ប៉ុន្តែមានបញ្ញត្តិរបស់សភាវៈដែលប្រាកដជានិមិត្ត គឺរមែងកាន់និមិត្តថាស្រី ប្រុស ឬនិមិត្តដែលជាវត្ថុនៃកិលេស មានសុភនិមិត្តជាដើម ដោយអំណាចឆន្ទរាគៈ ។ បើពេញចិត្តបញ្ញត្តិ គឺខ្សែក្រវាត់ បានសេចក្តីថាខ្សែក្រវាត់នោះមានសុភនិមិត្ត ទើបកើតសេចក្តីពេញចិត្តដោយអំណាចឆន្ទរាគៈ បើខ្សែក្រវាត់មិនស្អាត មិនមែនសុភនិមិត្តក៏មិនពេញចិត្តដូច្នោះ ពណ៌ដែលប្រាកដតាមផ្លូវភ្នែកទើបមានបញ្ញត្តិផ្សេង ។ គឺសុភនិមិត្ត និងអសុភនិមិត្ត ។

សេចក្តីតទៅមានថា **ពាក្យថា ជាអ្នកកាន់អនុព្យញ្ជនៈ** គឺកាន់យកអាការដ៏ផ្សេងដោយដៃជើង ការញញឹម ការសើច ការចរចារ ការក្រឡេកសម្លឹងទៅ និងការបទឆ្វេង បទស្តាំ ជាដើម (អនុព្យញ្ជនៈជាចំណែកល្អិតតូចតាច) ដែលមានវោហារថា " **អនុព្យញ្ជនៈ** " ព្រោះជាគ្រឿងប្រាកដនៃកិលេស គឺញ៉ាំងកិលេសឱ្យប្រាកដ ។

ដែលមានវោហារថា " **អនុព្យញ្ជនៈ** " ព្រោះជាគ្រឿងប្រាកដនៃកិលេស គឺញ៉ាំងកិលេសឱ្យប្រាកដ ដូច្នោះ ទើបយល់អនុព្យញ្ជនៈបានស្រួល ។

ដែលថាពេញចិត្តខ្សែក្រវាត់នោះ ព្រោះនិមិត្តផង និងអនុព្យញ្ជនៈផង បើខ្សែក្រវាត់ដូចតែគ្នាទាំងអស់ មិនធ្វើឱ្យវិចិត្រផ្សេង ។ គ្នាទេ អនុព្យញ្ជនៈក៏មិនផ្សេងគ្នា ប៉ុន្តែខ្សែក្រវាត់មានច្រើនបែប ច្រើនធុន ខុសគ្នាដោយអនុព្យញ្ជនៈ ដូច្នោះ អនុព្យញ្ជនៈ ទើបជាគ្រឿងប្រាកដនៃកិលេស គឺធ្វើកិលេសប្រភេទផ្សេង ។ កើតឡើង ។

សំណួរ - បើមិនឱ្យជាប់ក្នុងបញ្ញត្តិ ក្រែងតែមិនជ្រាបថា នេះ គឺ បិក

សុចិន្ត - នោះខុស ព្រោះមិនមែនដឹងសភាវធម៌តាមសេចក្តីពិតថាសភាវៈដែលប្រាកដតាមភ្នែក ប្រាកដហើយរលត់ទៅ ហើយមនោទ្វារវិថីចិត្តក៏កើតឡើងដឹងបញ្ញត្តិបន្ត បញ្ញាត្រូវដឹងសភាវធម៌តាមសេចក្តីពិតថារូបារម្មណ៍ដែលប្រាកដតាមចក្ខុទ្វារជាអ្វី ខុសពីខណៈដែលចិត្តដឹងបញ្ញត្តិយ៉ាងណា នេះទើបអាចនឹងលះបង់ចោលនូវការប្រកាន់រូបារម្មណ៍ដែល

កំពុងប្រាកដថាជាសត្វ បុគ្គល ជាវត្ថុ ទីតាំងនៃសេចក្តីពេញចិត្ត បាន ហើយនិងដឹងថា ក្នុងខណៈដែលឃើញ ជាស្រី ឬប្រុស ជាសត្វ ជាបុគ្គល ផ្សេង ។ នោះ ជាការដឹងនិមិត្ត ឬបញ្ញត្តិតាមផ្លូវមនោទ្វារ អ្នកអប់រំចម្រើន សតិប្បដ្ឋាន ដែលពុំទាន់ប្រចក្សការកើតរលត់ នៃនាមធម៌ និងរូបធម៌នោះ កាលនៅពុំទាន់ដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដជាប្រក្រតីតាម សេចក្តីពិតថា បរមត្ថធម៌មិនមែនបញ្ញត្តិ ក៏នឹងត្រូវចាំបាច់អប់រំចម្រើន បញ្ញាជារឿយ ។ ក្នុងខណៈដែលសភាវកំពុងប្រាកដតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។

សំណួរ - អាចារ្យប្រាប់ថា បញ្ញត្តិជាធម្មារម្មណ៍មួយបែបមែនទេ ?

សុចិន្ត - បញ្ញត្តិជាធម្មារម្មណ៍ ព្រោះថាជាអារម្មណ៍ដែលដឹងបាន តាមផ្លូវចិត្តតែ ១ ប៉ុណ្ណោះ ។

សំណួរ - ហើយធម្មារម្មណ៍នេះ ប្រសិនបើជាបរមត្ថអារម្មណ៍ ។

សុចិន្ត - ធម្មារម្មណ៍មាន ៦ ប្រភេទ ជាបរមត្ថធម៌ ៥ មិនមែន បរមត្ថធម៌ ១ ដូច្នោះ នឹងដឹងបានថា ខណៈណាមានបញ្ញត្តិជាអារម្មណ៍ ក៏គឺ ខណៈណាដែលមិនមានបរមត្ថធម៌ជាអារម្មណ៍ ខណៈនោះមានបញ្ញត្តិ ជាអារម្មណ៍ ។

មួយថ្ងៃ ។ បញ្ញត្តិបិទបាំងលក្ខណៈនៃបរមត្ថធម៌ ទាំងតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ទើបធ្វើឱ្យមិនដឹងនូវ សភាវធម៌តាមពិតសោះថា សភាវធម៌ដែលកំពុងប្រាកដតាមផ្លូវភ្នែកមិន

មែនសត្វ បុគ្គល តួខ្លួន គឺត្រឹមតែជាពណ៌វណ្ណៈ នៅពេលដែលប៉ះខ្ទប់ចក្ខុបសាទប៉ុណ្ណោះ ។ កាលណាបញ្ញាចម្រើនឡើងដល់ដឹងនូវសេចក្តីពិតក្នុងខណៈដែលកំពុងឃើញហើយក៏អាចលះបង់ការប្រកាន់ សភាវធម៌ថាជាតួខ្លួន សត្វ បុគ្គលបាន ហើយអាចដឹងនូវសេចក្តីខុសគ្នារវាង បរមត្ថអារម្មណ៍ និងបញ្ញត្តិអារម្មណ៍បានតាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ក៏មានន័យតែមួយដូចគ្នា ។

ខណៈដែលកំពុងយល់សប្តិជាអារម្មណ៍អ្វី ? មនុស្សទាំងឡាយតែងតែយល់សប្តិ មានតែព្រះអរហន្តទេ ដែលជាអ្នកមិនយល់សប្តិ ។ មនុស្សទាំងអស់យល់សប្តិ ពេលភ្ញាក់ឡើងក៏ប្រាប់ថាឃើញញាតិបងប្អូនដែលស្លាប់ទៅហើយ ។ ល ។ តើយល់សប្តិឃើញបញ្ញត្តិ ឬ ឃើញបរមត្ថអារម្មណ៍ ? បើមិនមានការពិចារណាទេ ក៏មិនដឹងសោះឡើយ ព្រោះដូចឃើញពិត ប៉ុន្តែតាមសេចក្តីពិតនោះ ពេលសួរថាឃើញអ្វី ? ក៏ឆ្លើយថាឃើញមនុស្ស ឃើញញាតិមិត្តបងប្អូន ឃើញសត្វ បុគ្គលផ្សេង ៗ នោះ គឺយល់សប្តិឃើញនូវរឿងបញ្ញត្តិ ព្រោះខណៈនោះ ចក្ខុទ្វារវិថីចិត្តមិនបានកើតឡើយ ព្រោះកំពុងដេកលក់ ។

ប៉ុន្តែមនោទ្វារវិថីចិត្ត កើតនឹកគិតឃើញជារឿងសត្វ បុគ្គល ផ្សេង ៗ ដូច្នោះ ខណៈដែលកំពុងយល់សប្តិនោះ ក៏នឹកគិតឃើញដល់រឿងបញ្ញត្តិនៃវត្ថុដែលធ្លាប់ឃើញ ធ្លាប់ឮ ជាដើមប៉ុណ្ណោះ ។ អស់លោក អាន កាសែតមានរឿងរ៉ាវផ្សេង ៗ និងមានរូបភាពផ្សេង ៗ ផង ខណៈដែលកំពុងដឹង

រឿងរ៉ាវ និងរូបភាពផ្សេង ។ នោះ សុទ្ធតែជាខណៈដែលនឹកគិតដល់បញ្ញត្តិទាំងអស់ ។ ដូច្នោះក្នុង ១ ថ្ងៃ ។ ទើបមិនដឹងនូវលក្ខណៈ នៃបរមត្ថធម៌ដែលថាផ្សេងពីបញ្ញត្តិយ៉ាងណា ព្រោះមិនថានឹងឃើញតាមផ្លូវភ្នែក ខណៈណាមិនថានឹងអានការសែត ឬធ្វើកិច្ចការងារ នៅទីណា ខណៈណាឡើយ ក៏នឹកគិតដល់បញ្ញត្តិទាំងនោះ ។

ចំពោះតាមផ្លូវត្រចៀកនោះ កាលកើតមកហើយ នៅកូនក្មេងក៏ឮសំឡេង ញយ ។ ជាប្រក្រតី តែមិនទាន់ដឹងពាក្យ មិនទាន់យល់ ក្នុងភាសាណាមួយឡើយ ប៉ុន្តែសញ្ញាសេចក្តីចាំក្នុងសំឡេងផ្សេង ។ កើនឡើង ។ ទើបធ្វើឱ្យនឹកគិតនូវបញ្ញត្តិ សេចក្តីសម្គាល់ផ្សេង ។ របស់សំឡេងដែលចាំទុកនោះ កូនក្មេងក៏ឃើញ ឮ ធុំក្លិន ដឹងរស ដឹងសភាវៈដែលប៉ះខ្ទប់សម្ផស្ស ឈឺ ខឹង ពេញចិត្ត មិនពេញចិត្ត យំ តែមិនដឹងពាក្យដែលនឹងអធិប្បាយ ដែលនឹងនិយាយ ដែលនឹងប្រាប់ រហូតទម្រាំនឹងធំឡើង ។ តើមានអ្នកណាដែលចាំហេតុការណ៍ទាំងឡាយ ពេលដែលទើបតែកើតមកបានទេ ? ទោះជាពេលនោះក៏ឃើញ ក៏ឮ ។ ល ។ ដែរ ប៉ុន្តែកាលណានៅមិនទាន់ មានពាក្យនឹងប្រាប់ទេ ព្រោះមិនទាន់យល់សេចក្តីនៃសំឡេងផ្សេង ។ សេចក្តីចាំហេតុការណ៍ ផ្សេង ។ ក៏រលុបរលត់ភ្លេចបាត់អស់ទៅវិញ ។

ដល់ពេលធំឡើងហើយ ដឹងសេចក្តីក្នុងសំឡេង ចេះភាសាផ្សេង ។ ដែលមិនត្រឹមតែចាំវត្ថុដែលឃើញតាមភ្នែករហូតដល់ចាំរឿងដែលបានឮ

តាមត្រចៀកទៀត រួមគ្នាជារឿងរ៉ាវច្រើនប្រការ លោកនៃសម្មតិបញ្ញត្តិ ទើបកើនឡើង ។ ជាវិវឌ្ឍនាការមិនចេះចប់ កាលអានសៀវភៅរឿងណាមួយហើយ ក៏នៅត្រូវធ្វើជាភាពយន្តឱ្យមើល ឱ្យឮសំឡេងផងទៀត កាលបើពិចារណាប្រៀបធៀបទៅក៏ល្មមនឹងឃើញបានថា លោកនៃសម្មតិនោះ បិទបាំងសភាវៈនៃបរមត្ថសន្ធឹកសន្ធាប់ដល់កម្រិតណាទៅ ដូចក្នុងខណៈដែលកំពុងមើលទូរទស្សន៍ នោះមានបញ្ញត្តិអ្វីខ្លះ មើលល្ខោនរឿងអ្វី អ្នកណាសម្តែងឆាកអ្វី មើលទៅហាក់ដូចជាថា អ្នកសម្តែងល្ខោន ក្នុងទូរទស្សន៍ជាមនុស្សពិត ។ ។ ប៉ុន្តែល្ខោន និងតួល្ខោនជារឿងបញ្ញត្តិយ៉ាងណា កាលបរមត្ថធម៌កើតឡើងប្រាកដហើយក៏រលត់ទៅយ៉ាងរហ័សបន្តគ្នានោះ ខណៈដែលដឹងថាបុគ្គលនេះ បុគ្គលនោះ ក៏ជាការដឹងបញ្ញត្តិយ៉ាងដូច្នោះដែរ ។

សភាវបរមត្ថធម៌ក្នុងជីវិតប្រចាំថ្ងៃត្រូវបិទបាំងដោយអវិជ្ជា ដែលមិនដឹងនូវសេចក្តីផ្សេងគ្នា ខុសគ្នារវាងបរមត្ថ និងបញ្ញត្តិ ទើបមិនអាចដឹងបាននូវសភាវដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដែលមិនមែនសត្វ បុគ្គល តួខ្លួននោះជាអ្វីឡើយ ។ អាស្រ័យហេតុនេះ ការសិក្សារឿងចិត្ត ចេតសិក រូប កាន់តែល្អិតឡើង ។ ទើបធ្វើឱ្យបញ្ញាក្នុងថ្នាក់នៃការស្តាប់ចម្រើនឡើងជាសង្ខារក្ខន្ធឧបត្ថម្ភគាក់តែងឱ្យកើតសតិរលឹកដឹងលក្ខណៈនៃបរមត្ថធម៌ ហើយធ្វើឱ្យលះបង់នូវការប្រកាន់មាំ ក្នុងនិមិត្ត ដែលជាអាការប្រាកដនៃបញ្ញត្តិ ។

សំណួរ - បញ្ញត្តិអាចជាអារម្មណ៍នៃសតិប្បដ្ឋានបានទេ ?

សុចិន្ត - មិនបាន

សំណួរ - កាលស្តាប់រួចមកអម្បាញ់មិញ ហាក់ដូចជាថា បញ្ញត្តិជាអារម្មណ៍របស់សតិប្បដ្ឋានបាន

សុចិន្ត - មានតែបរមត្ថធម៌ប៉ុណ្ណោះជាអារម្មណ៍របស់សតិប្បដ្ឋាន ។ ខណៈណាដែលរសកើតប៉ះខ្ទប់នឹងជិវ្ហាបសាទ ជាបច្ច័យឱ្យចិត្តកើតឡើងដឹងរសតាមជិវ្ហាទ្វារ ផ្តើមតាំងតែពីបញ្ចទ្វារាវជ្ជនចិត្ត ជិវ្ហាវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទាលម្ពណចិត្ត រួចហើយរសក៏រលត់ទើបមិនមានទំពាំងបាយជូរនោះ គឺបរមត្ថធម៌ តែដល់កាលណាប្រជុំគ្នាហើយជាផ្លែទំពាំងបាយជូរ ខណៈនោះ គឺជាបញ្ញត្តិ ។ ដូច្នោះនោះ សតិ-ប្បដ្ឋាន ទើបជាខណៈដែលរលឹកនូវលក្ខណៈសភាវធម៌ដែលជាបរមត្ថធម៌ និងពិចារណាសង្កេតដឹងបានថាសភាវធម៌នោះ ។ មិនមែនសត្វ បុគ្គល តួខ្លួន ។ ខណៈណាដែលសតិប្បដ្ឋានមិនកើត ក៏នឹងមិនមាន ការចែកញែកនូវលក្ខណៈនៃបរមត្ថធម៌ឱ្យចេញពីបញ្ញត្តិបានឡើយ ហើយទើបនៅតែមានសេចក្តីឃើញថា ជាសត្វ បុគ្គល តួខ្លួន រស់នៅរហូតរាល់វេលា។

សំណួរ - អម្បាញ់មិញនេះ អាចារ្យក៏បានពោលមកហើយថាបញ្ញត្តិដឹងបានតាមផ្លូវមនោទ្វារ បើមិនចម្រើនសតិប្បដ្ឋានតាមផ្លូវមនោទ្វារ ដែលបានស្តាប់ មានអារម្មណ៍ថាបញ្ញត្តិនឹងជាអារម្មណ៍របស់សតិប្បដ្ឋានបាន ។

សុចិន្ត - បើយ៉ាងនោះក៏ផ្តើមក្នុងខណៈនេះចុះ កំពុងឮសំឡេង មានបញ្ញត្តិ ឬទេ ? សំឡេងជាបរមត្ថធម៌ ខណៈដែលចិត្តដឹងសេចក្តីសំគាល់នៃ សំឡេងនោះ ចិត្តដឹងបញ្ញត្តិ ចិត្តដែលដឹងសេចក្តីសំគាល់នៃសំឡេង ជាចិត្តដែលដឹងបញ្ញត្តិតាមផ្លូវមនោទ្វារ ខណៈនោះចិត្តកើតឡើងនឹកជា ពាក្យ ។ សតិប្បដ្ឋានក៏កើតឡើងរលឹកដឹងថាខណៈនោះ ជាចិត្តមួយ ប្រភេទដែលកំពុងដឹងពាក្យ ត្រង់ពាក្យមួយ ។ ។

សំណួរ - សតិប្បដ្ឋានរលឹកដឹងនូវបរមត្ថធម៌ តែមិនរលឹកដឹងនូវបញ្ញត្តិ បើ យ៉ាងនោះ ក៏ស្តែងអោយឃើញថា សភាវៈដែលប្រាជកតាមផ្លូវភ្នែក ផ្លូវ ត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ នឹងផុតពីមនោទ្វារមិនបាន សោះឡើយ តើមែនទេ ? គឺពេលភ្នែកមើលសភាវៈដែលឃើញកើតឡើង មានភវង្គចិត្តកើតខណ្ឌ ហើយទើបបន្តទៅមនោទ្វារ ។

សុចិន្ត - វិថីចិត្តតាមផ្លូវមនោទ្វារនឹងត្រូវដឹងរូបមួយដូចគ្នានឹងវិថីចិត្តតាម បញ្ចទ្វារដឹង បើជវនចិត្តតាមផ្លូវបញ្ចទ្វារជាលោភមូលចិត្ត ជវនចិត្តតាម ផ្លូវមនោទ្វារវារៈដំបូងក៏ជាប្រភេទលោភមូលចិត្តតែមួយដូចគ្នា ចក្ខុទ្វារវិថី ចិត្ត និងមនោទ្វារវិថីចិត្តកើតបន្តគ្នាយ៉ាងរហ័សបំផុត ឧបមាដូចសត្វ ស្លាបដែលហើរទៅទុំមែកឈើ ស្រមោលនៃសត្វក៏ប្រាកដត្រង់ផែនដី យ៉ាង ណា កាលអារម្មណ៍ប្រាកដតាមផ្លូវចក្ខុទ្វារ ហើយក៏ប្រាកដបន្តទៅផ្លូវ មនោទ្វារទាន់ពេលយ៉ាងនោះដែរ ក្រោយពីពេលដែលភវង្គចិត្តកើតខណ្ឌ ហើយច្រើនខណៈយ៉ាងរហ័សជាទីបំផុត ទើបធ្វើឱ្យមិនដឹងថារូបារម្មណ៍

ដែលប្រាកដតាមផ្លូវភ្នែកនោះ ត្រឹមតែជាបរមត្ថធម៌ម្យ៉ាងកាលដែលប៉ះខ្ទប់នឹងចក្ខុបសាទហើយប្រាកដ ។

សំណួរ - ដូចយ៉ាងតាមផ្លូវភ្នែក ខណៈដែលឃើញ ពេលឃើញជាបិក ក៏ស្តែងថាពាក្យថាបិកជាផ្លូវមនោទ្វារហើយ ។

សុចិន្ត - នៅមិនទាន់បានគិតដល់ពាក្យថាបិក ក៏មានបញ្ញត្តិមុនស្រេចហើយ ។ ដូច្នោះបញ្ញត្តិទើបមិនបានសំដៅចំពោះតែសទ្ទបញ្ញត្តិ ឬនាមបញ្ញត្តិដែលជាសំឡេង ឬជាពាក្យប៉ុណ្ណោះទេ ។

សំណួរ - ពេលឃើញហើយបានចាំនោះក៏បញ្ញត្តិស្រេចហើយមែនទេ ?

សុចិន្ត - ដែលឈ្មោះថាជាបញ្ញត្តិពីព្រោះឱ្យដឹងបានដោយប្រការនោះ ។ ។

សំណួរ - នោះក៏បានសេចក្តីថា គ្រប់ទ្វារ ផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ត្រូវឆ្លងតាមផ្លូវមនោទ្វារផងដែរ មែនទេ ?

សុចិន្ត - អារម្មណ៍ទាំង ៥ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍នោះ ចិត្តដឹងបាន ២ ទ្វារ គឺចក្ខុទ្វារវិថីចិត្តដឹងរូបារម្មណ៍ហើយមនោទ្វារវិថីក៏ដឹងរូបារម្មណ៍នោះបន្ត នៅពេលភវង្គចិត្តកើតខណ្ឌហើយ ។ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ចិត្តក៏ដឹងបាន ២ ទ្វារ គឺកាលវិថីចិត្តតាមទ្វារនោះ ។ ដឹងអារម្មណ៍នោះ ។ បន្តតាមទ្វារនោះ ។ កាលភវង្គចិត្តកើតខណ្ឌហើយដោយមានន័យដូចគ្នា ។

សំណួរ - ឧបមាថាយើងដឹងរសជូរ ខណៈដែលជូរក៏ជាបញ្ញត្តិទៅហើយមែនទេ ?

សុចិន្ត - អ្វីជូរ ?

សំណួរ - ឧបមាថាទទួលទានក្រូចជូរ

សុចិន្ត - រសជូរជាបរមត្ថធម៌ នឹកគិតថាក្រូចជូរជាបញ្ញត្តិ ពាក្យជាសទ្ទបញ្ញត្តិ ខណៈដាក់ឈ្មោះ ហៅឈ្មោះជានាមបញ្ញត្តិ ។ បើមិនមានសំឡេង មិនមានពាក្យ មិនមានសេចក្តីសំគាល់រឿងរ៉ាវផ្សេង ។ ក៏នឹងមិនមានសន្ទឹកសន្ទាប់ដូចយ៉ាងដែលរស់នៅនេះឡើយ ប៉ុន្តែកាលនៅពេលដែលសំឡេងជាអារម្មណ៍ដល់ចិត្តតាមផ្លូវសោតទ្វារវិថីហើយ ក៏ជាអារម្មណ៍នៃចិត្តដែលកើតបន្តតាមផ្លូវមនោទ្វារផងដែរ (កាលភវង្គចិត្តកើតខណ្ឌហើយ) សញ្ញាដែលចាំ សំគាល់ដឹងសំឡេងផ្សេង ។ ធ្វើឱ្យនឹកដល់ពាក្យផ្សេង ។ ឈ្មោះផ្សេង ។ ។

សេចក្តីក្នុងអដ្ឋសាលិនី និក្ខេបកណ្ឌ ព្រះបាលីសម្តែងនិទ្ទេសអធិវចនទុក្កៈមានសេចក្តីថា **អធិវចនធម៌ គឺធម៌ជាឈ្មោះ** តើដូចម្តេច ?

អធិវចនធម៌ គឺធម៌ជាឈ្មោះតើយ៉ាងណា គឺការពោល ឆ្លើយ អានប្រកប បញ្ញត្តិ វោហារ នាម ការហៅឈ្មោះ ការដាក់ឈ្មោះ ការចេញឈ្មោះ ការហៅឈ្មោះនៃធម៌នោះ ។ ណាមួយ សភាវធម៌ទាំងនេះឈ្មោះថា អធិវចនធម៌ គឺធម៌ជាឈ្មោះ (គ្រប់យ៉ាងជាឈ្មោះទាំងអស់នោះ ដីស ប៉ាកកា តុ កៅអី ។ល។)

ធម៌ទាំងនេះឯងឈ្មោះថា **អធិវចនបថធម៌** គឺធម៌ជាហេតុនៃឈ្មោះ ។

បើមិនមានសភាវធម៌ ឈ្មោះក៏មិនមាន តែកាលបើមានសភាវធម៌ហើយ ដែលមិនមានឈ្មោះមានឬទេ ?

សេចក្តីក្នុងអដ្ឋកថាមានសម្តែងថា ធម៌ទាំងអស់នោះឯងឈ្មោះថាអធិវចនបថធម៌ គឺធម៌ជាហេតុនៃឈ្មោះ ។ បើចូលទៅក្នុងព្រៃមានដើមឈើច្រើនប្រភេទ និងមានគេសួរថា នេះដើមអ្វី ? អ្នកខ្លះស្គាល់ក៏ប្រាប់ថា ដើមរាំង ដើមស្វាយ ដើមគគី សូម្បីតែដើមឈើមិនមានឈ្មោះ ក៏នៅតែប្រាប់ថា ដើមឈើមិនមានឈ្មោះ ឬប្រាប់ថា ដើមនេះមិនស្គាល់ឈ្មោះដូច្នោះ គ្រប់យ៉ាងទើបមានឈ្មោះដែលនឹងឱ្យដឹង អាស្រ័យហេតុនេះ ទើបមិនមានធម៌ណា ៗ ឡើយដែលនឹងមិនជាហេតុនៃឈ្មោះ ។

សេចក្តីតទៅទៀតមានថា ពាក្យថា **ធម៌ទាំងអស់នេះឯង ឈ្មោះថាអធិវចនធម៌** គឺធម៌ជាហេតុនៃធម៌ជាឈ្មោះ អធិប្បាយនិយាយថា ធម៌ដែលមិនជាហេតុនៃធម៌ជាឈ្មោះរកមិនមាន ។

ធម៌មួយរមែងប្រមូលចូលក្នុងធម៌ទាំងអស់ ធម៌ទាំងអស់ក៏ប្រមូលចូលក្នុងធម៌មួយ ។ ប្រមូលចូលយ៉ាងណា ? អធិប្បាយថា នាមបញ្ញត្តិនេះឈ្មោះថាជាធម៌មួយ ធម៌មួយរមែងប្រមូលចូលក្នុងធម៌ទាំង ៤ ភូមិទាំងអស់ ទាំងសត្វ ទាំងសង្ខារឈ្មោះថា ផុតចាកទៅអំពីនាមរកមិនមាន ។

បើមិនមានឈ្មោះ ក៏លំបាកនឹងធ្វើឱ្យយល់គ្នាបានដែរ ដូច្នេះសូម្បីថាជា បរមត្ថធម៌ ជាសភាវធម៌ក៏ដោយ ក៏នៅតែមិនផុតអំពីឈ្មោះ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តិ តាមលក្ខណៈនៃសភាវធម៌នោះ ៗ គឺ

ខន្ធប្បញ្ញត្តិ ៥
អាយតនប្បញ្ញត្តិ ១២
ធាតុប្បញ្ញត្តិ ១៨
សច្ចប្បញ្ញត្តិ ៤
ឥន្ទ្រិយប្បញ្ញត្តិ ២២
បុគ្គលប្បញ្ញត្តិច្រើនពួក

នេះសម្តែងឱ្យឃើញថា សូម្បីព្រះធម៌ដែលព្រះអង្គសម្តែង ក៏មិនផុតទៅអំពីឈ្មោះនាមបញ្ញត្តិផ្សេង ៗ ដែរ ។

និរុត្តិ[២៦]ការនិយាយ គឺការពោលអត្ថចេញតាម អក្ខរៈ ឈ្មោះថានិរុត្តិ

ព្យញ្ជនៈ នាមដែលឈ្មោះថា ព្យញ្ជនៈ (ពាក្យ) ព្រោះអត្ថថាប្រកាសអត្ថ

អភិលាប សំឡេង ដែលឈ្មោះថា អភិលាប ព្រោះអត្ថ ជាសំឡេងបុគ្គលនិយាយ គឺលំដាប់នៃការប្រជុំនៃអក្សរដែលប្រាប់ទៅតាមសំឡេង ។

ក៏បញ្ញត្តិនោះមាន ២ យ៉ាង គឺ បញ្ញាបិយត្តាបញ្ញត្តិ (ការតែងតាំងព្រោះត្រូវដឹងន័យសេចក្តី) ១ បញ្ញាបនតោបញ្ញត្តិ (ការតែងតាំងដោយឱ្យដឹងអត្ថតាមសំឡេង) ១

---

[២៦] អភិធម្មត្ថសង្គហបាលី និងអភិធម្មត្ថវិភាវិនីដីកា បរិច្ឆេទទី ៨

បញ្ញត្តិទាំងឡាយមានប្រការផ្សេង ៗ ដូចនេះ

សន្តានបញ្ញត្តិ បញ្ញត្តិដែលប្រៀបធៀបអាការ គឺការផ្លាស់ប្តូរបន្តនៃភូតនោះ ៗ គឺបញ្ញត្តិថា ផែនដី ភ្នំ ដើមឈើ ជាដើម ។

សមូហបញ្ញត្តិ បញ្ញត្តិដែលសំដៅដល់អាការ គឺការប្រជុំនៃសម្ភារៈ ដូចបញ្ញត្តិថា រថ រទេះ ជាដើម ។

សម្មតិបញ្ញត្តិ បញ្ញត្តិជាដើមថា បុរស បុគ្គល សំដៅដល់ខន្ធបញ្ចកៈ

ទិសាបញ្ញត្តិ បញ្ញត្តិទិសសំដៅដល់ការវិលជុំវិញនៃព្រះចន្ទមានទិសខាងកើតជាដើម ។

កាលបញ្ញត្តិ បញ្ញត្តិកាលវេលា ដូចវេលាព្រឹកជាដើម ។

មាសាទិបញ្ញត្តិ បញ្ញត្តិខែ រដូវ និងឈ្មោះខែ មានវិសាខមាសជាដើម ។

អាកាសបញ្ញត្តិ បញ្ញត្តិ រណ្តៅ ក្រឡុក ល្អាង ជ្រោះ សំដៅដល់អាការដែលមហាភូតរូបមិនទល់ដល់គ្នា ។

និមិត្តបញ្ញត្តិ បញ្ញត្តិកសិណនិមិត្ត សំដៅដល់ភូតនិមិត្តនោះ ៗ និងអាការពិសេសដែលបន្តជាប់គ្នានៃភាវនា ឯបញ្ញត្តិដែលមានសេចក្តីផ្សេងគ្នា ដូចដែលបានពោលមកហើយដោយប្រការយ៉ាងនេះ សូម្បីនឹងមានដោយបរមត្ថក៏ដោយ ក៏ជាអារម្មណ៍នៃចិត្តុប្បាទដោយអាការ គឺស្រមោលនៃអត្ថ (ចំណែកប្រៀបផ្ទឹមនៃបរមត្ថ) ត្រូវកំណត់សំគាល់ដោយអាការ

នោះ ។ ព្រោះការប្រៀបធៀប គឺបានដល់ធ្វើអាការសណ្ឋាន ជាដើមនោះ ។ ឱ្យជាហេតុនិយាយគ្នាបាន ពន្យល់គ្នាបាន ហៅរកគ្នាបានឱ្យដឹងសេចក្តីគ្នាបាន ព្រោះដូច្នោះ ទើបលោកហៅថា បញ្ញត្តិ ។ លោភមូលចិត្ត ដែលកើតឡើងជាប្រចាំតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តនោះ សូម្បីនឹងថាជាលោភមូលចិត្ត ដែលមិនប្រកបដោយសេចក្តីយល់ខុស គឺជាលោភមូលចិត្តទិដ្ឋិគតវិប្បយុត្តក៏ដោយ ក៏មិនមែនថាត្រេកអរពេញចិត្តចំពោះតែបរមត្ថធម៌ ដែលប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តប៉ុណ្ណោះទេ តែនៅត្រេកអរពេញចិត្តទៅរហូតដល់បញ្ញត្តិផ្សេង ។ ទាំងនិមិត្តទាំងអនុព្យញ្ជនៈ និងទាំងឈ្មោះផ្សេង ។ រឿងរ៉ាវផ្សេង ។ ទៀតផងដែរ ។

ដូច្នោះ ក្នុងខណៈនេះ បើសួរដេញដោលគ្នាទៅ ក៏បានឆ្លើយហើយថាភាគច្រើនក្នុងជីវិតប្រចាំថ្ងៃនោះ មានអ្វីជាអារម្មណ៍ មានបញ្ញត្តិជាអារម្មណ៍រហូតដល់បិទបាំងមិនឱ្យដឹងលក្ខណៈនៃបរមត្ថធម៌ តាមសេចក្តីពិត ។

សំណួរ - ដែលថាទំពាំងបាយជូរ ឬរូបភាពទំពាំងបាយជូរ ដែលពេលយើងទៅប៉ះពាល់វា រឹង ទន់យ៉ាងនេះជាបរមត្ថ រស របស់ទំពាំងបាយជូរជាបរមត្ថ រួមគ្នាច្រើនយ៉ាងក៏ជាទំពាំងបាយជូរពិត ។ ដែលហៅថាបញ្ញត្តិព្រោះដូច្នោះ បញ្ញត្តិក៏ជារបស់ពិតដែរ ។

សុចិន្ត - រូបរស កើតហើយក៏រលត់ ព្រោះថាមានអាយុត្រឹមតែ ១៧ ខណៈចិត្តប៉ុណ្ណោះ រូបវណ្ណៈដែលឃើញថាជាទំពាំងបាយជូរក៏កើតឡើងហើយក៏រលត់ទៅយ៉ាងរហ័ស រូបមានអាយុត្រឹម ១៧ ខណៈចិត្ត ដូច្នេះ តើនឹងមានទំពាំងបាយជូរឬទេ ?

សំណួរ - មានសេចក្តីថាំ

សុចិន្ត - ដូច្នោះក៏ជាបញ្ញត្តិថា វត្ថុនោះជាទំពាំងបាយជូរ តែតាមពិតវត្ថុនោះគឺ រស ដែលកើតហើយរលត់ វត្ថុនោះ គឺរឹងដែលកើតហើយរលត់ប៉ុណ្ណោះឯង

សំណួរ- បញ្ញត្តិក៏មកអំពីការរួមគ្នានៃបរមត្ថច្រើនយ៉ាង ជាក្រុម ជាដុំដែរ

សុចិន្ត - កាលណាមិនប្រចក្សការកើត រលត់ នៃសភាវធម៌តែមួយបែប ៗ ដែលរួមគ្នាទេនោះ ក៏ប្រកាន់អាការដែលប្រាកដរួមគ្នានោះ ថាជារបស់នេះរបស់នោះ

សំណួរ - បញ្ញត្តិ តើមិនមែនជារបស់ពិត ឬ ? បញ្ញត្តិក៏មកអំពីបរមត្ថច្រើនយ៉ាង ទន់ រឹង ត្រជាក់ ក្តៅ ពណ៌ ក្លិន រស រួមគ្នាជាក្រុមកលាបៈជាវត្ថុទើបមានពណ៌យ៉ាងនោះ សណ្ឋានយ៉ាងនោះ ឬថាមានរូបរាងសណ្ឋានយ៉ាងនោះ ហើយក៏ជាបុគ្គលនោះទៅ បញ្ញត្តិក៏គឺមកពីបរមត្ថ

សុចិន្ត - ដែលនឹងអាចដឹងបានថា បញ្ញត្តិមិនមែនជាបរមត្ថនោះ ក៏នឹងត្រូវចែកញែកបរមត្ថធម៌ដែលកើតរួមគ្នា ចេញជាបរមត្ថធម៌តែមួយលក្ខណៈ ៗ ដែលប្រាកដតែមួយទ្វារ ៗ ។ សភាវរូបមានអាយុត្រឹម ១៧ ខណៈចិត្ត

ហើយក៏រលត់ទៅ រូបដែលកើតមក ១ ជួរ ១៧ ខណៈចិត្តនោះ នៅមិនទាន់ឈរ ឬដើរ ឬធ្វើអ្វី ។ នោះនៅឡើយទេ ព្រោះដែលលើកដៃឡើងជាដើមក៏គឺលើសពី ១៧ ខណៈចិត្តទៅហើយ ។ ដូច្នោះ ដែលឃើញមានមនុស្សដើរ ឬឃើញមានមនុស្សលើកដៃ គឺបញ្ជាក់ឱ្យឃើញថា រូបរលត់ហើយកើតបន្តប្រាកដ ទាំងតាមចក្ខុទ្វារវិថី និងមនោទ្វារវិថីច្រើនវារៈ ដោយមានភវង្គខណ្ឌ រហូតដល់ប្រាកដជាមានមនុស្សកំពុងដើរ ឬលើកដៃជាដើមទៅ តាមសេចក្តីពិត ១៧ ខណៈចិត្តនោះរហ័សណាស់ ដែលពិចារណាយល់តាមបានថា រូបដែលប្រាកដតាមភ្នែកដែលមានអាយុ ១៧ ខណៈ ចិត្តនោះត្រូវរលត់មុន ដែលនឹងឮសំឡេង ជាទូទៅដែលប្រាកដហាក់ដូចជាថា ទាំងឮផង ឃើញផង តែរវាងចិត្តឮ និងចិត្តឃើញនោះ គឺឆ្ងាយគ្នាហួសពី ១៧ ខណៈចិត្តទៅទៀត ។ ដូច្នោះ រូបដែលកំពុងប្រាកដតាមផ្លូវភ្នែកខណៈនេះ ដែលមានអាយុ ១៧ ខណៈចិត្តត្រូវរលត់ទៅមុន ចិត្តឮទើបកើតឡើងបាន ដូច្នេះ ដែលប្រាកដហាក់ដូចជាទាំងឮផងទាំងឃើញផងនោះ ក៏ព្រោះរូបកើត រលត់ប្រាកដបន្តទាំងតាមផ្លូវចក្ខុទ្វារវិថី និងមនោទ្វារវិថីយ៉ាងសន្ធឹកសន្ធាប់ដោយមានភវង្គខណ្ឌរហូតដល់ប្រាកដជាមានមនុស្សកំពុងដើរ ឬកំពុងលើកដៃនិងធ្វើចលនាផ្សេង ៗ ជាដើម ។ ប៉ុន្តែបើកាលណាមិនបានប្រចក្ស ការកើតឡើងនិងរលត់ទៅវិញយ៉ាងរហ័សរបស់នាមធម៌ និងរូបធម៌ ក៏ប្រកាន់នូវបញ្ញត្តិសភាវៈដែលប្រាកដនោះជាមនុស្សខ្លះ ជាស្រីខ្លះ ប្រុសខ្លះ វត្ថុនេះ វត្ថុនោះ

ខ្លះទៅវិញ ។ ប៉ុន្តែគួររំលឹកដឹងថា តាំងតែផ្តើមសិក្សាបរមត្ថធម៌នោះដឹងថា បរមត្ថធម៌ជាសភាវៈធម៌មានពិត ដែលមិនមែនសត្វ បុគ្គល តួខ្លួន មិនមែនស្រីប្រុស មិនមែនវត្ថុរបស់ណា ។ ឡើយ ធម៌ដែលជាសច្ចៈធម៌នោះ ត្រូវជាសេចក្តីពិតតាំងពីដើមរហូតជានិច្ច រហូតទាល់តែនឹងអប់រំចម្រើនបញ្ញាឡើងដល់ថ្នាក់ប្រចក្សច្បាស់នូវសភាវធម៌ តាមដែលសាំត្រចៀក និងនិយាយតាមថាបរមត្ថធម៌ ជាសភាវៈដែលមានពិតប្រាកដដែលមិនមែនសត្វ បុគ្គល តួខ្លួននោះ ។ រសមានពិត រឹងមានពិត បញ្ញត្តិរសនិងរឹងនោះ ថាទំពាំងបាយជូរ តែសភាវៈដែលមានពិត គឺរូបកើតឡើងហើយរលត់ទៅប៉ុណ្ណោះ ព្រោះដូច្នោះទើបមិនមានទំពាំងបាយជូរ មិនមានសត្វ បុគ្គល គឺមានត្រឹមតែរូបធម៌ និងនាមធម៌ដែលកើត រលត់បន្តគ្នាយ៉ាងរហ័សប៉ុណ្ណោះឯង ។ បរមត្ថធម៌ជាបរមត្ថធម៌ មិនមែនបញ្ញត្តិ **ការសិក្សា និងការបដិបត្តិធម៌ គឺត្រូវត្រង់តាមដែលបានសិក្សាក្នុងពេលមុន និងត្រូវត្រង់ ដល់លក្ខណៈនៃសភាវធម៌តាមសេចក្តីពិត** ដូចតាមដែលសិក្សាថា បរមត្ថធម៌ជាអនត្តានោះ ក៏នឹងត្រូវចូលទៅដល់អត្ថនៃបរមត្ថធម៌ទាំងថ្នាក់នៃការស្តាប់ ទាំងការពិចារណា ទាំងការអប់រំចម្រើនបញ្ញារហូតដល់ប្រចក្សច្បាស់នូវសេចក្តីពិត តាមដែលបានសិក្សារួចមកហើយផងដែរ ។

សំណួរ - អម្បាញ់មិញដែលលោកអ្នកស្តាប់សួរថាបញ្ញាជារបស់ពិតឬទេ ? បើនឹងនិយាយថា របស់ពិតត្រង់លោកញែកទុកថាជាបរមត្ថសច្ចៈ និងជាសម្មតិសច្ចៈ បញ្ញត្តិ នឹងជាសម្មតិសច្ចៈ បានឬទេ ?

សុចិន្ត - បាន តែបញ្ញត្តិមិនមែនបរមត្ថ ដូចឈ្មោះទំពាំងបាយជូរ ឈ្មោះទំពាំងបាយជូរមិនមែនរសអ្វីទាំងអស់ តែរសជាសភាវធម៌ដែលមានពិត និងបញ្ញត្តិរសនោះថា ជាទំពាំងបាយជូរ ។

លោភមូលចិត្តទិដ្ឋិគតវិប្បយុត្តនោះ ក្រៅពីពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងពេញចិត្តនូវបញ្ញត្តិក្នុងជីវិតប្រចាំថ្ងៃហើយ ក៏នៅមានពេញចិត្តក្នុងមិច្ឆាសមាធិបាន ដូចអ្នកដែលពេញចិត្តក្នុងការបរិហារ (ការថែទាំ) កាយ ដឹងថាបើហ្វឹកហាត់បែបយោគៈ ដោយឱ្យចិត្តតាំងមាំ ចុចត្រង់ខ្យល់ ដង្ហើមនឹងធ្វើឱ្យរាងកាយរឹងប៉ឹងក្នុងខណៈនោះ ជាការធ្វើសមាធិមួយប្រភេទ ដែលកាលណាមិនមែនកុសលចិត្ត ក៏នឹងត្រូវលោភមូលចិត្ត ដែលជាមិច្ឆាសមាធិ តែអ្នកនោះមិនបានយល់ខុសទេថានេះជាផ្លូវ ជាគន្លងដែលនឹងធ្វើឱ្យដឹងច្បាស់អរិយសច្ចធម៌ ខណៈនោះគឺត្រឹមតែជាសេចក្តីពេញចិត្តដែលនឹងធ្វើសមាធិ និងដឹងថាក្នុងខណៈនោះមានសេចក្តីប្រាថ្នាត្រូវការសមាធិ ដើម្បីប្រយោជន៍ដល់សុខភាព រាងកាយប៉ុណ្ណោះ មិនមែនយល់ខុសទេ ដោយប្រកាន់ថាត្រូវធ្វើយ៉ាងនេះសិនរួចហើយ ទើបមកពិចារណាជាក្រោយនូវនាមធម៌ និងរូបធម៌នឹងបានឆាប់រហ័ស សឹងបើយល់យ៉ាងនេះហើយ គឺមិនយល់លក្ខណៈនៃសម្មាសតិ

មិនដឹងថាសម្មាសតិជាអនត្តា ព្រោះថាមិនមែនត្រូវទៅឱ្យធ្វើមិច្ឆាសមាធិសិន រួចទើបបានមកឧបត្ថម្ភឱ្យបញ្ញាអាចនឹងដឹងនូវលក្ខណៈនៃនាមធម៌និងរូបធម៌បាននោះទេ ប៉ុន្តែការដែលសតិនឹងជាសម្មាសតិ ជាមគ្គ ១ ក្នុងមគ្គមានអង្គ ៨ បានក៏កាលណាជាសម្មាទិដ្ឋិ សេចក្តីយល់ត្រូវនូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដជាអារម្មណ៍ដែរ ដែលសតិនឹងត្រូវរលឹកឡើងដោយត្រឹមត្រូវ និងល្អិតល្អន់ជាសង្ខារក្ខន្ធតាក់តែងឱ្យសតិកើតរលឹកនូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដបានត្រឹមត្រូវ ដូចផ្លូវភ្នែក ដែលកំពុងឃើញក៏នឹងដឹងបានខណៈណាជាបញ្ញត្តិ និងខណៈណា ជាបរមត្ថ តាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តក៏ដូចតែគ្នា ។

ដូច្នោះ មិនថានឹងមើលទូរទស្សន៍ ឬកីឡាអ្វីទេ អានកាសែតក្តីមើលគំនូរក្តី ក៏នឹងដឹងថា ខណៈណាជាបញ្ញត្តិ និងខណៈណាជាបរមត្ថ បើមិនដូច្នោះ អាចនឹងគិតថា រឿងក្នុងទូរទស្សន៍ជាបញ្ញត្តិ តែខណៈដែលមិនមែនរឿងក្នុងទូរទស្សន៍នោះមិនមែនបញ្ញត្តិ តែសេចក្តីពិតនោះ ទាំងរឿងក្នុងទូរទស្សន៍ ទាំងមិនមែនក្នុងទូរទស្សន៍ក៏ជាបញ្ញត្តិទាំងអស់ សូម្បីតែឈ្មោះរបស់អស់លោកអ្នកគ្រប់គ្នា ក៏ជានាមបញ្ញត្តិដែរ ជាពាក្យដែលដាក់ឡើងដើម្បីឱ្យដឹងសម្គាល់ដល់ចិត្ត ចេតសិក រូបណាដែលកើតរួមគ្នាដែលសម្មតិឡើង ជាបុគ្គលនេះ បុគ្គលនោះប៉ុណ្ណោះ ។

មិច្ឆាសមាធិ ដែលជាលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ផ្សេងពីលោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ដែលយល់ថាមិច្ឆាសមាធិ នោះជាផ្លូវ

ដែលនឹងធ្វើឱ្យដឹងច្បាស់នូវអរិយសច្ចធម៌ ។ មិច្ឆាសមាធិមានជាទូទៅក្នុងគ្រប់ប្រទេស ព្រោះការធ្វើសមាធិខណៈណាក៏ដោយ ដែលមិនមែនកុសលញ្ញាណសម្បយុត្ត គឺមិនប្រកបដោយបញ្ញា ខណៈនោះ ក៏ត្រូវជាមិច្ឆាសមាធិ ។ បើអ្នកណាយល់ថា មិច្ឆាសមាធិជាផ្លូវដែលនឹងធ្វើឱ្យសតិរលឹកនូវលក្ខណៈនៃនាមធម៌ និងរូបធម៌បានឆាប់រហ័ស គឺជាការយល់ខុស **ព្រោះសម្មាសតិនឹងរលឹកនូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដបានត្រឹមត្រូវនោះ ក៏កាលណាយល់នូវលក្ខណៈដែលផ្សេងគ្នា នៃនាមធម៌ និងរូបធម៌ដែលកំពុងប្រាកដជាមុន** តែមិនមែនដោយអាស្រ័យការធ្វើមិច្ឆាសមាធិជាមុនសិននោះទេ ។

សំណួរ - ក្នុងលក្ខណាទិចតុក្កៈប្រាប់ថា សមាធិជាហេតុជិតរបស់វិបស្សនា

សុចិន្ត - សំដៅដល់សមាធិអ្វី ?

សំណួរ - ក៏គង់នឹងជាសម្មាសមាធិ ទើបនឹងជាហេតុជិត

សុចិន្ត - ត្រូវជាសម្មាសមាធិដែលកើតរួម ជាមួយសម្មាសតិ សម្មាទិដ្ឋិ សម្មាសង្កប្បៈ និងសម្មាវាយាមៈ ។

បញ្ញត្តិអារម្មណ៍ ជាអារម្មណ៍របស់ចិត្តក្នុងជីវិតប្រចាំថ្ងៃ ក្នុងខណៈដែលចិត្តមិនមានបរមត្ថធម៌ជាអារម្មណ៍ ព្រោះដូច្នោះ សាកល្បងគិតមើលថាមួយថ្ងៃ ។ នឹងមានបញ្ញត្តិជាអារម្មណ៍ច្រើនឬទេ ? តាមផ្លូវភ្នែកដែលកំពុងឃើញក៏មានរឿងរបស់សភាវៈដែលប្រាកដតាមភ្នែក តាមផ្លូវត្រចៀកដែលឮក៏មានរឿងរបស់សំឡេងដែលឮ តាមផ្លូវច្រមុះដែលដឹងក្លិនក៏មាន

រឿងរបស់ក្លិន តាមផ្លូវអណ្តាតដែលដឹងរសក៏មាន រឿងរបស់រស តាមផ្លូវកាយដែលប៉ះខ្ទប់សម្ផស្សក៏មានរឿងរបស់ផោដ្ឋព្វារម្មណ៍ ក្នុងមួយថ្ងៃ ៗ ចិត្តដែលកើតឡើងតាមផ្លូវចិត្តនោះដឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វារម្មណ៍ និងនឹកគិតរឿងរ៉ាវផ្សេង ៗ របស់អារម្មណ៍ទាំងនោះ ។ នឹងមានអារម្មណ៍ដទៃទៀតទេក្នុងមួយថ្ងៃ ៗ ? ក្រៅពីបរមត្ថអារម្មណ៍ និងបញ្ញត្តិអារម្មណ៍ ក្នុងមួយថ្ងៃ ៗ ទាំងជាតិនេះ ជាតិមុន ជាតិមុខ គ្រប់ភូមិ គ្រប់លោក តើនឹងមានអារម្មណ៍ដទៃទៀតបានឬទេ ? មិនបាន ព្រោះថាមានអារម្មណ៍ ៦ ប៉ុណ្ណោះ ហើយក្នុងអារម្មណ៍ ៦ នេះ ក្រៅពីបរមត្ថធម៌ហើយ គឺជាបញ្ញត្តិនោះឯង ដូច្នោះ ទើបមិនមានអារម្មណ៍ដទៃទៀតឡើយ ។

តើព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ មានបញ្ញត្តិជាអារម្មណ៍ឬទេ ?

ជីវិតប្រចាំថ្ងៃនៃរាល់សត្វបុគ្គលនោះ កាលណាចក្ខុទ្វារវិថីចិត្តរលត់អស់ហើយ ភវង្គចិត្តកើតខណ្ឌហើយមនោទ្វារវិថីចិត្ត ក៏មានបរមត្ថអារម្មណ៍តែមួយដូចនឹងផ្លូវចក្ខុទ្វារវិថីចិត្ត ដែលទើបរលត់ទៅនោះវារៈ ១ ហើយកាលណាភវង្គចិត្តកើតខណ្ឌហើយ មនោទ្វារវិថីចិត្ត ដែលកើតបន្ត ក៏នឹកដល់រូបរាងសណ្ឋានរបស់សភាវៈដែលប្រាកដ ព្រោះសភាវៈដែលប្រាកដតាមផ្លូវភ្នែកជារូបរាងមួយប្រភេទ ដែលកើតជាមួយធាតុ ដី ទឹក ភ្លើង ខ្យល់ ។ ដកពណ៌ចេញពី ដី ទឹក ភ្លើង ខ្យល់ តើបានទេ ? មិនបានឡើយ ព្រោះទីណាក៏ដោយដែលមានមហាភូតរូប ៤ ទីនោះត្រូវ

មានរូបពណ៌ (វណ្ណៈ) ក្លិន រស ឱជា នៅរួមជាមួយ បំបែកចេញពីគ្នាមិនបានឡើយ ។ កាលណាដកយកពណ៌ចេញពីមហាភូតរូបមិនបាន ពណ៌ទើបប្រាកដឱ្យឃើញតាមផ្លូវភ្នែក និងសញ្ញាចាំសំគាល់ជារូបរាង សណ្ឋាន ឱ្យដឹងបញ្ញត្តិថា សភាវៈដែលប្រាកដឱ្យឃើញនោះជាអ្វី ? បើមិនមានពណ៌សោះទេ ដកពណ៌ចេញពីមហាភូតរូបអស់ តើនឹងឃើញជាមនុស្ស សត្វ វត្ថុរបស់របរផ្សេង ៗ បានឬទេ ? សូម្បីចិត្តក៏កើតឡើងដឹងអារម្មណ៍តាមផ្លូវភ្នែកមិនបានឡើយ ព្រោះមិនមានសភាវៈដែលប៉ះខ្ទប់ចក្ខុបសាទ ។

ដូច្នោះ តើព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានបញ្ញត្តិជាអារម្មណ៍ឬទេ ? ត្រូវមានការស្តាប់ព្រះធម៌នោះ ត្រូវពិចារណា ហេតុផលរបស់សភាវធម៌ប្រកបផងដែរ អារម្មណ៍មាន ២ យ៉ាង គឺ**បរមត្ថធម៌** និង **បញ្ញត្តិ** ខណៈណាដែលមិនមានបរមត្ថធម៌ជាអារម្មណ៍ ខណៈនោះត្រូវមានបញ្ញត្តិជាអារម្មណ៍ ដែលពោលជ្រំហើយជ្រំទៀតជារឿយ ៗ ក៏ដើម្បីជាឧបការៈឱ្យសតិរលឹកលក្ខណៈ របស់សភាវធម៌ដែលកំពុងប្រាកដឱ្យត្រឹមត្រូវថា ក្នុងខណៈដែលមានសភាវៈកំពុងប្រាកដតាមផ្លូវភ្នែកជាពណ៌វណ្ណៈផ្សេង ៗ នោះ កាលណាពណ៌បែកពីមហាភូតរូបមិនបាន ពណ៌ដែលកើតជាមួយនឹងមហាភូតរូប ទើបប្រាកដឱ្យឃើញឡើងជាបញ្ញត្តិផ្សេង ៗ កាលណាសតិប្បដ្ឋានកើត ក៏ញែកបំបែករលឹកពិចារណាសង្កេតដឹងបានត្រឹមត្រូវថា សភាវៈដែលកំពុងប្រាកដជាពណ៌វណ្ណៈផ្សេង ៗ នោះជាសភាវធម៌មួយបែបដែលប្រាកដតាមភ្នែក និងខណៈដែលដឹងថាសភាវៈ

ដែលប្រាកដតាមផ្លូវភ្នែកជាអ្វី ។ នោះ ក៏ជាវិថីចិត្តដែលដឹង តាមផ្លូវ មនោទ្វារ ។

កាលបានសិក្សាយល់ហើយក៏នឹងឃើញបានថា ក្នុងជីវិតប្រចាំថ្ងៃនៃរាល់សត្វ បុគ្គលនោះ ខណៈចិត្តខ្លះមានបរមត្ថធម៌ជាអារម្មណ៍ និងខណៈចិត្តខ្លះក៏មានបញ្ញត្តិជាអារម្មណ៍បន្តគ្នា ដូចតាមផ្លូវភ្នែក ក៏មិនបានមានតែចក្ខុទ្វារវិថីចិត្តដែលមានតែពណ៌ជាអារម្មណ៍ប៉ុណ្ណោះទេ កាលចក្ខុទ្វារវិថីចិត្តរលត់អស់ហើយ រួចភវង្គចិត្តក៏កើតខណ្ឌហើយ មនោទ្វារវិថីចិត្តក៏កើតឡើង ទទួលដឹងពណ៌តពីចក្ខុទ្វារវិថី កាលណាមនោទ្វារវិថីចិត្តវារៈដំបូងរលត់អស់ហើយ ភវង្គចិត្តកើតខណ្ឌហើយ មនោទ្វារវិថីចិត្តវារៈបន្ទាប់ក៏កើតឡើងមានបញ្ញត្តិជាអារម្មណ៍ មិនដូច្នោះទេ តើនឹងមានជីវិតរស់នៅបានយ៉ាងណា ? បើមិនដឹងបញ្ញត្តិថាជាតុ ជាកៅអី ជាអាហារ ជាពែង ជាចាន ជាស្លាបព្រា ។ល។ ក៏នឹងមានជីវិតមិនបានឡើយ ។ សត្វតិរច្ឆាន មានបញ្ញត្តិជាអារម្មណ៍ឬទេ ? គឺត្រូវមានដូចគ្នា បើមិនមានបញ្ញត្តិជាអារម្មណ៍ទេ សូម្បីតែសត្វតិរច្ឆាន ក៏រមែងមានជីវិតនៅមិនបានព្រោះមិនដឹងថាអ្វីជាអាហារ អ្វីមិនមែនជាអាហារ ។

អ្នកដែលមានបញ្ញត្តិជាអារម្មណ៍ ដូចជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអរហន្តទាំងឡាយ ព្រះអានាគាមិបុគ្គល ព្រះសកទាគាមិបុគ្គល ព្រះសោតាបន្នបុគ្គល និងបុថុជ្ជនផ្សេងគ្នាយ៉ាងណា ឬក៏មិនផ្សេងគ្នាឡើយ

អ្នកដែលជាព្រះអរិយជាម្ចាស់ និងអ្នកដែលជាបុថុជ្ជន ផ្សេងគ្នាដោយបញ្ញា បុថុជ្ជនដែលមិនដឹងរឿងបរមត្ថធម៌សោះទេ ក៏ប្រកាន់ថាបញ្ញត្តិជាវត្ថុពិត ជាសភាវៈពិត ប៉ុន្តែ**អ្នកដែលដឹងច្បាស់នូវអរិយធម៌ហើយ ដឹងថាធម៌ទាំងឡាយជាអនត្តា** សភាវធម៌ដែលកើតឡើងប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត មិនទៀង និងបញ្ញត្តិមិនមែនបរមត្ថធម៌ ដែលឈ្មោះថា បញ្ញត្តិនោះ ព្រោះឱ្យដឹងបានដោយប្រការនោះ ។ ។ ដូច្នោះបញ្ញត្តិទើបជាអារម្មណ៍របស់ចិត្ត និងចេតសិក ខណៈដឹងការសម្គាល់ ឬអត្ថ របស់សភាវៈដែលប្រាកដ ។ បើមិនមានចិត្ត ចេតសិកទេ តើមានបញ្ញត្តិបាន ឬទេ ?

សភាវធម៌ ជាសភាវៈដែលពិចារណាបានតាមហេតុ ផល បើមិនមានចិត្ត ចេតសិក នឹងមានបញ្ញត្តិមិនបាន បើមានតែរូបធម៌ប៉ុណ្ណោះ មិនមាននាមធម៌សោះទេ មិនមានចិត្ត ចេតសិកសោះ តើនឹងមានបញ្ញត្តិទេ ? គឺមិនមាន ព្រោះថារូបមិនមែនសភាវៈដែលដឹងអារម្មណ៍ ចិត្ត និងចេតសិក ជាសភាវៈដែលដឹងអារម្មណ៍ បើចិត្ត ចេតសិក មិនកើតទេ ក៏មិនមានការដឹងបញ្ញត្តិដែរ ។ ការមានបញ្ញត្តិជាអារម្មណ៍របស់អ្នកដែលជាព្រះអរិយបុគ្គល និងអ្នកដែលមិនមែនជាព្រះអរិយបុគ្គលនោះ ផ្សេងគ្នាត្រង់អ្នកដែលមិនមែនព្រះអរិយបុគ្គលប្រកាន់បញ្ញត្តិថា ជាសភាវៈដែលមានពិត ប៉ុន្តែអ្នកដែលជាព្រះអរិយបុគ្គលដឹងថា ចិត្តខណៈណាមានបរមត្ថធម៌ជាអារម្មណ៍ និងចិត្តខណៈណាមានបញ្ញត្តិជាអារម្មណ៍ ។

ខណៈណាដែលចិត្តដឹងបញ្ញត្តិ គឺកំពុងមានបញ្ញត្តិជាអារម្មណ៍ ខណៈនោះ ជាមិច្ឆាទិដ្ឋិឬទេ ? ស្រេចតែប្រភេទរបស់ចិត្តដែលកំពុងមានបញ្ញត្តិជាអារម្មណ៍ ព្រះអរិយបុគ្គលទាំងឡាយមានបញ្ញត្តិជាអារម្មណ៍ តែព្រះអរិយបុគ្គលទាំងឡាយ មិនមានមិច្ឆាទិដ្ឋិ ព្រោះព្រះអរិយបុគ្គលទាំងឡាយរលត់ទិដ្ឋិចេតសិកជាសមុច្ឆេទ ។ ប្រសិនបើមិនពិចារណាដោយល្អិតល្អន់ទេ ក៏នឹងមិនដឹងថា លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត និងលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ផ្សេងគ្នាយ៉ាងណាទេ លោភមូលចិត្តទិដ្ឋិគ-តវិប្បយុត្ត ត្រេកអរពេញចិត្តក្នុងអារម្មណ៍គ្រប់យ៉ាង ពេញចិត្តសភាវៈដែលប្រាកដតាមផ្លូវភ្នែក ពេញចិត្តសំឡេង ដែលប្រាកដតាមផ្លូវត្រចៀក និងបញ្ញត្តិរបស់សំឡេង ដែលបានឮតាមផ្លូវត្រចៀកផងដែរ តាមផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តដូចន័យតែមួយដូចគ្នា ជាជីវិតប្រក្រតីប្រចាំថ្ងៃ ។

ខណៈណាដែលមិនមានសេចក្តីគិតយល់ខុស ក្នុងរឿងសភាវធម៌ ខណៈនោះមិនមែនលោភមូលចិត្តទិដ្ឋិគតសម្បយុត្តឡើយ ។

ព្រះសោតាបន្នបុគ្គល និងព្រះសកទាគាមិបុគ្គល មានលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ ព្រះអនាគាមិបុគ្គលមានលោភមូលចិត្តទិដ្ឋិគតវិប្បយុត្តក្នុងធម្មារម្មណ៍ ព្រោះបានរំលត់សេចក្តីត្រេកអរ ពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វារម្មណ៍ ដែលជាកាមារម្មណ៍ជាសមុច្ឆេទហើយ ចំណែកព្រះអរហន្តនោះ សូម្បីថាមានអារម្មណ៍ ៦ មែន តែក៏មិនមានទាំងកុសលធម៌ ទាំងអកុសលធម៌ណា ។

ទាំងអស់ ព្រោះព្រះអរហន្តបានរំលត់កិលេស និងអកុសលធម៌ទាំងអស់ជាសមុច្ឆេទ អ្នកដែលមិនមែនជាព្រះអរហន្តនោះ សូម្បីដល់បានដឹងនូវលក្ខណៈនៃអារម្មណ៍តាមសេចក្តីពិតថា ខណៈណាជាបរមត្ថធម៌ ខណៈណាជាបញ្ញត្តិហើយក៏ដោយ កាលណានៅមិនទាន់រំលត់កិលេសអស់ទេ ទើបនៅមានបច្ច័យនឹងឱ្យជាសុខ ជាទុក្ខ ត្រេកអរ មិនពេញចិត្តទៅតាមបរមត្ថអារម្មណ៍ និងបញ្ញត្តិតាមថ្នាក់នៃបុគ្គលនោះ ។ ។

ដូច្នោះ ត្រូវពិចារណាដោយល្អិតល្អន់ថា ខណៈណាជាមិច្ឆាទិដ្ឋិ ខណៈដែលប្រកាន់មាំក្នុងបញ្ញត្តិផ្សេង ។ ដោយសេចក្តីយល់ខុសថា សភាវៈដែលមិនមែនបរមត្ថធម៌នោះមានពិត ក្នុងខណៈនោះជាសក្កាយទិដ្ឋិ កាលបញ្ញត្តិមិនមែនបរមត្ថធម៌ តែការយល់ខុសប្រកាន់បញ្ញត្តិថាជាសភាវៈដែលជាតួខ្លួនពិត ។ ជាសត្វ បុគ្គល ជារបស់ផ្សេង ។ ពិត ទើបជាការយល់ខុសជាសក្កាយទិដ្ឋិ ។

កាលណាសក្កាយទិដ្ឋិនៅមិនទាន់រលត់ជាសមុច្ឆេទទេ ក៏រមែងនឹងជាបច្ច័យឱ្យកើតការយល់ខុសច្រើនប្រការផ្សេងបន្ថែមឡើងទៀត ដូចជាឃើញថាកម្មមិនមាន ផលរបស់កម្មមិនមាន ឃើញថាមានព្រះជាម្ចាស់ដ៏ធំក្រៃលែងជាអ្នកសាងនូវលោក និងសត្វបុគ្គលទាំងឡាយទាំងពួង ។ កាលណាមិនដឹងបច្ច័យដែលធ្វើឱ្យសង្ខារធម៌ទាំងឡាយកើតឡើងទេ ក៏ធ្វើឱ្យកើតការយល់ខុសផ្សេង ។ ប៉ុន្តែខណៈណាក៏ដោយដែលចិត្តមានបញ្ញត្តិជាអារម្មណ៍ ខណៈនោះមិនមែនសុទ្ធតែមានមិច្ឆាទិដ្ឋិគ្រប់ ។ ពេលនោះទេ

ព្រោះមិច្ឆាទិដ្ឋិជាខណៈត្រង់ដែលប្រកាន់មាំក្នុងការយល់ខុសផ្សេង ។ នោះឯង ។

តើបញ្ញត្តិជាអារម្មណ៍របស់អកុសលចិត្តបានទេ ? បាន ព្រោះជីវិតតាមសេចក្តីពិតជាយ៉ាងណាហើយក៏វាត្រូវជាយ៉ាងនោះ លោភមូលចិត្តកើតពេញចិត្តក្នុងបញ្ញត្តិ ទោសមូលចិត្តកើតមិនពេញចិត្តក្នុងបញ្ញត្តិ ដូចជាមិនពេញចិត្តបុគ្គលនោះ មិនពេញចិត្តបុគ្គលនេះ ក្នុងខណៈនោះមានអ្វីជាអារម្មណ៍ មានបញ្ញត្តិជាអារម្មណ៍ ដូច្នោះ បញ្ញត្តិទើបជាអារម្មណ៍របស់អកុសលចិត្តបានគ្រប់ប្រភេទ មិនថានឹងជាអកុសលប្រភេទណាក៏ដោយ ។

ក្នុងខណៈឱ្យទាន បើមិនដឹងថារបស់ដែលនឹងឱ្យនោះជាអ្វីទេ កុសលចិត្តក៏កើតមិនបាន ។ ក្នុងខណៈដែលវិរតិនូវទុច្ចរិតដោយការរក្សាសីល បើមិនដឹងថា អ្វីដែលប្រាកដនោះជាអ្វីទេ ក៏នឹងមិនមានការវិរតិទុច្ចរិតមិនបាន ។ ក្នុងខណៈដែលអប់រំចម្រើនសេចក្តីស្ងប់របស់ចិត្តដែលជាសមថភាវនា តើមានបញ្ញត្តិជាអារម្មណ៍បានឬទេ ? អស់លោកខ្លះ អាចនឹងគិតថា នៅមិនទាន់បានសិក្សារឿងសមថភាវនា ឬអារម្មណ៍របស់សមថភាវនាដោយល្អិតល្អន់ទេ ទើបមិនអាចឆ្លើយបាន ប៉ុន្តែបើមិនភ្លេចសេចក្តីពិតដែលថា ខណៈណាដែលមិនមានបរមត្ថធម៌ជាអារម្មណ៍ ខណៈនោះមានបញ្ញត្តិជាអារម្មណ៍ ក៏ល្មមនឹងដឹងបានថា សូម្បីសមថភាវនាក៏មានបញ្ញត្តិជាអារម្មណ៍បានដែរ ។ **ក្រៅអំពីសតិប្បដ្ឋាន និងបញ្ចទ្វារវិថីចិត្តហើយនោះ ចិត្តខណៈដទៃរមែងមានបញ្ញត្តិជាអារម្មណ៍បាន** ។ ការដែលនឹងដឹងថាសភាវធម៌

ណា ជាបរមត្ថធម៌នោះ ត្រូវអាស្រ័យការអប់រំចម្រើនសតិប្បដ្ឋានប៉ុណ្ណោះ ទើបនឹងដឹងបាន ។ បើខណៈណាសតិប្បដ្ឋានមិនកើត ខណៈនោះក៏មិនមានការពិចារណា សិក្សាសង្កេតដឹងលក្ខណៈនៃសភាវធម៌ ដែលជាបរមត្ថធម៌បានឡើយ ។ ដូច្នេះ ជីវិតប្រក្រតីប្រចាំថ្ងៃ ទើបមានបរមត្ថធម៌ជាអារម្មណ៍ខ្លះ មានបញ្ញត្តិជាអារម្មណ៍ខ្លះ ។

ការអប់រំចម្រើនសតិប្បដ្ឋាន ជារឿងល្អិតល្អន់ណាស់ ព្រោះជាការអប់រំចម្រើនបញ្ញាដឹងសភាវធម៌ដែលប្រាកដតាមសេចក្តីពិត ។

សំណួរ - សតិប្បដ្ឋានមិនមានបញ្ញត្តិជាអារម្មណ៍ ត្រូវ ឬខុស ?

សុចិន្ត - ត្រូវ

សំណួរ - ចម្រើនសតិប្បដ្ឋានដោយព្យាយាមមិនឱ្យចិត្តកើតឡើង ដឹងបញ្ញត្តិអារម្មណ៍ ត្រូវ ឬខុស ?

សុចិន្ត - ខុស ព្រោះថាមិនមែនជីវិតតាមសេចក្តីពិត នរណានឹងអាចឃាត់មិនឱ្យចិត្តកើតឡើងដឹងបញ្ញត្តិអារម្មណ៍បាននោះ ? ប៉ុន្តែបញ្ញានឹងអប់រំចម្រើនឡើងរហូតដល់អាចដឹងបានថា ខណៈដែលមានបញ្ញត្តិជាអារម្មណ៍នោះ គឺចិត្តដែលជានាមធម៌កំពុងដឹងបញ្ញត្តិ ពុំដូច្នោះទេនឹងមានបញ្ញត្តិជាអារម្មណ៍ក្នុងខណៈនោះមិនបាន ដោយហេតុនេះអ្នកដែលអប់រំចម្រើនសតិប្បដ្ឋាន ទើបមិនមែនព្យាយាមនឹងមិនគិតអ្វីឡើយ ឬព្យាយាមដែលនឹងមិនដឹងថា សភាវៈដែលប្រាកដតាមផ្លូវភ្នែកដែលធ្លាប់បានឃើញ បានដឹងជាប្រក្រតីនោះជាអ្វី បើព្យាយាមធ្វើយ៉ាងនោះក៏នឹងមិនអាចដឹងលក្ខណៈ

នៃនាមធម៌ពិត ។ ថាខណៈដែលកំពុងមានបញ្ញត្តិជាអារម្មណ៍នោះ ក៏នាមធម៌ គឺចិត្ត ចេតសិក កើតឡើងមានបញ្ញត្តិជាអារម្មណ៍ក្នុងខណៈនោះ ។ សតិប្បដ្ឋានរលឹកសិក្សា ពិចារណា សង្កេតដឹងថាខណៈណាដែលនឹកគិតខណៈនោះជានាមធម៌ដែលជាសភាពដឹង ជាធាតុដឹង ជាអាការដឹង មិនមែនតួខ្លួន សត្វ បុគ្គល និងដឹងសភាពដែលជាអនត្តារបស់ធម៌ទាំងឡាយថា បញ្ឈប់ចិត្តមិនឱ្យកើតឡើងគិតនឹករឿងរ៉ាវផ្សេង ។ នោះមិនបាន ដូច្នោះបញ្ញានឹងត្រូវដឹងទូទៅក្នុងលក្ខណៈនៃនាមធម៌ផ្សេង ។ ដែលមានអារម្មណ៍ផ្សេង ។ ទាំងតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ទើបនឹងអស់សេចក្តីសង្ស័យនៅក្នុងលក្ខណៈនៃនាមធម៌បាន ។ តែបើទៅបង្ខាំងមិនឱ្យដឹងបញ្ញត្តិ មិនឱ្យនឹកគិត ក៏មិនមែនជាការអប់រំចម្រើនបញ្ញា ព្រោះមិនមាននរណានឹងហាមការកើតឡើងប្រព្រឹត្តទៅរបស់សភាវធម៌ទាំងឡាយ ក្នុងជីវិតប្រចាំថ្ងៃតាមសេចក្តីពិតបានទេ ប៉ុន្តែព្រោះភាពមិនដឹង ទើបធ្វើឱ្យយល់ថានឹងព្យាយាមមិនឱ្យចិត្តនឹកគិត ឬព្យាយាមមិនឱ្យដឹងបញ្ញត្តិនៃសភាវៈដែលប្រាកដ ។

ព្រោះដូច្នោះ ទើបពិចារណាពីគន្លងផ្លូវបដិបត្តិបានថា គន្លងផ្លូវបដិបត្តិណាមិនមែនជាការអប់រំចម្រើនបញ្ញា ដែលសិក្សា សង្កេតដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ តែព្យាយាមធ្វើឱ្យខុសប្រក្រតីជីវិតប្រចាំថ្ងៃតាមសេចក្តីពិត គន្លងផ្លូវនោះ គឺជា**មិច្ឆាមគ្គ** គឺជាមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ

មិនមែនជា**សម្មាមគ្គ** ដែលជាការអប់រំចម្រើនសតិប្បដ្ឋាន អប់រំចម្រើនវិបស្សនានោះទេ ។

ការមិនដឹងនូវលក្ខណៈនៃសភាវធម៌ដែលប្រាកដ និងមិនដឹងហេតុមិនដឹងផលនៃសភាវធម៌នោះ ។ តាមសេចក្តីពិតទេ ធ្វើឱ្យយល់ខុសប្រកាន់មាំ ឃើញខុស និងពេញចិត្តស្វែងរកគន្លងផ្លូវបដិបត្តិដែលខុសដែរ ដោយភាពមិនដឹង ទោះជាក្នុងខណៈដែលឃើញពណ៌ផ្សេង ។ វត្ថុផ្សេង ។ ក៏ដោយ ។ ក្នុងសំយុត្តនិកាយមហាវារវគ្គ មគ្គសំយុត្ត ព្រហ្មសូត្រ មានសេចក្តីសង្ខេបថា សាវត្ថីនិទាន (គឺរឿងនេះកើតត្រង់ព្រះនគរសាវត្ថី)

គ្រានោះវេលាព្រឹក ព្រះអានន្ទដ៏មានអាយុ ប្រដាប់នូវចីវរ ហើយនិងបាត្របានចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានឃើញជាណុស្សាណីព្រាហ្មណ៍ចេញពីក្រុងសាវត្ថីដោយរថដែលទឹមដោយសេះសសុទ្ធ ។ ឮថាសេះដែលទឹមជាសេះស គ្រឿងប្រដាប់ស តួរថស ដំបូលរថស ខ្សែជន្លួញស ឆ័ត្រស ឆ្នូតក្បាលស សំពត់ស្លៀកស ទ្រនាប់ជើងស ផ្លិតវាលវិជនី ដែលមានដងផ្លិតក៏សដែរ ។

កាលប្រជាជនឃើញព្រាហ្មណ៍នោះហើយ ក៏និយាយយ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ យានប្រសើរណាស់ហ្ន៎ រូបនៃយានប្រសើរណាស់ហ្ន៎

(ឃើញត្រឹមតែពណ៌ស ក៏យល់ខុសបាន កាលណាមិនដឹងសភាវធម៌ មិនដឹងគន្លងផ្លូវដែលនឹងប្រចក្សច្បាស់ក្នុងសភាវៈដែលមិនមែនតួខ្លួន

ទេ ក៏ស្វែងរកផ្លូវដទៃ ហើយក៏យល់ឧសថា យានដែលមានពណ៌សជាយានប្រសើរ)

គ្រានោះ ព្រះអានន្ទដ៏មានអាយុទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ហើយវេលាបច្ឆាភត្ត ត្រឡប់ពីបិណ្ឌបាត ក៏ចូលទៅគាល់ ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ គង់អង្គុយក្នុងទីដ៏សមគួរ រួចហើយក៏បានក្រាបទូលនូវរឿងដែលឃើញ ជាណុស្សាណីព្រាហ្មណ៍ ដល់ព្រះមានព្រះភាគទ្រង់ជ្រាប ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងនូវអរិយមគ្គមានអង្គ ៨ ថាជាសភាវធម៌ដែលរំលត់កិលេស មិនមែនរថស និងគ្រប់យ៉ាង ស នោះទេ ហើយក៏បានត្រាស់គាថាពន្ធតទៅទៀតថា

អរិយមគ្គញ្ញាណនោះមានធម៌ គឺសទ្ធា និង**បញ្ញា** ជានឹម មាន**សទ្ធា** ជាទូក មាន**ហិរិ** ជាចន្ទោល មាន**ចិត្ត** ជាខ្សែទាញ មាន**សតិ** ជាសារថីកាន់កាប់ថែរក្សារថនោះ មាន**សីល** ជាគ្រឿងប្រដាប់ មាន**ឈាន** ជាភ្លៅ មាន**សេចក្តីព្យាយាម** ជាកង់ និងមាន**ឧបេក្ខា និងសមាធិ** ជាកំណល់នឹម មាន**សេចក្តីមិនប្រាថ្នា** ជាដំបូល ។ កុលបុត្រណាមាន**សេចក្តីមិនព្យាបាទ សេចក្តីមិនបៀតបៀន** និង**វិវេក** ជាអាវុធ មាន**សេចក្តីអត់ធន់** ជាស្បែកក្រោះ កុលបុត្រនោះរមែងជាអ្នកប្រព្រឹត្តទៅដើម្បីសេចក្តីក្សេមចាកយោគៈ ព្រហ្មយានដ៏ល្អបំផុតនេះ កើតក្នុងខ្លួននៃបុគ្គលទាំងឡាយហើយ បុគ្គល

ទាំងនោះ ជាអ្នកប្រាជ្ញ រមែងចេញចាកពីលោកដោយទំនុកទុកចិត្តថា មានជ័យជំនះដោយពិត ។

(សម្តែងឱ្យឃើញថា រថពណ៌ាស និងគ្រឿងប្រដាប់សទាំងអស់ មិនមែនជាអរិយយាន)

ក្នុងអដ្ឋកថា ព្រាហ្មណ៍សូត្រ មានសេចក្តីថា ជាណុស្សោណីព្រាហ្មណ៍ តែងតែធ្វើប្រទក្សិណនគរ ៦ ខែម្តង ដោយមានអ្នកប្រកាសចេញនាំមុខមុនថា ពីពេលនេះទៅព្រាហ្មណ៍នោះ នឹងធ្វើប្រទក្សិណនគរដោយថ្ងៃទាំងឡាយប្រមាណថ្មើរនេះ ។ ជនទាំងឡាយណា បានស្តាប់ប្រកាសនោះហើយ ទោះកំពុងតែចេញពីព្រះនគរ ជនទាំងឡាយនោះក៏នឹងមិនចេញទៅវិញ (ពេលបានដំណឹងថាជាណុស្សោណីព្រាហ្មណ៍នឹងប្រទក្សិណ សូម្បីអ្នកដែលមានធុរៈនឹងត្រូវចេញពីព្រះនគរ ក៏នៅមិនចេញទៅវិញ) សូម្បីជនទាំងឡាយណាគេចទៅហើយក្តី ក៏ជនទាំងនោះរមែងត្រឡប់មកវិញ ដើម្បីនឹងបានមើលជាណុស្សោណីព្រាហ្មណ៍ ធ្វើប្រទក្សិណព្រះនគរ ដោយគិតថា ពួកយើងនឹងបានឃើញសិរីសម្បត្តិ របស់លោកអ្នកមានបុណ្យ ។

ព្រាហ្មណ៍រមែងត្រាច់ទៅរហូតដល់នូវនគរថ្ងៃណា អ្នកស្រុកទាំងឡាយតែងបោសសំអាតថ្នល់ក្នុងកាលនោះ តាំងតែពីព្រឹកព្រហាម កៀរខ្សាច់ដាក់ពង្រាបឱ្យស្មើ បាចដោយផ្កាឈើទាំងឡាយ ដែលមានលាជជាគម្រប់ ទី ៥ ឱ្យដាក់នូវទឹកឆ្នាំង ជួយគ្នាលើកដើមចេកទាំងឡាយ និង

ទង់ទាំងឡាយឡើង ហើយរមែងធ្វើព្រះនគរ ពោរពេញទៅដោយអប់ក្លិន ធូប ។ ព្រាហ្មណ៍ប្រទក្សិណនគរដោយរថគ្រឿងប្រដាប់ គឺរថទឹមដោយ សេះទាំង ៤ ក្បាល ដែលពណ៌សសុទ្ធ កង់និងកាំទាំងអស់ហ៊ុមពាសទៅ ដោយប្រាក់ (គឺមិនថាគ្រឿងប្រដាប់ណា ។ មានពណ៌ស ទាំងអស់) រថ មាន ២ យ៉ាង គឺរថចម្បាំង ១ និងរថគ្រឿងប្រដាប់ ១ រថចម្បាំងមាន សណ្ឋាន ៤ ជ្រុងមិនធំពេក អាចផ្ទុកមនុស្ស ២ ឬ ៣ នាក់ តែរថគ្រឿង ប្រដាប់នោះជារថធំវែង ហើយទូលាយ មនុស្សបាំងឆ័ត្របាន កាន់ផ្លិតវាល វិជនី កាន់ផ្លិតស្លឹកត្នោត រមែងនៅក្នុងរថនោះ ៨ ឬ ១០ នាក់ អាចឈរ ក៏បាន ដេកក៏បាន តាមសប្បាយក្នុងរថនោះ ហើយសេះដែលទឹមនោះ ក៏ស គ្រឿងប្រដាប់របស់សេះទាំងនោះ ជាគ្រឿងប្រាក់ទាំងអស់ ។ រថដែល ឈ្មោះថា ស ព្រោះហ៊ុមទៅដោយប្រាក់ និងប្រដាប់ដោយភ្លុកដំរី រថដទៃ ទៀតមានហ៊ុមព័ទ្ធដោយស្បែករាជសីហ៍ខ្លះ ដោយស្បែកខ្លាដំបងខ្លះ ដោយសំពត់កម្ពលលឿងយ៉ាងណា ចំណែករថរបស់ជាណុស្សាណីព្រា-ហ្មណ៍នោះ រកឱ្យដូចយ៉ាងនោះ មិនមានឡើយ ព្រោះថាបានហ៊ុមព័ទ្ធ សំពត់យ៉ាងល្អ ខ្សែរុំទៅដោយប្រាក់ និងកែវប្រពាឡ សូម្បីដងជន្លួញ ក៏ហ៊ុមទៅដោយប្រាក់ សូម្បីឆ័ត្រ ដែលគេលើកឡើងកណ្តាលរថ ក៏ស សំពត់ឆ្នូតក្បាល ធ្វើដោយខ្សែប្រាក់ក៏ស សំពត់ស្លៀកស គឺមានពណ៌ដូច ដុំពពុះទឹក ក្នុងសំពត់ទាំងនោះ សំពត់ស្លៀកមានតម្លៃ ៥០០ សំពត់ជាហ៊ុម មានតម្លៃមួយពាន់ និងចំពោះទ្រនាប់ជើងនោះ អ្នកដំណើរ ឬអ្នកចូល

ព្រៃជ្រៅ រមែងតែងមាន តែចំណែកស្បែកជើងនេះ សម្រាប់ឡើងរថ ជាគ្រឿងប្រដាប់ផ្សំដោយប្រាក់ចាយ និងផ្លិតវាលវិជនីមានពណ៌ស មានដងធ្វើដោយកែវផលិក គឺគ្រឿងប្រដាប់សប៉ុណ្ណោះ បានមានដល់ព្រាហ្មណ៍នោះតែម្យ៉ាងប៉ុណ្ណោះរកមិនមានឡើយ សូម្បីគ្រឿងប្រដាប់របស់ព្រាហ្ម-ណ៍នោះ ក៏ធ្វើដោយប្រាក់ផងដែរ មានដូចយ៉ាងនេះថា គឺព្រាហ្មណ៍នោះពណ៌ប្រដាប់ ផ្កាឈើស ត្រង់ម្រាមទាំង ១០ ពាក់ដោយចិញ្ចៀន ត្រចៀកទាំង ២ ពាក់ ទុំហូ សូម្បីព្រាហ្មណ៍ជាបរិវារប្រមាណ ១០ ០០០ នាក់ ក៏ប្រដាប់សសុទ្ធទាំងអស់ ទាំងខោអាវ ផ្កាឈើ និងគ្រឿងប្រដាប់ខ្លួនដោយប្រមាណប៉ុណ្ណោះដូចគ្នា ។

ជាណុស្សាណីព្រាហ្មណ៍ជំរះខ្លួនតាំងពីព្រលឹម បរិភោគអាហារព្រឹកហើយ ក៏តាក់តែងខ្លួនដោយគ្រឿងសំអាង មានសំពត់ស្លៀកដណ្តប់សឈានជើងចុះពីប្រាសាទ ឡើងលើរថ ពួកព្រាហ្មណ៍ក៏តាក់តែងដោយសំពត់ផងដែរ គ្រឿងលាប និងផ្កាឈើសទាំងអស់កាន់នៅដ៏ត្រស ហែហមជុំវិញជាណុស្សាណីព្រាហ្មណ៍ ។

បន្ទាប់ពីនោះ ជនទាំងឡាយ ក៏រមែងចែកចាយផលាផល ដល់ពួកក្មេង ៗ មុន ដើម្បីការប្រជុំនៃមហាជន តពីនោះក៏រមែងបាចនូវប្រាក់មាសក តពីនោះក៏បាចកហាបណៈទាំងអស់ ។ មហាជនរមែងប្រជុំគ្នាស្រែកហ៊ោ និងក្រវីកន្សែង ព្រាហ្មណ៍រមែងទៅដល់នគរដោយមហាសម្បត្តិ កាលជនទាំងឡាយអ្នកមានសេចក្តីត្រូវការមង្គលសួស្តី ជាដើម ។

ការនៅធ្វើមង្គលសួស្តី មនុស្សទាំងឡាយ អ្នកមានបុណ្យឡើងទៅលើប្រាសាទមួយជាន់ បើកបង្អួចអើតមើល ដូចជាសត្វសារិកាកែវ សូម្បីព្រាហ្មណ៍ ក៏រមែងកុះករចោមរោមសំដៅទៅត្រង់ផ្លូវចូលទ្វារខាងត្បូង ហាក់ដូចជានគរគ្រប់គ្រងទៅដោយយស សិរី និងសម្បត្តិរបស់ខ្លួន ។ ពេលមហាជនឃើញរថនោះក៏ពោលថា អ្នកដ៏ចម្រើនទាំងឡាយ យានដ៏ប្រសើរហ្ន៎ ។ ប៉ុន្តែព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ធម្មតាមនុស្សទាំងឡាយឱ្យទ្រព្យដល់អ្នកដែលពោលសរសើរ ហើយក៏រមែងឱ្យច្រៀងសរសើរទារិកាទាំងឡាយ របស់ខ្លួនថាជាអ្នកគួរស្រឡាញ់ គួរគយគន់ មានទ្រព្យច្រើន មានភោគៈច្រើនយ៉ាងនេះ ប៉ុន្តែកូនចៅទាំងនោះ ក៏ជាអ្នកគួរជាទីស្រឡាញ់ ឬមានភោគៈច្រើន ឱ្យដូចជាការពោលសរសើរនោះក៏មិនមាន មហាជនឃើញរថព្រាហ្មណ៍ យ៉ាងនេះហើយ ទើបពោលសរសើរយ៉ាងនេះថា លោកអ្នកដ៏ចម្រើន យានប្រសើរហ្ន៎ សូម្បីដល់យ៉ាងនេះពិតក៏ដោយ យាននោះនឹងឈ្មោះថា ជាយានប្រសើរដោយត្រឹមតែការពោលសរសើរនោះមិនមានឡើយ ដែលពិតនោះ យាននោះជារបស់លាមក ជារបស់អាក្រក់ ។

ម្នាលអានន្ទ តែដោយបរមត្ថ យាននោះជាឈ្មោះ របស់អរិយមគ្គ មានអង្គ ៨ នេះប៉ុណ្ណោះឯង ឯអរិយមគ្គនេះប្រសើរ ព្រោះប្រាសចាកទោសទាំងពួង ដោយហេតុថា ព្រះអរិយៈទាំងឡាយ រមែងទៅដល់និព្វានដោយអរិយមគ្គនេះ ដូច្នោះ ទើបគួរពោលថា ព្រហ្មយានខ្លះ ធម្មយានខ្លះ

ព្រោះជាធម៌ និងជាយាន ពោលថាជារថពិជ័យសង្គ្រាម ដ៏ល្អជាទីបំផុតខ្លះ ព្រោះមិនមានវត្ថុដទៃដ៏ក្រៃលែងជាង និងព្រោះឈ្នះសង្គ្រាម គឺកិលេសហើយ ។

នេះគឺសេចក្តីផ្សេងគ្នា ដែលកើតអំពីត្រឹមតែការយើញប៉ុណ្ណោះ ក៏ធ្វើឱ្យការយល់ខុស សេចក្តីយល់ផ្លូវបដិបត្តិខុសទៅហើយ ព្រោះគិតថាពណ៌ាស នឹងជាមង្គល ធ្វើឱ្យជាអ្នកបរិសុទ្ធ ឬអស់កិលេសបាន ។ តែសេចក្តីពិតនោះ ព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ថា សេចក្តីពិតយាននោះ ជារបស់លាមក ជារបស់អាក្រក់ ព្រោះថាធ្វើឱ្យគេយល់ខុស គិតថាជាយានប្រសើរ ។ ព្រោះដូច្នោះ ការដែលនឹងដឹងសភាវធម៌តាមសេចក្តីពិតទើបមិនទាក់ទងនឹងរឿងពណ៌នៃគ្រឿងស្លៀកដណ្តប់ និងគ្រឿងប្រដាប់លំអរតាក់តែងនោះឡើយ គឺថាកាលណាពេលសតិបញ្ញាកើត រលឹកដឹងនូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ទើបឈ្មោះថា យាននោះមាននៅក្នុងអ្នកនោះមែន ដែលនឹងអាចនាំទៅដល់ការរំលត់កិលេសបាន ។

តាគបន្ថែម

ចិត្ត ៨៩ ឬ ១២១ ប្រភេទ

ចិត្ត ៨៩ ប្រភេទ គឺ

កាមាវចរចិត្ត	៥៤	ដួង
រូបាវចរចិត្ត	១៥	ដួង
អរូបាវចរចិត្ត	១២	ដួង
លោកុត្តរចិត្ត	៨	ដួង

ចិត្ត ១២១ ប្រភេទ គឺ

កាមាវចរចិត្ត	៥៤	ដួង
រូបាវចរចិត្ត	១៥	ដួង
អរូបាវចរចិត្ត	១២	ដួង
លោកុត្តរចិត្ត	៤០	ដួង

កាមាវចរចិត្ត ជាចិត្តថ្នាក់ដើមដែលកើតឡើង ហើយរលត់ជាប្រក្រតីប្រចាំថ្ងៃគ្រប់ខណៈ មិនថាដេកលក់ ឬភ្ញាក់ឡើយ ។ រូបបរមត្ថជាកាមារម្មណ៍ក្នុងបណ្តារូបបរមត្ថ ២៨ រូបនោះ រូបបរមត្ថដែលប្រាកដជាអារម្មណ៍តាមប្រក្រតីតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តនោះមាន ៧ រូប ហៅថា គោចរវិសយរូប (រូបដែល

ជាវិស័យជាគោចរ គឺរូបដែលចិត្តរមែងកើតឡើងដឹងជាប្រក្រតី) បានដល់រូបារម្មណ៍ (វណ្ណៈដែលប្រាកដនៅពេលប៉ះខ្ទប់ចក្ខុបសាទរូប) ១ រូប សទ្ទារម្មណ៍ (សំឡេងប្រាកដនៅពេលប៉ះខ្ទប់សោតបសាទរូប) ១ រូប គន្ធារម្មណ៍ (ក្លិនប្រាកដកាលប៉ះខ្ទប់ឃានបសាទរូប) ១ រូប រសារម្មណ៍ (រសប្រាកដកាលប៉ះខ្ទប់ជិវ្ហាបសាទរូប) ១ រូប ផោដ្ឋព្វារម្មណ៍ ៣ រូប (ទន់ ឬ រឹង ជាធាតុដី ១ ត្រជាក់ ឬក្តៅជាធាតុភ្លើង ១ តឹង ឬ ញ័រ ជាធាតុខ្យល់ ១ ប្រាកដកាលប៉ះខ្ទប់នឹងកាយបសាទរូប) ។

ចិត្តដែលកើតរលត់ជាប្រក្រតីក្នុងជីវិតគ្រប់ ៗ ខណៈ ជាចិត្តថ្នាក់កាមាវចរចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងរូបទាំងនេះ គឺមានរូបទាំងនេះជាអារម្មណ៍ ឬនឹកគិតរឿងរូបទាំងនេះ ។

កាមាវចរចិត្ត ៥៤ ដួង គឺ

អកុសលចិត្ត	១២	ដួង
អហេតុកចិត្ត	១៨	ដួង
កាមសោភណចិត្ត	២៤	ដួង

អកុសលចិត្ត ១២ ដួង

អកុសលចិត្ត ជាចិត្តដែលមិនល្អស្អាត ព្រោះមានអកុសលចេតសិកកើតរួមជាមួយ ។ អកុសលចិត្ត ១២ ដួង បានដល់លោភមូលចិត្ត

៨ ដួង ទោសមូលចិត្ត ២ ដួង មោហមូលចិត្ត ២ ដួង ។

មូល គឺដើមហេតុរបស់អកុសលធម៌ទាំងឡាយនោះ មាន ៣ គឺ លោភចេតសិក ១ ទោសចេតសិក ១ មោហចេតសិក ១ រួមជា អកុសលហេតុ ឬអកុសលហេតុមូល ៣ ។

លោភមូលចិត្ត គឺចិត្តដែលមានលោភចេតសិកកើតរួមជាមួយ ទើប ធ្វើឱ្យពេញចិត្ត ជាប់ជំពាក់ក្នុងអារម្មណ៍ដែលប្រាកដ ។ លោភមូលចិត្តមាន ៨ ប្រភេទ គឺ

ដួងទី ១ សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងសោមនស្សវេទនា (**សោមនស្សសហគតំ**) សេចក្តីដឹងខ្លួនសប្បាយចិត្តជាសុខ ប្រព្រឹត្តទៅជាមួយការយល់ខុស (**ទិដ្ឋិគតសម្បយុត្តំ**) គឺមានទិដ្ឋិចេតសិកកើតរួមជាមួយ ជាចិត្តមាន កម្លាំងកើតឡើង ដោយមិនត្រូវអាស្រ័យការបបួលដឹកនាំ(**អសង្ខារិកំ**) ។

ដួងទី ២ សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងសោមនស្សវេទនា ប្រព្រឹត្តទៅជាមួយការយល់ ខុស ជាចិត្តដែលមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួល ដឹកនាំ (**សសង្ខារិកំ**) ។

ដួងទី ៣ សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងសោមនស្សវេទនា មិនប្រព្រឹត្តទៅជាមួយការយល់ខុស (**ទិដ្ឋិគតវិប្បយុត្តំ**) គឺមិនមានទិដ្ឋិចេតសិកកើតរួមជាមួយជាចិត្តមានកម្លាំងកើតឡើង ដោយមិនត្រូវអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៤ សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងសោមនស្សវេទនា មិនប្រព្រឹត្តទៅជាមួយការយល់ខុស ជាចិត្តមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៥ ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងឧបេក្ខាវេទនា សេចក្តីដឹងខ្លួនមិនសុខមិនទុក្ខប្រព្រឹត្តទៅជាមួយការយល់ខុស ជាចិត្តមានកម្លាំងកើតឡើង ដោយមិនត្រូវអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៦ ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

លោភមូលចិត្ត កើតរួមនឹងឧបេក្ខាវេទនា ប្រព្រឹត្តទៅជាមួយការយល់ខុស ជាចិត្តមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៧ ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តកើតរួមនឹងឧបេក្ខាវេទនា មិនប្រព្រឹត្តទៅជាមួយ ការយល់ខុស ជាចិត្តមានកម្លាំងកើតឡើង ដោយមិនអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៨ ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តកើតរួមនឹងឧបេក្ខាវេទនា មិនប្រព្រឹត្តទៅជាមួយសេចក្តីយល់ខុស ជាចិត្តមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ទោសមូលចិត្ត គឺចិត្តដែលកើតរួមជាមួយទោសចេតសិក ដែលជាសភាវធម៌ដ៏គ្រោតគ្រាត មិនពេញចិត្តក្នុងអារម្មណ៍ ។ ទោសមូលចិត្តមាន ២ ប្រភេទ គឺ

ដួងទី ១ ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ

ទោសមូលចិត្តកើតរួមនឹងទោមនស្សវេទនា សេចក្តីដឹងខ្លួនមិនសប្បាយចិត្ត និងកើតរួមជាមួយនិងបដិឃៈ (ទោសចេតសិក) ដែលជាសភាវធម៌ គ្រោតគ្រាត ជាចិត្តមានកម្លាំងកើតឡើង ដោយមិនអាស្រ័យការបបួលដឹកនាំ ។

ដួងទី ២ ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

ទោសមូលចិត្តកើតរួមនឹងទោមនស្សវេទនា និងទោសចេតសិក ជាចិត្តមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

មោហមូលចិត្ត គឺចិត្តដែលកើតរួម នឹងមោហចេតសិក ដែលជាសភាវធម៌វង្វេង មិនដឹងសេចក្តីពិតនៃសភាវធម៌ទាំងឡាយ ។ មោហមូលចិត្តមាន ២ ប្រភេទ គឺ

ដួងទី ១ ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ

មោហមូលចិត្តកើតរួមនឹងឧបេក្ខាវេទនា ប្រកបដោយសេចក្តីសង្ស័យ (វិចិកិច្ឆាចេតសិក) ក្នុងសេចក្តីពិតនៃសភាវធម៌ទាំងឡាយ ។

ដួងទី ២ ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ

មោហមូលចិត្តកើតរួមនឹងឧបេក្ខាវេទនា ប្រកបដោយសេចក្តីរាយ-មាយ (ឧទ្ធច្ចចេតសិក) ។

ចិត្តមួយដួង ៗ នោះ មានចេតសិកកើតរួមជាមួយច្រើនប្រភេទ ។ ចិត្តមួយដួង ៗ នឹងមានចេតសិកកើតរួមជាមួយច្រើន តិចផ្សេងគ្នា តាមប្រភេទនៃចិត្តនោះ ៗ ចិត្តគ្រប់ដួង ត្រូវមានវេទនាចេតសិកកើតរួមជាមួយតាមប្រភេទនៃចិត្តនោះ ៗ ។

អកុសលចិត្តគ្រប់ដួង ត្រូវមានអកុសលសាធារណចេតសិក (ចេតសិកដែលកើតជាមួយ នឹងអកុសលចិត្តគ្រប់ដួង) ៤ ដួងកើតរួមជាមួយគឺ មោហចេតសិក ១ អហិរិកចេតសិក (សភាវធម៌ ដែលមិនខ្ពើមបាប) ១

អនោត្តប្បចេតសិក (សភាវធម៌ដែលមិនស្លុតខ្លាចទោសនៃអកុសលធម៌) ១ និងឧទ្ធច្ចចេតសិក (សភាវធម៌ដែលរាយមាយទៅតាមអកុសលធម៌) ១ ។

សេចក្តីផ្សេងគ្នានៃអកុសលចិត្ត ១២ ដួងដោយមូល (អកុសលហេតុ ៣ បានដល់ លោភៈ ទោសៈ មោហៈ) គឺ

មោហមូលចិត្ត មិនមានលោភចេតសិក និងទោសចេតសិកកើតរួម ។

ទោសមូលចិត្ត មិនមានលោភចេតសិកកើតរួមជាមួយ

លោភមូលចិត្ត មិនមានទោសចេតសិកកើតរួមជាមួយ សេចក្តីផ្សេងគ្នានៃអកុសលចិត្ត ១២ ដួងដោយ វេទនា ៣ (ឧបេក្ខាវេទនា សោមនស្សវេទនា ទោមនស្សវេទនា) គឺ

ឧបេក្ខាវេទនាចេតសិក កើតរួមនឹងលោភមូលចិត្ត និងមោហមូលចិត្តបាន កើតរួមនឹងទោសមូលចិត្តមិនបាន ។

សោមនស្សវេទនាចេតសិក កើតរួមនឹងលោភមូលចិត្ត តែកើតរួមនឹងទោសមូលចិត្ត និងមោហមូលចិត្តមិនបាន ។

ទោមនស្សវេទនាចេតសិក កើតរួមនឹងទោសមូលចិត្ត ២ ដួងប៉ុណ្ណោះ មិនកើតនឹងចិត្តប្រភេទដទៃ ៗ ឡើយ ។

សម្រាប់អកុសលចិត្តដួងចុងក្រោយ គឺមោហមូលចិត្តដួងទី ២ ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ នោះជាមោហមូលចិត្ត ដែលមិនមានវិចិកិច្ឆាចេតសិកកើតរួមជាមួយ តែក៏ជាអកុសលចិត្តមួយប្រភេទ ព្រោះ

មានអកុសលចេតសិកកើតរួមជាមួយ ។ ខណៈណាដែលមិនមែន ជាលោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង និងមោហមូលចិត្ត វិចិកិច្ឆាសម្បយុត្តអកុសលចិត្ត ខណៈនោះ គឺជាមោហមូលចិត្ត ឧទ្ធច្ច-សម្បយុត្ត ។ ពេលអកុសលចិត្តខណៈណាមានកម្លាំងខ្លាំងក្លា ក៏នឹងជាហេតុឱ្យចេតនាប្រព្រឹត្តនូវអកុសលកម្មបថ ១០ គឺ

កាយកម្ម ៣ បានដល់ បាណាតិបាត (សម្លាប់សត្វដែលមានជីវិត) ១ អទិន្នាទាន (កាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យមកជារបស់ខ្លួន) ១ កាមេសុមិច្ឆាចារ (ប្រព្រឹត្តខុសក្នុងកាម) ១ ។

វចីកម្ម ៤ បានដល់ មុសាវាទ (ពោលពាក្យកុហក) ១ ផរុសវាទ (ពោលពាក្យគ្រោតគ្រាត) ១ បិសុណាវាចា (ពោលពាក្យស៊ីកសៀត) ១ សម្ផប្បលាបវាចា (ពោលពាក្យរោយរាយ) ១ ។

មនោកម្ម ៣ បានដល់ អភិជ្ឈា (គិតសម្លឹងរំពៃបម្រុង យករបស់អ្នកដទៃមកជារបស់ខ្លួន) ១ ព្យាបាទ (គិតបៀតបៀនធ្វើឱ្យអ្នកដទៃវិនាស) ១ មិច្ឆាទិដ្ឋិ (គិតយល់ខុសថា ផលរបស់កម្មមិនមានជា នត្ថិកទិដ្ឋិ គឺឃើញថាផលដែលកើតឡើងនោះមិនបានកើតពីកម្ម ១ យល់ខុស ថាកម្មមិនមានផលជាអហេតុកទិដ្ឋិ គឺឃើញថា កម្មមិនដែលជាហេតុឱ្យកើតផល ១ យល់ខុស ថាកម្មត្រឹមជាកិរិយាអាការនៃកាយប៉ុណ្ណោះ ជា អកិរិយាទិដ្ឋិ ១) ១ ។ នៅពេលអកុសលចិត្ត ដែលជាហេតុឱ្យប្រព្រឹត្តនូវអកុសលកម្មបថរលត់ទៅហើយ ចេតនាចេតសិកដែលកើតជាមួយនឹងអកុសលចិត្ត

ដែលរលត់ទៅហើយនោះ ក៏ជាកម្មប្បច្ច័យឱ្យអកុសលវិបាកចិត្ត ៧ ដួង កើតឡើងជាផលនៃកម្មនោះ ។ កាលណា ដល់កាលវេលាដ៏សមគួរ ។

អហេតុកចិត្ត ១៨ ដួង

អហេតុកចិត្ត ១៨ ដួង គឺចិត្តដែលមិនកើតរួមជាមួយចេតសិកដែលជាហេតុ ៦ ដួងឡើយ ។ ចេតសិកដែលជាហេតុមាន ៦ ដួង គឺ លោភចេតសិក ១ ទោសចេតសិក ១ មោហចេតសិក ១ ជាអកុសលហេតុ ៣ (អកុសលហេតុ ៣ នេះកើតជាមួយនឹងអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ មិនកើតជាមួយនឹងចិត្តប្រភេទដទៃ ។ ឡើយ) អលោភចេតសិក ១ អទោសចេតសិក ១ បញ្ញាចេតសិក (អមោហៈ) ១ ជាសោភណហេតុ ៣ **ចិត្តណាមានសោភណហេតុកើតរួមជាមួយ ចិត្តនោះជាសោភណចិត្ត គឺជាចិត្តដែលល្អស្អាត ។**

ចិត្ត ១៨ ដួងមិនកើតរួមជាមួយនឹងចេតសិកដែលជាហេតុ ៦ ឡើយ ទើបចិត្ត ១៨ ដួងជាអហេតុកចិត្ត និងជាអសោភណចិត្តផងដែរ ចំណែកចិត្តដទៃ ។ ៧១ ដួងនោះ កើតរួមជាមួយនឹងចេតសិកដែលជាហេតុ ទើបចិត្ត ៧១ ដួងជាសហេតុកចិត្ត ។

អហេតុកចិត្ត ១៨ ដួង គឺអកុសលវិបាកចិត្ត ៧ ដួង អហេតុកកុសលវិបាកចិត្ត ៨ ដួង និងអហេតុកកិរិយាចិត្ត ៣ ដួង ។

អកុសលវិបាកចិត្ត ៧ ដួង គឺ

ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ
ចិត្តឃើញវណ្ណៈ (ដែលមិនល្អ)
កើតរួមនឹងឧបេក្ខាវេទនា
ឧបេក្ខាសហគតំ សោតវិញ្ញាណំ
ចិត្តឮសំឡេង (ដែលមិនល្អ)
កើតរួមនឹងឧបេក្ខាវេទនា
ឧបេក្ខាសហគតំ ឃានវិញ្ញាណំ
ចិត្តធុំក្លិន (ដែលមិនល្អ)
កើតរួមនឹងឧបេក្ខាវេទនា
ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ
ចិត្តទទួលដឹងរស (ដែលមិនល្អ)
កើតរួមនឹងឧបេក្ខាវេទនា
ទុក្ខសហគតំ កាយវិញ្ញាណំ
ចិត្តដឹងជោដ្ឋព្វៈ (ដែលមិនល្អ)
កើតរួមនឹងទុក្ខវេទនា

បញ្ចវិញ្ញាណ ៥ ដឹង អារម្មណ៍ ៥ ចំពោះ អារម្មណ៍នៃ ខ្លួនប៉ុណ្ណោះ

ឧបេក្ខាសហគតំ សម្បដិច្ឆន្នំ
ចិត្តទទួលដឹងអារម្មណ៍ ៥ តពីបញ្ចវិញ្ញាណអកុសលវិបាកចិត្ត ។

ឧបេក្ខាសហគតំ សន្តីរណំ

ចិត្តពិចារណាអារម្មណ៍ ៥ តពីសម្បដិច្ឆន្នៈអកុសលវិបាកចិត្ត ។

អកុសលវិបាកចិត្តគ្រប់ដួង ជាផលរបស់អកុសលកម្ម ទើបជាចិត្តដែលកើតឡើងដឹងអនិដ្ឋារម្មណ៍ គឺជាអារម្មណ៍ដែលមិនជាទីពេញចិត្ត ។

អហេតុកកុសលវិបាកចិត្ត ៨ ដួង ជាផលនៃកាមាវចរកុសលចិត្ត ៨ ដួង ដែលមានចេតនាជាកុសល សម្រេចក្នុងបុញ្ញកិរិយា ១០ គឺទាន សីល ភាវនា ជាដើម ។ កាលកុសលចេតនាកើតឡើងធ្វើកុសលកម្មសម្រេចហើយ កុសលចេតនានោះរមែងជាកម្មប្បច្ច័យឱ្យកើតផល គឺកាមាវចរ-កុសលវិបាកចិត្ត ១៦ ដួង គឺកាមាវចរសហេតុកកុសលវិបាកចិត្ត ៨ ដួង និងជាអហេតុកកុសលវិបាកចិត្ត ៨ ដួង ។

អហេតុកកុសលវិបាកចិត្ត ៨ ដួង គឺ

ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ

ចិត្តឃើញវណ្ណៈ (ដែលល្អ) កើតរួមនឹងឧបេក្ខាវេទនា

ឧបេក្ខាសហគតំ សោតវិញ្ញាណំ

ចិត្តឮសំឡេង (ដែលល្អ) កើតរួមនឹងឧបេក្ខាវេទនា

ឧបេក្ខាសហគតំ ឃានវិញ្ញាណំ

ចិត្តធុំក្លិន (ដែលល្អ) កើតរួមនឹងឧបេក្ខាវេទនា

ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ

ចិត្តដឹងរស (ដែលល្អ) កើតរួមនឹងឧបេក្ខាវេទនា

សុខសហគតំ កាយវិញ្ញាណំ

ចិត្តដឹងផោដ្ឋព្វៈ (ដែលល្អ) កើតរួមនឹងសុខវេទនា

ឧបេក្ខាសហគតំ សម្បដិច្ឆនំ

ចិត្តទទួលដឹងអារម្មណ៍ ៥ តពីបញ្ចវិញ្ញាណកុសលវិបាក ។

ឧបេក្ខាសហគតំ សន្តីរណំ

ចិត្តពិចារណាអារម្មណ៍ ៥ ដែលតពីសម្បដិច្ឆន្នៈ កុសលវិបាក ។

សោមនស្សសហគតំ សន្តីរណំ

ចិត្តពិចារណាអារម្មណ៍ ៥ ដែលល្អពិសេស តពីសម្បដិច្ឆន្នៈ កុសលវិបាក ។

អារម្មណ៍ដែលគួរជាទីពេញចិត្តនោះមាន ២ គឺឥដ្ឋារម្មណ៍ និង អតិឥដ្ឋារម្មណ៍ (អារម្មណ៍គួរជាទីពេញចិត្តក្រៃលែង) ។ ខណៈណាដែល ជាផលនៃកុសលកម្មដែលសោមនស្ស សប្បាយចិត្ត កុសលវិបាក ក៏កើតឡើង ដឹងអារម្មណ៍ដែលជាអតិឥដ្ឋារម្មណ៍ ហើយសន្តីរណចិត្ត ដែលពិចារណាដឹងអតិឥដ្ឋារម្មណ៍ ក៏កើតរួមនឹងសោមនស្សវេទនា ។

បើខណៈណាកុសលវិបាកចិត្តកើតឡើងដឹងឥដ្ឋារម្មណ៍ សន្តីរណចិត្ត ដែលពិចារណាដឹងឥដ្ឋារម្មណ៍នោះ ក៏កើតរួមនឹងឧបេក្ខាវេទនា ។

អហេតុកកិរិយាចិត្ត ៣ ដួង

កិរិយាចិត្ត គឺជាចិត្តដែលមិនមែនកុសលចិត្ត និងអកុសលចិត្ត ដែលជាហេតុ និងមិនមែនវិបាកចិត្តដែលជាផល ។ អហេតុកកិរិយាចិត្ត គឺកិរិយាចិត្តដែលមិនកើតរួមនឹងចេតសិកដែលជាហេតុ ។ អហេតុកកិរិយាចិត្តមាន ៣ ដួង គឺ

ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ ១ ដួង
ឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ ១ ដួង
សោមនស្សសហគតំ ហសិតុប្បាទចិត្តំ ១ ដួង

បញ្ចទ្វារាវជ្ជនចិត្ត (**បញ្ច** + **ទ្វារ** + **អាវជ្ជន**) គឺវិថីចិត្តខណៈដំបូងដែលកើតឡើងដឹងអារម្មណ៍ដែលប៉ះខ្ទប់នឹងភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

កិរិយាចិត្តផ្សេងពីវិបាកចិត្ត គឺកិរិយាចិត្តដឹងអារម្មណ៍ ជាឥដ្ឋារម្មណ៍ក៏បាន ជាអនិដ្ឋារម្មណ៍ក៏បាន ចំណែកវិបាកចិត្តនោះ កុសលវិបាកចិត្តដឹងបានចំពោះតែឥដ្ឋារម្មណ៍ អកុសលវិបាកចិត្តក៏ដឹងបាន ចំពោះតែអនិដ្ឋារម្មណ៍ប៉ុណ្ណោះ ។

កាលបញ្ចទ្វារវជ្ជនចិត្តកើតឡើង ដឹងថាអារម្មណ៍ណាប៉ះខ្ទប់ភ្នែក (ឬត្រចៀក ឬច្រមុះ ឬអណ្តាត ឬកាយ) ហើយក៏រលត់ទៅចក្ខុវិញ្ញាណ (ឬសោតវិញ្ញាណ ឬឃានវិញ្ញាណ ឬជិវ្ហាវិញ្ញាណ ឬកាយវិញ្ញាណ) ទើបកើតបន្តឃើញ (ឬឮ ឬធុំក្លិន ឬដឹងរស ឬដឹងផោដ្ឋព្វៈ) អារម្មណ៍តែមួយដូចគ្នានោះហើយរលត់ទៅ សម្បដិច្ឆន្នចិត្តកើតបន្តទទួលអារម្មណ៍តែមួយ ដូចគ្នានោះហើយរលត់ទៅ សន្តីរណចិត្តទើបកើតបន្តពិចារណាអារម្មណ៍តែមួយដូចគ្នានោះ ហើយរលត់ទៅ ។

កាលចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ នឹងកើតឡើងទទួលផលនៃកម្ម តាមផ្លូវភ្នែក ឬផ្លូវត្រចៀក ឬផ្លូវច្រមុះ ឬផ្លូវអណ្តាត ឬផ្លូវកាយ តែមួយវារៈ ។ នោះ បញ្ចទ្វារវជ្ជនចិត្តនឹងត្រូវកើតមុន ព្រោះត្រូវមានវិថីចិត្តដែលកើតឡើងដឹង អារម្មណ៍ប៉ះខ្ទប់ទ្វារណាមួយជាមុនសិន ។ ចិត្តដែលឈ្មោះថា អាវជ្ជនៈនោះ ព្រោះអត្ថថា នាំចេញទៅពីសន្តាន (ការបន្ត) ដែលជាភវង្គ ហើយបង្អោនទៅដល់អារម្មណ៍ដែលប៉ះខ្ទប់ទ្វារ ។ កាលណាបញ្ចទ្វារវជ្ជនចិត្តរលត់ហើយ ចក្ខុវិញ្ញាណ ឬសោតវិញ្ញាណ ឬឃានវិញ្ញាណ ឬជិវ្ហាវិញ្ញាណ ឬកាយវិញ្ញាណ ទើបកើតឡើងឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ តាមទ្វារនោះ ។ បាន ។

មនោទ្វារាវជ្ជនចិត្ត (**មនោ** + **ទ្វារ** + **អាវជ្ជន**) ជាវិថីចិត្តខណៈដំបូងដែលកើតឡើងដឹងអារម្មណ៍តាមផ្លូវចិត្ត និងជាចិត្តដែលកើតមុនអកុសលចិត្ត ឬកាមាវចរកុសលចិត្ត (បើជាព្រះអរហន្តក៏ជាកាមាវចរកិរិយាជំនួសកុសលចិត្ត) និងតាមបញ្ចទ្វារនោះ កាលសន្តីរណចិត្ត រលត់ទៅហើយ មនោទ្វារាវជ្ជនចិត្តក៏កើតតធ្វើវោដ្ឋវនកិច្ច ទើបជាវោដ្ឋព្វនចិត្ត (ព្រោះមិនបានកើតឡើងដឹងអារម្មណ៍តាមមនោទ្វារ ទើបមិនបានធ្វើអាវជ្ជនកិច្ច) គឺជាចិត្តដែលធ្វើផ្លូវឱ្យចិត្តដែលកើតបន្តអំពីមនសិការដែលធ្វើទុកក្នុងចិត្តមិនត្រូវទំនងជាអកុសលចិត្ត ឬមនសិការដោយឧបាយត្រូវទំនងជាកុសលចិត្ត (ឬកិរិយាចិត្តរបស់ព្រះអរហន្ត) តាមការសន្សំនៃចិត្ត ។

មិនថាចិត្តដួងនោះ នឹងកើតតាមបញ្ចទ្វារជាវោដ្ឋព្វនចិត្ត បន្តពីសន្តីរណចិត្តក្តី ឬកើតឡើងដឹងអារម្មណ៍តាមផ្លូវចិត្ត ខណៈដំបូងជាមនោទ្វារាវជ្ជនចិត្តក្តី ពេលចិត្តដួងនេះរលត់ទៅហើយ អកុសលចិត្ត ឬកាមាវចរកុសលចិត្ត (ឬកាមាវចរកិរិយាចិត្តរបស់ព្រះអរហន្ត) ទើបកើតឡើងបាន ។ ដូច្នោះ ចិត្តដួងនេះទើបកើតឡើងមុនអកុសលចិត្ត និងកាមាវចរកុសលចិត្ត (ឬកាមាវចរកិរិយាចិត្តនៃព្រះអរហន្ត) ទាំង ៦ ទ្វារ ។

ហសិតុប្បាទចិត្ត ជាចិត្តដែលត្រឹមតែធ្វើឱ្យព្រះអរហន្តរីករាយញញឹមញញែមក្នុង ៦ អារម្មណ៍ ៦ ទ្វារ ។

កាមាវចរសោភណចិត្ត ២៤ ដួង

កាមាវចរសោភណចិត្ត ២៤ ដួង ជាចិត្តដែលល្អស្អាតថ្នាក់កាមាវចរ ព្រោះមានចេតសិកល្អ (សោភណចេតសិក) កើតរួមជាមួយ ។

កាមាវចរសោភណចិត្ត ២៤ ដួង គឺកាមាវចរកុសលចិត្ត (មហាកុសល) ៨ ដួង កាមាវចរវិបាកចិត្ត (មហាវិបាក) ៨ ដួង កាមាវចរកិរិយាចិត្ត (មហាកិរិយា) ៨ ដួង ។

កាមាវចរកុសលចិត្ត ៨ ដួងគឺ

ដួងទី១ សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ

កុសលចិត្តកើតរួមនឹងសោមនស្សវេទនា ប្រកបដោយបញ្ញា (ញាណសម្បយុត្តំ) គឺមានបញ្ញាចេតសិក (អមោហៈ) កើតរួមផង ជាចិត្តមានកម្លាំងកើតឡើង ដោយមិនត្រូវអាស្រ័យការបបួលដឹកនាំ ។

ដួងទី ២ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ

កុសលចិត្តកើតរួមជាមួយនឹងសោមនស្សវេទនា ប្រកបដោយបញ្ញាជាចិត្តដែលមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៣ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ

កុសលចិត្តកើតរួមនឹងសោមនស្សវេទនា មិនប្រកបដោយបញ្ញាជាចិត្តដែលមានកម្លាំងកើតឡើង ដោយមិនអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៤ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

កុសលចិត្តកើតរួមនឹងសោមនស្សវេទនា មិនប្រកបដោយបញ្ញា ជាចិត្តដែលមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៥ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ

កុសលចិត្តកើតរួមនឹងឧបេក្ខាវេទនា ប្រកបដោយបញ្ញា ជាចិត្តដែលមានកម្លាំងកើតឡើង ដោយមិនអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៦ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ

កុសលចិត្តកើតរួមនឹងឧបេក្ខាវេទនា ប្រកបដោយបញ្ញា ជាចិត្តដែលមានកម្លាំងខ្សោយកើតឡើង ដោយអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៧ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ

កុសលចិត្តកើតរួមនឹងឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា ជាចិត្តដែលមានកម្លាំងកើតឡើង ដោយមិនអាស្រ័យការបបួលដឹកនាំ ។

ដួងទី ៨ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

កុសលចិត្តកើតរួមនឹងឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា ជាចិត្តដែលមានកម្លាំងខ្សោយ កើតឡើងដោយអាស្រ័យការបបួលដឹកនាំ ។

ចេតនាចេតសិកក្នុងកាមាវចរកុសលចិត្ត ៨ ដួងរមែងសម្រេចជាកុសលកម្មក្នុងបុញ្ញកិរិយាវត្ថុ ១០ គឺ[២៧]

[២៧] អដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ អធិប្បាយបុញ្ញកិរិយាវត្ថុ

ទានមយ បុណ្យសម្រេចដោយទាន ការលះបង់នូវវត្ថុ ដែលជាប្រយោជន៍ឱ្យដល់អ្នកដទៃ ។

សីលមយ បុណ្យសម្រេចដោយសីល ការវិរតិនូវទុច្ចរិតកម្ម ។

ភាវនាមយ បុណ្យសម្រេចដោយការចម្រើនសមថៈ និងការចម្រើនវិបស្សនា ។

អបចាយនមយ (អបចិតិសហគត) បុណ្យសម្រេចដោយ ការគោរពឱនលំទោន ដល់អ្នកដទៃដែលគួរគោរពឱនលំទោន ។

វេយ្យាវច្ចមយ (វេយ្យាវច្ចមយសហគត) បុណ្យសម្រេចដោយការខ្វល់ខ្វាយជួយសង្គ្រោះ ជ្រោមជ្រែងក្នុងកិច្ចការងារដែលគួរធ្វើ ។

បត្តិទានមយ (បត្តានុបទានមយ) បុណ្យសម្រេចដោយការឧទ្ទិសនូវចំណែកកុសលឱ្យអ្នកដទៃដឹងដើម្បីអនុមោទនា ។

បត្តានុមោទនាមយ (អព្ភានុមោទនាមយ) បុណ្យសម្រេចដោយការអនុមោទនាក្នុងកុសលរបស់អ្នកដទៃ ។

ទេសនាមយ បុណ្យសម្រេចដោយការសម្តែងព្រះធម៌ ។

សវនមយ បុណ្យសម្រេចដោយការស្តាប់ព្រះធម៌ ។

ទិដ្ឋុជុកម្មមយ បុណ្យសម្រេចដោយការយល់ឃើញឱ្យត្រឹមត្រូវ ។

ខណៈណាដែលចិត្តមិនប្រព្រឹត្តទៅក្នុងបុញ្ញកិរិយាវត្ថុ ១០ ខណៈនោះមិនមែនជាកុសលចិត្ត ។

កាមាវចរកុសលចិត្ត ជាកុសលដែលប្រព្រឹត្តទៅសង្គ្រោះក្នុងទាន

(ទាន បត្តិទាន បត្តានុមោទនា) សង្គ្រោះក្នុងសីល (សីល អបចាយន វេយ្យាវច្ច) សង្គ្រោះក្នុងភាវនា (ភាវនា ធម្មទេសនា ធម្មស្សវន ទិដ្ឋុជុកម្ម) កើតឡើងតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ។ ដោយហេតុនេះ កាមាវចរកុសលទើបឈ្មោះថា **មហាកុសល** ។

កាលកាមាវចរកុសលចិត្ត ៨ ដួងកើតឡើង សម្រេចជាកុសលកម្ម ហើយ ចេតនាដែលធ្វើកុសលកម្មនោះ ។ ជាកម្មប្បច្ច័យឱ្យកាមាវចរ-កុសលវិបាកចិត្ត ១៦ ដួង កើតជាផលរបស់កម្មនោះ ។ តាមសមគួរដល់ហេតុ និងកាល ។ កាមាវចរវិបាកចិត្ត ១៦ ដួង គឺអហេតុកកុសលវិបាក ៨ ដួង និងកាមាវចរសហេតុកកុសល (មហាវិបាក) ៨ ដួង ។

កាមាវចរ សហេតុកកុសលវិបាក (មហាវិបាក) ៨ ដួង គឺ

ដួងទី ១ សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
ដួងទី ២ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
ដួងទី ៣ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ដួងទី ៤ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
ដួងទី ៥ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
ដួងទី ៦ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
ដួងទី ៧ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ដួងទី ៨ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

មហាវិបាកចិត្ត ៨ ដួងនេះ មានសោភណហេតុចេតសិក កើតរួមជាមួយផង ទើបជាសហេតុកកុសលវិបាកចិត្ត ខុសពីអហេតុកកុសលវិបាកចិត្ត ៨ ដួង ដែលមិនមានសោភណហេតុចេតសិកកើតរួមជាមួយ ។

កាមាវចរសោភណកិរិយាចិត្ត (មហាកិរិយាចិត្ត) ៨ ដួង ជាចិត្តរបស់ព្រះអរហន្ត ដែលពេលរំលត់អកុសល និងកុសលទាំងឡាយដែលជាហេតុឱ្យកើតវិបាកចិត្តក្នុងកាលខាងមុខហើយ ។ សភាពនៃសោភណចិត្តដែលជាកុសល មុនជាព្រះអរហន្តនោះ កាលជាព្រះអរហន្តហើយ ក៏ត្រឹមតែជាកិរិយាចិត្ត ដែលមិនជាហេតុឱ្យកើតវិបាកចិត្តតទៅទៀត ។ ដូច្នោះ ព្រះអរហន្តទើបមានតែវិបាកចិត្ត និងកិរិយាចិត្ត គឺមានវិបាកចិត្ត ដែលជាផលរបស់អតីតកម្មមុនជាព្រះអរហន្ត និងមានកិរិយាចិត្ត ដែលមិនមែនកុសល ទើបមិនជាហេតុឱ្យកើតវិបាកចិត្តក្នុងកាលតទៅទៀតឡើយ ។

កាមាវចរសោភណកិរិយាចិត្ត ឬសហេតុកកិរិយាចិត្ត ឬមហាកិរិយាចិត្ត ៨ ដួង គឺ

ដួងទី ១ សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ
ដួងទី ២ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
ដួងទី ៣ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ដួងទី ៤ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ
ដួងទី ៥ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ

ជួនទី ៦ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ
ជួនទី ៧ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ
ជួនទី ៨ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ

រូបាវចរចិត្ត ១៥ ដួង

រូបាវចរចិត្ត ១៥ ដួង គឺរូបាវចរកុសលចិត្ត ៥ ដួង រូបាវចរវិបាកចិត្ត ៥ ដួង រូបាវចរកិរិយាចិត្ត ៥ ដួង ។

រូបាវចរចិត្ត ជាចិត្តលំដាប់ខ្ពស់ជាងកាមាវចរចិត្ត ជាចិត្តដែលបានអប់រំចម្រើនឡើងដល់ផុតកាមារម្មណ៍ ដោយអាស្រ័យការអប់រំចម្រើនកាមាវចរកុសលចិត្តឡើងស្ងប់ដ៏មាំជាសមថភាវនា ។ នៅពេលកាមាវចរ-កុសលចិត្ត ឡើងស្ងប់ដ៏មាំជាសមាធិថ្នាក់ផ្សេង ។ រហូតដល់ចិត្តតាំងមាំណែនក្នុងអារម្មណ៍ជាអប្បនាសមាធិខណៈណា ខណៈនោះក៏ជារូបាវចរ-កុសលចិត្ត (រូបឈានកុសលចិត្ត) ផុតចាកសភាពនៃកាមាវចរចិត្ត ។

រូបាវចរកុសលចិត្ត ៥ ដួង

វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ

បឋមជ្ឈានកុសលចិត្ត មានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា

វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ

ទុតិយជ្ឈានកុសលចិត្ត មានអង្គ ៤ គឺ វិចារ បីតិ សុខ ឯកគ្គតា

បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ

តតិយជ្ឈានកុសលចិត្ត មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា

សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ

ចតុត្ថជ្ឈានកុសលចិត្ត មានអង្គ ២ គឺ សុខ ឯកគ្គតា

ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ

បញ្ចមជ្ឈានកុសលចិត្ត មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា

ឈានចិត្ត ថ្នាក់ខ្ពស់ឡើង ៗ នោះ លះអង្គនៃឈានទៅតាមលំដាប់ដោយន័យនៃរូបជ្ឈាន ៤ នោះ មិនមានទុតិយជ្ឈាន តតិយជ្ឈានចិត្ត ទើបជាទុតិយជ្ឈាន ចតុត្ថជ្ឈានចិត្ត ទើបជាតតិយជ្ឈាន និងបញ្ចមជ្ឈានចិត្ត ទើបជាចតុត្ថជ្ឈាន ទាំងនេះព្រោះបុគ្គលខ្លះអាចមានសមត្ថភាពលះនូវ វិតក្ក និងវិចារបានព្រមគ្នា ។

រូបាវចរវិបាកចិត្ត ៥ ដួង

វិតក្ក វិចារ បីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ

បឋមជ្ឈានវិបាកចិត្ត មានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា

វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ

ទុតិយជ្ឈានវិបាកចិត្តមានអង្គ ៤ គឺ វិចារ បីតិ សុខ ឯកគ្គតា

បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្តំ

តតិយជ្ឈានវិបាកចិត្ត មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា

សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ

ចតុត្ថជ្ឈានវិបាកចិត្ត មានអង្គ ២ គឺ សុខ ឯកគ្គតា

ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ

បញ្ចមជ្ឈានវិបាកចិត្ត មានអង្គ ២ គឺឧបេក្ខា ឯកគ្គតា

កាលរូបាវចរចិត្តជាកុសលមានកម្លាំង ដល់ព្រមដោយវសី គឺការស្ទាត់ជំនាញដ៏ឈ្លាសក្នុងការកើតឡើងបានតាមកំណត់វេលា និងកើតរលត់បន្តគ្នាទៅដោយមិនដាច់ខ្សែតាមកំណត់វេលា និងចេញពីឈាន គឺឈានចិត្តកើតបន្តទៅទៀតតាមកំណត់វេលាជាដើម ការឈានចិត្តនោះមិនវិនាសបាត់បង់ទេ ឈានកុសលចិត្តថ្នាក់ណាមួយ រមែងមានបច្ច័យកើតឡើងមុនចុតិចិត្ត ហើយឈានកុសលចិត្តដែលកើតមុនចុតិចិត្ត រមែងជាបច្ច័យឱ្យឈានវិបាកចិត្តបដិសន្ធិកើតឡើង ជារូបព្រហ្មបុគ្គល តាមភូមិនៃឈានចិត្តនោះៗ ។

រូបាវចរកិរិយាចិត្ត ៥ ដួង

វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ
បឋមជ្ឈានកិរិយាចិត្ត មានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា
វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយាចិត្តំ
ទុតិយជ្ឈានកិរិយាចិត្ត មានអង្គ ៤ គឺ វិចារ បីតិ សុខ ឯកគ្គតា
បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ
តតិយជ្ឈានកិរិយាចិត្ត មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា

សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយាចិត្តំ

ចតុត្ថជ្ឈានកិរិយាចិត្ត មានអង្គ ២ គឺ សុខ ឯកគ្គតា

ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយាចិត្តំ

បញ្ចមជ្ឈានកិរិយាចិត្ត មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា

រូបាវចរកិរិយាចិត្ត គឺជាចិត្តរបស់ព្រះអរហន្តក្នុងខណៈដែលជាអប្បនាសមាធិ ។ រូបាវចរកិរិយាចិត្តមិនជាបច្ច័យឱ្យកើតរូបាវចរវិបាកចិត្តឡើយ ។

អរូបាវចរចិត្ត ១២ ដួង

អរូបាវចរឈានចិត្ត គឺបញ្ចមជ្ឈានចិត្តដែលមិនមានរូបកម្មដ្ឋាន ជាអារម្មណ៍ ព្រោះឃើញថាកាលនៅមានរូបជាអារម្មណ៍ គឺនៅជិតណាស់នឹងការដែលមានកាមជាអារម្មណ៍ កាលសម្រេចរូបបញ្ចមជ្ឈានហើយ ក៏បើករូបដែលជាអារម្មណ៍ ដោយបង្អោនរលឹកដល់ សភាពដែលមិនមានរូបនិមិត្ត និងមានអារម្មណ៍មិនមានទីបំផុត ។ អរូបាវចរចិត្ត ១២ ដួង គឺ អរូបាវចរកុសលចិត្ត ៤ ដួង អរូបាវចរវិបាកចិត្ត ៤ ដួង អរូបាវចរកិរិយាចិត្ត ៤ ដួង ។

អរូបាវចរកុសលចិត្ត ៤ ដួង

អាកាសានញ្ចាយតនកុសលចិត្តំ
វិញ្ញាណញ្ចាយតនកុសលចិត្តំ
អាកិញ្ចញ្ញាយតនកុសលចិត្តំ
នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ

អាកាសានញ្ចាយតនកុសលចិត្ត ជាអរូបបញ្ចមជ្ឈានចិត្ត ដែលរលឹកដល់អាកាសដែលទូលំទូលាយ ធំធេង មិនមានទីបំផុតជាអារម្មណ៍ ។

វិញ្ញាណញ្ចាយតនកុសលចិត្ត ជាអរូបបញ្ចមជ្ឈានចិត្ត ដែលមានវិញ្ញាណមិនមានទីបំផុត គឺអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ ។

អាកិញ្ចញ្ញាយតនកុសលចិត្ត ជាអរូបបញ្ចមជ្ឈាន ដែលមិនមានអ្វី ។ ជាអារម្មណ៍ឡើយ គឺមិនមានសូម្បីអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ ព្រោះដឹងថាការមិនមានអ្វីជាអារម្មណ៍ រមែងប្រណីតជាងមានអាកាសាន-ញ្ចាយតនចិត្តជាអារម្មណ៍ ។

នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ជាអរូបបញ្ចមជ្ឈានចិត្ត ដែលមានអាកិញ្ចញ្ញាយតនជាអារម្មណ៍ ព្រោះដឹងថា សូម្បីខណៈដែលមិនមានអ្វីជាអារម្មណ៍នោះក៏នៅមានអាកិញ្ចញ្ញាយតនចិត្តដែរ ។ ដូច្នោះ អរូបឈាន ថ្នាក់ខ្ពស់បំផុត គឺនេវសញ្ញានាសញ្ញាយតនចិត្ត ទើបមានអាកិញ្ចញ្ញាយតនចិត្ត ជាអារម្មណ៍ដែលជាសភាពដ៏ល្អិត ប្រណីតណាស់ ដោយខណៈនោះ នឹងថាមានសញ្ញាក៏មិនមែន ថាមិនមានសញ្ញាក៏មិនមែន ។

អរូបាវចរកុសលចិត្ត ៤ ដួងនេះ កាលដល់ព្រមដោយវសីមិនវិនាសបាត់បង់ទេ រមែងជាបច្ច័យឱ្យអរូបឈានកុសលដួងណាមួយ កើតមុនចុតិចិត្ត និងកាលចុតិចិត្តរលត់ហើយ អរូបឈានកុសលចិត្ត ដែលកើតមុនចុតិចិត្តនោះ ក៏ជាបច្ច័យឱ្យអរូបាវចរវិបាកចិត្តបដិសន្ធិកើតជាអរូបព្រហ្មបុគ្គល ក្នុងអរូបឈានភូមិ តាមជាន់ តាមថ្នាក់នៃអរូបឈានចិត្តនោះ ។

អរូបាវចរវិបាកចិត្ត ៤ ដួង

អាកាសានញ្ចាយតនវិបាកចិត្តំ
វិញ្ញាណញ្ចាយតនវិបាកចិត្តំ
អាកិញ្ចញ្ញាយតនវិបាកចិត្តំ
នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ

កាលអរូបាវចរវិបាកចិត្តដួងណាមួយ បដិសន្ធិកើតឡើង ជាអរូបព្រហ្មបុគ្គល ក្នុងអរូបព្រហ្មភូមិ តាមជាន់ តាមថ្នាក់ នៃអរូបឈានចិត្តនោះ ហើយក៏តម្រង់នូវភាពជាអរូបព្រហ្មបុគ្គលនោះ ។ រហូតទម្រាំនឹងចុតិពេលអស់អាយុនៃព្រហ្មភូមិនោះ ។ ។ រវាងដែលជាអរូបព្រហ្មបុគ្គលនោះ មិនមានរូបក្ខន្ធណា ។ កើតឡើយ មានតែនាមខន្ធ ៤ ប៉ុណ្ណោះ ទើបជាអរូបព្រហ្មបុគ្គល ។

អរូបាវចរកិរិយាចិត្ត ៤ ដួង

អាកាសានញ្ចាយតនកិរិយាចិត្តំ
វិញ្ញាណញ្ចាយតនកិរិយាចិត្តំ
អាកិញ្ចញ្ញាយតនកិរិយាចិត្តំ
នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តំ

អរូបាវចរកិរិយាចិត្ត ជាចិត្តរបស់ព្រះអរហន្ត ដែលបានអប់រំចម្រើនសមថភាវនា ហើយរហូតដល់បានអរូបឈាន ។ កាលបានបន្លុះនូវអរិយសច្ចធម៌ ជាព្រះអរហន្តហើយ អរូបាវចរឈានចិត្តដែលកើតឡើងទើបជាកិរិយាចិត្ត មិនមែនអរូបាវចរកុសលចិត្តតទៅទៀត ។

លោកុត្តរចិត្ត ៨ ដួង

លោកុត្តរចិត្ត គឺចិត្តដែលប្រចក្សច្បាស់នូវលក្ខណៈនៃព្រះនិព្វាន ដោយជាចិត្តដែលរំលត់កិលេស ជាលោកុត្តរចិត្ត ៤ ដួង មួយប្រភេទ និងដោយជាចិត្តដែលរំលត់កិលេសបានហើយ ជាលោកុត្តរវិបាកចិត្ត ៤ ដួង មួយប្រភេទ ។ លោកុត្តរចិត្ត ៨ ដួង គឺ

សោតាបត្តិមគ្គចិត្ត (**កុសល**) **១ ដួង**
សោតាបត្តិផលចិត្ត (**វិបាក**) **១ ដួង**
សកទាគាមិមគ្គចិត្ត (**កុសល**) **១ ដួង**
សកទាគាមិផលចិត្ត (**វិបាក**) **១ ដួង**
អនាគាមិមគ្គចិត្ត (**កុសល**) **១ ដួង**
អនាគាមិផលចិត្ត (**វិបាក**) **១ ដួង**
អរហត្តមគ្គចិត្ត (**កុសល**) **១ ដួង**
អរហត្តផលចិត្ត (**វិបាក**) **១ ដួង**

កាលកាមាវចរកុសលញាណសម្បយុត្តចិត្ត កើតរលឹក និងពិចារ-ណាដឹងនូវលក្ខណៈនៃនាមធម៌ និងរូបធម៌ រហូតដល់ប្រចក្សច្បាស់នូវ លក្ខណៈរបស់នាមធម៌ និងរូបធម៌ហើយនិងលះបង់ចោលនូវសេចក្តីប្រ-កាន់មាំយល់ខុសក្នុងសភាវធម៌ រហូតដល់សម្រេចនូវវិបស្សនាញាណ តាម លំដាប់ថ្នាក់ ហើយលោកុត្តរចិត្តក៏កើតឡើងប្រចក្សច្បាស់នូវលក្ខណៈនៃ ព្រះនិព្វាន និងរលត់កិលេសតាមលំដាប់ថ្នាក់គឺ

សោតាបត្តិមគ្គចិត្តជាលោកុត្តរកុសលចិត្ត កើតឡើងត្រឹមតែ មួយ ខណៈក្នុងសង្សារវដ្តធ្វើកិច្ចរំលត់កិលេស គឺមិច្ឆាទិដ្ឋិ វិចិកិច្ឆា និងអកុសល ធម៌ក្នុងឋានៈតែមួយដូចគ្នា ទើបមិនមានបច្ច័យឱ្យកើតក្នុងអបាយភូមិទៀត ឡើយ ។

កាលសោតាបត្តិមគ្គចិត្ត រលត់ហើយ សោតាបត្តិផលចិត្ត ដែលជា លោកុត្តរវិបាកចិត្ត ក៏កើតបន្តទាន់ពេលភ្លាម ដោយមិនមានចិត្តដទៃកើត ខណ្ឌឡើយ ។ សោតាបត្តិមគ្គចិត្ត ជាកុសលកម្មដែលឱ្យផលភ្លាម ។ ដោយ ជាបច្ច័យឱ្យកើតសោតាបត្តិផលចិត្ត ដែលជាលោកុត្តរវិបាកកើតឡើងមាន ព្រះនិព្វានជាអារម្មណ៍បន្តពីសោតាបត្តិមគ្គចិត្តភ្លាម ។ ប៉ុន្តែផ្សេងគ្នាដោយ សភាពត្រង់សោតាបត្តិមគ្គចិត្តកើតឡើងរំលត់កិលេស ពេលមានព្រះនិព្វា-នជាអារម្មណ៍ ឯសោតាបត្តិផលចិត្តកើតឡើងទទួលផល គឺមានព្រះនិព្វាន ជាអារម្មណ៍ ដោយជាចិត្តដែលរំលត់កិលេសរួចហើយ ។

សកទាគាមិមគ្គចិត្ត គឺដោយន័យតែមួយដូចគ្នា គឺកើតឡើងត្រឹមតែមួយខណៈក្នុងសង្សារវដ្ត ធ្វើកិច្ចរំលត់សេចក្តីត្រេកអរ ពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលយ៉ាងគ្រោតគ្រាត ។ កាលសកទាគាមិមគ្គចិត្តរលត់ហើយ **សកទាគាមិផលចិត្ត** ក៏កើតបន្តមានព្រះនិព្វានជាអារម្មណ៍ ដោយជាចិត្តដែលរំលត់កិលេសរួចហើយ ។

អនាគាមិមគ្គចិត្ត កើតឡើងត្រឹមតែមួយខណៈក្នុងសង្សារវដ្ត ធ្វើកិច្ចរំលត់សេចក្តីត្រេកអរ ពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ យ៉ាងល្អិត កាលអនាគាមិមគ្គចិត្តរលត់ហើយ **អនាគាមិផល** ក៏កើតបន្តមានព្រះនិព្វានជាអារម្មណ៍ ដោយជាចិត្តដែលរំលត់កិលេស រួចហើយ ។

អរហត្តមគ្គចិត្ត កើតឡើងតែមួយខណៈក្នុងសង្សារវដ្តធ្វើកិច្ចរំលត់កិលេសដែលនៅសល់ទាំងអស់ ។ កាលអរហត្តមគ្គចិត្តរលត់ទៅហើយ **អរហត្តផល** ក៏កើតបន្តមានព្រះនិព្វានជាអារម្មណ៍ ដោយជាចិត្តដែលរំលត់កិលេសរួចហើយ ។

លោកុត្តរចិត្ត ៤០ ដួង

ឈានលាភីបុគ្គល គឺអ្នកដែលចម្រើនសមថភាវនា រហូតដល់ស្ទាត់ជំនាញក្រៃលែងនោះ ខណៈណាដែលថ្នាក់ឈានចិត្តណាមួយកើត កាមាវចរញាណសម្បយុត្តចិត្ត ក៏កើតផ្លាស់ប្តូរ រលឹកដឹង នូវលក្ខណៈ

នៃនាមធម៌ និងរូបធម៌ខណៈនោះ ។ កាលណាបញ្ញាពិចារណា លក្ខណៈនៃនាមធម៌ និងរូបធម៌កើនឡើង ជាក់ច្បាស់ឡើង ក៏រមែងលះបង់នូវសេចក្តីប្រកាន់ ឃើញខុសថាជាតួខ្លួនចេញអស់បាន ។ កាលលោកុត្តរចិត្តថ្នាក់ណាកើតឡើងព្រមនឹងអង្គនៃឈានថ្នាក់ណា ។ ដោយមានឈានថ្នាក់នោះជាបាទក៏ជាមគ្គចិត្ត និងផលចិត្ត ដែលជាលោកុត្តរឈាន ថ្នាក់នោះ ។ ។ ដូច្នោះ ទើបជាលោកុត្តរចិត្ត ៤០ ដួង គឺ

សោតាបត្តិមគ្គ	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
សោតាបត្តិផល	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
សកទាគាមិមគ្គ	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
សកទាគាមិផល	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
អនាគាមិមគ្គ	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
អនាគាមិផល	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១		
អរហត្តមគ្គ	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១

	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១			
អរហត្តផល	បឋមជ្ឈាន	១	ទុតិយជ្ឈាន	១	តតិយជ្ឈាន	១	
	ចតុត្ថជ្ឈាន	១	បញ្ចមជ្ឈាន	១			

មគ្គចិត្តទាំង ៤ ដួងនោះ កើតឡើងបានត្រឹមតែមួយខណៈ ប៉ុណ្ណោះ ក្នុងសង្សារវដ្ត ប៉ុន្តែលោកុត្តរឈានវិបាក គឺផលចិត្តនោះរមែងតែងកើតឡើងបានទៀតពេលបុគ្គលនោះមានឈានចិត្តស្ទាត់ជំនាញ ជាបច្ច័យឱ្យលោកុត្តរឈានវិបាកចិត្តកើតឡើងក្នុងវារៈដទៃ ។ លោកុត្តរឈានចិត្តដែលកើតក្នុងវារៈក្រោយ ។ មិនមែនក្នុងមគ្គវិថីដែលរំលត់កិលេសនោះទេ គឺជាផលសមាបត្តិ ព្រោះជាលោកុត្តរឈានវិបាកចិត្ត (ផលចិត្ត) ដែលកើតរលត់បន្តគ្នា ដោយមិនមានចិត្តដទៃកើតជ្រែកខណ្ឌបានឡើយក្នុងរវាងដែលកំពុងនៅជាផលសមាបត្តិនោះ ។

ចេតសិក ៥២ ប្រភេទ

ចេតសិក ៥២ ប្រភេទ គឺ

អញ្ញសមានាចេតសិក	**១៣**	**ដួង**
អកុសលចេតសិក	**១៤**	**ដួង**
សោភណចេតសិក	**២៥**	**ដួង**

អញ្ញសមានាចេតសិក ១៣ ដួង

អញ្ញសមានាចេតសិក គឺចេតសិកដែលស្មើនឹងចេតសិកប្រភេទដទៃ ដែលអញ្ញសមានាចេតសិកកើតរួមជាមួយ គឺកាលណា អញ្ញសមានាចេតសិកកើតរួមនឹងអកុសលចេតសិក អញ្ញសមានាចេតសិក ក៏ជាអកុសលដែរ កាលណាអញ្ញសមានាចេតសិកកើតរួមជាមួយនឹងសោភ-ណចេតសិក អញ្ញសមានាចេតសិកក៏ជាសោភណៈដែរ ។ អញ្ញសមានាចេតសិកកើតរួមនឹងអកុសលចេតសិកក៏បាន កើតរួមនឹងសោភណចេត-សិកក៏បាន ប៉ុន្តែអកុសលចេតសិកកើតរួម នឹងសោភណចេតសិកមិនបានឡើយ ។

អញ្ញសមានាចេតសិក ១៣ ដួង មាន ២ ប្រភេទ គឺសព្វចិត្ត-សាធារណចេតសិក ៧ ដួង និងបកិណ្ណកចេតសិក ៦ ដួង ។

សព្វចិត្តសាធារណចេតសិក ៧ ដួង គឺចេតសិកដែលកើតជាមួយនឹងចិត្តគ្រប់ដួង ។ ចិត្តគ្រប់ប្រភេទ និងគ្រប់ខណៈដែលកើតឡើងនោះ មានចេតសិក ៧ ដួងនេះកើតរួមជាមួយ ។ ចំពោះទ្វិបញ្ចវិញ្ញាណ ១០ ដួង មានសព្វចិត្តសាធារណចេតសិក ៧ ដួងនេះ កើតរួមជាមួយតែប៉ុណ្ណោះ មិនមានចេតសិកដទៃ ។ កើតរួមជាមួយទៀតឡើយ ។ ដូច្នោះ **ទ្វិបញ្ច-វិញ្ញាណ ១០ ដួង ទើបមានចេតសិកកើតរួមជាមួយ តិចបំផុត គឺមានចេតសិកកើតរួមជាមួយត្រឹមតែ ៧ ដួង**នេះប៉ុណ្ណោះ ឯចិត្តដទៃ ។ ទៀតក្រៅពីនេះមានចេតសិកកើតរួមជាមួយលើសពី ៧ ដួង តាមប្រភេទនៃចិត្តនោះ ។ ។

សព្វចិត្តសាធារណចេតសិក ៧ ដួង

១ - ផស្សចេតសិក ជាចេតសិកដែលប៉ះខ្ទប់អារម្មណ៍ ។ ផស្សចេតសិកកើតឡើងប៉ះខ្ទប់អារម្មណ៍ណា ក៏ជាបច្ច័យឱ្យចិត្ត និងចេតសិកដទៃ ។ ដែលកើតរួមគ្នាក្នុងខណៈនោះ ធ្វើកិច្ចការងារតាមនាទីនៃចិត្ត និងចេតសិកនោះ ។ ក្នុងអារម្មណ៍ដែលផស្សចេតសិកប៉ះខ្ទប់ ។ ចិត្ត ផស្សចេតសិក និងចេតសិកដទៃ ។ កើតឡើងធ្វើកិច្ចការងាររៀង ។ ខ្លួន ព្រមគ្នាហើយក៏រលត់ទៅវិញយ៉ាងលឿនរហ័ស ។ ការប៉ះខ្ទប់អារម្មណ៍របស់ផស្សចេតសិក ទើបធ្វើឱ្យអារម្មណ៍ប្រាកដព្រមជាមួយនៃអាការ នៃ

ចេតសិកផ្សេង ។ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍នោះ ដូចជាពេញចិត្ត (លោភៈ) ឬមិនពេញចិត្ត (ទោសៈ) ក្នុងអារម្មណ៍នោះជាដើម ផស្សចេតសិក ទើបជាអាហារ នាំមកនូវផល គឺចិត្ត និងចេតសិកផ្សេង ។ កើតឡើងរួមគ្នា ធ្វើកិច្ចឱ្យប្រាកដនូវការប្រព្រឹត្តទៅនៃសភាវធម៌ក្នុងខណៈនោះ ។ ដូច្នោះ ផស្សចេតសិក ទើបជាអាហារប្បច្ច័យនៃចិត្ត និងចេតសិកដទៃ ។ ដែលកើតរួមគ្នា ។

២- **វេទនាចេតសិក** ជាចេតសិកដែលដឹងខ្លួន ។ ខណៈណាដែលចិត្តកើតឡើងដឹងអារម្មណ៍ណា វេទនាចេតសិកដែលកើតរួមនឹងចិត្តក្នុងខណៈនោះ ក៏ដឹងខ្លួនសប្បាយចិត្ត ឬលំបាកចិត្ត សុខ ឬទុក្ខ ឬព្រងើយ ។ ក្នុងអារម្មណ៍នោះ ។ វេទនាចេតសិកកើតនឹងចិត្តគ្រប់ដួង និងផ្សេងគ្នាទៅដោយប្រភេទនៃចិត្តនោះ ។ ដូចជា ទោមនស្សវេទនាកើតរួមនឹងទោសមូលចិត្ត ឧបេក្ខាវេទនាកើតរួមនឹងមោហមូលចិត្ត និងលោភមូលចិត្ត ជាដើម ។

៣- **សញ្ញាចេតសិក** ជាចេតសិកដែលចាំសំគាល់អារម្មណ៍ ។ សញ្ញាចេតសិក ចាំអារម្មណ៍គ្រប់យ៉ាងដែលប្រាកដ បន្តជារឿងរ៉ាវ សត្វ បុគ្គល ផ្សេង ។ ។ សញ្ញាចាំសេចក្តីដឹងខ្លួនជាសុខ ទុក្ខ សប្បាយចិត្ត លំបាកចិត្ត ព្រងើយ ។ ក្នុងអារម្មណ៍គ្រប់យ៉ាង ។ សញ្ញាចេតសិកជាបច្ច័យសំខាន់ដែលផ្តុងផ្តើម ពាក់ព័ន្ធ ការប្រកាន់មាំក្នុងជីវិត ដូចគ្នាជាមួយនឹងវេទនាចេតសិក ដែលកាលណាដឹងខ្លួនជាសុខស្រួល ឬ

សប្បាយចិត្ត ជាដើម ក៏រមែងសំគាល់ដោយការប្រកាន់មាំ និងពាក់ព័ន្ធ ត្រូវការសេចក្តីដឹងខ្លួននោះ ។ តទៅរឿយ ។ ។ ដោយហេតុនេះ វេទនាចេតសិក ទើបជាវេទនាខន្ធ ១ និងសញ្ញាចេតសិកទើបជាសញ្ញាខន្ធ ១ ចំណែកចេតសិក ៥០ ទៀតដែលសល់ពីនោះក៏តាក់តែងចិត្តទៅតាមសភាពនៃចេតសិកនោះ ។ ចេតសិក ៥០ ដួងនោះ ទើបជាសង្ខារក្ខន្ធ ។

៤- ចេតនាចេតសិក ជាចេតសិកដែលគិតចាត់ចែង តាំងចិត្តខ្ជល់ខ្ជាយ ធ្វើកិច្ចតាមប្រភេទនៃចេតនា និងសម្បយុត្តធម៌ដែលកើតរួមគ្នាក្នុងខណៈនោះ ។ ចេតនាចេតសិកជា **កម្មប្បច្ច័យ** ។ ចេតនាចេតសិកដែលកើតរួមនឹងវិបាកចិត្ត ជាសហជាតកម្មប្បច្ច័យ ព្រោះធ្វើកិច្ចនៃចេតនាដែលជាវិបាក ព្រមនឹងវិបាកចិត្ត និងវិបាកចេតសិកដទៃ ។ ដែលកើតរួមគ្នាហើយក៏រលត់ទៅ ។ ចេតនាចេតសិកដែលជាកិរិយាកើតឡើងធ្វើកិច្ចនៃចេតនារួមនឹងកិរិយាចិត្ត និងកិរិយាចេតសិកដទៃ ។ ហើយក៏រលត់ទៅ ក៏ជាសហជាតកម្មប្បច្ច័យ ប៉ុន្តែអកុសលចេតនាដែលកើតនឹងអកុសល-ចិត្ត និងកុសលចេតនាដែលកើតនឹងកុសលចិត្តនោះ កាលណាសម្រេចជាអកុសលកម្មបថយ៉ាងណាមួយ ឬកុសលកម្មបថយ៉ាងណាមួយហើយរលត់ទៅ ជានានាខណិកកម្មប្បច្ច័យ ព្រោះធ្វើឱ្យវិបាកចិត្ត និងចេតសិកកើតឡើងក្នុងកាលខាងមុខ ដែលមិនមែនក្នុងខណៈជាមួយនឹងអកុសលចេតនា ឬកុសលចេតនាដែលធ្វើកម្មនោះទេ ។ កាលណាឱ្យផលផ្សេងខណៈ គឺធ្វើឱ្យវិបាកចិត្ត និងចេតសិកកើតខាងក្រោយពីអកុសលចេតនា

ឬកុសលចេតនា ដែលជាហេតុរលត់ទៅហើយ ចេតនាកម្មដែលជាអកុសលចេតនា ឬកុសលចេតនានោះ ទើបជានានាខណិកកម្មប្បច្ច័យ ។

៥- ឯកគ្គតាចេតសិក ជាចេតសិកដែលតាំងមាំក្នុងអារម្មណ៍ មិនថាចិត្តកើតឡើងដឹងអារម្មណ៍ណា ឯកគ្គតាចេតសិកក៏តាំងមាំក្នុងអារម្មណ៍នោះ ប៉ុន្តែឯកគ្គតាចេតសិកដែលកើតនឹងអកុសលចិត្ត មិនមានកម្លាំងតាំងមាំគង់វង្សក្នុងអារម្មណ៍ ដូចឯកគ្គតាចេតសិក ដែលកើតនឹងកុសលចិត្តនោះទេ ។ ខណៈណាដែលចិត្តកើត រលត់ ដឹងអារម្មណ៍តែមួយបន្តគ្នាបានយូរ ៗ លក្ខណៈនៃឯកគ្គតាចេតសិកដែលតាំងមាំក្នុងអារម្មណ៍មួយខណៈ ៗ ចិត្តនោះ ក៏ប្រាកដជាសមាធិថ្នាក់ផ្សេង ៗ ។ ខណៈណា ដែលកុសលឯកគ្គតាតាំងមាំក្នុងអារម្មណ៍ ខណៈនោះទើបជាសម្មាសមាធិ តាមលំដាប់ថ្នាក់នៃកុសលនោះ ៗ ។

៦- ជីវិតិន្ទ្រិយចេតសិក ជាចេតសិកដែលតម្រង់រក្សាសម្បយុត្តធម៌ឱ្យតម្រង់ជីវិតតាំងនៅមុនដែលនឹងរលត់ទៅ ។ សូម្បីតែនាមធម៌ដែលកើតឡើងហើយនោះ នឹងតម្រង់តាំងនៅត្រឹមមួយជួរខណៈបាន ក៏នៅត្រូវអាស្រ័យបច្ច័យ គឺជីវិតិន្ទ្រិយចេតសិកដែលកើតរួមគ្នាក្នុងខណៈនោះ រក្សាទុកទើបតម្រង់តាំងនៅបានជីវិតិន្ទ្រិយចេតសិកក៏ជាបច្ច័យដល់ចិត្ត និងចេតសិកដែលកើតរួមគ្នា ដោយជាឥន្ទ្រិយប្បច្ច័យ គឺជាធំក្នុងការរក្សានូវសម្បយុត្តធម៌ ដែលកើតរួមជាមួយឱ្យតម្រង់តាំងនៅមួយជួរខណៈមុនដែលនឹងរលត់ទៅ ។

៧- មនសិការចេតសិក ជាចេតសិកដែលធ្វើទុកក្នុងចិត្ត យកចិត្តទុកដាក់ក្នុងអារម្មណ៍ ។ ការដាក់ចិត្តក្នុងអារម្មណ៍ រមែងជាបច្ច័យឱ្យចេតសិកដទៃ ។ ត្រិះរិះដល់អារម្មណ៍ និងតាក់តែងជាសេចក្តីវិចិត្រផ្សេង ។ ជាវិទ្យាការផ្សេង ។ មិនចេះចប់ក្នុងផ្លូវលោក ចំណែកក្នុងផ្លូវធម៌នោះ គឺផ្ទុយគ្នាអំពីផ្លូវលោក ។

កាលណាសព្វចិត្តសាធារណចេតសិក ៧ ដួងនេះ កើតជាមួយនឹងចិត្តប្រភេទណា ក៏ស្មើនឹងចិត្តប្រភេទនោះ គឺកាលណាកើតជាមួយនឹងកុសលចិត្ត ក៏ជាកុសល កាលណាកើតជាមួយនឹងអកុសលចិត្ត ក៏ជាអកុសល កាលណាកើតជាមួយនឹងវិបាកចិត្ត ក៏ជាវិបាក កាលណាកើតជាមួយនឹងកិរិយាចិត្ត ក៏ជាកិរិយា កាលណាកើតជាមួយនឹងកាមាវចរចិត្ត ក៏ជាកាមាវចរ កាលណាកើតជាមួយរូបាវចរចិត្ត ក៏ជារូបាវចរ កាលណាកើតជាមួយនឹងអរូបាវចរចិត្ត ក៏ជាអរូបាវចរៈ កាលណាកើតជាមួយនឹងលោកុត្តរចិត្ត ក៏ជាលោកុត្តរៈ ។

បកិណ្ណកចេតសិក ៦ ដួង គឺចេតសិកដែលកើតរួមជាមួយនឹងអកុសលចេតសិកក៏បាន សោភណចេតសិកក៏បាន តែវៀរមិនកើតនឹងចិត្តដួងខ្លះ តាមប្រភេទនៃចិត្តនោះ ។ ។

បកិណ្ណកចេតសិក ៦ ដួង

១- វិតក្កចេតសិក ជាចេតសិកដែលច្រត់ទល់ ឬត្រិះរិះក្នុងអារម្មណ៍ដែលផស្សចេតសិកប៉ះខ្ទប់ ។ វិតក្កចេតសិកកើតរួមនឹងចិត្ត ៥៥ ដួង គឺ

កាមាវចរចិត្ត ៤៤ ដួង និងបឋមជ្ឈានចិត្ត ១១ ដួង **វៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង និងទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន** ។ វិតក្កចេតសិករមែងទល់ ឬត្រិះរិះក្នុងអារម្មណ៍តាមសភាពនៃចិត្ត និងចេតសិកដែលកើតរួមជាមួយ ។ វិតក្កចេតសិកដែលទល់ ឬត្រិះរិះក្នុងអារម្មណ៍នោះ ដូចជាជើងនៃលោក ព្រោះធ្វើឱ្យលោកឈានទៅ (ដោយចិត្តកើតឡើងប្រព្រឹត្តទៅ) តាមវិតក្កចេតសិកនោះ ។ ។

២- វិចារចេតសិក ជាចេតសិកដែលផ្គងតាមវិតក្ក ។ មិនថាវិតក្កនឹងត្រិះរិះយ៉ាងណា វិចារចេតសិកក៏ផ្គងតាមយ៉ាងនោះ ។ វិចារចេតសិកកើតជាមួយនឹងចិត្ត ៦៦ ដួង គឺកាមាវចរចិត្ត ៤៤ ដួង បឋមជ្ឈានចិត្ត ១១ ដួង និងទុតិយជ្ឈាន ១១ ដួង **វៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន** ។ ចិត្តណាមានវិតក្កចេតសិកកើតរួមជាមួយ ចិត្តនោះត្រូវមានវិចារចេតសិកកើតរួមជាមួយផង វៀរចិត្ត ១១ ដួងដែលមានវិចារចេតសិក ដោយមិនមានវិតក្កចេតសិកកើតរួមជាមួយឡើយ គឺទុតិយជ្ឈានចិត្ត ១១ ដួង ។

៣- អធិមោក្ខចេតសិក ជាចេតសិកដែលចុះចិត្តស៊ប់ មិនសង្ស័យក្នុងអារម្មណ៍ ។ អធិមោក្ខចេតសិកកើតរួមជាមួយនឹងចិត្ត ៧៨ ដួង **វៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង និងមោហមូលចិត្ត វិចិកិច្ឆាសម្បយុត្ត ១ ដួង** ។ ដោយអធិមោក្ខចេតសិក ជាចេតសិកដែលចុះចិត្តស៊ប់ មិនសង្ស័យក្នុងអារម្មណ៍ ទើបមិនកើតជាមួយនឹងមោហមូលចិត្តវិចិកិច្ឆាសម្បយុត្ត ។

៤- វីរិយចេតសិក ជាចេតសិកដែលឧស្សាហៈ គាំទ្រជ្រោមជ្រែង សហជាតធម៌មិនឱ្យរាថយ ។ វីរិយចេតសិកកើតជាមួយនឹងចិត្ត ៧៣ ដួង វៀរ **អហេតុកចិត្ត ១៦ ដួង** គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង សម្បដិច្ឆន្នចិត្ត ២ ដួង សន្តីរណចិត្ត ៣ ដួង ព្រោះចិត្ត ១៦ ដួងនេះ ធ្វើកិច្ចរបស់ខ្លួន ៗ បានដោយមិនមានវីរិយចេតសិកជាបច្ច័យឡើយ ។

៥- បីតិចេតសិក ជាចេតសិកដែលរីករាយចិត្ត ឆ្អែតចិត្ត ចិត្តរីករាយទើបកើតរួមជាមួយ នឹងសោមនស្សវេទនាប៉ុណ្ណោះ មិនកើតរួមនឹងវេទនាដទៃ ៗ ឡើយ ។ បីតិចេតសិកកើតរួមនឹងចិត្តដែលមានសោមនស្សវេទនាកើតរួមជាមួយផង ៥១ ដួង គឺកាមសោមនស្សចិត្ត ១៨ ដួង បឋមជ្ឈានចិត្ត ១១ ដួង ទុតិយជ្ឈានចិត្ត ១១ ដួង តតិយជ្ឈានចិត្ត ១១ ដួង ។ **ចិត្តដែលមានសោមនស្សវេទនាកើតរួមជាមួយ តែមិនមានបីតិចេតសិកកើតរួមផងនោះ មាន ១១ ដួង គឺចតុត្ថជ្ឈានចិត្ត ១១ ដួង ទាំងនេះ ព្រោះចតុត្ថជ្ឈានចិត្តប្រណីតជាងតតិយជ្ឈានចិត្ត ដែលមានបីតិចេតសិកកើតរួមជាមួយ ។**

៦- ឆន្ទចេតសិក ជាចេតសិកដែលពេញចិត្តធ្វើ កើតរួមជាមួយនឹងចិត្ត ៦៩ ដួង **វៀរមិនកើតជាមួយនឹងចិត្ត ២០ ដួង គឺអហេតុកចិត្ត ១៨ ដួង និងមោហមូលចិត្ត ២ ដួង** ។ ទាំងនេះព្រោះអហេតុកចិត្ត ជាចិត្តដែលកើតឡើងដោយមិនមានហេតុចេតសិកកើតរួមជាមួយ ។ ឯចំណែកមោហមូលចិត្តនោះ សូម្បីថាមានមោហមូលចេតសិកកើតរួមជាមួយដែរ

ក៏ដោយ តែកាលណាមិនមានលោភចេតសិក ឬទោសចេតសិក កើតរួមផងទេ ទើបមិនមានឆន្ទចេតសិកកើតរួមផងដែរ ព្រោះឆន្ទចេតសិកជាសភាវធម៌ដែលពេញចិត្តតាមសភាពរបស់លោភមូលចិត្ត ឬទោសមូលចិត្ត ឬចិត្តដទៃ ។ ដែលឆន្ទចេតសិកកើតរួមជាមួយ ។

អកុសលចេតសិក ១៤ ដួង

អកុសលចេតសិក គឺចេតសិកដែលមិនល្អស្អាត កាលណាកើតជាមួយនឹងចិត្តណា ចិត្តនោះក៏ជាអកុសល ដូច្នោះ អកុសលចេតសិកទើបកើតបានតែជាមួយអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ កើតរួមជាមួយនឹងកុសលចិត្តមិនបាន កើតរួមនឹងវិបាកចិត្តមិនបាន កើតរួមនឹងកិរិយាចិត្តក៏មិនបាន ។ អកុសលចេតសិកក្នុងមួយដួង រមែងកើតរួមជាមួយនឹងអកុសលចិត្ត តាមប្រភេទរបស់អកុសលចិត្តនោះ ។ ប៉ុន្តែអកុសលចិត្តគ្រប់ដួង នឹងត្រូវមានអកុសលចេតសិក ៤ ដួង គឺមោហចេតសិក អហិរិកចេតសិក អនោត្តប្បចេតសិក ឧទ្ធច្ចចេតសិក កើតរួមជាមួយផង ដូច្នោះ អកុសលចេតសិក ៤ ដួងនេះ ទើបជា**អកុសលសាធារណចេតសិក** ក្រៅពីអកុសលសាធារណចេតសិក ៤ ដួងនេះហើយ អកុសលចេតសិកដទៃ ។ ក៏កើតរួមជាមួយនឹងអកុសលចិត្តតាមគួរដល់អកុសលចិត្តនោះ ។ ។

១- មោហចេតសិក ជាចេតសិកដែលមិនដឹងលក្ខណៈរបស់សភាវធម៌ តាមសេចក្តីពិត មោហចេតសិកកើតរួមជាមួយនឹងអកុសលចិត្ត ១២ ដួង ។

២- អហិរិកចេតសិក ជាចេតសិកដែលមិនខ្មាស់ខ្ពើមចំពោះអកុសលធម៌ កើតរួមជាមួយនឹងអកុសលចិត្ត ១២ ដួង ។

៣- អនោត្តប្បចេតសិក ជាចេតសិកដែលមិនស្លុតភ័យ ចំពោះអកុសលធម៌ កើតរួមជាមួយនឹងអកុសលចិត្ត ១២ ដួង ។

៤- ឧទ្ធច្ចចេតសិក ជាចេតសិកដែលមិនស្ងប់ក្នុងអារម្មណ៍ កើតរួមជាមួយនឹងអកុសលចិត្ត ១២ ដួង ។

៥- លោភចេតសិក ជាចេតសិកដែលជាប់ជំពាក់ ត្រូវការអារម្មណ៍ កើតរួមជាមួយនឹង លោភមូលចិត្ត ៨ ដួង ។

៦- ទិដ្ឋិចេតសិក ជាចេតសិកដែលឃើញខុសក្នុងសភាវធម៌ ទើបធ្វើឱ្យប្រកាន់មាំក្នុងគន្លងផ្លូវប្រព្រឹត្តបដិបត្តិដែលមិនត្រឹមត្រូវ តាមហេតុ និងផលរបស់សភាវធម៌ និងខ្វល់ខ្វាយ ក្នុងការប្រព្រឹត្តមង្គលភ្ញាក់ផ្អើល ផ្សេង ។ ។ ខណៈណាដែលឃើញខុស ខ្វល់ខ្វាយបដិបត្តិធម៌ ខុស ។ តាមផ្លូវ កាយ វាចា ចិត្ត ខណៈនោះទិដ្ឋិចេតសិកកើតរួមជាមួយនឹងលោភមូលចិត្ត ៤ ដួង (ទិដ្ឋិគតសម្បយុត្ត) ។ ទិដ្ឋិចេតសិកនឹងរលត់ជាសមុច្ឆេទ មិនកើតតទៅទៀតឡើយ កាលណាសោតាបត្តិមគ្គចិត្តកើតឡើង ដឹងច្បាស់នូវ

អរិយសច្ចធម៌ ។ អ្នកដែលជាព្រះសោតាបន្នបុគ្គលហើយ ទើបមិនមាន លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ៤ ដួងនេះទៀតឡើយ ។

៧- មានៈចេតសិក ជាចេតសិកដែលសម្គាល់ខ្លួន តម្កើងខ្លួន កើតបានជាមួយនឹងលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ៤ ដួង ។ លោភមូលចិត្ត ទិដ្ឋិគតវិប្បយុត្ត ៤ ដួងនោះ វារៈខ្លះក៏មានមានៈចេតសិកកើតរួមផងដែរ វារៈខ្លះក៏មិនមានមានៈចេតសិកកើតរួមផងដែរ មានៈចេតសិកនឹងរលត់ជាសមុច្ឆេទ មិនកើតបន្តទៀតឡើយ កាលណាដឹងច្បាស់នូវអរិយសច្ចធម៌ ជាព្រះអរហន្តបុគ្គល ។

៨- ទោសចេតសិក ជាចេតសិកដែលគ្រោតគ្រាតទទឹងទទែង ជាសភាវធម៌ដែលប្រទូសរ៉ាយ ក្តៅក្រហាយ អាក់អន់ មួរម៉ៅ កើតរួមជាមួយនឹងទោសមូលចិត្ត ២ ដួង ។ ទោសចេតសិករលត់ជាសមុច្ឆេទ កាលណាដឹងច្បាស់នូវអរិយសច្ចធម៌ថ្នាក់អនាគាមិបុគ្គល ។ ដូច្នោះ ព្រះសោតាបន្នបុគ្គល ទើបនៅមានសេចក្តីសោយសោក ខូចចិត្ត ព្រោះនៅមានទោសមូលចិត្តទាំង ២ ដួង ។

៩- ឥស្សាចេតសិក ជាចេតសិកដែលច្រណែន ឫស្សានឹងសម្បត្តិអ្នកដទៃ ទាំងរូបសម្បត្តិ ទ្រព្យសម្បត្តិ ទាំងគុណសម្បត្តិ ។ ឥស្សាចេតសិកកើតរួមជាមួយនឹងទោសមូលចិត្ត ។ ទោសមូលចិត្ត ២ ដួងនោះ វារៈខ្លះក៏មានឥស្សាចេតសិកកើតរួមជាមួយផង វារៈខ្លះក៏មិនមានឥស្សាចេតសិកកើតរួមជាមួយផង ។ ឥស្សាចេតសិករលត់ជាសមុច្ឆេទ កាលណា

សោតាបត្តិមគ្គចិត្តកើតឡើង ដឹងច្បាស់នូវអរិយសច្ចធម៌ ។ ដូច្នោះ ព្រះអរិយបុគ្គល ទើបមិនមានឥស្សាចេតសិកទៀតឡើយ ។

១០- មច្ឆរិយចេតសិក ជាចេតសិកដែលកំណាញ់នូវសម្បត្តិរបស់ខ្លួន មិនត្រូវការឱ្យបុគ្គលដទៃមានចំណែករួមប្រើប្រាស់ បានទទួលប្រយោជន៍ណា ។ ពីសម្បត្តិរបស់ខ្លួន ។ មច្ឆរិយចេតសិក កើតបានជាមួយនឹងទោសមូលចិត្ត ២ ដួង តែមិនកើតជាមួយនឹងលោភមូលចិត្តឡើយ ព្រោះខណៈណាដែលមច្ឆរិយចេតសិកកើត ខណៈនោះចិត្តក្តៅក្រហាយ មិនសប្បាយចិត្ត មច្ឆរិយចេតសិក ទើបកើតរួមជាមួយនឹងលោភមូលចិត្ត មិនបាន ព្រោះលោភមូលចិត្តកើតរួមជាមួយនឹងឧបេក្ខាវេទនា និងសោមនស្សវេទនាប៉ុណ្ណោះ តែមច្ឆរិយចេតសិកត្រូវកើតរួមជាមួយនឹងទោមនស្សវេទនាគ្រប់ពេល ។ ទោសមូលចិត្ត ២ ដួងនោះ វារៈខ្លះ ក៏មានមច្ឆរិយចេតសិកកើតរួមផង វារៈខ្លះក៏មិនមានមច្ឆរិយចេតសិកកើតរួមជាមួយផង ។ មច្ឆរិយចេតសិករលត់ជាសមុច្ឆេទ កាលណាសោតាបត្តិមគ្គចិត្តកើតឡើងដឹងច្បាស់នូវអរិយសច្ចធម៌ ។ អ្នកដែលជាព្រះអរិយបុគ្គលមិនមានមច្ឆរិយចេតសិកកើតទៀតឡើយ ប៉ុន្តែដែលព្រះសេក្ខបុគ្គល (អ្នកនៅត្រូវសិក្សា និងបដិបត្តិដើម្បីរំលត់កិលេស បានដល់ព្រះអរិយបុគ្គលដែលមិនមែនព្រះអរហន្ត) អ្នកជាគ្រហស្ថនៅមិនទាន់លះបង់នូវសម្បត្តិទាំងឡាយ ក៏ព្រោះនៅមានលោភចេតសិក ប៉ុន្តែកាលណាប្រព្រឹត្តទៅក្នុងផ្លូវដែលត្រឹមត្រូវដែលគួរហើយ ព្រះសេក្ខបុគ្គលអ្នកជាគ្រហស្ថដែល

ប្រាសចាកមច្ឆរិយៈហើយ រមែងលះបង់នូវវត្ថុនោះទៅជាទានបាន ព្រោះសោតាបត្តិមគ្គចិត្តរំលត់មច្ឆរិយៈជាសមុច្ឆេទ ។

១១- កុក្កុច្ចចេតសិក ជាចេតសិកដែលរោលរាល រំខានចិត្ត ក្នុងអកុសលដែលបានធ្វើហើយ និងក្នុងកុសលដែលមិនបានធ្វើ កុក្កុច្ចចេតសិក កើតបានជាមួយនឹងទោសមូលចិត្ត ២ ដួង វារៈខ្លះទោសមូលចិត្តក៏មានកុក្កុច្ចចេតសិកកើតរួមជាមួយផង វារៈខ្លះ ទោសមូលចិត្តក៏មិនមានកុក្កុច្ចចេតសិកកើតរួមជាមួយដែរ កុក្កុច្ចចេតសិករំលត់ជាសមុច្ឆេទ ដោយអនាគាមិមគ្គចិត្ត ។

១២- ថីនចេតសិក ជាចេតសិកដែលធ្វើឱ្យចិត្តរួញរា អស់កម្លាំង កើតបានជាមួយនឹងអកុសលសសង្ខារិកចិត្ត ៥ ដួង គឺលោភមូលចិត្ត សសង្ខារិក ៤ ដួង និងទោសមូលចិត្ត សសង្ខារិក ១ ដួង វារៈខ្លះអកុសលសសង្ខារិក ក៏មានថីនចេតសិកកើតរួមជាមួយផង វារៈខ្លះ អកុសលសសង្ខារិកក៏មិនមានថីនចេតសិកកើតរួមជាមួយដែរ ។

១៣- មិទ្ធចេតសិក ជាចេតសិកដែលធ្វើឱ្យចេតសិកដែលកើតរួមជាមួយ ងងុយងោកងក់ ខ្សោយកម្លាំង កើតបានជាមួយនឹងអកុសលសសង្ខារិក ៥ ដួង ដោយន័យដូចតែនឹងថីនចេតសិក ព្រោះថីនចេតសិកនិងមិទ្ធចេតសិក ត្រូវកើតរួមជាមួយគ្នាជានិច្ចគ្រប់ពេល បែកគ្នាមិនបានឡើយ ។ ថីនចេតសិក និងមិទ្ធចេតសិករលត់ជាសមុច្ឆេទដោយអរហត្តមគ្គចិត្ត ។

១៤- វិចិកិច្ឆាចេតសិក ជាចេតសិកដែលសង្ស័យក្នុងលក្ខណៈនៃនាមធម៌ និងរូបធម៌ សង្ស័យក្នុងអរិយសច្ចធម៌ សង្ស័យក្នុងព្រះរតនត្រ័យ កើតរួមជាមួយនឹងមោហមូលចិត្ត ១ ដួង (ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ) ។ វិចិកិច្ឆាចេតសិករលត់ជាសមុច្ឆេទដោយសោតាបត្តិមគ្គចិត្ត ។

ដើម្បីស្រួលដល់ការចាំ ទើបចំណែកអកុសលចេតសិក ១៤ ដួង ជាជំពូក ៗ ដូចនេះ

មោចតុក្ក: (ចេតសិក ៤ មានមោហៈចេតសិក ជាដើម) បានដល់ អកុសលសាធារណចេតសិក ៤ ដួង គឺមោហចេតសិក ១ អហិរិកចេតសិក ១ អនោត្តប្បចេតសិក ១ ឧទ្ធច្ចចេតសិក ១ ។

លោតិក: (ចេតសិក ៣ មានលោភចេតសិក ជាដើម) បានដល់ លោភចេតសិក ១ ទិដ្ឋិចេតសិក ១ មានៈចេតសិក ១ ។ ទិដ្ឋិចេតសិកកើតរួមជាមួយលោភចេតសិក មានៈចេតសិកកើតរួមជាមួយលោភចេតសិក ប៉ុន្តែទិដ្ឋិចេតសិក និងមានៈចេតសិកមិនកើតរួមជាមួយគ្នាទេ ខណៈណាដែលមានទិដ្ឋិចេតសិក (លោភមូលចិត្ត ទិដ្ឋិគតសម្បយុត្ត) ខណៈនោះមិនមានមានៈចេតសិកកើតរួមជាមួយផងទេ ។ ដូច្នោះ មានៈចេតសិកទើបកើតជាមួយនឹងលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ៤ ដួង ដោយមិនប្រាកដ គឺគ្រាខ្លះ ក៏ជាលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ដែលមិនមាន

មានៈចេតសិកកើតរួមជាមួយ ហើយគ្រាខ្លះ ក៏ជាលោភមូលចិត្តទិដ្ឋិគតវិ-ប្បយុត្ត ដែលមានមានៈចេតសិកកើតរួមជាមួយផងដែរ ។

ទោចតុក្កៈ (ចេតសិក ៤ មានទោសចេតសិក ជាដើម) បានដល់ ទោសចេតសិក ១ ឥស្សាចេតសិក ១ មច្ឆរិយចេតសិក ១ កុក្កុច្ចចេតសិក ១ ។ ឥស្សាចេតសិក មច្ឆរិយចេតសិក កុក្កុច្ចចេតសិក កើតរួមជាមួយ នឹងទោសចេតសិក ដោយមិនប្រាកដ និងមិនកើតព្រមគ្នា ដូច្នោះ ទោសមូលចិត្ត ២ ដួងនេះ វារៈខ្លះមិនមានឥស្សាចេតសិក មច្ឆរិយចេតសិក កុក្កុច្ចចេតសិក កើតរួមជាមួយឡើយ ហើយវារៈខ្លះក៏មានឥស្សាចេតសិក ឬ មច្ឆរិយចេតសិក ឬកុក្កុច្ចចេតសិក កើតរួមជាមួយ ១ ខណៈ ១ ដួង ។

ថីទុកៈ (ចេតសិក ២ មានថីនចេតសិក ជាដើម) បានដល់ ថីន ចេតសិក ១ និងមិទ្ធចេតសិក ១ ។ ចេតសិក ២ ដួង នេះមិនបែកគ្នាទេ មិនថានឹងកើតក្នុងខណៈណាឡើយ ត្រូវកើតរួមគ្នាជានិច្ចគ្រប់ពេល ។

រួមអកុសលចេតសិក ៤ ជំពូក ជាអកុសលចេតសិក ១៣ ដួង **និង វិចិកិច្ឆាចេតសិក ១ ដួង** ទើបរួមជាអកុសលចេតសិក ១៤ ដួង ។

សោភណចេតសិក ២៥ ដួង

សោភណចេតសិក ជាចេតសិកដែលល្អស្អាត កាលណាកើតរួមជាមួយចិត្តណា ចិត្តនោះក៏ជាចិត្តល្អស្អាត ជាសោភណចិត្ត ។ សោភណចេតសិកផ្សេងពីអកុសលចេតសិក ព្រោះអកុសលចេតសិកកើតរួមនឹងអកុសលចិត្ត ១២ ដួងប៉ុណ្ណោះ ប៉ុន្តែសោភណចេតសិកកើតរួមជាមួយនឹងកុសលចិត្តក៏បាន កើតរួមនឹងកុសលវិបាកចិត្តក៏បាន កើតរួមនឹងសោភណកិរិយាចិត្តក៏បាន ។ ដូច្នោះ សោភណចេតសិក ទើបកើតរួមជាមួយនឹងកាមាវចរកុសល (មហាកុសល) រូបាវចរកុសល អរូបាវចរកុសល លោកុត្តរកុសល កាមាវចរសហេតុកវិបាក (មហាវិបាក) រូបាវចរវិបាក អរូបាវចរវិបាក លោកុត្តរវិបាក កាមាវចរសហេតុកកិរិយា មហាកិរិយា រូបាវចរកិរិយា អរូបាវចរកិរិយា ។

សោភណចេតសិក កើតរួមជាមួយនឹងសោភណចិត្តតាមគួរដល់ប្រភេទនៃសោភណចេតសិក ដូចនេះ គឺ

សោភណសាធារណចេតសិក ១៩ ដួង កើតជាមួយនឹងសោភណចិត្តគ្រប់ដួង ។

វិរតិចេតសិក ៣ ដួង កើតជាមួយនឹងចិត្ត ១៦ ដួង គឺមហាកុសល ៨ ដួង និងលោកុត្តរចិត្ត ៨ (ឬ ៤០) ដួង ។

អប្បមញ្ញាចេតសិក ២ ដួង កើតជាមួយនឹងចិត្ត ២៨ ដួង គឺ មហាកុសលចិត្ត ៨ ដួង មហាកិរិយា ៨ ដួង និងរូបាវចរកុសល ៤ ដួង (រៀរ បញ្ចមជ្ឈាន) រូបាវចរវិបាក ៤ ដួង រូបាវចរកិរិយា ៤ ដួង ។

បញ្ញាចេតសិក ១ ដួង កើតជាមួយនឹងចិត្ត ៤៧ ដួង គឺ កាមាវចរញាណសម្បយុត្ត ១២ ដួង មហគ្គតចិត្ត ២៧ ដួង (រូបាវចរចិត្ត ១៥ + អរូបាវចរចិត្ត ១២) លោកុត្តរចិត្ត ៨ ដួង ។

សោភណសាធារណចេតសិក ១៩ ដួង

១- សទ្ធាចេតសិក ជាចេតសិកដែលបរិសុទ្ធ ជ្រះថ្លាស្អាត ប្រៀបដូចជាសារធាតុជូរ សាច់ជូរ ឬកែវមណី ដែលធ្វើឱ្យទឹកថ្លាស្អាត ប្រាសចាកកករល្អក់ ។ កាលណាសទ្ធាចេតសិកកើតឡើង អកុសលធម៌ ទាំងឡាយដែលប្រៀបដូចជាភក់ជ្រាំរមែងធ្លាក់ចុះទៅ គឺកើតមិនបាន ព្រោះខណៈនោះសទ្ធាជាសភាពដែលជ្រះថ្លាក្នុងកុសលធម៌ ។

២- សតិចេតសិក ជាចេតសិកដែលរលឹកបាន ក្នុងកុសល ទាំងឡាយ ។ ខណៈដែលអកុសលកើតឡើងក្នុងមួយថ្ងៃ ៗ នោះ ខណៈ នោះ សតិមិនបានកើតឡើងរលឹកប្រព្រឹត្តទៅក្នុងទាន សីល ឬភាវនា ខណៈណា ខណៈនោះសតិចេតសិកកើតឡើងរលឹក ជាកុសលប្រភេទ នោះ ៗ ។

៣- ហិរិចេតសិក ជាចេតសិកដែលខ្មាស់ខ្ពើមអកុសលធម៌ ។ ខណៈដែលកុសលចិត្តកើតឡើង ខណៈនោះខ្មាស់អកុសលធម៌ ។ លក្ខណៈនៃហិរិចេតសិក ទើបប្រៀបបាននឹងការរង្កៀសខ្ពើម មិនចាប់កាន់នូវរបស់មិនស្អាត ។

៤- ឱត្តប្បចេតសិក ជាចេតសិកដែលស្លុត ភ័យខ្លាចនូវទោសរបស់អកុសលធម៌ទាំងឡាយ ។ ខណៈណាដែលអកុសលធម៌ប្រភេទណាកើតឡើង ទោះជាស្រាលយ៉ាងណាក្តី ក៏ខណៈនោះមិនមានសេចក្តីស្លុតភ័យខ្លាចក្នុងទោសនៃអកុសលធម៌នោះផងដែរ ។ លក្ខណៈនៃឱត្តប្ប-ចេតសិក ទើបប្រៀបបាននឹងការមិនចាប់កាន់នូវដុំដែកក្តៅ ។

៥- អលោភចេតសិក ជាចេតសិក ដែលមិនជាប់ជំពាក់ក្នុងអារម្មណ៍ បើខណៈណាមានសេចក្តីត្រេកអរ ជាប់ជំពាក់ក្នុងអារម្មណ៍ ខណៈនោះទាន សីល ភាវនា ក៏កើតមិនបាន ដូច្នោះ កុសលចិត្តគ្រប់ប្រភេទ ទើបកើតឡើងដោយមានអលោភចេតសិកជាហេតុ លក្ខណៈ អាការរបស់អលោភចេតសិកនោះ ដូចជាដំណក់ទឹកមិនជាប់ដក់នៅលើត្របកផ្កាឈូក ។

៦- អទោសចេតសិក ជាចេតសិកដែលមិនមួរម៉ៅ មិនគ្រោតគ្រាត កាចសាហាវ មានលក្ខណៈអាការជាមិត្ត មេត្រីភាព (និងព្រោះផ្សាយប្រយោជន៍ អនុគ្រោះដល់សត្វទាំងឡាយ ទើបឈ្មោះថា មេត្តា)

៧- តត្រមជ្ឈត្តតាចេតសិក ជាចេតសិកដែលជាកណ្តាល មិនលំអៀង ប្រាសចាកអគតិ ទើបជាអាការព្រងើយ ឧបេក្ខាក្នុងអារម្មណ៍ ។

ឧបេក្ខា ការព្រងើយមាន ១០ យ៉ាង គឺ

ឆឡង្គុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកជាសភាពដែលព្រងើយក្នុងអារម្មណ៍ ៦ របស់ព្រះអរហន្ត ដែលរំលត់កិលេសអស់គ្មានសេសសល់ឡើយ ។

ព្រហ្មវិហារុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកដែលព្រងើយជាកណ្តាលក្នុងសត្វទាំងឡាយ ។

ពោជ្ឈង្គុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកដែលជាអង្គ គឺចំណែកប្រកបដែលធ្វើឱ្យត្រាស់ដឹងនូវអរិយសច្ចធម៌ ។

វីរិយុបេក្ខា បានដល់ វីរិយចេតសិកដែលជាសេចក្តីព្យាយាមត្រូវដែលមិនតឹងពេក មិនធូរពេក ក្នុងការចម្រើនភាវនា ។

សង្ខារុបេក្ខា បានដល់ បញ្ញាចេតសិកដែលព្រងើយ កាលណាប្រចក្សត្រៃលក្ខណ៍របស់សង្ខារធម៌ ។

វេទនុបេក្ខា បានដល់ វេទនាចេតសិកដែលដឹងខ្លួន មិនជាសុខ មិនជាទុក្ខ ។

វិបស្សនុបេក្ខា បានដល់ បញ្ញាចេតសិកដែលជាកណ្តាល ក្នុងការពិចារណា អារម្មណ៍ដែលកើតតាមហេតុបច្ច័យ ។

តត្រមជ្ឈត្តុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកដែលជាកណ្តាល មិនលំអៀងដោយអគតិ ។

ឈានុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកក្នុងឈានដែលលះបង់នូវសេចក្តីប្រាថ្នា ក្នុងធម៌ដទៃដែលធ្វើមិនឱ្យស្ងប់ តាំងនៅមាំ ដោយចំពោះ បានដល់តតិយជ្ឈាន (ដោយចតុត្ថន័យ) ដែលលះបង់បីតិហើយ ។

ចារិសុទ្ធុបេក្ខា បានដល់ តត្រមជ្ឈត្តតាចេតសិកក្នុងចតុត្ថជ្ឈាន (ដោយចតុត្ថន័យ) ដែលស្ងប់ហ្មត់ចត់ ហើយប្រាសចាកសត្រូវទាំងពួង មិនត្រូវធ្វើកិច្ចលះអង្គឈានណាទៀត ។

៨- កាយបស្សទ្ធិចេតសិក ជាចេតសិកដែលស្ងប់ មិនរាយមាយ ធ្វើឱ្យចេតសិកដែលកើតជាមួយស្ងប់មិនរាយមាយ ។

៩- ចិត្តបស្សទ្ធិចេតសិក ជាចេតសិក ដែលធ្វើឱ្យចិត្តកើតរួមជាមួយស្ងប់ ខណៈដែលពេញចិត្តនៅម្នាក់ឯងដោយស្ងៀមស្ងាត់ មិនខ្វល់ខ្វាយនោះ មិនមែនស្ងប់ បើចិត្តខណៈនោះមិនប្រព្រឹត្តទៅក្នុងទាន សីល ភាវនា (សមថភាវនា គឺការចម្រើនអប់រំសេចក្តីស្ងប់ ចេញចាកអកុសល ដោយបញ្ញា វិបស្សនាភាវនា គឺការអប់រំចម្រើនបញ្ញា ដឹងលក្ខណៈរបស់សភាវធម៌ដែលប្រាកដតាមសេចក្តីពិត) បើពេញចិត្តពេលដែលនៅម្នាក់

ឯង ដោយស្ងៀមស្ងាត់ សូម្បីក្នុងព្រៃ ក៏ជាលោភមូលចិត្ត ក្នុងខណៈដែលមិនមែនជាទាន សីល ភាវនា ។

(កាយបស្សទ្ធិ និងចិត្តបស្សទ្ធិជាសភាពចេតសិក ដែលផ្ទុយនឹងឧទ្ធច្ចចេតសិក)

១០- កាយលហុតា ជាចេតសិកដែលស្រាល ធ្វើឱ្យចេតសិកទាំងឡាយដែលកើតរួមជាមួយស្រាល មិនធ្ងន់ដូចអកុសល ។

១១- ចិត្តលហុតា ជាចេតសិកដែលធ្វើឱ្យចិត្តដែលកើតរួមជាមួយមិនធ្ងន់ ។

(កាយលហុតា និងចិត្តលហុតា ជាចេតសិកដែលផ្ទុយនឹងថីនចេតសិក និងមិទ្ធចេតសិក)

១២- កាយមុទុតា ជាចេតសិកដែលទន់ភ្លន់ ធ្វើឱ្យចេតសិកទាំងឡាយកើតរួមជាមួយមិនគ្រោតគ្រាត រឹងត្អឹង ។

១៣- ចិត្តមុទុតា ជាចេតសិកដែលធ្វើឱ្យចិត្តកើតរួមជាមួយទន់ភ្លន់ មិនគ្រោតគ្រាត រឹងត្អឹង ។

(កាយមុទុតា និងចិត្តមុទុតា ជាចេតសិកដែលផ្ទុយនឹងទិដ្ឋិចេតសិក និងមានៈចេតសិក)

១៤- កាយកម្មញ្ញតា ជាចេតសិកដែលគួរដល់ការងារ របស់សោភណធម៌ ធ្វើឱ្យចេតសិកទាំងឡាយដែលកើតរួមជាមួយគួរដល់ការងាររបស់សោភណធម៌ ។

១៥- ចិត្តកម្មញ្ញតា ជាចេតសិកដែលធ្វើឱ្យចិត្តកើតរួមជាមួយ គួរដល់ការងារ របស់សោភណធម៌ ។

(កាយកម្មញ្ញតា និងចិត្តកម្មញ្ញតា ជាចេតសិកដែលផ្ទុយនឹង អកុសលធម៌ ដែលសល់ធ្វើឱ្យចិត្តមិនគួរដល់ធម៌ល្អស្អាត)

១៦- កាយបាគុញ្ញតា ជាចេតសិកដែលស្ងាត់ជំនាញ និងធ្វើឱ្យ ចេតសិកទាំងឡាយ ដែលកើតរួមជាមួយ ស្ងាត់ជំនាញក្នុងធម៌ ដែល ល្អស្អាត ។

១៧- ចិត្តបាគុញ្ញតា ជាចេតសិកដែលធ្វើឱ្យចិត្តដែលកើតរួមជា មួយស្ងាត់ជំនាញក្នុងធម៌ដែលល្អស្អាត ។

(កាយបាគុញ្ញតា និងចិត្តបាគុញ្ញតាជាចេតសិកដែលផ្ទុយនឹងការ មិនជឿជាដើម ក្នុងធម៌ដែលល្អស្អាត) ។

១៨- កាយុជុកតា ជាចេតសិកដែលត្រង់ ធ្វើឱ្យចេតសិកកើត រួមជាមួយមិនវៀចវេរ មិនឆបោក ប្រាថ្នាត្រង់ចំពោះធម៌ដែលល្អស្អាត ។

១៩- ចិត្តុជុកតា ជាចេតសិកដែលធ្វើឱ្យចិត្តត្រង់ចំពោះធម៌ ដែលល្អស្អាត ។

(កាយុជុកតា និងចិត្តុជុកតាជាចេតសិកដែលផ្ទុយជាមួយនឹងឧប-ក្កិលេស មានមាយា សាឋេយ្យ ជាដើម ដែលធ្វើឱ្យចិត្តវៀចវេរ ឆបោក មិនត្រង់) ។

ចេតសិក ១៩ ដួងនេះ កើតរួមនឹងសោភណចិត្តគ្រប់ដួង **វៀរមិនកើតនឹងអកុសលចិត្ត ១២ ដួង និងអហេតុកចិត្ត ១៨ ដួង រួមជា ៣០ ដួង** ដូច្នោះ សោភណចិត្តទើបជាទ្វិហេតុកៈ ឬតិហេតុកៈ ប៉ុន្តែដែលជាឯកហេតុកៈមិនមានឡើយ ចំណែកអកុសលចិត្ត ១២ ដួងនោះ ជាឯកហេតុកៈ ២ ដួង ជាទ្វិហេតុកៈ ១០ ដួង ជាតិហេតុកៈមិនមានឡើយ ។

វិរតិចេតសិក ៣ ដួង

វិរតិចេតសិក ជាចេតសិកដែលកើតឡើងធ្វើកិច្ច វៀរចាកនូវទុច្ចរិត មាន ៣ ដួង គឺ

១-(២០) សម្មាវាចាចេតសិក ជាចេតសិកដែលកើតឡើងធ្វើកិច្ចវៀរចាកនូវវចីទុច្ចរិត ៤ គឺមុសាវាទ បិសុណាវាចា ផរុសវាទ សម្ផប្បលាបវាចា ខណៈណាដែលមិនល្មើសកន្លងវចីទុច្ចរិត ខណៈនោះសម្មាវាចាចេតសិកកើតឡើងវៀរចាកនូវទុច្ចរិតប្រភេទនោះ ៗ ។

២-(២១) សម្មាកម្មន្តចេតសិក ជាចេតសិកដែលកើតឡើងវៀរចាកនូវកាយទុច្ចរិត ៣ គឺបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ ខណៈណាដែលវៀរចាកកាយទុច្ចរិត ៣ ខណៈនោះសម្មាកម្មន្តចេតសិកកើតឡើង ធ្វើកិច្ចវិរតិកាយទុច្ចរិតនោះ ៗ ។

៣-(២២) សម្មាអាជីវចេតសិក ជាចេតសិកដែលកើតឡើងវៀរចាកនូវកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ដែលជាមិច្ឆាជីព ។ ខណៈណា

ដែលលះវៀរនូវមិច្ឆាជីព ខណៈនោះសម្មាអាជីវចេតសិកកើតឡើងធ្វើកិច្ច វិរតិមិច្ឆាជីពនោះ ៗ ។

អប្បមញ្ញាចេតសិក ២ ដួង

ជាចេតសិកដែលមានសត្វ បុគ្គល ជាអារម្មណ៍ មិនកើតជាមួយនឹង មហាវិបាកចិត្ត រូបាវចរបញ្ចមជ្ឈាន អរូបាវចរចិត្ត លោកុត្តរចិត្ត ។ អប្បមញ្ញា ចេតសិក ២ ដួង គឺ

១- (**២៣**) **ករុណាចេតសិក** ជាចេតសិកដែលករុណា (អាណិត) សត្វដែលកើតទុក្ខ មានការមិនបៀតបៀនជាអាការប្រាកដ ។

២- (**២៤**) **មុទិតាចេតសិក** ជាចេតសិកដែលត្រេកអរចំពោះ សត្វដែលជាសុខ ជាចេតសិកដែលផ្គុំយនឹងឥស្សា ។

បញ្ញាចេតសិក ១ ដួង

២៥ - **បញ្ញាចេតសិក** ជាចេតសិកដែលឃើញត្រូវ យល់ត្រូវក្នុង សភាវធម៌ និងក្នុងហេតុផលរបស់សភាវធម៌នោះៗ ។

សោភណចេតសិក ២៥ ដួង កើតជាមួយនឹងសោភណចិត្តទាំង នេះ

សោភណសាធារណចេតសិក ១៩ ដួង កើតជាមួយនឹងសោភណចិត្តគ្រប់ដួង ទាំងកុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ទាំងកាមាវចរចិត្ត រូបាវចរចិត្ត អរូបាវចរចិត្ត និងលោកុត្តរចិត្ត ។

វិរតិចេតសិក ៣ ដួង កើតបានជាមួយនឹងមហាកុសល ៨ ដួង និងលោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួងប៉ុណ្ណោះ មហាកុសលចិត្តដួងខ្លះក៏មិនមាន វិរតិចេតសិកកើតរួមជាមួយដែរ វិរតិចេតសិកដួងណាមួយនឹងកើតជាមួយមហាកុសលចិត្ត ដែលកំពុងតែវៀរចាកទុច្ចរិតប្រភេទណាមួយ ក្នុងខណៈនោះប៉ុណ្ណោះ **វិរតិចេតសិកទាំង ៣ ដួង នឹងកើតឡើងព្រមគ្នាក្នុងមហាកុសលចិត្តមិនបានឡើយ តែខណៈដែលលោកុត្តរចិត្តកើតឡើងនោះ វិរតិចេតសិកទាំង ៣ ដួង កើតឡើងព្រមគ្នា** ដោយធ្វើកិច្ចវៀរចាកនូវទុច្ចរិតជាសមុច្ឆេទតាមថ្នាក់របស់លោកុត្តរចិត្តនោះ ។ លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង ត្រូវមានវិរតិចេតសិកទាំង ៣ ដួង កើតរួមជាមួយដែរ ។

វិរតិចេតសិកមិនកើតជាមួយនឹងមហាកិរិយាចិត្ត ព្រោះកាលណាព្រះអរហន្តរំលត់កិលេសគ្រប់ប្រភេទជាសមុច្ឆេទហើយ វិរតិចេតសិកមិនកើតឡើងវៀរចាកនូវទុច្ចរិតណា ៗ ឡើយ ។

វិរតិចេតសិកមិនកើតជាមួយនឹងមហាវិបាកចិត្ត ព្រោះមហាវិបាកផ្សេងគ្នាពីរូបាវចរវិបាក អរូបាវចរវិបាក លោកុត្តរវិបាក គឺរូបាវចរកុសលជាកម្មប្បច្ច័យឱ្យកើតផលជារូបាវចរវិបាក ដែលមិនផ្សេងពីរូបាវចរកុសលនោះ ។ ឧបមាដូចតួខ្លួន និងស្រមោល រូបាវចរកុសលមានចេតសិកអ្វីកើតរួម

ជាមួយប៉ុណ្ណា រូបាវចរវិបាកក៏មានចេតសិកនោះ ។ កើតរួមជាមួយប៉ុណ្ណោះ រូបាវចរកុសលមានអារម្មណ៍អ្វី រូបាវចរវិបាកក៏មានអារម្មណ៍នោះ អរូបាវច-រកុសល និងអរូបាវចរវិបាក លោកុត្តរកុសល និងលោកុត្តរវិបាកក៏មានន័យតែមួយដូចគ្នា ។

ប៉ុន្តែ មហាកុសលមិនមែនជាយ៉ាងនេះឡើយ វិរតិចេតសិក កើតជាមួយនឹងមហាកុសលចិត្តចំពោះក្នុងខណៈដែលវៀរចាកនូវទុច្ចរិត តែមហាវិបាកដែលជាផលរបស់មហាកុសលនោះ មិនមានវិរតិចេតសិក និងអប្បមញ្ញាចេតសិក កើតរួមជាមួយ ព្រោះមហាវិបាកមិនបានធ្វើកិច្ចវៀរទុច្ចរិត ដូចជាមហាកុសល ។

វិរតិចេតសិកមិនកើតជាមួយនឹងរូបាវចរចិត្ត និងអរូបាវចរចិត្ត ព្រោះខណៈដែលជាមហគ្គតចិត្តនោះ មិនមានការប្រព្រឹត្តណា ។ តាមផ្លូវកាយ វាចា ដែលវិរតិចេតសិកនឹងត្រូវកើតឡើង វៀរចាកនូវទុច្ចរិតតាមផ្លូវកាយ ឬតាមផ្លូវវាចាឡើយ ។

អប្បមញ្ញាចេតសិក ២ ដួង មិនកើតព្រមគ្នា អប្បមញ្ញាដួងណាមួយរមែងកើតក្នុងខណៈដែលចិត្តមានសត្វ បុគ្គល (ដែលជាទុក្ខ ឬជាសុខ) ជាអារម្មណ៍ប៉ុណ្ណោះ ។ អប្បមញ្ញាចេតសិកមិនកើតជាមួយនិងមហាវិបាកចិត្តដោយន័យដូចជាមួយនឹងវិរតិចេតសិកដែរ ។ ប៉ុន្តែអប្បមញ្ញាចេតសិកដួងណាមួយកើតជាមួយនឹងមហាកុសលចិត្ត និងមហាកិរិយាចិត្តបាន

ពេលមានសត្វដែលមានទុក្ខ ឬមានសុខជាអារម្មណ៍ និងក្នុងការចម្រើនព្រហ្មវិហារភាវនា គឺមេត្តាភាវនាបានដល់អទោសចេតសិក ករុណាភាវនាបានដល់ករុណាចេតសិក មុទិតាភាវនាបានដល់មុទិតាចេតសិក ឧបេក្ខាភាវនាបានដល់តត្រមជ្ឈត្តតាចេតសិក ពេលអប់រំចម្រើនសមថភាវនាដែលជាព្រហ្មវិហារនោះ មហាកុសលដែលប្រកបដោយមេត្តា ឬករុណា ឬមុទិតារមែងចម្រើនថែមឡើង រហូតដល់ជាសេចក្តីស្ងប់មានកម្លាំងមាំទាំជាឧបចារសមាធិ (សមាធិជិតដល់ការតាំងស៊ប់ក្នុងអារម្មណ៍) និងអប្បនាសមាធិ (តាំងស៊ប់ក្នុងអារម្មណ៍) ដែលជាឈានចិត្តថ្នាក់ទី ១ និងនៅពេលអប់រំចម្រើនតទៅ ក៏បន្លុះបានដល់ឈានចិត្តថ្នាក់ទី ២ ថ្នាក់ទី ៣ និងថ្នាក់ទី ៤ តាមលំដាប់ ប៉ុន្តែមេត្តា ករុណា មុទិតា មិនអាចបន្លុះដល់ថ្នាក់បញ្ចមជ្ឈាន ដែលជារូបឈានទី ៥ បាន ព្រោះឈានចិត្តថ្នាក់ទី ១ - ២ - ៣ - ៤ កើតរួមជាមួយនឹងសោមនស្សវេទនា ដូច្នោះ កាលនឹងអប់រំព្រហ្មវិហារភាវនាឱ្យដល់បញ្ចមជ្ឈាន ត្រូវជាឧបេក្ខាព្រហ្មវិហារប៉ុណ្ណោះ ដូចនេះ មេត្តា ករុណា មុទិតា ទើបអាចបានត្រឹមបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ចំណែកឧបេក្ខាព្រហ្មវិហារនោះ ជាបញ្ចមជ្ឈានប៉ុណ្ណោះ ។

អប្បមញ្ញាចេតសិក ២ ដួង មិនកើតជាមួយនឹងអរូបាវចរចិត្ត ព្រោះអរូបាវចរចិត្តមិនមានសត្វ បុគ្គលជាអារម្មណ៍ ។

អប្បមញ្ញាចេតសិក ២ ដួង មិនកើតជាមួយនឹងលោកុត្តរចិត្ត ព្រោះលោកុត្តរចិត្តមាននិព្វានជាអារម្មណ៍។

បញ្ញាចេតសិក ១ ដួង កើតរួមជាមួយនឹងកាមាវចរចិត្តដែលជាញាណសម្បយុត្តទាំងអស់ និងកើតរួមជាមួយនឹងរូបាវចរចិត្ត អរូបាវចរចិត្ត និងលោកុត្តរចិត្តដែរ ព្រោះចិត្តទាំងនេះត្រូវប្រកបជាមួយបញ្ញាចេតសិកទាំងអស់ ។

នឹងឃើញបានថា ដោយទូទៅកាមាវចរកុសលចិត្តកើតរួមជាមួយនឹងសោភណសាធារណចេតសិកប៉ុណ្ណោះ ប៉ុន្តែកាលខ្លះក៏មានវិរតិចេតសិក ១ ដួង កើតរួមជាមួយផងពេលវិរតិទុច្ចរិត និងកាលខ្លះក៏មានអប្បមញ្ញាចេតសិក ១ ដួង កើតរួមជាមួយដែរ និងការខ្លះក៏កើតរួមជាមួយនឹងបញ្ញាចេតសិក ខណៈអប់រំចម្រើនសមថភាវនា និងវិបស្សនាភាវនានោះ ជាមហាកុសលចិត្តដែលមានបញ្ញាចេតសិកកើតរួមជាមួយផង ទើបជាមហាកុសលញាណសម្បយុត្ត ។

រូប ២៨ ប្រភេទ

រូបជាបរមត្ថធម៌ដែលមិនមែនសភាពដឹង ។ រូបជាសង្ខតធម៌ ជាសភាវធម៌ដែលកើតរលត់ ទើបត្រូវមានបច្ច័យតាក់តែងឱ្យរូបកើតឡើង ។ ឧបាទាយរូបអាស្រ័យមហាភូតរូប ទើបកើតឡើងប្រព្រឹត្តទៅបាន ប៉ុន្តែដែលឧបាទាយរូប និងមហាភូតរូបនឹងកើតឡើងបាននោះ ក៏ត្រូវមានសមុដ្ឋាន គឺធម៌ដែលបង្កឱ្យរូបទាំងអស់នោះកើតឡើង មិនដូច្នោះទេ រូបទាំងអស់ក៏កើតឡើងប្រព្រឹត្តទៅមិនបានឡើយ ។ **សមុដ្ឋាន គឺធម៌ដែលបង្កឱ្យរូបកើតមាន ៤ សមុដ្ឋាន គឺកម្ម ១ ចិត្ត ១ ឧតុ ១ អាហារ ១** ។

រូបដែលកើតពីកម្មជាសមុដ្ឋាន ហៅថា **កម្មជរូប**
រូបដែលកើតពីចិត្តជាសមុដ្ឋាន ហៅថា **ចិត្តជរូប**
រូបដែលកើតពីឧតុជាសមុដ្ឋាន ហៅថា **ឧតុជរូប**
រូបដែលកើតពីអាហារជាសមុដ្ឋាន ហៅថា **អាហារជរូប**

កម្មជរូប

រូបដែលកើតចំពោះតែកម្មជាសមុដ្ឋាន មិនកើតពីសមុដ្ឋានដទៃ នោះមាន ៩ រូបគឺ

១ - ចក្ខុបសាទរូប

២ - សោតបសាទរូប

៣ - ឃានបសាទរូប

៤ - ជិវ្ហាបសាទរូប

៥ - កាយបសាទរូប

៦ - ឥត្ថីភាវរូប

៧ - បុរិសភាវរូប

៨ - ហទយរូប

៩ - ជីវិតិន្ទ្រិយរូប

វត្ថុណាក៏ដោយ ដែលមើលទៅហាក់ដូចជាមានជីវិត តែមិនបានកើតពីអកុសលកម្ម ឬកុសលកម្មណា ។ ជាសមុដ្ឋានទេ ដូចជាគ្រាប់ពូជផ្សេង ។ មិនមានកម្មជរូបទាំង ៩ នេះឡើយ ។

បុគ្គលខ្លះ កម្មមិនជាសមុដ្ឋានឱ្យកើតចក្ខុបសាទរូបខ្លះ សោត-បសាទរូបខ្លះ ឃានបសាទរូបខ្លះ ជិវ្ហាបសាទរូបខ្លះ កាយបសាទរូបខ្លះ ឥត្ថីភាវរូបខ្លះ បុរិសភាវរូបខ្លះ ប៉ុន្តែការដែលជាសត្វ បុគ្គល ក្នុងភូមិដែលមានខន្ធ ៥ ហើយ ត្រូវមានហទយរូប ដែលជាទីកើតនៃចិត្ត និងមាន **ជីវិតិន្ទ្រិយរូបដែលរួមនឹងកម្មជរូបដទៃ ។ ក្នុងគ្រប់ ។ កម្មជកលាប ។** ចំពោះអសញ្ញសត្តាព្រហ្មបុគ្គល ដែលជាព្រហ្មបុគ្គលមានតែរូប មិនមាននាមធម៌ គឺរយៈពេលដែលជាអសញ្ញសត្តាព្រហ្មនោះ ចិត្ត ចេតសិកមិន

កើតឡើយ ទើបមានកម្មជ្ជរូបត្រឹមតែមួយកលាបៈ គឺកលាបៈដែលមានតែជីវិតិន្ទ្រិយប៉ុណ្ណោះ (មិនមានចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូប ឥត្ថីភាវរូប បុរិសភាវរូប ហទយរូប) ។ កម្មជ្ជរូប ៩ រូបនេះ ជាឧបាទាយរូប ដូច្នោះ ទើបត្រូវកើតរួមនឹងអវិនិព្ភោគរូប ៨ រូប ដូចនេះ គឺ

១ - **ចក្ខុទសកកលាប** (សំណុំនៃចក្ខុបសាទរូបដែលមានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + ចក្ខុបសាទរូប + ជីវិតិន្ទ្រិយរូប ។

២ - **សោតទសកកលាប** (សំណុំនៃសោតបសាទរូបដែល មានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + សោតបសាទរូប + ជីវិតិន្ទ្រិយរូប ។

៣ - **ឃានទសកកលាប** (សំណុំនៃឃានបសាទដែលមានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + ឃានបសាទរូប + ជីវិតិន្ទ្រិយរូប ។

៤ - **ជិវ្ហាទសកកលាប** (សំណុំនៃជិវ្ហាបសាទរូបដែលមានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + ជិវ្ហាបសាទរូប + ជីវិតិន្ទ្រិយរូប ។

៥ - **កាយទសកកលាប** (សំណុំនៃកាយបសាទរូបដែលមានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + កាយបសាទរូប + ជីវិតិន្ទ្រិយរូប ។

៦ - **ឥត្ថីភាវទសកកលាប** (សំណុំនៃឥត្ថីភាវរូបដែលមានរូបរួម ១០ រូប)គឺអវិនិព្ភោគរូប ៨ + ឥត្ថីភាវរូប + ជីវិតិន្ទ្រិយរូប ។

៧-**បុរិសភាវទសកកលាប** (សំណុំបុរិសភាវរូបដែល មានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + បុរិសភាវរូប + ជីវិតិន្ទ្រិយរូប ។

៨-ហទយទសកកលាប (សំណុំនៃហទយរូបដែលមានរូបរួម ១០ រូប) គឺអវិនិព្ភោគរូប ៨ + ហទយរូប + ជីវិតិន្ទ្រិយរូប ។

៩-ជីវិតនវកកលាប (សំណុំនៃជីវិតរូបដែលមានរូបរួម ៩ រូប) គឺអវិនិព្ភោគរូប ៨ + ជីវិតិន្ទ្រិយរូប ។

កម្មជ្ជកលាបទាំងនេះ កើតព្រមនឹងឧប្បាទខណៈនៃបដិសន្ធិចិត្ត តាមសមគួរដល់ភពភូមិនោះ ។ នឹងកើតគ្រប់អនុខណៈនៃចិត្តគ្រប់ដួង គឺ កើតក្នុងឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ នៃចិត្តគ្រប់ដួងនីមួយ ។ ហើយនឹងឈប់លែងកើតទៀតមុនចុតិចិត្ត ១៦ ខណៈចិត្ត ដូច្នោះកម្មជ្ជរូប ទាំងអស់ទើបរលត់ព្រមនឹងចុតិចិត្ត ។

កម្មជ្ជរូបដែលកើតព្រមនឹងបដិសន្ធិចិត្តក្នុងភូមិមនុស្ស ដែលជា ជលាពុជៈកំណើត (កំណើតក្នុងគភ៌) មាន ៣ កលាប គឺហទយទសក-កលាប កាយទសកកលាប ភាវទសកកលាប ការចម្រើនធំធាត់ឡើង ចក្ខុទសកកលាប សោតទសកកលាប ឃានទសកកលាប ជិវ្ហាទសកកលាប ក៏កើតតាមគួរដល់កាលនៃកលាបនោះ ។ ។

អ្នកដែលបដិសន្ធិជាឧបបាតិកកំណើត (កើតជាកាយដែលមាន អវយវៈគ្រប់ភ្លាមតែម្តង) ដូចជា ទេវតា ប្រេត អសុរកាយ និងអ្នកដែល កើតក្នុងនរក មានកម្មជ្ជរូបគ្រប់ ទាំង ៧ កលាប ព្រមគ្នាភ្លាមតែម្តងក្នុង ខណៈបដិសន្ធិ គឺហទយទសកកលាប កាយទសកកលាប

ភាវទសកកលាប ចក្ខុទសកកលាប សោតទសកកលាប ឃានទសកកលាប ជិវ្ហាទសកកលាប ប៉ុន្តែបើកម្មប្រភេទណាមិនជាបច្ច័យ ឱ្យរូបប្រភេទណាកើត ក៏រៀររូបកលាបនោះ ។ ទាំងក្នុងបដិសន្ធិកាល (ខណៈបដិសន្ធិចិត្តកើត) និងក្នុងបវត្តិកាល គឺខណៈក្រោយពីបដិសន្ធិ ។

អ្នកដែលបដិសន្ធិជាព្រហ្មបុគ្គល ក្នុងរូបព្រហ្មភូមិជាឧបបាតិក កំណើតមានកម្មជរូប ៤ កលាបប៉ុណ្ណោះ គឺហទយទសកកលាប ចក្ខុទសកកលាប សោតទសកកលាប និងជីវិតនវកកលាប រៀរ ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូប ភាវរូប ដែលជាផលរបស់ការរំងាប់ សេចក្តីភ្លើតភ្លើនត្រេកត្រអាលក្នុងកាមារម្មណ៍ ដោយកម្លាំងនៃឈានចិត្ត ដែលជាបច្ច័យឱ្យកើតជារូបព្រហ្មបុគ្គល ។

អ្នកដែលជាអសញ្ញសត្តាព្រហ្មបុគ្គល គឺព្រហ្មដែលមានតែរូបធម៌ មិនមាននាមធម៌សោះនោះ មានកម្មជកលាប ១ កលាប គឺជីវិតនវកកលាប ។ ការកើតជាអសញ្ញសត្តាព្រហ្មនោះ ជាផលរបស់បញ្ចមជ្ឈាន ដែលនឿយណាយនូវសេចក្តីត្រេកអរក្នុងនាមធម៌ ព្រោះឃើញទោសរបស់នាមធម៌ ដែលប្រព្រឹត្តទៅតាមកិលេស ទើបប្រាថ្នានឹងកុំឱ្យមាននាមធម៌ ។ កាលបញ្ចមជ្ឈានកុសលចិត្តមិនវិនាសទេ និងបញ្ចមជ្ឈាន កុសលចិត្តកើតមុនចុតិចិត្ត ដោយសេចក្តីនឿយណាយក្នុងនាមធម៌ ទើបជាបច្ច័យឱ្យរូបបដិ-សន្ធិ ក្នុងអសញ្ញសត្តាព្រហ្មភូមិមានអាយុ ៥០០ កប្ប ។ កាលមិនមាននាមធម៌កើតសោះឡើយ ទើបមិនមានការធ្វើចលនាណា ។ ទាំងអស់ ។

ពេលចុតិ (មុនសភាពជាអសញ្ញសត្តាព្រហ្ម) ដោយឥរិយាបថណា រូប បដិសន្ធិរបស់អសញ្ញសត្តាព្រហ្ម ក៏ជាឥរិយាបថនោះ ទម្រាំដល់រូបនឹងចុតិ ហើយនឹងកុសលកម្មមួយ ទើបជាបច្ច័យឱ្យ បដិសន្ធិចិត្ត និង កម្មជរូប កើតក្នុងកាមសុគតិ ភូមិវិលវល់ផ្លាស់ប្តូរជា កិលេស កម្ម វិបាក តទៅទៀត ដរាបណាដែលនៅមិនទាន់បានរំលត់ កិលេសជាសមុច្ឆេទទេ ។

ចិត្តជរូប

រូបដែលកើតអំពីចិត្តជាសមុដ្ឋាន មាន ៦ កលាប គឺ

១- សុទ្ធដ្ឋកកលាប ជាកលាបដែលមានតែអវិនិព្ភោគរូប ៨ រូប ប៉ុណ្ណោះ មិនមានរូប ដទៃ ។ កើតរួមជាមួយឡើយ ។

កាលបដិសន្ធិចិត្តរលត់ទៅហើយ ភវង្គចិត្តកើតបន្ត ចិត្តជរូបដែល ជាសុទ្ធដ្ឋកលាប កើតព្រមនឹងឧប្បាទខណៈនៃបឋមភវង្គចិត្ត និងគ្រប់ ឧប្បាទខណៈនៃចិត្ត វៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង ដែលមិនមានកម្លាំងល្មម និងជាសមុដ្ឋានឱ្យកើតរូបបានឡើយ ។ ចិត្តដែលមិនជាសមុដ្ឋានឱ្យចិត្ត-ជរូប មាន ១៦ ដួង គឺអរូបាវចរវិបាកចិត្ត ៤ ដួង បដិសន្ធិចិត្ត ១ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង ចុតិចិត្តនៃព្រះអរហន្ត ១ ដួង រួមជា ១៦ ដួង ។ អរូបជ្ឈានវិបាកចិត្ត ៤ ដួង មិនជាសមុដ្ឋានឱ្យកើតរូបឡើយ ព្រោះជា ផលនៃអរូបជ្ឈានកុសល ដែលឃើញទោសរបស់រូបថាជាធម៌ដែលទ្រទ្រង់

ឧបត្តម្ភដល់កិលេស ទើបចម្រើនអរូបជ្ឈានកុសលដែលមិនមានរូបណា ៗ ជាអារម្មណ៍ឡើយ ។ ពេលអរូបជ្ឈានវិបាកធ្វើកិច្ចបដិសន្ធិ ក្នុងអរូបព្រហ្ម ភូមិ ទើបមិនជាបច្ច័យឱ្យរូបណា ៗ ទាំងអស់កើតឡើយ ។

បដិសន្ធិចិត្តមិនជាសមុដ្ឋានឱ្យកើតចិត្តជ្ជរូប ព្រោះជាចិត្តខណៈដំបូង ក្នុងភពភូមិមួយ ទើបនៅមិនទាន់មានកម្លាំងល្មម និងជាសមុដ្ឋានឱ្យកើតចិត្តជ្ជរូបបានឡើយ ។

ចុតិចិត្តរបស់ព្រះអរហន្តមិនជាសមុដ្ឋានឱ្យកើតរូបដែរ ព្រោះជាចិត្តដួងចុងក្រោយនៃសង្ខារវដ្ត ដែលអស់សភាព ភាពជាបច្ច័យធ្វើឱ្យរូបកើតបាន ។

២-កាយវិញ្ញត្តិនវកកលាប ក្រុម (សំណុំ) នៃកាយវិញ្ញត្តិរូប ដែលមានរូបរួមគ្នា ៩ រូប គឺអវិនិព្ភោគរូប ៨ កាយវិញ្ញត្តិរូប ១ រមែងកើតព្រមនឹងឧប្បាទខណៈនៃចិត្ត ដែលត្រូវការឱ្យរូបសម្តែងសេចក្តីសំគាល់ដោយកាយ ។

៣-វចីវិញ្ញត្តិសទ្ទទសកកលាប សំណុំរបស់រូបរួមគ្នា ១០ រូប គឺអវិនិព្ភោគរូប ៨ + វចីវិញ្ញត្តិរូប ១ + សទ្ទរូប ១ រមែងកើតព្រមនឹងឧប្បាទខណៈនៃចិត្ត ដែលជាសមុដ្ឋានរបស់សំឡេង គឺវាចា ។

៤-លហុតាទិឯកាទសកកលាប សំណុំនៃរូបរួមគ្នា ១១ រូប គឺ អវិនិព្ភោគរូប ៨ រូប + វិការរូប ៣ រមែងកើតព្រមនឹងឧប្បាទខណៈនៃចិត្ត ដែលត្រូវការឱ្យរូបប្រព្រឹត្តទៅក្នុងឥរិយាបថផ្សេង ៗ ។

៥-កាយវិញ្ញត្តិលហុតាទ្វិទសកកលាប សំណុំនៃរូបរួមគ្នា ១២ រូប គឺអវិនិព្ភោគរូប ៨ + វិការរូប ៣ + កាយវិញ្ញត្តិរូប ១ រមែងកើតព្រមនឹងឧប្បាទខណៈនៃចិត្តដែលត្រូវការឱ្យរូបប្រព្រឹត្តទៅក្នុងកិរិយាអាការផ្សេង ៗ ដែលសម្តែងសេចក្តីសំគាល់ដោយកាយ ។

៦-វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកលាប សំណុំនៃរូបរួម ១៣ រូបគឺ អវិនិព្ភោគរូប ៨ + វិការរូប ៣ + វចីវិញ្ញត្តិរូប ១ + សទ្ទរូប ១ រមែងកើតព្រមនឹងឧប្បាទខណៈនៃចិត្តដែលត្រូវការឱ្យកើតសំឡេង ពិសេសដែលត្រូវអាស្រ័យវិការរូបទើបនឹងកើតសំឡេងនោះ ។ ត្រង់ស្ថាននៃសំឡេងបាន ។

ចិត្តជ្ជកលាប គ្រប់កលាបត្រូវកើតព្រមនឹងឧប្បាទខណៈនៃចិត្តដែលជាសមុដ្ឋានឱ្យចិត្តជ្ជកលាបនោះកើត ចិត្តជ្ជកលាបនឹងមិនកើតក្នុងឋិតិខណៈ និងភង្គខណៈនៃចិត្តឡើយ ។

ឧតុជរូប

រូបដែលកើតពីឧតុ មាន ៤ កលាប គឺ

១-សុទ្ធដ្ឋកកលាប មានអវិនិព្ភោគរូប ៨ រូបប៉ុណ្ណោះ មិនមានរូបដទៃ ៗ កើតរួមជាមួយឡើយ ក្នុងរូបដែលមានចិត្តគ្រប់គ្រងនោះ កាលបដិសន្ធិចិត្តកើតឡើងនោះក្នុងឧប្បាទខណៈ ឋិតិខណៈ ភង្គខណៈ នៃបដិសន្ធិចិត្តមានកម្មជរូបកើតតាមដែលបានពោលហើយ ប៉ុន្តែក្នុងឋិតិខណៈ នៃបដិសន្ធិចិត្តនោះឯង ឧតុ គឺធាតុភ្លើងក្នុងកម្មជកលាប ដែលកើតនោះ ក៏ជាសមុដ្ឋានឱ្យឧតុជរូប ដែលជាសុទ្ធដ្ឋកកលាបកើតឡើង ហើយឧតុជសុទ្ធដ្ឋកកលាបនេះ នឹងកើតឡើងក្នុងឋិតិខណៈនៃរូប ត ៗ ទៅ ។

២-សទ្ទនវកកលាប សំណុំនៃសំឡេងដែលមានរូបរួមគ្នា ៩ រូបគឺ អវិនិព្ភោគរូប ៨ + សទ្ទរូប ១ ។ ខណៈណាដែលរូបសំឡេងមិនបានកើតពីចិត្តជាសមុដ្ឋាន ឱ្យវចីវិញ្ញត្តិរូបប៉ះខ្ទប់ត្រង់ស្ថាននៃសំឡេងទេ ខណៈនោះសំឡេងកើតអំពីឧតុជាសមុដ្ឋាន ដូចសំឡេងរថយន្ត សំឡេងទឹកធ្លាក់ ជាដើម ។

៣-លហុតាទិឯកាទសកកលាប សំណុំនៃវិការរូប ដែលមានរូបរួមគ្នា ១១ រូប គឺអវិនិព្ភោគរូប ៨ + វិការរូប ៣ ។ ឧតុរមែងជាសមុដ្ឋាន ១ ដែលធ្វើឱ្យកើតរូបស្រាល រូបទន់ភ្លន់ និងរូបគួរដល់ការងារ ប្រសិនបើឧតុមិនស្មើទេ ក៏កើតរោគ និងចំណែកកាយណាមិនមានវិការរូប សូម្បីចិត្ត

ជាសមុដ្ឋានឱ្យចំណែកកាយនោះ មានចលនាប្រព្រឹត្តទៅតាមសេចក្តីត្រូវការមិនបានឡើយ ។

៤-សទ្ទលហុតាទិទ្វាទសកកលាប សំណុំនៃវិការរូប និងសំឡេងរួមគ្នាទាំងអស់ ១២ រូប គឺអវិនិព្ភោគរូប ៨ + វិការរូប ៣ + សទ្ទរូប ១ ។ ក្នុងខណៈដែលសំណុំនៃវិការរូបនោះ មានសំឡេងកើតរួមជាមួយដូច ផ្លាត់ម្រាមដៃ ទះដៃ ជាដើម ។

អាហារជរូប

រូបដែលកើតអំពីឱជារូបក្នុងកវឡិង្ការាហារ គឺអាហារដែលជាដុំពំនូតដែលទំពាលេបចូលទៅនោះ មាន ២ កលាប ។ អាហារជកលាបនេះកើតបានចំពោះតែក្នុងរាងកាយនៃសត្វ បុគ្គលប៉ុណ្ណោះ ។ អាហារជកលាប ២ កលាប គឺ

១-សុទ្ធដ្ឋកកលាប មានអវិនិព្ភោគរូប ៨ ប៉ុណ្ណោះ មិនមានរូបដទៃកើតរួមជាមួយឡើយ ។

២-លហុតាទិឯកាទសកកលាប សំណុំនៃវិការូប ដែលមានរូបរួមគ្នា ១១ រូប គឺអវិនិព្ភោគរូប ៨ + វិការូប ៣ ក្រៅពីចិត្ត និងឧតុ ជាសមុដ្ឋានឱ្យកើតវិការូប ៣ ហើយអាហារក៏ជាសមុដ្ឋានមួយទៀត ដែលធ្វើឱ្យកើតវិការូប ៣ បើមានត្រឹមតែវិការូបដែលកើតអំពីឧតុប៉ុណ្ណោះ តែអត់

អាហារ គឺសូម្បីអាកាសល្អតែគ្មានអាហារ វិការរូបក៏មិនមានកម្លាំងល្មមនឹងធ្វើចលនាឱ្យបានស្រួលរហ័សរហួនឡើយ ។

អាហារជ្ជរូប អាស្រ័យការចែកចាយសាយសព្វនៃឱជាក្នុងអាហារដែលទំពាលេបចូលទៅនោះជាសមុដ្ឋានពេលណា ក៏កើតឡើងក្នុងឋិតិខណៈនៃឱជារូបដែលជាសមុដ្ឋានពេលនោះ ។

រួបរួមរូបនីមួយ ៗ រូបកើតពីសមុដ្ឋានណាមួយក្នុង ៤ សមុដ្ឋាន ដូចនេះ គឺ

អវិនិព្ភោគរូប ៨ កើតបានពីសមុដ្ឋាន ៤ គឺ
កលាបខ្លះក៏មានកម្មជាសមុដ្ឋាន
កលាបខ្លះក៏មានចិត្តជាសមុដ្ឋាន
កលាបខ្លះក៏មានឧតុជាសមុដ្ឋាន
កលាបខ្លះក៏មានអាហារជាសមុដ្ឋាន

បសាទរូប ៥ កើតពីកម្មជាសមុដ្ឋានតែប៉ុណ្ណោះ

ភាវរូប ២ កើតពីកម្មជាសមុដ្ឋានតែប៉ុណ្ណោះ

ហទយរូប ១ កើតពីកម្មជាសមុដ្ឋានតែប៉ុណ្ណោះ

ជីវិតិន្ទ្រិយរូប ១ កើតពីកម្មជាសមុដ្ឋានតែប៉ុណ្ណោះ

វិការរូប ៣ កើតពីសមុដ្ឋាន ៣ គឺ
កលាបខ្លះកើតពីចិត្តជាសមុដ្ឋាន
កលាបខ្លះកើតពីឧតុជាសមុដ្ឋាន

កលាបខ្លះកើតពីអាហារជាសមុដ្ឋាន

វិញ្ញត្តិរូប ២ កើតពីចិត្តជាសមុដ្ឋានតែប៉ុណ្ណោះ

សទ្ទរូប ១ កើតពីសមុដ្ឋាន ២ គឺ
កលាបខ្លះកើតពីចិត្តជាសមុដ្ឋាន
កលាបខ្លះកើតពីឧតុជាសមុដ្ឋាន

បរិច្ឆេទរូប ១ កើតពីសមុដ្ឋាន ៤ គឺកើតពីកម្មជាសមុដ្ឋានពេលខណ្ឌចន្លោះរវាងកលាប ដែលកើតពីកម្មជាសមុដ្ឋាន ។ កើតពីចិត្តជាសមុដ្ឋាន ពេលខណ្ឌចន្លោះរវាងកលាបដែលកើតពីចិត្តជាសមុដ្ឋាន ។ កើតពីឧតុជាសមុដ្ឋាន ពេលខណ្ឌចន្លោះរវាងកលាបដែលកើតពីឧតុជាសមុដ្ឋាន ។ កើតពីអាហារជាសមុដ្ឋាន ពេលខណ្ឌចន្លោះរវាងកលាបដែលកើតពីអាហារជាសមុដ្ឋាន ។

លក្ខណៈរូប ៤ មិនកើតពីសមុដ្ឋានណាឡើយ ព្រោះត្រឹមតែជាលក្ខណៈ អាការនៃសភាវរូប ១៨ រូប

រូប ២៨ រូបចំណែកបានច្រើននិយដូចនេះ គឺ

សភាវរូប ១៨	គឺរូបដែលមានលក្ខណៈចំពោះនៃខ្លួន បានដល់ អវិនិព្ភោគរូប ៨ បសាទរូប ៥ ភាវរូប ២ ហទយរូប ១ ជីវិតិន្ទ្រិយរូប ១ សទ្ធរូប ១ រួម ១៨ ។
អសភាវរូប ១០	គឺរូបដែលមិនមានលក្ខណៈចំពោះផ្សេងទៀត បានដល់ វិការរូប ៣ វិញ្ញត្តិរូប ២ បរិច្ឆេទរូប ១ លក្ខណៈរូប ៤ ។
អជ្ឈត្តិករូប ៥	គឺរូបខាងក្នុង បានដល់ បសាទរូប ៥ ។
ពាហិររូប ២៣	គឺរូបខាងក្រៅ បានដល់ រូបដែលសល់ ២៣ រូប ។
វត្ថុរូប ៦	គឺរូបដែលជាទីកើតនៃចិត្ត បានដល់ បសាទរូប ៥ ហទយរូប ១ ។
អវត្ថុរូប ២២	បានដល់រូបដែលសល់ ២២ រូប ។
ទ្វាររូប ៧	គឺរូបដែលជាផ្លូវទទួលអារម្មណ៍ បានដល់ បសាទ-រូប ៥ និងជាផ្លូវរបស់កាយកម្ម និងវិចីកម្ម គឺ កាយវិញ្ញត្តិរូប ១ វិចីវិញ្ញត្តិរូប ១ ។
អទ្វាររូប ២១	បានដល់រូបដែលសល់ ២១ រូប ។
ឥន្ទ្រិយរូប ៨	គឺរូបដែលជាធំក្នុងកិច្ចការងារចំពោះនៃខ្លួន ៨ រូប បានដល់ បសាទរូប ៥ ភាវរូប ២ ជីវិតិន្ទ្រិយរូប ១។
អនិន្ទ្រិយរូប ២០	បានដល់រូបដែលសល់ ២០ រូប ។

ឱឡារិករូប ១២ គឺរូបគ្រោតគ្រោត១២ រូប បានដល់វិសយរូប ៧ (រូបដែលជាអារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ) បសាទរូប ៥ ។

សុខុមរូប ១៦ គឺរូបល្អិត បានដល់ រូបដែលសល់ ១៦ រូប ។

សន្តិកេរូប ១២ គឺរូបជិត (ដល់ការពិចារណាដឹងបាន) បានដល់ បសាទរូប ៥ វិសយរូប ៧

ទូរេរូប ១៦ គឺរូបឆ្ងាយ (លំបាកដល់ការពិចារណាចាក់ធ្លុះ) បានដល់ រូបដែលសល់ ១៦ រូប ។

សប្បដិឃរូប ១២ គឺរូបដែលប៉ះខ្ទប់បាន បានដល់ បសាទរូប ៥ វិសយរូប ៧ ។

អប្បដិឃរូប ១៦ គឺរូបដែលប៉ះខ្ទប់មិនបាន បានដល់ រូបដែលសល់ ១៦ រូប ។

គោចរគ្គាហិករូប ៥ គឺរូបដែលប៉ះខ្ទប់អារម្មណ៍បានដល់បសាទរូប ៥ ។

អគោចរគ្គាហិករូប ២៣ គឺរូបដែលប៉ះខ្ទប់អារម្មណ៍មិនបាន បានដល់រូបដែលសល់ ២៣ រូប ។

អវិនិព្ភោគរូប ៨ គឺរូបដែលបែកគ្នាមិនបាន ៨ រូប ។

វិនិព្ភោគរូប ២០ គឺរូបដែលបែកគ្នាបាន បានដល់ រូបដែលសល់ ២០ រូប ។

សំណួរសាឡើងវិញ ភាគបន្ថែម

១- ចិត្តដែលមិនកើតរួមព្រមនឹងអលោភហេតុ អទោសហេតុ អមោហហេតុ ជាអកុសលចិត្ត ឬទេ ?

២- អសោភណចិត្ត និងអកុសលចិត្ត ផ្សេងគ្នាយ៉ាងណា ?

៣- អសោភណចិត្តមានប៉ុន្មានដួង ? អ្វីខ្លះ ?

៤- ចិត្តអ្វី ធ្វើភវង្គកិច្ច ?

៥- បញ្ចទ្វារាវជ្ជនចិត្ត ជាជាតិអ្វី ?

៦- ពេលសំឡេងប៉ះខ្ចប់ត្រចៀក តើចិត្តអ្វីដឹងសំឡេងជាខណៈដំបូង ?

៧- ចិត្តអ្វី ដែលកើតមុនហសិតុប្បាទចិត្ត ?

៨- មនោទ្វារាវជ្ជនចិត្ត ជាមនោទ្វារមែន ឬ ?

៩- មនោទ្វារាវជ្ជនចិត្ត មានកិច្ចប៉ុន្មាន ? កើតបានទ្វារប៉ុន្មាន ? ដឹងបានអារម្មណ៍អ្វីខ្លះ ?

១០- ហេតុ ជាបរមត្ថធម៌អ្វី ?

១១- ហេតុ ជាខន្ធអ្វី ?

១២- និព្វានជាហេតុ ឬ នហេតុ ? អហេតុក ឬ សហេតុក ?

១៣- នហេតុដែលមិនមែនសង្ខារក្ខន្ធ បានដល់អ្វីខ្លះ ?

១៤- សង្ខារក្ខន្ធដែលជានហេតុ មានប៉ុន្មានដួង ?

១៥- បរមត្ថធម៌ដែលជានហេតុនោះ ជាខន្ធអ្វីខ្លះ ?

១៦- លោកុត្តរចិត្តជាអសង្ខតធម៌មែនឬ ?

១៧- ខន្ធអ្វីជាកុសល ?

១៨- ខន្ធអ្វីជាអព្យាកតធម៌ ?

១៩- ខន្ធដែលមិនមែនអព្យាកតធម៌មាន ឬទេ ?

២០- អព្យាកតធម៌ដែលមិនមែនខន្ធ មានទេ ?

២១- កុសលធម៌ដែលមិនមែនខន្ធមាន ឬទេ ?

២២- អកុសលចិត្តក្នុងអរូបព្រហ្មភូមិ ជាជាតិអ្វី ?

២៣- វេទនាចេតសិកជាភូមិអ្វី ?

២៤- និព្វានមានវេទនា ឬទេ ? ព្រោះអ្វី ?

២៥- ចេតសិកអ្វី មិនមានវេទនាកើតរួមជាមួយ ?

២៦- ចិត្តភូមិណា មាន ១ ជាតិ ?

២៧- ចិត្តភូមិណា មាន ២ ជាតិ ?

២៨- ចិត្តភូមិណា មាន ៣ ជាតិ ?

២៩- ចិត្តជ្ជរូប ដែលកើតពីមោហមូលចិត្តជាសមុដ្ឋានកើតព្រោះហេតុ-ប្បច្ច័យ ឬក៏មិនមែន ?

៣០- មោហចេតសិក ដែលកើតជាមួយនឹងមោហមូលចិត្តកើតរួមនឹងហេតុ ឬក៏មិនមែន ?

សមថភាវនា

សមថភាវនា

សមថភាវនាមិនមែនការធ្វើសមាធិ ។ សមាធិជាសភាវធម៌ដែលតាំងមាំក្នុងអារម្មណ៍ ដែលបានដល់ឯកគ្គតាចេតសិក ដែលកើតជាមួយនឹងចិត្តគ្រប់ ៗ ដួង ។ កាលណាចិត្តស្តុងមានអារម្មណ៍ណាមួយយូរ ៗ លក្ខណៈនៃឯកគ្គតាចេតសិកក៏ប្រាកដជាសមាធិ គឺតាំងមាំណែននៅត្រង់អារម្មណ៍ណាមួយត្រឹមតែជាអារម្មណ៍មួយប៉ុណ្ណោះ ។ ឯកគ្គតាចេតសិកដែលកើតជាមួយនឹងអកុសលចិត្ត ជា**មិច្ឆាសមាធិ** ឯកគ្គតាចេតសិកដែលកើតជាមួយនឹងកុសលចិត្ត ជា**សម្មាសមាធិ** ។

ការធ្វើសមាធិឱ្យចិត្តផ្តោតចំត្រង់អារម្មណ៍ណាមួយយូរ ៗ នោះ **កាលណាមិនប្រកបដោយបញ្ញាទេក៏ជាមិច្ឆាសមាធិ** ព្រោះខណៈនោះ ជាសេចក្តីពេញចិត្តដែលនឹងឱ្យចិត្តតាំងមាំ ណែនត្រង់អារម្មណ៍តែមួយ កាលណាប្រាសចាកនូវបញ្ញាហើយក៏មិនអាចដឹងសេចក្តីផ្សេងគ្នា នៃលោភមូលចិត្ត និងកុសលចិត្ត ព្រោះលោភមូលចិត្ត និងកាមាវចរកុសលចិត្តមានវេទនាប្រភេទដូចគ្នាកើតជាមួយ គឺ

លោភមូលចិត្ត ៨ ដួង មានឧបេក្ខាវេទនាកើតរួមជាមួយ ៤ ដួង មានសោមនស្សវេទនាកើតរួមជាមួយ ៤ ដួង ។

កាមាវចរកុសលចិត្ត ៨ ដួង មានឧបេក្ខាវេទនាកើតរួមជាមួយ ៤ ដួង មានសោមនស្សវេទនាកើតរួមជាមួយ ៤ ដួង ។

ដូច្នោះ ខណៈណាដែលឧបេក្ខាវេទនាកើតឡើង ឬសោមនស្សវេទនាកើតឡើង ទើបលំបាកនឹងដឹងថា ចិត្តដែលមិនសុខមិនទុក្ខ មិនក្តៅក្រហាយ ឬខណៈដែលសោមនស្សរីករាយជាសុខនោះ តើជាលោភមូលចិត្ត ឬជាមហាកុសលចិត្ត ។

សេចក្តីផ្សេងគ្នារបស់លោភមូលចិត្ត ៨ ដួង និងមហាកុសលចិត្ត ៨ ដួង គឺលោភមូលចិត្តមានអកុសលចេតសិកកើតរួមជាមួយ មហាកុសលចិត្តមានសោភណចេតសិកកើតរួមជាមួយ ។ អកុសលចេតសិក ដែលបញ្ជាក់សេចក្តីផ្សេងគ្នានៃលោភមូលចិត្ត និងមហាកុសលចិត្ត គឺមិច្ឆាទិដ្ឋិ ការយល់ឃើញខុស និងសោភណចេតសិក ដែលបញ្ជាក់សេចក្តីផ្សេងគ្នានៃកុសលចិត្ត និងលោភមូលចិត្ត គឺសម្មាទិដ្ឋិ ដែលជាបញ្ញាចេតសិក ។ ដូច្នោះ សេចក្តីផ្សេងគ្នានៃលោភមូលចិត្ត ៨ ដួង និងមហាកុសល ៨ ដួង គឺ

លោភមូលចិត្ត ៨ ដួង កើតរួមជាមួយនឹងទិដ្ឋិចេតសិក ៤ ដួង មិនកើតរួមនឹងទិដ្ឋិចេតសិក ៤ ដួង ។

មហាកុសលចិត្ត ៨ ដួង កើតរួមជាមួយនឹងបញ្ញាចេតសិក ៤ ដួង មិនកើតរួមនឹងបញ្ញាចេតសិក ៤ ដួង ។

ដូច្នោះ អ្នកដែលនឹងចម្រើនសមថភាវនា ទើបត្រូវដឹងសេចក្តីផ្សេងគ្នានៃលោភមូលចិត្ត និងកុសលចិត្ត មិនដូច្នោះទេ ក៏នឹងធ្វើសមាធិដោយលោភមូលចិត្ត ជាមិច្ឆាសមាធិនៅពេលមិនប្រកបដោយ **បញ្ញា** ។

ភាគច្រើន អ្នកដែលធ្វើសមាធិមិនត្រូវការចង់ឱ្យចិត្តរើរវាយ ក្តៅក្រហាយ កង្វល់ទៅនឹងរឿងរ៉ាវផ្សេង ។ ទេ ពេញចិត្តនឹងឱ្យចិត្តតាំងនៅមាំត្រង់អារម្មណ៍ណាមួយ ដោយមិនដឹងថាខណៈដែលកំពុងត្រូវការ ចង់ឱ្យចិត្តផ្តោតអារម្មណ៍ដែលត្រូវការនោះ មិនមែនមហាកុសលញាណសម្បយុត្ត ។

ការចម្រើនសមថភាវនា ជាការចម្រើនមហាកុសលញាណសម្បយុត្ត **អ្នកដែលនឹងចម្រើនសមថភាវនា ត្រូវជាអ្នកមានបញ្ញាឃើញទោសរបស់អកុសលទាំងលោភៈ** និង**ទាំងទោសៈ** មិនមែនឃើញតែទោសរបស់ទោសមូលចិត្ត ដែលជាកង្វល់ចិត្ត ក្តៅក្រហាយចិត្តផ្សេង ។ ប៉ុណ្ណោះទេ ។ អ្នកដែលមិនស្គាល់កិលេស និងមិនឃើញទោសរបស់លោភៈ រមែងមិនចម្រើនសមថភាវនា ដូច្នោះ អ្នកដែលចម្រើនសមថភាវនាទើបជាអ្នកត្រង់មានបញ្ញាឃើញទោសរបស់លោភៈ និងមានសតិសម្បជញ្ញៈដឹងខណៈដែលផ្សេងគ្នានៃលោភមូលចិត្ត និងមហាកុសលញាណសម្បយុត្តចិត្ត ទើបនឹងចម្រើនមហាកុសលញាណសម្បយុត្តកើនឡើង ។ រហូតអកុសលចិត្តមិនកើតជ្រែកខណ្ឌបានរហូតដល់នឹងជាឧបចារសមាធិ ហើយបន្តុះនូវអប្បនាសមាធិ គឺបឋមជ្ឈាន កុសលចិត្តប្រកបដោយអង្គឈាន ៥ គឺវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

ការចម្រើនសមថភាវនា ដែលនឹងឱ្យមហាកុសលញាណសម្បយុត្តចិត្តចម្រើនឡើង ។ រហូតដល់ជាបាទឱ្យកើតបឋមជ្ឈានកុសលចិត្ត ដែល

ជារូបាវចរកុសលនោះ ជាសភាវៈដែលធ្វើបានដោយលំបាក ព្រោះនឹងមិនត្រូវជាអភ័ព្វបុគ្គល គឺអ្នកដែលចម្រើនសមថ ឬវិបស្សនា ក៏មិនអាចបន្លុះនូវឈានចិត្ត ឬលោកុត្តរចិត្តបាន ។

អ្នកដែលជាភ័ព្វបុគ្គល គឺអ្នកដែលនៅពេលចម្រើនសមថភាវនា ឬវិបស្សនាភាវនា ក៏នឹងអាចបន្លុះឈានចិត្ត ឬលោកុត្តរចិត្តបាននោះ ត្រូវជាអ្នកដែល

១- មិនមានវិបាកជាគ្រឿងរារាំង[២៧] គឺបដិសន្ធិ ជាតិហេតុកៈមានបញ្ញាចេតសិកកើតរួមជាមួយ ។

២- មិនមានកម្មជាគ្រឿងរារាំង គឺមិនបានធ្វើនូវអនន្តរិយកម្ម យ៉ាងណាមួយ ក្នុងអនន្តរិយកម្មទាំង ៥ ដែលជាគ្រឿងរារាំង សួគ៌ មគ្គ ផល ។ អនន្តរិយកម្ម ៥ គឺសម្លាប់មាតា ១ សម្លាប់បិតា ១ សម្លាប់ព្រះអរហន្ត ១ ធ្វើប្រទូស្តនឹងព្រះមានព្រះភាគឱ្យពុះពោរពងនូវព្រះលោហិត ១ ធ្វើសង្ឃភេទ គឺបំបែកសង្ឃឱ្យបែកគ្នាដោយមិនធ្វើសង្ឃកម្មរួមជាមួយគ្នា ១ ។

៣- មិនមានកិលេសជាគ្រឿងរារាំង គឺមិនមាននិយតមិច្ឆាទិដ្ឋិ ៣ បានដល់ នត្ថិកទិដ្ឋិ ១ អហេតុកទិដ្ឋិ ១ អកិរិយទិដ្ឋិ ១ ។

[២៧] អង្គុត្តរនិកាយ ឆក្កនិបាត ភ័ព្វសូត្រ និង អាវរណតាសូត្រ

សូម្បីថា បដិសន្ធិចិត្តជាតិហេតុកៈប្រកបដោយបញ្ញា តែបើត្រេកអរភ្លើតភ្លើនក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដោយមិនឃើញទោស ក៏រមែងនឹងមិនគិតបន្តយបន្សាត់បង់សេចក្តីភ្លើតភ្លើនក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដោយការរក្សាសីល ឬចម្រើនភាវនាឡើយ ។ ដូច្នោះ ការអប់រំសមថភាវនាឱ្យដល់ឧបចារសមាធិ និងអប្បនាសមាធិ ទើបមិនងាយឡើយ មិនមែនត្រឹមតែការផ្តោតចិត្តត្រង់អារម្មណ៍ណាមួយ ដែលត្រូវការក៏នឹងជាមហាកុសលញាណសម្បយុត្ត ដែលនឹងធ្វើឱ្យបន្លុះដល់ឧបចារសមាធិបាន បើយល់ខុសថា លោភមូលចិត្ត ខណៈនោះ ជាមហាកុសលក៏នឹងធ្វើឱ្យគិតថា និមិត្តផ្សេង ។ ទាំងឡាយដែលចិត្តតាក់តែងឱ្យកើតឡើងឃើញ ជានរក ជាសួគ៌ ជាទីស្តាន ជារឿងរ៉ាវ ហេតុការណ៍ផ្សេង ។ នោះជាឧបចារសមាធិ ជាអប្បនាសមាធិដែលជាឈានចិត្តថ្នាក់ផ្សេង ។ ។

ដូច្នោះ សមថភាវនា ទើបជារឿងល្អិតល្អន់ដែលនឹងត្រូវសិក្សាឱ្យយល់ត្រឹមត្រូវពិត ។ ។

ក្នុងមួយថ្ងៃ ។ ក្នុងខណៈដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងនឹកគិត អកុសលចិត្តរមែងកើតច្រើនជាងកុសលចិត្ត ។ កុសលចិត្តដែលកើតក្នុងមួយថ្ងៃ ។ នោះតែងជាទានខ្លះ សីលខ្លះ ត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ក្នុងមួយថ្ងៃ ។ មួយខែ ។ អ្នកដែលឃើញទោសរបស់អកុសលទើបអប់រំចិត្ត ឱ្យជាកុសលកើនឡើងជាមួយផង ក្នុងខណៈដែលមិនមែន

ជាទាន និងជាសីល ។ ការអប់រំចិត្តឱ្យស្ងប់ចាកអកុសលទាំងឡាយ ក្នុងមួយថ្ងៃ ៗ នោះ ជាកុសលថ្នាក់សមថភាវនាក្នុងជីវិតប្រចាំថ្ងៃ សូម្បីថា មិនអាចនឹងដល់ថ្នាក់ឧបចារសមាធិ និងអប្បនាសមាធិក៏ដោយ ក៏ជាអ្វីដែលគួរចម្រើន ។ តែការនឹងរំងាប់ចិត្តឱ្យស្ងប់ចាកអកុសលនោះ ត្រូវតែជាបញ្ញាដែលដឹងថា ចិត្តនឹងស្ងប់ក្នុងខណៈដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងនឹកគិតបានយ៉ាងណា ៗ បើមិនដូច្នោះទេ កុសលចិត្តក៏កើតមិនបានឡើយ ។

ចិត្តដែលស្ងប់ចាកអកុសលជាសមថភាវនានោះ ត្រូវជាកុសលចិត្តក្នុងអារម្មណ៍ ៤០ អារម្មណ៍ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ ព្រហ្មវិហារ ៤ អរូបជ្ឈានអារម្មណ៍ ៤ ។

កសិណ ១០

ឈ្មោះថា កសិណ ព្រោះអត្ថថា ធ្វើអារម្មណ៍ទាំងអស់ ។ កសិណ ១០ បានដល់

១ - បឋវីកសិណ	រលឹកដល់តែ ដី ប៉ុណ្ណោះ
២ - អាបោកសិណ	រលឹកដល់តែ ទឹក ប៉ុណ្ណោះ
៣ - តេជោកសិណ	រលឹកដល់តែ ភ្លើង ប៉ុណ្ណោះ

๔ - វាយោកសិណ រលឹកដល់តែ ខ្យល់ ប៉ុណ្ណោះ
๕ - នីលកសិណ រលឹកដល់តែ ពណ៌ខៀវ ប៉ុណ្ណោះ
๖ - បីតកសិណ រលឹកដល់តែ ពណ៌លឿង ប៉ុណ្ណោះ
๗ - លោហិតកសិណ រលឹកដល់តែ ពណ៌ក្រហម ប៉ុណ្ណោះ
๘ - ឱទាតកសិណ រលឹកដល់តែ ពណ៌ស ប៉ុណ្ណោះ
๙ - អាលោកកសិណ រលឹកដល់តែ ពន្លឺ ប៉ុណ្ណោះ
๑๐ - អាកាសកសិណ រលឹកដល់តែ អាកាស ប៉ុណ្ណោះ

ចិត្តដែលរលឹកដល់តែដី ជាកុសល ឬ ជាអកុសល ? កាលណាបញ្ញាមិនកើត ខណៈដែលគិតដល់ដី ក៏ជាអកុសលដែលនឹងត្រូវការគិតដល់ដី ឬត្រូវការតម្កល់ផ្តោតត្រង់ដី ។

កាលណាបញ្ញាកើត ចិត្តដែលរលឹកដល់ ដីក៏ជាកុសល ការដឹងថារូបគ្រប់យ៉ាងដែលប្រាកដប្រាសចាក ធាតុដីមិនបាន វត្ថុដែលធ្លាប់ពេញចិត្ត ប្រាថ្នា ត្រូវការទាំងអស់នោះ សុទ្ធត្រឹមតែជាដីប៉ុណ្ណោះ ។ កាលណាដឹងដល់ខ្លឹមពិតនៃវត្ថុទាំងពួងក្នុងលោកដែលធ្លាប់ពេញចិត្ត ប្រាថ្នាថាត្រឹមតែជាដីហើយ ក៏ធ្វើឱ្យលះបង់នូវសេចក្តីពេញចិត្ត ក្នុងវត្ថុទាំងឡាយក្នុងខណៈ ដែលរលឹកដឹងថា ត្រឹមតែជាដីប៉ុណ្ណោះ ។

កាលដែលចិត្តនឹងជាកុសលរលឹកដល់តែដីនោះ ប្រព្រឹត្តទៅបានដោយលំបាក ព្រោះពេលដែលអារម្មណ៍ប៉ះខ្ទប់ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តក៏ទោរទៅតាមអារម្មណ៍នោះ ។ ភ្លាម ។ ដោយហេតុនេះ

ការចម្រើនសមថភាវនាដែលនឹងឱ្យចិត្តស្ងប់ចាកអកុសល តាំងមាំឡើង នោះទើបត្រូវអាស្រ័យទីកន្លែងដែលស្ងាត់ប្រាសចាកសំឡេង មនុស្សម្នារំខាន ហើយធ្វើដីជារង្វង់មូលរាបស្មើ (បឋវីកសិណ) ប្រាសចាកទោសមន្ទិល ដែលធ្វើឱ្យចិត្តបង្អោនទៅនឹកពេញចិត្តក្នុងរូបរាងសណ្ឋានផ្សេង ។ បាន (សេចក្តីល្អិតមានក្នុងគម្ពីរវិសុទ្ធិមគ្គ សមាធិនិទ្ទេស បឋវីកសិណ) ។ ខណៈដែលមើលបឋវីកសិណនោះ កាលណាចិត្តរលឹកដល់ដីប្រកបដោយបញ្ញា ជាមហាកុសលញាណសម្បយុត្ត ទើបចិត្តនឹងស្ងប់បាន ហើយនឹងត្រូវមើលបឋវីកសិណដើម្បីដាស់តឿនឱ្យរលឹកដល់ដីប៉ុណ្ណោះ ជារឿយ ។ ទៅ ដើម្បីមិនឱ្យចិត្តដឹងអារម្មណ៍ដទៃ ។

តើលំបាកប៉ុណ្ណាដែលនឹកដល់តែដីដោយចិត្តដែលស្ងប់ ចាកពីអកុសលទាំងឡាយ តាំងនៅជារឿយ ។ ដោយមើលបឋវីកសិណ ដែលមិនតូចពេក មិនធំពេក មិនឆ្ងាយពេក មិនជិតពេក មិនខ្ពស់ពេក មិនទាបពេកនោះ ។ ដូច្នោះ វិតក្កចេតសិកទើបជាអង្គឈាន ដែលខ្វះមិនបានឡើយ វិតក្កចេតសិកដែលកើតព្រមនឹងមហាកុសលញាណសម្ប-យុត្តចិត្តនឹងត្រូវច្រត់ទាល់ត្រង់បឋវីកសិណ ដោយចិត្តដែលស្ងប់ចាកពីអកុសលទាំងឡាយ ទាំងក្នុងខណៈបិទភ្នែកក្តី ឬបើកភ្នែកក្តី រហូតទម្រាំដល់ឧគ្គហនិមិត្ត គឺនិមិ្មតរបស់បឋវីកសិណដែលប្រាកដតាមផ្លូវមនោទ្វារស្មើដូចជានឹងក្នុងខណៈដែលបើកភ្នែក ដែលលោកអ្នកខ្លះ សូម្បីបដិសន្ធិចិត្ត និងជាតិហេតុកៈក្តី តែឧគ្គហនិមិត្តក៏មិនប្រាកដឡើយ ។ ឧគ្គហនិមិត្ត

នឹងប្រាកដកាលណាមហាកុសលញាណសម្បយុត្ត បន្ថែមសេចក្តីស្ងប់តាំងមាំទាំក្នុងបឋវីកសិណរួចហើយ តែខណៈដែលឧគ្គហនិមិត្តប្រាកដនោះ ក៏នៅមិនទាន់ដល់ឧបចារសមាធិ ។

ការឧបត្ថម្ភថែរក្សាមហាកុសលញាណសម្បយុត្តចិត្ត តាំងមាំក្នុងឧគ្គហនិមិត្តតទៅ បន្តទៀតរឿយ ។ និងមាំទាំឡើងនោះមិនងាយឡើយ ។ តាមសេចក្តីក្នុង វិសុទ្ធិមគ្គ បឋវីកសិណនិទ្ទេស កាលនីវរណៈទាំងឡាយ (អកុសលដែលគ្របសង្កត់ចិត្ត) រំងាប់ទ្រោមចុះដោយលំដាប់ហើយ ចិត្តក៏រមែងស្ងប់មាំទាំ ជាឧបចារសមាធិពេលដែលមានបដិភាគនិមិត្តប្រាកដ ហាក់បីដូចជាជ្រែកឧគ្គហនិមិត្តចេញមក ។ បដិភាគនិមិត្ត ជានិមិត្តដែលថ្លាផូរផង់ជាងឧគ្គហនិមិត្ត ។ ខណៈដែលបដិភាគនិមិត្តប្រាកដនោះ មហាកុសលញាណសម្បយុត្តចិត្តស្ងប់ មាំទាំ មិនកំរើកដល់ថ្នាក់ឧបចារសមាធិ គឺសមាធិដែលជិតដល់ការស្ងប់តាំងណែនក្នុងអារម្មណ៍ ថ្នាក់អប្បនាសមាធិ ដែលជាបឋមជ្ឈានចិត្ត ។

ការឧបត្ថម្ភថែរក្សាមហាកុសលញាណសម្បយុត្តចិត្ត ដែលស្ងប់ដល់ ថ្នាក់ឧបចារសមាធិបានស្ងប់តទៅទៀតជារឿយ ។ ហើយបន្ថែមនូវសេចក្តីស្ងប់មាំទាំឡើងរហូតដល់ថ្នាក់អប្បនាសមាធិ ដែលជាចិត្តថ្នាក់រូបាវចរៈ ជាបឋមជ្ឈានចិត្តកើតឡើងបាននោះ ត្រូវរក្សាឧបចារសមាធិដែលបានហើយ ដូចនាងកែវរក្សាគភ៌ដែលជាទីឧបត្តិនៃស្តេចចក្រពត្តិ

ហើយត្រូវវៀរហេតុ ដែលមិនមែនជាសប្បាយៈ (ធម៌ដែលស្រួលសប្បាយ ឧបត្ថម្ភ គាំទ្រដល់ការចម្រើនភាវនា) ៧ យ៉ាងនេះគឺ

១ - វៀរអាវាស គឺទីអាស្រ័យនៅ ដែលកាលណានៅហើយ និមិត្ត ដែលមិនទាន់កើតក៏មិនកើត និមិត្តដែលកើតហើយក៏បាត់បង់ទៅវិញ ។

២ - វៀរគោចរ គឺផ្លូវទៅដែលឆ្ងាយដាច់ពីអាវាស ឬដែលជិតនឹងអាវាសពេក ដែលរកសុំអាហារមិនបានងាយស្រួល និងមិនសម្បូរ ។

៣ - វៀរពាក្យពេចដែលមិនសប្បាយ ដែលទាក់ទិននឹងតិរច្ឆានកថា គឺកថាដែលមិនឧបការៈដល់បញ្ញា ដែលធ្វើឱ្យនិមិត្តកើតឡើងហើយ បាត់បង់ទៅវិញ។

៤ - វៀរបុគ្គលដែលសម្បូរច្រើនទៅដោយកិលេស ដែលខ្វល់ខ្វាយរវល់តែក្នុងកិលេស ព្រោះធ្វើឱ្យចិត្តកើតសេចក្តីសៅហ្មង ។

៥ - ៦ - វៀរភោជន និងអាកាសដែលមិនសម មិនត្រូវនឹងរាងកាយដែលនឹងធ្វើឱ្យឈឺចាប់គ្រុនរងារ ។

៧ - វៀរឥរិយាបថដែលមិនធ្វើឱ្យចិត្តតាំងមាំ ។ កាលណាវៀរនូវវត្ថុដែលគួរវៀរ និងសេពនូវវត្ថុដែលគួរសេព ហើយអប្បនាសមាធិ ក៏នៅមិនទាន់កើត ក៏នឹងត្រូវបំពេញអប្បនាកោសល្យឱ្យពេញលេញ គឺប្រកបដោយអប្បនាកោសល្យ ចំណេះចេះដឹងឈ្លាសវៃក្នុងធម៌ដែលឧបត្ថម្ភឱ្យឈានចិត្តកើតឡើងបាន ១០ ប្រការគឺ[២៩]

---

[២៩] វិសុទ្ធិមគ្គ បឋវីកសិណនិទ្ទេស

១ - ដោយការធ្វើវត្ថុឱ្យជារបស់ស្អាត គឺទាំងរាងកាយ និងគ្រឿងស្លៀកដណ្តប់ និងទីអាស្រ័យនៅឱ្យស្អាត បើមិនដូច្នោះ ចិត្តក៏មិនភ្លឺថ្លា ។

២ - ដោយការញុំាងសេចក្តីស្មើគ្នានៃឥន្ទ្រិយ ៥ គឺសទ្ធា និង បញ្ញា វីរិយៈ និងសមាធិឱ្យស្មើគ្នាដោយសតិ ។

៣ - ដោយការឈ្លាសវៃចំពោះនិមិត្ត ។

៤ - រមែងផ្គងចិត្តដោយសម័យដែលគួរផ្គង ។

៥ - រមែងសង្កត់ចិត្តដោយសម័យដែលគួរសង្កត់ ។

៦ - រមែងញុំាងចិត្តឱ្យរីករាយក្នុងសម័យដែលគួរឱ្យរីករាយ ។

៧ - រមែងព្រងើយចិត្តក្នុងសម័យដែលគួរព្រងើយ ។

៨ - ដោយការវៀរបុគ្គលអ្នកដែលមិនតាំងមាំ ។

៩ - ដោយសេពនឹងបុគ្គលអ្នកដែលតាំងមាំ ។

១០-ដោយសេចក្តីជាអ្នកមានអធ្យាស្រ័យបង្អោនទៅក្នុងគុណនោះ ៗ ។

បើមិនជាអ្នកឈ្លាសវៃក្នុងអប្បនាកោសល្យ ១០ នេះទេ មហា-កុសលញ្ញាណសម្បយុត្តចិត្ត ក៏មិនអាចបន្ថែមសេចក្តីស្ងប់មាំទាំឡើងទៅទៀត រហូតជាបាទឱ្យអប្បនាសមាធិ គឺរូបាវចរបឋមជ្ឈានចិត្តកើតបានឡើយ ។

ខណៈរូបាវចរបឋមជ្ឈានចិត្ត ដែលជាចិត្តលំដាប់ថ្នាក់ មួយទៀត គឺជាចិត្តភូមិមួយទៀតកើតឡើង ផុតចាកអំពីសភាពចិត្ត ដែលជា

ការមាវថរនោះ វិថីចិត្តនឹងកើតបន្តគ្នាតាមលំដាប់ តាមផ្លូវមនោទ្វារជា **ឈានវិថី** ដូចនេះ

ភវង្គចិត្ត ជា មហាវិបាកញ្ញាណសម្បយុត្ត
ភវង្គចលនៈ ជា មហាវិបាកញ្ញាណសម្បយុត្ត
ភវង្គុបច្ឆេទៈ ជា មហាវិបាកញ្ញាណសម្បយុត្ត
មនោទ្វារាវជ្ជនៈ ជា អហេតុកកិរិយា
បរិកម្ម ជា មហាកុសលញ្ញាណសម្បយុត្ត
ឧបចារៈ ជា មហាកុសលញ្ញាណសម្បយុត្ត
(ប្រភេទដូចនឹងបរិកម្ម)
អនុលោម ជា មហាកុសលញ្ញាណសម្បយុត្ត
(ប្រភេទដូចនឹងបរិកម្ម)
គោត្រភូ ជា មហាកុសលញ្ញាណសម្បយុត្ត
(ប្រភេទដូចនឹងបរិកម្ម)
បឋមជ្ឈានកុសលចិត្ត ជា រូបាវចរកុសលចិត្ត
ភវង្គចិត្ត ជា មហាវិបាកញ្ញាណសម្បយុត្ត

រូបាវចរបឋមជ្ឈានកុសលចិត្តដែលកើតជាគ្រាដំបូងនោះ ត្រឹមតែ ១ ខណៈប៉ុណ្ណោះ ។ ដល់ពេលជាខាងក្រោយស្ទាត់ជំនាញឡើងហើយ ឈានចិត្ត ទើបអាចកើតរលត់បន្តថែមឡើង ៗ បាន ដោយមិនមានភវង្គចិត្តកើតជ្រែកខណ្ឌឡើយតាមកំណត់វេលាដែលតាំងចិត្តទុកបាន ។ ឈាន

វិថីចិត្តដែលកើតរលត់បន្តគ្នា ដោយមិនមាន ភវង្គចិត្តកើតជ្រែកខណ្ឌ សោះនោះ ជា**ឈានសមាបត្តិ** គឺជាការបន្តុះដល់សភាពចិត្តដែលស្ងប់ តាំងណែនក្នុងអារម្មណ៍របស់ឈាន បានតាមកំណត់វេលា ដែលតាំងចិត្តទុក ។

មុនដែលឈានវិថីចិត្តដែលកើតឡើង ត្រូវមានមហាកុសលញាណសម្បយុត្តចិត្តកើតមុនគ្រប់ ៗ គ្រា ។

មហាកុសលជវន ខណៈទី ១ ជាបរិកម្ម គឺជាបរិកម្មនៃអប្បនាសមាធិ ព្រោះតាក់តែងអប្បនា គឺបើមហាកុសលដែលជាបរិកម្មមិនកើតចិត្តខណៈបន្ទាប់តទៅ និងអប្បនាសមាធិ គឺឈានចិត្តក៏កើតមិនបាន ។

មហាកុសលជវន ខណៈទី ២ ជាឧបចារ ព្រោះចូលទៅជិតអប្បនាសមាធិ ។

មហាកុសលជវន ខណៈទី ៣ ជាអនុលោម ព្រោះឧបការៈដល់អប្បនាសមាធិ ។

មហាកុសលជវន ខណៈទី ៤ ជាគោតត្រភូ ព្រោះឆ្លងផុតកាមាវចរភូមិ ដើម្បីឡើងដល់រូបាវចរភូមិ ។

កាលដែលមហាកុសលជវន ខណៈទី ៤ រលត់ហើយជវនវិថីចិត្តខណៈបន្ទាប់តទៅ ទើបជារូបាវចរបឋមជ្ឈានកុសលចិត្ត ។

រូបាវចរឈានកុសលចិត្ត ប្រកបដោយអង្គ ៥ គឺវិតក្ក វិចារ បីតិ សុខ ឯកគ្គតា ។ សូម្បីថា មានសោភណចេតសិកកើតរួមជាមួយក៏ដោយ តែ

អង្គប្រកបដែលធ្វើឱ្យរូបាវចរបឋមជ្ឈានចិត្តកើតនោះ បានដល់ ចេតសិក ៥ ដួងនេះដែលជាបដិបក្ខដល់នីវរណធម៌ គឺអកុសលធម៌ដែលគ្របសង្កត់ រារាំងចិត្តមិនឱ្យដំណើរទៅក្នុងផ្លូវសួ្គ ។ នីវរណធម៌ ៥ គឺ

កាមឆន្ទនីវរណៈ បានដល់ សេចក្តីត្រេកអរ ពេញចិត្តក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។

ព្យាបាទនីវរណៈ បានដល់ សេចក្តីមួរម៉ៅចិត្ត

ថីនមិទ្ធនីវរណៈ បានដល់ សេចក្តីរួញរា ក្រៀមក្រំ និង ការងងុយងោកងក់ ។

ឧទ្ធច្ចកុក្កុច្ចនីវរណៈ បានដល់ សេចក្តីរាយមាយ និងការរំខាន ចិត្ត ។

វិចិកិច្ឆានីវរណៈ បានដល់ សេចក្តីសង្ស័យមិនប្រាកដ ជាក់ ច្បាស់ក្នុងសភាវធម៌ និងក្នុងហេតុក្នុងផល នៃសភាវធម៌ ។

អង្គឈាន ៥ ជាបដិបក្ខដល់នីវរណធម៌ ៥ ដោយ វិតក្កចេតសិក ច្រត់ទាល់ត្រង់អារម្មណ៍ ដែលធ្វើឱ្យចិត្តស្ងប់បានហើយវិចារចេតសិក តាម ឧបត្ថម្ភជ្រោមជ្រែងផ្គងអារម្មណ៍ ដែលវិតក្កចេតសិកចុះច្រត់ទល់ធ្វើឱ្យចិត្ត មិនរាយមាយទៅកាន់អារម្មណ៍ដទៃឡើយ ។ បីតិចេតសិក ជាសភាព ដែលឆ្អែត សុខវេទនាបន្ថែមក្រៃលែងឡើងតាមសេចក្តីឆ្អែតយ៉ាងស្ងប់ នោះ ហើយឯកគ្គតា ដែលអង្គឈាន ៤ ឧបការៈ ទំនុកបម្រុងហើយ

តាំងមាំទាំក្នុងអារម្មណ៍ ដោយអាការនៃបឋមជ្ឈាន ដែលប្រកបដោយ អង្គ ៥ ។

អង្គឈាន ៥ ជាបដិបក្ខដល់នីវរណៈ ៥ ដូចនេះ[៣០] គឺ

១- វិតក្កចេតសិក ជាបដិបក្ខដល់ថីនមិទ្ធនីវរណៈ ព្រោះពេលវិតក្កចេតសិកត្រិះរិះដល់អារម្មណ៍នៃសមថភាវនាច្រើនឡើង ជារឿយ ៗ សេចក្តីរួញរាក្រៀមក្រំ និងការងងុយងោកងក់ ក៏រមែងកើតមិនបាន ។

២- វិចារចេតសិក ជាបដិបក្ខដល់វិចិកិច្ឆានីវរណៈ ពេលវិចារចេតសិកឧបត្តម្ភ ជ្រោមជ្រែង ផ្គងអារម្មណ៍តាមវិតក្កចេតសិក ដែលច្រត់ទល់ចុះទៅក្នុងអារម្មណ៍នៃសមថភាវនាជារឿយ ៗ នោះ សេចក្តីសង្ស័យ សេចក្តីមិនជាក់ច្បាស់ក្នុងចិត្តក្នុងសភាវធម៌ និងក្នុងហេតុផលនៃសភាវធម៌ ក៏កើតមិនបាន ។

៣- បីតិចេតសិក ជាបដិបក្ខដល់ព្យាបាទនីវរណៈ កាលសេចក្តីស្ងប់ក្នុងអារម្មណ៍ នៃសមថភាវនាកើនឡើង បីតិក៏ឆ្អែតស្កប់ក្នុងសេចក្តីស្ងប់នោះ ក្រៃលែងឡើង ធ្វើឱ្យសេចក្តីព្យាបាទមួរម៉ៅចិត្តកើតមិនបានក្នុងរវាងនោះ ។

៤- សុខ (សោមនស្សវេទនា) ជាបដិបក្ខដល់ឧទ្ធច្ចកុក្កុច្ចនីវរណៈ ពេលកំពុងនៅជាសុខក្នុងអារម្មណ៍របស់សមថភាវនា សេចក្តីក្តៅក្រហាយ

---

[៣០] អភិធម្មត្ថវិភាវិនី បរិច្ឆេទទី ២ វិគ្រោះអង្គឈាន

ចិត្ត ការកង្វល់ចិត្ត និងសេចក្តីរាយមាយក្នុងអារម្មណ៍ដទៃ ក៏កើតមិនបាន ព្រោះកំពុងនៅជាសុខ ក្នុងសមថអារម្មណ៍ក្នុងខណៈនោះ ។

៥- ឯកគ្គតាចេតសិក ជាបដិបក្ខដល់កាមច្ឆន្ទនីវរណៈ ព្រោះពេលសមាធិតាំងមាំក្នុងអារម្មណ៍នៃសមថភាវនាហើយ ក៏មិនត្រេកអរក្នុងកាមអារម្មណ៍ណា ។ ឡើយ ។

រូបាវចរបឋមជ្ឈានកុសលចិត្ត ជាអប្បនាសមាធិដែលចុះស៊ប់ណែនក្នុងអារម្មណ៍ដោយអង្គឈាន ៥ ។ ដូច្នោះ សូម្បីដល់ទៅថា រូបាវចរឈានកុសល នឹងកើតឡើងគ្រាដំបូងត្រឹមតែមួយខណៈក៏ដោយ កាលណាភវង្គចិត្តកើតខណ្ឌច្រើនខណៈរលត់ទៅហើយ មនោទ្វារវិថីចិត្តក៏កើតបន្ត ដោយមនោទ្វារាវជ្ជនចិត្តកើតឡើងរំពឹងដល់អង្គនៃឈាន ១ ខណៈ ហើយរលត់ទៅ រួចហើយមហាកុសលញាណសម្បយុត្តចិត្តកើតឡើងពិចារណាអង្គឈាននោះ ៧ ខណៈ ហើយភវង្គចិត្តក៏កើតខណ្ឌ ។ មនោទ្វារវិថីចិត្តកើតឡើង ពិចារណាអង្គឈានមួយក្នុង ១ វារៈ ខណៈដែលមនោទ្វារវិថីចិត្តកើតឡើងពិចារណាអង្គនៃឈាននីមួយ ។ នៃវារៈនីមួយ ។ នោះ ជា**បច្ចវេក្ខណវិថី** ដែលត្រូវកើតចេញអំពីឈានវិថីគ្រប់គ្រា ។ បញ្ញានៃអ្នកដែលបន្លុះរូបាវចរឈានកុសលចិត្ត ទើបដឹងសេចក្តីខុសគ្នានៃអង្គឈានទាំង ៥ គឺដឹងសេចក្តីផ្សេង ។ គ្នានៃវិតក្កចេតសិក និងវិចារចេតសិក ដឹងសេចក្តីផ្សេងគ្នានៃបីតិចេតសិក និងសុខ (សោមន-

ស្សវេទនាចេតសិក) និងដឹងនូវលក្ខណៈនៃឯកគ្គតាចេតសិកដែលជា អប្បនាសមាធិ ។

អ្នកចម្រើនសមថភាវនាត្រូវមានសតិសម្បជញ្ញៈជាប្រក្រតី និងដឹង លក្ខណៈនៃចិត្ត ដែលជាកុសលនិងអកុសលដែលកើតឆ្លាស់ប្តូរគ្នា និង ជ្រែកខណ្ឌគ្នាយ៉ាងរហ័សឱ្យបានត្រឹមត្រូវ ។ បើមិនដូចយ៉ាងនោះទេ ក៏នឹង យល់ខុសថា លោភមូលចិត្តដែលកើតរួមនឹងសោមនស្សវេទនា ជាសេចក្តី ស្ងប់ និងជាកុសល ។

អ្នកចម្រើនសមថភាវនាមិនមានអាការខុសប្រក្រតីណា ។ ឡើយ ព្រោះការចម្រើនសមថភាវនា ជាការចម្រើនកុសលតាមផ្លូវចិត្ត ដែលកាល ណាចិត្តស្ងប់ហើយ ក៏នឹងប្រាកដ តែនិមិត្តនៃអារម្មណ៍ដែលធ្វើឱ្យចិត្ត បង្អោនទៅជាកុសលតាំងមាំក្រៃលែងឡើង ដូចអ្នកដែលចម្រើនអាបោ-កសិណ ក៏មាននិមិត្តនៃអាបោកសិណជាអារម្មណ៍ នឹងមិនឃើញនរក សួគ៌ ទេវតា ហេតុការណ៍ រឿងរ៉ាវផ្សេង ។ ឡើយ ។

ខណៈដែលធ្វើសមាធិហើយឃើញនូវភាពផ្សេង ។ ខណៈនោះ មិនមែនសមថភាវនា ។

ការចម្រើនសមថភាវនា ត្រូវជាមហាកុសលញាណសម្បយុត្តចិត្ត ដែលស្ងប់ ព្រោះរលឹកនូវអារម្មណ៍ណាមួយនៃសមថភាវនាក្នុង ៤០ អារម្មណ៍ ។ សូម្បីលោភមូលចិត្ត ឬមហាកុសលញាណវិប្បយុត្តចិត្ត នឹង មានអារម្មណ៍ណាមួយក្នុង ៤០ អារម្មណ៍ ក៏មិនមែនជាសមថភាវនាដែរ

ដូចក្មេង ឬមនុស្សចាស់ ដែលទន្ទេញថា ពុទ្ធោ ។ ដោយមិនបានរំលឹកដល់ព្រះពុទ្ធគុណប្រការផ្សេង ។ ក៏មិនមែនជា មហាកុសលញាណសម្ប-យុត្តចិត្ត ។ អ្នកដែលឃើញសាកសព ហើយភ័យខ្លាច ក៏ជាទោសមូលចិត្ត មិនមែនមហាកុសលញាណសម្បយុត្ត ។ អ្នកដែលព្យាយាមធ្វើទាំងមិនជាក់ប្រាកដ ក្នុងចិត្តត្រង់ខ្យល់ដកដង្ហើម ដោយមិនទាំងដឹងថា ព្រោះហេតុអ្វីចិត្តទើបនឹងស្ងប់បាន ក៏មិនមែនជាមហាកុសលញាណសម្បយុត្ត ។ កសិណដទៃ ។ និងអារម្មណ៍ដទៃ ។ នៃសមថភាវនានោះ មហាកុសល-ញាណសម្បយុត្តចិត្ត ត្រូវពិចារណាដោយត្រឹមត្រូវ ទើបចិត្តស្ងប់បាន ដោយន័យតែមួយដូចនឹងការចម្រើនបឋវីកសិណ ។

កាលអ្នកបន្លុះបឋមជ្ឈានកុសល ឃើញទោសនៃវិតក្កចេតសិក ដែលជាចេតសិកច្រត់ទល់ចុះក្នុងអារម្មណ៍ថា ប្រក្រតីរមែងច្រត់ទល់ចុះក្នុងអារម្មណ៍ ដែលជាកាមារម្មណ៍ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ទើបនៅជិតបង្កើយនឹងអកុសលធម៌ទាំងឡាយ បើអាចឱ្យឈានចិត្តនោះ ប្រាសចាកវិតក្កចេតសិក ឱ្យមានតែវិចារចេតសិក បីតិ សុខ ឯកគ្គតា ក៏រមែងស្ងប់ប្រណីតជាង ហើយទើបព្យាយាមរលឹកដល់ អារម្មណ៍នៃបឋមជ្ឈានកុសល ដែលបានបន្លុះហើយ រួចព្យាយាមថែរក្សាឱ្យចិត្តស្ងប់តាំងមាំត្រង់អារម្មណ៍នៃបឋមជ្ឈាន ដោយមិនឱ្យវិតក្កចេតសិកត្រូវច្រត់ទល់ក្នុងអារម្មណ៍នោះឡើយ ដែលនឹងសម្រេចបានកាលណាដល់ព្រមដោយ**វសី ៥** គឺសេចក្តីជំនាញ វាងវៃក្នុងឈាន ៥ ប្រការសិន ។

វសី ៥ គឺ[៣១]

១-អាវជ្ជនវសី ជំនាញក្នុងការនឹកដល់បឋមជ្ឈានក្នុងស្ថានទី និងខណៈតាមដែលប្រាថ្នា ។

២-សមាបជ្ជនវសី ជំនាញក្នុងការចូលឈានគឺឱ្យឈានចិត្ត កើតបានក្នុងស្ថានទី និងខណៈតាមដែលប្រាថ្នា ។

៣-អធិដ្ឋានវសី ជំនាញក្នុងការឱ្យឈានចិត្តកើតរលត់បន្ត យូរឆាប់តិចច្រើនក្នុងស្ថានទី និងខណៈតាមដែលប្រាថ្នា ។

៤-វុដ្ឋានវសី ជំនាញក្នុងការចេញចាកឈានបានក្នុងស្ថានទី និងខណៈ ឮ តាមដែលប្រាថ្នា ។

៥-បច្ចវេក្ខណវសី ជំនាញក្នុងការនឹកដល់អង្គឈាននីមួយ ៗ បានក្នុងស្ថានទី និងខណៈតាមដែលប្រាថ្នា ។

ការដែលបន្លុះឈានចិត្តថ្នាក់ខ្ពស់ឡើងទៅបាននោះ ត្រូវឃើញទោសរបស់អង្គឈានថ្នាក់ដើម ៗ ហើយលះអង្គឈានបានតាមលំដាប់ គឺ

ទុតិយជ្ឈាន លះវិតក្កៈ ទើបប្រកបជាមួយអង្គឈាន ៤ គឺវិចារៈ បីតិ សុខៈ ឯកគ្គតា ។

តតិយជ្ឈាន លះវិចារៈ ទើបប្រកបជាមួយអង្គឈាន ៣ គឺបីតិ សុខៈ ឯកគ្គតា ។

---

[៣១] ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ មហាវគ្គ ញាណកថា

ចតុត្ថជ្ឈាន លះបីតិ ទើបប្រកបជាមួយអង្គឈាន ២ គឺ សុខៈ ឯកគ្គតា

បញ្ចមជ្ឈាន លះសុខៈ ទើបប្រកបជាមួយអង្គឈាន ២ គឺ ឧបេក្ខា ឯកគ្គតា ។

ការលះអង្គឈានទៅនីមួយ ៗ នោះ ជាឈានដោយបញ្ចកន័យ គឺដោយន័យនៃឈាន ៥ ។

ចំពោះអ្នកដែលបញ្ញាអាចលះវិតក្កៈ និងវិចារៈបានព្រមគ្នានោះ ជាឈានដោយចតុក្កន័យ គឺដោយន័យនៃឈាន ៤ ដូចនេះ

ទុតិយជ្ឈាន លះវិតក្កៈ វិចារៈ ទើបប្រកបដោយអង្គឈាន ៣ គឺ បីតិ សុខៈ ឯកគ្គតា ។

តតិយជ្ឈាន លះបីតិ ទើបប្រកបដោយអង្គឈាន ២ គឺ សុខៈ ឯកគ្គតា ។

ចតុត្ថជ្ឈាន លះសុខៈ ទើបប្រកបដោយអង្គឈាន ២ គឺ ឧបេក្ខា ឯកគ្គតា ។

ទុតិយជ្ឈានដោយចតុក្កន័យ ក៏គឺតតិយជ្ឈានដោយបញ្ចកន័យ ។

តតិយជ្ឈានដោយចតុក្កន័យ ក៏គឺចតុត្ថជ្ឈានដោយបញ្ចកន័យ ។

ចតុត្ថជ្ឈានដោយចតុក្កន័យ ក៏គឺបញ្ចមជ្ឈានដោយបញ្ចកន័យ ។

បើខ្វះនូវវសីហើយ ការលះអង្គឈានថ្នាក់ដើម ៗ ដើម្បីបន្ទុះឈានថ្នាក់ខ្ពស់ឡើងជារឿយ ៗ នោះ ក៏ប្រព្រឹត្តទៅមិនបានឡើយ ។

កាលណាឈានវិថីចិត្តរលត់ហើយ បច្ចវេក្ខណវិថីត្រូវកើតតគ្រប់លើក ។

ការរំងាប់កិលេសដោយការចម្រើនសមថភាវនា មិនមែនជាការរំលត់កិលេសជាសមុច្ឆេទ ដូច្នេះ ទើបឈានចិត្តអាចទ្រុឌទ្រោមអន់ថយ គឺកើតយឺតមិនជំនាញវាងវៃ ដូចពីដើមក៏មាន ឬអាចនឹងមិនកើតទាល់តែសោះក៏មាន ។ ដូច្នេះ ដែលឈានចិត្តនឹងកើតបាន ជំនាញវាងវៃនោះ ទើបត្រូវមានវសីគ្រប់ ៗ ឈាននៅជាដរាប (សេចក្តីលំអិតមាននៅក្នុងវិសុទ្ធិមគ្គ)

អារម្មណ៍នៃសមថភាវនា ៤០ នោះ អារម្មណ៍ខ្លះចិត្តក៏ស្ងប់បានមិនដល់ឧបចារសមាធិទេ អារម្មណ៍ខ្លះចិត្តក៏ស្ងប់បានដល់ឧបចារសមាធិ អារម្មណ៍ខ្លះចិត្តក៏ស្ងប់ បានដល់បឋមជ្ឈានប៉ុណ្ណោះ អារម្មណ៍ខ្លះ ក៏ស្ងប់បានដល់ចតុត្ថជ្ឈានបញ្ចកន័យ អារម្មណ៍ខ្លះក៏ស្ងប់បានដល់ បញ្ចម-ជ្ឈាន ហើយអារម្មណ៍ខ្លះ ក៏ជាអារម្មណ៍ចំពោះតែបញ្ចមជ្ឈាន ប៉ុណ្ណោះ ដូចយ៉ាងនេះគឺអនុស្សតិ ៦ បានដល់ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ ចាគានុស្សតិ ១ សីលានុស្សតិ ១ ទេវតានុស្សតិ ១ ។ អ្នកដែលមិនមែន ព្រះអរិយបុគ្គលរលឹកដល់អនុស្សតិ ៦ នេះ ចិត្តស្ងប់បានមិនដល់ឧបចារសមាធិទេ ចំពោះព្រះអរិយបុគ្គលនោះអាចស្ងប់បានដល់ឧបចារសមាធិប៉ុណ្ណោះ មិនដល់អប្បនាសមាធិឡើយ ។

អនុស្សតិ ២ គឺឧបសមានុស្សតិ ការរលឹកដល់ព្រះនិព្វាន និង មរណានុស្សតិ ការរលឹកដល់សេចក្តីស្លាប់នោះ មរណានុស្សតិ សូប់បាន ដល់ឧបចារសមាធិប៉ុណ្ណោះ តែឧបសមានុស្សតិសូប់ បានដល់ឧបចារ-សមាធិ ចំពោះតែអ្នកដែលជាព្រះអរិយបុគ្គលប៉ុណ្ណោះ ។

អាហារបដិកូលសញ្ញា ១ គឺការរលឹកដល់សេចក្តី បដិកូលនៃ អាហារ ចិត្តសូប់បានដល់ឧបចារសមាធិ ។

ចតុធាតុវវដ្ឋាន ១ គឺការរលឹកដល់ធាតុដី ទឹក ភ្លើង ខ្យល់ ត្រង់កាយ ចិត្តសូប់ បានដល់ ឧបចារសមាធិ ។

អសុភ ១០ គឺការរលឹកដល់សភាពនៃសាកសព ១០ យ៉ាង ចិត្តសូប់បានដល់បឋមជ្ឈាន ។

កាយគតាសតិ (អនុស្សតិ) ១ គឺការនឹកដល់សេចក្តីមិនគួរ ប្រាថ្នានៃចំណែកផ្សេង ។ គឺអាការ ៣២ នៃកាយមួយចំណែក ដូចសក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម ចិត្តអាចសូប់បាន ដល់បឋមជ្ឈាន ។

អានាបាណស្សតិ (អនុស្សតិ) ១ ការរលឹកដល់ខ្យល់ដង្ហើម ចិត្តសូប់ ដល់បញ្ចមជ្ឈាន ។

កសិណ ១០ ចិត្តសូប់បានដល់បញ្ចមជ្ឈាន ។

ព្រហ្មវិហារ ៣ គឺមេត្តា ១ ករុណា ១ មុទិតា ១ ចិត្តសូប់ បានចតុត្ថជ្ឈានដោយបញ្ចកន័យ (តតិយជ្ឈានដោយចតុក្កន័យ) ។

ព្រហ្មវិហារ ១ គឺឧបេក្ខាព្រហ្មវិហារ កាលណាចិត្តស្ងប់ចាកពីព្រហ្មវិហារ ៣ ដល់ចតុត្ថជ្ឈានហើយ ទើបចម្រើនឧបេក្ខាព្រហ្មវិហារធម៌តទៅទៀតបាន ។ ក្នុងបណ្តាព្រហ្មវិហារធម៌ ៤ ឧបេក្ខាព្រហ្មវិហារ ទើបមានអារម្មណ៍ចំពោះតែបញ្ចមជ្ឈាន តែមួយឈានប៉ុណ្ណោះ ។

អរូបជ្ឈាន ៤ គឺបញ្ចមជ្ឈានដែលមិនមានរូបជាអារម្មណ៍ ។ អ្នកដែលនឹងចម្រើនអរូបជ្ឈានបាននោះ ត្រូវបន្លុះរូបបញ្ចមជ្ឈានសិន ពេលឃើញទោសនៃរូបបញ្ចមជ្ឈាន ថាសូម្បីនឹងដល់ជារូបជ្ឈានថ្នាក់ខ្ពស់បំផុត គឺ ថ្នាក់រូបបញ្ចមជ្ឈានក៏ពិតមែនក៏ដោយ តែកាលណានៅមានរូបជាអារម្មណ៍ ក៏នៅជិតបង្កើយញាប់ញ័រដល់ការដែលនឹងបង្អោនទៅដល់រូបដែលជាកាមារម្មណ៍បានដោយងាយ គួរនឹងលើករូបដែលជាអារម្មណ៍ចេញ ហើយបង្អោនចិត្តទៅដល់អារម្មណ៍ដែលមិនមែនរូប ដែលស្ងប់ប្រណីតជាងរូបទៅទៀត ។

កាលណាលើកបើករូបចេញ ហើយរលឹកដល់សេចក្តី មិនអាចមានទីបំផុតនៃអរូបជាអារម្មណ៍ រហូតអប្បនាសមាធិកើត ក៏ជាអរូបជ្ឈានកុសល ដោយវិថីចិត្តកើតរលត់បន្តគ្នាតាមផ្លូវមនោទ្វារ ដូចតែគ្នានឹងឈានវិថី ហើយនិងត្រូវប្រកបដោយវសី ៥ ទើបនឹងបន្លុះដល់អរូបជ្ឈានថ្នាក់ខ្ពស់ឡើង ៗ បាន ។

អរូបជ្ឈានមាន ៤ ថ្នាក់ ជាបញ្ចមជ្ឈានទាំង ៤ ថ្នាក់ តែផ្សេងគ្នាត្រង់

អារម្មណ៍ល្អិតឡើង ជាលំដាប់ថ្នាក់ គឺ

អរូបជ្ឈានទី ១ អាកាសានញ្ចាយតនឈានចិត្តមានអាកាស ដែលមិនមានទីបំផុតជាអារម្មណ៍ ។

អរូបជ្ឈានទី ២ វិញ្ញាណញ្ចាយតនឈានចិត្ត មានអាកាសានញ្ចាយតនចិត្ត ជាអារម្មណ៍ព្រោះពិចារណាឃើញថា អាកាសដែលមិនមានទីបំផុតជាអារម្មណ៍នោះ ក៏នៅមិនទាន់ល្អិតប្រណីតស្មើនឹង អាកាសានញ្ចាយតនចិត្ត ដែលមានអាកាសមិនមានទីបំផុតជាអារម្មណ៍ដែរ ដូច្នោះ ទើបកន្លងអាកាសដែលមិនមានទីបំផុតជាអារម្មណ៍ ហើយបង្អោនទៅដល់អាកាសានញ្ចាយតនចិត្តជាអារម្មណ៍ រហូតអប្បនាសមាធិកើតឡើង ជាអរូបជ្ឈានទី ២ គឺវិញ្ញាណញ្ចាយតនចិត្ត ដែលជាអរូបជ្ឈានចិត្តមានវិញ្ញាណ គឺ អាកាសាញ្ចាយតនចិត្ត ជាអារម្មណ៍ ។

អរូបជ្ឈានទី ៣ អាកិញ្ចញ្ញាយតនឈានចិត្ត មានភាវៈដែលមិនមានអ្វីជាអារម្មណ៍ ព្រោះជាភាវៈដែលមិនមានអាកាសានញ្ចាយតនចិត្ត ជាអារម្មណ៍ហើយ កាលពិចារណាឃើញថា ពេលនៅមានអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ ក៏នៅមិនទាន់សូប់ មិនល្អិតប្រណីតស្មើដូចនឹងមិនមានអ្វីជាអារម្មណ៍ឡើយ ទើបកន្លងនូវអាកាសានញ្ចាយតនចិត្ត ដែលជាអារម្មណ៍ ហើយបង្អោនទៅដល់ភាវៈដែលមិនមានអាកាសានញ្ចាយតនចិត្ត ជាអារម្មណ៍រហូតអប្បនាសមាធិកើតឡើងជាអរូបជ្ឈានទី ៣ គឺ

អាកិញ្ចញ្ញាយតនឈានចិត្ត មានភាវៈដែលមិនមានអ្វីឡើយជាអារម្មណ៍ ព្រោះមិនមានអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ ។

អរូបជ្ឈានទី ៤ នេវសញ្ញានាសញ្ញាយតនឈានចិត្ត មានអាកិញ្ចញ្ញាយតនឈានចិត្តជាអារម្មណ៍ ។ កាលណាពិចារណាឃើញថា អាកិញ្ចញ្ញាយតនឈានចិត្ត ដែលមានភាវៈមិនមានអ្វីឡើយជាអារម្មណ៍ នោះ ជាសភាវៈដែលល្អិតណាស់ ទើបបង្អោនទៅដល់ភាវៈនៃអាកិញ្ចញ្ញាយតនចិត្តដែលល្អិតនោះ រហូតអប្បនាសមាធិចិត្តកើតឡើងជាអរូបជ្ឈានទី ៤ គឺនេវសញ្ញានាសញ្ញាយតនឈានចិត្ត ជាសភាពដែលសញ្ញាព្រមទាំងសម្បយុត្តធម៌ទាំងឡាយ ដែលកើតរួមគ្នានោះល្អិតរហូត ពោលមិនបានថាមាន ឬមិនមាន ព្រោះមិនបានធ្វើកិច្ចនៃសម្បយុត្តធម៌ទាំងឡាយពេញកម្លាំង ទើបមិនបានថាមាន ឬ មិនមានសម្បយុត្តធម៌នោះ ។ ។ អរូបជ្ឈានទី ៤ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតន គឺមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ការចម្រើនសមថភាវនា រហូតចិត្តស្ងប់ចាកអកុសលធម៌ទាំងឡាយដល់ថ្នាក់អរូបជ្ឈាននោះ ជាចិត្តដែលមានកម្លាំង អាចហ៊ឹកហាត់ឱ្យជាប្រយោជន៍តាមសេចក្តីប៉ងប្រាថ្នាបាន ដូចរលឹកជាតិបាន អធិដ្ឋានឱ្យកើតទិព្វចក្ខុឃើញវត្ថុផ្សេង ។ ដែលនៅឆ្ងាយ ឬដែលកំបាំងបាន អធិដ្ឋានឱ្យកើតសោតទិព្វ ឮសំឡេងផ្សេង ។ ជិត ឬឆ្ងាយបាន សម្រេចឥទ្ធិបាដិហារិយ

ផ្សេង ៗ ដូចដើរលើទឹក ជ្រែកក្នុងដី ហោះហើរក្នុងអាកាស និងនិមិត្តនូវវត្ថុ ផ្សេង ៗ បានជាដើម ។ ប៉ុន្តែការនឹងហ្វឹកហាត់អប់រំឱ្យកើតគុណវិសេស ម្យ៉ាង ៗ នេះ នឹងចាំបាច់ជាអ្នកមានសមត្ថភាពក្នុងកសិណគ្រប់កសិណ និងឈានសមាបត្តិទាំង ៨ (រូបឈាន ៤ ដោយចតុក្កន័យ និងអរូបឈាន ៤) យ៉ាងប្រសើរក្រៃលែង ហើយនឹងត្រូវហ្វឹកហាត់ចិត្តដោយអការ ១៤ គឺ[៣២]

១- កសិណានុលោមតោ ចូលឈានតាមលំដាប់កសិណ ។

២-កសិណបដិលោមតោ ចូលឈានត្រឡប់បញ្ច្រាស់កសិណ ។

៣- កសិណានុលោមបដិលោមតោ ចូលឈានតាមលំដាប់កសិណ ហើយត្រឡប់បញ្ច្រាស់កសិណ ។

៤-ឈានានុលោមតោ ចូលឈានតាមលំដាប់ឈានតាំងពីបឋមជ្ឈានដល់នេវសញ្ញានាសញ្ញាយតនឈាន ។

៥-ឈានបដិលោមតោ ចូលឈានដោយត្រឡប់បញ្ច្រាស់ឈានតាមលំដាប់ តាំងពីនេវសញ្ញានាសញ្ញាយតនឈាន ដល់បឋមជ្ឈាន។

៦- ឈានានុលោមបដិលោមតោ ចូលឈានតាមលំដាប់ឈានហើយត្រឡប់បញ្ច្រាស់ឈានតាមលំដាប់ ។

---

[៣២] វិសុទ្ធិមគ្គ សមាធិនិទ្ទេស ឥទ្ធិវិធ្ធនិទ្ទេស

៧- ឈានឆុន្នកតោ ចូលឈានដោយឆ្លងឈាន តែមិនឆ្លងកសិណ ។

៨- កសិណុក្ករន្តកតោ ចូលឈានដោយឆ្លងកសិណ តែមិនឆ្លងឈាន ។

៩-ឈានកសិណុក្ករន្តកតោ ចូលឈានដោយឆ្លងឈាន និងឆ្លងកសិណ ។

១០- អង្គសង្ខន្តិតោ ចូលឈានដោយកន្លងអង្គ ។

១១- អារម្មណសង្ខិន្តិតោ ចូលឈានដោយកន្លងអារម្មណ៍។

១២- អង្គារម្មណសង្ខន្តិតោ ចូលឈានដោយកន្លងទាំងអង្គ និងទាំងអារម្មណ៍ ។

១៣-អង្គវវដ្ឋាបនតោ ចូលឈានដោយកំណត់អង្គនៃឈាននីមួយ ៗ ។

១៤- អារម្មណវវដ្ឋាបនតោ ចូលឈានដោយកំណត់អារម្មណ៍នៃឈាននីមួយៗ ។

ការធ្វើណា ៗ ឬប្រព្រឹត្តកម្មណា ៗ ដែលមើលទៅហាក់ដូចជាគុណវិសេសទាំងឡាយនោះ ប៉ុន្តែមិនមែនគុណវិសេសពិតប្រាកដទេកាលណាហេតុមិនសមគួរដល់ផល ។

សេចក្តីក្នុងវិសុទ្ធិមគ្គសម្តែងថា អ្នកផ្តើមបំពេញព្យាយាម នៅមិនទាន់ហ្វឹកហាត់ចិត្តដោយអាការ ១៤ ទាំងនេះ និងញុំាងឥទ្ធិឫទ្ធិផ្សេង ៗ ឱ្យសម្រេចបាននោះ មិនមែនហានៈនឹងប្រព្រឹត្តទៅបានឡើយ ។

សូម្បីក្នុងការបរិកម្មកសិណ គឺការផ្តើមបំពេញសមថភាវនានោះ ក្នុងរាប់រយ ឬរាប់ពាន់នាក់នោះរមែងអាចនឹងធ្វើសម្រេចបាន ប្រហែលត្រឹមតែម្នាក់ ។ ហើយកាលណាចម្រើនសមថភាវនា គឺបរិកម្មកសិណទៅហើយ ត្រង់ឧគ្គហនិមិត្តនឹងកើតបាន ក្នុងរាប់រយ ឬរាប់ពាន់នាក់នោះ រមែងអាចនឹងសម្រេចបាន ប្រហែលត្រឹមតែម្នាក់ ។ កាលណា ឧគ្គហនិមិត្តកើតហើយ ការថែរក្សាទុកនូវចិត្តឱ្យស្ងប់តាំងមាំឡើង រហូតបដិភាគនិមិត្តកើតហើយ បន្លុះអប្បនាសមាធិនោះ ក្នុងរាប់រយ ឬរាប់ពាន់នាក់ រមែងអាចនឹងសម្រេចបាន ត្រឹមតែម្នាក់ ។ ក្នុងបណ្តាអ្នកដែលសម្រេចឈានសមាបត្តិ ៨ ហើយនោះ ក្នុងរាប់រយ រាប់ពាន់នាក់ នឹងហ្វឹកហាត់ចិត្តដោយអាការ ១៤ នេះបានប្រហែលត្រឹមតែមួយនាក់ ។ ក្នុងបណ្តាអ្នកដែលហ្វឹកហាត់ចិត្តដោយអាការ ១៤ បានហើយ ក្នុងរាប់រយ រាប់ពាន់នាក់ នឹងអាចសម្តែងឫទ្ធិបានប្រហែលត្រឹមតែមួយនាក់ ហើយក្នុងបណ្តាអ្នកដែលសម្តែងឫទ្ធិបានរាប់រយ រាប់ពាន់នាក់នោះ អ្នកដែលនឹងសម្តែងឫទ្ធិបានយ៉ាងឆាប់រហ័សទាន់ពេលនោះ គឺនឹងអាចធ្វើសម្រេចបានត្រឹមតែមួយនាក់ប៉ុណ្ណោះ ។

សូម្បីក្នុងរឿងការរលឹកជាតិ ក៏មានន័យដូចគ្នា ។ នរណាទៅនឹងបានឧបចារសមាធិ កាលណាមិនមែនចិត្តដែលស្ងប់ដោយមហាកុសលញាណសម្បយុត្ត នរណាទៅនឹងបានអប្បនាសមាធិដែលជាបឋមជ្ឈាន នរណាទៅនឹងបានទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន និងអរូបជ្ឈាន នរណាទៅនឹងហ្វឹកហាត់អប់រំរលឹកជាតិ ដោយហ្វឹកហាត់រលឹកត្រឡប់បញ្ច្រាស់ពីខណៈនេះទៅគ្រប់ ។ ខណៈ រហូតដល់ព្រឹកមិញ ថយដេញរហូតដល់យប់មិញ ព្រឹកថ្ងៃម្សិល រឿយ ។ រលឹកថយដេញទៅ ។ ដោយចិត្ត ដែលស្ងប់មាំទាំរហូតដល់បដិសន្ធិ ហើយទើបរហូតដល់ ខណៈចុងក្រោយ ថ្ងៃចុងក្រោយនៃជាតិមុន រួចហើយទើបថយដេញទៅ ។ តាមលំដាប់ដោយកម្លាំងនៃឈានចិត្ត ដែលហ្វឹកហាត់ អប់រំឱ្យជំនាញពូកែ ជាកម្លាំង កាលណាអធិដ្ឋានឱ្យមហាកុសលញាណសម្បយុត្តចិត្តកើតឡើងរលឹកបានសម្រេចពីខណៈមួយ ហើយថយដេញទៅខណៈមួយ ។ ទៀត ។

អ្នកដែលសិក្សាយល់ហេតុនិងផល នៃគុណវិសេសទាំងឡាយដោយល្អិតល្អន់ ទើបដឹងបានថា ព្រឹត្តិការណ៍ណាជាគុណវិសេសពិតប្រាកដ ហើយព្រឹត្តិការណ៍ណាដែលមិនមែនគុណវិសេស ដែលពិតប្រាកដ ។

ការចម្រើនសមថភាវនា មិនមែនការរំលត់កិលេសជាសមុច្ឆេទព្រោះមិនមែនការប្រចក្សនូវលក្ខណៈនៃសភាវធម៌ ជាប្រក្រតីតាមសេចក្តីពិតឡើយ ។

កាលណាឈានចិត្តមិនសាបសូន្យ ហើយឈានវិថីចិត្ត កើតមុនចុតិចិត្ត ជាកម្មប្បច្ច័យឱ្យឈានវិបាកចិត្តបដិសន្ធិក្នុងព្រហ្មភូមិជាន់ផ្សេង ។ ប៉ុន្តែ កាលណា អស់អាយុហើយនៃព្រហ្មភូមិនោះ ។ រួចហើយក៏ត្រូវត្រឡប់មក ដល់សេចក្តីជាយ៉ាងនេះទៀត គឺត្រេកអរ ពេញចិត្ត ជាប់ជំពាក់ ក្នុងតួខ្លួន ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ ការធ្លាប់ចម្រើនសមថភាវនា សន្សំមកខ្លះក្នុងជាតិមុន ។ ក្នុងសង្សារវដ្ត អាចនឹងធ្វើឱ្យលោកខ្លះមាន ហេតុការណ៍ដឹកនាំបណ្តាលឱ្យកើតឡើងក្នុងចិត្ត គំនិតជាដើម ។ ចំណែក អ្នកដែលធ្វើសមាធិ ហើយឃើញវត្ថុផ្សេង ។ ឃើញហេតុការណ៍ ផ្សេង ។ នោះ កាលណាមិនមែនការអប់រំសមថភាវនាដោយមហាកុសលញាណ-សម្បយុត្តចិត្ត ដែលស្ងប់ចុះណែនតាំងមាំក្នុងអារម្មណ៍តាមលំដាប់ រហូត ជាឈានចិត្តថ្នាក់ផ្សេង ។ ទេ ដែលរមែងនឹងប្រព្រឹត្តទៅ បានលំបាក យ៉ាងក្រៃលែងនោះ ក៏មិនមែនគុណវិសេសដែលជាឧត្តរិមនុស្សធម៌ គឺធម៌ ដែលក្រៃលែងជាងប្រក្រតីនៃមនុស្សទាំងឡាយ ។ ដូច្នោះកាលណាធ្វើ សមាធិហើយ ឃើញវត្ថុផ្សេង ។ ខ្លះ ឃើញហេតុការណ៍ផ្សេង ។ ជា ដើមនោះ ទើបជាផលបន្តិចបន្តួច ខុសខ្លះ ត្រូវខ្លះ នៃសមាធិដែលមិនមែន ការចម្រើនសមថភាវនាទេ ។

ការចម្រើនសមថភាវនា ដែលនឹងបន្លះដល់សូម្បីឧបចារសមាធិ ក៏ដោយ ក៏សែនលំបាកណាស់ទៅហើយ ព្រោះជាប្រក្រតីកាលណា អារម្មណ៍ណាប៉ះខ្ទប់ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក៏រមែង

បណ្តោយទៅតាមអារម្មណ៍នោះ ដោយលោភៈខ្លះ ទោសៈខ្លះ មោហៈខ្លះ ។ កុសលដែលប្រព្រឹត្តក្នុងទានខ្លះ ក្នុងសីលខ្លះ ក្នុងភាវនាខ្លះនោះ ក្នុងមួយថ្ងៃ ។ មានតិចតួចណាស់ កាលណាធៀប នឹងអកុសលដែលកើតឡើង យ៉ាងរហ័សជាប្រចាំតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ហើយការចម្រើនសមថភាវនានោះ ក៏រំលត់កិលេសមិនបាន កាលកិលេសកើតឡើងគ្របសង្កត់ចិត្តខណៈណា សមថភាវនាដែលព្យាយាមអប់រំ មករហូតដល់ថ្នាក់អាចសម្តែងឥទ្ធិបាដិហារិយផ្សេង ។ បានក៏វិនាសបាត់អស់ទៅវិញ ។

មុននៃការត្រាស់ដឹង នៃព្រះដ៏មានព្រះភាគ ក៏មានអ្នកបំពេញព្យាយាម ចម្រើននូវសមថភាវនា រហូតដល់បន្តុះ ដល់នេវសញ្ញានាសញ្ញាយតនឈាន ហើយនឹងហ្វឹកហាត់អប់រំចិត្ត រហូតដល់អធិដ្ឋានឱ្យមានភ្នែកទិព្វ ត្រចៀកទិព្វ រលឹកជាតិបាន និងអាចធ្វើឥទ្ធិបាដិហារិយបានដែរ ប៉ុន្តែសូម្បីយ៉ាងនោះក៏ដោយ លោកទាំងនោះក៏នៅមិនទាន់អាចដឹងច្បាស់នូវអរិយសច្ចធម៌បានឡើយ កាលណាមិនបានអប់រំចម្រើនហេតុ គឺវិបស្សនាភាវនា រហូតដល់បរិបូណ៌ នឹងជាបច្ច័យឱ្យដឹងច្បាស់នូវអរិយសច្ចធម៌បាន ហើយលោកខ្លះក៏ញាុំងការយល់ខុស ប្រកាន់មាំក្នុងការបដិបត្តិដែលមិនមែនគន្លងផ្លូវឱ្យដឹងច្បាស់នូវអរិយសច្ចធម៌ទៀត សូម្បីពេលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង និងទ្រង់សម្តែងព្រះធម៌ហើយក៏ដោយ ។ អ្នកឃើញច្បាស់នូវអរិយសច្ចធម៌ ដល់សេចក្តីជាព្រះអរិយសាវក ដែល

មិនបានបន្លុះឈានចិត្ត ក៏មានច្រើនជាងព្រះអរិយសាវ័ក អ្នកដឹងច្បាស់នូវអរិយសច្ចធម៌ ព្រមដោយអង្គនៃឈានថ្នាក់ផ្សេង ៗ[๓๓] ។

ទាំងនេះរមែងសម្តែងឱ្យឃើញថា ការចម្រើនសមថភាវនា ដែលត្រឹមត្រូវនោះ ជាសភាវៈធ្វើបានដោយលំបាកប៉ុណ្ណាទៅ ។

[๓๓] សំយុត្តនិកាយ សគាថវគ្គ វិគីសសំយុត្ត បវារណាសូត្រ

ទិបស្សនាភាវនា

វិបស្សនាភាវនា

កិលេសមាន ៣ ថ្នាក់ គឺអនុស័យកិលេស បរិយុដ្ឋានកិលេស វិតិក្កមកិលេស ។

វិតិក្កមកិលេស ជាកិលេសយ៉ាងគ្រោតគ្រាត ធ្វើឱ្យប្រព្រឹត្តកន្លងជាទុច្ចរិតកម្មតាមផ្លូវកាយ វាចា ។ វិរតិ គឺលះវៀរនូវវិតិក្កមកិលេសបានដោយសីល ។

បរិយុដ្ឋានកិលេស ជាកិលេសយ៉ាងកណ្តាល ដែលកើតរួមជាមួយនឹងអកុសលចិត្ត តែមិនដល់ថ្នាក់ប្រព្រឹត្តកន្លងជាទុច្ចរិតកម្មទេ ។ រំងាប់បរិយុដ្ឋានកិលេសបានម្តងម្កាល ជាវិក្ខម្ភនបហាន ដោយឈានកុសលចិត្ត ។

អនុស័យកិលេស ជាកិលេសយ៉ាងល្អិត ពេលណានៅមិនទាន់បានរំលត់កិលេសទេ អនុស័យកិលេសក៏ស្រាំនៅក្នុងចិត្ត ដែលកើតរលត់បន្តគ្នា ជាក្រសែ ជាបច្ច័យឱ្យកើតនូវបរិយុដ្ឋានកិលេសទៀត ។ កិលេសទាំងឡាយនឹងរលត់អស់ជាសមុច្ឆេទបហាន មិនកើតទៀតឡើយ កាលណា លោកុត្តរមគ្គចិត្តនឹងដឹងច្បាស់នូវអរិយសច្ចធម៌ ដោយប្រចក្សច្បាស់សភាពនៃព្រះនិព្វានតាមលំដាប់ថ្នាក់នៃមគ្គចិត្ត ដែលបហានកិលេសជាសមុច្ឆេទតាមលំដាប់ថ្នាក់នៃមគ្គចិត្តនោះ ។ ។

មុនការត្រាស់ដឹងនៃព្រះដ៏មានព្រះភាគនោះ មានអ្នកដែលរក្សាសីលវិរតិទុច្ចរិត និងចម្រើនសមថភាវនារហូតដល់អរូបជ្ឈានថ្នាក់ខ្ពស់

បំផុត គឺនេវសញ្ញានាសញ្ញាយតនឈាន រំងាប់កិលេសបានម្តងម្កាលជាវិក្ខម្ភនបហាន ប៉ុន្តែមិនមានអ្នកណារំលត់នូវអនុស័យកិលេសបានឡើយ ។ កាលដែលព្រះមានព្រះភាគទ្រង់បំពេញនូវព្រះបារមី ៤ អសង្ខ្យៃយកប្រៃមួយសែនកប្បមកហើយទើបព្រះអង្គបានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់បានសម្តែងគន្លងផ្លូវបដិបត្តិ ដើម្បីការដឹងច្បាស់អរិយសច្ចធម៌ ទើបមាននូវអរិយសង្ឃសាវ័កបន្លុះអរិយសច្ចធម៌ រំលត់កិលេសបានជាចំនួនច្រើន ។

បន្តរហូតមកដរាបដល់មានអ្នកសិក្សា និងបដិបត្តិធម៌តាមដែលព្រះដ៏មានព្រះភាគបានត្រាស់ដឹង និងទ្រង់បានសម្តែងព្រះធម៌ទុកដោយល្អិតសុខម រហូតអស់ ៤៥ ព្រះវស្សា ។ ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកហើយនោះ សុខុម ល្អិតជ្រាលជ្រៅ ព្រោះព្រះអង្គទ្រង់សម្តែងនូវលក្ខណៈនៃសភាវធម៌ទាំងឡាយដែលព្រះអង្គត្រាស់ដឹង ដោយព្រះអង្គទ្រង់ប្រចក្សច្បាស់តាមសេចក្តីពិតនៃសភាវធម៌នោះ ។ ។ **បើអ្នកណាមិនសិក្សានូវព្រះធម៌ដែលព្រះអង្គ ទ្រង់សម្តែងទុកមកល្អហើយដោយល្អិតល្អន់ ឱ្យបានយល់យ៉ាងត្រឹមត្រូវទេ ក៏រមែងមិនអាចអប់រំចម្រើនបញ្ញា និងប្រចក្សច្បាស់នូវលក្ខណៈនៃសភាវធម៌ និងរំលត់កិលេសបានឡើយ ។**

ការដែលបញ្ញានឹងប្រចក្សច្បាស់នូវលក្ខណៈនៃសភាវធម៌ តាមសេចក្តីពិតបាននោះ ក៏ចាំបាច់នឹងត្រូវយល់តាំងពីដើមដំបូងថា សភាវធម៌ដែលបញ្ញានឹងប្រចក្សច្បាស់តាមសេចក្តីពិតនោះ គឺអ្វីទៅ គឺគ្រប់សភាវៈ

ដែលជារបស់ពិតដែលកំពុងប្រាកដ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក្នុងខណៈនេះឯង ។ ស្តែងគ្រប់ខណៈដែល ឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងនឹកគិតនោះ មិនបានដឹងលក្ខណៈនៃសភាវធម៌ត្រង់តាមសេចក្តីពិតនៃសភាវធម៌នោះ ។ ឡើយ ។

ព្រះមានព្រះភាគទ្រង់សម្តែងសភាវធម៌ ដែលកើតឡើងប្រាកដប្រព្រឹត្តទៅតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រាល់ ។ ថ្ងៃគ្រប់ ។ ខណៈដោយល្អិតដើម្បីឱ្យឃើញទោស របស់អកុសលធម៌ និងឃើញភ័យក្នុងសង្សារវដ្ត ដែលកាលណាមិនទាន់ឃើញទោស ឃើញភ័យនៃសង្សារ-វដ្ត ក៏រមែងមិនព្យាយាមអប់រំចម្រើនវិបស្សនា ដែលជាបញ្ញាដែលប្រចក្សច្បាស់នូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ជាប្រក្រតីតាមសេចក្តីពិត រហូតដល់រំលត់កិលេសបាន ។

ការចម្រើនសមថភាវនា និងការចម្រើនវិបស្សនាភាវនាផ្សេងគ្នា ត្រង់អារម្មណ៍ និងលំដាប់ថ្នាក់នៃបញ្ញា ។ សមថភាវនាមានអារម្មណ៍ដែលមហាកុសលញាណសម្បយុត្តចិត្ត ពិចារណាហើយស្ងប់ រហូតតាំងមាំចុះណែនត្រង់អារម្មណ៍តែមួយនោះ ។ វិបស្សនាភាវនាមានបរមត្ថអារម្មណ៍ គឺ នាមធម៌ និងរូបធម៌ដែលកើតឡើងប្រាកដហើយរលត់ទៅវិញ ជាអារម្មណ៍ដែលមហាកុសលញាណសម្បយុត្ត ផ្តើមសង្កេតពិចារណាអារម្មណ៍មួយ ។ សន្សឹម ។ ជារឿយ ។ រហូតដល់ដឹងថាជាសភាវធម៌តែម៉្យាង តែមួយប្រភេទ ដែលមិនមែនសត្វ បុគ្គល តួខ្លួនឡើយ ។ ផលនៃសមថភាវនា

ធ្វើឱ្យកើតជាព្រហ្មបុគ្គលក្នុងព្រហ្មភូមិ ។ ផលនៃវិបស្សនាភាវនាធ្វើឱ្យបញ្ញាដឹងច្បាស់នូវសភាវធម៌ តាមសេចក្តីពិត និងរលត់កិលេសជាសមុច្ឆេទតាមថ្នាក់នៃលោកុត្តរមគ្គចិត្ត ដែលមានព្រះនិព្វានជាអារម្មណ៍ រហូតដល់អរហត្តមគ្គចិត្តដែលរំលត់កិលេសទាំងអស់ មិនមានសេសសល់ឡើយ ទើបរំលត់សង្សារវដ្ត មិនកើតទៀតឡើយ ។

អ្នកអប់រំចម្រើនវិបស្សនាត្រូវជាអ្នកត្រង់ ដែលដឹងថានៅមានកិលេសគ្រប់បែបយ៉ាង និងមិនត្រូវការទៅរំលត់លោភៈឱ្យអស់សិននោះទេ ។ ចំពោះអ្នកដែលជាបុថុជ្ជន នឹងឆ្លងទៅដល់បានសភាពជាព្រះអរហន្ត តែម្តងភ្លាម ។ នោះមិនបានឡើយ ព្រោះត្រូវរំលត់នូវលោភៈ ដែលកើតរួមនឹងសក្កាយទិដ្ឋិ ដែលប្រកាន់នូវសភាវធម៌ដែលកើតរួមគ្នា ជាតួខ្លួន សត្វ បុគ្គល ឱ្យអស់ជាសមុច្ឆេទសិន ទើបកិលេសដទៃ ។ នឹងរំលត់ដាច់អស់ជាសមុច្ឆេទ បន្តបន្ទាប់តាមលំដាប់បាន ។

កាលណាមិនដឹងថា ខណៈដែលកំពុងឃើញមិនមែនតួខ្លួន សត្វ បុគ្គល តើនឹងលះកិលេស គឺសេចក្តីស្រឡាញ់ ស្អប់ ។ ល ។ បានយ៉ាងណា ? តាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ក៏ដោយន័យដូចគ្នា ។

សភាវធម៌នីមួយ ។ កើតឡើងហើយក៏រលត់អស់ទៅវិញយ៉ាងរហ័សរាល់ ។ វេលា ព្រះមានព្រះភាគព្រះអង្គទ្រង់សម្តែងគន្លងផ្លូវបដិបត្តិដែលនឹងអប់រំចម្រើនបញ្ញា ឱ្យដឹងច្បាស់នូវសភាវធម៌ទាំងនោះ តាមសេចក្តីពិត

ថា មានផ្លូវតែមួយគត់ គឺការចម្រើនអរិយមគ្គមានអង្គ ៨ បានដល់ សម្មាទិដ្ឋិ (បញ្ញាចេតសិក) ១ សម្មាសង្កប្បៈ (វិតក្កចេតសិក) ១ សម្មាវាចា (សម្មាវាចាចេតសិក) ១ សម្មាកម្មន្តៈ (សម្មាកម្មន្តចេតសិក) ១ សម្មាអាជីវៈ (សម្មាអាជីវចេតសិក) ១ សម្មាវាយាមៈ (វីរិយចេតសិក) ១ សម្មាសតិ (សតិចេតសិក) ១ សម្មាសមាធិ (ឯកគ្គតាចេតសិក) ១ ។

ពេលដំបូងដែលលោកុត្តរចិត្តមិនទាន់កើតនោះ មគ្គមានអង្គ ៥ (វៀរវិរតិ ព្រោះវិរតិកើត មួយដួង ។ វិរតិចេតសិកទាំង ៣ ដួង នឹងកើតព្រមគ្នាបាន ចំពោះតែក្នុងលោកុត្តរចិត្តប៉ុណ្ណោះ) រមែងកើតឡើងធ្វើកិច្ចរួមគ្នាក្នុងខណៈដែលសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលជា នាមធម៌ ឬរូបធម៌យ៉ាងណាមួយតាមភ្នែក ឬតាមត្រចៀក ឬតាមច្រមុះ ឬតាមអណ្តាត ឬតាមកាយ ឬតាមចិត្ត ហើយបញ្ញាចេតសិកដែលកើតរួមនឹងសម្មាសតិក្នុងខណៈនោះ ក៏ផ្តើម សង្កេតពិចារណា ដឹងលក្ខណៈនៃនាមធម៌ ឬរូបធម៌នោះ ។ បន្តិចម្តង ។ សន្សឹម ។ ជារឿយ ។ ទៅរហូតបានដឹងច្បាស់ថាជានាមធម៌ ឬរូបធម៌ ។

សភាវធម៌ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត នោះចំណែកជា **សតិប្បដ្ឋាន ៤** កាលណាសតិកើតឡើងរលឹកដឹងលក្ខណៈនៃសភាវធម៌នោះ ។ គឺ

១- កាយានុបស្សនាសតិប្បដ្ឋាន ខណៈណាដែលសតិកើតឡើងរលឹកដឹងលក្ខណៈ នៃរូបត្រង់កាយ ខណៈនោះជាកាយនុបស្សនាសតិប្ប-ដ្ឋាន ។

២-វេទនានុបស្សនាសតិប្បដ្ឋាន ខណៈណាដែលសតិកើតឡើងរលឹកដឹងលក្ខណៈនៃសេចក្តីដឹងខ្លួនដែលកំពុងប្រាកដ ខណៈនោះជាវេទនា-នុបស្សនាសតិប្បដ្ឋាន ។

៣- ចិត្តានុបស្សនាសតិប្បដ្ឋាន ខណៈណាដែលសតិកើតឡើងរលឹកដឹងលក្ខណៈនៃចិត្តប្រភេទផ្សេង ៗ ខណៈនោះជាចិត្តានុបស្សនា-សតិប្បដ្ឋាន ។

៤- ធម្មានុបស្សនាសតិប្បដ្ឋាន ខណៈណាដែលសតិកើតឡើងរលឹកដឹងលក្ខណៈនៃរូបធម៌ និងនាមធម៌ដទៃ ។ ខណៈនោះជាធម្មានុបស្ស-នាសតិប្បដ្ឋាន ។

ពាក្យថា **សតិប្បដ្ឋាន** មាន ៣ ន័យ គឺ

១- សតិប្បដ្ឋាន ជាសតិចេតសិកដែលកើតព្រម នឹងញាណសម្ប-យុត្តចិត្ត ដែលរលឹកដឹងអារម្មណ៍ ដែលជាសតិប្បដ្ឋាន ។

២- សតិប្បដ្ឋានជាបរមត្ថអារម្មណ៍ គឺនាមធម៌ និងរូបធម៌ ដែលសតិរលឹកដឹង (សតិប្បដ្ឋាន ៤) ។

៣- សតិប្បដ្ឋានការដែលព្រះសាស្តាប្រព្រឹត្ត គន្លងសេចក្តីសោម-នស្ស និងទោមនស្ស ក្នុងក្រុមសាវ័កអ្នកបដិបត្តិ ៣ យ៉ាង (បដិបត្តិតាម

មិនបដិបត្តិតាម បដិបត្តិតាមខ្លះ មិនបដិបត្តិតាមខ្លះ) ។

អរិយមគ្គមានអង្គ ៨ គឺការអប់រំចម្រើនសតិប្បដ្ឋាន ៤ រលឹកដឹងលក្ខណៈនៃសភាវធម៌ មួយ ៗ ដែលកើតឡើងប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក្នុងមួយថ្ងៃ ។ នោះ រមែងកើតយ៉ាងលំបាក ហើយមិនជាញឹកញាប់ទេដោយហេតុគឺ អវិជ្ជា លោភៈ និងអកុសលធម៌ទាំងឡាយ ដែលបានសន្សំកពូនមកយូរយារណាស់ហើយក្នុងសង្សារវដ្ត ហើយសូម្បីក្នុងជាតិនេះតាំងពីកើតមករហូតរាល់ថ្ងៃ ។ អ្នកដែលយល់ហេតុ និងផលរបស់សភាវធម៌តាមសេចក្តីពិត ទើបជាអ្នកអត់ធន់យ៉ាងក្រៃលែងដល់ការនឹងស្តាប់នូវព្រះធម៌ សិក្សានូវព្រះធម៌ ពិចារណានូវព្រះធម៌ ឱ្យយល់នូវរឿងនៃសភាវធម៌តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រហូតទាល់តែនឹងជាបច្ច័យតាក់តែងឱ្យសតិប្បដ្ឋានកើតឡើងរលឹកដឹង សង្កេត ពិចារណា សិក្សាលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដត្រឹមត្រូវបាន តាមដែលបានស្តាប់ និងបានយល់ហើយនោះ ។ ធម៌ទាំងឡាយសូម្បីសតិប្បដ្ឋាន និងអរិយមគ្គមានអង្គ ៨ ក៏ជាអនត្តាដែរ រមែងកើតឡើងបាននៅពេលមានហេតុបច្ច័យ គឺកាលណាមហាកុសលញាណសម្បយុត្តសន្សំមកសមគួរហើយ ធ្វើឱ្យមិនបែរត្រឡប់ទៅប្រព្រឹត្តបដិបត្តិគន្លងផ្លូវដែលមិនមែនជាការរលឹកដឹង សង្កេត ពិចារណាសភាពនៃនាមធម៌ និងរូបធម៌តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដែលកំពុងប្រាកដនោះឡើយ ។

អ្នកអប់រំបញ្ញាជាអ្នកត្រង់ កាលណាសតិប្បដ្ឋានកើតក៏ដឹងថា ផ្សេងពីខណៈ ដែលវង្វេងភ្លេចសតិ ។ កាលសតិប្បដ្ឋានកើតក្នុងពេលដំបូង ៗ នោះ នៅមិនទាន់ដឹងជាក់នូវលក្ខណៈនៃនាមធម៌ និងរូបធម៌ទេ ។ សេចក្តីព្យាយាមដែលកើតព្រមសតិប្បដ្ឋានដែលរលឹកដឹង សង្កេត ពិចារណា លក្ខណៈនៃនាមធម៌ និងរូបធម៌ដែលប្រាកដ ទើបជា **សម្មប្បធាន ៤** គឺ សំវរបធាន ១ បហានបធាន ១ ភាវនាបធាន ១ អនុរក្ខនាបធាន ១ ។

សំវរបធាន គឺព្យាយាមដើម្បីមិនឱ្យអកុសលធម៌ (ដែលមិនទាន់កើត) កើតឡើង ។

បហានបធាន គឺព្យាយាមដើម្បីលះអកុសលធម៌ដែលកើតឡើងហើយ ។

ភាវនាបធាន គឺព្យាយាមដើម្បីឱ្យកុសលធម៌ (ដែលមិនទាន់កើត) កើតឡើង ។

អនុរក្ខនាបធាន គឺព្យាយាមដើម្បីសេចក្តីចម្រើន តាំងមាំ បរិបូណ៌នៃកុសលធម៌ដែលកើតឡើងហើយ ។

សេចក្តីព្យាយាមដែលជាសម្មប្បធាន ៤ នោះរមែងជាបាទឱ្យសម្រេចផលរួមនឹងសម្បយុត្តធម៌ទាំងឡាយ ដែលកើតរួមនឹងសភាវធម៌ ដែលជា **ឥទ្ធិបាទ ៤** គឺ

១- ឆន្ទិទ្ធិបាទ បានដល់ ឆន្ទចេតសិក សេចក្តីពេញចិត្តនឹងសង្កេត ពិចារណា ដឹងលក្ខណៈនៃសភាពនាមធម៌ និងរូបធម៌ដែលកំពុង

ប្រាកដតាមសេចក្តីពិត[៣៤] ។ ការញុំាងផលសម្រេចឱ្យកើតឡើង ដោយអាស្រ័យសេចក្តីពេញចិត្តនោះ គប្បីឃើញដូចជា បុត្រ អាមាត្យមិនប្រមាទក្នុងការទំនុកបម្រុងរក្សាព្រះរាជា ទើបបានឋានន្តរៈ ដោយអាស្រ័យការបម្រុងរក្សានោះ។

២-វីរិយិទ្ធិបាទ បានដល់ វីរិយចេតសិក សេចក្តីព្យាយាម នឹងសង្កេត ពិចារណា ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកំពុងប្រាកដ[៣៥] ។ ការញុំាងផលឱ្យសម្រេចកើតឡើង ដោយអាស្រ័យសេចក្តីព្យាយាមនោះ គប្បីឃើញដូចជា បុត្រ អាមាត្យ ដែលញុំាងឱ្យព្រះរាជា សព្វព្រះរាជហឫទ័យដោយសេចក្តីជាអ្នកក្លាហានក្នុងការងាររួមហើយបាននូវឋានន្តរៈ ។

៣-ចិត្តិទ្ធិបាទ បានដល់ ចិត្ត[៣៦] ។ ការញុំាងផល សម្រេចឱ្យកើតឡើងដោយ អាស្រ័យចិត្តនោះ គប្បីឃើញដូចជាបុត្រ អាមាត្យ ដែលបានឋានន្តរៈ ព្រោះសេចក្តីដល់ដោយល្អនៃជាតិ ។

៤-វីមំសិទ្ធិបាទ បានដល់ បញ្ញាចេតសិក ដែលត្រិះរិះ សង្កេតពិចារណា លក្ខណៈនៃសភាវធម៌ ។ ការញុំាងផលសម្រេចឱ្យកើតឡើង[៣៧]

---

[៣៤] សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ ឥទ្ធិបាទវិភង្គនិទ្ទេស

[៣៥] សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ ឥទ្ធិបាទវិភង្គនិទ្ទេស

[៣៦] សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ ឥទ្ធិបាទវិភង្គនិទ្ទេស

[៣៧] សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ ឥទ្ធិបាទវិភង្គនិទ្ទេស

ដោយអាស្រ័យបញ្ញានោះ គប្បីឃើញដូចជា បុត្រ អាមាត្យដែលបានហានន្តរៈ ព្រោះអាស្រ័យចំណេះចេះដឹង ។

បុត្រ អាមាត្យទាំងនោះ ទោះជាទាំងអស់ក៏ដោយដល់ហើយនូវហានន្តរៈ ដោយកម្លាំងនៃភាវៈដែលជាទីអាស្រ័យ (ដោយសមត្ថភាព) នៃខ្លួន ។

ការដែលឥទ្ធិបាទ ៤ ទាំងនេះ នឹងដំណើរទៅបានក៏ត្រូវអាស្រ័យការសន្សំ ចម្រើនឡើងនៃ**ឥន្ទ្រិយ ៥** ដែលជាសភាវធម៌ ជាធំក្នុងការនាំទៅកាន់ សម្មាមគ្គ គន្លងផ្លូវបដិបត្តិ ដែលត្រឹមត្រូវ ។ ឥន្ទ្រិយ ៥ គឺ

១-**សទ្ធិន្ទ្រិយ** បានដល់ សទ្ធាចេតសិក ជាធំក្នុងការមានសទ្ធាដែលនឹងរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ។

២-**វីរិយិន្ទ្រិយ** បានដល់ វីរិយចេតសិក ជាធំមិនខ្ជិលច្រអូសមិនរុញរា ក្នុងការរលឹកលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ។

៣-**សតិន្ទ្រិយ** បានដល់ សតិចេតសិក ជាធំក្នុងការមិនវង្វេងភ្លេចរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលប្រាកដ ។

៤-**សមាធិន្ទ្រិយ**បានដល់ ឯកគ្គតាចេតសិក ជាធំក្នុងការតាំងមាំក្នុងអារម្មណ៍ដែលប្រាកដ ។

៥-**បញ្ញិន្ទ្រិយ** បានដល់ បញ្ញាចេតសិក ជាធំក្នុងការត្រិះរិះពិចារណា សង្កេតសិក្សា លក្ខណៈនៃសភាវធម៌ដែលប្រាកដ ។

កាលណាឥន្ទ្រិយ ៥ ចម្រើនកើនឡើងជាសភាវធម៌ដែលមានកម្លាំង មិនញាប់ញ័រ ក្នុងការពិចារណាអារម្មណ៍ណា ៗ ដែលប្រាកដក៏ជាសភាវធម៌ដែលជា **ពលៈ ៥** គឺ

១ - **សទ្ធាពលៈ** មិនកម្រើកញាប់ញ័រទៅដោយការមិនមានសទ្ធា ។

២ - **វីរិយពលៈ** មិនកម្រើកញាប់ញ័រទៅដោយសេចក្តីខ្ជិលច្រអូសរុញរា ។

៣ - **សតិពលៈ** មិនកម្រើកញាប់ញ័រ ក្នុងការរលឹកដឹងលក្ខណៈនៃសភាវធម៌ ណា ៗ ដែលប្រាកដ ។

៤ - **សមាធិពលៈ** មិនកម្រើកញាប់ញ័រទៅដោយការរវើរវាយមិនតាំងមាំ ។

៥ - **បញ្ញាពលៈ** មិនកម្រើកញាប់ញ័រទៅដោយសេចក្តីមិនដឹង ។

ការដែលសទ្ធា វីរិយៈ សតិ សមាធិ នឹងជាសភាវធម៌ ដែលមានកម្លាំងបាន គឺកាលបញ្ញាជាពលៈ ព្រោះដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ទាំងអស់ឡើង ទើបមិនកម្រើកញាប់ញ័រនិងរលឹកដឹងបានថា ខណៈដែលកំពុងឃើញ ជានាមធម៌ និង ជារូបធម៌យ៉ាងណា ? ខណៈដែលកំពុងឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈក៏ដោយន័យដូចគ្នា ។

កាលណាបញ្ញាដែលកើតព្រមនឹងសតិរលឹកដឹងលក្ខណៈ នៃនាមធម៌ និងរូបធម៌សម្បូរជាវិបស្សនាញាណថ្នាក់នីមួយៗហើយ ក៏ប្រកប

ដោយ ពោជ្ឈង្គ ៧ គឺអង្គធម៌នៃការត្រាស់ដឹងអរិយសច្ចធម៌ ។ ពោជ្ឈង្គ ៧ គឺ

១ - សតិសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺសតិចេតសិក

២ - ធម្មវិចយសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺបញ្ញាចេតសិក

៣ - វីរិយសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺវីរិយចេតសិក

៤ - បីតិសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺបីតិចេតសិក

៥ - បស្សទ្ធិសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺកាយបស្សទ្ធិចេតសិក និងចិត្តបស្សទ្ធិចេតសិក ។

៦ - សមាធិសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺឯកគ្គតាចេតសិក

៧ - ឧបេក្ខាសម្ពោជ្ឈង្គ

អង្គនៃការត្រាស់ដឹង គឺតត្រមជ្ឈត្តតាចេតសិក

កាលណាបញ្ញាអប់រំសម្បូរព្រមទាំងដឹងច្បាស់នូវអរិយសច្ចធម៌ ប្រកបដោយអង្គនៃការត្រាស់ដឹង គឺពោជ្ឈង្គ ៧ សម្បូរដោយពោធិបក្ខិយធម៌

៣៧ (សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គទាំង ៧ មគ្គមានអង្គ ៨) ហើយលោកុត្តរចិត្ត ប្រកបដោយមគ្គមានអង្គ ៨ គ្រប់ទាំង ៨ អង្គ គឺ

សម្មាទិដ្ឋិ

សម្មាសង្កប្ប

សម្មាវាចា

សម្មាកម្មន្ត

សម្មាអាជីវ

សម្មាវាយាម

សម្មាសតិ

សម្មាសមាធិ ក៏កើតឡើងប្រចក្សច្បាស់នូវព្រះនិព្វាន ជា**មគ្គវិថី** តាមផ្លូវមនោទ្វារដូចនេះ គឺ

ភវង្គៈ ជាវិបាកញាណសម្បយុត្តចិត្ត

ភវង្គចលនៈ ជាវិបាកញាណសម្បយុត្តចិត្ត (ប្រភេទដូចគ្នានឹងភវង្គៈ)

ភវង្គុបច្ឆេទៈ ជាវិបាកញាណសម្បយុត្តចិត្ត (ប្រភេទដូចគ្នានឹងភវង្គៈ)

មនោទ្វារាវជ្ជនៈ ជាកិរិយាចិត្ត

ជវនវិថីចិត្ត

- **បរិកម្ម** ជាមហាកុសលញាណសម្បយុត្តចិត្ត
- **ឧបចារៈ** ជាមហាកុសលញាណសម្បយុត្តចិត្ត (ប្រភេទដូចគ្នានឹងបរិកម្ម)
- **អនុលោម** ជាមហាកុសលញាណសម្បយុត្តចិត្ត (ប្រភេទដូចគ្នានឹងបរិកម្ម)
- **គោត្រភូ** ជាមហាកុសលញាណសម្បយុត្តចិត្ត (ប្រភេទដូចគ្នានឹងបរិកម្ម)
- **សោតាបត្តិមគ្គចិត្ត** ជាលោកុត្តរកុសលចិត្ត

ជវនវិថីចិត្ត

- **សោតាបត្តិផលចិត្ត** ជាលោកុត្តរវិបាកចិត្ត
- **សោតាបត្តិផលចិត្ត** ជាលោកុត្តរវិបាកចិត្ត
- **ភវង្គចិត្ត** ជាវិបាកញាណសម្បយុត្តចិត្ត

បើជាលោកុត្តរឈានចិត្តថ្នាក់ណា ក៏កើតរួមនឹងអង្គឈានថ្នាក់នោះ គឺបើជាលោកុត្តរទុតិយជ្ឈាន ក៏មិនមានវិតក្កចេតសិកដែលជាសម្មាសង្កប្បៈ កើតរួមជាមួយ បើជាលោកុត្តតតិយជ្ឈាន ក៏មិនមានវិចារចេតសិកកើតរួមជាមួយ បើជាលោកុត្តចតុត្ថជ្ឈាន ក៏មិនមានបីតិចេតសិកកើតរួមជាមួយ បើជាលោកុត្តរបញ្ចមជ្ឈាន ក៏មានឧបេក្ខាវេទនាកើតរួមជាមួយជំនួសសោមនស្សវេទនា ។

មគ្គវិថីចិត្ត នៃអ្នកបន្លុះអរិយសច្ចធម៌បានរហ័សនោះ ជាតិក្នុបុគ្គលមិនចាំបាច់ត្រូវមានបរិកម្មឡើយ ដូច្នោះមគ្គជវនវិថីទើបមាន ឧបចារៈ ១ ខណៈ អនុលោម ១ ខណៈ គោត្រភូ ១ ខណៈ មគ្គចិត្ត ១ ខណៈ និងផលចិត្តថែមពី ២ ខណៈ ត្រូវជា ៣ ខណៈ រួមជាជវនវិថីចិត្ត ៧ ខណៈ ។

កាលណាមគ្គវិថីចិត្តរលត់ទៅហើយ ភវង្គចិត្តកើតបន្តច្រើនខណៈហើយ បច្ចវេក្ខណវិថីក៏កើតឡើង ពិចារណាមគ្គចិត្តវារៈ ១ ផលចិត្តវារៈ ១ ព្រះនិព្វានវារៈ ១ កិលេសដែលរលត់ហើយវារៈ ១ កិលេសដែលនៅសល់វារៈ ១ រួមជាបច្ចវេក្ខណវិថី ៥ វារៈ ។ កាលមគ្គវិថីរលត់ទៅហើយ បច្ចវេក្ខណវិថីត្រូវកើតបន្តគ្រប់ពេល អាស្រ័យហេតុនេះ ទើបព្រះអរិយបុគ្គលមិនយល់ខុសក្នុងគុណធម៌ ដែលខ្លួនបានសម្រេច គឺព្រះសោតាបន្ន-បុគ្គល មិនយល់ខុសថា លោកជាព្រះសកទាគាមិបុគ្គល ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តក៏ដោយន័យដូចគ្នា ។

ការបន្លុះនូវអរិយសច្ចធម៌ថ្នាក់បន្តបន្ទាប់ គឺសកទាគាមិវិថី អនាគាមិវិថី និងអរហត្តមគ្គវិថីនោះ មហាកុសលដែលជាគោត្រភូ ក៏ផ្លាស់ជាវោទាន (ផ្ងផង់ឡើង) ព្រោះលោកបានឆ្លងផុតពីភាពជាបុថុជ្ជនហើយ ។

មុនដែលមគ្គវិថីនឹងកើតឡើងបាននោះ មហាកុសលញាណសម្ប-យុត្តចិត្ត កើតឡើងរលឹកសិក្សា ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌តាំងតែអំពីជាតិមួយ ។ មករហូតទាល់តែបញ្ញាដែលសង្កេត ដឹងលក្ខណៈនៃ

នាមធម៌ និងរូបធម៌មានការកើនឡើងៗ ។ កាលណាបញ្ញាតាំងមាំដល់ថ្នាក់ណា មហាកុសលញាណសម្បយុត្តចិត្ត ដែលជាវិបស្សនាញាណ ក៏កើតឡើងប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌តាមលំដាប់ថ្នាក់នៃវិបស្សនាញាណ តាមផ្លូវមនោទ្វារ គឺ

វិបស្សនាញាណទី ១ នាមរូបបរិច្ឆេទញាណ

មហាកុសលញាណសម្បយុត្តចិត្តកើតឡើង ប្រចក្សនូវលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលចែកញែកដាច់ពីគ្នាត្រង់អារម្មណ៍មួយ ។ លោកប្រាកដសភាពដែលសូន្យទទេចាកតួខ្លួន ខណៈនោះមិនមាន អត្ត-សញ្ញាដែលធ្លាប់ចាំនូវសភាវធម៌រួមគ្នាជាលោក ។ កាលណាសភាវធម៌ខណៈនោះ ប្រាកដលក្ខណៈដែលជាអនត្តា សញ្ញាចាំលក្ខណៈដែលជាអនត្តានៃសភាវធម៌នោះ ។ ទើបនឹងផ្តើមមានបាន ហើយសតិប្បដ្ឋាន ក៏នឹងត្រូវរលឹកដល់អនត្តសញ្ញាដែលបានប្រចក្សហើយពេលពិចារណាលក្ខណៈនៃនាមធម៌ និងរូបធម៌ដទៃ ។ បន្តបន្ទាប់ ព្រោះថាបើមិនរលឹកដល់អនត្តសញ្ញាដែលបានប្រចក្សហើយ ក្នុងនាមរូបបរិច្ឆេទញាណ បន្តែមឡើងទៀតទេ អត្តសញ្ញាដែលសន្សំកពូនមកជាយូរយារក្នុងសង្សារវដ្តហើយនោះ ក៏អស់ទៅមិនបានឡើយ ។

វិបស្សនាញាណទី ២ បច្ចយបរិគ្គហញាណ

កាលណាវិបស្សនាញាណរលត់អស់ទៅហើយ លោកក៏ប្រាកដរួមគ្នាដូចដើម ទើបអ្នកចម្រើនសតិប្បដ្ឋានដឹងជាក់ច្បាស់នូវសេចក្តីផ្សេងគ្នានៃលក្ខណៈដែលវិបស្សនាញាណកើតឡើង និងខណៈដែលមិនមែនវិបស្សនាញាណ ។ កាលណាវិបស្សនាញាណរលត់អស់ហើយ សេចក្តីមិនដឹង សេចក្តីសង្ស័យក្នុងនាមធម៌ និងរូបធម៌ដទៃ ។ ក៏កើតបានទៀត ព្រោះសេចក្តីមិនដឹង និងសេចក្តីសង្ស័យ មិនទាន់រលត់អស់ជាសមុច្ឆេទ ។ នាមរូបបរិច្ឆេទញាណជាញាតបរិញ្ញា គឺញាណដែលដឹងចំពោះតែលក្ខណៈនៃសភាវធម៌ដែលប្រាកដក្នុងខណៈដែលជាវិបស្សនាញាណប៉ុណ្ណោះ ក្នុងខណៈដែលជាវិបស្សនាញាណនោះ មិនមានសេចក្តីមិនដឹង និងសេចក្តីសង្ស័យនូវលក្ខណៈធម៌ដែលប្រាកដឡើយ ។ នាមរូបបរិច្ឆេទញាណ ជាវិបស្សនាថ្នាក់ដំបូង ដែលនាំផ្លូវទៅដល់វិបស្សនាញាណថ្នាក់បន្តបន្ទាប់ ។ ទៀត ដែលប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌កើតឡើង ។

កាលណាសតិប្បដ្ឋានរលឹកដឹង និងពិចារណាសង្កេតនូវលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលប្រាកដ ត ។ ទៅទៀត រមែងពិចារណាដឹងលក្ខណៈដែលអារម្មណ៍នីមួយ ។ ប្រាកដថា សភាពដឹងមួយប្រភេទ ។ នោះរមែងកើតឡើងតាមបច្ច័យ គឺអារម្មណ៍ បើអារម្មណ៍នោះ ។ មិនប្រាកដ នាមធម៌ដែលដឹងអារម្មណ៍ក៏កើតមិនបានដែរ ការប្រាកដនៃ

អារម្មណ៍នីមួយ ។ រមែងទើបធ្វើឱ្យបញ្ញាឃើញសភាពការណ៍ជាបច្ច័យ នៃធម៌ដែលកំពុងប្រាកដ ធ្វើឱ្យដឹងលក្ខណៈ ដែលជាអនត្តានៃធម៌ទាំង ឡាយសន្សឹម ។ លះបង់នូវការស្គុងគំនិតជាប់តាមអារម្មណ៍ ដោយ សេចក្តីជាតួខ្លួន ។ កាលណាមគ្គមានអង្គ ៨ (ធម្មតាមានអង្គ ៥) ដែលជាសង្ខារក្ខន្ធចម្រើន សម្បូរឡើងខណៈណា ក៏តាក់តែងឱ្យ វិបស្សនាញាណទី ២ គឺបច្ចយបរិគ្គហញាណកើតឡើងប្រចក្សការកើត ឡើងនៃនាមធម៌ និងរូបធម៌តាមបច្ច័យផ្សេង ។ ក្នុងខណៈដែលសភាវធម៌ នោះ ។ កើតឡើងដូចជាប្រចក្សនៃការកើតឡើងនៃនាមឮ ឬ សំឡេង ប្រចក្សនូវការកើតឡើងនៃសុខវេទនា ឬទុក្ខវេទនា ឬនាមនឹកគិត ដែល ប្រាកដដោយសភាពដែលចែកដាច់ពីគ្នា នៃអារម្មណ៍នីមួយ ។ ដោយ លក្ខណៈសូន្យទទេចាកតួខ្លួនជាដើម ។

វិបស្សនាញាណប្រចក្សច្បាស់លក្ខណៈនៃសភាវធម៌ ដែលកើត ឡើងប្រាកដតាមប្រក្រតី តែជាការប្រចក្សច្បាស់លក្ខណៈនៃសភាវធម៌ តាមផ្លូវមនោទ្វារ ដែលចែកដាច់លក្ខណៈនៃអារម្មណ៍នីមួយ ។ ដោយ លក្ខណៈដែលសូន្យទទេចាកតួខ្លួន និងចាកវត្ថុជារបស់ខ្លួន ។ កាលណា វិបស្សនាញាណរលត់អស់ហើយ លោកក៏ប្រាកដរួមគ្នាដូចដើម ។

វិបស្សនាញាណទី ៣ សម្មសនញាណ

សម្មសនញាណជាបញ្ញាដែលប្រចក្សច្បាស់ ការកើត រលត់បន្តគ្នាយ៉ាងរហ័សនៃនាមធម៌ និងរូបធម៌ ។ កាលណាមិនមែនវិបស្សនាញាណ ទោះជានឹងពិចារណាដឹងថានាមធម៌ និងរូបធម៌កើតរលត់យ៉ាងរហ័ស ក៏ដោយ ប៉ុន្តែការកើត រលត់បន្តគ្នាយ៉ាងរហ័សនៃនាមធម៌ និងរូបធម៌ ក៏មិនប្រាកដដដែល ឬសូម្បីក្នុងវិបស្សនាញាណទី ១ និងទី ២ ក៏ដោយ ការប្រចក្សច្បាស់លក្ខណៈនៃនាមធម៌ និងរូបធម៌ ក៏ត្រឹមតែជាការប្រចក្សចំពោះលក្ខណៈនៃនាមធម៌ និងរូបធម៌មួយយ៉ាង ។ ប៉ុណ្ណោះ ។

វិបស្សនាញាណទី ១ ទី ២ ទី ៣ ជាតរុណវិបស្សនា ជាវិបស្សនាញាណថ្នាក់ដើមដំបូង ទើបជាវិបស្សនាញាណដែលនៅទន់ខ្សោយ មិនមែនជាពលវិបស្សនា គឺវិបស្សនាញាណដែលមានកម្លាំង ដែលជាវិបស្សនាញាណថ្នាក់ជាន់ខ្ពស់ឡើងនោះទេ ។ តរុណវិបស្សនា នៅមានការត្រិះរិះដល់នាមធម៌ និងរូបធម៌ដែលកំពុងប្រចក្សច្បាស់ សូម្បីដោយអាការដែលសូន្យទទេចាកលោកដែលធ្លាប់រួមគ្នាក៏ដោយ ។

កាលណានៅមានការត្រិះរិះដល់នាមធម៌ និងរូបធម៌ ដែលកំពុងប្រចក្ស ទើបឈ្មោះថា ចិន្តាញាណ ដែលធ្វើឱ្យអស់លោកខ្លះយល់ថាវិបស្សនាញាណទាំង ៣ នេះ គឺខណៈដែលកំពុងរលឹក សង្កេតដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌នឹងយល់ជាក់ឡើង ។ ប៉ុន្តែដរាបណាដែលវិបស្សនាញាណនៅមិនទាន់កើតឡើងនោះទេ ក៏រមែងមិនដឹងបាន

ឡើយថា វិបស្សនាញាណដែលប្រចក្សច្បាស់លក្ខណៈនៃនាមធម៌ និងរូបធម៌ផ្លូវមនោទ្វារនោះ តើនឹងកើតឡើងដោយសេចក្តីជាអនត្តា ក្នុងស្ថានទីណា ខណៈណា ហើយនិងមាននាមធម៌ណា រូបធម៌ណាប្រាកដជាអារម្មណ៍ ប៉ុន្មានអារម្មណ៍ខ្លះ ។

អស់លោកខ្លះយល់ថា ខណៈដែលកំពុងរលឹកដឹង ពិចារណាសង្កេតដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ និងគិតថាដឹងជាក់ហើយនោះ ជានាមរូបបរិច្ឆេទញាណទៅហើយ ។ ត្រង់យល់យ៉ាងនេះ ព្រោះមិនទាន់ដឹងថា **វិបស្សនាញាណ ត្រូវកើតឡើង ប្រាកដដោយភាពជាអនត្តា** ដូចគ្នានឹងនាមធម៌ដទៃ ។ នោះដែរ និងជាការប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌ បន្តគ្នាតាមផ្លូវមនោទ្វារ ដោយលក្ខណៈដែលទ្វារដទៃ ហាក់ដូចជាត្រូវមនោទ្វារបិទបាំងទុក ។ ដោយន័យផ្ទុយពីខណៈដែលវិបស្សនាញាណមិនកើត ដែលសូម្បី មនោទ្វារវិថីចិត្តកើតខណ្ឌបញ្ចទ្វារវិថីចិត្តគ្រប់វារៈ តែមនោទ្វារវិថីក៏មិនប្រាកដ ព្រោះអារម្មណ៍នៃបញ្ចទ្វារវិថីចិត្តបិទបាំងទុក ។

អស់លោកខ្លះគិតថា ខណៈដែលពិចារណាដឹងថា នាមនេះកើតចេញពីរូបនេះ រូបនោះកើតចេញពីរូបនោះ ដល់យល់យ៉ាងនោះហើយជាវិបស្សនាញាណ គឺបច្ចយបរិគ្គហញាណ ។ ប៉ុន្តែកាលណា នាមរូប-បរិច្ឆេទញាណនៅមិនទាន់កើតទេ វិបស្សនាញាណដទៃ ។ ក៏កើតមិនបាន

ឡើយ ហើយកាលណានាមរូបបរិច្ឆេទញាណកើតហើយ ក៏នឹងមិនយល់ខុសថា ខណៈដែលមិនមែនវិបស្សនាញាណ ជាវិបស្សនាញាណឡើយ ។ អ្នកដែលវិបស្សនាញាណកើតរួចហើយ រមែងដឹងសភាពជាអនត្តា នៃវិបស្សនាញាណថា វិបស្សនាញាណនឹងកើតឡើង តាមដែលមគ្គមានអង្គ ៨ (ប្រក្រតីមានអង្គ ៥) តាក់តែងរហូតទៅដល់សភាព សម្បូរនៃវិបស្សនាញាណនោះ ។ វិបស្សនាញាណនោះ ។ ទើបកើតឡើងតាមហេតុបច្ច័យ ។ ដូច្នោះ ទើបអ្នកអប់រំចម្រើនហេតុ គឺសតិប្បដ្ឋានរលឹកសិក្សា ពិចារណា សង្កេត ដឹងលក្ខណៈនាមធម៌ និងរូបធម៌ជាប្រក្រតីទៅជារឿយ ។ កើនឡើង ។ ល្អិតឡើង ។ ។

អស់លោកខ្លះគិតថា ពេលសម្មសនញាណកើតឡើងនោះ នឹងឃើញនាមធម៌កើតឡើង និងរលត់ទៅជាដួងមូល ។ ត ។ គ្នា ។ នាមធម៌មិនមែនរូបធម៌ កាលណាមិនដឹងលក្ខណៈនៃនាមធម៌ដែលជាធាតុដឹង ព្រោះមិនបានអប់រំសតិប្បដ្ឋានរលឹកដឹងលក្ខណៈនៃនាមធម៌មួយប្រភេទ ។ ទេក៏គិតថានាមធម៌ ដែលកើតរលត់នោះ ជាលក្ខណៈដូចនឹងរូបណាមួយ **អ្នកដែលអន្ទះអន្ទែង ចង់នឹងឱ្យវិបស្សនាញាណកើតភ្លាម ។ ឆាប់ ។ នោះ រមែងតែងព្យាយាមបែបដទៃជំនួសការរលឹកពិចារណា សង្កេត លក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកើតឡើងប្រាកដ តាមហេតុបច្ច័យតាមសេចក្តីពិត ។ ប៉ុន្តែ មិនមានផ្លូវនឹងបង្គាប់ឱ្យបញ្ញាកើតឆាប់ ។ នោះបានឡើយ ។ ហេតុដែលនឹងអប់រំបញ្ញាឱ្យចម្រើនឡើងសន្សឹម ។ បន្តិចម្តង ។**

បាននោះ មានផ្លូវតែមួយ គឺសតិប្បដ្ឋានតាមប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ប៉ុណ្ណោះ ។ បើធ្វើបែបយ៉ាងដទៃដែលខុសពីនេះ គឺប្រាកដជាបានផលខុសទៅតាមហេតុ ដែលខុសដែរ ។ ការបដិបត្តិខុសនោះកើតពីការសង្ឃឹមផលរហ័សនាប់ ។ ពេក ព្រោះមិនយល់នូវផ្លូវបដិបត្តិ ដែលត្រឹមត្រូវ ។ ឯលោភៈមូលចិត្ត ដែលកើតរួមនឹងសេចក្តីយល់ខុស ទើបជាមិច្ឆាមគ្គ ដែលនាំទៅដល់មិច្ឆាវិមុត្តិ គឺការផុតស្រឡះយ៉ាង ខុស ។ ព្រោះមិនមែនការផុតស្រឡះចាកកិលេសយ៉ាងត្រឹមត្រូវឡើយ តែក៏យល់ខុសថា ផុតស្រឡះចាកកិលេសហើយ ។

វិបស្សនាញាណទី ៤ ឧទយព្វយញាណ

សូម្បីថាវិបស្សនាញាណទី ៣ នឹងប្រចក្សការកើតឡើង និងរលត់ទៅជាបន្តគ្នានៃនាមធម៌ និងរូបធម៌យ៉ាងរហ័សរួចហើយក៏ដោយ ក៏ខណៈនោះ បញ្ញានៅមិនទាន់ល្អិតល្អន់នឹងលះបង់ ឬឃើញទោសនៃការកើតឡើង និងរលត់ទៅនៃនាមធម៌ និងរូបធម៌ទេ ព្រោះការកើតឡើងបន្តពីការរលត់ទៅនោះ រហ័សពេករហូតដល់បិទបាំងទោសនៃការកើត រលត់ ។ បញ្ញានឹងត្រូវសម្បូរដល់ថ្នាក់បន្តបន្ទាប់ទៅ ដែលចាក់ធ្លុះនូវការកើតឡើង និងរលត់ទៅនៃនាមធម៌ និងរូបធម៌មួយប្រភេទ ៗ ជាក់ច្បាស់ក្រៃលែងឡើងទៀត ដែលមិនមាននរណានឹងទៅព្យាយាម ប្រឹងប្រែង យ៉ាងដទៃ

បានឡើយ ក្រៅពីការពិចារណា លក្ខណៈនៃនាមធម៌ និងរូបធម៌បន្ត បន្ទាប់ទៅ ដោយមិនកម្រើកញាប់ញ័រ ដោយទូទៅទាំងអស់ មិនថា នឹងជានាមធម៌ រូបធម៌ប្រភេទណា កុសលធម៌ អកុសលធម៌ ថ្នាក់ណា ឡើយ តាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត វិបស្សនាញាណថ្នាក់ទី ៤ ដែលជាឧទយព្វយញាណនោះ ប្រចក្សការកើតឡើង និងការរលត់ ទៅនៃនាមធម៌ និងរូបធម៌មួយប្រភេទ ។ យ៉ាងជាក់ច្បាស់ក្រៃលែង ដែល ឧទយព្វយញាណនឹង កើតឡើងបាននោះ ពេលដែលតីរណបរិញ្ញា គឺ បញ្ញាដែលពិចារណាលក្ខណៈនៃនាមធម៌ និងរូបធម៌ បានទូទៅទាំង ៦ ផ្លូវ ដល់សេចក្តីសម្បូរហើយ ។ ដរាបណាដែលសតិប្បដ្ឋាន នៅមិនទាន់រលឹក ដឹង នូវលក្ខណៈនៃនាមធម៌ និងរូបធម៌បានជាក់ច្បាស់ទូទៅទាំង ៦ ទ្វារទេ ឧទយព្វយញាណក៏មិនមានបច្ច័យដែលនឹងកើតបានឡើយ ។

អ្នកដែលអប់រំចម្រើនអរិយមគ្គ គឺសម្មាមគ្គដែលត្រឹមត្រូវ ទើបដឹង ថា មិនមានផ្លូវដែលនឹងដឹងច្បាស់សភាពនៃព្រះនិព្វាន ដែលជាធម៌រំលត់ កិលេសបានឡើយ បើមិនអប់រំចម្រើនបញ្ញាដឹងលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដជាប្រក្រតីតាមសេចក្តីពិតមុនទេនោះ ការនឹងដឹងច្បាស់ នូវសភាពនៃព្រះនិព្វានដោយបញ្ញាមិនពិចារណា ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ទាំង ៦ ទ្វារដោយល្អិតល្អន់ ទូទៅ នោះនឹងប្រព្រឹត្តទៅមិនបាន ឡើយ ព្រោះបើមិនដឹងនូវលក្ខណៈនៃនាមធម៌ និងរូបធម៌ពិត ។ ទូទៅទេ នោះ ក៏មិនដឹងថា នាមធម៌និងរូបធម៌ មួយលក្ខណៈ ។ តើផ្សេងគ្នាយ៉ាង

ណា ? កាលណាមិនប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌ផ្សេងគ្នាទាំង ៦ ទ្វារទេ ក៏ប្រចក្សច្បាស់នូវការកើតឡើង និងរលត់ទៅនៃនាមធម៌ និងរូបធម៌មិនបានដែរ កាលណាមិនប្រចក្សច្បាស់នូវការកើតឡើង និងការរលត់ទៅ នៃនាមធម៌និងរូបធម៌ទេ ក៏នឹងរលត់សេចក្តីមិនដឹង គឺអវិជ្ជា សេចក្តីសង្ស័យ និងសេចក្តីយល់ខុស ឃើញខុសក្នុងសភាវធម៌មិនបានឡើយ ។

វិបស្សនាញាណទី ៥ ភង្គញាណ

សូម្បីថា ឧទយព្វយញាណ នឹងប្រចក្សការកើតឡើង និងការរលត់ទៅនៃនាមធម៌ និងរូបធម៌ មួយលក្ខណៈ ។ យ៉ាងជាក់ច្បាស់រួចហើយ ក៏ដោយ តែសេចក្តីត្រេកអរ ពេញចិត្ត សេចក្តីប្រកាន់មាំក្នុងសភាវធម៌ ទាំងឡាយដែលសន្សំជាយូរយារមកក្នុងសង្សារវដ្ត ក៏នៅតាំងមាំណែនជានិច្ច នេះសម្តែងឱ្យឃើញមូលឫស ដែលកប់យ៉ាងណែននៃអវិជ្ជា និងតណ្ហា ក្នុងសេចក្តីជាតួខ្លួន ដែលបញ្ញានឹងត្រូវអប់រំបន្ថែមឡើង ។ ទៀត ដោយសតិប្បដ្ឋានរលឹកដឹងនូវលក្ខណៈដែលបានប្រចក្សការកើតឡើង និងការរលត់ទៅនៃនាមធម៌ និងរូបធម៌ ដែលប្រាកដដល់ឧទយព្វយញាណរួចហើយ ហើយនឹងត្រូវយកចិត្តទុកដាក់ ពិចារណាការរលត់ទៅនៃនាមធម៌ និង រូបធម៌ ដែលចេះតែរលត់ទៅ ។ ។ កាលណាសតិប្បដ្ឋានចម្រើនឡើង

បញ្ញាកើនឡើងរហូតដល់មានបច្ច័យសម្បូរព្រមខណៈណា ភង្គញាណ ក៏កើតឡើងប្រចក្សច្បាស់នូវសេចក្តីមិនមានសារៈនៃការកើតឡើង និងរលត់ទៅ ។ នៃសភាវធម៌ដែលប្រាកដជា បហានបរិញ្ញា ដែលនឹងនាំទៅដល់ការចម្រើនបញ្ញាថ្នាក់បន្ត ។ ទៅ ដែលចាប់ផ្តើមនឹងលះបង់សេចក្តីពេញចិត្ត ប្រកាន់មាំក្នុងសភាវធម៌ ថាជាតួខ្លួន សត្វ បុគ្គល ។

វិបស្សនាញាណទី ៦ ភយញាណ

កាលណាភង្គញាណរលត់អស់ហើយ អ្នកអប់រំចម្រើនសតិប្ប-ដ្ឋាន ក៏ដឹងថា កិលេសទាំងឡាយនៅមានកម្លាំងកើតឡើងប្រព្រឹត្តទៅតាមការសន្សំ ដែលសូម្បីនឹងដាក់ចិត្តរលឹកដល់លក្ខណៈដែលរលត់ទៅ ។ នៃនាមធម៌ និងរូបធម៌ក៏ដោយ សេចក្តីប្រកាន់នូវនាមធម៌ និងរូបធម៌ថាជាតួខ្លួន ក៏នៅកប់ណែនជានិច្ច ដែលនឹងលះបង់ចោលបានក៏អាស្រ័យដោយការឃើញភ័យនៃការលត់ទៅ ។ នៃនាមធម៌ និងរូបធម៌នោះឯង សតិប្បដ្ឋាន និងបញ្ញារលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ បន្ត ។ ទៅដោយការពិចារណាឃើញភ័យនៃការលត់ទៅ ។ នៃនាមធម៌ និងរូបធម៌ ។ កាលណាបញ្ញាសម្បូរព្រមដោយបច្ច័យខណៈណា ភយញាណក៏កើតឡើងឃើញភ័យនៃនាមធម៌ និងរូបធម៌ក្នុងខណៈដែលកំពុងប្រចក្សការកើតរលត់នៃនាមធម៌ និងរូបធម៌ក្នុងខណៈនោះ ។

វិបស្សនាញាណទី ៧ អាទីនវញាណ

សូម្បីថា ភយញាណនឹងឃើញភ័យនៃការកើតឡើង និងរលត់ទៅ នៃនាមធម៌ និងរូបធម៌ហើយក៏ដោយ កាលណាភយញាណរលត់អស់ទៅ ហើយ សេចក្តីត្រេកអរពេញចិត្ត ក្នុងការប្រកាន់នាមធម៌ និងរូបធម៌ថា ជាតួខ្លួន ក៏នៅតែមិនទាន់អស់ដែរ អ្នកចម្រើនសតិប្បដ្ឋានទើបដឹងថា នឹង ត្រូវឃើញទោសនៃនាមធម៌ និងរូបធម៌ ដែលកើតរលត់បន្តែមឡើង ។ ទៀត រហូតទាល់តែនឹងលះបង់ចោលនូវនាមធម៌ និងរូបធម៌ ថាជាតួខ្លួន ទៅទៀត ។ កាលណាសតិរលឹកដឹងនូវលក្ខណៈនៃសភាវធម៌ដែលកើត រលត់ បញ្ញាក៏ឃើញទោសនៃការកើតឡើង និងរលត់ទៅនៃនាមធម៌ និង រូបធម៌ល្អិតល្អន់ឡើង ។ រហូតបច្ច័យសម្បូរព្រមនឹងតាក់តែងឱ្យអាទីនវ-ញ្ញាណ កើតឡើងខណៈណា អាទីនវញ្ញាណក៏កើតឡើងប្រចក្សច្បាស់នូវ ទោសនៃនាមធម៌ និងរូបធម៌ដែលកើតរលត់ក្នុងខណៈនោះ ។

វិបស្សនាញាណទី ៨ និព្វិទាញាណ

កាលណាប្រចក្សច្បាស់ក្នុងទោសនៃសង្ខារធម៌ទាំងឡាយ ដូចផ្ទះ ដែលត្រូវភ្លើងឆេះសន្ធោសន្ធៅទាំងខ្នងហើយ ក៏រមែងលះបង់នូវសេចក្តី

ត្រេកអរក្នុងភព ដោយសេចក្តីដឹងជាក់នូវសេចក្តីនឿយណាយពីលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលប្រាកដ ទើបជានិព្វិទាញាណ ។

វិបស្សនាញាណទី ៩ មុញ្ចិតុកម្យតាញាណ

កាលណាបញ្ញាដឹងច្បាស់សេចក្តីនឿយណាយក្នុងនាមធម៌ និងរូបធម៌ដែលប្រាកដបន្តែមឡើង ។ ទៀត រមែងកើតបញ្ញាដែលត្រូវការនឹងផុតចាកពីនាមធម៌ និងរូបធម៌ដែលកើតរលត់ប្រាកដក្នុងខណៈនោះ ។ បញ្ញាដែលត្រូវការចង់នឹងផុតចាកពីនាមធម៌ និងរូបធម៌ជាមុញ្ចិតុកម្យតាញាណ ។

វិបស្សនាញាណទី ១០ បដិសង្ខារញាណ

កាលណាកើតបញ្ញាដែលត្រូវការនឹងចង់ផុតចាកនាមធម៌ និងរូបធម៌ទាំងឡាយ ក្រៃលែងឡើងហើយនោះ បញ្ញាក៏ពិចារណានូវត្រៃលក្ខណៈនៃសង្ខារធម៌ទាំងឡាយតាមសភាវៈដែលជាអនិច្ចលក្ខណៈ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ បន្តទៅទៀត រួចហើយទើបប្រចក្សអនិច្ចលក្ខណៈ នៃសង្ខារធម៌ទាំងឡាយដែលកើត រលត់ ។ នោះ ដោយជាសភាពដែលមិនតាំងមាំជាទីបំផុតជាជួរខណៈមិនណែន រង្គោះរង្គើ ប្រែ

ប្រួល មិនស្ថិតស្ថេរ មិនមានសារៈ ។ ប្រចក្សច្បាស់ក្នុងទុក្ខលក្ខណៈនៃសង្ខារធម៌ទាំងឡាយដែលកើតរលត់ ។ នោះ ដោយសភាពដែលបៀតបៀនជារឿយ ។ មិនមានផ្លូវគេចវេះ មិនមានផ្លូវកែប្រែ ជាទុក្ខភ័យ គឺជាសភាពដែលមិនគួរពេញចិត្តជាប់ជំពាក់ ។ ប្រចក្សច្បាស់ក្នុងអនត្តលក្ខណៈនៃសង្ខារធម៌ទាំងឡាយដែលកើតរលត់ ។ នោះ ដោយសភាពដែលសូន្យទៅ អស់ទៅ មិនមានម្ចាស់ មិនបាននៅក្នុងអំណាច បង្គាប់បញ្ជាឡើយ ។ បញ្ញា ដែលប្រចក្សច្បាស់ត្រៃលក្ខណៈនៃសង្ខារធម៌ទាំងឡាយនោះ ជាបដិសង្ខារញាណ ។

វិបស្សនាញាណទី ១១ សង្ខារុបេក្ខាញាណ

កាលណាបញ្ញាប្រចក្សច្បាស់នូវត្រៃលក្ខណៈ នៃសង្ខារធម៌ទាំងឡាយកើនក្រៃលែងឡើងហើយ ធ្វើឱ្យសង្ខារធម៌ទាំងឡាយ ដែលធ្លាប់ប្រាកដដោយជាសភាពទៀងជាសុខ និងជាតួខ្លួននោះ ក៏ខ្សោយកម្លាំងថយចុះ រហូតដល់កើតសេចក្តីព្រងើយកន្តើយក្នុងសង្ខារធម៌ទាំងឡាយ ព្រោះដឹងជាក់ថា ដរាបណានៅមិនទាន់ដល់កាលដែលនឹងប្រចក្សច្បាស់នូវលក្ខណៈនៃព្រះនិព្វាន ដោយមានព្រះនិព្វានប្រាកដជាអារម្មណ៍ ដរាបនោះ ក៏ពិចារណានូវត្រៃលក្ខណៈ លក្ខណៈណាមួយទៅជាអារម្មណ៍រឿយ ។ បញ្ញាដែលដឹងច្បាស់ដោយសេចក្តីព្រងើយកន្តើយក្នុងសង្ខារធម៌ទាំង

ឡាយ ដែលកើត រលត់ប្រាកដនោះ ជាសង្ខារុបេក្ខាញាណ ។ សង្ខារុ-
បេក្ខាញាណនេះ ជាវិបស្សនាដែលបន្លុះដល់កំពូលជាវុដ្ឋានគាមនីបញ្ញា គឺ
បញ្ញាដែលនាំចេញទៅផុតចាកភាវៈនៃបុថុជ្ជន កាលណាមគ្គវិថីកើតឡើង
វុដ្ឋានគាមនី ជាឈ្មោះរបស់ញាណ គឺ សង្ខារុបេក្ខាញាណ អនុលោម-
ញាណ និងគោត្រភូញាណ ។

វិបស្សនាញាណទី ១២ អនុលោមញាណ

អនុលោមញាណជាវិបស្សនាញាណក្នុងមគ្គវិថី ដែលអនុលោម
បន្តដល់ការដឹងច្បាស់អរិយសច្ចធម៌ ។ អនុលោមញាណជាមហាកុសល
ញាណសម្បយុត្តចិត្ត ៣ ខណៈក្នុងមគ្គវិថី គឺ បរិកម្ម ១ ខណៈ ឧបចារ ១
ខណៈ អនុលោម ១ ខណៈ ។ មហាកុសលញាណសម្បយុត្តចិត្ត ៣
ខណៈនេះមានត្រៃលក្ខណ៍ លក្ខណៈណាមួយជាអារម្មណ៍ គឺមានអនិច្ច
លក្ខណៈនៃសង្ខារធម៌ជាអារម្មណ៍ ឬ មានទុក្ខលក្ខណៈនៃសង្ខារធម៌ ជា
អារម្មណ៍ ឬ មានអនត្តលក្ខណៈនៃសង្ខារធម៌ជាអារម្មណ៍ ដែលអនុលោម
បន្តដល់ការដែលនឹងលែងចោលនូវអារម្មណ៍ដែលជាសង្ខារធម៌ ។

[๓๘]ចំពោះបុគ្គលដែលជាតិក្ខបុគ្គល គឺមានបញ្ញាខ្លាំងក្លាបន្លុះអរិយសច្ចធម៌បានរហ័ស អនុលោមក៏មាន ២ ខណៈ គឺវៀរខណៈបរិកម្ម ១ ហើយ បន្ថែមផលចិត្តជា ៣ ខណៈ ។

វិបស្សនាញាណទី ១៣ គោត្រភូញាណ

កាលណាអនុលោម ៣ ខណៈ (ចំពោះអ្នកជាមណ្ឌបុគ្គលគឺអ្នកបន្លុះអរិយសច្ចធម៌យឺតជាងតិក្ខបុគ្គល) ឬ ២ ខណៈ (ចំពោះអ្នកជាតិក្ខបុគ្គល) រលត់ទៅហើយ គោត្រភូញាណ គឺមហាកុសលញាណសម្បយុត្តចិត្តក៏កើតបន្ត ដោយបង្អោនទៅមាននិព្វានជាអារម្មណ៍ជាអាសេវនប្បច្ច័យឱ្យសោតាបត្តិមគ្គចិត្តកើតបន្តមាននិព្វានជាអារម្មណ៍ ដោយជាលោកុត្តរកុសលចិត្តដែលរំលត់កិលេសជាសមុច្ឆេទ ។

តាមធម្មតានៃជវនវិថីក្នុងវារៈជាមួយគ្នា ៧ ខណៈនោះ ត្រូវមានអារម្មណ៍ជាមួយគ្នា ប៉ុន្តែក្នុងមគ្គវិថីនោះ ជវនវិថី ៧ ខណៈមានអារម្មណ៍ផ្សេងគ្នា គឺបរិកម្ម ១ ខណៈ ឧបចារៈ ១ ខណៈ អនុលោម ១ ខណៈ មានត្រៃលក្ខណ៍ លក្ខណៈណាមួយក្នុង ៣ លក្ខណៈជាអារម្មណ៍ ប៉ុន្តែ **គោត្រភូចិត្ត ១ ខណៈ មគ្គចិត្ត ១ ខណៈ និងផលចិត្ត ២ ខណៈមាននិព្វានជាអារម្មណ៍** ។ កាលណាគោត្រភូចិត្ត ជាមហាកុសលចិត្តដែល

---

[๓๘] សច្ចសង្ខេប

មាននិព្វានជាអារម្មណ៍ខណៈដំបូង ទើបជាអាវជ្ជនៈនៃសោតាបត្តិមគ្គចិត្ត មាននិព្វានជាអារម្មណ៍បន្តពីគោត្រភូចិត្ត ទើបសោតាបត្តិមគ្គចិត្តធ្វើកិច្ចរំលត់កិលេសបាន ។

សេចក្តីក្នុងអដ្ឋសាលិនី ចិត្តុប្បាទកណ្ឌ ពណ៌នាលោកុត្តរកុសល និងវិសុទ្ធិមគ្គ ញាណទស្សនវិសុទ្ធិនិទ្ទេស ឧបមាអនុលោម និងគោត្រភូញាណ ដូចជាបុរសអ្នកងើយមើលដួងព្រះច័ន្ទ ក្នុងពេលកណ្តាលអាធ្រាត ខណៈនោះដួងច័ន្ទមិនប្រាកដ ព្រោះដុំពពកស្អាប់នៅបាំងភ្លាម នោះមានដុំខ្យល់មួយមកផាត់ ដុំពពកដ៏ក្រាស់នោះឱ្យបែកខ្ចាយទៅហើយ ដុំខ្យល់មួយទៀត ក៏មកផាត់ពពកដែលបែកខ្ចាយហើយនោះឱ្យរសាត់ចេញទៅ ហើយដុំខ្យល់មួយទៀតក៏ផាត់ពពក សូម្បីល្អិតបន្តិចបន្តួចក៏ដោយដែលបិទបាំងដួងព្រះច័ន្ទឱ្យរសាត់ចេញទៅអស់ បុរសនោះទើបឃើញដួងច័ន្ទដែលប្រាសចាកពពកបិទបាំង ។ និព្វានប្រៀបដូចដួងច័ន្ទ អនុលោម ៣ ខណៈ ប្រៀបដូចខ្យល់ ៣ កង គោត្រភូញាណ ប្រៀបដូចបុរសអ្នកឃើញដួងច័ន្ទដែលប្រាសចាកពពកបិទបាំង ។

អនុលោមញាណ ៣ ខណៈដូចខ្យល់ ៣ កង ដែលអាចកំចាត់ពពកបិទបាំងដួងច័ន្ទបាន ប៉ុន្តែមិនអាចឃើញដួងច័ន្ទបានឡើយយ៉ាងណា អនុលោមញាណក៏បន្សាត់នូវសេចក្តីងងឹតដែលបិទបាំងសច្ចៈបាន តែមិនអាចឃើញនិព្វានបានក៏យ៉ាងដូច្នោះដែរ ហើយបុរសនោះអាចឃើញ ដួងច័ន្ទបានតែប៉ុណ្ណោះ តែមិនអាចកំចាត់ពពកបានឡើយយ៉ាងណាគោត្រភូ

ក៏យ៉ាងដូច្នោះដែរ គឺអាចឃើញនិព្វានបាន តែមិនអាចទំលាយសេចក្តីងងឹត គឺកិលេសបានឡើយ ។

វិបស្សនាញាណទី ១៤ មគ្គញាណ

កាលណាគោត្រភូចិត្តរលត់អស់ទៅហើយ សោតាបត្តិមគ្គចិត្តដែលកើតបន្ត ក៏ឆ្លងផុតពីសភាពជាបុថុជ្ជន ដល់ភាពជាព្រះអរិយបុគ្គល ។ សោតាបត្តិមគ្គចិត្តកើតឡើងរំលត់កិលេសជាសមុច្ឆេទ តាមលំដាប់ថ្នាក់នៃលោកុត្តរបញ្ញា ។

វិបស្សនាញាណទី ១៥ ផលញាណ

កាលណាសោតាបត្តិមគ្គចិត្ត ដែលជាលោកុត្តរកុសលចិត្ត រលត់ទៅហើយ ក៏ជាបច្ច័យឱ្យសោតាបត្តិផលចិត្ត ដែលជាលោកុត្តរវិបាកចិត្តកើតបន្ត ដោយមិនមានចិត្តដទៃកើតខណ្ឌឡើយ ។ **លោកុត្តរកុសលចិត្តជាអកាលិកោ ជាអនន្តរកម្មប្បច្ច័យ ដែលធ្វើឱ្យលោកុត្តរវិបាកចិត្តកើតបន្តទាន់ពេល ដោយមិនមានចិត្តដទៃកើតខណ្ឌឡើយ លោកុត្តរវិបាកចិត្តទើបជាវិបាកចិត្ត ដែលផ្សេងពីវិបាកដទៃ ។ គឺធ្វើជវនចិត្តបន្តពីលោកុត្តរកុសលចិត្ត ២ ឬ ៣ ខណៈក្នុងមគ្គវិថី** ហើយលោកុត្តរវិបាក គឺផលចិត្ត

ដែលកើតខាងក្រោយមគ្គវិថីចិត្តនោះ ក៏ធ្វើជវនកិច្ច មិនធ្វើកិច្ចនៃវិបាកចិត្ត ដទៃ ។ ឡើយ ។

វិបស្សនាញាណទី ១៦ បច្ចវេក្ខណញាណ

កាលណាមគ្គវិថីចិត្តរលត់ទៅហើយ ភវង្គចិត្តក៏កើតបន្ត ហើយ ក្រោយពីនោះមនោទ្វារវិថីចិត្តក៏កើតឡើង ពិចារណាសភាវធម៌ ដែលទើប នឹងប្រចក្សច្បាស់ វារៈនីមួយៗ គឺពិចារណាមគ្គចិត្ត វារៈ ១ ពិចារណា ផលចិត្ត វារៈ ១ ពិចារណាកិលេសដែលលះបានរួចហើយ វារៈ ១ ពិចារណាកិលេសដែលនៅសល់ វារៈ ១ ពិចារណានិព្វាន វារៈ ១ ។

សម្រាប់អ្នកដែលបានបន្លុះអរហត្តមគ្គ និងអរហត្តផលហើយនោះ មិនមានពិចារណាកិលេសដែលនៅសល់ទេ ព្រោះអរហត្តមគ្គចិត្តរំលត់ កិលេស គ្រប់ប្រភេទអស់ជាសមុច្ឆេទ មិនមានកិលេសណា ។ សេសសល់ ឡើយ ។

វិបស្សនាញាណ ១៦ នោះ ក្នុងកន្លែងខ្លះ សម្តែងវិបស្សនាញាណ ៩ ដែលជាពលវិបស្សនាញាណ គឺ

១ - ឧទយព្វយញាណ

២ - ភង្គញាណ

៣ - ភយញាណ

៤ - អាទីនវញាណ

៥ - និព្វិទាញាណ

៦ - មុញ្ចិតុកម្យតាញាណ

៧ - បដិសង្ខាញាណ

៨ - សង្ខារុបេក្ខាញាណ

៩ - អនុលោមញាណ

ក្នុងកន្លែងខ្លះសម្តែង **វិបស្សនាញាណ ១០ គឺ**ផ្តើមតាំងតែពីសម្មសនញាណដល់អនុលោមញាណ ។ ការដែលសម្តែងវិបស្សនាញាណតាំងតែពីមានដំបូងដល់អនុលោមញាណនោះ ក៏ព្រោះវិបស្សនាញាណទាំងនោះ សន្សឹម ៗ ចាស់ក្លាឡើង ៗ រហូតអនុលោមបន្តដល់ការមាននិព្វានជាអារម្មណ៍ ។

ការអប់រំចម្រើនសតិប្បដ្ឋានធ្វើឱ្យបញ្ញាចាស់ក្លា និងបរិសុទ្ធឡើងជាវិបស្សនាញាណតាមលំដាប់ថ្នាក់នោះ ជាវិសុទ្ធិ ៧ ដូចនេះ

១ - សីលវិសុទ្ធិ បានដល់ សីលពេលដែលសតិរលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ ខណៈនោះវិសុទ្ធិចាកការមិនដឹងសភាវបរមត្ថធម៌ដែលមិនមែនតួខ្លួន ។ ខណៈដែលសតិប្បដ្ឋានមិនកើត មិនមែនសីលវិសុទ្ធិ ព្រោះប្រកាន់សីលថាជាយើង ជាតួខ្លួន ។

២ - ចិត្តវិសុទ្ធិ បានដល់ សមាធិថ្នាក់ផ្សេង ៗ ខណៈដែលសតិរលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ និងខណៈណាដែលឈានចិត្តជា

អារម្មណ៍របស់សតិប្បដ្ឋាន ឈានចិត្តនោះក៏ជាចិត្តវិសុទ្ធិ ព្រោះខណៈនោះ មិនប្រកាន់ឈានចិត្តនោះថាជាយើង ជាតួខ្លួន ។

៣ - ទិដ្ឋិវិសុទ្ធិ បានដល់ នាមរូបបរិច្ឆេទញាណ ជាញាណដែលប្រចក្សច្បាស់លក្ខណៈនៃនាមធម៌ និងរូបធម៌ដោយសភាពដែលមិនមែនតួខ្លួន ខណៈនោះទើបវិសុទ្ធិចាកការមិនធ្លាប់ប្រចក្សច្បាស់លក្ខណៈនៃនាមធម៌ និងរូបធម៌ដោយសភាពដែលមិនមែនតួខ្លួនមកពីមុនឡើយ ។

៤ - កង្ខាវិតរណវិសុទ្ធិ កាលណាទិដ្ឋិវិសុទ្ធិកើតឡើងរួចហើយ បញ្ញាក៏ចម្រើនឡើងពីការចម្រើនសតិប្បដ្ឋាន ក៏ជាយថាភូតញាណទស្សនៈ គឺឃើញលក្ខណៈនៃសភាវធម៌តាមសេចក្តីពិតរបស់សភាវធម៌នោះ ។ ក្នុងខណៈដែលសតិរលឹកលក្ខណៈនៃសភាវធម៌តាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត រហូតដល់សម្បុរដល់ថ្នាក់ជាបច្ចយបរិគ្គហញាណ ឆ្លងផុតសេចក្តីសង្ស័យក្នុងការកើតឡើងនៃនាមធម៌ និងរូបធម៌ ទាំងឡាយថា ប្រព្រឹត្តទៅតាមបច្ច័យទាំងអស់ បច្ចយបរិគ្គហញាណ ទើបជាកង្ខាវិតរណវិសុទ្ធិ ។

៥ - មគ្គាមគ្គញាណទស្សនវិសុទ្ធិ កាលណាកង្ខាវិតរណវិសុទ្ធិកើតឡើងហើយ បញ្ញាដែលចម្រើនឡើងពីសតិប្បដ្ឋានដែលពិចារណាលក្ខណៈនៃនាមធម៌ និងរូបធម៌ទាំងអស់ឡើងរហូតដល់ថ្នឹក ដឹងថាត្រឹមតែជានាមធម៌ និងរូបធម៌ប៉ុណ្ណោះស្មើគ្នាទាំងអស់គ្រប់ប្រភេទ ធ្វើឱ្យលះបង់ការដាក់ចិត្តស្វែងរក ប្រកាន់មាំក្នុងនាមណាមួយ រូបណាមួយ

ដោយចំពោះ ហើយបង្អោន ពិចារណាការកើតរលត់ សេចក្តីមិនទៀង សេចក្តីជាទុក្ខ សេចក្តីជាអនត្តានៃនាមធម៌ និងរូបធម៌ដែលប្រាកដ រហូតដល់ប្រចក្សការកើតរលត់បន្តគ្នានៃនាមធម៌ និងរូបធម៌ជា សម្មសនញាណ និងជាឧទយព្វយញាណតាមលំដាប់ ។ កាលណាឧទយព្វយញាណរលត់ទៅហើយ កិលេសដែលនៅមិនទាន់បានរលត់ជាសមុច្ឆេទនោះ ក៏ធ្វើឱ្យកើតសេចក្តីត្រេកអរ ពេញចិត្តនៅក្នុង **វិបស្សនូបក្កិលេស ១០ យ៉ាង ណាមួយ គឺ**

១ - ឱភាស	ពន្លឺ
២ - ញាណ	សេចក្តីដឹង
៣ -បីតិ	សេចក្តីឆ្អែតចិត្ត
៤ - បស្សទ្ធិ	សេចក្តីស្ងប់ចិត្ត
៥ - សុខ	សេចក្តីសប្បាយក្សេមក្សាន្តចិត្ត
៦ -អធិមោក្ខ	សេចក្តីបង្អោនចិត្តជឿ
៧ -បគ្គាហ	សេចក្តីព្យាយាម
៨ - ឧបដ្ឋាន	សេចក្តីមាំទាំ
៩ - ឧបេក្ខា	សេចក្តីព្រងើយកន្តើយ
១០ - និកន្តិ	សេចក្តីប្រាថ្នាត្រូវការ

១ - កាលឧទយព្វយញាណរលត់ទៅហើយ ឱភាសរមែងកើតពីចិត្តដែលស្ងប់ដល់ថ្នាក់ជាបច្ច័យឱ្យពន្លឺកើតឡើងបាន ។ ខណៈដែល

កើតសេចក្តីត្រេកអរក្នុងឱភាសនោះជាវិបស្សនូបក្កិលេស ព្រោះធ្វើឱ្យ
វិបស្សនាសៅហ្មង មិនបានពិចារណាភាពកើតរលត់ មិនទៀង ជាទុក្ខ ជា
អនត្តា មិនមែនតួខ្លួននៃសភាវធម៌ក្នុងខណៈនោះ ។

២ - ខណៈដែលសេចក្តីត្រេកអរក្នុងសេចក្តីចាស់ក្លានៃបញ្ញា ដែល
ប្រចក្សការកើត រលត់នៃនាមធម៌ និងរូបធម៌យ៉ាងរហ័សដូចផ្លេកបន្ទោរ
នោះក៏ជាវិបស្សនូបក្កិលេស ព្រោះមិនបានពិចារណាសេចក្តីកើតរលត់មិន
ទៀង ជាទុក្ខ ជាអនត្តា មិនមែនតួខ្លួនរបស់សភាវធម៌ក្នុងខណៈនោះតទៅ ។

៣ - ខណៈដែលត្រេកអរក្នុងបីតិ សេចក្តីឆ្អែតដែលប្រចក្សការ កើត
រលត់នៃនាមធម៌ និងរូបធម៌នោះ ក៏ជាវិបស្សនូបក្កិលេស ។

៤ - ខណៈដែលត្រេកអរក្នុងសេចក្តីស្ងប់ ដែលប្រាសចាកសេចក្តី
ក្រវ៉ល់ក្រវាយ សេចក្តីរឹងត្អឹង សេចក្តីរៀចរេវ មិនគួរដល់ការងារជាដើម
ក៏ជាវិបស្សនូបក្កិលេស ។

៥ - ខណៈដែលត្រេកអរក្នុងសេចក្តីសុខ ដែលជាសោមនស្ស
វេទនាយ៉ាងក្រៃលែងនោះ ក៏ជាវិបស្សនូបក្កិលេស ។

៦ - ខណៈដែលត្រេកអរក្នុងសេចក្តីបង្អោនចិត្តជឿដែលមាំក្រៃ
លែងឡើងនោះ ក៏ជាវិបស្សនូបក្កិលេស ។

៧ - ខណៈដែលត្រេកអរក្នុងសេចក្តីព្យាយាម ដែលមិនតឹងពេក
មិនធូរពេកប្រកបដោយវិបស្សនាញាណ ក៏ជាវិបស្សនូបក្កិលេស ។

៨ - ខណៈដែលត្រេកអរក្នុងសេចក្តីតាំងមាំ នៃសតិប្បដ្ឋាន ៤ ដែលប្រកបដោយវិបស្សនាញាណនោះ ក៏ជាវិបស្សនូបក្កិលេស ។

៩ - ខណៈដែលត្រេកអរក្នុងសេចក្តីព្រងើយកន្តើយ គឺជាកណ្តាលស្មើ ។ គ្នានៃសង្ខារធម៌ទាំងពួង ដែលប្រកបដោយវិបស្សនាញាណ នៅពេលប្រចក្សការកើត រលត់នៃអារម្មណ៍ សេចក្តីដែលប្រាកដយ៉ាងរហ័ស ដូចផ្លេកបន្ទោរនោះ ក៏ជាវិបស្សនូបក្កិលេស ។

១០ - ខណៈដែលត្រេកអរចង់បានប្រចក្សច្បាស់លក្ខណៈនៃសភាវធម៌ដោយវិបស្សនាញាណនោះ ក៏ជាវិបស្សនូបក្កិលេស ។

កាលណាបញ្ញាពិចារណាដឹងថា វិបស្សនូបក្កិលេស ជាសភាវៈដែលគួរលះខណៈដែលបញ្ញាចាស់ក្លាដឹងច្បាស់ សេចក្តីល្អិតនៃវិបស្សនូបក្កិលេស សុទ្ធតែមិនមែនផ្លូវដែលនឹងនាំទៅដល់ការលះបង់ ភាពជាប់ជំពាក់នៃសភាវធម៌ទាំងឡាយដែលល្អិតនោះ ។ ខណៈនោះជា មគ្គាមគ្គញាណទស្សនវិសុទ្ធិ គឺឧទយព្វយញាណដែលផុតចាក វិបស្សនូបក្កិលេសហើយ ។

៦ - **បដិបទាញាណទស្សនវិសុទ្ធិ** កាលណាផុតចាកពី វិបស្សនូបក្កិលេសហើយ បញ្ញាដែលចម្រើនឡើង ពីការចម្រើនសតិប្បដ្ឋានត ។ មកនោះ ក៏ជាបដិបទាញាណទស្សនវិសុទ្ធិ តាំងតែពីឧទយព្វយញាណ

ដែលប្រាសចាកវិបស្សនូបក្កិលេស រហូតដល់អនុលោមញាណ ៣ ខណៈ ក្នុងមគ្គវិថី គឺ បរិកម្ម ឧបចារ អនុលោម ។

៧ - **ញាណទស្សនវិសុទ្ធិ** កាលណាអនុលោមញាណ ៣ ខណៈរលត់ហើយ គោត្រភូញាណក៏កើត ។ គោត្រភូញាណមិនមែន បដិបទាញាណទស្សនវិសុទ្ធិ និងមិនមែនញាណទស្សនវិសុទ្ធិ ព្រោះ គោត្រភូញាណមានឋានៈដូចជាអាវជ្ជនៈ នៃលោកុត្តរចិត្ត រវាងបដិបទា ញាណទស្សនវិសុទ្ធិ និងញាណទស្សនវិសុទ្ធិ ប៉ុន្តែដរាបបានថា ជាវិបស្សនាញាណ ព្រោះជាក្រសែនៃវិបស្សនា ។ កាលណា គោត្រភូញាណរលត់ហើយ មគ្គចិត្តកើតជាញាណទស្សនវិសុទ្ធិ ។

បរិញ្ញា ៣

ការចម្រើនសតិប្បដ្ឋាន ដែលជាការអប់រំចម្រើនបញ្ញា ដើម្បីដឹង ច្បាស់នូវអរិយសច្ចធម៌នោះ ធ្វើឱ្យកើតបរិញ្ញា គឺបរិញ្ញាដឹងជុំវិញ ៣ ថ្នាក់ បានដល់ញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា ។

ញាតបរិញ្ញា គឺបញ្ញាដែលប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌ ដែលប្រាកដដោយសភាពមិនមែនតួខ្លួន ដោយនាមរូបបរិច្ឆេទញាណ ជាដើមទៅ ជាមូលដ្ឋានដើម្បីបង្អោនពិចារណាលក្ខណៈនៃនាមធម៌ និងរូប

ធម៌ដទៃ ។ បន្ថែមឡើង ដឹងសព្វទូទៅឡើងតាមលក្ខណៈនៃនាមធម៌ និងរូបធម៌ ដែលបានប្រចក្សហើយក្នុងនាមរូបបរិច្ឆេទញាណ ។

តីរណបរិញ្ញា គឺ**បញ្ញាដែលពិចារណាលក្ខណៈ** របស់សភាវធម៌ដែលប្រាកដស្មើគ្នា ដោយដឹងជុំវិញទូទៅ មិនចោះចំពោះ ប្រាថ្នាត្រង់នាមធម៌ និងរូបធម៌ណានោះឡើយ ព្រោះដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដរហូតទូទៅទាំង ៦ ទ្វារ ។ ភាពសម្បូរនៃបញ្ញា ដែលជាក់ច្បាស់ក្នុងការស្មើគ្នានៃនាមធម៌ និងរូបធម៌ ធ្វើឱ្យប្រចក្សការកើតឡើង និងរលត់ទៅនៃនាមធម៌ និងរូបធម៌តាំងតែពីឧទយព្វយញាណ ជាដើមទៅ ។

បហានបរិញ្ញា គឺពិចារណាសេចក្តីរលត់ទៅនៃនាមធម៌ និងរូបធម៌ រហូតប្រចក្សច្បាស់ការរលត់ទៅនៃនាមធម៌ និងរូបធម៌ដោយ ភង្គញាណ ហើយបញ្ញាដឹងជុំវិញទូទៅកើនឡើង ក៏ផ្តើមលះបង់នូវសេចក្តីត្រេកអរក្នុងនាមធម៌រូបធម៌ ព្រោះឃើញទោសនៃនាមធម៌ និងរូបធម៌ខ្លាំងឡើង ។ ជាបហានបរិញ្ញា ជាដើមទៅរហូតដល់មគ្គញាណ ។

ក្នុងមួយថ្ងៃ ។ បច្ច័យដែលនឹងឱ្យសតិប្បដ្ឋានកើតរលឹកដឹងលក្ខ-ណៈនៃសភាវធម៌ដែលកំពុងប្រាកដជាប្រក្រតី តាមសេចក្តីពិតនោះ តិចជាងបច្ច័យដែលនឹងឱ្យអកុសលធម៌កើតឡើងច្រើនហួសពេក ដូច្នោះទើបការចម្រើនឡើងនៃពោធិបក្ខិយធម៌ ៣៧ ដែលជាចំណែក ប្រកបនៃការដឹងច្បាស់អរិយសច្ចធម៌ ៤ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨

រួមជាពោធិបក្ខិយធម៌ ៣៧ នោះ ត្រូវសន្សំអប់រំដ៏យូរណាស់ ព្រោះមិនមែនជាការធ្វើឡើងនូវសភាវៈណាមួយសម្រាប់ដឹងឡើយ តែជាការរលឹកហើយរលត់ទៅយ៉ាងរហ័សជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក្នុងខណៈនេះឯង ។ បើខណៈនេះមិនដឹងថា សតិប្បដ្ឋានជាអ្វី យ៉ាងណា មិនដឹងថាសភាវៈដែលកំពុងប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដោយសភាពដែលជាបរមត្ថធម៌ មិនមែនតួខ្លួនយ៉ាងនោះយ៉ាងណាទេ ក៏នឹងត្រូវអប់រំបញ្ញាថ្នាក់ដើម ដោយការស្តាប់ព្រះធម៌ ដែលព្រះដ៏មានព្រះភាគសម្តែងទុក ដើម្បីឱ្យពុទ្ធបរិស័ទយល់លក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ត្រឹមត្រូវ ត្រង់តាមសេចក្តីពិត តាមដែលព្រះអង្គបានត្រាស់ដឹង ហើយនឹងត្រូវពិចារណា គន្លងផ្លូវបដិបត្តិ គឺការអប់រំចម្រើនបញ្ញាឱ្យត្រឹមត្រូវថា ហេតុត្រូវ សមគួរដល់ផល ។ កាលណាផលគឺបញ្ញាដែលប្រចក្សច្បាស់ នៃត្រៃលក្ខណៈ គឺអនិច្ចំ ទុក្ខំ អនត្តា សភាពដែលកើតឡើង និងរលត់ទៅជាទុក្ខ ព្រោះមិនមែនជាសភាពដែលគួរត្រេកអរ និងជាអនត្តានៃសភាវធម៌ដែលកំពុងប្រាកដក្នុងខណៈនេះ ក៏រមែងដឹងថាមិនមែនផ្លូវដទៃឡើយ ក្រៅពីផ្លូវតែមួយ គឺ សតិប្បដ្ឋានកើតឡើងរលឹកដឹង សិក្សា សង្កេតលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដក្នុងខណៈនេះទៅជារឿយ ៗ រហូតទាល់តែសង្ខារក្ខន្ធ ទាំងឡាយ នឹងជាបច្ច័យតាក់តែងឱ្យបញ្ញាដែលអប់រំសម្បូរហើយកើតឡើង ជាវិបស្សនាញាណមួយថ្នាក់ ៗ ។

ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់អប់រំព្រះបារមី ៤ អសង្ខ្យេយ្យ សែនកប្ប ក្រោយពីពេលដែលព្រះអង្គទ្រង់បានទទួលព្រះពុទ្ធព្យាករណ៍ ពីព្រះទីបង្ករសម្មាសម្ពុទ្ធជាម្ចាស់ហើយ ព្រះអង្គទ្រង់អប់រំចម្រើនបារមីមកដោយរហូត ហើយបានគាល់នូវព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ២៤ ព្រះអង្គ មុននឹងព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ជាព្រះសោតាបន្នបុគ្គល ព្រះសកទាគាមិបុគ្គល ព្រះអនាគាមិបុគ្គល រួចហើយបន្លុះនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ដោយលំដាប់ ក្នុងបច្ឆិមយាម ត្រង់គល់នៃដើមព្រះស្រីមហាពោធិ៍ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ។

ព្រះអគ្គសាវ័កទាំង ២ គឺព្រះសារីបុត្រ អ្នកកំពូលលើសខាងបញ្ញា និងព្រះមហាមោគ្គល្លានអ្នកកំពូលលើសខាងឥទ្ធិឫទ្ធិនោះ អប់រំចម្រើនបញ្ញារួចមកហើយ ១ អសង្ខ្យេយ្យ សែនកប្ប ។ ក្នុងជាតិក្រោយបង្អស់នៃព្រះសារីបុត្រ បន្លុះជាព្រះសោតាបន្នបុគ្គល ពេលបានស្តាប់ព្រះអស្សជិសម្តែងធម៌ ដល់លោកដ៏មានអាយុ និងព្រះមោគ្គល្លាន ក៏បានបន្លុះជាព្រះសោតាបន្ន ពេលបានស្តាប់ព្រះសារីបុត្រសម្តែងធម៌ដែលព្រះអស្សជិបានសម្តែងហើយនោះ ។

ព្រះមហាសាវ័កជាឯតទគ្គ គឺជាកំពូលលើសក្នុងផ្លូវផ្សេង ។ ដូចជាព្រះមហាកស្សប ព្រះអានន្ទ ព្រះឧបាលី ព្រះអនុរុទ្ធ ជាដើម ក៏បានអប់រំចម្រើនបញ្ញាមកហើយអស់សែនកប្បដែរ ។ ព្រះអរហន្តសាវ័ក និង

ពុទ្ធបរិស័ទក៏បានអប់រំចម្រើនបញ្ញាមកហើយ រហូតដឹងច្បាស់ អរិយសច្ច-ធម៌ ជាព្រះអរិយបុគ្គលជាចំនួនច្រើនក្នុងកាលសម្បត្តិ គឺសម័យដែល ព្រះមានព្រះភាគ ព្រះអង្គមិនទាន់រំលត់ខន្ធ បរិនិព្វាន និងក្រោយពី ព្រះអង្គ រំលត់ខន្ធបរិនិព្វានហើយ មិនយូរប៉ុន្មានឡើយ បន្តមករហូត ដល់យុគ សម័យបច្ចុប្បន្ន ដែលការដឹងច្បាស់នូវអរិយសច្ចធម៌ រមែងស្រុតថយចុះ តិចទៅ ។ តាមការសិក្សា ការយល់ព្រះធម៌ និងការបដិបត្តិធម៌ ដោយ ត្រឹមត្រូវ និងដោយហេតុ គឺការអប់រំសន្សំចម្រើនបញ្ញាដែលសមគួរ ដល់ផល ។

មុនការត្រាស់ដឹងនៃព្រះមានព្រះភាគនោះ មានអ្នកអប់រំចម្រើន សមថភាវនារហូតដល់អាចសម្រេចគុណវិសេស ធ្វើឥទ្ធិបាដិហារិយ៍ផ្សេង ៗ បាន តែមិនអាចរំលត់កិលេសបានជាសមុច្ឆេទឡើយ ។ កាលព្រះដ៏មាន ព្រះភាគ ព្រះអង្គទ្រង់ត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ និង ព្រះអង្គទ្រង់បានសម្តែងព្រះធម៌ហើយ ក៏មានអ្នកដឹងច្បាស់នូវអរិយសច្ច ធម៌មានចំនួនច្រើន និងលោកខ្លះ ដែលចម្រើនសមថភាវនាសម្រេច ឈានចិត្តមកហើយ នៅពេលចម្រើនសតិប្បដ្ឋាន ក៏ដឹងច្បាស់អរិយសច្ច ធម៌ដែរ ។ ដូច្នេះ ព្រះអរិយសាវ័កទើបមាន ២ ប្រភេទ គឺអ្នកមិនបានឈាន ១ និងអ្នកបានឈានផងដែរ ១ ។

ព្រះអរិយបុគ្គល ជាអ្នកមិនបានឈាននោះសម្រេចមគ្គចិត្តដោយ មិនមានឈានជាបាទ គឺមិនបានបន្លុះឈានចិត្តឡើយ ទើបឈានចិត្ត

មិនកើតឡើងជាអារម្មណ៍ឱ្យពិចារណា ហើយសូម្បីដល់ទៅថា លោកុត្តរ ចិត្តប្រចក្សនូវនិព្វានយ៉ាងច្បាស់លាស់ មាំមួនដូចគ្នានឹងអប្បនាសមាធិ ដែលតាំងមាំណែនក្នុងអារម្មណ៍នៃឈានចិត្តថ្នាក់ផ្សេង ។ ក៏ដោយ តែ កាលណាព្រះអរិយមិនបានឈាន មិនបានបន្លុះឈានទេ ក៏មិនអាច ចូលដល់ឈានសមាបត្តិបានឡើយ ។ ការរាប់ប្រភេទចិត្តដោយន័យ ៨៩ ដួង ទើបជាការរាប់ដោយន័យរបស់ព្រះអរិយបុគ្គល ដែលជាអ្នកមិនបាន ឈាន ។ ចំណែកព្រះអរិយបុគ្គលដែលបានឈានផងនោះ បន្លុះមគ្គចិត្ត ផលចិត្ត ដោយមានឈានជាបាទ ដូច្នោះ ទើបត្រូវជាអ្នកបន្លុះឈាន ព្រមដោយ វសី ឈានចិត្តកើតឡើងជាអារម្មណ៍ ឱ្យមហាកុសលញាណ សម្បយុត្តចិត្ត ពិចារណារហូតដល់បន្លុះលោកុត្តរមគ្គចិត្ត ផលចិត្តបាន ដោយការពិចារណាឈានចិត្តនោះឯង ព្រះអរិយបុគ្គលដែលបន្លុះ មគ្គ ផល និព្វាន ព្រមដោយអង្គនៃឈានថ្នាក់ផ្សេង ។ ផុតចាកកិលេស ដោយ បញ្ញា និងដោយសេចក្តីស្ងប់ នៃឈានចិត្តថ្នាក់ផ្សេង ។ ។ ការរាប់ប្រភេទ ចិត្ត ដោយន័យ ១២១ ដួង ទើបជាការរាប់ដោយន័យនៃព្រះអរិយបុគ្គល ដែលជាអ្នកបានឈាន ។

សមាបត្តិ ៣

សមាបត្តិ ៣ គឺ ឈានសមាបត្តិ ១ ផលសមាបត្តិ ១ និរោធសមាបត្តិ ១ បុថុជ្ជនដែលបន្លុះឈានចិត្ត និងមាន វសី ៥ គឺការស្ទាត់ជំនាញក្នុងការចូលចេញឈានថ្នាក់នីមួយ ។ ជាដើមនោះជាឈានលាភីបុគ្គល គឺជាអ្នកមានឈានជាលាភ ទើបអាចចូល **ឈានសមាបត្តិ** គឺឈានវិថីចិត្តកើតបន្តគ្នាតាមផ្លូវមនោទ្វារ ដោយមិនមានភវង្គចិត្តកើតខណ្ឌឡើយរាល់ ។ វេលាដែលកំណត់ទុក ក្នុង ១ ថ្ងៃ ។ ខណៈដែលជាឈានសមាបត្តិនោះ រំងាប់ទុក្ខកាយ និងទុក្ខចិត្ត ព្រោះ ខណៈនោះស្ងប់ចាកពីអារម្មណ៍ដទៃ ។ ទាំងអស់ មានតែសេចក្តីសុខស្ងប់ដោយការចូលដល់អារម្មណ៍ នៃឈានត្រឹមតែម្យ៉ាងប៉ុណ្ណោះ ខណៈនោះទើបជាឈានសមាបត្តិ ។

ព្រះអរិយបុគ្គលដែលជាអ្នកបានឈាននោះ អាចចូល**ផលសមាបត្តិ** គឺលោកុត្តរបឋមជ្ឈានផលចិត្ត ឬលោកុត្តរទុតិយជ្ឈានផលចិត្ត ឬលោកុត្តរតតិយជ្ឈានផលចិត្ត ឬលោកុត្តរចតុត្ថជ្ឈានផលចិត្ត ឬលោកុត្តរបញ្ចមជ្ឈានផលចិត្ត កើតឡើងមាននិព្វានជាអារម្មណ៍រាល់ ។ វេលាដែលកំណត់ទុកក្នុង ១ ថ្ងៃ ។ ដោយមិនមានភវង្គចិត្តកើតខណ្ឌឡើយ ។ ផលសមាបត្តិជាការចូលដល់លោកុត្តរឈានតាមលំដាប់ថ្នាក់នៃលោកុត្តរផលចិត្តដែលកើតព្រមជាមួយអង្គនៃឈាននោះ ។ ។

ខណៈដែលផលសមាបត្តិវិថីនឹងកើតនោះ កាមាវចរចិត្ត ដែលកើតមុន មិនឈ្មោះថាបរិកម្ម និងឧបចារទេ តែជាអនុលោមទាំង ៣ ខណៈ ព្រោះ អនុលោមដល់ការដែលលោកុត្តរផលចិត្តធ្លាប់កើតហើយ នឹងកើតឡើងមាននិព្វានជាអារម្មណ៍ទៀត តាមថ្នាក់នៃលោកុត្តរឈាន ខុសផ្សេងនឹងបរិកម្ម ឧបចារ អនុលោមក្នុងមគ្គវិថីដែលមគ្គចិត្តនឹងកើតឡើង ដើម្បីរំលត់កិលេសជាសមុច្ឆេទ ។ ខណៈដែលផលចិត្តកើតឡើងមាននិព្វានជាអារម្មណ៍ រាល់វេលាដែលកំណត់ទុក មួយថ្ងៃ ៗ នោះជាផលសមាបត្តិ ។

ចំពោះព្រះអនាគាមិបុគ្គល និងព្រះអរហន្តដែលបន្លុះដល់ នេវសញ្ញានាសញ្ញាយតនឈាននោះ អាចចូល**និរោធសមាបត្តិ** គឺរំលត់ចិត្ត និងចេតសិកមិនលើសពី ៧ ថ្ងៃ ព្រោះអាហារដែលបរិភោគហើយនោះ ទ្រទ្រង់រាងកាយបានមិនហួស ៧ ថ្ងៃឡើយ ។ ការចូលនិរោធសមាបត្តិ ដែលរំលត់ចិត្តនិង ចេតសិកបានមួយគ្រា ៗ នោះ ត្រូវប្រកបដោយកម្លាំង ២ ផ្នែក គឺទាំងសមថៈ និងវិបស្សនា គឺសូម្បីដល់ថាជាព្រះអនាគាមិបុគ្គល ឬព្រះអរហន្តក៏ដោយ តែបើមិនបន្លុះដល់នេវសញ្ញានាសញ្ញាយតនឈានទេ ក៏ចូលនិរោធសមាបត្តិមិនបានដែរ ឯព្រះសោតាបន្នបុគ្គល និងព្រះសកទាគាមិបុគ្គលទោះជាបានបន្លុះដល់ នេវសញ្ញានាសញ្ញាយតនឈានក៏ដោយ ក៏ចូលនិរោធសមាបត្តិមិនបាន ។

ពេលនឹងចូលនិរោធសមាបត្តិនោះ ត្រូវចូលតាំងពីបឋមជ្ឈានជាលំដាប់ទៅព្រោះពេលចេញពីបឋមជ្ឈានហើយពិចារណាសង្ខារទាំងឡាយ

ដោយជាសភាពមិនទៀង ជាទុក្ខ ជាអនត្តា រួចទើបចូលទុតិយជ្ឈាន ចេញពីទុតិយជ្ឈាន ហើយពិចារណាសង្ខារទាំងឡាយ ដោយសភាព មិនទៀង ជាទុក្ខ ជាអនត្តា រួចទើបចូលតតិយជ្ឈាន ចេញពីតតិយជ្ឈាន ហើយ ពិចារណាសង្ខារទាំងឡាយ ដោយសភាពមិនទៀង ជាទុក្ខ ជាអនត្តា ។ ល ។ រហូតទៅដល់អាកិញ្ចញ្ញាយតនឈាន ពេលចេញពី អាកិញ្ចញ្ញាយតនឈានហើយធ្វើកិច្ចខាងដើម ៤ យ៉ាងគឺ[៣៩]

នានាពន្ធអវិកោបន	១
សង្ឃបដិមានន	១
សត្ថុបក្កោសន	១
អទ្ធានបរិច្ឆេទ	១

នានាពន្ធអវិកោបន គឺអធិដ្ឋានឱ្យរបស់បរិក្ខារប្រើប្រាស់ ដែលជាប់នឹងខ្លួន ដូចជាបាត្រ ចីវរ គ្រែ ទីអាស្រ័យ មិនត្រូវវិនាសហិនហោច ដោយភ្លើង ទឹក ខ្យល់ ចោរ ជាដើម ក្នុងរយៈពេល ៧ ថ្ងៃដែលជានិរោធសមាបត្តិនោះឡើយ ចំណែកវត្ថុណាដែលប្រើនៅជាប់នឹងខ្លួន ដូចជា សំពត់ស្មៀក សំពត់ដណ្តប់ ទីអង្គុយ មិនមានកិច្ចក្រៅផ្សេងដែលនឹងអធិដ្ឋានឡើយ ព្រោះសមាបត្តិនោះឯង រមែងគ្រប់គ្រងការពារមិនឱ្យត្រូវវិនាសហិនហោច បាត់បង់ឡើយ ។

---

[៣៩] សទ្ធម្មបកាសិនី អដ្ឋកថាខុទ្ទកនិកាយ បដិសម្ភីទាមគ្គ អដ្ឋកថានិរោធសមាបត្តិញាណនិទ្ទេស

សង្ឃបដិមានន គឺអធិដ្ឋានឱ្យចេញពីនិរោធសមាបត្តិ ពេលត្រូវរួមប្រជុំសង្ឃ ដើម្បីធ្វើសង្ឃកម្មណាមួយ ។

សត្ថុបក្កោសន គឺអធិដ្ឋានឱ្យចេញពីនិរោធសមាបត្តិ ពេលព្រះមានព្រះភាគត្រាស់ហៅរក ។

អទ្ធានបរិច្ឆេទ គឺការពិចារណាកំណត់កាលនៃជីវិតថា នឹងមានអាយុ ទៅរហូត ៧ ថ្ងៃឬទេ ព្រោះនៅចន្លោះនិរោធសមាបត្តិនោះ ចុតិចិត្តកើតមិនបាន កាលណាមានអាយុទៅរហូត ៧ ថ្ងៃបានទើបចូលនិរោធសមាបត្តិ ។

កាលធ្វើបុព្វកិច្ច ៤ នេះហើយ ក៏ចូលនេវសញ្ញានាសញ្ញាយតនឈានដោយចិត្តកើត រលត់បន្តគ្នាតាមលំដាប់វារៈនៃនេវសញ្ញានាសញ្ញាយតនឈានវិថីចិត្ត ដោយនេវសញ្ញានាសញ្ញាយតន ឈានចិត្តកើត ២ ខណៈ រួចហើយចិត្ត ចេតសិកមិនកើតឡើយ ក្នុងចន្លោះដែលជានិរោធសមាបត្តិរហូត ៧ ថ្ងៃ ។

កាលដល់កំណត់ចេញចាកនិរោធសមាបត្តិហើយ ផលចិត្តកើតឡើង ១ ខណៈ ហើយភវង្គចិត្តទើបកើតបន្ត ។

និរោធសមាបត្តិមានចំពោះតែក្នុងភូមិដែលមាន ខន្ធ ៥ ប៉ុណ្ណោះ ក្នុងអរូបព្រហ្មភូមិមិនមាននិរោធសមាបត្តិទេ ព្រោះមិនមានរូបឈានចិត្ត ។

គន្ថធម្មវាចម្រើនវិបស្សនា

គន្លងផ្លូវចម្រើនវិបស្សនា

អ្នកសួរ ការចម្រើនសមថភាវនាមានអារម្មណ៍ទាំងអស់ ៤០ ប្រភេទ ឃើញថាភាគច្រើនតែងនិយមអានាបាណស្សតិ យល់ថានឹងមិនអាចដុសខាត់កិលេសមិនដល់ព្រះនិព្វាន ឬបន្លុះអរិយសច្ចធម៌បានឡើយ ។

សុចិន្ត បើជាការចម្រើនសមថភាវនា ក៏រលត់កិលេសមិនបាន ព្រោះមិនសម្រេចដល់ព្រះនិព្វាន ដែលជាការដឹងច្បាស់អរិយសច្ចធម៌ ។

អ្នកសួរ បើយ៉ាងនោះការនឹងដុសខាត់កិលេសបាន ដូចយ៉ាងបុគ្គលទូទៅនេះ ដែលបំណងនឹងដុសខាត់កិសេលឱ្យដល់ព្រះនិព្វាន តែគេមិនយល់ទាល់តែសោះក្នុងជីវិតប្រចាំថ្ងៃនេះថា អ្វីជាហេតុឱ្យយើងប្រកាន់ ។ បើសិនមិនយល់ តែជាលោភៈ ឬជាចំណង់ប្រាថ្នា ត្រូវការដែលថានឹងចង់លះកិលេសតែម្យ៉ាង ដោយមិនស្គាល់កិលេសនោះ តើនឹងអាចចម្រើនសតិប្បដ្ឋាន ឬទេ ?

សុចិន្ត ប្រព្រឹត្តទៅមិនបានឡើយ ។

អ្នកសួរ សមថភាវនា និងវិបស្សនាភាវនាទាំង ២ យ៉ាងនេះចម្រើនមិនបាន ឬ ?

សុចិន្ត គំនិតយល់តែខ្លួនឯងថា កំពុងចម្រើនសមថភាវនា ឬវិបស្សនាភាវនាប៉ុណ្ណោះ សេចក្តីពិតកាលបើមិនមែនបញ្ញាទេនោះ ក៏ចម្រើនសមថភាវនា និងវិបស្សនាភាវនាមិនបាន ។

អ្នកសួរ ពេលនេះបើនឹងចម្រើនសតិប្បដ្ឋាន តើអាចារ្យនឹងមានគន្លងផ្លូវយ៉ាងណាដែរឱ្យគេពិចារណា ?

សុចិន្ត មិននរណា ទប់ជ្រែង រុញច្រាន បង្ខំឱ្យនរណាចម្រើនសតិប្បដ្ឋានបានឡើយ ។ ទៅយកកូនក្មេងម្នាក់មកអង្គុយក្នុងទីនេះ ហើយប្រាប់ឱ្យចម្រើនសតិប្បដ្ឋាន ក្មេងមិនស្គាល់ពីកិលេសសោះ ថែមទាំងមិនបានចង់លះកិលេសដែរនោះ តើក្មេងនឹងចម្រើនសតិប្បដ្ឋានបានយ៉ាងណាទៅ ហើយដល់ធំជាមនុស្សចាស់ក៏នៅតែមិនបានអស់កិលេស ។ មនុស្សចាស់គ្រប់រូបក៏មានកិលេស ដែលម្នាក់ ៗ សន្ធឹកសន្ធាប់ណាស់ ឥឡូវសាកល្បង សួរគាត់មនុស្សចាស់ម្នាក់ ៗ ថាតើចង់អស់កិលេសទេ ? ភាគច្រើន ក៏ឆ្លើយថាមិនចង់អស់ទេ ទោះជាអ្នកខ្លះឆ្លើយថាមិនចង់មានកិលេស ក៏ដោយ ប៉ុន្តែកាលពោលពាក្យថា **កិលេស**នោះ តើស្គាល់កិលេសពិតប្រាកដហើយឬនៅ ? លោភៈជាកិលេសតើចង់បានលោភៈឬទេ ? មិនចូលចិត្តឈ្មោះលោភៈ ប៉ុន្តែត្រូវការលោភៈគ្រប់ ៗ ខណៈ នេះបញ្ជាក់ថាមិនយល់នូវលក្ខណៈនៃលោភៈ ដែលជាកិលេស ។ អាហារឆ្ងាញ់ឬទេ ? សំពត់ស្រស់ទេ ? ភ្លេងនេះពីរោះទេ?

ក្លិននេះក្រអូបទេ ? កៅអីនេះទន់ល្អទេ ? ប៉ះស្ពាបសម្ផស្ស ហើយសប្បាយទេ ? នេះគឺមិនចូលចិត្តឈ្មោះលោភៈតែគ្រប់ ខណៈចិត្តត្រូវការលោភៈ ។ ការចម្រើនសតិប្បដ្ឋានជាការចម្រើន សតិបញ្ញា មិនមែនជាការចង់ធ្វើសមាធិទេ ។

អ្នកសួរ អត្តសញ្ញា គឺអ្វី ?

សុចិន្ត អត្តសញ្ញា គឺសេចក្តីចាំដោយការប្រកាន់ថា ជាតួខ្លួន ។ សេចក្តីពិត មិនគួរសង្ស័យក្នុងអត្តសញ្ញាឡើយ ព្រោះថាគ្រប់មនុស្សមាន អត្តសញ្ញា ។ កាលណាដឹងច្បាស់នូវអរិយសច្ចធម៌ ជាព្រះសោតា-បន្នបុគ្គល ទើបរំលត់សេចក្តីយល់ខុសដែលប្រកាន់សភាវធម៌ ថា ជាតួខ្លួន សត្វ បុគ្គលបាន ប៉ុន្តែមុនដែលសតិនឹងកើត និងបញ្ញា សិក្សាយល់លក្ខណៈនៃសភាវធម៌រហូតដល់ដឹងជាក់ប្រចក្សច្បាស់ នូវសភាវធម៌ដែលមិនមែនតួខ្លួនបាននោះ ក៏នឹងត្រូវមានអត្តសញ្ញា ។ កាល ណាសតិមិនកើត ទើបមិនរលឹកដឹងលក្ខណៈ នៃសភាវធម៌ ដែលប្រាកដត្រង់ទ្វារនីមួយ ៗ តាមសេចក្តីពិត ទើបយល់ខុស ប្រកាន់សភាវធម៌ដែលប្រាកដរួមគ្នាជាអត្តា គឺជាតួខ្លួន ជាវត្ថុណា មួយ ។ កាលណាមិនដឹងសេចក្តីពិតនៃសភាវធម៌ខណៈនេះទេ ក៏ មានអត្តសញ្ញា មានការចងចាំថាជាយើង ដែលឃើញនិងចាំវត្ថុ ដែលឃើញនោះជាសត្វ បុគ្គល តួខ្លួន ផ្សេង ៗ ។

បញ្ញាដែលកើតពីការស្តាប់ មិនអាចប្រចក្សច្បាស់ថា វត្ថុដែលធ្លាប់ឃើញជាមនុស្ស ជាសត្វនោះទេ សេចក្តីពិតត្រឹមតែជាសភាវៈ ដែលកំពុងប្រាកដតាមភ្នែកប៉ុណ្ណោះ ដូច្នោះការស្តាប់ព្រះធម៌ ការសិក្សាព្រះធម៌ ទើបត្រូវពិចារណារឿយ ៗ ជាញយ ៗ ពិចារណាហើយ ពិចារណាទៀត ពិចារណាយ៉ាងល្អិតល្អន់រហូតដល់យល់ក្នុងពាក្យដែលសម្តែងលក្ខណៈនៃសភាវធម៌ ដូចពាក្យថា **វត្ថុដែលប្រាកដតាមផ្លូវភ្នែក** នោះជាពាក្យដែលត្រឹមត្រូវបំផុត ព្រោះសម្តែងថា ជាធាតុមួយបែបដែលប្រាកដតាមភ្នែក វត្ថុដែលប្រាកដឱ្យឃើញនោះ មិនថាជាពណ៌ក្រហម ពណ៌ខៀវ ពណ៌ផ្ទៃមេឃ ពណ៌លឿង ពណ៌ស ពណ៌ថ្លា ពណ៌ល្អក់ទេ ក៏ត្រូវតែប្រាកដកាលប៉ះខ្ទប់នឹងចក្ខុបសាទ ហើយដល់កាលណាឃើញហើយមិនដឹងសភាវធម៌តាមសេចក្តីពិតទេ ទើបមានអត្តសញ្ញាថាជាមនុស្ស សត្វ បុគ្គល ផ្សេង ៗ ។ ខណៈដែលយកចិត្តទុកដាក់ក្នុងពណ៌ផ្សេង ៗ នោះធ្វើឱ្យនឹកគិតជារូបរាង សណ្ឋាន កើតសេចក្តីចងចាំក្នុងរូបរាងសណ្ឋាន ទើបឃើញជាមនុស្ស សត្វ វត្ថុរបស់របរផ្សេង ៗ ដែលរូបរាងដែលឃើញជាមនុស្ស សត្វ វត្ថុរបស់របរផ្សេង ៗ នោះ ក៏ត្រូវមានច្រើនពណ៌ ដូចជា ពណ៌ខ្មៅ ពណ៌ស ពណ៌សាច់ ជាដើម បើមិនចាំ ចំណាំពណ៌ផ្សេង ៗ ជា

រូបរាង សណ្ឋានទេ សេចក្តីកំណត់សំគាល់ថា ជាសត្វ បុគ្គល វត្ថុ ផ្សេង ។ ក៏មានមិនបាន ។

ដូច្នោះខណៈពេលដែលឃើញហើយចាប់អារម្មណ៍ភ្លើតភ្លើន ក្នុងនិមិត្ត គឺរូបរាង សណ្ឋាន និងអនុព្យញ្ជនៈ គឺចំណែកល្អិតនៃវត្ថុ ដែលប្រាកដ ឱ្យជ្រាបថាខណៈនោះព្រោះពណ៌ប្រាកដ ទើបធ្វើឱ្យ នឹកគិតជារូបរាង សណ្ឋាន និងចំណែកល្អិតនៃវត្ថុផ្សេង ។ ឡើង ។ ដល់កាលណាសតិកើតរលឹកដឹង និងបញ្ញាផ្តើមសិក្សាពិចារណា ក៏នឹងផ្តើមដឹងថា និមិត្ត និងអនុព្យញ្ជនៈទាំងឡាយសុទ្ធតែជាពណ៌ ផ្សេង ។ នោះ ក៏ត្រឹមតែជាសភាវៈដែលប្រាកដតាមភ្នែកប៉ុណ្ណោះ នេះគឺបញ្ញាដែលផ្តើមចូលដល់លក្ខណៈនៃសភាវធម៌ ដែលមិន មែនជាតួខ្លួន សត្វ បុគ្គល ។ កាលណាសតិកើតរលឹកដឹងជារឿយ ។ ញយ ។ ទៅ ក៏នឹងយល់អត្ថដែលព្រះមានព្រះភាគត្រាស់ថា មិនជាប់ក្នុងនិមិត្ត និងអនុព្យញ្ជនៈ (ដោយការអប់រំចម្រើនបញ្ញា ដឹងសភាវធម៌ ដែលប្រាកដតាមសេចក្តីពិត) និងលះបង់នូវអត្ត សញ្ញាក្នុងវត្ថុដែលកំពុងប្រាកដតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ អណ្តាត កាយ ចិត្ត តាមថ្នាក់នៃបញ្ញាដែលចម្រើនឡើង ។

ដូច្នោះ នឹងត្រូវយល់ថា មិនថាព្រះត្រៃបិដកនឹងពោលដល់ ត្រង់ន័យសេចក្តីណា ឬព្យញ្ជនៈណា ។ ឡើយ ក៏ជារឿងសភាវធម៌ ក្នុងជីវិតប្រចាំថ្ងៃពិត ។ ដែលសតិនឹងត្រូវរលឹក និងពិចារណាឱ្យ

យល់ រហូតទាល់តែបញ្ញានឹងដឹងច្បាស់ ប្រចក្សច្បាស់លក្ខណៈនៃ
សភាវធម៌ដែលប្រាកដ រហូតដល់រំលត់កិលេសបានជាសមុច្ឆេទ ។
នេះជារឿងដែលអ្នកទាំងឡាយគ្រប់ ៗ គ្នា សន្សឹមជារឿយ ៗ
ស្តាប់ទៅ សិក្សាទៅ ពិចារណាទៅតាមប្រក្រតីក្នុងសភាវៈដែល
ជាជីវិតពិត ៗ ព្រោះនៅមិនទាន់អាចនឹងរំលត់កិលេស លោភៈ
ទោសៈ មោហៈ ។ ល ។ បានទេ សឹងមនុស្សទាំងឡាយចង់នឹង
រំលត់កិលេសឱ្យអស់ចេញពេកណាស់ តែនឹងត្រូវដឹងថា កិលេស
នឹងរំលត់បានក៏នៅពេលណា លោកុត្តរមគ្គចិត្ត កើតឡើងរំលត់
សក្កាយទិដ្ឋិ គឺការប្រកាន់សភាវធម៌ថា ជាតួខ្លួន សត្វ បុគ្គល តាម
ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជាព្រះអរិយ
បុគ្គលថ្នាក់សោតាបន្នជាមុនសិន រួចហើយបញ្ញាទើបចម្រើនឡើង
រហូតដឹងច្បាស់នូវអរិយសច្ចធម៌ ជាព្រះសកទាគាមី ព្រះអនាគាមី
ព្រះអរហន្តតាមលំដាប់ ។ ដូច្នោះ ទើបត្រូវអប់រំចម្រើនបញ្ញា
មិនមែនបែរមុខសំដៅបង្ខំយ៉ាងលឿននឹងទៅបដិបត្តិ អស់ថ្ងៃ អស់
ខែ អស់ឆ្នាំ ដោយមិនយល់ហេតុបច្ច័យថា សតិ ជាសម្មាសតិ
ដែលជាមគ្គមានអង្គ ៨ នោះនឹងកើតឡើងកាលណាសិក្សាយល់
លក្ខណៈនៃសភាវធម៌ដែលប្រាកដតាមភ្នែក ត្រចៀក ច្រមុះ
អណ្តាត កាយ ចិត្ត ពិត ៗ ជាមុនសិន រួចហើយទើបសម្មាសតិកើត
រលឹកបាន និងបញ្ញាផ្តើមសិក្សាពិចាណា រហូតប្រចក្សច្បាស់

លក្ខណៈនៃសភាវធម៌ ជាប្រក្រតី តាមសេចក្តីពិតក្នុងជីវិតប្រចាំថ្ងៃ ។ ការចម្រើនសតិប្បដ្ឋានជាត្រៃសិក្ខា គឺអធិសីលសិក្ខា អធិចិត្តសិក្ខា (សមាធិ) អធិបញ្ញាសិក្ខា ព្រោះក្នុងខណៈ ដែលសតិរលឹកលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដនោះ ជាសីលយ៉ាងល្អិត គឺជាអធិសីលសិក្ខា ជាការរលឹកដឹងលក្ខណៈនៃចិត្ត ចេតសិក រូប ដឹងលក្ខណៈនៃកុសលធម៌ និងអកុសលធម៌មុននឹងកើតការប្រព្រឹត្តណា ។ តាមកាយ តាមវាចា ។ សតិប្បដ្ឋានជា អធិសីលសិក្ខា ព្រោះជាសេចក្តីតាំងមាំនៃឯកគ្គតាចេតសិក (សមាធិ) ក្នុងអារម្មណ៍ ដែលប្រាកដ ដែលកើតរលត់យ៉ាងលឿនរហ័ស ។ សតិប្បដ្ឋានជាអធិបញ្ញាសិក្ខា ព្រោះជាបញ្ញាដែលពិចារណាសិក្សាដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ជាប្រក្រតីដោយល្អិតល្អន់តាមសេចក្តីពិត ។

អ្នកសួរ ខ្ញុំសូមអភ័យទោសអ្នកស្តាប់ផងបាទ៎ ដែលលោកអាចារ្យ អធិប្បាយរួចទៅហើយនេះ ត្រូវចំនឹងខ្លួនខ្ញុំតែម្តង ហើយខ្លួនខ្ញុំក៏មិនមែនថាមិនយល់តាមដែលអាចារ្យពោលនេះដែរ តែមិនយល់ខ្លាំងជាងនោះទៀតដូចជាសម្មតិថា យើងនឹងបដិបត្តិរឿងសតិប្បដ្ឋាន

នេះ អម្បាញ់មិញថាក្លាយជាខ្លួនយើងទៅប្រើសតិ សតិក៏មានច្រើនផ្លូវ ច្រើនទ្វារ សតិខាងដើមនេះឯង បាទ ! ចំពោះខ្លួនខ្ញុំនៅមិនទៅជាយ៉ាងណាឡើយ តាមដែលត្រួតមើលខ្លួនឯងខាងដើមនេះ នៅមិនទាន់ចូលនាមរូបបរិច្ឆេទញាណសោះតែម្តង តើនឹងធ្វើយ៉ាងណាល្អ ?

សុចិន្ត ពេលនឹង**ធ្វើវិបស្សនា**ម្តងណា ក៏តែងតែរវល់ខ្វល់ខ្វាយលំបាកម្តងនោះភ្លាម ព្រោះថានឹងធ្វើ នឹងធ្វើបានត្រូវដូចម្តេចនឹងកើត បើនៅតែមានខ្លួនជាអ្នកធ្វើយ៉ាងនេះ យ៉ាងនោះនុ៎ះ ពេលនឹងផ្តើមធ្វើ ក៏ស្តែងថាមានសេចក្តីប្រាថ្នាត្រូវការនឹងចង់ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌តាមផ្លូវណាមួយកើតឡើងទៅហើយ ដែលសេចក្តីពិតហើយនោះ លក្ខណៈនៃសតិប្បដ្ឋានជាសភាវធម៌ដែលរលឹកដឹងត្រង់លក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដតាមផ្លូវណាមួយ ដូចតាមផ្លូវភ្នែកក្នុងខណៈដែលកំពុងឃើញឥឡូវនេះ សតិប្បដ្ឋានក៏រលឹកបានជាប្រក្រតីបន្តិចម្តង ។ ហើយបញ្ញាក៏នឹងចាប់ផ្តើមសិក្សាពិចារណាដឹងលក្ខណៈដែលជានាមធម៌ និងរូបធម៌បន្តិចម្តង ។ ។

អ្នកសួរ តើខណៈដែលកំពុងឃើញ នឹងចម្រើនសតិប្បដ្ឋានយ៉ាងណាទៅ ?

សុចិន្ត ខណៈដែលកំពុងឃើញ ក៏រលឹកដឹងថា វត្ថុដែលកំពុងប្រាកដឱ្យឃើញជាសភាវធម៌មួយបែបដែលត្រឹមតែប្រាកដតាមភ្នែកប៉ុណ្ណោះ

ទោះនឹងឃើញជាសក់ ជាតុ ជាកៅអី ជាសសរ ជាសាលា ជាអ្វីក៏ដោយ សេចក្តីពិតស្រេចហើយនោះ ក៏ត្រឹមតែជាសភាវៈដែលប្រាកដតាមផ្លូវភ្នែកប៉ុណ្ណោះ មិនអាចប្រាកដតាមផ្លូវត្រចៀក ច្រមុះ អណ្តាត តាមកាយឡើយ ។ កាលណាអប់រំចម្រើនបញ្ញានៅមិនទាន់ដល់ថ្នាក់នាមរូបបរិច្ឆេទញាណទេ ក៏ជានាមរូបបរិច្ឆេទញាណមិនបាន ។

អ្នកសួរ ខ្ញុំបាទសូមជម្រាបថា ពេលបានទទួលសៀវភៅធម៌បដិបត្តិក្នុងជីវិតប្រចាំថ្ងៃហើយ ខ្ញុំបានអានមិនដឹងជាប៉ុន្មានចប់ទៅហើយទេ ៧ - ៨ ចប់ ឬច្រើនជាងនេះទៅទៀតទេក៏នៅមិនដឹង ចង់នឹងបដិបត្តិឱ្យបាន តែវានៅជាតួខ្លួនរាល់ពេល តាមភ្នែកក៏យើងឃើញ មិនមែនពណ៌ជារូប ឃើញជានាមឡើយ នឹក ។ ទៅវាផ្សេងដាច់ពីគ្នាទាំងអស់ តែមិនញែកចេញពីគ្នាសោះ ឬមិនចំត្រង់ជាទ្វារណាឡើយ មិនចូលជានាមរូបដូចដែលថានេះ សូមជួយអធិប្បាយត្រង់នេះម្តងទៀតបាទ ។

សុចិន្ត ខណៈដែលឃើញតាមផ្លូវភ្នែក រលឹកដឹងនូវលក្ខណៈនៃសភាវធម៌ដែលប្រាកដតាមប្រក្រតី ខណៈនោះបាន ឬទេ ? ខ សំខាន់ប្រការដំបូងក៏គឺនឹងត្រូវដឹងថា ការអប់រំចម្រើនសេចក្តីដឹង រហូតដល់សេចក្តីសម្បូរនៃបញ្ញាដែលជានាមរូបបរិច្ឆេទញាណនោះ ត្រូវផ្តើមអំពីសតិរលឹកសិក្សាលក្ខណៈដែលផ្សេងគ្នានៃនាមធម៌ និងរូបធម៌

ដែលកំពុងប្រាកដតាមផ្លូវណាមួយជាប្រក្រតី មិនមែនដោយថ្នាក់ការស្តាប់ទេ ហើយមិនមែនគ្រាន់តែឃើញក៏ផ្តើមទៅខ្វល់ខ្វាយរសាប់រសល់នឹកបែកខ្ញែកថា វត្ថុដែលកំពុងប្រាកដជារូប និងសភាពដែលកំពុងឃើញជានាមនោះទេ ខណៈនោះមិនមែនជាការរលឹកសិក្សាលក្ខណៈដែលជានាមធម៌ និងលក្ខណៈដែលជារូបធម៌ឡើយ ការដែលសតិប្បដ្ឋាន នឹងកើតបាននោះ គឺត្រូវយល់នូវលក្ខណៈនៃនាមធម៌ និងរូបធម៌យ៉ាងត្រឹមត្រូវជាមុនសិនថានាមធម៌ដែលកំពុងឃើញនោះជាសភាពដឹង មិនមានរូបរាង តួខ្លួន មិនត្រូវយកដៃ ជើង ម្រាម បាតដៃ បាតជើងមកផ្សំបូករួមប្រកបចូលគ្នា ជាទ្រង់ទ្រាយថាឈរហើយឃើញ អង្គុយហើយឃើញដេកហើយឃើញនោះទេ ។ សតិប្បដ្ឋានរលឹកដឹងត្រង់ចំពោះតែអាការដែលកំពុងឃើញពិត ៗ ថាជាសភាពដឹងមួយបែប មិនមែនយើង មិនមែនតួខ្លួន មិនមែនសត្វ បុគ្គលណា ៗ ទាំងអស់ឡើយ ហើយខណៈដែលសតិប្បដ្ឋានកើតឡើង រលឹកដឹងនូវលក្ខណៈនៃរូបដែលប្រាកដតាមផ្លូវភ្នែកនោះ ក៏ពិចារណាសិក្សាយល់រហូតទាល់តែដឹងថា ជាសភាវធម៌មួយបែប មិនមែនតួខ្លួន សត្វ បុគ្គលណា ៗ ទាំងអស់ ។

អ្នកសួរ ដើម្បីឱ្យការបដិបត្តិត្រឹមត្រូវជាក់លាក់ មិនក្រវ៉ល់ក្រវ៉ាយ រសាប់រសល់ដូចដែលលោកអាចារ្យមានប្រសាសន៍នោះ គឺបើយើងប្រើវិធីអានាបាណស្សតិប្បដ្ឋានតើនឹងបានឬទេ ? កាយ វេទនា ចិត្ត ធម្ម តែយើងប្រើគួបនឹងអានាបាណស្សតិ ខ្ញុំបាទ់តែម្តងក៏តាំងឈ្មោះ ពិសេសរបស់ខ្ញុំបាទ់ថា អានាបាណស្សតិប្បដ្ឋាន ការបដិបត្តិដូចនេះបាទ់ ។

សុចិន្ត ភាគច្រើនដោយបំណងចង់បានផលទើបនាំទៅឱ្យរកធ្វើវិធីផ្សេងផ្សំព្រោះកន្លែងខ្លះ ដល់មិនដឹងថានឹងធ្វើយ៉ាងណា ក៏សាកល្បងប្រើយ៉ាងនេះគួបផ្សំនឹងយ៉ាងនោះ រួមគ្នាទៅ ប្រសិនបើថានឹងមានសម្បជញ្ញៈសម្បូរ និងសតិមាន មិនវង្វេងភ្លេច និងសញ្ជប់សញ្ជឹងផ្តោតនៅទីណាមួយបានយូរនោះ តែនេះតើជាលក្ខណៈនៃសេចក្តីត្រូវការឬទេ ? លោកដែលត្រូវការឱ្យចិត្តផ្តោតជាប់ត្រង់អារម្មណ៍ណាមួយយូរ ។ តែផ្លូវភ្នែកក៏រលឹកមិនបាន រលឹកមិនត្រូវ ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ប្រក្រតីធម្មតាក៏រលឹកមិនត្រូវ កាលណាត្រូវការឱ្យចិត្តផ្តោតជាប់ត្រង់ទីណាមួយ ក៏ព្យាយាមគួបផ្សំរួមគ្នាច្រើនផ្លូវ ដែលជាយ៉ាងនោះក៏ព្រោះតែសេចក្តីប្រាថ្នាត្រូវការ ទើបមិនមែនជាការអប់រំចម្រើនបញ្ញា ។ អ្នកមានប្រក្រតីចម្រើនសតិប្បដ្ឋាននោះ គឺអប់រំចម្រើនបញ្ញា ដើម្បីដឹងរួចហើយលះបង់ តែកាលណានៅមិនទាន់ដឹងក៏មិនលះ ។ ការព្យាយាម

នឹងធ្វើឱ្យចិត្តផ្តោតជាប់នោះ តើលះសេចក្តីត្រូវការបំណងប្រាថ្នា ឬទេ ? ហើយទាំងមិនមែន ជាការអប់រំចម្រើនបញ្ញា ដើម្បីដឹង ហើយលះដែរ កុំបំផ្លើសធ្វើយ៉ាងដទៃ ឬផ្សំការបដិបត្តិដទៃ ។ ចូល មកទៀត ព្រោះមិនអាចធ្វើឱ្យដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ ខណៈនេះដែលកំពុងប្រាកដជាប្រក្រតីតាមសេចក្តីពិត ។ ឮជា ប្រក្រតី នឹកគិតជាសុខ ជាទុក្ខ ជាប្រក្រតីនោះ សុទ្ធតែជាធម៌ ទាំងអស់ ដរាបណា ដែលសតិមិនកើតឡើងរលឹកដឹងទេ ក៏មិន មែនជាការអប់រំចម្រើនសតិប្បដ្ឋានដែរ ព្រោះសូម្បីព្យាយាមធ្វើ យ៉ាងដទៃផ្សំវិធីផ្សេង ។ ច្រើនដល់ប៉ុណ្ណាក៏ដោយ បញ្ញាក៏មិន បានដឹងសភាវធម៌ដែលកំពុងប្រាកដជាប្រក្រតី តាមសេចក្តីពិត ឡើយ ដូច្នេះ នឹងមានប្រយោជន៍អ្វីដែលនឹងទៅផ្សំឡើងនូវវិធីផ្សេង ។ ក្នុងពេលដែលមិនមែនបញ្ញាសិក្សាពិចារណាដឹង លក្ខណៈ ដែលជានាមធម៌ និងរូបធម៌ជាប្រក្រតីតាមផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តនោះ ។ សូមជ្រាបថា ខណៈដែលកំពុងផ្សំវិធីបដិបត្តិផ្សេង ។ នោះ មានប្រយោជន៍អ្វីខ្លះ? កើតសេចក្តីដឹងអ្វីឡើងខ្លះ ?

អ្នកសួរ តាមដែលអាចារ្យសួរខ្ញុំថា បានការចេះដឹងអ្វីខ្លះ ? ខ្ញុំក៏បានការ ចេះដឹងនូវផ្លូវត្រៃលក្ខណ៍ ព្រោះថាក្នុងភស្តុតាងរបស់លោកអាចារ្យ ព្រះធម្មកថិកមានអានាបាណស្សតិ ៣ ក្បាល ខ្ញុំក៏ទៅអានចតុក្កៈទី

៤ លោកថា អនិច្ចំ ទុក្ខំ អនត្តា ហើយអធិប្បាយអនិច្ចំ ទុក្ខំ អនត្តា ដែរតាមដែលខ្ញុំអាន លោកចង្អុលច្បាស់ថា អានាបាណស្សតិ នេះមាន ៦ ខ តែចតុក្កៈ ទី ៤ នេះជាធម្មានុបស្សនាសតិប្បដ្ឋាន ទាក់ទងនឹងបញ្ញាដោយពិត មិនបានទាក់ទងនឹងខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូលប៉ុណ្ណោះទេ ពេលនេះយើងក៏បានយក អានាបាណស្សតិ ទុកបញ្ញា ទើបនឹងមិនផ្សាយទៅជាយ៉ាងដទៃឡើយ បើនឹកអ្វី ៗ មិនចេញ គឺវិបស្សនាដូចដែលអាចារ្យបង្រៀនបាទ់ ខ្យល់ដកដង្ហើមចេញ ខ្យល់ដកដង្ហើមចូល ទុកបញ្ញាឱ្យមូលតែម្តង គិតអ្វីមិនចេញក៏ដកដង្ហើមចូល ដកដង្ហើមចេញ ចងទុក ។ បើកើតមានបញ្ហាឡើងក៏គិតទៅជាយ៉ាងនេះឯង ដែលគិតនេះខ្ញុំក៏មិនបានទៅគិតក្រៅផ្សេងពីអាចារ្យដែរបាទ់ ក៏ចង់នឹងគិតថាភ្នែកឃើញជានាម ក៏ចង់នឹងគិតយ៉ាងនោះទៅ មិនមែនតួខ្លួនទេ ក៏ឃើញក៏បានឮ មិនមែនតួខ្លួន តែទីនេះ ម្ចាស់តួខ្លួន ម្ចាស់សក់ ម្ចាស់យើង ម្ចាស់គិតនេះ វាមានជារឿយ ៗ វាធ្ងន់ចិត្តណាស់បាទ់ ។

សុចិន្ត ការផ្សំយ៉ាងនេះហើយបានជានៅតែធ្ងន់ចិត្តនោះ ព្រោះមិនមែនជាបញ្ញាដែលពិចារណា សិក្សាលក្ខណៈនៃសភាវធម៌ដែលប្រាកដជាប្រក្រតីតាមសេចក្តីពិត ។ លោកប្រាប់ថាប្រយោជន៍ដែលលោកបានគឺដឹងផ្លូវត្រែលក្ខណ៍ ប្រសិនបើមិនដឹងសភាពនាមធម៌និងរូបធម៌នោះហើយ តើនឹងដឹងនូវត្រែលក្ខណ៍នៃអ្វីទៅ ? គឺ

ត្រឹមតែជាការដឹងត្រៃលក្ខណ៍តាមសៀវភៅប៉ុណ្ណោះ ការប្រចក្ស ត្រៃលក្ខណ៍ពិត ៗ នោះ គឺត្រូវជាវិបស្សនាញាណ ហើយ វិបស្សនាញាណនេះ នឹងមិនដឹងនូវលក្ខណៈនៃនាមធម៌ និងរូបធម៌ នោះមិនបានឡើយ ដូច្នោះ នឹងពោលបានថាការដឹងត្រៃលក្ខណ៍ ដោយមិនដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌នោះ រមែងមិនបាន។

អ្នកសួរ តទៅនេះ គឺសូមអង្វរជម្រាបសួរអាចារ្យថា ការរលឹកនេះ តើរលឹក យ៉ាងម៉េច រលឹកខ្លាំង ៗ ឬរលឹកបន្តិចបន្តួច ? ខ្ញុំថារឿងនេះ ជា រឿងធំបាទ់ ដូចជាសតិ យើងដឹងថាជាការរលឹក តើនឹងរលឹក យ៉ាងម៉េច ? មានបញ្ញាហើយ រលឹកបន្តិចបន្តួច ឬរលឹកឱ្យជ្រៅ ឡើង រលឹកឱ្យទៅដល់ អនិច្ច ទុក្ខ អនត្តា ឬនឹកតែទន់ តែរឹង ខ្ញុំយល់ដែលអាចារ្យបង្រៀនស្តាប់មក ២ - ៣ ឆ្នាំ ហើយយល់ តែវេលាបដិបត្តិ បដិបត្តិមិនបានរូបនាម អ្វីគឺរូប នាមទាំងអស់ ដែលខ្ញុំមិនបានរៀនព្រះត្រៃបិដកខ្ញុំយល់ បាទ ទីនេះខណៈដែល រលឹកបច្ចុប្បន្ន ដែលរលឹកបច្ចុប្បន្នធម៌ ខណៈដែលរលឹក តើរលឹក យ៉ាងម៉េច ? នឹងមានឧបាយក្នុងការរលឹកនេះសំខាន់ ៗ បាទ់ រលឹករាក់ រលឹកជ្រៅ រលឹកខ្លាំង រលឹកវែង រលឹកខ្លី រលឹកសើ ៗ ដាក់ចិត្តចាំក៏តួខ្លួន ជាយើង ជាគេទៅ នេះនាម នឹកហើយនេះ....

សុចិន្ត បើព្យាយាមនឹងធ្វើគឺពិតជាកង្វល់ហើយ បើនឹងឱ្យសតិរលឹកសើ ។ ឬនឹងឱ្យរលឹកខ្លាំង នឹងឱ្យច្រើន ឬនឹងឱ្យតិច ។ ការអប់រំចម្រើនសេចក្តីដឹង គឺបញ្ញានោះមិនមែនមានពិធីរបៀបសម្រាប់ធ្វើទេ តែផ្តើម ដោយស្តាប់ និងសិក្សាសភាវៈដែលសតិនឹងរលឹកដឹង រហូតដល់យល់ចម្រើនឡើងល្មម នឹងបច្ច័យឱ្យសតិកើតរលឹកដឹងត្រង់លក្ខណៈនៃសភាពនាមធម៌ ឬរូបធម៌ជាប្រក្រតីតាមសេចក្តីពិត កាលណាសភាវធម៌ដែលប្រាកដមានពិតយ៉ាងណា ក៏រលឹកដឹងតាមសេចក្តីពិតយ៉ាងនោះប៉ុណ្ណោះ មិនត្រូវទៅសង្កត់ឱ្យធ្ងន់ មិនត្រូវទៅបន្ធូរឱ្យស្រាល មិនត្រូវទៅធ្វើឱ្យសើ ។ ឬអ្វី ។ នោះឡើយ ព្រោះថាធ្វើយ៉ាងនោះ ក៏ជារឿងតួខ្លួន មិនមែនការពិចារណាសិក្សាលក្ខណៈនៃសភាវធម៌ដែលប្រាកដតាមសេចក្តីពិតទេ សភាវធម៌តាមសេចក្តីពិតជាយ៉ាងណា **អ្នកមិនវង្វេងភ្លេចសតិ គឺកំពុងរលឹកដឹងសភាវធម៌នោះ ជាប្រក្រតីតាមសេចក្តីពិត ត្រង់លក្ខណៈនោះ ហើយផ្តើមពិចារណាដឹងលក្ខណៈដែលជានាមធម៌ ឬរូបធម៌នោះ ។ បន្តិចម្តង ។** ដោយមិនមែនទៅឱ្យសតិផ្តោត ចោះឱ្យជ្រៅទៅទៀត ឬថាឱ្យសើ ។ ចេញមកតិច ។ ឬអ្វី ។ យ៉ាងណានោះទេ កាលដែលសតិកើតនោះ រលត់ទៅរួចក៏អាច នឹងវង្វេងភ្លេចសតិបន្តទៅទៀត ឬសតិក៏អាចនឹងរលឹកត្រង់អារម្មណ៍ ដទៃតទៅទៀតក៏បាន ទើបនឹងឃើញភាពជាអនត្តានៃសតិប្បដ្ឋាន ។

កាលណាដឹងថាសភាវធម៌ទាំងឡាយ នឹងសតិប្បដ្ឋានក៏ជាអនត្តា ទើបនឹងមិនខ្វល់ បើមិនដូច្នោះទេ សេចក្តីដឹងក្នុងអារម្មណ៍ថា ជាតួខ្លួន ក៏ធ្វើឱ្យខ្វល់ជាប្រាកដ ព្រោះសូម្បីគ្រាន់នឹងរលឹក ក៏មិនជ្រាបថារលឹកត្រឹមណាទើបនឹងត្រូវ នឹងរលឹកធ្ងន់ ឬស្រាល និងជ្រៅ ឬសើ ។ បើជាការរលឹកសិក្សាពិចារណាយល់លក្ខណៈ នៃសភាវធម៌ ដែលកំពុងប្រាកដ គឺនឹងមិនខ្វល់ខ្វាយសោះឡើយ ព្រោះកាលណាជាប្រក្រតីហើយ តើនឹងខ្វល់បានយ៉ាងណា នៅពេលខុសពីប្រក្រតីហើយ ទើបនឹងរវល់ខ្វល់ ។

អ្នកសួរ សតិប្បដ្ឋាន ខ្ញុំក៏នៅមិនទាន់ជ្រាបនៅឡើយ ថាលក្ខណៈដែលពិតប្រាកដយ៉ាងណា គឺ គ្រាខ្លះ ពេលខ្ញុំស្តាប់អាចារ្យបរិយាយផ្លូវចម្រើនវិបស្សនា វេលាតាំងចិត្តនៅស្តាប់ ក៏ដឹងរឿងរ៉ាវដែរ ហើយមានសតិដឹងថាពេលស្តាប់នោះអាចារ្យបរិយាយអ្វីក៏ដឹងរឿង តែមិនបានពិចារណា ឱ្យជារូប ជានាមក្នុងខណៈនោះ មិនជ្រាបថាតើនឹងជាសតិប្បដ្ឋានឬទេ ?

សុចិន្ត ខណៈដែលមិនដឹងថាជានាមធម៌ ឬជារូបធម៌ ក៏មានសេចក្តីប្រកាន់សភាវធម៌នោះថាជាតួខ្លួនយ៉ាងពេញទំហឹង ។ ភាពជាតួខ្លួនដែលមាននៅយ៉ាងពេញទំហឹងនេះ នឹងលះបង់អស់ទៅបានក៏អាស្រ័យដោយសតិដែលរលឹកដឹងពិចារណាសិក្សា យល់នូវលក្ខណៈនៃនាមធម៌ និងរូបធម៌ ដែលកំពុងប្រាកដបន្តិចម្តង ។ ។

ការចេះដឹងដែលកើតឡើងបន្តិចម្តង ។ នោះ លះសេចក្តីមិនដឹងនាមធម៌ និងរូបធម៌ ទៅបន្តិចម្តង ។ នឹងលះឱ្យទៅទាំងអស់ភ្លាម ។ មិនបាន ព្រោះកាលណាសតិកើត នឹងដឹងច្បាស់ជាក់ភ្លាម ។ ថា សភាវធម៌ដែលប្រាកដនោះ ជានាមធម៌ ជារូបធម៌ សេចក្តីដឹងដែលកើតឡើងបន្តិចម្តង ។ នោះ សន្សំតិច ។ រហូតដោយ មិនដឹងខ្លួនប្រៀបដូចការចាប់ដងកាំបិត ដែលដងកាំបិតក៏ផ្តើមសឹកទៅបន្តិចម្តង ។ ជាពិតប្រាកដ ព្រោះជាចីរកាលភាវនា[៥០] ។ អ្នកខ្លះក៏មិនពេញចិត្តត្រង់ដែលសតិ និងបញ្ញាចម្រើនឡើងបន្តិចម្តង ។ នោះ ដែលមិនមានគន្លងផ្លូវដទៃឡើយព្រោះមិនពេញចិត្តហើយទៅផ្សំវិធីដទៃ ក៏នឹងធ្វើឱ្យខ្វល់ខ្វាយក្រៃលែងឡើង ។

អ្នកសួរ ការបដិបត្តិជាប្រក្រតីនិងការបដិបត្តិដែលខុសប្រក្រតី តើផ្សេងគ្នាយ៉ាងណា ?

សុចិន្ត ខណៈនេះកំពុងអង្គុយជាប្រក្រតី រលឹកដឹងនូវសភាវធម៌ដែលកំពុងប្រាកដតាមសេចក្តីពិត ដូចជាសភាវធម៌ដែលទន់ រឹង ដែលប្រាកដត្រង់កាយ ឬសភាវធម៌ដែលប្រាកដតាមភ្នែក នោះជាប្រក្រតី តែបើយល់ថា កាលណាចម្រើនសតិប្បដ្ឋាន នឹងត្រូវទៅអង្គុយសមាធិ

[៥០] បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ចរិយាបិដក និទានកថា

ផ្តោតត្រង់នេះ ត្រង់នោះ នុ៎ះមិនមែនជាប្រក្រតី ពីព្រោះជាសេចក្តីប៉ងប្រាថ្នាត្រូវការ ជ្រើសដឹងសភាវធម៌ដែលនៅមិនទាន់កើតឡើង រំលងការរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដ ដូចជាសភាវធម៌ដែលកំពុងឃើញ សភាវធម៌ដែលកំពុងឮ សភាវធម៌ដែលកំពុងប្រាកដតាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន ត្រជាក់ ក្តៅ ទន់ រឹង ។ ល ។ ដែលកំពុងប្រាកដ សូម្បីសេចក្តីយល់ខុស ត្រឹមតែតិចតួចក៏ដោយ កិលេសតណ្ហាក៏បិទបាំង មិនឱ្យបញ្ញាកើតឡើងដឹងសភាវធម៌ ដែលកំពុងប្រាកដជាប្រក្រតី តាមសេចក្តីពិតក្នុងខណៈនោះបានដែរ ។ អ្នកដែលនឹងអប់រំចម្រើនសតិប្បដ្ឋានបាននោះ នឹងត្រូវយល់ឱ្យត្រឹមត្រូវថា ខណៈដែលវង្វេងភ្លេចសតិ និងខណៈដែលមានសតិនោះផ្សេងគ្នាយ៉ាងណា បើមិនដឹងទេក៏ចម្រើនសតិប្បដ្ឋានមិនបាន ។ ធ្លាប់វង្វេង ភ្លេចសតិយ៉ាងណា ក៏នៅវង្វេងភ្លេចសតិតទៅយ៉ាងនោះ ឬក៏មិនដូច្នោះទេ គឺត្រូវការប្រាថ្នាជ្រើសរើស ផ្តោត ចោះ ត្រង់អារម្មណ៍ដែលនឹងឱ្យសមាធិកើតឡើងសុទ្ធតែមិនមែន ជាការចម្រើនសតិប្បដ្ឋាននោះឯង ដូច្នោះទើបត្រូវតែយល់ឱ្យត្រឹមត្រូវថា **ខណៈដែលវង្វេងភ្លេចសតិ គឺខណៈដែលមិនដឹងលក្ខណៈនៃសភាវធម៌ ដែលកំពុងប្រាកដជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃនោះឯង មិនរលឹកដឹងសភាពដែលឃើញ សភាពឮជាដើម ។** ចំណែកខណៈដែលមានសតិនោះ

ជាខណៈដែលរលឹកបាន ទើបពិចារណាសិក្សា ដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ជាប្រក្រតីតាមផ្លូវណាមួយ គឺផ្លូវភ្នែក ឬផ្លូវត្រចៀក ឬផ្លូវច្រមុះ ឬផ្លូវអណ្តាត ឬផ្លូវកាយ ឬផ្លូវចិត្ត ដោយមិនបង្គាប់បញ្ជា ចោះចំពោះ មិនជ្រើសរើស ឬត្រូវការអារម្មណ៍នេះ អារម្មណ៍នោះឡើយ ព្រោះបើប្រព្រឹត្ត ដោយលក្ខណៈនេះហើយ ក៏នឹងមិនប្រចក្សថា សតិជាអនត្តាទេ ដូច្នោះ ខណៈដែលមានសតិ គឺខណៈដែលរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ តាមសេចក្តីពិតនៃសភាវធម៌នោះ ។ ដូចជាខណៈដែលក្លិនប្រាកដ ក៏រលឹកដឹងសភាពនៃក្លិន ដែលប្រាកដតាមច្រមុះ ពិចារណាដឹងថាក្លិនត្រឹមតែជាសភាវធម៌មួយបែប ដែលកើតឡើងប្រាកដហើយ ក៏រលត់ទៅ ឬរលឹកដឹងសភាព ដែលកំពុងដឹងក្លិន ខណៈនោះថាត្រឹមតែជាសភាពដឹងមួយបែប ដែលកើតឡើងដឹងក្លិនហើយក៏អស់ទៅ មិនមែនសត្វបុគ្គល តួខ្លួនជាដើម ។

អ្នកសួរ បើយ៉ាងនោះអ្នកដែលជាព្រះសោតាបន្នបុគ្គល ក៏មិនដឹងថា តើនរណាជាឪពុក នរណាជាម្តាយទៅហើយ ។

សុចិន្ត អ្នកដែលជាព្រះសោតាបន្នបុគ្គលដឹងច្បាស់លាស់ គឺដឹងច្បាស់ថា សភាព ដែលកំពុងឃើញជានាមធម៌មួយបែប កាលឃើញហើយ ក៏ដឹងថា វត្ថុដែលឃើញជាមនុស្ស ជាសត្វ ឬជាវត្ថុរបស់របរផ្សេងៗ សភាពដែលដឹងយ៉ាងនោះក៏ជានាមធម៌មួយបែប កើតឡើង ហើយ ក៏រលត់ទៅ តើមាននរណាខ្លះដែលឃើញហើយ មិនដឹងថា ជាឃើញអ្វីយ៉ាងនោះ បើដូច្នោះមែននុ៎ះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏មិនអាចទ្រង់ស្គាល់ព្រះអានន្ទ ព្រះមហាមោគ្គល្លានដែរ គឺព្រះអង្គ មិនដឹងអ្វីទាល់តែសោះ ហើយបើជាយ៉ាងនោះ ក៏នឹងមានត្រឹមតែជានាមធម៌ ដែលឃើញប៉ុណ្ណោះ មិននាមធម៌ដទៃដែលដឹងថាឃើញអ្វី ។ ជាដើមនោះឡើយ ប៉ុន្តែសភាវធម៌តាមសេចក្តីពិតនោះ ក្រៅពីនាមធម៌ដែលឃើញហើយ ក៏នៅមាននាមធម៌ដែលដឹងថាឃើញអ្វីដែរ ។

អ្នកសួរ ឃរាវាសដែលចង់ផុតទុក្ខ ព្រោះឃើញថាទុក្ខនេះធ្ងន់ធ្ងរក្រៃលែងណាស់ និងនៅជារៀងរហូតកើតហើយ នឹងកើតទៀតផងដែរ តើនឹងធ្វើយ៉ាងណា វិធីខ្លី ៗ ដែរទៅ ?

សុចិន្ត ដែលថាទុក្ខនេះសន្ធឹកសន្ធាប់ក្រៃលែងនោះ ក៏ព្រោះមានសេចក្តីឃើញខុស ប្រកាន់ថាជាតួខ្លួន **បើមិនមានសេចក្តីឃើញខុសប្រកាន់ថាជាតួខ្លួនហើយ ក៏នឹងលះបង់បន្ថយទុក្ខចុះបានច្រើនភ្លាម** ព្រះមានព្រះភាគព្រះអង្គសម្តែងថា សេចក្តីទុក្ខទាំងឡាយនឹងលះបង់ស្រាលស្តើងចុះបាន កាលណាកិលេសរលត់ទៅតាមលំដាប់ កាលណាកិលេសនៅមិនទាន់រលត់អស់ទេ ការកើត ក៏រមែងនៅមានប្រមាណរាប់មិនបាន ដរាបណាដែលនៅកើត ដរាបនោះ ក៏នៅមានទុក្ខ ព្រះសោតាបន្នបុគ្គលរំលត់កិលេសថ្នាក់ដើមបានហើយ ទើបកើតយ៉ាងច្រើនបំផុតទៀត ៧ ជាតិ ប៉ុណ្ណោះ ។ សេចក្តីក្នុងព្រះសូត្រមានថា[៥១] ព្រះមានព្រះភាគព្រះអង្គទ្រង់ឆ្កឹះធូលីបន្តិចជាប់ត្រង់ចុងព្រះនខា (ក្រចក) ហើយត្រាស់ថា ធូលីបន្តិចដែលនៅជាប់ត្រង់ចុងក្រចកនេះ ប្រៀបបាននឹងការកើតទៀត នៃព្រះសោតាបន្នបុគ្គលដែលមានត្រឹមតែ ៧ ជាតិ ឯចំណែកមហាប្រឹថពីនោះ ប្រៀបបាននឹងជាតិ ដែលនឹងត្រូវកើតទៀតនៃពួកបុថុជ្ជន កាលណាជាតិ គឺការកើតនៃបុថុជ្ជនមានច្រើនហួស

[៥១] សំយុត្តនិកាយ មហាវារវគ្គ អភិសមយវគ្គទី ៦ នខសិខាសូត្រ

ប្រមាណយ៉ាងនេះ ទុក្ខដែលកើតព្រោះជាតិ ក៏នឹងត្រូវច្រើនហួសប្រមាណដូចដែលសួរអម្បាញ់មិញហ្នឹងឯង ។

អ្នកសួរ គ្រប់លោកអ្នកដែលនៅអង្គុយក្នុងទីនេះ គង់នឹងចង់ជ្រាបដឹងថា នឹងផ្តើមបដិបត្តិវិបស្សនាឥឡូវនេះ តើនឹងធ្វើយ៉ាងណា ?

សុចិន្ត រលឹកដឹងលក្ខណៈនៃសភាវធម៌ដែលប្រាកដ ខណៈដែលសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ណាមួយនោះ សម្មាសង្កប្បៈ គឺ វិតក្កចេតសិកក៏ត្រិះរិះ គឺផ្តោតក្នុងលក្ខណៈនៃអារម្មណ៍ ដែលកំពុងប្រាកដ ហើយបញ្ញាផ្តើមសិក្សាពិចារណាលក្ខណៈដែលពិតនៃសភាវធម៌ដែលប្រាកដបន្តិចម្តង ។ រហូតដល់សេចក្តីដឹងនឹងកើនចម្រើនឡើង ។ សេចក្តីដឹងនឹងកើតឡើង និងចម្រើនឡើង បានអំពីការពិចារណាដឹងលក្ខណៈនៃសភាវធម៌ ដែលប្រាកដក្នុងខណៈដែលសតិរលឹកដឹងលក្ខណៈនៃសភាវធម៌នោះ សភាវធម៌កើតឡើងប្រាកដហើយ ក៏អស់ទៅយ៉ាងរហ័សហួសប្រមាណ ពេលខ្លះក៏នៅមិនទាន់នឹងពិចារណា សិក្សាលក្ខណៈនៃសភាវធម៌នោះផង ដូចខណៈឮ សតិកើតរលឹកដឹងសភាពឮតែមួយបែប តែនៅមិនទាន់សិក្សាពិចារណាដឹងថាជាសភាពដឹងសំឡេង សភាពឮក៏អស់ទៅហើយសូម្បីថា ក្នុងពេលដំបូងបញ្ញា នឹងមិនកើតឡើងដឹងជាក់ក្នុងលក្ខណៈ នៃសភាពឮក៏ដោយ ក៏ជាធម្មតាដែលនឹងជា

យ៉ាងនោះ ព្រោះមិននរណាអាចតោងចាប់ សំឡេង ឬនាមធម៌ដែលឮ យកមកត្រួតមើល យកមកពិសោធន៍ពិចារណា បានឡើយ តែថាសភាពឮក៏នឹងត្រូវកើតទៀត អ្នកអប់រំចម្រើន សតិ និងបញ្ញា ទើបរលឹកដឹងលក្ខណៈនៃនាមធម៌ដែលឮ ក្នុង គ្រាបន្ទាប់ទៀតបាន ។ ខណៈនេះសតិនឹងកើតឡើងរលឹកដឹង លក្ខណៈនៃនាមធម៌ ឬរូបធម៌ដែលកំពុងប្រាកដតាមផ្លូវភ្នែក តាម ត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្ត ផ្លូវណាមួយក៏បានមួយលក្ខណៈ ។ ហើយពិចារណាសិក្សាដឹង លក្ខណៈនៃសភាវធម៌នោះ ។ បន្តិចម្តង ។ រហូតទាល់តែបញ្ញា នឹងកើនចម្រើនឡើងដឹងច្បាស់ក្នុងលក្ខណៈដែលផ្សេងគ្នា នៃនាម ធម៌ និងរូបធម៌ដែលអាចនឹងចែកញែកដឹងលក្ខណៈ ដែលផ្សេង គ្នានៃនាមធម៌ដែលឮ និងសំឡេង ។ ល ។ ក្នុងទីបំផុត ក៏នឹងថ្នឹក ក្នុងសភាពនៃនាមធម៌ និងរូបធម៌ច្រើនឡើង កាលថ្នឹកហើយ សេចក្តីដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ក៏កើនចម្រើនឡើង ទៀត ។ មិនថានាមធម៌ណា រូបធម៌ណានឹងកើតក្នុងស្ថានទីណាទេ សតិ និងបញ្ញាក៏អាចកើតរលឹកដឹងលក្ខណៈនៃសភាវធម៌នោះ ។ ក្នុងខណៈនោះ បានជាប្រក្រតីតាមសេចក្តីពិត ។ ការចម្រើន សតិប្បដ្ឋានជាការចម្រើនសតិបញ្ញា សេចក្តីដឹងណាដែលបាន

អប់រំឱ្យកើតឡើងហើយ សេចក្តីចេះដឹងនោះក៏នឹងចម្រើនឡើង និងលះបង់សេចក្តីមិនដឹងឱ្យស្រុតចុះ តិចទៅផងដែរ ។

អ្នកសួរ សន្មតិថាសំពះព្រះ សូត្រធម៌ រៀបរយស្រេចបាច់រួចហើយ គិតថានឹងទៅអង្គុយកម្មដ្ឋាន តើនឹងយោនិសោមនសិការយ៉ាងណាទៅ ទើបនឹងមិនមានអភិជ្ឈា និងទោមនស្សក្នុងអារម្មណ៍ ?

សុចិន្ត ដែលនឹងជាយោនិសោមនសិការពិត ។ នោះ ត្រូវជាសម្មាសតិក្នុងការចម្រើនមគ្គមានអង្គ ៨ ដូច្នោះ ទើបមិនគួរគិតថានឹងអង្គុយកម្មដ្ឋានឡើយ ដែលគិតថានឹងអង្គុយកម្មដ្ឋានក៏ព្រោះយល់ខុសថាមានតួខ្លួនដែលអាចនឹងឱ្យសតិកើតឡើងបាន តាមពេលកំណត់តែសម្មាសតិនោះមិនត្រូវចាំរហូតដល់សំពះព្រះ សូត្រធម៌ រួចហើយនោះទេ ។ អ្នកណាសំពះព្រះ កាលណាមិនដឹងថាជានាមធម៌ ជារូបធម៌ទេ ក៏ប្រកាន់សភាវធម៌ក្នុងខណៈ ដែលកំពុងសំពះព្រះនោះ ជាតួខ្លួន គឺជាយើងសំពះព្រះក្នុងខណៈដែលសូត្រធម៌ កាលមិនដឹងថាជានាមធម៌ ជារូបធម៌ទេ ក៏ប្រកាន់ថាជាយើងសូត្រធម៌ សម្មាសតិនឹងកើតឡើងរលឹកដឹងលក្ខណៈនៃសភាវធម៌ណាមួយខណៈដែលកំពុងសំពះព្រះ សូត្រធម៌ ឬក្នុងខណៈដទៃ ។ មិនថានឹងនៅក្នុងឥរិយាបថណា គឺបានទាំងអស់ ។

អ្នកសួរ អាត្មាភាពនឹងចង់សួររឿងការចម្រើនសតិប្បដ្ឋាន អាត្មាភាពបានអានអភិធម្មបិដកភាគ ២ ខន្ធវិភង្គ ក្នុងពួកនៃរូប ២៨ មានរូបដែលឃើញមិនបាន ប៉ះខ្ទប់មិនបាន រូបល្អិត រូបឆ្ងាយ ជាដើម ។

សុចិន្ត រូបទាំងអស់មាន ២៨ រូប ហើយមានត្រឹមតែរូបមួយប៉ុណ្ណោះដែលឃើញបាន គឺរូបារម្មណ៍ដែលប្រាកដតាមភ្នែក ជារូបដែលឃើញបាន (សនិទស្សនរូប) និងប៉ះខ្ទប់បាន (សប្បដិឃរូប) ។ សល់ ១១ រូប គឺ សំឡេង ១ ក្លិន ១ រស ១ ជោដ្ឋព្វៈ ៣ ចក្ខុបសាទរូប ១ សោតបសាទរូប ១ ឃានបសាទរូប ១ ជិវ្ហាបសាទរូប ១ កាយបសាទរូប ១ ជារូបដែលប៉ះខ្ទប់បានតែឃើញមិនបាន រូប ១២ រូប ដែលប៉ះខ្ទប់បាននោះ ជារូបគ្រោតគ្រាត ទើបជារូបជិតដល់ការពិចារណាដឹងបាន ចំណែករូប ១៦ ទៀតដែលសល់នោះ ឃើញមិនបាននឹងប៉ះខ្ទប់មិនបាន ទើបជារូបល្អិត និងជារូបឆ្ងាយដល់ការពិចារណាដឹងបាន ។ សភាវធម៌មានពិតដែលព្រះមាន-ព្រះភាគទ្រង់ សម្តែងទុកនោះ អ្នកអប់រំចម្រើនសតិប្បដ្ឋានអាចពិសោធន៍ដឹងលក្ខណៈនៃសភាវធម៌នោះ ។ ដែលកំពុងប្រាកដជាប្រក្រតីតាមសេចក្តីពិតបាន តែក៏ជារឿងល្អិតល្អន់ហើយជ្រាលជ្រៅខ្លាំងណាស់ ដូចជា រូបារម្មណ៍ ដែលជាសភាវធម៌ដែលប្រាកដតាមភ្នែកនោះ ត្រឹមតែបានស្តាប់ប៉ុណ្ណោះ ក៏ដឹងខ្លួនថានឹងយល់បានមិនពិបាកទេ ប៉ុន្តែមិនមែនសេចក្តីដឹងក្នុងខណៈកំពុង

ឃើញ បើបុគ្គលនោះមិនបានអប់រំចម្រើនសតិប្បដ្ឋាន រហូតបញ្ញាចាស់ក្លានោះទេ ក៏នឹងមិនដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ តាមសេចក្តីពិត ព្រោះខណៈឃើញតាមភ្នែកនោះមានរូបារម្មណ៍ពិត ។ តែក៏ឃើញជាមនុស្ស ជាសត្វ ជាវត្ថុផ្សេង ។ ទៅរហូតដល់កើតសេចក្តីសង្ស័យថា រូបារម្មណ៍នោះជាអ្វី មានលក្ខណៈយ៉ាងណា ។ រូបារម្មណ៍ជាសភាវធម៌ដែលប្រាកដពេលបើកភ្នែក ហើយឃើញដោយមិនទាន់បាននឹកដល់វត្ថុណាមួយឡើយនោះ នុ៎ះឯង ជាលក្ខណៈពិត ។ នៃរូបារម្មណ៍ សុទ្ធតែបញ្ញានឹងត្រូវចម្រើនរហូតដល់យល់ រហូតដល់ច្នឹកច្បាស់ថា រូបារម្មណ៍មិនមែនជាសត្វ បុគ្គល តួខ្លួន ឬវត្ថុណា ។ ទាំងអស់ លក្ខណៈដែលពិតប្រាកដនៃរូបារម្មណ៍ជាសភាវធម៌ ដែលប្រាកដតាមភ្នែកប៉ុណ្ណោះពិត ។ ។ ដូច្នោះ ពេលសតិប្បដ្ឋាននៅមិនទាន់កើត ក៏នៅមិនទាន់រលឹកសិក្សាពិចារណាលក្ខណៈនៃរូបារម្មណ៍ពិត ។ ថាត្រឹមតែជាវត្ថុដែលប្រាកដតាមភ្នែក ទើបលះបង់នូវការប្រកាន់វត្ថុដែលធ្លាប់ឃើញជាមនុស្ស ជាសត្វ ជាវត្ថុផ្សេងមិនបានឡើយ ។

អ្នកសួរ សិក្សាមានន័យសេចក្តីថាយ៉ាងដូចម្តេច ?

សុចិន្ត ខណៈដែលសតិកើតរលឹកដឹង លក្ខណៈនៃសភាវធម៌ណាមួយដែលប្រាកដ និងពិចារណាដឹងលក្ខណៈនៃសភាវធម៌នោះ ។ (មិនមែនគិតក្នុងចិត្ត ជាពាក្យ ។ នោះទេ) ដើម្បីប្រចក្សច្បាស់ ត្រៃ

លក្ខណ៍ នៃសភាពដឹង និងសភាវធម៌ដែលមិនមែនសភាពដឹង នុ៎ះឯងគឺការសិក្សាលក្ខណៈ ដែលមិនមែនតួខ្លួននៃសភាវធម៌ដែលប្រាកដ ។

អ្នកសួរ បើកភ្នែកនៅឃើញ តែមិនដាក់ចិត្តមែនឬទេ ?

សុចិន្ត ហាមការកើតរលត់បន្តនៃចិត្ត ដែលប្រព្រឹត្តទៅតាមប្រក្រតីមិនបានឡើយ តែដល់ពេលសតិកើតឡើង សតិរលឹកដឹងលក្ខណៈនៃសភាវធម៌ណាមួយដែលកំពុងប្រាកដជាប្រក្រតីនុ៎ះឯង ។

អ្នកសួរ បើយ៉ាងនោះគោលបំណងក្នុងការចម្រើនសតិប្បដ្ឋាន ក្នុងជីវិតប្រចាំថ្ងៃ ភាគច្រើនយើងនាំគ្នាធ្វើដើម្បីឱ្យផុតទុក្ខ ពេលមានបញ្ញាកើតឡើងហើយ ទើបផុតទុក្ខ ។

សុចិន្ត រឿងផុតទុក្ខ ជារឿងដែលនឹងផុតមិនបានងាយ ។ ទេ រហូតទាល់តែបញ្ញានឹងចម្រើនឡើងជាថ្នាក់ ។ ហើយលះសេចក្តីមិនដឹង សេចក្តីសង្ស័យ សេចក្តីយល់ខុសដែលប្រកាន់នូវសភាវធម៌ជាសត្វ បុគ្គល តួខ្លួនជាមុនសិន អ្នកដែលមានប្រក្រតីចម្រើនសតិប្បដ្ឋានដឹងថាសតិ និងបញ្ញានឹងអប់រំចម្រើនឡើងបានបន្តិចម្តង ។ សន្សឹម ។ នោះព្រោះអវិជ្ជាក្នុងមួយថ្ងៃ ។ កើតច្រើនជាងកុសល ទាំងក្នុងអតីត អនន្តជាតិ និងទាំងក្នុងបច្ចុប្បន្នជាតិ ។

អ្នកសួរ ប៉ុន្តែបញ្ហាដែលកើតឡើង គឺថាវេលាដែលមានអ្វីមកប៉ះខ្លាំង យើងច្រើនតែខ្វះសតិ ?

សុចិន្ត ជាធម្មតា កាលណាសតិនៅមិនទាន់មានកម្លាំង នឹងឱ្យសតិកើត ទាន់ពេលភ្លាម ។ នោះជាសភាពដែលប្រព្រឹត្តទៅមិនបាន ។

អ្នកសួរ ចេញពីការសិក្សាក្នុងបទសូត្រធម៌នៅវត្តពេលព្រឹក ដែលលោកហៅថា ឧបាទានក្ខន្ធ ទុក្ខា គឺការចូលទៅប្រកាន់មាំក្នុងខន្ធ ៥ ជាទុក្ខ នេះជាយ៉ាងណាទៅ ?

សុចិន្ត ជាទុក្ខយ៉ាងពិត កាលណាមិនដឹងសភាពសេចក្តីពិតនៃធម៌ដែលប្រាកដទេ ក៏រមែងត្រេកអរ មិនពេញចិត្ត ហើយក្នុងខណៈដែលត្រេកអរីករាយក៏ជាទុក្ខម៉្យាង ព្រោះខណៈនោះមិនស្ងប់ចាកពីកិលេសឡើយ ។ ដរាបណាដែលបញ្ញានៅតែមិនទាន់កើតឡើង ក៏នៅតែមិនទាន់ដឹងសភាពដែលផ្សេងគ្នានៃកុសលចិត្ត និងអកុសលចិត្តដែរ ។ គ្រប់គ្នាពេញចិត្ត លោភៈ មិនចេះល្មមក្នុងលោភៈរហូតទាល់តែបញ្ញានឹងឃើញសេចក្តីផ្សេងគ្នា នៃខណៈដែលជាកុសលមិនមានលោភៈ និងខណៈដែលជាលោភៈ ស្រណុក រីករាយ ប្រាថ្នា ពេញចិត្តជាប់ជំពាក់ ។ កាលណាបញ្ញាមិនកើត ក៏ពេញចិត្តក្នុងកិលេស ពេញចិត្តក្នុងលោភៈ ដែលមិនមានថ្ងៃគ្រប់គ្រាន់ មិនថាជាផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ដោយមិនដឹងសោះឡើយថា ខណៈនោះជាទុក្ខ ជាទោស ជាភ័យ ការប្រកាន់នូវឧបាទានក្ខន្ធ ៥ ទើបជាទុក្ខ ។

អ្នកសួរ ពេលនេះបើយើងប្រយ័ត្នពេលប៉ះខ្ទប់ ដូចភ្នែកប៉ះខ្ទប់រូប ត្រចៀកប៉ះខ្ទប់សំឡេង បើយើងមានសតិ ពេលនោះក៏នឹងមិនមែនជាសេចក្តីពេញចិត្ត និងមិនមែនមិនពេញចិត្តនោះឬ ?

សុចិន្ត មិនមាននរណាប្រយ័ត្ន ឬបង្គាប់ឱ្យសតិកើតបានឡើយ កាលណាសតិកើតក៏ដឹងសេចក្តីផ្សេងគ្នាថា ខណៈដែលសតិកើត ខុសផ្សេងពីខណៈដែលសតិមិនកើត ។

អ្នកសួរ ខន្ធ ៥ របស់បុថុជ្ជនក៏រមែងមានដូចតែនឹងព្រះអរហន្តដែរ តែខន្ធ ៥ របស់បុថុជ្ជនពេញទៅដោយឧបាទាន ដែលនាំឱ្យកើតទុក្ខ ។ ពេលនេះបើយើងប្រយ័ត្នចាំពេលប៉ះខ្ទប់ កាលភ្នែកប៉ះខ្ទប់រូប ត្រចៀកប៉ះខ្ទប់សំឡេង ហើយមានសតិ តើនឹងជាការចម្រើនសតិ ត្រឹមត្រូវទេ ?

សុចិន្ត ការចម្រើនសតិដែលត្រឹមត្រូវនោះ គឺដឹងថាធម៌ទាំងឡាយ ជាអនត្តាទើបដឹងថា ខណៈណាសតិកើត ខណៈណាសតិមិនកើត តែបើមានតួខ្លួនដែលនឹងប្រយ័ត្ន គឺមិនមែនសតិប្បដ្ឋាន ។

អ្នកសួរ ពាក្យថា **អនត្តា** នេះដូចជាសសៃសក់បាំងភ្នំ អ្នកខ្លះក៏ដឹងថា **អនត្តា** ប្រែថាអ្វី ឬ **អត្តា** ប្រែថាអ្វី ហើយតែសួរច្រើនគ្នា ទៅក៏អធិប្បាយខុស ផ្សេងគ្នាទាំងអស់ ដោយច្រើនពោលថា អនត្តាមិនមែនតួខ្លួន ទាំងជាទូទៅតួខ្លួនក៏នៅមាន ។

សុចិន្ត តើអ្វីទៅជាតួខ្លួន ?

អ្នកសួរ សម្មតិថា ខ្លួនយើងជាតួខ្លួន តែព្រះមានព្រះភាគត្រាស់ថា មានត្រឹមតែខន្ធ ៥ មកប្រជុំគ្នា ។

សុចិន្ត កាលណាជាខន្ធ ក៏មិនមែនតួខ្លួន តែពេលមិនដឹងថាជាខន្ធ ក៏យល់ថាជាតួខ្លួន ។

អ្នកសួរ ទាំងជាទូទៅដែលដឹងយ៉ាងនេះ ពេលឃើញតាមភ្នែកក៏ថាយើងជាអ្នកឃើញ ។

សុចិន្ត ព្រោះនៅមិនទាន់ប្រចក្សច្បាស់លក្ខណៈនៃខន្ធថា ខន្ធ គឺសភាវធម៌ដែលកើតឡើងហើយរលត់ទៅ យ៉ាងលឿនរហ័សពិត ។ ទើបចំណែកជាអតីត ជាអនាគត ជាបច្ចុប្បន្ន ជាខាងក្នុង ជាខាងក្រៅ គ្រោតគ្រាត ល្អិត ថោកទាប ប្រណីត ឆ្ងាយ ជិត កាលណាប្រចក្សលក្ខណៈនៃខន្ធពិត ។ ក៏ដឹងថាសភាវធម៌មួយខណៈ ។ ដែលកើតរលត់នោះជារូបក្ខន្ធ ឬវេទនាខន្ធ ឬជាសញ្ញាខន្ធ ឬជាសង្ខារក្ខន្ធ ឬជាវិញ្ញាណក្ខន្ធនោះឯង ។

អ្នកសួរ សូមឱ្យអធិប្បាយរឿងឥរិយាបថបិទបាំងទុក្ខ ?

សុចិន្ត ដែលថាឥរិយាបថបិទបាំងទុក្ខនោះ ត្រូវយល់ដែរថា គឺសំដៅដល់លក្ខណៈនៃសភាវធម៌ទាំងឡាយ មិនមែនសំដៅចំពោះ ទុក្ខវេទនាទេ សូម្បីខណៈនេះនឹងអង្គុយ ដេក ឈរ ដើរ ដោយនៅ

មិនទាន់ចុករោយស្រពន់ក៏ដោយឥរិយាបថក៏បិទបាំងទុក្ខលក្ខណៈដែរសុទ្ធសឹងតែជាការកើតរលត់ នៃនាមធម៌ និងរូបធម៌ដែលកើតរួមគ្នា ក្នុងឥរិយាបថនោះ ។ បញ្ញាដែលប្រចក្សច្បាស់ ការកើតរលត់នៃនាមធម៌ និងរូបធម៌នោះ ក៏មិនមែនដឹងឥរិយាបថណាមួយដែលប្រែផ្លាស់ឥរិយាបថមួយទៀតនោះទេ ទើបពោលថាឥរិយាបថបិទបាំងទុក្ខ និងបើដូច្នោះនោះ ក៏នឹងត្រូវពោលថា ការផ្លាស់ប្តូរឥរិយាបថបាំងទុក្ខ ។ ប៉ុន្តែត្រង់ដែលព្រះធម៌សម្តែងថាឥរិយាបថបិទបាំងទុក្ខនោះ ក៏ព្រោះតែមានកើតរួមគ្នានៃនាមរូប ជាឥរិយាបថផ្សេង ។ ទើបបិទបាំងមិនឱ្យដឹងទុក្ខលក្ខណៈ នៃរូបនីមួយ ។ នាមនីមួយ ។ ដែលកំពុងកើតរលត់នៅរាល់ ។ វេលា ។ លោកខ្លះ ដែលទើបតែអង្គុយអម្បាញ់មិញនេះ បើសួរថាកើតទុក្ខទេ ? គាត់ក៏ឆ្លើយថាមិនមានទេ ។ កាលណាមិនមានទុក្ខហើយ តើឥរិយាបថនឹងបិទបាំងទុក្ខបានយ៉ាងណាដូចម្តេចកើត បើកាលណាទុក្ខមិនមានទេ នឹងពោលថាឥរិយាបថបិទបាំងមិនបាន ទាល់តែមានទុក្ខ ទើបនឹងពោលបានថា ឥរិយាបថបិទបាំងទុក្ខ ។ ប៉ុន្តែសេចក្តីពិត សូម្បីដល់ថាឥរិយាបថណាមិនមានទុក្ខវេទនា កើតឡើងក៏ដោយ ក៏ឥរិយាបថនោះបិទបាំងទុក្ខរួចស្រេចហើយ ព្រោះមិនឃើញការកើតរលត់នៃនាមរូបក្នុងខណៈនោះ ។ បើកាលណាមិនអប់រំចម្រើនបញ្ញាឱ្យដឹងលក្ខណៈនៃនាម និងរូបទេ ក៏យល់ខុស

ថា ដឹងទុក្ខខណៈដែលពិចារណាមុនផ្លាស់ឥរិយាបថនោះឯង តែថាដឹងទុក្ខអ្វីទៅ ? ក្នុងពេលណាដែលនៅមិនទាន់ដឹងលក្ខណៈដែលមិនមែនតួខ្លួននៃសភាពដឹងតាមផ្លូវភ្នែក ជាមួយនឹងវត្ថុដែលប្រាកដតាមផ្លូវភ្នែក សភាពឮជាមួយនឹងសំឡេងដែលប្រាកដតាមផ្លូវត្រចៀក សភាពដឹងក្លិនជាមួយនឹងក្លិន សភាពដឹងរស ជាមួយនឹងរស សភាពដឹងផោដ្ឋព្វៈ ជាមួយនឹងផោដ្ឋព្វៈ សភាពនឹកគិត សុខទុក្ខផ្សេង ។ ឬសូម្បីតែសភាវធម៌ដែលគិតនឹងប្រែផ្លាស់ឥរិយាបថនោះទេ ក៏មិនដឹងថាមិនមែនតួខ្លួន ជានាមធម៌មួយបែបដែលកើតឡើងហើយរលត់ទៅប៉ុណ្ណោះ ។ កាលណាមិនរលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ ជាប្រក្រតីតាមសេចក្តីពិតទេ បញ្ញាក៏សម្បូរឡើងតាមលំដាប់ថ្នាក់មិនបាន ហើយក៏មិនប្រចក្សទុក្ខ-អរិយសច្ចបានឡើយ ព្រោះបញ្ញានៅមិនទាន់ប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌នេះ ។

អ្នកសួរ ខណៈណាដែលមានសតិ គឺមានតែទុក្ខដែលប្រាកដ ? តែមិនបានចែករូបនាមតាមផ្លូវភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្តទេ ព្រោះការចែកនោះ ចែកមកជាច្រើនណាស់មកហើយ តែចែកគ្នាតាមបែបបរិយត្តិ នាងខ្ញុំមានការសិក្សាតិចត្រឹមតែបដិបត្តិតែមួយមុខ បន្តិចបន្តួច ដែលសំណាក់បដិបត្តិ កើតសេចក្តីដឹងឡើងមកយ៉ាងនោះ ក៏រៀនឱ្យយល់ ឱ្យជ្រាបទៅនឹងថា

ដឹងតាមអរិយសច្ច ឬដឹងតាមអ្វីក៏ស្រេចតែនឹងយល់ចុះចាស តែដឹងយ៉ាងនោះពិត ។ ។

សុចិន្ត តើពេញចិត្តក្នុងសេចក្តីដឹងយ៉ាងនេះហើយឬនៅ ?

អ្នកសួរ នៅកំពុងក្នុងរវាងការសិក្សា នឹងថាសមដូចចិត្តក៏មិនបាន ។

សុចិន្ត ដែលពោលថា ទៅសំណាក់បដិបត្តិ ដើម្បីសេចក្តីដឹង សេចក្តីយល់ក្នុងផ្លូវបដិបត្តិនោះ តែបើទៅហើយមិនដឹង មិនយល់សភាវធម៌ទេ តើការទៅនោះនឹងមានប្រយោជន៍ឬទេ ?

អ្នកសួរ គឺមាន តាមធម្មតាយើងនៅផ្ទះ អកុសលចិត្តកើតច្រើន កាលណាយើងទៅសំណាក់បដិបត្តិ បានជួបកល្យាណមិត្ត ជួបទីកន្លែងដែលស្ងប់ស្ងាត់ កុសលចិត្តក៏កើតច្រើន យ៉ាងនេះនាងខ្ញុំយល់ថាមានប្រយោជន៍ ។

សុចិន្ត សោតាបត្តិយង្គៈ អង្គធម៌នៃការបន្លុះសោតាបន្នមាន ៤ គឺសេពគប់សប្បុរស ១ ស្តាប់ធម៌ពីលោក ១ ពិចារណាធម៌ ដែលបានស្តាប់ដោយការត្រឹមត្រូវ ១ បដិបត្តិធម៌សមគួរដល់ធម៌ ១ គ្មានទាក់ទងនឹងទីកន្លែងសោះ ។ ដូច្នោះ ក្នុងរឿងនៃសំណាក់បដិបត្តិនោះ គួរវិលត្រឡប់ទៅពិចារណា សំណាក់នៃព្រះមានព្រះភាគវិញម្តង ដើម្បីប្រៀបធៀបឱ្យឃើញថា សំណាក់បដិបត្តិក្នុងសម័យនេះ តើដូចនឹងសំណាក់នៃព្រះមានព្រះភាគឬទេ ? សំណាក់នៃព្រះមាន-ព្រះភាគ ក្នុងអតីតកាលនោះ ព្រះភិក្ខុទាំងឡាយ បិណ្ឌបាត

សន្ទនាធម៌ ធ្វើកិច្ចផ្សេង ៗ តាមព្រះវិន័យបញ្ញត្តិ ព្រះមានព្រះភាគ ព្រះអង្គទ្រង់សរសើរកុសលទាំងពួង **តែអ្នកដែលទៅកាន់សំណាក់ បដិបត្តិក្នុងសម័យនេះ តើបដិបត្តិដូចគ្នាជាមួយនឹងពុទ្ធបរិស័ទក្នុង កាលនោះឬទេ ? ឬលើសជាង ឬផ្សេងគ្នា** ? បើហេតុគឺការ បដិបត្តិផ្សេងគ្នា តើផលនឹងដូចគ្នាបានឬទេ ? ឧបាសក និង ឧបាសិកាក្នុងគ្រាសម័យពុទ្ធកាល ដូចជាលោកអនាថបិណ្ឌិក សេដ្ឋី លោកក៏ទៅព្រះជេតវនមហាវិហារ ដែលលោកបានកសាង ទុក តែលោកទាំងនោះ ក៏មិនបានយល់ខុសថា នឹងត្រូវសម្រេច មគ្គ ផល បានតែក្នុងស្ថានទីទាំងនោះទេ ព្រោះលោកទាំងនោះ សម្រេច មគ្គ ផល និព្វាន ក្នុងទីកន្លែងផ្សេង ៗ គ្នា តាមជីវិតប្រចាំ ថ្ងៃពិត ៗ របស់លោកម្នាក់ ៗ ។ ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត អរញ្ញវគ្គទី ៤ អរញ្ញកសូត្រ ព្រះមានព្រះភាគត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ ភិក្ខុដែលកាន់យកនូវព្រៃជាវត្ត ៥ ជំពូកនេះ ៥ ជំពូកនេះដូចម្តេច ? គឺភិក្ខុអ្នកកាន់យកនូវព្រៃជាវត្តព្រោះការល្ងង់ ខ្លៅ ព្រោះការរវៃងភ្លីភ្លើមិនដឹង ១ មានសេចក្តីប្រាថ្នាលាមក ត្រូវតណ្ហាគ្របសង្កត់ ទើបកាន់យកនូវព្រៃជាវត្ត ១ កាន់យកនូវ ព្រៃជាវត្តព្រោះឆ្កួត ព្រោះចិត្តរវើរវាយ ១ កាន់យកនូវព្រៃជាវត្ត ព្រោះដឹងថាជាវត្តដែលព្រះពុទ្ធជាម្ចាស់ និងសាវ័កពុទ្ធទាំងឡាយ ពោលសរសើរ ១ កាន់យកនូវព្រៃជាវត្ត ព្រោះអាស្រ័យជាអ្នក

មានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីដុសខាត់ ជាអ្នក
មានសេចក្តីត្រូវការដោយ ខ បដិបត្តិស្អាតល្អដូចនេះ ១ ។

សេចក្តីតទៅមានថា

ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ៥ ជំពូក នេះឯង ភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ព្រោះអាស្រ័យជាអ្នកមានសេចក្តី ប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីដុសខាត់ ជាអ្នកមានសេចក្តីត្រូវការ ដោយ ខ បដិបត្តិស្អាតល្អ ដូចនេះជាអ្នកប្រសើរលើសវិសេស ជាប្រធាន ខ្ពស់បំផុត ហើយល្អជាងភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ៥ ជំពូក នេះប្រៀប ដូចទឹកដោះសុទ្ធកើតពីគោ ទឹកដោះជូរកើតពីទឹកដោះសុទ្ធ ប្រេងថ្លា កើតពី ប្រេងខាប់ ក្បាលប្រេងថ្លាកើតពីប្រេងថ្លា ក្បាលប្រេងថ្លាសត្វ លោក រមែងពោលថាជាកំពូលក្នុងចំណោមគោរស ៥ ទាំងនោះយ៉ាងណា បណ្តា ភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ៥ ជំពូកនេះ ភិក្ខុអ្នកកាន់យកនូវព្រៃជា វត្ត ព្រោះអាស្រ័យជាអ្នកមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តី ដុសខាត់ សេចក្តីស្ងប់ស្ងាត់ សេចក្តីជាអ្នកមានសេចក្តីត្រូវការដោយ ខ បដិបត្តិដ៏ល្អយ៉ាងដូចនេះ ក៏ជាអ្នកប្រសើរលើសវិសេស ជាប្រធានខ្ពស់ បំផុតហើយល្អជាងក្នុងចំណោមភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ៥ ជំពូកនេះ ក៏យ៉ាងដូច្នោះដូចគ្នា ។

(ចប់សូត្រទី ១)

ដូចម្តេចទើបមានភិក្ខុអ្នកកាន់យកនូវព្រៃជាវត្ត ព្រោះការលង់ខ្លៅ ព្រោះសេចក្តីវង្វេងភ្លីភ្លើ គឺដោយសារលោកខ្លះគិតថា ទៅនៅព្រៃហើយ គឺប្រាកដជានឹងបានដឹងច្បាស់អរិយសច្ចធម៌ អ្នកដែលយល់យ៉ាងនោះ ជាអ្នកនៅព្រៃ តើព្រោះតែសេចក្តីលង់ខ្លៅ ព្រោះសេចក្តីវង្វេងភ្លីភ្លើឬទេ ? បើយល់ហេតុផលហើយនឹងឃើញថា មិនមានជីវិតណាដែលប្រសើរក្រៃលែងជាងបព្វជិតអ្នកលះបង់ជីវិតឃរាវាស ទៅកាន់សំណាក់នៃព្រះដ៏មានព្រះភាគ ដែលមិនមែនជាការទៅកាន់សំណាក់បដិបត្តិ ត្រឹមតែមួយភ្លែត ។ ដើម្បីត្រូវការប្រាថ្នាបន្លុះមគ្គផលនោះឡើយ ព្រោះគិតថា ការទៅធ្វើវិបស្សនា នៅឯសំណាក់បដិបត្តិដែលមិនមែនអធ្យាស្រ័យពិត ។ នោះនឹងជាហេតុឱ្យដឹងច្បាស់អរិយសច្ចធម៌បានមែននោះ បើពិតជាយ៉ាងនោះដូច្នោះ គ្រហស្ថដែលទៅធ្វើវិបស្សនានៅឯសំណាក់បដិបត្តិ ក៏គួរដល់ការសរសើរក្រៃលែង ជាងភិក្ខុក្នុងសំណាក់នៃព្រះមានព្រះភាគទៅទៀត ដែលលោកមានជីវិតជាប្រក្រតីធម្មតាតាមព្រះវិន័យបញ្ញត្តិ គឺបិណ្ឌបាត ស្តាប់ធម៌ សន្ទនាធម៌ និងប្រព្រឹត្តនូវកិច្ចផ្សេង ។ នៃសង្ឃផងដែរ ។

អ្នកសួរ ដែលថាមិនមែនអធ្យាស្រ័យនេះក៏យល់ហើយ តែថានឹងជំទាស់អធ្យាស្រ័យមិនជាការសមគួរឬ ?

សុចិន្ត បែបនេះត្រូវការពិចារណាហេតុផលឱ្យត្រឹមត្រូវ មានភិក្ខុចំនួនច្រើនណាស់ដែលមិនបាននៅព្រៃ ។ ព្រះមានព្រះភាគព្រះអង្គទ្រង់មិនបង្គាប់ឱ្យទៅចម្រើនសតិប្បដ្ឋាននៅព្រៃ ឬក្នុងបន្ទប់ ឬក្នុង

ទីកន្លែងដែលហាមមិនឱ្យធ្វើកិច្ចអ្វីណាឡើយនោះទេ ព្រះមានព្រះភាគ ព្រះអង្គទ្រង់សរសើរការនៅក្នុងព្រៃ ទ្រង់សរសើរការមិនច្រឡូកច្រឡំគ្នា ទ្រង់សរសើរគ្រប់យ៉ាងដែលមិនជាបច្ច័យឱ្យកើតលោភៈ ទោសៈ មោហៈ ប៉ុន្តែព្រះអង្គទ្រង់មិនបានបង្គាប់ មិនបានដាក់ច្បាប់ទម្លាប់ ក្នុងការចម្រើនបញ្ញានោះឡើយ ព្រោះព្រះអង្គទ្រង់ដឹងនូវអធ្យាស្រ័យនៃសត្វលោក ព្រះអង្គទ្រង់សម្តែងធម៌ ឱ្យពុទ្ធបរិស័ទយល់សភាវធម៌ត្រឹមត្រូវ ដើម្បីដុសខាត់កិលេស ដែលមាននៅជាប្រក្រតីតាមសេចក្តីពិត ដោយការចម្រើនសតិប្បដ្ឋានតាមភេទនៃបព្វជិត និងគ្រហស្ថ ។ កាលណាសតិរលឹកដឹងពិចារណា សិក្សាលក្ខណៈនៃនាមធម៌ និងរូបធម៌ចម្រើនឡើងបន្តិចម្តង ។ នោះ ក៏នឹងសង្កេតបានថា សន្សឹម ។ លះនិស្ស័យចាស់ដែលធ្លាប់ភ្លើតភ្លើនតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដោយលោភៈ ទោសៈ មោហៈ ទៅបន្តិចម្តង ។ ជាអធ្យាស្រ័យពិត ។ មិនមែនជាការប្រព្រឹត្តទៅមួយភ្លែត ។ ម្តងម្កាលនោះទេ មិនមែនដូចដែលលោកខ្លះពោលថាកន្លែងបដិបត្តិនោះមិនគួរលាបពណ៌ទេ ព្រោះធ្វើឱ្យកើតលោភៈ នៅពេលត្រឡប់មកផ្ទះ ក៏លាបថ្នាំផ្ទះ ដាំដើមឈើ ដាំដើមផ្កាដែរ តាមអធ្យាស្រ័យពិត ។ ដែលសន្សឹមក ។

ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងព្រះធម៌ ដែលជាសច្ចធម៌ ជាសេចក្តីពិតដើម្បីឱ្យកើតសេចក្តីឃើញត្រូវក្នុងហេតុ និងផលនៃសភាវធម៌ទាំងឡាយ ព្រះអង្គ ទ្រង់សម្តែងការអប់រំចម្រើនបញ្ញា ដោយការចម្រើនសតិ-ប្បដ្ឋាន ដើម្បីលះបង់នូវអនុស័យកិលេស ដែលប្រចាំនៅក្នុងចិត្ត ដែលកើតរលត់បន្តគ្នាមកក្នុងអតីត អនន្តជាតិ រហូតដល់ខណៈនេះ ។ អវិជ្ជាសេចក្តីមិនដឹងលក្ខណៈនៃសភាវធម៌ និងការយល់ខុស ដែលប្រកាន់សភាវធម៌ថាជាតួខ្លួននោះ ជាអនុស័យកិលេស មិនថានឹងឃើញខណៈណា ឮខណៈណា ធុំក្លិនខណៈណា ដឹងរសខណៈណា ដឹងផោដ្ឋព្វៈ នឹកគិត សុខ ទុក្ខខណៈណា ក៏ប្រកាន់ថាជាតួខ្លួនទាំងអស់ ។ ដូច្នោះ ផ្លូវតែមួយដែលនឹងលះអនុស័យកិលេសបានក៏គឺចម្រើនសតិ ពិចារណាដឹងលក្ខណៈនៃសភាវៈដែលកំពុងប្រាកដ វិបស្សនាញាណថ្នាក់ទី ១ គឺនាមរូបបរិច្ឆេទញាណ ដែលជាសេចក្តីសម្បូរបញ្ញា ដែលប្រចក្សច្បាស់លក្ខណៈដែលផ្សេងគ្នា នៃនាមធម៌ និងរូបធម៌ដែលប្រាកដ ក្នុងខណៈនោះ ។

ការអប់រំចម្រើនបញ្ញាមិនមែនជាការព្យាយាមកសាងសេច-ក្តីទុក្ខឱ្យកើតឡើងដោយការអង្គុយ ដេក ដើរ ឃូរ ។ ដើម្បីឱ្យកើតទុក្ខវេទនានោះទេ តែជាការរលឹកដឹង ពិចារណាសិក្សា

លក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកំពុងប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជាប្រក្រតីតាមសេចក្តីពិត ដែលកើតឡើងហើយ តាមហេតុបច្ច័យ មិនថានឹងនៅទីណាក៏ដោយ ។

អ្នកសួរ ការចម្រើនសតិប្បដ្ឋាន ៤ គឺកាយានុបស្សនាសតិប្បដ្ឋាន វេទនានុបស្សនាសតិប្បដ្ឋាន ចិត្តានុបស្សនាសតិប្បដ្ឋាន ធម្មានុបស្សនាសតិប្បដ្ឋាន ។ សតិប្បដ្ឋានទាំង ៤ នេះ លោកអដ្ឋកថាចារ្យឧបមាដូចទ្វារទាំង ៤ នៃប្រទេស បើនរណាចូលតាមទ្វារណាមួយ ក៏ដោយ មិនថានឹងជាទ្វារ ទិសខាងកើត ទិសខាងលិច ទិសខាងជើង ទិសខាងត្បូងទេ បើចូលទៅ គឺទៅដល់កណ្តាលប្រទេសបានដូចគ្នា ព្រោះដូច្នេះហើយរាល់ថ្ងៃនេះក៏មានអាចារ្យច្រើនតៗ គ្នា ដែលថាមិនចាំបាច់ត្រូវចម្រើនសតិប្បដ្ឋានទាំង ៤ នោះទេ យកត្រឹមតែកាយានុបស្សនាសតិប្បដ្ឋានមួយប៉ុណ្ណឹងល្មមហើយ ព្រោះអដ្ឋកថាចារ្យលោកខៃសេចក្តីទុកថា ចូលទ្វារណាមួយ ក៏ដល់កណ្តាលប្រទេសដូចគ្នាដែរ តើកាយានុបស្សនាសតិប្បដ្ឋាននេះចម្រើនតែម្យ៉ាងនឹងដល់ព្រះនិព្វានបានទេបាទ ?

សុចិន្ត ការចម្រើនបញ្ញាជារឿងល្អិតសុខុមណាស់ មិនមែនថាអ្នកណាមួយបានអានអដ្ឋកថាហើយក៏បដិបត្តិបាននោះទេ ទ្វារនៅទីណា ? បើមិនទាន់ជ្រាបនៅឡើយថា ទ្វារនៅទីណាហើយ តើនឹងចូលតាមទ្វារណា ?

អ្នកសួរ ទ្វារក៏គឺកាយ វេទនា ចិត្ត ធម៌នោះឯង ។

សុចិន្ត កាលណាទ្វារ គឺកាយ វេទនា ចិត្ត ធម៌ ហើយដឹងអ្វីត្រង់កាយដែលនឹងត្រូវពិចារណាដោយល្អិតល្អន់ពិត ។ សភាវធម៌ទាំងឡាយមិនថា ជាខន្ធ អាយតនៈ ធាតុ អរិយសច្ច ក៏មិនមែនសត្វ បុគ្គល តួខ្លួនដែរ ព្រោះជានាមធម៌ គឺសភាពដឹង ១ និងជារូបធម៌ គឺមិនមែនសភាពដឹង ១ ការយល់ដូចនេះមិនមែនជាការប្រចក្សច្បាស់នូវលក្ខណៈដែលមិនមែនតួខ្លួននៃនាមធម៌ និងរូបធម៌ទេ ក្នុងថ្នាក់ការស្តាប់នោះ មិនសង្ស័យឡើយថារូបធម៌មានពិត រូបកើតឡើងប្រាកដតាមភ្នែកជាពណ៌វណ្ណៈផ្សេង ។ សំឡេងជារូបដែលប្រាកដតាមផ្លូវត្រចៀក ក្លិនជារូបដែលប្រាកដតាមច្រមុះ រសជារូបដែលប្រាកដតាមអណ្តាតជាដើម និងនាមធម៌ក៏មានពិតកើតឡើងដឹងអារម្មណ៍ផ្សេង ។ ដោយថ្នាក់នៃការស្តាប់នោះយល់បាន ត្រឹមត្រូវតែឯការដែលបញ្ញានឹងដឹងលក្ខណៈនៃនាមធម៌ជាសភាពដឹង ជាធាតុដឹង ជាអាការដឹងនោះ តើនឹងដឹងបានយ៉ាងណា បើមិនរលឹកដឹងលក្ខណៈនៃសភាពដឹងទេនោះ ? ដូច្នោះការចម្រើន កាយានុបស្សនាសតិប្បដ្ឋាន តែមួយយ៉ាង តើនឹងធ្វើឱ្យដឹងលក្ខណៈនៃនាមធម៌បានឬ ?

អ្នកដែលអប់រំចម្រើនបញ្ញា សតិរលឹកដឹង លក្ខណៈនៃសភាពដឹង ក្នុងខណៈដែលកំពុងឃើញ ពិចារណា សិក្សាដឹងថា

ត្រឹមតែជាសភាពដឹងម្យ៉ាង ខណៈឮក៏រលឹកបាន ពិចារណាយល់លក្ខណៈ នៃនាមធម៌ដែលបានឮ ដើម្បីនឹងដឹងពិត ។ ថាខណៈនោះជាសភាពដឹងសំឡេង ។ កាលណាអប់រំចម្រើនសតិ សិក្សាពិចារណាយល់ និងដឹងលក្ខណៈនៃនាមធម៌តាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ ។ ល ។ សន្សឹម ។ ជារឿយ ។ បញ្ញាក៏នឹងដឹងបានថានៅមាននាមធម៌ដទៃ ។ ទៀតដែលនឹងត្រូវរលឹកដឹងរហូតទម្រាំលក្ខណៈនៃនាមធម៌ដែលជាសភាពដឹង ឬអការដឹងនោះនឹងប្រាកដពិត ។ ឱ្យប្រចក្សច្បាស់ថាត្រឹមតែជាធាតុដឹងអាការដឹង សុទ្ធតែមិនមែនសត្វ បុគ្គល តួខ្លួន ។

បើអ្នកណានឹងរលឹកត្រឹមលក្ខណៈនៃនាមធម៌ដែលឮ តែមិនរលឹកដឹង លក្ខណៈនៃនាមធម៌ ដែលកំពុងឃើញសោះទេ ហើយមានសេចក្តីតាំងចិត្តឧស្សាហ៍ ព្យាយាមនឹងដឹងត្រឹមលក្ខណៈនៃនាមធម៌ ដែលឮសំឡេងតែប៉ុណ្ណោះ តើនឹងយល់លក្ខណៈនៃសភាវធម៌ដែលជាធាតុដឹងពិត ។ ក្នុងខណៈដែលឃើញបានទេ ? និងពិសោធន៍បានដោយខ្លួនឯង ថាមិនអាចជាយ៉ាងនោះឡើយ ។ ដូច្នោះ ការអប់រំចម្រើនបញ្ញា ដោយសតិរលឹកដឹង ពិចារណាសិក្សាយល់លក្ខណៈនៃនាមធម៌ ទាំងតាមផ្លូវភ្នែក ទាំងតាមផ្លូវត្រចៀក ទាំងតាមផ្លូវច្រមុះ ទាំងតាមផ្លូវអណ្តាត ទាំងតាមផ្លូវកាយ ទាំងតាមផ្លូវចិត្ត គឺដើម្បីនឹងប្រចក្ស

ច្បាស់លក្ខណៈនៃសភាវធម៌ ដែលជាធាតុដឹង រហូតអស់ការសង្ស័យពិត ។ ។

កាលណាសតិកើត និងបញ្ញាពិចារណាដឹងលក្ខណៈនៃនាមធម៌តាមផ្លូវភ្នែក ផ្លូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដោយទូទៅហើយ ក៏លះបង់នូវសេចក្តីសង្ស័យ ក្នុងលក្ខណៈ នៃនាមធាតុសុទ្ធតែជាធាតុដឹងទៅបន្តិចម្តង ។ បាន រហូតទាល់តែបញ្ញា ការដឹងច្បាស់លក្ខណៈនៃសភាវធម៌ នឹងចម្រើនកើនឡើង ។ ជាលំដាប់ **តែបើអ្នកណាត្រូវការដឹង ត្រឹមនាមតែមួយប៉ុណ្ណោះ ក៏ស្តែងថាគឺត្រូវនៅមានសេចក្តីមិនដឹង និងសេចក្តីសង្ស័យក្នុងលក្ខណៈនៃនាមធម៌ដទៃ ។** ដោយហេតុនេះហើយ ការដែលនឹងកម្ចាត់សេចក្តីសង្ស័យ សេចក្តីមិនដឹងក្នុងលក្ខណៈនៃធាតុដឹងនោះ ទើបប្រព្រឹត្តទៅមិនបាន ដែលដឹងត្រឹមតែលក្ខណៈនៃនាមធម៌មួយប៉ុណ្ណោះ ព្រោះបើដឹងត្រឹមនាមធម៌តែមួយប៉ុណ្ណោះនោះ ។ ក៏សម្តែងថាមិនដឹងសភាពនាមធម៌ដទៃ ។ ជាក់ច្បាស់ឡើយ ។

អ្នកសួរ ការស្តាប់ គេក៏ស្តាប់ហើយយល់ វេលាបដិបត្តិគេក៏ឆ្លងកាត់នាមរូបបរិច្ឆេទញាណ ។

សុចិន្ត ឆ្លងកាត់យ៉ាងណា ?

អ្នកសួរ និយាយនេះមិនមែនខ្លួនខ្ញុំទេ ។

សុចិន្ត ព្រោះដូច្នោះ មិនត្រូវភ្ញាក់ផ្អើលនឹងការឆ្លងកាត់នៃអ្នកដទៃទេ នឹងត្រូវជាបញ្ញារបស់លោកខ្លួនឯង ដែលពិចារណាដឹងថា បញ្ញាដែលបានអប់រំចម្រើនឡើង ។ រហូតជាបច្ច័យឱ្យវិបស្សនាញាណកើតឡើងនោះ ប្រចក្សច្បាស់សភាពនាមធម៌ និងរូបធម៌ដែលកំពុងប្រាកដជាប្រក្រតីម្យ៉ាង ។ តាមមនោទ្វារប្រចក្សលក្ខណៈនៃនាមធម៌ និងរូបធម៌ មួយលក្ខណៈ ។ ដែលកំពុងប្រាកដមិនមែនត្រឹមនាមធម៌តែមួយ ឬ រូបធម៌តែមួយប៉ុណ្ណោះនោះទេ ។

អ្នកសួរ អ្នកដែលបដិបត្តិរហូតដល់បាននិព្វិទាញាណ ការបដិបត្តិរបស់គេក៏គឺមើលរូបអង្គុយ រូបដេក រូបឈរ រូបដើរ ។ ខ្ញុំសង្ស័យថា រូបអង្គុយ រូបដេក រូបឈរ រូបដើរ តើគេនាំគ្នាមើលដូចម្តេចនាំគ្នាបដិបត្តិយ៉ាងណា រហូតបានសម្រេចនិព្វិទាញាណ ?

សុចិន្ត នាមរូបបរិច្ឆេទញាណជាយ៉ាងណា ? កាលណាមិនដឹងក៏នឹងដល់និព្វិទាញាណមិនបាន ។ កាយានុបស្សនាសតិបដ្ឋានគឺខណៈដែលសតិរលឹកដឹងលក្ខណៈ នៃរូបបរមត្ថធម៌មួយខណៈដែលប្រាកដត្រង់កាយ គឺ រូបត្រជាក់ខ្លះ រូបក្តៅខ្លះ រូបទន់ខ្លះ រូបរឹងខ្លះ រូបតឹងខ្លះ រូបញ័រខ្លះ មិនមែនមើលរូបត្រង់ទ្រង់ទ្រាយជាអង្គុយ ដេក ឈរ ដើរនោះទេ កាលណា សភាពត្រជាក់ប្រាកដត្រង់កាយក៏ត្រឹមតែជាសភាវធម៌ដែលត្រជាក់ ទើបមិនមែនយើង មិនមែនរបស់យើង មិនមែនតួខ្លួន កាលណាមិនដឹងលក្ខណៈនៃរូបធម៌

ដែលប្រាកដត្រង់ទ្វារនីមួយ ។ ថាត្រឹមតែជារូបដែលប្រាកដបានតែទ្វារមួយ ។ ប៉ុណ្ណោះទេ ក៏នឹងដល់នាមរូបបរិច្ឆេទញាណមិនបាន ហើយបើកាលណាបញ្ញាមិនដល់នាមរូបបរិច្ឆេទញាណទេ ក៏នឹងដល់និព្វិទាញាណមិនបាន ។

អ្នកសួរ ក្នុងសម្បជញ្ញបព្វៈ ព្រះអង្គក៏សម្តែងទុកថា យើងឈរក៏ដឹងថាយើងឈរ ខណៈដែលដើរក៏ឱ្យដឹងថាយើងដើរ ខណៈដែលអង្គុយក៏ឱ្យដឹងថាយើងអង្គុយ ឬបត់ចូលលាចេញក៏ឱ្យដឹងក្នុងលក្ខណៈសណ្ឋានផ្សេង ។ នោះ ។ ពាក្យថាយើងដើរក៏ឱ្យដឹងថាយើងដើរ តើខណៈដែលដើរឈ្មោះថាបដិបត្តិរូបដើរបានទេ បាទ ?

សុចិន្ត បើមិនមានរូប តើនឹងមានដើរបានទេ ?

អ្នកសួរ មិនមានរូប ក៏មានតែអាកាស អាកាសដើរមិនបាន ។

សុចិន្ត ខណៈដែលកំពុងដើរ មានរូបតែមួយលក្ខណៈ ។ ប្រាកដឱ្យដឹងបានតែមួយទ្វារ ។

អ្នកសួរ រូបដើរឬទេបាទ ?

សុចិន្ត រូបដែលប្រាកដ មិនថាខណៈអង្គុយ ឬដេក ឬឈរ ឬដើរនោះ នឹងត្រូវប្រាកដតាមផ្លូវណាមួយ គឺផ្លូវភ្នែក ឬផ្លូវត្រចៀក ឬផ្លូវច្រមុះ ឬផ្លូវអណ្តាត ឬផ្លូវកាយ ឬផ្លូវចិត្ត ដោយមិនចោះចំពោះ ដោយជាអនត្តា ។

អ្នកសួរ ដែលគេតាំងចិត្ត ព្រោះក្នុងអដ្ឋកថា លោកក៏ឧបមាទុកថាចូលទ្វារណាមួយក៏ដល់កណ្តាលប្រទេសដូចគ្នា ព្រោះដូច្នោះហើយ ចម្រើនចំពោះតែកាយានុបស្សនាសតិប្បដ្ឋានប៉ុណ្ណោះទៅ បដ្ឋានដទៃគេមិនយក ។

សុចិន្ត ការអានអដ្ឋកថា នឹងត្រូវយល់ដែរថា បញ្ញាដែលលះសេចក្តីយល់ខុសប្រកាន់សភាវធម៌ជាតួខ្លួនបានពិត ។ នោះ តើជាបញ្ញាដែលដឹងអ្វី ? សភាវធម៌មាន ២ យ៉ាង គឺរូបធម៌ និងនាមធម៌ កាលណាមិនដឹងជាក់ច្បាស់ក្នុងលក្ខណៈនៃនាមធម៌ និងរូបធម៌ទេ ក៏នៅតែប្រកាន់ទាំងនាមធម៌ និងរូបធម៌ថាជាតួខ្លួន ។ សេចក្តីដែលថា ក្នុងខណៈដែលដើរក៏ឱ្យដឹងថាយើងដើរ តាមសេចក្តីពិតនោះមិនមានយើងទេ មានតែរូប ខណៈដែលសតិប្បដ្ឋានរលឹកដឹងលក្ខណៈនៃរូបត្រង់កាយដែលប្រាកដ ក្នុងខណៈដែលដើរក៏ជាកាយានុបស្សនាសតិប្បដ្ឋាន តែនឹងបង្គាប់សតិឱ្យរលឹកដឹងរូបដែលប្រាកដត្រង់កាយនៅជាដរាបរាល់ ។ វេលាមិនបាន រមែងស្រេចតែសតិដែលជាអនត្តា នឹងកើតឡើងរលឹកដឹងនូវលក្ខណៈនៃនាមធម៌ណា ឬរូបធម៌ណាដែលកើតឡើងប្រាកដជាប្រក្រតីតាមសេចក្តីពិត បញ្ញាដែលលះការប្រកាន់សភាវធម៌ថាជាតួខ្លួននោះ ដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកើតឡើងប្រាកដ រហូតទូទៅទាំងអស់ទាំង ៦ ទ្វារ ទើបដឹងជាក់ច្បាស់បានថា មិនមែនតួខ្លួនពិត ។ បាន។

ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ សមុទ្ទវគ្គ ទី ៣ **ឧទាយីសូត្រ** មានសេចក្តីថា

សម័យមួយ ព្រះអានន្ទដ៏មានអាយុ និងព្រះឧទាយីដ៏មានអាយុ នៅក្នុងឃោសិតារាម ជិតព្រះនគរកោសម្ពី គ្រានោះឯងវេលាល្ងាច ព្រះឧទាយីដ៏មានអាយុ បានចេញចាកពីទីពួនសម្ងំ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុដល់ទីកន្លែង បានប្រាស្រ័យនឹងព្រះអានន្ទ ។ គ្រាកាលដែលរួចរាល់ពីការប្រាស្រ័យល្មមឱ្យរលឹកដល់គ្នារួចហើយ ទើបអង្គុយត្រង់ទីដ៏សមគួរ រួចហើយបានពោលទៅកាន់ព្រះអានន្ទថា ម្នាលអានន្ទដ៏មានអាយុ កាយនេះព្រះមានព្រះភាគត្រាស់ប្រាប់ បើក ពន្យល់ ប្រកាសហើយ ដោយបរិយាយផ្សេង ។ ថា សូម្បីព្រោះហេតុនេះ កាយនេះជាអនត្តា ដូច្នេះយ៉ាងណា សូម្បីវិញ្ញាណនេះ ព្រះអង្គអាចនឹងសម្តែង ប្រាប់ បញ្ញត្តិ តែងតាំង បង្ហើប ពន្យល់ ចំណែកធ្វើឱ្យរាក់ថា សូម្បីព្រោះហេតុនេះ វិញ្ញាណក៏ជាអនត្តាដូច្នោះដែរឬ ?

កាលនៅមិនទាន់ដឹងជាក់ច្បាស់ក្នុងសភាវធម៌ ក៏នៅមិនអស់សេចក្តីសង្ស័យ កាលនៅសង្ស័យនៅឡើយ តើនឹងដឹងច្បាស់អរិយសច្ចធម៌បានយ៉ាងណា ? តើនឹងចូលតាមទ្វារណា ? **ព្រោះទ្វារដែលថានេះសំដៅដល់ខណៈ ដែលលោកុត្តរចិត្តនឹងកើតឡើងដឹងច្បាស់នូវនិព្វាន** មុនដែលលោកុត្តរចិត្តនឹងកើតនោះ កាមាវចរចិត្តត្រូវកើតមុន ស្រេចតែថាកាមាវចរចិត្តនោះ មានសតិប្បដ្ឋានណាក្នុង ៤ សតិប្បដ្ឋានជាអារម្មណ៍ តែ

មិនមែនថាមិនដឹងជាក់ច្បាស់លក្ខណៈនៃរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ហើយអាចទៅចូលទ្វារ គឺបន្លុះអរិយសច្ចធម៌ ប្រចក្សលក្ខណៈនៃព្រះនិព្វានបាននោះទេ ព្រោះមាននិព្វានជាអារម្មណ៍បាន និងទម្រាំអាចយល់បានថា កាយនេះជាអនត្តា... សូម្បីវិញ្ញាណនោះ ក៏ជាអនត្តាបាន ក៏ត្រូវប្រាប់សម្តែង បញ្ញត្តិ តែងតាំង បង្ហើប ពន្យល់ ចំណែក ធ្វើឱ្យភ្ញាក់រលឹកលក្ខណៈនៃនាមធម៌ និងរូបធម៌ ក្នុងខណៈដែលកំពុងឃើញ កំពុងឮ កំពុងធុំក្លិន កំពុងដឹងរស កំពុងដឹងសភាវៈដែលប៉ះពាល់ កំពុងនឹកគិត ព្រោះលំបាកនឹងយល់ចូលដល់អត្ថ និងប្រចក្សច្បាស់លក្ខណៈនៃសភាវធម៌ទាំងឡាយដែលជាអនត្តាបានណាស់ ។

ព្រះអានន្ទមានអាយុពោលថា ម្នាលព្រះឧទាយីដ៏មានអាយុ កាយនេះព្រះមានព្រះភាគ ត្រាស់ប្រាប់ បង្ហើប ប្រកាសហើយ ដោយបរិយាយផ្សេង ៗ ថា សូម្បីព្រោះហេតុនេះ កាយនេះជាអនត្តា ដូច្នេះយ៉ាងណា សូម្បីវិញ្ញាណនេះ ខ្ញុំអាចនឹងប្រាប់សម្តែង បញ្ញត្តិ តែងតាំង បង្ហើប ចំណែក ធ្វើឱ្យរាក់ថាសូម្បីព្រោះហេតុនេះវិញ្ញាណនេះក៏ជាអនត្តាដែរ ដូច្នោះ ។

បើព្រះអានន្ទមិនបានជាព្រះសោតាបន្នបុគ្គលទេ មិនដឹងច្បាស់នូវសភាវធម៌ ដែលជារូបធម៌ និងនាមធម៌ដោយទូទៅ ដរាបដល់លះសេចក្តីខុស ដែលប្រកាន់នូវនាមធម៌ និងរូបធម៌ ជាតួខ្លួន សត្វ បុគ្គលបានទេ ព្រះអានន្ទក៏គង់នឹងពោលទៅនឹងព្រះឧទាយីមិនបានដែរ ថាខ្ញុំអាចប្រាប់

សម្តែង បញ្ញត្តិ តែងតាំង បង្ហើប ចំណែក ធ្វើឱ្យរាក់ថា សូម្បីព្រោះហេតុនេះ វិញ្ញាណនេះក៏ជាអនត្តា ។

ដូច្នោះ បុគ្គលណាសម្រេចធម៌ណា ធម៌នោះរមែងប្រាកដ នឹងបុគ្គលនោះ ។ វេលានេះសភាវធម៌កើតឡើងហើយ ក៏រលត់ទៅ យ៉ាងរហ័ស កាលណាបុគ្គលណានៅមិនទាន់សម្រេចធម៌ណា ធម៌នោះក៏មិនទាន់ ប្រាកដនឹងបុគ្គលនោះ សូម្បីនឹងប្រាប់គ្នាច្បាស់ប៉ុណ្ណាថា នាមធម៌ជាសភាពដឹង ជាធាតុដឹង ក្នុងខណៈកំពុងឃើញ កំពុងឮ យ៉ាងណាក៏ដោយ តែកាលណាបុគ្គលនោះនៅមិនទាន់សម្រេចធម៌ណា ធម៌នោះក៏នៅមិនប្រាកដដល់បុគ្គលនោះ តែបើកាលណាធម៌ប្រាកដនឹងបុគ្គលនោះហើយ បុគ្គលនោះក៏ដឹងច្បាស់ នូវលក្ខណៈដែលពិតប្រាកដនៃធម៌នោះ។

ព្រះអានន្ទលោកមិនបានមានសេចក្តីសង្ស័យ ក្នុងលក្ខណៈនៃនាមធម៌ និងរូបធម៌ឡើយ ទាំងផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ។ បើមនុស្សសម័យនេះយល់ថា នឹងដឹងត្រឹម កាយានុបស្សនាសតិប្បដ្ឋាន តែម៉្យាង ឬដឹងត្រឹមនាមតែមួយ ឬរូបតែមួយប៉ុណ្ណោះ តើនឹងឈ្មោះថា ដឹងលក្ខណៈដែលពិតប្រាកដនៃនាមធម៌ និងរូបធម៌បានឬទេ ? ព្រោះបើដឹងពិតហើយ ហេតុអ្វីតាមផ្លូវភ្នែកមិនដឹងក្នុងពេលតាមផ្លូវភ្នែកជានាមធម៌ ជាធាតុដឹង ដែលកំពុងឃើញ ? ហេតុអ្វី តាមផ្លូវត្រចៀកមិនដឹងក្នុងពេលតាមផ្លូវត្រចៀកជានាមធម៌ ជាធាតុដឹង ដែល

កំពុងឮ ? បើដឹងលក្ខណៈនៃនាមធម៌ពិត ។ ប្រចក្សច្បាស់ក្នុងធាតុដឹង អាការដឹងហើយ ហេតុអ្វីមិនដឹងថា ក្នុងខណៈដែលនឹកគិត ក៏ត្រឹមតែជា នាមធម៌ដែលកំពុងដឹងរឿង ដឹងពាក្យ ប៉ុណ្ណោះឯង ។

ការដែលនឹងត្រួតពិនិត្យមើលឱ្យឃើញពិត នូវបញ្ញារបស់លោកខ្លួន ឯងថា **ដឹងពិត** ឬទេ គឺមិនថាជានាមធម៌ណា រូបធម៌ណា តាមភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ តាមចិត្ត កាលណា ដឹងពិតក៏ត្រូវដឹង លក្ខណៈនៃនាមធម៌ ដែលផ្សេងនឹងរូបធម៌ ក្នុងខណៈ ដែលឃើញ ដែលឮ ធុំក្លិន ដឹងរស ដឹងសភាវៈ ដែលប៉ះពាល់ នឹកគិត ទើបជាការដឹងពិតក្នុងអត្ថ និងលក្ខណៈនៃសភាវធម៌ទាំងឡាយ ដោយ សេចក្តីជាអនត្តា ។

ព្រះអានន្ទពោលទៅកាន់ព្រះឧទាយីថា "ម្នាលព្រះឧទាយីដ៏មាន អាយុ ចក្ខុវិញ្ញាណរមែងកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូបឬ"

ឧទាយី យ៉ាងនោះហើយលោកដ៏មានអាយុ

អានន្ទ ហេតុនិងបច្ច័យ ដែលចក្ខុវិញ្ញាណអាស្រ័យកើតឡើង គប្បី នឹងរលត់ទៅទាំងអស់ រកចំណែកសេសសល់មិនបាន តើ ចក្ខុវិញ្ញាណនឹងប្រាកដខ្លះឬហ្ន៎ ?

ឧទាយី មិនប្រាកដឡើយលោកដ៏មានអាយុ ។

ក្នុងខណៈដែលឮមិនមានឃើញនេះ គឺការប្រចក្សលក្ខណៈ នៃ សភាវធម៌តាមសេចក្តីពិត ក្នុងខណៈដែលនឹកគិតរឿងរ៉ាវផ្សេង ។ មិនមាន

ឃើញ មិនមានឮ ព្រោះខណៈនោះកំពុងដឹងរឿង សភាពដឹងកំពុងគិតរឿង ដែលកំពុងដឹងនៅក្នុងខណៈនោះ ។ នេះគឺការប្រចក្សលក្ខណៈនៃសភាវធម៌តាមសេចក្តីពិត ព្រះអានន្ទពោលទៅកាន់ព្រះឧទាយីថា កាលចក្ខុ-វិញ្ញាណ គឺការឃើញកើតឡើង ព្រោះអាស្រ័យចក្ខុ គឺភ្នែក និងវត្ថុដែលប្រាកដតាមភ្នែក កាលបើចក្ខុ និងរូបដែលមិនទៀងរលត់ទៅហើយ តើការឃើញនឹងមានបានយ៉ាងណា ? ការឃើញក៏ត្រូវរលត់ទៅ ។

ក្នុងខណៈនេះ អ្នកដែលប្រចក្សលក្ខណៈនៃសភាពដឹង ធាតុដឹងពិត ។ ជានាមរូបបរិច្ឆេទញាណហើយ ទម្រាំនឹងអប់រំចម្រើនបញ្ញា រហូតដល់ និព្វិទាញាណបាន បញ្ញានឹងត្រូវចម្រើនឡើង រហូតដល់ដឹងបច្ច័យនៃសភាវធម៌ ដែលកើតឡើងសម្រេចដល់បច្ចយបរិគ្គហញាណ ហើយទើបបញ្ញានឹងអប់រំចម្រើនតទៅទៀត រហូតទាល់តែនឹងប្រចក្សការកើតឡើង និងរលត់ទៅនៃសភាវធម៌ដែលបន្តគ្នា ជាសម្មសនញាណ ហើយបញ្ញាក៏នឹងត្រូវអប់រំចម្រើនតទៅ រហូតទាល់តែប្រចក្សការកើត រលត់ ញែកដាច់ពីគ្នានៃសភាវធម៌ក្នុងមួយលក្ខណៈ ។ ជាឧទយព្វយញាណ ហើយបញ្ញាក៏នឹងត្រូវ អប់រំចម្រើនតទៅ រហូតទាល់តែប្រចក្សសេចក្តីមិនទៀង នៃសភាវធម៌ដែលរលត់ទៅ ។ ជាភង្គញាណ ហើយបញ្ញាទើបអប់រំចម្រើនឡើងរហូតទាល់តែប្រចក្ស ទោសភ័យនៃការរលត់ទៅនៃសភាវធម៌ ជាភយ-ញាណ និងអាទីនវញាណ រួចបញ្ញាក៏នឹងត្រូវអប់រំចម្រើនឡើងរហូតទាល់តែដល់និព្វិទាញាណ បញ្ញានឹងត្រូវដឹងច្បាស់លាស់ពិត ។ ដោយ

ប្រចក្សលក្ខណៈនៃសភាវធម៌ មិនមែនថាមិនដឹងលក្ខណៈនៃនាមធម៌ ហើយ នឹងចូលទ្វារនិព្វាន ដោយត្រឹមតែដឹងទ្រង់ទ្រាយអង្គុយ ទ្រង់ទ្រាយដេក ទ្រង់ទ្រាយឈរ ទ្រង់ទ្រាយដើរ សឹងជាការចាំរូប ដែលកើតរួមគ្នាជាសណ្ឋានអាការផ្សេង ។ នោះទេ គឺមិនមែនជាការដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌តែមួយលក្ខណៈ ។ ដែលកើតឡើងប្រាកដតាមទ្វារផ្សេង ។ ហើយរលត់ទៅតាមប្រក្រតីជាសេចក្តីពិត ។

ព្រះអានន្ទដ៏មានអាយុពោលថា ដោយបរិយាយនេះឯង ចក្ខុ-វិញ្ញាណនេះ ព្រះមានព្រះភាគត្រាស់ប្រាប់ បង្ហើប ពន្យល់ ប្រកាស ហើយថា សូម្បីព្រោះហេតុនេះ វិញ្ញាណនេះជាអនត្តាដូចនេះ ។ សេចក្តីដដែល ។ តទៅរហូតទៅដល់ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ដោយន័យតែមួយដូចគ្នា ។

ព្រះសូត្រនេះ សម្តែងឱ្យឃើញប្រយោជន៍ដែលព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្តែង ព្រះធម៌ដោយល្អិត ជាដរាបក្នុងរឿងនៃវិញ្ញាណទាំង ឡាយ ដែលជានាមធម៌ បើអាចដឹងច្បាស់នូវអរិយសច្ចធម៌បានដោយ សតិប្បដ្ឋានតែមួយនោះ តើព្រះមានព្រះភាគទ្រង់នឹងសម្តែងធម៌ដទៃ ។ ដើម្បីប្រយោជន៍អ្វី ? មិនថាជាការឃើញ ការឮ ការធុំក្លិន ការដឹងរស ការដឹងវត្ថុដែលប៉ះពាល់ ការនឹកគិត សេចក្តីសុខ សេចក្តីទុក្ខ ការចាំ ។ ល ។ ដ៏យ៉ាងច្រើនទាំងអស់នេះ ក៏ដើម្បីឧបការៈឱ្យសតិរលឹក ឱ្យបញ្ញាពិចារណា សិក្សាដឹងជាក់រហូតដល់រលត់នូវសេចក្តីសង្ស័យ និងសេចក្តីយល់ខុស

ដែលប្រកាន់នាមធម៌ និងរូបធម៌បានជាសមុច្ឆេទ ហើយនិងដែលពោលថា អាចដឹងច្បាស់នូវអរិយសច្ចធម៌បាន ដោយមិនចាំបាច់ទៅដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ប្រក្រតីតាមសេចក្តីពិតនោះ ក៏សម្តែងសេចក្តីសង្ស័យ ហើយថានឹងដឹងនាមធម៌ដទៃ រូបដទៃមិនបាន មិនដូច្នោះទេ ក៏នឹងមិនបានពោលថាឱ្យដឹងត្រឹមតែនាមមួយ រូបមួយ ។

ព្រះអានន្ទដ៏មានអាយុពោលថា " ម្នាលឧទាយី បុរសត្រូវការខ្លឹមឈើដើរស្វែងរកខ្លឹមឈើ ដោយកាន់ដឹងដ៏មុតចូលដល់ព្រៃ ជួបដើមចេកយ៉ាងធំ ហើយត្រង់ស្រលូនក្នុងព្រៃនោះ ក៏កាត់ត្រង់គល់ ហើយកាត់ត្រង់កណ្តាល រួចហើយបកយកស្រទបចេញ សូម្បីស្រាយត្រង់ដើមចេកនោះ ក៏មិនជួប ធ្វើម៉េចនឹងជួបខ្លឹមឈើបាន យ៉ាងណាមិញ ម្នាលព្រះឧទាយី ភិក្ខុនឹងពិចារណារកតួខ្លួន ឬវត្ថុជារបស់ខ្លួនក្នុងផស្សាយតនៈ ៦ មិនបាន ក៏យ៉ាងដូច្នោះដែរ ។ កាលណាសម្លឹងឃើញនៅយ៉ាងនេះ ក៏មិនប្រកាន់វត្ថុណា ។ ក្នុងលោក កាលណាលែងប្រកាន់ ក៏មិនខ្វល់ខ្វាយ មិនកង្វល់ កាលណាមិនកង្វល់ ក៏បរិនិព្វានដោយពិតប្រាកដ ហើយរមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយបានចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ កិច្ចដទៃដើម្បីសេចក្តីជាយ៉ាងនេះ មិនមាន "។

សេចក្តីចុងក្រោយដែលព្រះអានន្ទពោលថា "ម្នាលព្រះឧទាយី បុរសត្រូវការខ្លឹមឈើ ដើរស្វះស្វែងរកខ្លឹមឈើ ដោយកាន់ដឹងដ៏មុត

ចូលព្រៃ ជួបដើមចេកយ៉ាងធំ ហើយត្រង់ស្រលូនក្នុងព្រៃនោះ" កាលជាដើមចេក ក៏នៅជាទ្រង់ទ្រាយ រូបរាង ព្រោះរួមគ្នាជាក្រុម ជាដុំ ។

" ក៏កាត់ត្រង់គល់ ហើយកាត់ត្រង់កណ្តាល រួចហើយបកយកស្រទបចេញ" គឺបើកចេញនូវវត្ថុដែលធ្លាប់ប្រកាន់រួមគ្នា ប្រជុំគ្នា ជាវត្ថុជាតួខ្លួន ជាទ្រង់ទ្រាយរូបរាងចេញ ។ "សូម្បីស្រាយត្រង់ដើមចេកនោះ ក៏មិនជួប ដូចម្តេចនឹងជួបខ្លឹមបាន " ទើបនឹងលះការប្រកាន់ថាជាដើមចេក ។ ឧទាហរណ៍ ដូចជា ខ្លួនគោ បើនៅមិនទាន់ពន្លាត់ស្បែកចេញ មិនទាន់កាត់សសៃចំណែកផ្សេង ។ ចេញទេ ក៏គង់នៅឃើញជាគោ ដរាបណាដែលរូបទាំងឡាយនៅប្រជុំរួមគ្នា ក៏នៅចាំទុកជាទ្រង់ទ្រាយ រូបរាងជាអាការណាមួយ និងនៅគង់ឃើញថាសភាវៈនោះជាវត្ថុ នៅជាតួខ្លួនបុគ្គល ដល់ពេលណាដឹងលក្ខណៈនៃសភាវធម៌តាមសេចក្តីពិត កាលនោះទើបនឹងមិនប្រកាន់នូវសភាវធម៌ជាសត្វ ជាបុគ្គល ដូចការបកស្រទបចេកចេញ សូម្បីស្រាយត្រង់ដើមចេកក៏មិនជួប ដូចម្តេចនឹងជួបខ្លឹមបានយ៉ាងណា ។

"ម្នាលព្រះឧទាយី ភិក្ខុនឹងពិចារណារកតួខ្លួន ឬវត្ថុដែលជាតួខ្លួនក្នុងផស្សាយតនៈ ៦ មិនបាន" ក្នុងផស្សាយតនៈ ៦ មិនបានមានទ្រង់ទ្រាយអ្វីឡើយ ភ្នែកជាអាយតនៈមួយ រូបាយតនៈត្រឹមតែជាវត្ថុដែលប្រាកដ បើដរាបណាដែលនៅឃើញមានមនុស្សកំពុងអង្គុយ ខណៈនោះនឹងពោលថាមិនមែនតួខ្លួន ក៏ត្រឹមតែជាសេចក្តីនឹកគិតដោយខ្លួនឯងថា

មិនមែនតួខ្លួន តែមិនប្រកែកថា ដែលមិនមែនតួខ្លួនពិត ។ នោះ បញ្ញានឹងត្រូវដឹងថា ខណៈដែលឃើញនោះឃើញត្រឹមតែសភាវៈដែលប្រាកដតាមផ្លូវភ្នែកប៉ុណ្ណោះ ក្រោយពីនោះមកទើបត្រិះរិះ ឬចាំសណ្ឋាននៃសភាវៈដែលប្រាកដ រួចទើបដឹងថាសភាវៈដែលប្រាកដជាអ្វី សូម្បីខណៈនោះក៏ជានាមធម៌ ដែលដឹង ដែលចាំ មិនមែនសត្វ បុគ្គល តួខ្លួនដែរ ។ តាមផ្លូវត្រចៀកដែលកំពុងឮនោះ ក៏មិនមានសេចក្តីចងចាំសល់ មិនទាន់អស់ពីភ្នែកថា កំពុងឃើញមនុស្សអង្គុយជជែកគ្នា ឬកំពុងនិយាយឡើយព្រោះខណៈនោះ សតិរលឹកដឹងលក្ខណៈនៃសភាពឮដែលជាធាតុដឹងប៉ុណ្ណោះ ហើយក្រោយពីនោះទើបចិត្តនឹកគិតពាក្យ ឬរឿងតាមសំឡេងខ្ពស់ សំឡេងទាបដែលឮ បញ្ញាដឹងថា ខណៈដែលដឹងពាក្យនោះ ក៏ជានាមធម៌មួយបែបដែលដឹងពាក្យ ។

កាលណាដឹងសភាវធម៌ទាំងឡាយជានាមធម៌ និងរូបធម៌តែមួយលក្ខណៈ ។ សេចក្តីយល់ខុសដែល ប្រកាន់សភាវធម៌ជាតួខ្លួន ទើបលះបង់ចោល និងសេចក្តីចងចាំដែលប្រកាន់រូបរួមគ្នា ជាទ្រង់ទ្រាយ ទើបនឹងអាចអស់ទៅ ហើយនឹងអាចយល់នូវអត្ថ ដែលថា**សេចក្តីស្ងប់ខាងក្នុង** ព្រោះចិត្តមិនបានចេញទៅពពាក់ពពូនទាក់ទាញខាងក្រៅ ដែលជាតួខ្លួន មនុស្ស សត្វឡើយ មិនមានលោកមុន ដែលជាលោកខាងក្រៅពេញទៅដោយមនុស្សម្នា វត្ថុរបស់ផ្សេង ។ ដែលធ្លាប់ប្រកាន់ថាជាបុគ្គលនេះ បុគ្គលនោះ វត្ថុនេះ វត្ថុនោះ យ៉ាងទៀងទាត់បិតថេរមាំមួននោះទេ ប៉ុន្តែថាសតិកើត

ខណៈណា បញ្ញាដឹងជាក់ច្បាស់ខណៈនោះ ទើបជាសេចក្តីស្ងប់ខាងក្នុង ព្រោះមិនមានមនុស្ស សត្វ បុគ្គល វត្ថុណា ៗ ។ ដែលមិនស្ងប់ ក៏ព្រោះមនុស្សច្រើន មានរឿងច្រើន បើជាបុគ្គលដែលធ្លាប់មានការពាក់ព័ន្ធ ឬមានរឿងវ៉ាវទាក់ទិនគ្នាផងនោះ ពេលឃើញតែមួយភ្លែតក៏តជារឿងយ៉ាងវែង តែបើជាមនុស្សដែលមិនធ្លាប់ស្គាល់ទេ រឿងក៏ខ្លីរហ័សចប់ ។ ពេលឃើញ ក៏គិតភ្លែតក៏អស់ទៅ ហើយមិនបានជាប់តាមទៅជារឿងវ៉ាវផ្សេង ៗ ឡើយ ។

កាលណាអប់រំចម្រើនបញ្ញាពិត ៗ ក៏នឹងឃើញព្រះគុណ របស់ព្រះមានព្រះភាគ ដែលព្រះអង្គទ្រង់សម្តែងព្រះធម៌ដោយយ៉ាងល្អិតសុខុមជ្រាលជ្រៅ តាំងពីថ្នាក់បាតិមោក្ខសំវរសីល សេចក្តីប្រព្រឹត្តតាមផ្លូវកាយ និងផ្លូវវាចា ដែលសមគួរដល់សមណៈ គឺភេទបព្វជិតអ្នកស្ងប់ សូម្បីតែការមើល ក៏មើលប្រវែងមួយជួរនឹមដើម្បីឱ្យរលឹកនៅជានិច្ចថា មិនគួរតរឿងឱ្យវែងអន្លាយទេ កាលឃើញហើយក៏មិនគួរគិតវិចិត្រជាមនុស្សនេះ មនុស្សនោះ រឿងនេះ រឿងនោះ សន្ធឹកសន្ធាប់ទេ កាលឃើញហើយ ក៏ដឹងថា ត្រឹមតែជា**ឃើញ** ទោះបីជាមួយជួរនឹម ឬមិនមួយជួរនឹមក៏ដោយ ឃើញហើយក៏ចប់ ខណៈនោះ ក៏នឹងមិនពាក់ព័ន្ធទាក់ទងក្នុងនិមិត្តអនុព្យញ្ជនៈ ។ កាលណាបញ្ញាដឹងច្បាស់ពិត ៗ ថាដែលធ្លាប់ឃើញជាលោកខាងក្រៅមានមនុស្សម្នា សន្ធឹកសន្ធាប់នោះ ក៏មានព្រោះគិត បើមិនគិតឃើញហើយក៏អស់ទៅ តើនឹងឃើញមនុស្សសន្ធឹកសន្ធាប់ទេ ? ប៉ុន្តែ

ព្រោះដោយគិតមកយូរយារហើយ ព្រោះដូច្នោះក៏រមែងគិត ស្រេចតែថា នឹងគិតអ្វី សូម្បីថានឹងឃើញវត្ថុតែមួយដូចគ្នា តែមនុស្សម្នាក់ ៗ គិតមិន ដូចគ្នាឡើយ តាមហេតុ តាមបច្ច័យដែលបានសន្សំមក ដូចជាឃើញផ្កា ម្នាក់ពេញចិត្តថាស្អាតស្រស់ ម្នាក់ទៀតថាមិនស្អាត មិនស្រស់ ដូចនេះ ស្អាតស្រស់ ឬ ? មិនស្អាត ស្រស់ ទើបជាសេចក្តីគិតរបស់មនុស្សម្នាក់ ៗ លោកដែលពិតប្រាកដ ទើបជាលោកនៃគំនិតរបស់មនុស្សម្នាក់ ៗ ពេល សតិរលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ពិត ៗ ហើយក៏នឹងដឹង ច្បាស់ថា ខណៈនោះជានាមធម៌ ដែលកំពុងគិតរឿងរ៉ាវផ្សេង ៗ ប៉ុណ្ណោះ មិនថានឹងគិតជាអ្វីក៏ដោយ ។ កាលណាដឹងលក្ខណៈនៃនាមធម៌ ដែលគិត ក៏ដឹងថារឿងរ៉ាវដែលជាមនុស្ស សត្វផ្សេង ៗ មិនមានពិត ៗ ។ ខណៈ ដែលមានទុក្ខកង្វល់ចិត្ត ក៏ដឹងថាទុក្ខព្រោះការគិត ខណៈដែលមានសុខ ក៏ដោយន័យតែមួយដូចគ្នា ខណៈមើលទូរទស្សន៍រឿងដែលពេញចិត្ត ក៏ជា សុខ ព្រោះគិតតាមរូបភាពដែលឃើញ ដូច្នោះ មិនថាជានៅក្នុងទីណា ៗ ក៏ដោយ ក៏នៅក្នុងលោក នៃសេចក្តីនឹកគិតនោះឯង ។ លោកតែមួយ ខណៈ ៗ ទើបជានាមធម៌ដែលកើតឡើងដឹងអារម្មណ៍ដែលប្រាកដតាម ភ្នែក តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយហើយក៏នឹកគិតតាម ផ្លូវចិត្តជារឿងរ៉ាវផ្សេង ៗ ប៉ុណ្ណោះឯង ។

អ្នកសួរ ដែលអាចារ្យពោលថា សេចក្តីសុខ សេចក្តីទុក្ខ នេះជារឿងនៃគំនិត ពេលនេះខ្ញុំមិនទាន់សូវយល់ទេ វេលាមានសេចក្តីទុក្ខ តើនរណាគេក៏នឹងចង់គិតឱ្យទុក្ខ មិននរណាចង់បានទុក្ខទេ ដូច្នោះ អាចារ្យនិយាយថាសេចក្តីទុក្ខកើតអំពីគំនិត គិតឱ្យជាទុក្ខ តើគិតយ៉ាងម៉េចបាទ ?

សុចិន្ត មិនមែនគិតឱ្យជាទុក្ខទេ មានហេតុ មានបច្ច័យឱ្យគិត ហើយជាទុក្ខ ។

អ្នកសួរ បានសេចក្តីថា មានបច្ច័យកើតឡើង ដូចជាសម្បត្តិព្រាត់ប្រាសទៅ ឬថាចាក់សេះចាញ់អស់ហើយត្រឡប់មកដល់ផ្ទះ ក៏គិតថា ចាញ់អស់ប៉ុណ្ណេះ អស់ប៉ុណ្ណោះ តើការចាក់សេះជាបច្ច័យឬ ?

សុចិន្ត បើមិនគិតរឿងចាញ់សេះ តើនឹងមានសេចក្តីទុក្ខទេ ?

អ្នកសួរ មិនទុក្ខទេបាទ

សុចិន្ត ពេលឃើញ ឮ រួចហើយគិត បញ្ញានឹងត្រូវដឹងថា ខណៈដែលគិតនោះ គឺនាមធម៌ដែលគិតរឿងផ្សេង ។ រួចហើយរលត់ទៅ ។ ខណៈដែលគិតរឿងសេះ មិនមានសេះក្នុងខណៈនោះទេ មានសេចក្តីចាំរឿងសេះ ដែលធ្វើឱ្យកើតសេចក្តីទុក្ខឡើង ។ ដូច្នោះ ទើបទុក្ខកើតព្រោះគិតរឿងដែលមិនពេញចិត្ត និងសុខក៏កើតព្រោះគិតរឿងដែលពេញចិត្ត ។

ធម៌ដែលបានស្តាប់ទាំង ៣ បិដក រួមទាំងអដ្ឋកថា និងដីកា ក៏ដើម្បីឱ្យបញ្ញាកើតឡើងដឹងសភាវធម៌ ដែលកំពុងប្រាកដក្នុងខណៈនេះជាប្រក្រតីតាមសេចក្តីពិត មិនថានឹងស្តាប់ច្រើន រៀនច្រើន សន្ទនាធម៌ច្រើន ត្រិះរិះពិចារណាធម៌ច្រើនដល់ប៉ុណ្ណា ក៏គឺដើម្បីជាសង្ខារក្ខន្ធ តាក់តែងឱ្យសតិកើតរលឹកសិក្សា ពិចារណាដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដតាមផ្លូវភ្នែក តាមផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ក្នុងខណៈនេះ ។ សូម្បីថា នឹងបានឮ បានស្តាប់យ៉ាងនេះ ដដែលហើយ ដដែលទៀតក៏ដោយ ក៏នឹងត្រូវពិចារណាឱ្យយល់លក្ខណៈនៃសភាវធម៌ម្យ៉ាង ។ ដែលកំពុងប្រាកដពិត ។ សុទ្ធតែសតិ នឹងត្រូវរលឹកដឹង ។ បើមិនដូច្នោះទេ ក៏មិនអាចនឹងសិក្សា ពិចារណាដឹងលក្ខណៈនៃសភាវធម៌ដែលជាអនត្តាក្នុងមួយថ្ងៃ ។ ដែលកន្លងទៅ ។ ដែលជានាមធម៌ និងរូបធម៌ដែលកើតឡើង ហើយរលត់ទៅ គ្រប់ខណៈមិនមានអ្វីសេសសល់ឡើយ សូម្បីតែមួយខណៈ ។

មនុស្សគ្រប់គ្នាដឹងថា អតីតជាសុខសប្បាយ ឬ សេចក្តីទុក្ខដែលកើតឡើងក៏រលត់អស់ទៅហើយ គង់សល់នៅតែបច្ចុប្បន្នតែមួយខណៈនេះ ត្រឹមតែមួយខណៈពិត ។ ដែលនឹងត្រូវសិក្សាឱ្យយល់លក្ខណៈដែលមិនមែនតួខ្លួន សត្វ បុគ្គល មនុស្សខ្លះ ក៏ប្រាប់ថាសូមកុំជួបមនុស្សនេះ មនុស្សនោះទៀតក្នុងជាតិមុខ បើជា

អ្នកដែលយល់ព្រះធម៌ហើយ ក៏នឹងមិនគិតយ៉ាងនេះឡើយ ព្រោះជាតិមុខនឹងមិនមានមនុស្សនេះ និងមិនមានមនុស្សនោះ ដែលកំពុងយល់ថាជាយើងទៀតក្នុងជាតិមុខផងដែរ ។ ជាតិនេះប៉ុណ្ណោះដែលនៅជាមនុស្សនេះ ឬជាមនុស្សនោះ ដល់ពេលស្លាប់ទៅក៏អស់សភាពសេចក្តីជាបុគ្គលនេះ និងបុគ្គលនោះ ក្នុងជាតិនេះយ៉ាងដាច់ខាត ឯជាតិមុខក៏ត្រូវជាបុគ្គលដទៃពិត ។ ដូច្នោះក៏មិនត្រូវហួងហែងកង្វល់ថានឹងត្រូវទៅជួបនឹងមនុស្សនេះ មនុស្សនោះទៀតឡើយ ដែលមិនមានផ្លូវនឹងប្រព្រឹត្តទៅបានទេ ព្រោះថាភាពជាបុគ្គលនេះ បុគ្គលនោះ នឹងមិនជាប់តាមទៅដល់ជាតិមុខដែរ ។

បើនៅតែមានសេចក្តីមួរម៉ៅ ឬសេចក្តីមិនពេញចិត្ត ក្នុងបុគ្គលណាមួយ ក៏សូមឱ្យយល់ថា សេចក្តីពិតមិនមានបុគ្គលនោះឡើយ គឺមានតែសភាវធម៌ដែលជាចិត្ត ចេតសិក រូប កើតឡើងហើយរលត់ទៅ គ្រប់ជីវិតតម្រង់នៅត្រឹមតែមួយជួរខណៈចិត្តប៉ុណ្ណោះឯង ។ ការរលឹកដល់សេចក្តីស្លាប់ញយ ។ ជារឿយ ។ រមែងមានប្រយោជន៍ដល់ការចម្រើនសតិប្បដ្ឋាន ពេលរលឹកដឹងបានថាអាចនឹងស្លាប់ល្ងាចនេះ ឬព្រឹកនេះក៏បាន ក៏នឹងជាបច្ច័យឧបត្ថម្ភឱ្យសតិរលឹកដឹងលក្ខណៈនៃនាមធម៌ និងរូបធម៌ដែលកំពុងប្រាកដ ព្រោះអ្នកដែលនៅមិនទាន់ដឹងច្បាស់អរិយសច្ចធម៌ ជា

ព្រះអរិយបុគ្គលនោះ កាលចុតិហើយ ក៏នៅមិនប្រាកដច្បាស់លាស់ថា នឹងបដិសន្ធិក្នុងសុគតិភូមិ ឬទុគ្គតិភូមិ និងមានឱកាសបានស្តាប់ព្រះធម៌ និងចម្រើនសតិប្បដ្ឋានទៀតដែរ ឬអត់ ។

សេចក្តីស្លាប់ព្រាត់ប្រាស់គ្រប់យ៉ាងអំពីជាតិនេះ ទៅទាំងអស់ មិនមានអ្វីទៀតសេសសល់ឡើយ សូម្បីតែសេចក្តីចងចាំក៏ដោយ ដូចជាពេលកើតមកជាតិនេះ ក៏ចាំមិនបានដែរថាជាតិមុននោះ តើជាអ្នកណា នៅកន្លែងណា តើធ្វើអ្វី ? អស់ភាពជាបុគ្គលក្នុងជាតិមុនសូន្យឈឹងយ៉ាងណា ជាតិនេះទាំងអស់ មិនថានឹងធ្លាប់ធ្វើកុសលកម្ម អកុសលកម្មអ្វីមកហើយក៏ដោយ ឬជាបុគ្គលដែលមានមានះ ក្នុងជាតិត្រកូល ទ្រព្យសម្បត្តិ កិត្តិយសកេរ្តិ៍ឈ្មោះអ្វី ។ ក៏ដោយក៏នឹងត្រូវអស់ឈឹង **សូន្យរលីង** មិនមានការពាក់ព័ន្ធ សេសសល់ ទាក់ទងនឹងភពនេះ ជាតិនេះទៀតឡើយ អស់សេចក្តីជាប់ជំពាក់ ប្រកាន់គ្រប់ខណៈក្នុងជាតិនេះថាជា**យើង** តទៅទៀត ក៏យ៉ាងដូច្នោះដែរ ។

ការប្រចក្សច្បាស់លក្ខណៈដែលពិតប្រាកដ នៃបរមត្ថធម៌ និងប្រាសចាកការប្រកាន់សភាវធម៌ ដែលកើតឡើងព្រោះហេតុបច្ច័យថាជាសត្វ បុគ្គល តួខ្លួន សូម្បីតែសេចក្តីចងចាំដែលកើតឡើង ហើយក៏រលត់ទៅនោះក៏ដោយ ក៏ត្រឹមតែជានាមធម៌មួយប្រភេទប៉ុណ្ណោះ ។ សតិដែលរលឹកដឹងលក្ខណៈនៃនាមធម៌ និង

រូបធម៌ រហូតបញ្ចាប្រចក្សច្បាស់សភាវធម៌ ទើបប្រាសចាកសេចក្តីជាតួខ្លួន ជាបុគ្គលក្នុងជាតិនេះ កាលណាប្រចក្សលក្ខណៈដែលជាខណិកមរណៈនៃសភាវធម៌ទាំងឡាយ ព្រោះមរណៈ ឬសេចក្តីស្លាប់នោះមាន ៣ ប្រភេទគឺ[៥២] ខណិកមរណៈ សម្មតិមរណៈ សមុច្ឆេទមរណៈ ។

ខណិកមរណៈ គឺការកើតឡើង និងរលត់ទៅនៃសង្ខារធម៌ទាំងឡាយ

សម្មតិមរណៈ គឺសេចក្តីស្លាប់ក្នុងជាតិមួយ ភពមួយ

សមុច្ឆេទមរណៈ គឺបរិនិព្វាន ការស្លាប់នៃព្រះអរហន្ត ដែលមិនមានការកើតទៀតឡើយ ។

[៥២] សម្មោហវិនោទនី អដ្ឋកថាសច្ចវិភង្គនិទ្ទេស និទ្ទេសមរណៈ

ឯកសារយោង និងមានឧបការៈក្នុងការចារធម្មទានេះ

១- បរមត្ថធម៌សង្ខេប ចិត្តសង្ខេប និងភាគបន្ថែម ប្រែដោយ លោកគ្រូ រស់ សុជាត (បកប្រែឆ្នាំ ព.ស. ២៥៣៨)

២- ព្រះត្រៃបិដកខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស. ២៥០២

៣- វចនានុក្រមខ្មែរ សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ) ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១១

៤- ព្រះអភិធម្ម មេរៀនដំបូង លោកអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស ព.ស. ២៥៥៤

មតិ និងការយល់ឃើញរបស់ពុទ្ធបរិស័ទអ្នកសិក្សា

……

……

……

……

……

……

……

……

……

……

……

……

……

……

……

……

……

…….

ម្នាលភិក្ខុទាំងឡាយ ឥណ្ហីយចុះ ឥឡូវនេះ តថាគតប្រាប់
អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយ
មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ
ចូរញុ៉ាំងកិច្ចទាំងពួងឱ្យសម្រេច
ដោយសេចក្តីមិនប្រមាទចុះ ។
នេះជាបច្ឆិមវាចា របស់ព្រះតថាគត ។

ទីឃនិកាយ មហាវគ្គ
មហាបរិនិព្វានសូត្រ

សព្វទានំ ធម្មទានំ ជិនាតិ
ធម្មទានឈ្នះអស់ទានទាំងពួង ។